# កាលីហ្វ័រញ៉ា

# ការ បោះឆ្នោត សកល

## ថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា ឆ្នាំ 2012

★ សៀវភៅមគ្គុទ្ទេសក៍ព័ត៌មានជាផ្លូវការសំរាប់អ្នកបោះឆ្នោត ★

*វិញ្ញាបនប័ត្រនៃភាពត្រឹមត្រូវ*

ខ្ញុំ, Debra Bowen, រដ្ឋលេខាធិការនៃរដ្ឋកាលីហ្វ័រញ៉ា សូមប្រកាសជាផ្លូវការថាវិធានការដែលមានក្នុងទីនេះ
នឹងត្រូវដាក់ជូនទៅកាន់អ្នកមានសិទ្ធិបោះឆ្នោតពេលបោះឆ្នោតសកល ដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012
ហើយសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះបានត្រូវគេរៀបចំឡើងដោយអនុលោមត្រឹមត្រូវតាមច្បាប់។

សូមផ្តល់ជាសាក្សីដោយហត្ថារបស់ខ្ញុំ និងត្រាដ៏អស្ចារ្យរបស់រដ្ឋក្នុងក្រុងសាក្រាម៉ិនតូ កាលីហ្វ័រញ៉ា នៅថ្ងៃនេះ ទី13th នៃខែសីហា ឆ្នាំ 2012។

**មន្ទីរបោះឆ្នោត**
**បើកទ្វារពីម៉ោង**
**7:00 ព្រឹក ដល់ 8:00 យប់**
**នាថ្ងៃបោះឆ្នោត**

Debra Bowen
*រដ្ឋលេខាធិការ*

# *រដ្ឋលេខាធិការ*

សួស្តីអ្នកបោះឆ្នោតជាទីរាប់អាន៖

តាមរយៈការចុះឈ្មោះបោះឆ្នោត អ្នកបានបោះជំហានដំបូងក្នុងការ ដើរតួនាទីដ៏សកម្មមួយក្នុងការកំណត់អនាគតរបស់រដ្ឋកាលីហ្វ័រញ៉ា។ ឥឡូវនេះ ដើម្បីជួយឲ្យអ្នកធ្វើការសំរេចចិត្តរបស់អ្នក ការិយាល័យរបស់ខ្ញុំបានបង្កើតនូវកំរងណែនាំព័ត៌មានអ្នកបោះឆ្នោតជាផ្លូវការ – គឺគ្រាន់តែជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ដែលមានប្រយោជន៍ជាច្រើនសំរាប់ការរៀនបន្ថែមអំពីអ្វីដែលនឹងមានដាក់នៅលើសន្លឹកឆ្នោតរបស់អ្នកនិងអំពីរបៀបប្រព្រឹត្តទៅនៃការបោះឆ្នោតនេះ។ ព័ត៌មានអំពីបេក្ខជននិងវិធានការសំរាប់តែតំបន់របស់អ្នក គឺអាចរកឃើញនៅក្នុងកូនសៀវភៅបោះឆ្នោតគំរូ សំរាប់តំបន់របស់អ្នក។ ហើយសំរាប់ព័ត៌មានលំអិតបន្ថែមទៀតសំរាប់ដំណើរការបោះឆ្នោត – រួមមានរបៀបពិនិត្យ ស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក កន្លែងទៅបោះឆ្នោត ឬក៏ថាតើសន្លឹកឆ្នោតដែលបោះតាមសំបុត្រត្រូវបានទទួល ឬទេ – សូមចូលមើលក្នុងគេហទំព័រ *www.sos.ca.gov/elections* ឬទូរស័ព្ទមកលេខ (888) 345-4917។

ការបោះឆ្នោតគឺងាយស្រួល ហើយរាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះ មានជំរើសបោះឆ្នោតតាមសំបុត្រឬនៅ តាមកន្លែងបោះឆ្នោតនៅក្នុងតំបន់។ ថ្ងៃចុងក្រោយដើម្បីស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រពីការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកគឺថ្ងៃទី 30 ខែតុលា។ នៅថ្ងៃបោះឆ្នោត មន្ទីរបោះឆ្នោតទាំងឡាយ បើកទ្វារចាប់ពីម៉ោង 7:00 ព្រឹក ដល់ ម៉ោង 8:00 យប់។

មានជំរើសជាច្រើនដើម្បីចូលរួមនៅក្នុងដំណើរការបោះឆ្នោត។

- ធ្វើជាអ្នកធ្វើការនៅមន្ទីរបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយជួយឲ្យការបោះឆ្នោតមានភាពងាយស្រួលសំរាប់អ្នកបោះឆ្នោតដែលមានសិទ្ធិទាំងអស់ និងការពារសន្លឹកឆ្នោតរហូតដល់បានរាប់ដោយមន្ត្រីបោះឆ្នោត។
- ផ្សព្វផ្សាយនូវពាក្យអំពីកាលកំណត់ការចុះឈ្មោះអ្នកបោះឆ្នោតនិងសិទ្ធិបោះឆ្នោតតាមរយៈអ៊ីម៉េល ទូរស័ព្ទ កូនសៀវភៅព័ត៌មាន និងប័ណ្ណប្រកាស។
- ជួយអប់រំអ្នកបោះឆ្នោតផ្សេងទៀតអំពីបេក្ខជនឈរឈ្មោះនិងបញ្ហានានា ដោយរៀបចំក្រុមពិភាក្សាឬចូលរួមក្នុងការពិភាក្សាវែកញែកជាមួយមិត្តភក្តិ គ្រួសារ និងមេដឹកនាំសហគមន៍។

សៀវភៅមគ្គុទ្ទេសក៍ណែនាំនេះមានចំណងជើងនិងសេចក្តីសង្ខេបនៃវិធានការឆ្នោតរបស់រដ្ឋដែល រៀបចំដោយអគ្គមេធាវី Kamala D. Harris ការវិភាគដោយមិនលំអៀងនៃវិធានការ ឆ្នោតនិងសក្តានុពលនៃថ្លៃ ចំណាយដែលអាច កើតមានចំពោះអ្នកបង់ពន្ធដែលរៀបចំដោយអ្នកវិភាគនិតិបញ្ញត្តិ Mac Taylor ទឡ្ហីករណ៍គាំទ្រ និងប្រឆាំងវិធានការឆ្នោតដែលរៀបចំដោយអ្នកគាំទ្រនិងអ្នកប្រឆាំង អត្ថបទនៃ សំណើច្បាប់ដែលរៀបចំនិងពិនិត្យមើលដោយ មេធាវីនិតិបញ្ញត្តិ Diane F. Boyer-Vine និងព័ត៌មានមានប្រយោជន៍ផ្សេងទៀត។ ការបោះពុម្ពនូវសៀវភៅណែនាំ នេះត្រូវបានធ្វើឡើងនៅក្រោមការត្រួតពិនិត្យរបស់អ្នកបោះពុម្ពរបស់រដ្ឋស្តីទី Kevin P. Hannah។

វាជាសិទ្ធិដ៏អស្ចារ្យមួយក្នុងលទ្ធិប្រជាធិបតេយ្យក្នុងការមានជំរើសមួយនិងសិទ្ធិបញ្ចេញមតិរបស់អ្នក។ ដូចដែលអ្នក ដឹងហើយការប្រកួតប្រជែងខ្លះពិតជាប្រផិតប្រផើយមែនទែនគឺគ្រាន់តែឃ្លាតគ្នាតែពីរបីសំឡេងប៉ុណ្ណោះ។ ខ្ញុំសូម លើកទឹកចិត្តអ្នកឲ្យចំណាយពេលអានអំពីបេក្ខជនមួយរូបៗនិងវិធានការឆ្នោតដោយយកចិត្តទុកដាក់ – និង ដើម្បី ដឹងពីសិទ្ធិបោះឆ្នោតរបស់អ្នក។

សូមអរគុណសំរាប់ការប្រកាន់ខ្ជាប់នូវករណីយកិច្ចជាពលរដ្ឋយ៉ាងយកចិត្តទុកដាក់របស់អ្នកនិងការធ្វើឲ្យសំឡេងរបស់អ្នកបានឮ!

# តារាងមាតិកា


ទំព័រ

**មគ្គុទ្ទេសក៍យោង-ឆាប់រហ័ស** 5

**សំណើប្រជាមតិ**

30 ពន្ធបណ្តោះអាសន្នសំរាប់ផ្តល់ថវិកា ការអប់រំ។ ការផ្តល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ។ ....12

31 គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។ ....20

32 វិភាគទានខាងនយោបាយ តាមរយៈការកាត់ពីប្រាក់ខែ។ វិភាគទានទៅឱ្យបេក្ខជន។ លក្ខន្តិកៈផ្តួចផ្តើម។ ....28

33 ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ តំម្លៃនៃការធានារ៉ាប់រង យោងទៅលើប្រវត្តិរបស់អ្នកបើកបរ។ លក្ខន្តិកៈផ្តួចផ្តើម។....32

34 ទោសប្រហារជីវិត។ លក្ខន្តិកៈផ្តួចផ្តើម។....36

35 ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។....42

36 ច្បាប់ប្រព្រឹត្តិល្មើសបីដង។ ទុរជនបទឧក្រឹដ្ឋច្រំដែលៗ។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។ ....48

37 អាហារដែលបានបំភ្លៃពូជ។ ការដាក់ស្លាក។ លក្ខន្តិកៈផ្តួចផ្តើម។ ....54

38 ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំបូង។ លក្ខន្តិកៈផ្តួចផ្តើម។. ....58

39 លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។....68

40 ការដាក់កំរិត។ មណ្ឌលរដ្ឋព្រឹទ្ធសភា។ ប្រជាមតិ។ ....74

**សេចក្តីថ្លែងនៃបេក្ខជនព្រឹទ្ធសភាសហរដ្ឋអាមេរិក** 79

**អត្ថបទនៃច្បាប់ដែលបានស្នើ** 80

**កម្រងសិទ្ធិឯកកត្តជនអ្នកបោះឆ្នោត** 143

ទំព័រពត៌មាន

របៀបបោះឆ្នោត .... 4

ធនធានតាមបណ្តាញអនឡាញ .... 10

អំពីឆ្នោតទទ្បហីករណ៍ .... 10

ការបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ា.... 11

បេក្ខជនប្រធានាធិបតីសហរដ្ឋអាមេរិក .... 78

បេក្ខជនអង្គនិតិបញ្ញត្តិ និងសហសភា.... 78

សៀវភៅមគ្គុទ្ទេសក៍អក្សរបោះពុម្ពធំៗនិងខ្សែអាត់សំឡេងសំរាប់អ្នកបោះឆ្នោត .... 142

ទទួលប្រាក់ ហើយធ្វើឱ្យមានភាពខុសគ្នា បំរើជាអ្នកធ្វើការនៅតាមមន្ទីរបោះឆ្នោតនៅថ្ងៃបោះឆ្នោត.... 142

ការចុះឈ្មោះរបស់អ្នកបោះឆ្នោត .... 142

ការតំរូវរបស់រដ្ឋនិងសហព័ន្ធឱ្យអ្នកបោះឆ្នោតមានអត្តសញ្ញាណប័ណ្ណ .... 142

# របៀបបោះឆ្នោត

អ្នកមានជំរើសពីរពេលអ្នកបោះឆ្នោត។ អ្នកអាចបោះឆ្នោតដោយផ្ទាល់នៅតាមមន្ទីរបោះឆ្នោតនៅក្នុងខោនធី របស់អ្នក ឬអ្នកអាចបោះឆ្នោតដោយផ្ញើតាមសំបុត្រ។

អ្នកមិនចាំបាច់ត្រូវតែបោះឆ្នោតរៀងរាល់ការប្រកួតប្រជែងនៅក្នុងសន្លឹកឆ្នោតរបស់អ្នកទេ។ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវគេរាប់សំរាប់រាល់ការប្រកួត ប្រជែងទាំងអស់ដែលអ្នកបោះឱ្យ។

## ការបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតនៅថ្ងៃបោះឆ្នោត

មន្ទីរបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ាបើកទ្វារពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត។ ខោនធីខ្លះផ្តល់ពេលវេលាឱ្យបោះឆ្នោតមុនបន្តិចនៅតាមមន្ទីរបោះឆ្នោតមួយចំនួនមុនថ្ងៃបោះឆ្នោត។ នៅពេលអ្នកទទួលកូនសៀវភៅព័ត៌មានអំពីសន្លឹកឆ្នោតគំរូ តាមសំបុត្រពីរ បីអាទិត្យមុនថ្ងៃបោះឆ្នោត សូមរកមើលមន្ទីរបោះឆ្នោតរបស់អ្នកនៅក្របខាងខ្នងនៃកូនសៀវភៅនោះ។ បើសិនជាអ្នកមិនទទួលកូនសៀវភៅសន្លឹកឆ្នោតគំរូ សូមទាក់ទងមក ការិយាល័យបោះឆ្នោតនៅតាមខោនធីរបស់អ្នក។ អ្នកអាចទទួលអាសយដ្ឋាននៃមន្ទីរបោះឆ្នោតតាមមណ្ឌលរបស់អ្នកដោយចូលមើលក្នុងគេហទំព័រ *www.sos.ca.gov/elections/find-polling-place.htm* or ទូរស័ព្ទមកបណ្តាញពិសេសឥតបង់ថ្លៃរបស់លេខាធិការរដ្ឋ (888) 345-4917។ នៅពេលអ្នកអញ្ជើញមកដល់មន្ទីរបោះឆ្នោត អ្នកធ្វើការនៅតាមមន្ទីរបោះឆ្នោតនឹងសួរឈ្មោះអ្នក ហើយគេពិនិត្យផ្ទៀងផ្ទាត់មើលឈ្មោះអ្នកនៅក្នុងបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតសំរាប់មន្ទីរបោះឆ្នោតនោះ។ បន្ទាប់ពីអ្នកចុះហត្ថលេខានៅជិតឈ្មោះរបស់អ្នកនៅក្នុងបញ្ជីនោះហើយ អ្នកធ្វើការ នៅមន្ទីរបោះឆ្នោត នឹងឱ្យសន្លឹកឆ្នោតមួយសន្លឹក, លេខសំងាត់ពិសេស, ឬកាតម៉េម៉័រីសំរាប់កុំព្យូទ័រ ទៅតាមសភាពជាក់ស្តែងនៃប្រព័ន្ធបោះឆ្នោតដែល គេប្រើនៅតាមខោនធីរបស់អ្នក។

រួចអ្នកចូលទៅក្នុងបន្ទប់ឯកជនមួយ ហើយចាប់ផ្តើមបោះឆ្នោត។ អ្នកធ្វើការនៅតាមមន្ទីរបោះឆ្នោតនិមួយៗ គេនៅទីនោះរង់ចាំជួយអ្នកក្នុងដំណើរការបោះឆ្នោត។ បើសិនជាអ្នកមិនសូវ យល់ច្បាស់ពីរបៀបបោះឆ្នោត ចូរសួរអ្នកធ្វើការនៅទីនោះឱ្យគេជួយណែនាំពីរបៀបប្រើម៉ាស៊ីនបោះឆ្នោត។ ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធតំរូវឱ្យអ្នកបោះឆ្នោតមួយរូបៗមានលទ្ធភាពបោះឆ្នោតរបស់គេដោយឯកជន និងដោយឯករាជ្យ។ នៅតាមមន្ទីរបោះឆ្នោតនិមួយៗតំរូវឱ្យមានយ៉ាងហោចណាស់ម៉ាស៊ីនបោះឆ្នោតមួយដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោត ដោយរួមទាំងអ្នកបោះឆ្នោតដែលពិការភ្នែក ឬខូចប្រព័ន្ធចក្ខុប្រសាទ អាចបោះឆ្នោតបានដោយគ្មានជំនួយ។ ម៉ាស៊ីនបោះឆ្នោតនោះក៏ត្រូវតែមានលទ្ធភាពអនុញ្ញាតឱ្យអ្នកអាចបញ្ជាក់មើលជំរើសបោះឆ្នោតរបស់អ្នកដោយឯកជន ហើយដោយឯករាជ្យ បើសិនជាវាខុស វាអនុញ្ញាតឱ្យអ្នកកែតំរូវជំរើសនោះបានវិញមុននឹងបោះឆ្នោតជាចុងបញ្ចប់។

## ការបោះឆ្នោតផ្ញើតាមប៉ុស្តិ៍សំបុត្រ

បើសិនជាអ្នក មិនមែនជាអ្នកបោះឆ្នោតផ្ញើតាមប៉ុស្តិ៍សំបុត្រជាអចិន្ត្រៃយ៍ (ដែលពីមុនគេតែងតែហៅថាអ្នកបោះឆ្នោតអវត្តមាន) អ្នកនៅតែមានជំរើសអាចបោះឆ្នោតផ្ញើតាមសំបុត្រ។ កូនសៀវភៅសន្លឹកឆ្នោតគំរូតាមខោនធីរបស់អ្នកមានពាក្យសុំសំរាប់បោះឆ្នោតផ្ញើតាមសំបុត្រ។ ថ្ងៃចុងក្រោយដែលអ្នកអាចស្នើសុំសន្លឹកឆ្នោតបោះផ្ញើតាមសំបុត្រពីការិយាល័យបោះឆ្នោតតាមខោនធីរបស់អ្នកគឺថ្ងៃទី 30 ខែតុលា។ បន្ទាប់ពីអ្នកគូសជំរើសរបស់អ្នកលើសន្លឹកឆ្នោតបោះផ្ញើតាមប៉ុស្តិ៍សំបុត្ររួចមក ចូរដាក់សន្លឹកឆ្នោតនោះនៅក្នុងស្រោមសំបុត្រផ្តល់ដោយការិយាល័យបោះឆ្នោតតាមខោនធីរបស់អ្នក រួចបិទវាឱ្យជិត។ ចុះហត្ថលេខាលើស្រោមសំបុត្រនៅខាងក្រៅដូចតាមការណែនាំ។ អ្នកអាចផ្ញើសន្លឹកឆ្នោតដែលបោះតាមការផ្ញើតាមប៉ុស្តិ៍នោះមកតាម ៖

- ផ្ញើសន្លឹកឆ្នោតនោះមកការិយាល័យបោះឆ្នោតតាមខោនធីរបស់អ្នក;
- ប្រគល់ដោយផ្ទាល់ខ្លួនទៅមន្ទីរបោះឆ្នោតណាមួយ ឬការិយាល័យបោះឆ្នោតនៅក្នុងខោនធីរបស់អ្នកនៅថ្ងៃបោះឆ្នោត; ឬ
- អនុញ្ញាតឱ្យជនស្របច្បាប់ភាគីទីបី (ប្តី/ប្រពន្ធ, កូន, ឪពុក/ម្តាយ, ជីដូនជីតា, ចៅ, បងប្រុស/ស្រី, ប្អូនប្រុស/ស្រី, ឬជនណាដែលរស់នៅក្នុងគេហដ្ឋានជាមួយអ្នក) ឱ្យយកសំបុត្រនោះទៅមន្ទីរបោះឆ្នោតណាមួយ ឬការិយាល័យបោះឆ្នោតនៅក្នុងខោនធីរបស់អ្នកនៅថ្ងៃបោះឆ្នោតជំនួសអ្នក។

**សន្លឹកឆ្នោតបោះតាមប៉ុស្តិ៍សំបុត្រត្រូវតែផ្ញើចេញហើយបានទទួលដោយការិយាល័យបោះឆ្នោតនៅក្នុងខោនធី មិនឱ្យហួសពីម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត ដូច្នេះសូមកុំភ្លេចផ្ញើសន្លឹកឆ្នោតរបស់អ្នកមកឱ្យបានពីរ បីថ្ងៃមុនថ្ងៃបោះឆ្នោត។**

ទោះបីជាអ្នកទទួលសន្លឹកឆ្នោតបោះផ្ញើតាមសំបុត្ររបស់អ្នករួចហើយ, អ្នកអាចដូរចិត្តគំនិតបាន ហើយមកបោះឆ្នោតនៅតាមមន្ទីរបោះឆ្នោតនៅថ្ងៃបោះឆ្នោតនោះ។ តែទោះជាយ៉ាងណាក៏ដោយអ្នកត្រូវតែនាំយកមកជាមួយនូវសន្លឹកឆ្នោតត្រូវបោះផ្ញើតាមប៉ុស្តិ៍សំបុត្រមកកាន់មន្ទីរបោះឆ្នោតនោះផង ហើយឱ្យទៅអ្នកធ្វើការនៅទីនោះដើម្បីប្តូរយកសន្លឹកឆ្នោតបោះនៅតាមកន្លែងនោះ។ បើសិនជាអ្នកមិនមានសន្លឹកឆ្នោតបោះផ្ញើតាមប៉ុស្តិ៍មកជាមួយទេ គេនឹងអនុញ្ញាតិឱ្យអ្នកបោះឆ្នោតបណ្តោះអាសន្ន។

## សន្លឹកឆ្នោតបណ្តោះអាសន្ន

បើសិនជាឈ្មោះរបស់អ្នក មិនមាននៅក្នុងបញ្ជីបោះឆ្នោតនៅតាមមន្ទីរបោះឆ្នោតកន្លែងអ្នកទេ អ្នកមានសិទ្ធិបោះឆ្នោតតាមសន្លឹកឆ្នោតបណ្តោះអាសន្ននៅតាមមន្ទីរបោះឆ្នោតណាមួយក៏បានដែរនៅក្នុងខោនធីដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ សន្លឹកឆ្នោតបណ្តោះអាសន្នគឺឆ្នោតដែលបោះដោយជនដែល ៖

- ជឿថាគេបានចុះឈ្មោះបោះឆ្នោត ទោះបីជាឈ្មោះរបស់អ្នកមិនមាននៅក្នុងបញ្ជីចុះឈ្មោះបោះឆ្នោតជាផ្លូវការក៏ដោយ;
- ជឿថាបញ្ជីចុះឈ្មោះបោះឆ្នោតជាផ្លូវការនោះរាយឈ្មោះគណបក្សនយោបាយអាទិភាពរបស់គេមិនត្រឹមត្រូវ; ឬ
- បោះឆ្នោតផ្ញើតាមប៉ុស្តិ៍សំបុត្រ តែមិនអាចរកឃើញសន្លឹកឆ្នោតដែលត្រូវបោះដោយផ្ញើតាមប៉ុស្តិ៍សំបុត្រឃើញ ហើយក៏សំរេចចិត្តបោះនៅតាមមន្ទីរបោះឆ្នោតនៅនឹងកន្លែងនោះវិញ។

សន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នកនិងត្រូវគេរាប់នៅពេលដែលមន្ត្រីធ្វើការតាមមន្ទីរបោះឆ្នោតបានអះអាងថាអ្នកជាអ្នកបានចុះឈ្មោះបោះឆ្នោតមែន ហើយមិនមានបោះឆ្នោតនៅកន្លែងណាផ្សេងទៀតឡើយពេលបោះឆ្នោតដូចគ្នានេះ។

# មគ្គុទ្ទេសក៍យោង-ឆាប់រហ័ស

## សប្រជាមតិ 30 ពន្ធបណ្តោះអាសន្ន សំរាប់ផ្តល់ថវិកា ការអប់រំ។ ការផ្តល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ការបង្កើនពន្ធលើប្រាក់រកបានច្រើនជាង$250,000ចំនួនប្រាំពីរឆ្នាំនិងពន្ធថ្លៃលក់ដូរដោយ ¼សេន ចំនួនបួនឆ្នាំ ដើម្បីផ្តល់ថវិកាឲ្យសាលារៀន។ ការផ្តល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋានដែលអះអាង។ ឥទ្ធិពលហិរញ្ញវត្ថុៈ ពន្ធប្រាក់ចំណូលរបស់រដ្ឋដែលកើនរហូតដល់ឆ្នាំ 2018-19 ជាមធ្យមប្រហែល $6 កោដិ ជាប្រចាំឆ្នាំ ចំនួនពីរបីឆ្នាំខាងមុខ។ ប្រាក់ចំណូលដែលមានសំរាប់គំរោងថវិកានៃការផ្តល់ថវិការបស់រដ្ឋ។ ក្នុងឆ្នាំ 2012-13 ដែលបានបំរុងកាត់បន្ថយការចំណាយ ជាចំបងចំពោះកម្មវិធីអប់រំ នឹងមិនកើតឡើងទេ។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោតបាទ/ចាសនៅក្នុងវិធានការនេះគឺមានន័យថា ៖ រដ្ឋនឹងត្រូវដំឡើងពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនលើអ្នកបង់ពន្ធណាដែលមានប្រាក់ចំណូលខ្ពស់ សំរាប់ប្រាំពីរឆ្នាំ និងពន្ធទំនិញលក់ ចេញសំរាប់បួនឆ្នាំ។ ប្រាក់ចំណូលពន្ធថ្មីនេះនឹងអាចមានសំរាប់ផ្តល់ដល់កម្មវិធីនានានៅក្នុងថវិការដ្ឋ។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធានការនេះគឺមានន័យថា ៖ រដ្ឋនឹងមិនដំឡើងប្រាក់ពន្ធចំណូលផ្ទាល់ខ្លួន ឬ ពន្ធទំនិញលក់ចេញទេ។ កាត់បន្ថយការចំណាយរបស់រដ្ឋ ជាសំខាន់បំផុតសំរាប់កម្មវិធីអប់រំ គឺនឹងចូលជាធរមានក្នុងឆ្នាំ 2012–13។

### ទឡ្ហីករណ៍

**គាំទ្រ** ក្រោយពីការកាត់បន្ថយថវិកាសំរាប់សាលនិងកម្មវិធីសុវត្ថិភាពសាធារណៈ ឥឡូវដល់ពេលត្រូវក្រោកឈរហើយ។ សំណើប្រជាមតិ 30 សុំឱ្យអ្នកមានបំផុតបង់ពន្ធច្រើនថែមទៀតដើម្បីការពារការកាត់បន្ថយជ្រៅថែមទៀតទៅលើថវិកាសាលា, ផ្តល់ថវិការាប់កោដិដុល្លារសំរាប់ថវិកាអប់រំថ្មីធានាសុវត្ថិភាពសាធារណៈមូលដ្ឋាន និងជួយឱ្យមានតុល្យភាពថវិការដ្ឋ។ ស្វែងយល់ថែមទៀតសូមចូល គេហទំព័រ *YesOnProp30.com*។

**ប្រឆាំង** ទេ សំរាប់សំណើប្រជាមតិ 30—$50 ប្រាំពាន់កោដិក្នុងពន្ធទំនិញលក់ចេញ និងពន្ធប្រាក់ចំណូលខ្ពស់ តែមិនមានធានាសំរាប់ប្រាក់បន្ថែមសំរាប់សាលារៀន។ សំណើប្រជាមតិ 30 មិនកែទម្រង់សាលារៀន,ប្រាក់សោធនិវត្តន៍ ឬកាត់បន្ថយភាពខ្ជីខ្ជា និងការិយាធិបតេយ្យ។ យើងមិនដែលដឹងថាតើប្រាក់ទាំងនោះទៅទីណាទេ។ អ្នកអប់រំ, ជំនួញខ្នាតតូច, និងក្រុមអ្នកបង់ពន្ធ និយាយ ទេ លើសំណើប្រជាមតិលេខ 30។

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**
Ace Smith
Yes on Proposition 30
2633 Telegraph Avenue #317
Oakland, CA 94612
(510) 628-0202
YesOnProp30@TakeAStandCA.com
YesOnProp30.com

**ប្រឆាំង**
No on 30—អ្នកកាលីហ្វ័រញ៉ាសំរាប់ ការកែទម្រង់ និងការងារ, មិនមែនពន្ធទេ។
925 University Avenue
Sacramento, CA 95825
(866) 955-5508
info@StopProp30.com
www.StopProp30.com

## សប្រជាមតិ 31 គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ស្ថាបនាគំរោង ថវិការដ្ឋ រយៈពេលពីរ-ឆ្នាំ។ កំណត់ច្បាប់សំរាប់ការទូរទាត់នូវការចំណាយថ្មី ហើយអភិបាលរដ្ឋកាត់បន្ថយគំរោងថវិកា ក្នុងភាព អាសន្នហិរញ្ញវត្ថុ។ រដ្ឋាភិបាលមូលដ្ឋានអាចប្តូរការអនុវត្តន៍ច្បាប់នៃការគ្រប់គ្រងកម្មវិធីរដ្ឋបានផ្តល់ថវិកា។ឥទ្ធិពលហិរញ្ញវត្ថុៈ ពន្ធប្រាក់ចំណូលរដ្ឋនៃការលក់ដូរចុះថយប្រហែល$200លានជាប្រចាំឆ្នាំដោយមានការកើនឡើងស្របគ្នានៃការផ្តល់ថវិកាឲ្យរដ្ឋាភិបាលមូលដ្ឋានខ្លះ។ផ្សេងៗទៀតអាចនឹងមានការផ្លាស់ប្តូរខ្លាំងច្រើនទៀត ក្នុងគំរោងថវិការបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន អាស្រ័យទៅលើការសំរេចនៅអនាគត ដោយមន្ត្រីសាធារណៈ។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោតបាទ/ចាសនៅក្នុងវិធានការនេះគឺមានន័យថា៖ការទទួលខុសត្រូវផ្អែកសារពើពន្ធមួយចំនួនរបស់អង្គនិតិបញ្ញត្តិនិងអភិបាលរដ្ឋរួមទាំងការរៀបចំថវិការបស់រដ្ឋនិងមូលដ្ឋាននិងនិតិវិធីមើលខុសត្រូវនឹងមានការប្រែប្រួល។ រដ្ឋបាលមូលដ្ឋានដែលបង្កើតផែនការសម្របសម្រួលសេវានានានឹងទទួលថវិកាពីរដ្ឋ ហើយអាចបង្កើតនិតិវិធីផ្ទាល់ខ្លួនគេសំរាប់មើលគ្រប់គ្រងកម្មវិធីនានារបស់រដ្ឋ។

**ទេ** សន្លឹកឆ្នោត ទេនៅក្នុងវិធានការ នេះគឺមានន័យថា ៖ ការទទួលខុសត្រូវផ្អែកសារពើពន្ធរបស់អង្គ និតិបញ្ញត្តិ និងអភិបាលរដ្ឋ រួមទាំងការ រៀបចំថវិការបស់រដ្ឋ និងមូលដ្ឋាននិងនិតិ វិធីមើលខុសត្រូវនឹងមិនប្រែប្រួលទេ។ រដ្ឋាភិបាលមូលដ្ឋាននឹងមិនត្រូវបានផ្តល់ (1) ថវិកាសំរាប់អនុវត្តផែនការថ្មីដែលជួយសម្របសម្រួលសេវានានា ឬ (2) អាជ្ញាធរបង្កើតនិតិវិធីផ្ទាល់ខ្លួនគេសំរាប់មើលគ្រប់គ្រងកម្មវិធីនានារបស់រដ្ឋ។

### ទឡ្ហីករណ៍

**គាំទ្រ** បាទ/ចាស លើសំណើប្រជាមតិ 31 និងបញ្ឈប់អ្នកនយោបាយ ពីការទុករដ្ឋកាលីហ្វ័រញ៉ាឱ្យនៅក្នុងភាពងងិតអំពីរបៀបដែលរដ្ឋាភិបាលប្រតិបត្តិការ។ វានឹងរារាំងរដ្ឋមិនឱ្យអនុម័តថវិកានៅពីក្រោយទ្វារបិទជិត, បញ្ឈប់អ្នកនយោបាយមិនឱ្យបង្កើតកម្មវិធីនានាជាមួយប្រាក់ដែលរដ្ឋមិនមានហើយដែលតំរូវឱ្យរដ្ឋាភិបាលធ្វើរបាយការណ៍លទ្ធផលមុននឹងចំណាយប្រាក់ថែមតទៅទៀត។

**ប្រឆាំង** សំណើប្រជាមតិ 31 គឺជាការផ្តើមប្រជាសិទ្ធិមួយមានវិបត្តិធ្ងន់ធ្ងរដែលចាក់សោរខមាត្រាថ្លៃៗនិងមានទំនាស់នានានៅក្នុងរដ្ឋធម្មនុញ្ញ បណ្តាលឱ្យមានបណ្តឹងវិវាទ, ការភាន់ច្រឡំ, ហើយបណ្តាលឱ្យសំណើប្រជាមតិ 31 គំរាមដល់សុខភាពសាធារណៈ,បរិស្ថាន,រារាំងមិនឱ្យមានការដំឡើងថវិកានាពេលអនាគត់សំរាប់សាលារៀន ហើយទប់ស្កាត់ការកាត់ពន្ធ។ ចូលរួមជាមួយគ្រូបង្រៀន, តម្រួត, អ្នកអភិរក្សនិយម, អ្នកកែទម្រង់ពន្ធ ៖ បោះឆ្នោត ទេ លើសំណើប្រជាមតិ 31។

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**
អ្នកបង់ពន្ធសំរាប់គណនេយ្យភាពរដ្ឋាភិបាល
(916) 572-7111
info@accountableca.org
www.accountableca.org

**ប្រឆាំង**
អ្នកកាលីហ្វ័រញ៉ាសំរាប់តំឡាភាព និងគណនេយ្យភាពរដ្ឋាភិបាល។

## សប្រជាមតិ 32

**វិភាគទានខាងនយោបាយ តាមរយៈការកាត់ពីប្រាក់ខែ។ វិភាគទានទៅឲ្យបេក្ខជន។ លក្ខន្តិកៈផ្តួចផ្តើម។**

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ដាក់កំរិតដល់សហជីព ពីការប្រើថវិកាកាត់ពីប្រាក់ខែ សំរាប់គោលបំណងនយោបាយ។ អនុវត្តទៅលើកំរិតការប្រើដូចគ្នាចំពោះការកាត់ពីប្រាក់ខែបើសិនមានកាត់ដោយសារជីវកម្ម ឬអ្នកម៉ៅការឲ្យរដ្ឋាភិបាល។ដាក់កំរិតដល់សហជីពនិងសារជីវកម្មធ្វើវិភាគទានទៅឲ្យបេក្ខជន និង សហគមន៍របស់គេ។ កំរិតដល់អ្នកម៉ៅការឲ្យរដ្ឋាភិបាល ធ្វើវិភាគទានដើម្បីជ្រើសរើសនាយកជាប់ឆ្នោត ឬគណកម្មាធិការរបស់គេ។ ឥទ្ធិពលហិរញ្ញវត្ថុ : ការចំណាយបានកើនឡើងចំពោះរដ្ឋនិងរដ្ឋាភិបាលមូលដ្ឋាន—អាចនឹងហួសពី$1លានជាប្រចាំឆ្នាំ—ដើម្បីប្រតិបត្តិ និងប្រព្រឹត្តិតាមសេចក្តីដំរូវរបស់វិធានការ។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោតបាទ/ចាសនៅក្នុងវិធានការនេះគឺមានន័យថា ៖ សហជីព និងសាជីវកម្មមិន អាចប្រើប្រាក់កាត់ពីប្រាក់ខែសមាជិកសំរាប់គោលបំណងនយោបាយ។ សហជីព, សាជីវកម្ម និងអ្នកម៉ៅការរដ្ឋាភិបាលអាចនឹងជាកម្មវត្ថុសំរាប់ការហាមឃាត់ផ្នែកថវិកាឃោសនាបន្ថែមទៀត។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធានការនេះគឺមានន័យថា ៖ នឹងគ្មានអ្វីប្រែប្រួលទៅលើច្បាប់ដែលមានមកអំពីការត្រួតត្រាលើលទ្ធភាពរបស់សហជីព និងសាជីវកម្មក្នុងការប្រើប្រាក់កាត់ពីប្រាក់ខែរបស់សមាជិកសំរាប់គោលបំណងនយោបាយ។ សហជីព, សាជីវកម្ម និងអ្នកម៉ៅការរដ្ឋាភិបាលអាចនឹងបន្តជាកម្មវត្ថុអនុវត្តតាមច្បាប់ថវិកាសំរាប់ការឃោសនាដែលមានមកហើយ។

### ទឡ្ហីករណ៍

**គាំទ្រ** សំណើប្រជាមតិ32 ផ្តាច់ប្រាក់ចំណងរវាងក្រុមមានផលប្រយោជន៏ពិសេសនិងអ្នកនយោបាយ ឱ្យដល់កំរិតដែលច្បាប់រដ្ឋធម្មនុញ្ញអនុញ្ញាត។ ហាមឃាត់មិនឱ្យមានការធ្វើវិភាគទានពីសាជីវកម្មនិងសហជីពទៅឱ្យអ្នកនយោបាយ។ ហាមឃាត់មិនឱ្យមានការធ្វើវិភាគទានពីអ្នកម៉ៅការរដ្ឋទៅឱ្យអ្នកនយោបាយបញ្ឈប់ការកាត់ប្រាក់ពីបញ្ជីប្រាក់ខែសំរាប់នយោបាយ។ ធ្វើវិភាគទានទាំងអស់ ជាការស្ម័គ្រចិត្ត។ គ្មានការបញ្ចៀសពន្ធដារ គ្មានការលើកលែង។ បោះឆ្នោត បាទ/ចាស ដើម្បីសំអាត Sacramento។

**ប្រឆាំង** សំណើប្រជាមតិ 32 មិនមែនកែទម្រង់ទេ— គឺវាលើកលែងពាណិជ្ជកម្មកំពូល Super PACs និងពាណិជ្ជកម្មធំៗរាប់ពាន់ទៀតពីខមាត្រារបស់វា។ទន្ទឹមគ្នានេះវាក៏អនុវត្តការហាមឃាត់មកលើពលរដ្ឋធ្វើការ និងសហជីពរបស់គេ។ វាជារឿងអយុត្តិធម៌ណាស់, មិនមានតុល្យភាព ហើយវាមិនយកប្រាក់ចេញពីនយោបាយទេ។ សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតជំរុញឱ្យបោះឆ្នោត ទេ!

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**

បាទ/ចាស លើប្រជាមតិ 32—បញ្ឈប់ប្រាក់ពីក្រុមមានផល ប្រយោជន៏ពិសេសឥឡូវនេះ។ គាំទ្រដោយម្ចាស់ពាណិជ្ជកម្មខ្នាតតូច, កសិករ, អ្នកអប់រំ និងអ្នកបង់ពន្ធដារ។
(800) 793-6522
info@yesprop32.com
www.yesprop32.com

**ប្រឆាំង**

Chris Dombrowski
បោះឆ្នោត ទេ លើប្រជាមតិ 32, ឧបត្ថម្ភគាំទ្រដោយក្រុមអ្នកអប់រំ, ក្រុមពន្លត់អគ្គិភ័យ, និយោជិកសាលា, អ្នកផ្តល់ការបំរើថែទាំសុខភាព,មន្ត្រីប៉ូលិសនិងអង្គការពលកម្មប្រឆាំងចំពោះការលើកលែងពិសេសពីថវិកាសំរាប់ឃោសនាគ្របគ្រងសំរាប់រួមសាជីវកម្មក្រុមអ្នកមានបផលប្រយោជន៏ពិសេស។
1510 J Street, Suite 210
Sacramento, CA 95814
(916) 443-7817
info@VoteNoOn32.com
www.VoteNoOn32.com

## សប្រជាមតិ 33

**ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ ដំឡៃនៃការធានារ៉ាប់រង យោងទៅលើប្រវត្តិរបស់អ្នកបើកបរ។ លក្ខន្តិកៈផ្តួចផ្តើម។**

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ការផ្លាស់ប្តូរច្បាប់បច្ចុប្បន្នអនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងកំណត់ដំឡៃយោងទៅលើថាតើអ្នកបើកបរធ្លាប់មានការធានារ៉ាប់រងពីមុនជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រង។អនុញ្ញាតភាគនៃការចុះថ្លៃទៅឲ្យអ្នកបើកបរដែលមានការធានារ៉ាប់រងខ្លះពីមុន។អនុញ្ញាតឲ្យដំឡើងដំឡៃសំរាប់អ្នកបើកបរដែលគ្មានប្រវត្តិនៃការរ៉ាប់រងជាបន្តមក។ ឥទ្ធិពលហិរញ្ញវត្ថុ:ប្រហែលជាគ្មានឥទ្ធិពលហិរញ្ញវត្ថុខ្លាំងក្លាទៅលើពន្ធប្រាក់ចំណូលនៃថ្លៃបង់ធានារ៉ាប់រងរបស់រដ្ឋទេ។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោតបាទ/ចាសនៅក្នុងវិធានការនេះគឺមានន័យថា ៖ ក្រុមហ៊ុនធានារ៉ាប់រងអាចផ្តល់ជូនអតិថិជនថ្មីនូវការបញ្ចុះតំលៃសំរាប់បុព្វលាភធានារ៉ាប់រងសំរាប់រថយន្តដោយផ្អែកលើចំនួនឆ្នាំក្នុងរយៈពេលប្រាំឆ្នាំមុនដែលអតិថិជនមានការធានារ៉ាប់រង។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធានការ នេះគឺមានន័យថា ៖ ធានាការីអាចបន្តផ្តល់ការបញ្ចុះតំលៃដល់អតិថិជនធានារ៉ាប់រងរថយន្តរយៈពេលយូររបស់គេបានតទៀត ក៏ប៉ុន្តែនឹងបន្តហាមមិនឱ្យផ្តល់ការបញ្ចុះតំលៃទៅឱ្យអតិថិជនថ្មីដែលប្តូរពីអ្នកធានាការីផ្សេងទៀត។

### ទឡ្ហីករណ៍

**គាំទ្រ** ពលរដ្ឋកាលីហ្វ័រញ៉ាដែលមានការធានារ៉ាប់រងរថយន្តទទួលបានការបញ្ចុះតំលៃសំរាប់បុព្វលាភធានារ៉ាប់រងដោយការធ្វើតាមច្បាប់។ ក៏ប៉ុន្តែ បើអ្នកប្តូរក្រុមហ៊ុនធានារ៉ាប់រង អ្នកនឹងបាត់បង់ការបញ្ចុះតំលៃនោះ។ សំណើប្រជាមតិ 33 អនុញ្ញាតឱ្យអ្នកមានសេរីភាពផ្លាស់ប្តូរក្រុមហ៊ុនធានារ៉ាប់រង ហើយរក្សាការបញ្ចុះតំលៃរបស់អ្នក។ សំណើប្រជាមតិ 33 ធ្វើឱ្យក្រុមហ៊ុនធានារ៉ាប់រងមានការប្រកួតប្រជែងគ្នា, ជួយបញ្ចុះតំលៃកំរិតទាប, និងធារ៉ាប់រងអ្នកបើកបរបានកាន់តែច្រើនទៀត។

**ប្រឆាំង** សំណើប្រជាមតិ 33 គឺជាកលល្បិចរបស់ក្រុមហ៊ុនធានារ៉ាប់រងដ៏គួរឱ្យខកចិត្តមួយ។ក្រុមហ៊ុនធានារ៉ាប់រងបានចំណាយប្រាក់រាប់លានដុល្លារដើម្បីឱ្យគេអនុម័តច្បាប់ស្រដៀងគ្នានេះនៅឆ្នាំ 2010—អ្នកបោះឆ្នោតបានធ្វើឱ្យវាបរាជ័យ។សំណើប្រជាមតិ33អនុញ្ញាតឱ្យធានាការី*តំលើងបុព្វលាភធានារ៉ាប់រងដល់អ្នកបើកបរដែលមានការទទួលខុសត្រូវរហូតដល់$1,000*,អយុត្តិធម៌ដាក់ទណ្ឌកម្មដល់ពលរដ្ឋដែលឈប់បើកបរដោយមូលហេតុស្របច្បាប់។ អ្នកប្រើប្រាស់ជំទាស់ និងសំណើរប្រជាមតិ 33។

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**

បាទ/ចាស លើប្រជាមតិ 33—2012 ច្បាប់ការបញ្ចុះតំលៃក្រុមហ៊ុនធានារ៉ាប់រង
1415 L Street, Suite 410
Sacramento, CA 95814
(916) 448-3444
info@yesprop33.com
www.yesprop33.com

**ប្រឆាំង**

យុទ្ធនាការឃោសនាឃ្លាំមើលអ្នកប្រើប្រាស់
(310) 392-0522
VoteNo@StopProp33.org
www.StopProp33.org

## សប្រជាមតិ 34 ទោសប្រហារជីវិត។ លក្ខន្តិក:ផ្តួចផ្តើម។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

លុបបំបាត់ទោសប្រហារជីវិតនិងជំនួសវាជាមួយនឹងការជាប់គុកមួយជីវិតដោយមិនអាចមានលក្ខខ័ណ្ឌការដោះលែងឡើយ។ អនុវត្តបកក្រោយ ទៅលើទោសប្រហារជីវិតជាធរមាន។ ផ្តល់ប្រាក់$100លាន ទៅឲ្យភ្នាក់ងារ នគរបាល សំរាប់ការសើបអង្កេតឃាតកម្ម និងករណីការរំលោភផ្លូវភេទ។ ឥទ្ធិពលហិរញ្ញវត្ថុ : ការសន្សំប្រាក់ ជាហូរហែរបស់រដ្ឋ និងខោនធី ប្រហែល$130លានជាប្រចាំឆ្នាំ ក្នុងពេលពីរបីឆ្នាំ ដែលអាចនឹងខុសគ្នាដោយដប់លានដុល្លារ។ រដ្ឋចំណាយមួយដង $100 លាន សំរាប់ប្រាក់សម្បទានឲ្យនគរបាលមូលដ្ឋាន។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោត បាទ/ចាស នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ គ្មានជនល្មើសអាចត្រូវបានកាត់ទោសប្រហារជីវិតក្រោមច្បាប់រដ្ឋ។ ជនល្មើសដែលបច្ចុប្បន្ននេះក្រោមការកាត់ទោសប្រហារជីវិតអាចនឹងត្រូវកាត់ទោសសារជាថ្មីទៅជាការជាប់ទោសមួយជីវិតដោយគ្មានលទ្ធភាពដោះលែងដោយមានលក្ខខណ្ឌ។ រដ្ឋនឹងផ្តល់ប្រាក់សរុប $100 ដុល្លារជាមូលនិធិទៅឱ្យទីភ្នាក់ងារអាជ្ញាធរមូលដ្ឋានអំឡុងពេលបួនឆ្នាំក្រោយ។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ជនល្មើសមួយចំនួនត្រូវបានផ្តន្ទាទោស សំរាប់ឃាតកម្មអាចបន្តកាត់ទោសប្រហារជីវិត។ សភាពនៃជនល្មើសបច្ចុប្បន្នក្រោមការកាត់ទោសប្រហារជីវិតនឹងមិនប្រែប្រួលឡើយ។ រដ្ឋនឹងមិនតំរូវឱ្យផ្តល់ទីភ្នាក់ងារអាជ្ញាធរមូលដ្ឋាននូវមូលនិធិ បន្ថែមទៀតឡើយ។

### ទឡ្ហីករណ៍

**គាំទ្រ** 34 ធានាថាយើងមិនដែលប្រហារជីវិតជនគ្មានទោសដោយជំនួសវិញជាមួយការបំភ្លេចសន្យារបស់កាលីហ្វ័រញ៉ាគឺការដាក់ពន្ធនាគារមួយជីវិតដោយគ្មានលទ្ធភាពដោះលែងដោយមានលក្ខខណ្ឌ។ សំណើប្រជាមតិនេះធ្វើឱ្យឃាតករធ្វើការ ហើយបង់សំណងខូចខាតទៅឱ្យជនរងគ្រោះដែលបញ្ជាដោយតុលាការ។ 34 សំចៃប្រាក់ពន្ធដារដែលហិនហោច ហើយចាត់ចែងប្រាក់ $100 លានដុល្លារទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយ សំណុំរឿងរំលោភ និងឃាតកម្ម។

**ប្រឆាំង** កាលីហ្វ័រញ៉ាគឺក្ស័យធន។ សំណើប្រជាមតិ 34 អស់ថ្លៃដល់អ្នកបង់ពន្ធចំនួន $100 លានរយៈពេលបួនឆ្នាំ ហើយច្រើនលានដុល្លារថែមទៀតរយៈពេលយូរ។ អ្នកបង់ពន្ធនឹងបង់យ៉ាង ហោចណាស់ $50,000 ដុល្លារប្រចាំឆ្នាំ ផ្តល់ការថែទាំសុខភាពប្រចាំជីវិត/លំនៅដ្ឋានដល់ឃាតករដែលធ្វើទារុណកម្ម,រំលោភ ហើយសំឡាប់កុមារ, ប៉ូលិស, មាតា និងបិតា។ DA's, នាយកតម្រួតតំបន់ និង ប៉ូលិស និយាយថា បោះឆ្នោត ទេ។.

### សំរាប់ព័ត៌មានបន្ថែម


**គាំទ្រ**
Steve Smith
បាទ/ចាស លើប្រជាមតិ 34—SAFE California Campaign
237 Kearny Street #334
San Francisco, CA 94108
(415) 525-9000
info@safecalifornia.org
www.YesOn34.org

**ប្រឆាំង**
ពលរដ្ឋកាលីហ្វ័រញ៉ាដើម្បីយុត្តិធម៌ និងសុវត្ថិភាពសាធារណៈ
455 Capitol Mall, Suite 600
Sacramento, CA 95814
www.waitingforjustice.net


## សប្រជាមតិ 35 ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិក:ផ្តួចផ្តើម។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

បង្កើនការកាត់ទោសឲ្យជាប់ពន្ធនាគារ និងផាកពិន័យ សំរាប់ការជាប់ ទោសបទការជួញមនុស្ស។ អ្នកជាប់ទោសនៃបទការជួញមនុស្ស ដំរូវឲ្យចុះបញ្ជីជាទុរជនផ្លូវភេទ។ ទុរជនផ្លូវភេទដែលបានចុះបញ្ជីដំរូវឲ្យបើកសំដែងសកម្មភាពនិងភិនភាគនៅតាមអ៊ិនទ័រណិត។ ឥទ្ធិពលហិរញ្ញវត្ថុ : រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ចំណាយពីរបី លានដុល្លារជាប្រចាំឆ្នាំសំរាប់ដោះស្រាយបទល្មើសការជួញមនុស្ស។ ប្រាក់ចំណូលការផាកពិន័យប្រចាំឆ្នាំអាចនឹងបានបង្កើន នូវចំនួនស្រដៀងគ្នា ដែលត្រៀមទុកជាបឋមសំរាប់ជនរងគ្រោះនៃការជួញមនុស្ស។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោត បាទ/ចាស នៅក្នុងវិធានការនេះគឺមានន័យថា ៖ កាត់ទោសឱ្យជាប់គុកយូរ និងបង់ពិន័យច្រើនសំរាប់ប្រព្រឹត្តិឧក្រិដ្ឋកម្មជួញដូរមនុស្សខុសច្បាប់។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ ការដាក់ទណ្ឌកម្មផ្នែកឧក្រិដ្ឋសំរាប់ការជួញដូរមនុស្សខុសច្បាប់នឹងនៅមានឥទ្ធិពល។

### ទឡ្ហីករណ៍

**គាំទ្រ** បាទ/ចាស លើសំណើប្រជាមតិ 35—បញ្ឈប់ការជួញដូរមនុស្សខុសច្បាប់។ ការពារការកេងប្រវ័ញ្ចផ្លូវភេទកុមារ។អ្នកជួញដូរបង្ខំស្ត្រី និងកុមារឱ្យលក់រាងកាយរបស់គេនៅតាមដងផ្លូវ និងតាម បណ្តាញអនឡាញ។ សំណើប្រជាមតិ 35 វាយតប ជាមួយនឹងការកាត់ទោសដ៏តឹងរឹងបំផុត, ជួយអ្នករងគ្រោះការពារកុមារតាមបណ្តាញអនឡាញ។ អ្នកនៅរស់ពីការជួញដូរ;អ្នកគាំទ្រកុមារនិងជនរងគ្រោះជំរុញឱ្យបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ35។

**ប្រឆាំង** សំណើប្រជាមតិ35 តាមពិតគំរាមកំហែងមនុស្សគ្មានទោសកំហុសជាច្រើននាក់។ "កូនរបស់ខ្ញុំដែលបំពើកងក្នុងយោធាហើយឥឡូវនេះចូលរៀនមហាវិទ្យាល័យ អាចត្រូវគេពាក់ផ្លាកអ្នកជួញដូរមនុស្សខុសច្បាប់ហើយត្រូវតែចុះបញ្ជីជាជនប្រព្រឹត្តបទល្មើសផ្លូវភេទបើសិនជាខ្ញុំឧបត្ថម្ភប្រាក់ដែលខ្ញុំរកបានផ្តល់សេវាស្រើបស្រាល។"
—Maxine Doogan
សូមបោះឆ្នោត ទេ។

### សំរាប់ព័ត៌មានបន្ថែម


**គាំទ្រ**
Kristine Kil
បោះឆ្នោតបាទ/ចាស លើប្រជាមតិ 35
P.O. Box 7057
Fremont, CA 94537
(510) 473-7283
info@VoteYesOn35.com
www.VoteYesOn35.com

**ប្រឆាំង**
Maxine Doogan
សាជីវកម្មបំពើការស្រើបស្រាល អ្នកផ្តល់ការបំរើស្របច្បាប់, គំរោងអប់រំ និងការស្រាវជ្រាវ, Inc.
2261 Market Street #548
San Francisco, CA 94114
(415) 265-3302
noonprop35@gmail.com
http://esplerp.org/

## សប្រជាមតិ 36 ច្បាប់ប្រព្រឹត្តិល្មើសបីដង។ ទុរជនបទឧក្រិដ្ឋច្រំដែលៗ។ ទោសបញ្ញត្តិ។ លក្ខន្តិក:ផ្តួចផ្តើម។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ការកែប្រែច្បាប់ដើម្បីកាត់ទោសអស់មួយជីវិតលុះត្រាតែនៅពេលជាប់ទោសបទឧក្រិដ្ឋថ្មី គឺធ្ងន់ធ្ងរ ឬឃោឃៅ។ អាចនឹងអនុញ្ញាតការកាត់ទោសសាថ្មី បើការជាប់ ទោសប្រព្រឹត្តិល្មើសបីដង មិនជាធ្ងន់ធ្ងរ ឬឃោឃៅ។ ឥទ្ធិពលហិរញ្ញវត្ថុ : រដ្ឋសន្សំប្រាក់ ប្រហែល $70 លាន ជាប្រចាំឆ្នាំ ទៅលើ ការកែខៃខ្លួនជាហូរហែ ហើយអាចសន្សំប្រាក់ (ដល់ទៅ $90 លាន) ក្នុងរយ:ពេលពីរបីទសវត្សរ៍ខាងមុខ។ ការសន្សំប្រាក់ទាំងនេះ អាចខុសៗគ្នាយ៉ាងខ្លាំង អាស្រ័យទៅលើវិធានការរបស់រដ្ឋនៅពេលអនាគត។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោត បាទ/ចាសនៅក្នុងវិធានការនេះគឺមានន័យថា ៖ ជនប្រព្រឹត្តបទល្មើសខ្លះដែលមានការផ្តន្ទាទោសឧក្រិដ្ឋកំរិតធ្ងន់ធ្ងរ ឬហឹង្សាពីរដង ពីមុនមកហើយប្រព្រឹត្តិអំពើឧក្រិដ្ឋមួយចំនួន មិនធ្ងន់ធ្ងរមិនហឹង្សានឹងត្រូវគេកាត់ទោសរយ:ពេលខ្លីនៅក្នុងពន្ធនាគាររដ្ឋ។ ជាបន្ថែម ជនប្រព្រឹត្តបទល្មើសខ្លះដែលមានការផ្តន្ទាទោសឧក្រិដ្ឋកំរិតធ្ងន់ធ្ងរឬហឹង្សាពីរដងពីមុនហើយបច្ចុប្បន្ននេះកំពុងជាប់ទោសមួយជីវិតសំរាប់ការផ្តន្ទាទោសច្រើនដងកំរិតមិនធ្ងន់ធ្ងរ មិនហឹង្សាអាចកាត់ទោសឡើងវិញឱ្យជាប់ពន្ធនាគាររយ:ពេលខ្លី។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ ជនប្រព្រឹត្តបទល្មើសខ្លះដែលមានការផ្តន្ទាទោសឧក្រិដ្ឋកំរិតធ្ងន់ធ្ងរ ឬហឹង្សាពីរដងពីមុនមក ហើយប្រព្រឹត្តិអំពើឧក្រិដ្ឋថ្មីអាចនៅបន្តទទួលការជាប់ទោសមួយជីវិត។ ជាបន្ថែមជនប្រព្រឹត្តបទល្មើសដែលមានការផ្តន្ទាទោសឧក្រិដ្ឋកំរិតធ្ងន់ធ្ងរ ឬហឹង្សាពីរដងពីមុនហើយបច្ចុប្បន្ននេះកំពុងជាប់ទោសមួយជីវិតសំរាប់ការផ្តន្ទាទោស មិនធ្ងន់ធ្ងរ មិនហឹង្សា អាចនឹងបន្តជាប់ទោសសំរាប់ពេលនៅសល់ទាំងប៉ុន្មាននៃទោសមួយជីវិតរបស់គេ។

### ទឡ្ហីករណ៍

**គាំទ្រ** បញ្ចូលឡើងវិញនូវគោលបំណងដើមនៃច្បាប់ចែងពីបទល្មើសបីដងដោយផ្តោតលើឧក្រិដ្ឋកម្មហឹង្សា។ អ្នកប្រព្រឹត្តបទល្មើសច្រំដែលៗនៃអំពើឧក្រិដ្ឋកំរិតធ្ងន់ ឬហឹង្សាទទួលទោសជាប់ពន្ធនាគារមួយជីវិត។ ជនល្មើសអហឹង្សាទទួលទោសពីរដងនៃការកាត់ឱ្យជាប់ពន្ធនាគារធម្មតា។ សំចៃប្រាក់លើ $100,000,000 ប្រចាំឆ្នាំ ហើយធានារក្សាអ្នករំលោភគេ, ឃាតករ, និងឧក្រិដ្ឋជនគ្រោះថ្នាក់ផ្សេងៗទៀតឱ្យនៅក្នុងពន្ធធនាគារមួយជីវិត។

**ប្រឆាំង** សំណើប្រជាមតិ36នឹងបញ្ចេញឧក្រិដ្ឋជនគ្រោះថ្នាក់ពីពន្ធធនាគារដែលគេត្រូវបានកាត់ទោសជាប់គុកមួយជីវិតដោយសារប្រវត្តិឧក្រិដ្ឋកម្មដ៏យូរពេលរបស់គេ។ការផ្តើមប្រជាសិទ្ធិមានគុណវិបត្តិខ្លាំងណាស់ដែលឧក្រិដ្ឋជនទាំងនោះនឹងត្រូវបញ្ចេញពីពន្ធធនាគារដោយគ្មានការមើលគ្រប់គ្រង! ចូលរួមជាមួយក្រុមតម្រួតកាលីហ្វ័រញ៉ា ប៉ូលីស, រដ្ឋអាជ្ញា, និងក្រុមអ្នករងគ្រោះដោយឧក្រិដ្ឋកម្មក្នុងការបោះឆ្នោតទេលើសំណើប្រជាមតិ 36។

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**
Pedro Rosado
គណ:កម្មការសំរាប់កែទម្រង់ច្បាប់បទល្មើសបីដង
(415) 617-9360
pedro@FixThreeStrikes.org
www.FixThreeStrikes.org

**ប្រឆាំង**
Mike Reynolds
រក្សាទុក ច្បាប់បទល្មើសបីដង
P.O. Box 4163
Fresno, CA 93744
SaveThreeStrikes.com

## សប្រជាមតិ 37 អាហារដែលបានបំភ្លែពូជ។ ការដាក់ស្លាក។ លក្ខន្តិក:ផ្តួចផ្តើម។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ដំរូវឲ្យមានការដាក់ស្លាកអាហារឆៅឬបានធ្វើសំរាប់លក់ទៅឲ្យអតិថិជនបើសិនបានធ្វើមកពីដំណាំ ឬសត្វដែលបានផ្លាស់ប្តូរសំភារ:សំគាល់ពូជ ក្នុងរបៀបណាមួយ។ ហាមឃាត់ការផ្សាយលក់នូវអាហារបែបនោះឬអាហារបានធ្វើផ្សេងទៀតថាជា"ធម្មជាតិ"។ផ្តល់ការលើកលែង។ ឥទ្ធិពលហិរញ្ញវត្ថុ : ការចំណាយរបស់រដ្ឋកើនឡើង ចាប់តាំងពី ពីរបីរយពាន់ដុល្លារ រហូតដល់ទៅជាង $1 លាន ដើម្បីដាក់បញ្ញត្តិការដាក់ស្លាក នៃអាហារដែលបំភ្លែពូជ។ មិនតែប៉ុណ្ណោះ ប៉ុន្តែប្រហែលមិនខ្លាំងក្លាទេ ដែលការចំណាយរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយការល្មើសនៅក្រោមវិធានការ។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោត បាទ/ចាស នៅក្នុងវិធានការនេះគឺមានន័យថា ៖ អាហារវិស្វកម្មពន្ធុដែលលក់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាគួរត្រូវតែមានបិទផ្លាកដាក់លាក់ជាអាហារវិស្វកម្មពន្ធុ។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ អាហារវិស្វកម្មពន្ធុដែលលក់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាគួរនៅបន្តមិនមានបិតផ្លាកដាក់លាក់ដូចតាមការតំរូវឡើយ។

### ទឡ្ហីករណ៍

**គាំទ្រ** សំណើប្រជាមតិ 37 ផ្តល់ឱ្យយើងនូវសិទ្ធិដឹងនូវអ្វីមានក្នុងចំណីអាហារដែលយើងបរិភោគ និងចិញ្ចឹមគ្រួសាររបស់យើង។ ជាការងាយបំផុតគឺតំរូវឱ្យបិតផ្លាកនៃអាហារដែលផលិតដោយធ្វើវិស្វកម្មពន្ធុ, ដើម្បីយើងអាចជ្រើសរើសថាតើយើងគួរទិញផលិតផលនោះឬយ៉ាងណា។យើងមានសិទ្ធិដឹងពីអ្វីនៅក្នុនោះ។

**ប្រឆាំង** សំណើប្រជាមតិ 37 គឺជាផែនការបិទផ្លាកលើចំណីអាហារ ដ៏គួរឱ្យខកចិត្ត មានគុណវិប្បត្តិយ៉ាងស៊ីជំរៅ នឹងពេញទៅដោយការលើកលែងនានាសំរាប់ក្រុមគ្មានផលប្រយោជន៍ពិសេសនិងការបញ្ចៀសពន្ធចេញពីច្បាប់។សំណើប្រជាមតិ 37 នឹង ៖ បង្កើតការិយាធិបតេយ្យថ្មីមួយក្នុងរដ្ឋាភិបាលអស់ថ្លៃដល់អ្នកបង់ពន្ធរាប់លានដុល្លារ, អនុញ្ញាតការចំណាយថ្លៃលើបណ្តឹងវិវាទប្រឆាំងនឹងកសិករ និងពាណិជ្ជកម្មខ្នាតតូចហើយតំឡើងវិក្កយបត្រទិញទំនិញរបស់គ្រួសារ រាប់រយដុល្លារក្នុងមួយឆ្នាំៗ។
*www.NoProp37.com*

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**
Gary Ruskin
កាលីហ្វ័រញ៉ា សិទ្ធិក្នុងការដឹង
5940 College Avenue
Oakland, CA 94618
(213) 784-5656
GaryR@CARightToKnow.org
www.CARightToKnow.org

**ប្រឆាំង**
បោះឆ្នោត ទេ លើសំណើប្រជាមតិ 37, បញ្ឈប់ផែនការបិតផ្លាកចំណីអាហារដែលធ្វើឱ្យខកចិត្ត។
(800) 331-0850
info@NoProp37.com
www.NoProp37.com

# មគ្គុទ្ទេសក៍យោង-ឆាប់រហ័ស

## សំ.ប្រជាមតិ 38 ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំដូង។ លក្ខន្តិក:ផ្តួចផ្តើម។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

កំណើនពន្ធលើប្រាក់រកបាន ដោយប្រើខ្នាតរំកិល ចំនួនដប់ពីរឆ្នាំ។ ប្រាក់ចំណូល សំរាប់សាលារៀនថ្នាក់ K-12 និងកម្មវិធីកុមារវ័យដំបូង និងចំនួនបួនឆ្នាំ ដើម្បីសងបំណុលរដ្ឋ។ ឥទ្ធិពលហិរញ្ញវត្ថុ : ពន្ធប្រាក់ចំណូលរបស់រដ្ឋបានកើនឡើងចំនួន 12 ឆ្នាំ—ប្រហាក់ប្រហែល$10កោដិជាប្រចាំឆ្នាំក្នុងឆ្នាំដំបូងដែលទំនងនឹងកើនឡើងគ្រឿនៗ។ថវិកាដែលបានប្រើសំរាប់សាលារៀន ការមើលថៃក្មេង និងមតេយ្យសាលា ព្រមទាំងផ្តល់ការ សន្សំប្រាក់ដើម្បីសងបំណុលរដ្ឋផង។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោតបាទ/ចាសនៅក្នុងវិធាន ការនេះគឺមានន័យថា ៖ កំរិតពន្ធចំណូលប្រចាំឆ្នាំផ្ទាល់ខ្លួនរដ្ឋនឹងកើនសំរាប់រយៈពេល12 ឆ្នាំ។ ប្រាក់ចំណូលបន្ថែមនឹងត្រូវប្រើសំរាប់សាលា,ការថៃទាំកុមារ, មត្តេយ្យសាលា, និងការសងបំណុលរដ្ឋ។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ អត្រាពន្ធចំណូលប្រចាំឆ្នាំផ្ទាល់ខ្លួនរដ្ឋនឹងនៅកំរិតដដែលដូចបច្ចុប្បន្ន។ មិនមានមូលនិធីអ្វីបន្ថែមសំរាប់សាលា, ការថៃទាំកុមារ, មត្តេយ្យសាលា, និងការសងបំណុលរដ្ឋ។

### ទទ្បហីករណ៍

**គាំទ្រ** សំណើប្រជាមតិ 38 ធ្វើឱ្យសាលាជាអាទិភាពឡើងវិញ។ វាធានានូវថវិកាថ្មីសំរាប់សិស្សដោយផ្ទាល់ទៅកាន់សាលាសាធារណៈតាមមូលដ្ឋានដើម្បីដាក់ឱ្យមានវិញនូវថវិកាបានកាត់បន្ថយហើយធ្វើឱ្យប្រសើរឡើងវិញលទ្ធផលនៃការអប់រំ។ សំណើប្រជាមតិ 38 ហាមឃាត់ អ្នកនយោបាយទាំងឡាយនៅ Sacramento មិនឱ្យប៉ះពាល់ប្រាក់នោះឡើយ។ សេចក្តីសំរេចក្នុងការចំណាយត្រូវធ្វើឡើងតាមមូលដ្ឋានជាមួយនឹងការណែនាំយោបល់ ពីសហគមន៏និងការតំរូវគណនេយ្យភាពខ្លាំងរួមទាំងសវនកម្មឯករាជ្យ។

**ប្រឆាំង** បោះឆ្នោត ទេ លើសំណើប្រជាមតិ 38 ៖ បើអ្នករកបាន $17,346 ក្នុងមួយឆ្នាំ នៃប្រាក់ចំណូលជាប់ពន្ធ ពន្ធរបស់អ្នកកើន។ សរុបចំនួន $120មួយរយម្ភៃពាន់កោដិក្នុងពន្ធកំរិតខ្ពស់។គ្មានការតំរូវធ្វើឱ្យសិស្សមានភាពប្រសើរក្នុងការសិក្សា។មិនអាចប្តូររហូតដល់12 ឆ្នាំ ទោះបីជាមួយការលួចបន្លំក៏ដោយ។ខូចខាតដល់ពាណិជ្ជកម្មខ្នាតតូច, សំឡាប់ការងារ។ អ្នកអប់រំ, អ្នកបង់ពន្ធ និងពាណិជ្ជករ បដិសេធ សំណើប្រជាមតិ 38។

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 38
(323) 426-6263
info@prop38forlocalschools.org
www.prop38forlocalschools.org

**ប្រឆាំង**

Jason Kinney
បញ្ឈប់ការឡើងពន្ធប្រាក់ចំណូលសំរាប់គ្រួសារថ្នាក់កណ្តាល។—បោះឆ្នោត ទេ លើសំណើប្រជា 38
980 9th Street, Suite 2000
Sacramento, CA 95814
(916) 806-2719

## សំ ប្រជាមតិ 39 លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិក:ផ្តួចផ្តើម។

### សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ដំរូវឲ្យពាណិជ្ជកម្មពហុរដ្ឋបង់ពន្ធលើប្រាក់ចំណូលដោយយោងទៅលើភាគរយនៃការលក់ដូររបស់គេ ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។ ត្រៀមទុកប្រាក់ចំណូល ចំនួនប្រាំឆ្នាំ សំរាប់ផែនការថាមពលល្អស្អាត/បរិបូរណ៍។ ឥទ្ធិពលហិរញ្ញវត្ថុ : ប្រាក់ចំណូលរបស់រដ្ឋកើន ឡើង $1 កោដិ ជាប្រចាំឆ្នាំ ដែលពាក់កណ្តាលនៃប្រាក់ចំណូលចំនួនប្រាំឆ្នាំខាង មុខ ត្រូវបានចំណាយ ទៅលើផែនការថាមពល បរិបូរណ៍។ ក្នុងបណ្តានៃប្រាក់ចំណូលដែលនៅសល់មួយផ្នែកធំប្រហែលនឹងបានចំណាយទៅលើសាលារៀនសាធារណៈ។

### សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោតបាទ/ចាសនៅក្នុងវិធានការនេះគឺមានន័យថា ៖ ពាណិជ្ជកម្មពហុរដ្ឋនឹងមិនអាចជ្រើសរើសរបៀបកំណត់លើប្រាក់ចំណូលជាប់ពន្ធរដ្ឋរបស់គេដែលមានសារៈប្រយោជន៏សំរាប់គេ។ ពាណិជ្ជកម្មពហុរដ្ឋខ្លះនឹងត្រូវបង់ពន្ធប្រាក់ចំណូលសាជីវកម្មច្រើនចំពោះការផ្លាស់ប្តូរនេះ។ ប្រហែលពាក់កណ្តាលនៃកំណើនពន្ធនេះ ក្នុងរយៈពេលប្រាំឆ្នាំខាងមុខនឹងត្រូវប្រើសំរាប់ឧបត្ថម្ភ គំរោងប្រសិទ្ធិភាពថាមពល និងគំរោងថាមពលទ្វេបថ។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ ពាណិជ្ជកម្មពហុរដ្ឋភាគច្រើននឹងអាចបន្តជ្រើសយករបៀបមួយក្នុងចំណោមពីរដើម្បីកំណត់នូវប្រាក់ចំណូលជាប់ពន្ធរដ្ឋកាលីហ្វ័រញ៉ា។

### ទទ្បហីករណ៍

**គាំទ្រ** បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39 បិតការបញ្ចៀសពន្ធអយុត្តិធម៌ បណ្តោយឱ្យវាចេញទៅក្រុមសាជីវកម្មក្រៅរដ្ឋដែលជៀសវាងបង់ពន្ធដោយរក្សាទុកការងារនៅក្រៅរដ្ឋកាលីហ្វ័រញ៉ា។ការបិតការបញ្ចៀសនេះការពារការងារតាមមូលដ្ឋាន ហើយផ្តល់ថវិកា $1 មួយរយកោដិទៅឱ្យកាលីហ្វ័រញ៉ា។មូលនិធិត្រូវបានប្រើសំរាប់គំរោងលើការងារបង្កើតថាមពលមានប្រសិទ្ធិភាពនៅសាលានិងសំរាប់កាត់បន្ថយឱនភាព។ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39—បិតការបញ្ចៀសពន្ធ។

**ប្រឆាំង** សំណើប្រជាមតិ 39 គឺជាកំណើនពន្ធដ៏សន្ធឹកសន្ធាប់ $1 មួយរយកោដ លើអ្នកបង្កើតការងារក្នុងរដ្ឋកាលីហ្វ័រញ៉ាដែលបំរើមនុស្សរាប់រយពាន់នាក់ពីក្រុមអ្នកធ្វើការថ្នាក់កណ្តាល។ គឺជាបង្កាន់ដៃសំរាប់ការខ្ជះខ្ជាយ និងពុករលួយ ផ្តល់ឱ្យអ្នកនយោបាយនៅ Sacramento សន្លឹកសែកចំហរចំណាយរាប់រយកោដិដោយគ្មាន គណនេយ្យភាពពិតប្រាកដ។ កាលីហ្វ័រញ៉ាគឺមានបំណុលរាប់រយកោដិ; សំណើប្រជាមតិ 39 ធ្វើឱ្យបំណុលនេះកាត់តែយ៉ាប់យ៉ឺនឡើង។

### សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ39—កាលីហ្វ័រញ៉ានឹងបិតការបញ្ចៀសពន្ធសំរាប់សាជីវកម្មក្រៅរដ្ឋ។
www.cleanenergyjobsact.com

**ប្រឆាំង**

សមាគមបច្ចេកវិទ្យា & ឧស្សាហកម្មកាលីហ្វ័រញ៉ា
1115 11th Street
Sacramento, CA 95814
info@Stop39.com
www.Stop39.com

# សប្រជាមតិ 40 ការដាក់កំរិត។ មណ្ឌលរដ្ឋព្រឹត្តិសភា។ ប្រជាមតិ។

## សេចក្តីសង្ខេប

*ដាក់ក្នុងសន្លឹកឆ្នោតដោយហត្ថលេខាពលរដ្ឋលើបដ្ឋនាលិខិត*

ការបោះឆ្នោត "បាទ/ចាស" មានន័យថាយល់ព្រម ហើយការបោះឆ្នោត "ទេ" មានន័យថាបដិសេធ ដ្បិតមណ្ឌលរដ្ឋព្រឹទ្ធសភាថ្មី ត្រូវបានចាប់ឆ្នោតដោយ គណៈកម្មការពល រដ្ឋបែងចែកមណ្ឌល។ បើសិនបានបដិសេធមណ្ឌលនឹងបានកែសំរួលដោយមន្ត្រីដែលត្រួតមើលដោយតុលាការជាន់ខ្ពស់រដ្ឋកាលីហ្វ័រនីញ៉ា។ ឥទ្ធិពលហិរញ្ញវត្ថុ : ការយល់ព្រមប្រជាមតិនឹងគ្មានឥទ្ធិពលហិរញ្ញវត្ថុទៅលើរដ្ឋនិងរដ្ឋាភិបាលមូលដ្ឋានទេ។ការបដិសេធន៍ប្រជាមតិ នឹងបណ្តាល ឲ្យមានការចំណាយមួយដង ប្រហែល $1 លាន ចំពោះរដ្ឋ និងខោនធី។

## សំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

**បាទ/ចាស** សន្លឹកឆ្នោតបាទ/ចាសនៅក្នុងវិធានការនេះគឺមានន័យថា ៖ ព្រំដែនមណ្ឌលព្រឹទ្ធសភារដ្ឋត្រូវបានបញ្ជាក់ដោយគណកម្មការពលរដ្ឋបែងចែកមណ្ឌលនឹងត្រូវបន្តប្រើប្រាស់តទៅទៀត។

**ទេ** សន្លឹកឆ្នោត ទេ នៅក្នុងវិធាន ការនេះគឺមានន័យថា ៖ តុលាការកំពូលនឹងចាត់តាំងអ្នកជំនាញពិសេសដើម្បីកំណត់ព្រំដែនមណ្ឌលព្រឹទ្ធសភារដ្ឋជាថ្មី។

## ទទ្បហីករណ៍

**គាំទ្រ** បោះឆ្នោត"បាទ/ចាស"លើសំណើប្រជាមតិ 40 ការពារផែនទីព្រឹទ្ធសភារដ្ឋគូសដោយគណៈកម្មការពលរដ្ឋបែងចែកមណ្ឌលឯករាជ្យដែលបានយល់ព្រមដោយអ្នកបោះឆ្នោត។ បាទ/ចាស លើសំណើប្រជាមតិ 40 ប្រកាន់តាមឆន្ទៈអ្នកបោះឆ្នោតនៅកាលីហ្វ័រញ៉ាឱ្យអ្នកនយោបាយទទួលខុសត្រូវដោយរក្សាពួកគេនៅក្រៅដំណើរការបែងចែកមណ្ឌលនេះ។ ក្រុមរដ្ឋាភិបាលល្អ, ព្រឹទ្ធាចារ្យ, ពាណិជ្ជកម្ម និងអ្នកបង់ពន្ធ ឱ្យអនុសាសន៍បោះឆ្នោត "បាទ/ចាស លើសំណើប្រជាមតិ 40."

**ប្រឆាំង** ក្នុងនាមជាអ្នកឧបត្ថម្ភនៃសំណើប្រជាមតិ 40, គោលបំណងរបស់យើងគឺច្រានចោលគណៈកម្មការមណ្ឌលព្រឹទ្ធសភារដ្ឋសំរាប់ឆ្នាំ 2012។ ក៏ប៉ុន្តែដោយសារតុលាការកំពូលរដ្ឋសំរេចថារក្សាមណ្ឌល់ទាំងឡាយនោះឱ្យនៅនឹងកន្លែងសិនសំរាប់ឆ្នាំ 2012,យើងបានព្យួរការឃោសនារបស់យើងទុកសិន ហើយយើងមិនស្វែងរកសំឡេងឆ្នោត ទេ ឡើយ។

## សំរាប់ព័ត៌មានបន្ថែម

**គាំទ្រ**

បោះឆ្នោត "បាទ/ចាស" លើសំណើប្រជាមតិ 40
Hold Politicians Accountable
1215 K Street, Suite 2260
Sacramento, CA 95814
(866) 408-4527
Info@HoldPoliticiansAccountable.org
www.HoldPoliticiansAccountable.org

**ប្រឆាំង**

FAIRDISTRICTS2012.com

### ចូលទស្សនាគេហទំព័រ រដ្ឋលេខាធិការ ដើម្បី ៖

- ស្រាវជ្រាវអំពីការធ្វើវិភាគទានឃោសនា និងសកម្មភាពតស៊ូមតិ
  *http://cal-access.sos.ca.gov*
- ពិនិត្យមគ្គុទ្ទេសក៍បោះឆ្នោតជាភាសាផ្សេងៗទៀត
  *www.voterguide.sos.ca.gov*
- រកមើលមន្ទីរបោះឆ្នោតនៅក្នុងស្រុករបស់អ្នក
  *www.sos.ca.gov/elections/find-polling-place.htm*
- សុំព័ត៌មានអំពីការបោះឆ្នោតផ្ញើតាមប៉ុស្តសំបុត្រ
  *www.sos.ca.gov/elections/elections_m.htm*
- ទទួលព័ត៌មាន មានប្រយោជន៍សំរាប់អ្នកបោះឆ្នោតលើកដំបូង
  *www.sos.ca.gov/elections/new-voter*
- មើលលទ្ធផលបោះឆ្នោតរស់រវើកក្រោយពីមន្ទីរបោះឆ្នោតត្រូវបិទ នៅថ្ងៃបោះឆ្នោត
  *http://vote.sos.ca.gov*

### អំពីឆ្នោតទទ្បហីករណ៍

រដ្ឋលេខាធិការមិនសរសេរឆ្នោតទទ្បហីករណ៍ទេ។ ទទ្បហីករណ៍ក្នុងការ គាំទ្រ និងជំទាស់ ក្នុងវិធានការសន្លឹកឆ្នោតគឺត្រូវបានផ្តល់ដោយ អ្នកគាំទ្រ និងអ្នកជំទាស់នៃវិធានការសន្លឹកឆ្នោត។ ភាសាថ្លែងក្នុងទទ្បហីករណ៍ដែលបានដាក់បញ្ជូនមកមិនអាចត្រូវបានធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់សំរាប់ភាពត្រឹមត្រូវ ឬត្រូវបានកែប្រែអ្វីឡើយ លុះត្រាតែមានដីកាតុលាការថាភាសាក្នុងទទ្បហីករណ៍ណាមួយគួរត្រូវកែប្រែ ទើបយើងអាចធ្វើបាន។

សំរាប់ព័ត៌មានទៀតថែមអំពីសិទ្ធិបោះឆ្នោតរបស់អ្នក, សូមអានទំព័រ 143 នៃមគ្គុទ្ទេសក៍នេះ។

# ការ បោះឆ្នោតក្នុងរដ្ឋកាលីហ្វ័រញ៉ា

ច្បាប់នៃការបើកបោះឆ្នោតលប្បងស្តីពីបេក្ខជនកំពូលពីរនាក់ ដែលចូលជាធរមាននាថ្ងៃទី1 ខែមករា ឆ្នាំ 2011 តំរូវថា គ្រប់បេក្ខជនទាំងអស់ឈរឈ្មោះសំរាប់ការិយាល័យអ្នកបោះ ឆ្នោតតែងតាំងគឺត្រូវរាយឈ្មោះនៅក្នុងក្រដាសសន្លឹកឆ្នោតតែមួយ។ កន្លងមកពីមុនហៅថាការិយាល័យបក្សព័ន្ធ (partisan offices), ការិយាល័យអ្នក បោះ ឆ្នោតតែងតាំង (voter-nominated offices) គឺជាការិយាល័យ នីតិបញ្ញត្តិរដ្ឋ, ការិយាល័យសភា នៃសហរដ្ឋអាមេរិក, និងការិយាល័យរដ្ឋធម្មនុញ្ញរដ្ឋ។ គឺមានតែបេក្ខជនពីររូបប៉ុណ្ណោះដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេ—ដោយមិនគិតពីគណៈបក្សអាទិភាព—បន្តធ្វើការបោះឆ្នោតជាសកលដោយមិនគិតពីចំនួនសរុបសន្លឹកឆ្នោត។

បេក្ខជនដែលចារឈ្មោះចូលក្នុងសន្លឹកឆ្នោតសំរាប់ការិយាល័យអ្នកបោះឆ្នោតតែងតាំងអាចឈរឈ្មោះនៅក្នុងការបោះឆ្នោតសាកល្បងតែប៉ុណ្ណោះ។ តែទោះជាយ៉ាងណាក៏ដោយ បេក្ខជនដែលចារឈ្មោះចូលក្នុងសន្លឹកឆ្នោតអាចបន្តឈរឈ្មោះបានសំរាប់ការបោះឆ្នោតសកលទៀតលុះត្រាតែបេក្ខជននោះគឺជាបេក្ខជនម្នាក់នៃអ្នកជ្រើសរើសកំពូលពីរនាក់នៅក្នុងការបោះឆ្នោតសាកល្បង។ ជាបន្ថែមទៀត គឺគ្មានដំណើរការតែងតាំងដោយឯករាជ្យសំរាប់ការបោះឆ្នោតសកល។

ច្បាប់ប្រព័ន្ធបើកបោះឆ្នោតល្បងថ្មីនៅរដ្ឋកាលីហ្វ័រញ៉ាមិនអនុវត្តន៍ចំពោះបេក្ខជនដែលឈរឈ្មោះសំរាប់ប្រធានាធិបតីសហរដ្ឋអាមេរិក, គណៈកម្មការកណ្តាលខោនធី, ឬសំរាប់ការិយាល័យមូលដ្ឋានឡើយ។

ច្បាប់រដ្ឋកាលីហ្វ័រញ៉ាតំរូវឱ្យបោះពុម្ពព័ត៌មានខាងក្រោមនេះនៅក្នុងសេចក្តីជូនដំណឹងនេះ។

## បេក្ខជនបក្ស-តែងតាំង/ការិយាល័យបក្សព័ន្ធ

គណៈបក្សនយោបាយអាចតែងតាំងបេក្ខជនជាផ្លូវការសំរាប់ការិយាល័យបក្ស-តែងតាំង/ការិយាល័យបក្សព័ន្ធនៅពេលបោះឆ្នោតល្បង។ បេក្ខជនដែលបានតែងតាំងនឹងតំណាងឱ្យគណៈបក្សនោះជាបេក្ខជនផ្លូវការរបស់គណៈបក្សសំរាប់ឈរនៅការិយាល័យជាក់លាក់ណាមួយពេលបោះឆ្នោតសកល ហើយចំនួនសន្លឹកឆ្នោតនឹងឆ្លុះបញ្ចាំងពីការចាត់តាំងនោះជាផ្លូវការ។ អ្នកដែលទទួលបានសន្លឹកឆ្នោតកំពូលនៅក្នុងបក្សនិមួយៗនៅពេលបោះឆ្នោតល្បងនឹងបន្តទៅឈរឈ្មោះពេលបោះឆ្នោតសកលទៀត។ បក្សនិមួយៗក៏ជ្រើសមន្ត្រីគណៈកម្មការកណ្តាលនៃខោនធីនៅពេលបោះឆ្នោតល្បងរបស់បក្សដែរ។

អ្នកបោះឆ្នោតមួយរូបអាចបោះឆ្នោតនៅក្នុងការបោះឆ្នោតល្បងនៃគណៈបក្សនយោបាយដែលគាត់បានបង្ហាញថាជាគណៈបក្សអាទិភាពរបស់គាត់នៅពេលបានចុះឈ្មោះដើម្បីបោះឆ្នោត។ តែទោះបីជាយ៉ាងណា គណៈបក្សនយោបាយមួយអាចអនុញ្ញាតបុគ្គលម្នាក់ដែលបដិសេធមិនប្រាប់ពីគណៈបក្សអាទិភាពឲ្យបោះឆ្នោតនៅក្នុងការបោះឆ្នោតល្បងនៃគណៈបក្សនោះបានដែរ។

## បេក្ខជនការិយាល័យ អ្នក បោះឆ្នោត តែងតាំង

គណៈបក្សនយោបាយទាំងឡាយគឺមិនមានសិទ្ធិតែងតាំងបេក្ខជនជាផ្លូវការសំរាប់ការិយាល័យអ្នកបោះឆ្នោតតែងតាំងនៅពេលបោះឆ្នោតល្បងបានទេ។ បេក្ខជនដែលបានតែងតាំងសំរាប់ការិយាល័យអ្នកបោះឆ្នោតតែងតាំងនៅពេលបោះឆ្នោតល្បងគឺជាអ្នកតែងតាំង នៃពលរដ្ឋ គឺមិនមែនជាអ្នកតែងតាំងផ្លូវការដោយគណៈបក្សណាម្នាក់នៅពេលបោះឆ្នោតសកលទេ។ បេក្ខជនតែងតាំងសំរាប់ការិយាល័យអ្នកបោះឆ្នោតតែងតាំងគួរតែមានគណៈបក្សអាទិភាព ឬគ្មានគណៈបក្សអាទិភាពរបស់គេ បានចែងនៅក្នុងសន្លឹកឆ្នោត ក៏ប៉ុន្តែការចាត់តាំងគណៈបក្សអាទិភាពគឺត្រូវបានជ្រើសរើសដោយបេក្ខជនតែម្នាក់ឯង ហើយក៏មានបង្ហាញសំរាប់ជាព័ត៌មានរបស់អ្នកបោះឆ្នោតតែប៉ុណ្ណោះ។ នេះគឺមិនមានន័យថា បេក្ខជនត្រូវបានគេតែងតាំងឬយល់ព្រមដោយគណៈបក្សដែលតែងតាំងទេ ឬថាមានទំនាក់ទំនងរវាងគណៈបក្សនិងបេក្ខជនទេហើយគ្មានបេក្ខជនត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតគួរត្រូវចាត់ទុកថាបេក្ខជនតែងតាំងជាផ្លូវការរបស់គណៈបក្សនយោបាយណាមួយឡើយ។ នៅក្នុងកូនសៀវភៅបោះឆ្នោតគំរូនៃខោនធី គណៈបក្សទាំងអស់អាចចុះរាយឈ្មោះបេក្ខជនសំរាប់ការិយាល័យអ្នកបោះឆ្នោតតែងតាំង ដែលបានទទួលដោយមានការគាំទ្រជាផ្លូវការពីគណៈបក្ស។

អ្នកបោះឆ្នោតម្នាក់ៗអាចបោះឆ្នោតសំរាប់បេក្ខជនណាក៏បានសំរាប់ការិយាល័យអ្នកបោះឆ្នោតតែងតាំង បើសិនជាបេក្ខជនទាំងនោះជួបនូវគុណសម្បត្តិ នៃការតំរូវផ្សេងៗទៀតដើម្បីជ្រើសតាំងសំរាប់ការិយាល័យនោះ។ បេក្ខជនទទួលសន្លឹកឆ្នោតកំពូលពីរនាក់ដែលបានពីការបោះឆ្នោតល្បងត្រូវបន្តទៅការបោះឆ្នោតសកលសំរាប់ការិយាល័យអ្នកបោះឆ្នោតតែងតាំងទោះបីជាបេក្ខជនទាំងពីរនាក់នោះមានការបញ្ជាក់តែងតាំងពីគណៈបក្សអាទិភាពដូចគ្នាក៏ដោយ។ គ្មានគណៈបក្សណាមួយមានសិទ្ធិដាក់បេក្ខជនដែលមានការតែងតាំងគណៈបក្សអាទិភាពឱ្យបន្តទៅការបោះឆ្នោតសកលបានទេ លើកលែងតែបេក្ខជននោះគឺជាបេក្ខជនម្នាក់នៃចំណោមអ្នកទទួលសន្លឹកឆ្នោតកំពូលទាំងពីរនៅពេលបោះឆ្នោតល្បង។

## បេក្ខជនការិយាល័យក្រៅបក្សព័ន្ធ

គណៈបក្សនយោបាយទាំងអស់មិនអាចផ្តល់សិទ្ធិតែងតាំងបេក្ខជនខ្លួនសំរាប់បំរើការិយាល័យពីក្រៅបក្សព័ន្ធនៅពេលបោះឆ្នោតល្បងទេ ហើយបេក្ខជនដែលឈរឈ្មោះបោះឆ្នោតល្បងគឺមិនមែនជាអ្នកតែងតាំងជាផ្លូវការនៃគណៈបក្សណាមួយសំរាប់ការិយាល័យជាក់លាក់នៅពេលបោះឆ្នោតសកលឡើយ។ បេក្ខជនដែលតែងតាំងសំរាប់ការិយាល័យក្រៅបក្សព័ន្ធមិនអាចចាត់តាំងសំរាប់គណៈបក្សអាទិភាពរបស់គេ ឬមិនមានគណៈបក្សអាទិភាព របស់គេទេនៅក្នុងសន្លឹកឆ្នោតទេ។ អ្នកទទួលសន្លឹកឆ្នោតកំពូលច្រើនជាងគេ ពីរូបពេលបោះឆ្នោតល្បងនោះបន្តទៅការបោះឆ្នោតសកលសំរាប់ជាបេក្ខជនការិយាល័យនៅក្រៅបក្សព័ន្ធ។

# សំណើប្រជាមតិ 30 ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

**ចំណងជើងជាផ្លូវការ និងសេចក្ដីសង្ខេប** — **រៀបចំដោយអគ្គមេធាវី**

## ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។  ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

- ការបង្កើនពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន លើប្រាក់រកបានប្រចាំឆ្នាំ ច្រើនជាង $250,000 ចំនួនប្រាំពីរឆ្នាំ។
- ការបង្កើនពន្ធថ្លៃលក់ដូរ និងប្រើប្រាស់ ដោយ ¼ សេន ចំនួនបួនឆ្នាំ។
- ការបែងចែកពន្ធប្រាក់ចំណូលបណ្ដោះអាសន្ន 89% សំរាប់សាលារៀនថ្នាក់ K-12 និង 11% សំរាប់មហាវិទ្យាល័យ សហគមន៍។
- ហាមឃាត់ការប្រើថវិកាសំរាប់ចំណាយលើការគ្រប់គ្រង ប៉ុន្តែផ្ដល់អត្តនោម័តឲ្យគណៈគ្រប់គ្រងសាលារៀនតាមមូលដ្ឋាន ដើម្បីសំរេចក្នុងអង្គប្រជុំដែលបើកចំហ និងត្រូវបានជំរះបញ្ជីជាប្រចាំឆ្នាំ នូវលក្ខណៈថវិកាត្រូវបានចំណាយជាយ៉ាងណា។
- ការផ្ដល់ថវិកាដែលអះអាង សំរាប់សេវាខាងសុវត្ថិភាពសាធារណៈ បានធ្វើឲ្យស្របគ្នាវិញ ចេញពីរដ្ឋ ទៅឲ្យរដ្ឋាភិបាល មូលដ្ឋាន។

**សេចក្ដីសង្ខេបនៃអ្នកវិភាគនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានៈ**

- ពន្ធប្រាក់ចំណូលបន្ថែមរបស់រដ្ឋ ប្រហែល $6 ប្រាំមួយរយកោដិជាប្រចាំឆ្នាំ ចាប់តាំងពីឆ្នាំ 2012-13 រហូតដល់ឆ្នាំ 2016-17។  ចំនួនប្រាក់ចំណូលបន្ថែមតិចជាង នឹងមានសំរាប់ប្រើក្នុងឆ្នាំ 2011-12, 2017-18, និងឆ្នាំ 2018-19។
- ប្រាក់ចំណូលបន្ថែមទាំងនេះ នឹងមានសំរាប់ការផ្ដល់ថវិកាឲ្យកម្មវិធីនានា ក្នុងគំរោងថវិការបស់រដ្ឋ។  ការកាត់បន្ថយ នូវការចំណាយប្រហែល $6 ប្រាំមួយរយកោដិ ក្នុងឆ្នាំ 2012-13 ជាចំបងសំរាប់កម្មវិធីអប់រំ នឹងមិនមានឥទ្ធិពលទេ។

---

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ**

## ទិដ្ឋភាពទូទៅ

វិធានការនេះ បង្កើនអត្រាពន្ធថ្លៃលក់ដូររបស់រដ្ឋ សម្រាប់អ្នកជាប់ពន្ធទាំងអស់ និងអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន (PIT) សម្រាប់អ្នកជាប់ពន្ធប្រាក់ចំណូលកម្រិតខ្ពស់។ ការបង្កើនពន្ធបណ្ដោះអាសន្នទាំងនេះ ផ្ដល់នូវប្រាក់ចំណូលបន្ថែម ដើម្បីទូទាត់សម្រាប់កម្មវិធីទាំងឡាយ ដែលត្រូវបានផ្ដល់ថវិកានៅក្នុងគំរោងថវិការបស់រដ្ឋ។ គំរោងថវិកាឆ្នាំ 2012–13 របស់រដ្ឋដែលបានអនុម័តដោយអង្គនីតិបញ្ញត្តិ និងអភិបាលរដ្ឋនៅខែមិថុនា ឆ្នាំ 2012 សន្មតថាមាន ការអនុម័តនៃវិធានការនេះ។ ទោះបីជាយ៉ាងណា គំរោងថវិកានេះ ក៏រួមបញ្ចូលផងដែរនូវផែនការបំរុង ដែលតម្រូវឲ្យមានការកាត់បន្ថយចំណាយ (ហៅថា "ការកាត់ឆ្លើយតបតាមហេតុការណ៍") ក្នុងករណីដែលអ្នកបោះឆ្នោតបដិសេធវិធានការនេះ។ វិធានការនេះក៏ដាក់បញ្ចូលទៅក្នុងធម្មនុញ្ញផងដែរ នូវលក្ខខណ្ឌតម្រូវមួយចំនួន ដែលពាក់ព័ន្ធនឹងការផ្ទេរការទទួលខុសត្រូវនៃកម្មវិធីរបស់រដ្ឋខ្លះ ទៅឲ្យរដ្ឋបាលមូលដ្ឋានថ្មីៗនេះ។ តារាងទី 1 សង្ខេបអំពីខចែងសំខាន់ៗនៃសំណើប្រជាមតិនេះ ដែលត្រូវបានពិភាក្សាលម្អិតថែមទៀតនៅខាងក្រោម។

**តារាងទី 1**
**ទិដ្ឋភាពទូទៅនៃសំណើបជាមតិ លេខ 30**

**ពន្ធដាររដ្ឋ និងប្រាក់ចំណូល**

- បង្កើនអត្រាពន្ធលក់ទំនិញបាន មួយ-ភាគបួន សេនសំរាប់រាល់ដុល្លារក្នុងអំឡុងពេល បួនឆ្នាំ។
- បង្កើនពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនចំពោះ អ្នកជាប់ពន្ធថ្នាក់ខ្ពស់សំរាប់រយៈពេលប្រាំពីរឆ្នាំ។
- តំឡើងប្រហែល $6 ប្រាំមួយរយកោដិដុល្លារបន្ថែមពីលើប្រាក់ចំណូលរដ្ឋប្រចាំឆ្នាំពីឆ្នាំ 2012–13 រហូតដល់ឆ្នាំ 2016–17, ជាមួយនឹង ចំនួនតូចក្នុងឆ្នាំ 2011–12, 2017–18, នឹង 2018–19។

**ការចំណាយរបស់រដ្ឋ**

- បើសិនជាយល់ព្រមដោយអ្នកបោះឆ្នោត ប្រាក់ចំណូលបន្ថែមនឹងមានសំរាប់ជួយតុល្យភាពថវិការដ្ឋរហូតដល់ឆ្នាំ 2018–19.
- បើសិនជាត្រូវបដិសេធដោយអ្នកបោះឆ្នោត ថវិកា ឆ្នាំ 2012–13 ត្រូវបន្ថយមកត្រឹម $6 ប្រាំមួយរយកោដិដុល្លារ។ ប្រាក់ចំណូលរដ្ឋទាបរហូតដល់ ឆ្នាំ 2018–19។

**កម្មវិធីរដ្ឋបាលមូលដ្ឋាន**

- ធានាថារដ្ឋបាលមូលដ្ឋានទទួលប្រាក់ពន្ធ ចំណូលប្រចាំឆ្នាំដើម្បីផ្ដល់មូលនិធិដល់កម្មវិធីនានាដែលទទួលខុសត្រូវការផ្ទេរឱ្យគេដោយរដ្ឋក្នុងឆ្នាំ 2011។

# សំណើប្រជាមតិ 30 ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។



## ពន្ធរដ្ឋ និងប្រាក់ចំណូល

### សាវតារ

កញ្ចប់ថវិកាទូទៅគឺជាគណនីប្រតិបត្តិការចម្បងរបស់រដ្ឋ។ ក្នុងឆ្នាំសារពើពន្ធ 2010–11 (ដែលដំណើរការពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2010 ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2011) ប្រាក់ចំណូលសរុបរបស់កញ្ចប់ថវិកាទូទៅគឺ $93 ពាន់លាន។ ប្រភពប្រាក់ចំណូលធំបំផុតទាំងបី របស់កញ្ចប់ថវិកាទូទៅគឺ អត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន ពន្ធលក់ដូរ និងពន្ធប្រាក់ចំណូលរបស់សាជីវកម្ម។

***ពន្ធលក់ដូរ។*** អត្រាពន្ធទំនិញលក់ចេញនៅរដ្ឋកាលីហ្វ័រញ៉ា ខុសៗគ្នាអាស្រ័យទៅតាមមូលដ្ឋាន។ បច្ចុប្បន្ននេះ អត្រាពន្ធទំនិញលក់ចេញជាមធ្យមគឺច្រើនជាង 8 ភាគរយតែប៉ុណ្ណោះ។ មួយភាគនៃប្រាក់ចំណូលពន្ធលក់ដូរចូលទៅក្នុងរដ្ឋ ចំណែកភាគដែលនៅសេសសល់ ត្រូវបានបែងចែកទៅឲ្យរដ្ឋបាលមូលដ្ឋាន។ កញ្ចប់ថវិកាទូទៅរបស់រដ្ឋ បានទទួល $27 ពីរពាន់ប្រាំពីររយកោដិ នៃប្រាក់ចំណូលពន្ធលក់ដូរ ក្នុងអំឡុងឆ្នាំសារពើពន្ធ 2010–11។

***ពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន។*** ពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន (PIT) គឺជាពន្ធទៅលើប្រាក់ឈ្នួល អាជីវកម្ម ការវិនិយោគ និងប្រាក់ចំណូលផ្សេងៗ របស់បុគ្គល និងគ្រួសារ។ អត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនរបស់រដ្ឋ មានលំដាប់ពី 1 ភាគរយ ដល់ 9.3 ភាគរយ ទៅលើភាគនៃប្រាក់ចំណូលរបស់អ្នកជាប់ពន្ធម្នាក់ នៅក្នុងក្រុមនីមួយៗនៃក្រុមប្រាក់ចំណូលជាច្រើន។ (ទាំងនេះសំដៅទៅលើអត្រាពន្ធឯកតាបន្ថែម។) អត្រាពន្ធឯកតាបន្ថែមដែលខ្ពស់ជាងនេះត្រូវបានគិតថ្លៃដូចការបង្កើនប្រាក់ចំណូលដែរ។ ប្រាក់ចំណូលពន្ធដែលបង្កើតចេញពីពន្ធនេះ ដែលចំនួនសរុបគឺ $49.4 បួនពាន់ប្រាំបួនរយបួនកោដិ នៅអំឡុងឆ្នាំសារពើពន្ធ 2010–11 ត្រូវបានដាក់បញ្ចូលចូលក្នុងកញ្ចប់ថវិកាទូទៅរបស់រដ្ឋ។ បន្ថែមពីលើនេះទៀត ពន្ធបន្ថែម 1 ភាគរយទៀត ត្រូវបានអនុវត្តចំពោះប្រាក់ចំណូលប្រចាំឆ្នាំ ដែលលើសពី $1 លាន (ជាមួយនឹងប្រាក់ចំណូលពាក់ព័ន្ធ ដែលបានបរិច្ចាគជូនសេវាសុខភាពផ្លូវចិត្ត)។

## សេចក្ដីស្នើច្បាប់

***ការបង្កើនអត្រាពន្ធទំនិញលក់ចេញចាប់ពីឆ្នាំ 2013 ដល់ 2016។*** វិធានការនេះ បង្កើនអត្រាពន្ធទំនិញលក់ចេញទូទាំងរដ្ឋ ត្រឹមមួយភាគបួនសេនសម្រាប់រាល់មួយដុល្លារនៃទំនិញដែលបានទិញ។ អត្រាពន្ធដែលខ្ពស់ជាងមុននេះ នឹងមានសុពលភាពរយៈពេលបួនឆ្នាំ គឺចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2013 រហូតដល់ចុងឆ្នាំ 2016។

***ការបង្កើនអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនពីឆ្នាំ 2012 ដល់ 2018។*** ដូចដែលបានបង្ហាញនៅក្នុងតារាងទី 2 វិធានការនេះ បង្កើនអត្រាប្រាក់ចំណូលផ្ទាល់ខ្លួន 9.3 ភាគរយបច្ចុប្បន្នទៅលើប្រាក់ចំណូលខ្ពស់ជាងមុន។ អត្រាពន្ធឯកតាបន្ថែម នឹងមានការកើនឡើងនៅពេលប្រាក់ចំណូលជាប់ពន្ធសុទ្ធកើនឡើងដែរ។ ឧទាហរណ៍ សម្រាប់អ្នកប្រកាសពន្ធរួមគ្នា នឹងត្រូវបង់ក្នុងអត្រាពន្ធឯកតាបន្ថែម 1 ភាគរយថែមទៀត ទៅលើប្រាក់ចំណូលចន្លោះពី $500,000 និង $600,000 ក្នុងមួយឆ្នាំ ដែលបង្កើនអត្រាសរុបដល់ 10.3 ភាគរយ។ ស្រដៀងគ្នានេះដែរ នឹងត្រូវបង់ក្នុងអត្រាពន្ធឯកតាបន្ថែម 2 ភាគរយថែមទៀត ទៅលើប្រាក់ចំណូលចន្លោះពី $600,000 និង $1 លាន ហើយនឹងត្រូវបង់ក្នុងអត្រាពន្ធឯកតាបន្ថែម 3 ភាគរយថែមទៀត ទៅលើប្រាក់ចំណូលលើសពី $1 លាន ដែលបង្កើនអត្រាសរុបទៅលើក្រុមប្រាក់ចំណូលទាំងនេះរហូតដល់ 11.3 ភាគរយ និង 12.3 ភាគរយរៀងៗខ្លួន។ អត្រាពន្ធថ្មីទាំងនេះ នឹងប៉ះពាល់ប្រហែល 1 ភាគរយនៃអ្នកប្រកាសពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន របស់រដ្ឋកាលីហ្វ័រញ៉ា។ (បច្ចុប្បន្ននេះ អ្នកជាប់ពន្ធទាំងនេះ បង់ប្រហែល 40 ភាគរយនៃពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនរបស់រដ្ឋ។) អត្រាពន្ធនឹងមានសុពលភាពរយៈពេលប្រាំពីរឆ្នាំ—

**តារាងទី 2**
**អត្រាពន្ធប្រាក់ចំណូលបច្ចុប្បន្ន និងគម្រោងសុំក្រោម សំណើប្រជាមតិ លេខ 30**

| អ្នកបំពេញពន្ធដារម្នាក់ឯង ប្រាក់ចំណូលជាប់ពន្ធ[a] | អ្នកបំពេញពន្ធដាររួមគ្នា ប្រាក់ចំណូលជាប់ពន្ធ[a] | អ្នកបំពេញពន្ធដារជាមេគ្រួសារ ប្រាក់ចំណូលជាប់ពន្ធ[a] | អត្រាពន្ធកំរិតកំណត់បច្ចុប្បន្ន[b] | គម្រោងសុំបន្ថែមនៃអត្រាពន្ធកំរិតកំណត់[b] |
|---|---|---|---|---|
| $0-$7,316 | $0-$14,632 | $0-$14,642 | 1.0% | - |
| 7,316-17,346 | 14,632-34,692 | 14,642-34,692 | 2.0 | - |
| 17,346-27,377 | 34,692-54,754 | 34,692-44,721 | 4.0 | - |
| 27,377-38,004 | 54,754-76,008 | 44,721-55,348 | 6.0 | - |
| 38,004-48,029 | 76,008-96,058 | 55,348-65,376 | 8.0 | - |
| 48,029-250,000 | 96,058-500,000 | 65,376-340,000 | 9.3 | - |
| 250,000-300,000 | 500,000-600,000 | 340,000-408,000 | 9.3 | 1.0% |
| 300,00-500,000 | 600,000-1,000,000 | 408,000-680,000 | 9.3 | 2.0 |
| លើស 500,000 | លើស 1,000,000 | លើស 680,000 | 9.3 | 3.0 |

[a] ឃ្លៀបនៃប្រាក់ចំណូលបានបង្ហាញគឺត្រូវចូលជាធរមាន សំរាប់ឆ្នាំ 2011 និងត្រូវលៃសំរួលសំរាប់អតិផរណា នៅឆ្នាំអនាគត។ អ្នកបំពេញពន្ធដារម្នាក់ឯង រួមទាំង បុគ្គលបានរៀបការ និងដៃគូភេទដូចគ្នាមានចុះឈ្មោះ (RDPS) ដែលបំពេញពន្ធដារប្រចាំឆ្នាំដាច់ដោយឡែក។ អ្នកបំពេញពន្ធដាររួមគ្នា រួមទាំងអ្នកបានរៀបការ និង ដៃគូភេទដូចគ្នា RDP ដែលបំពេញពន្ធដាររួមគ្នា ព្រមទាំងជនពោះម៉ាយ ឬមេម៉ាយដែលមានគុណសម្បត្តិ នឹងកូនក្រោមបន្ទុក។

[b] អត្រាពន្ធកំរិតកំណត់អនុវត្តលើប្រាក់ចំណូល ជាប់ពន្ធក្នុងឃ្លៀបពន្ធដារដែលមានរាយ ឈ្មោះ។ គម្រោងសុំអត្រាពន្ធបន្ថែមនឹងត្រូវ ចូលជាធរមានចាប់ផ្ដើមក្នុងឆ្នាំ 2012 ហើយ ត្រូវចប់នៅឆ្នាំ 2018។ អត្រាពន្ធបច្ចុប្បន្នដែល មានរាយនោះមិនមានបញ្ចូលអត្រាពន្ធសំរាប់ សុខភាពផ្លូវចិត្ត នៃ 1 ភាគរយសំរាប់ប្រាក់ ចំណូលជាប់ពន្ធដែលលើសពី $1លាន ដុល្លារ។

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 30, សូមអានទំព័រ 80។*

សំណើប្រជាមតិ

# 30 ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

ដោយចាប់ផ្ដើមពីឆ្នាំពន្ធ 2012 និងបញ្ចប់នៅពេលបុកសរុបឆ្នាំពន្ធ 2018។ (ដោយសារតែការបង្កើនអត្រានឹងត្រូវបានអនុវត្តចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2012 នោះ អ្នកជាប់ពន្ធដែលរងការប៉ះពាល់ ទំនងជានឹងត្រូវបង់ច្រើនជាងមុន នៅខែខាងមុខ ដើម្បីទូទាត់ផលប៉ះពាល់ពេញមួយឆ្នាំនៃការបង្កើនអត្រា។) អត្រា 1 ភាគរយបន្ថែមសម្រាប់សេវាសុខភាពផ្លូវចិត្ត នឹងនៅតែត្រូវបានអនុវត្តចំពោះប្រាក់ចំណូលដែលលើសពី $1 លាន ដដែល។ ដូច្នេះ ការផ្លាស់ប្ដូរអត្រារបស់សំណើប្រជាមតិលេខ 30 នឹងបង្កើនអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនលើឯកតាបន្ថែម របស់អ្នកជាប់ពន្ធទាំងនេះចាប់ពី 10.3 ភាគរយ ដល់ 13.3 ភាគរយ។ សំណើប្រជាមតិលេខ 38 អំពីសន្លឹកឆ្នោតនេះ ក៏នឹងបង្កើនអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនផងដែរ។ ប្រអប់ដែលនៅជិត បរិយាយអំពីអ្វីដែលនឹងកើតឡើង ប្រសិនបើវិធានការទាំងពីរត្រូវបានយល់ព្រម។

**តើមានអ្វីកើតឡើងបើ អ្នកបោះឆ្នោតយល់ព្រមលើសំណើប្រជាមតិទាំងពីរ 30 សំណើប្រជាមតិ 38?**

***រដ្ឋធម្មនុញ្ញរដ្ឋបញ្ជាក់នូវអ្វីនឹងកើតឡើងបើមានវិធានការពីរចំរូងចំរាស់។*** បើខមាត្រាទាំងឡាយនៃវិធានការពីរត្រូវបានយល់ព្រមនៅក្នុងសន្លឹកឆ្នោតទូទាំងរដ្ឋ រដ្ឋធម្មនុញ្ញបញ្ជាក់ថាខមាត្រានៃវិធានការណាដែលទទួលការគាំទ្រ "បាទ/ចាស" ពីអ្នកបោះឆ្នោតច្រើនជាងគេឈ្នះ។

សំណើប្រជាមតិ 30 និង សំណើប្រជាមតិ 38 នៅក្នុងសន្លឹកឆ្នោតទូទាំងរដ្ឋនេះ ទាំងពីរនេះតំឡើងអត្រាពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន (PIT) ហើយ ដូចយ៉ាងនេះហើយ វាអាចពិនិត្យបានថាមានភាពចំរូងចំរាសគ្នា។

***វិធានការរដ្ឋដែលការតំឡើងពន្ធដារតែមួយផ្នែកចូលជាធរមាន។*** សំណើប្រជាមតិ 30 នឹង សំណើប្រជាមតិ 38 ទាំងពីរនេះមានវគ្គមួយចំនួនមានបំណងដោបញ្ជាក់ឱ្យច្បាស់លាស់ថាតើខមាត្រាមួយណាដែលនឹងចូលជាធរមាន បើសិនជាវិធានការទាំងពីរត្រូវឈ្នះ

- ***បើសិនជា សំណើប្រជាមតិ 30 ទទួលសន្លឹកឆ្នោត បាទ/ចាស ច្រើនជាង។*** សំណើប្រជាមតិ 30 មានវគ្គមួយបង្ហាញថាខមាត្រារបស់វាអាចឈ្នះទាំងអស់ ហើយគ្មានខមាត្រាណាមួយនៃវិធានការដ៏ទៃទៀតតំឡើងអត្រាពន្ធដារផ្ទាល់ខ្លួន PIT—នៅក្នុងករណីនេះ សំណើប្រជាមតិ 38—នឹងចូលជាធរមាន។
- ***បើសិនជា សំណើប្រជាមតិ 38 ទទួលសន្លឹកឆ្នោត បាទ/ចាស ច្រើនជាង។*** សំណើប្រជាមតិ 38 មានវគ្គមួយបង្ហាញថាខ មាត្រារបស់វាអាចឈ្នះ ហើយខមាត្រានៃអត្រាពន្ធនៃវិធានការដ៏ទៃទៀតបោះពាល់ដល់ការលក់ដូរ ឬអត្រាពន្ធ PIT—នៅក្នុងករណីនេះ សំណើប្រជាមតិ 30—នឹងមិនចូលជាធរមានទេ។ ក្រោមឆាករបៀបនេះ ការកាត់បន្ថយចំណាយដែលគេស្គាល់ថា "ការកាត់ឆ្លើយតបតាមហេតុការណ៍" នឹងចូលជាធរមានជាលទ្ធផលមកពីកំណើនពន្ធដារនៃសំណើប្រជាមតិ30 មិនចូលជាធរមាន។

### ការប៉ះពាល់សារពើពន្ធ

***ប្រាក់ចំណូលរដ្ឋបន្ថែមរហូតដល់ឆ្នាំ 2018–19។*** *ក្នុងឆ្នាំសារពើពន្ធប្រាំឆ្នាំកន្លងមក* ដែលការបង្កើនពន្ធទំនិញលក់ចេញ និងពន្ធប្រាក់ចំណូលផ្ទាល់ខ្លួននឹងមានសុពលភាព (2012–13 ដល់ 2016–17), កំណើនប្រាក់ចំណូលរដ្ឋប្រចាំឆ្នាំ ដែលបណ្ដាលមកពីការបង្កើនពន្ធរបស់វិធានការនេះ ត្រូវបានប៉ាន់ស្មានថាមានចំនួន ប្រហែល $6 ប្រាំមួយរយកោដិ។ ទំនងជាមានការកើនប្រាក់ចំណូលតិចជាងនេះនៅក្នុងឆ្នាំសារពើពន្ធ 2011–12, 2017–18 និងឆ្នាំ 2018–19 ដោយសារការអនុវត្តបន្តិចម្ដងៗ និងការធ្វើឲ្យ លែងមានបន្តិចម្ដងៗនៃអត្រាពន្ធខ្ពស់ជាងមុន។

(ត)

***ប្រាក់ចំណូលអាចមានការផ្លាស់ប្ដូរច្រើនពីមួយឆ្នាំទៅមួយឆ្នាំ។*** ប្រាក់ចំណូលដែលបង្កើនដោយវិធានការនេះ អាចស្ថិតនៅក្រោមចំនួនផ្លាស់ប្ដូរពហុរយកោដិដុល្លារ ដែលអាចច្រើនជាង ឬតិចជាងប្រាក់ចំណូលដែលបានគន់គូរខាងលើ។ នេះគឺដោយសារតែភាគច្រើននៃប្រាក់ចំណូលបន្ថែមដែលបានពីវិធានការនេះ នឹងបានមកពីការបង្កើនអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនទៅលើអ្នកជាប់ពន្ធប្រាក់ចំណូលកម្រិតខ្ពស់។ ប្រាក់ចំណូលភាគច្រើន ដែលត្រូវបានរាយការណ៍ដោយអ្នកជាប់ពន្ធប្រាក់ចំណូលកម្រិតខ្ពស់ មានការពាក់ព័ន្ធខ្លះទៅនឹងការវិនិយោគ និងអាជីវកម្មរបស់ពួកគេ ជាជាងប្រាក់ឈ្នួល និងប្រាក់បៀវត្ស។ ខណៈប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍សម្រាប់អ្នកជាប់ពន្ធប្រាក់ចំណូលកម្រិតខ្ពស់ ប្រែប្រួលក្នុងកម្រិតខ្លះ ប្រាក់ចំណូលនៃការវិនិយោគរបស់ពួកគេ អាចផ្លាស់ប្ដូរយ៉ាងច្រើនពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យលើការអនុវត្តនៃផ្សារសន្លឹកហ៊ុន តម្លៃផ្ទះសំបែង និងសេដ្ឋកិច្ច។ ឧទាហរណ៍ ពន្ធសុខភាពផ្លូវចិត្តបច្ចុប្បន្នទៅលើប្រាក់ចំណូលលើសពី $1 លាន បានបង្កើតប្រហែល $730 លាន នៅឆ្នាំ 2009–10 ប៉ុន្តែកើនឡើងទ្វេដងច្រើនជាងចំនួនប្រាក់ក្នុងឆ្នាំមុនៗ។ ដោយសារចំនួនប្រែប្រួលនៃប្រាក់ចំណូលរបស់អ្នកជាប់ពន្ធទាំងនេះ និងភាពមិនច្បាស់លាស់នៃការឆ្លើយតបរបស់ពួកគេទៅនឹងការបង្កើនអត្រានោះ ប្រាក់ចំណូលដែលបង្កើនដោយវិធានការនេះ មានការពិបាកក្នុងការប៉ាន់ស្មាន។

## ការចំណាយរបស់រដ្ឋ

### សារតារ

***ថវិកាទូទៅរបស់រដ្ឋឧបត្ថម្ភដល់កម្មវិធីជាច្រើន។*** ប្រាក់ចំណូលដែលត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិកាទូទៅ បានគាំទ្រដល់កម្មវិធីជាច្រើន រួមមានសាលារៀនរដ្ឋ សាកលវិទ្យាល័យរដ្ឋ កម្មវិធីសុខភាព សេវាសង្គមកិច្ចនិងពន្ធនាគារ។ ការចំណាយទៅលើសាលារៀន គឺជាផ្នែកដ៏ធំជាងគេនៃគំរោងថវិការបស់រដ្ឋ។ សំណើប្រជាមតិមុនៗ ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតរបស់រដ្ឋ តម្រូវឲ្យរដ្ឋផ្ដល់នូវចំនួនប្រាក់ប្រចាំឆ្នាំជាអប្បបរមា ដែលហៅជារួមថា ការធានាជាអប្បបរមានៃសំណើប្រជាមតិលេខ 98 សម្រាប់សាលារៀន (មត្តេយ្យសិក្សារហូតដល់វិទ្យាល័យ) និងមហាវិទ្យាល័យសហគមន៍ (ជារួមហៅថា ការអប់រំកម្រិត K–14)។ ការធានាជាអប្បបរមា ត្រូវបានផ្ដល់ថវិកាតាមរយៈការបូកបញ្ចូលគ្នានូវកញ្ចប់ថវិកាទូទៅរបស់រដ្ឋ និងប្រាក់ចំណូលពន្ធលើទ្រព្យសម្បត្តិមូលដ្ឋាន។ ក្នុងរយៈពេលជាច្រើនឆ្នាំ ការគណនារកការធានាជាអប្បបរមាមានលក្ខណៈរសើបខ្ពស់ចំពោះការផ្លាស់ប្ដូរប្រាក់ចំណូលកញ្ចប់ថវិកាទូទៅរបស់រដ្ឋ។ ក្នុងបណ្ដាឆ្នាំទាំងឡាយ នៅពេលដែលប្រាក់ចំណូលកញ្ចប់ថវិកាទូទៅ កើនឡើងក្នុងចំនួនច្រើនការធានា ក៏ទំនងជាមានការកើនឡើងក្នុងចំនួនខ្ពស់ដែរ។ ការចែករំលែកមួយភាគធំនៃការផ្ដល់ថវិការបស់រដ្ឋ និងក្នុងមូលដ្ឋានដែលត្រូវបានបែងចែកទៅឲ្យសាលារៀន និងមហាវិទ្យាល័យសហគមន៍គឺ "ពុំមានលក្ខខណ្ឌទេ" មានន័យថា ពួកគេអាចប្រើថវិកាសម្រាប់គោលបំណងអប់រំណាមួយក៏បាន។

### សំណើច្បាប់

***ប្រាក់ចំណូលពន្ធថ្មីដែលមានលទ្ធភាពផ្ដល់ថវិកាដល់សាលារៀន និងជួយ ធ្វើឲ្យមានតុល្យភាពគំរោងថវិកា។*** ប្រាក់ចំណូលដែលបង្កើតដោយការបង្កើនពន្ធបណ្ដោះអាសន្នរបស់វិធានការ នឹងត្រូវដាក់បញ្ចូលទៅក្នុងការគណនារកការធានាជាអប្បបរមានៃសំណើប្រជាមតិលេខ 98 ដោយបង្កើនការធានារាប់រយកោដិដុល្លារជារៀងរាល់ឆ្នាំ។ ដូច្នេះ មួយភាគនៃប្រាក់ចំណូលថ្មី នឹងត្រូវបានប្រើសម្រាប់គាំទ្រការផ្ដល់ថវិកាដល់សាលារៀនខ្ពស់ជាងមុន ជាមួយនឹងភាគដែលនៅសេសសល់ជួយ ធ្វើឲ្យមានតុល្យភាពគំរោងថវិកា

សំណើប្រជាមតិ
# 30 ពន្ធបណ្តោះអាសន្ន សំរាប់ផ្តល់ថវិកា ការអប់រំ។ ការផ្តល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ។



របស់រដ្ឋ។ តាមទស្សនៈគណនេយ្យ ប្រាក់ចំណូលថ្មីនឹងត្រូវបញ្ចូលទៅក្នុងគណនីរដ្ឋដែលទើបបង្កើតថ្មី ដែលមានឈ្មោះថា គណនីការពារវិស័យអប់រំ (EPA)។ ក្នុងចំណោមថវិកានៅក្នុងគណនី 89 ភាគរយ នឹងត្រូវបានផ្តល់ទៅឲ្យសាលារៀន ហើយ 11 ភាគរយទៀត ត្រូវបានផ្តល់ទៅឲ្យមហាវិទ្យាល័យសហគមន៍។ សាលារៀន និងមហាវិទ្យាល័យសហគមន៍ អាចប្រើថវិកាទាំងនេះសម្រាប់គោលបំណងអប់រំណាមួយក៏បាន។ ថវិកានឹងត្រូវបានចែកចាយក្នុងលក្ខណៈដូចគ្នាទៅនឹងការផ្តល់ថវិកាដល់សិស្សម្នាក់ ដោយគ្មានលក្ខខណ្ឌ សម្រាប់ពេលបច្ចុប្បន្ន លើកលែងតែគ្មានការិយាល័យអប់រំស្រុកណាមួយ នឹងទទួលបានតិចជាង $200 នៅក្នុងថវិកា EPA សម្រាប់សិស្សម្នាក់ ហើយគ្មានមហាវិទ្យាល័យសហគមន៍ក្នុងស្រុកណាមួយ នឹងទទួលបានតិចជាង $100 នៅក្នុងថវិកា EPA សម្រាប់និស្សិតពេញម៉ោងម្នាក់។

## ឥទ្ធិពលសារពើពន្ធ បើវិធានការត្រូវបានយល់ព្រម

***គំរោងថវិកាឆ្នាំ 2012–13 ពឹងផ្អែកលើការអនុម័តរបស់អ្នកបោះឆ្នោតទៅលើវិធានការនេះ។*** អង្គនីតិបញ្ញត្តិ និងអភិបាលបានអនុម័តគំរោងថវិកនៅខែមិថុនា ដើម្បីដោះស្រាយឱនភាពគំរោងថវិកាដែលបានគន់គូរត្រឹមត្រូវសម្រាប់ឆ្នាំសារពើពន្ធ 2012–13 ក៏ដូចជាឱនភាពថវិកាដែលបានគន់គូរសម្រាប់ឆ្នាំទាំងឡាយក្នុងពេលអនាគត។ គំរោងថវិកាឆ្នាំ 2012–13 (1) សន្មត់ថា អ្នកបោះឆ្នោតយល់ព្រមលើវិធានការនេះ និង (2) ចំណាយប្រាក់ចំណូលដែលផ្តល់ផលទៅលើកម្មវិធីរដ្ឋជាច្រើន។ ការចែករំលែកមួយភាគធំនៃប្រាក់ចំណូលដែលត្រូវបានបង្កើតដោយវិធានការនេះ ត្រូវបានចំណាយទៅលើសាលារៀន និងមហាវិទ្យាល័យសហគមន៍។ ការនេះ ជួយពន្យល់បកស្រាយអំពីកំណើនយ៉ាងច្រើននៃការផ្តល់ថវិកាសម្រាប់សាលារៀន និងមហាវិទ្យាល័យ សហគមន៍ក្នុងឆ្នាំ 2012–13 ដែលមានកំណើនចំនួន $6.6 ប្រាំមួយរយកោដិប្រាំមួយលានដុល្លារ (14 ភាគរយ) ក្នុងឆ្នាំ 2011–12។ ស្ទើរតែទាំងអស់នៃកំណើននេះ ត្រូវបានប្រើសម្រាប់ទូទាត់ចំណាយរបស់ K–14 ពីឆ្នាំមុន និងកាត់បន្ថយភាពយឺតយ៉ាវនៅក្នុងការទូទាត់មួយចំនួននៃ K–14 របស់រដ្ឋ។ ដរាបណាមានឱនភាពគំរោងថវិកាដែលបានគន់គូរច្រើន គំរោងថវិកាក៏ដាក់បញ្ចូលវិធានការទាំងឡាយ ដើម្បីទប់ទល់នឹងចំណាយនៅក្នុងកម្មវិធីសេវាសុខាភិបាល និងសង្គមកិច្ច កាត់បន្ថយសំណងទៅឲ្យនិយោជិករបស់រដ្ឋ ប្រើថវិកាតែមួយលើក និងខ្ចីពីគណនីដទៃទៀតរបស់រដ្ឋផងដែរ។

***ផលប៉ះពាល់ទៅលើគំរោងថវិកាហូតដល់ឆ្នាំ 2018–19។*** ប្រាក់ចំណូលពន្ធបន្ថែមរបស់វិធានការនេះ នឹងមានលទ្ធភាពប្រើប្រាស់ សម្រាប់ជួយធ្វើឲ្យមានតុល្យភាពគំរោងថវិការបស់រដ្ឋហូតដល់ឆ្នាំ 2018–19។ ប្រាក់ចំណូលបន្ថែមពីវិធានការនេះ ផ្តល់ថវិកាជាច្រើនពាន់ដុល្លារក្នុងមួយឆ្នាំ រហូតដល់ឆ្នាំ 2018–19 ដែលនឹងមានលទ្ធភាពអាចប្រើប្រាស់សម្រាប់គោលបំណងជាច្រើន រួមមាន ការផ្តល់ថវិកាដល់កម្មវិធីដែលមានស្រាប់របស់រដ្ឋ ការបញ្ចប់ភាពយឺតយ៉ាវក្នុងការទូទាត់របស់ការអប់រំកម្រិតK–14 និងការទូទាត់បំណុលផ្សេងៗរបស់រដ្ឋ។ វិធានការនាពេលអនាគតរបស់អង្គនីតិបញ្ញត្តិ និងអភិបាលនឹងកំណត់អំពីការប្រើប្រាស់ថវិកាទាំងនេះ។ ស្របពេលជាមួយគ្នានេះដែរ ដោយសារមានចំនួនប្រែប្រួលនៃអ្នកជាប់ពន្ធប្រាក់ចំណូលកម្រិតខ្ពស់ ភាពប្រែប្រួលប្រាក់ចំណូលរដ្ឋ ដែលមានសក្តានុពលក្រោមវិធានការនេះ អាចធ្វើឲ្យការគ្រោងថវិការបស់រដ្ឋមានភាពស្មុគស្មាញក្នុងឆ្នាំខ្លះ។ ក្រោយពីការបង្កើនពន្ធដែលបានស្នើផុតកំណត់ ការខាតប្រាក់ចំណូលពន្ធដែលពាក់ព័ន្ធអាចបង្កើតសម្ពាធគំរោងថវិកាបន្ថែមទៀតនៅក្នុងឆ្នាំបន្តបន្ទាប់។

## ឥទ្ធិពលសារពើពន្ធ បើវិធានការត្រូវបានបដិសេធ

***គំរោងថវិកាបំរុងកាត់បន្ថយការចំណាយ ប្រសិនបើអ្នកបោះឆ្នោតបដិសេធវិធានការនេះ។*** ប្រសិនបើវិធានការនេះបរាជ័យ រដ្ឋនឹងមិនទទួលបានប្រាក់ចំណូលបន្ថែម ដែលបានបង្កើតដោយការបង្កើនពន្ធរបស់សំណើប្រជាមតិឡើយ។ ក្នុងស្ថានភាពនេះ គំរោងថវិកាឆ្នាំ 2012–13 តម្រូវឲ្យការចំណាយរបស់ខ្លួនកាត់បន្ថយមកនៅត្រឹម $6 ប្រាំមួយរយកោដិ។ ការកាត់ឆ្លើយតបតាមហេតុការណ៍ទាំងនេះ ដូចដែលបានគ្រោងនៅក្នុងច្បាប់រដ្ឋបច្ចុប្បន្ន មានបង្ហាញនៅក្នុងតារាងទី 3។ ការកាត់បន្ថយស្ទើរតែទាំងអស់ ត្រូវបានផ្តល់ទៅឲ្យកម្មវិធីអប់រំ ដែលក្នុងនោះ $5.4 ប្រាំរយកោដិបួនលាន ត្រូវបានផ្តល់ទៅឲ្យការអប់រំកម្រិត K–14 និង $500 លាន ទៅឲ្យសាកលវិទ្យាល័យរដ្ឋ។ ក្នុងចំណោមការកាត់បន្ថយរបស់កម្រិតសិក្សា K–14 ប្រហែល $3 ប៊ីរយកោដិ គឺជាការកាត់នៅក្នុងការផ្តល់ថវិកាដែលគ្មានលក្ខខណ្ឌ។ សាលារៀន និងមហាវិទ្យាល័យសហគមន៍ អាចឆ្លើយតបទៅនឹងការកាត់នេះតាមវិធីជាច្រើន រួមមាន ប្រើការដកថវិកាបំរុងទុក ការធ្វើឲ្យឆ្នាំសិក្សាសម្រាប់សាលារៀនកាន់តែខ្លី និងការកាត់បន្ថយការចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យសហគមន៍។ ការកាត់បន្ថយដែលនៅសេសសល់ចំនួន $2.4 ពីររយកោដិបួនលានដុល្លារ នឹងបង្កើនចំនួននៃការទូទាត់យឺតយ៉ាវទៅឲ្យសាលារៀន និងមហាវិទ្យាល័យសហគមន៍ ត្រឡប់ទៅកម្រិតឆ្នាំ 2011–12 វិញ។ ការនេះ អាចប៉ះពាល់ដល់តម្រូវការសាច់ប្រាក់របស់សាលារៀន និង មហាវិទ្យាល័យសហគមន៍ ធ្វើឲ្យមានភាពយឺតយ៉ាវនៅក្នុងឆ្នាំសារពើពន្ធ ដែលជាសក្តានុពលបណ្តាលឲ្យមានកម្ចីរយៈពេលខ្លីកាន់តែច្រើនឡើង។

***ផលប៉ះពាល់ទៅលើគំរោងថវិកាហូតដល់ឆ្នាំ 2018–19។*** ប្រសិនបើវិធានការនេះត្រូវបានបដិសេធដោយអ្នកបោះឆ្នោត ប្រាក់ចំណូលរបស់រដ្ឋនឹងធ្លាក់ចុះរាប់រយកោដិដុល្លារជារៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ 2018–19 ទាបជាងការយល់ព្រមលើវិធានការនេះ។ វិធានការនាពេលអនាគតរបស់អង្គនីតិបញ្ញត្តិ និងអភិបាលរដ្ឋ នឹងកំណត់អំពីរបៀបធ្វើឲ្យមានតុល្យភាពគំរោងថវិការបស់រដ្ឋ ទៅតាមប្រាក់ចំណូលដែលមានកម្រិតទាបជាងមុននេះ។ គំរោងថវិកាពេលអនាគតរបស់រដ្ឋ អាចធ្វើឲ្យមានតុល្យភាពបានតាមរយៈការកាត់ទៅឲ្យសាលារៀន ឬកម្មវិធីផ្សេងៗ ប្រាក់ចំណូលថ្មី និងវិធានការតែមួយលើក។

### តារាងទី 3
### ការកាត់បន្ថយការចំណាយឆ្នាំ 2012–13 បើសិនជាអ្នកបោះឆ្នោតបដិសេធសំណើប្រជាមតិលេខ 30

*(គិតជាលានដុល្លារ)*

| | |
|---|---|
| សាលា និង មហាវិទ្យាល័យសហគមន៍ | $5,354 |
| សកលវិទ្យាល័យកាលីហ្វ័រញ៉ា | 250 |
| សកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា | 250 |
| ក្រសួងអភិវឌ្ឍន៍សេវាកម្ម | 50 |
| មូលនិធិក្រសួងប៉ូលិសក្រុង | 20 |
| CalFire | 10 |
| កម្មវិធីគ្រួតត្រាទឹកជំនន់ DWR | 7 |
| មូលនិធិល្បាតមើលសុវត្ថិភាពទឹក | 5 |
| ក្រសួងមច្ឆាជាតិ នឹងប្រមាញ់ | 4 |
| ក្រសួងឧទ្យាននឹងការកំសាន្ត | 2 |
| កម្មវិធីអាជ្ញាធរមានសមត្ថកិច្ច DOJ | 1 |
| **សរុប** | **$5,951** |

DWR = ក្រសួងធនធាន DOJ = ក្រសួងយុត្តិធ

សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 30, សូមអានទំព័រ ៨០។

# ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** (ត)

## កម្មវិធីនានាតាមរដ្ឋបាលមូលដ្ឋាន

### សាវតារ

នៅឆ្នាំ 2011 រដ្ឋបានផ្ទេរការទទួលខុសត្រូវចំពោះការគ្រប់គ្រងរដ្ឋបាលនិងការផ្ដល់ថវិកាដល់កម្មវិធីជាច្រើនដល់រដ្ឋបាលមូលដ្ឋាន (ជាដំបូងទៅឲ្យខោនធី)។ ការទទួលខុសត្រូវរបស់កម្មវិធីដែលបានផ្ទេរ រួមមាន ការឃុំខ្លួនជនល្មើសជាមនុស្សពេញវ័យមួយចំនួន ការត្រួតពិនិត្យអ្នកដែលត្រូវបានដោះលែងបណ្ដោះអាសន្ន និងការផ្ដល់សេវាព្យាបាលអ្នកសេពគ្រឿងញៀន។ ដើម្បីទូទាត់សម្រាប់កាតព្វកិច្ចថ្មីៗទាំងនេះ អង្គនីតិបញ្ញត្តិបានអនុម័តច្បាប់មួយ ដែលផ្ទេរប្រហែល $6 ប្រាំមួយរយកោដិដុល្លារ នៃប្រាក់ចំណូលពន្ធរបស់រដ្ឋទៅឲ្យរដ្ឋបាលមូលដ្ឋានក្នុងមួយឆ្នាំ។ ភាគច្រើននៃថវិកាទាំងនេះ បានមកពីការបង្វែរមួយភាគនៃពន្ធទំនិញលក់ចេញ ពីរដ្ឋទៅឲ្យរដ្ឋបាលមូលដ្ឋាន។

### សំណើច្បាប់

វិធានការនេះ បានដាក់បញ្ចូលទៅក្នុងធម្មនុញ្ញនូវខចែងមួយចំនួន ដែលពាក់ព័ន្ធនឹងការផ្ទេរការទទួលខុសត្រូវនៃកម្មវិធីរបស់រដ្ឋក្នុងឆ្នាំ 2011។

***ការធានាប្រាក់ចំណូលជាហូរហៃទៅឲ្យរដ្ឋបាលមូលដ្ឋាន។*** វិធានការនេះ តម្រូវឲ្យរដ្ឋបន្តផ្ដល់ប្រាក់ចំណូលពន្ធដែលបានប្ដូរទិសដៅក្នុងឆ្នាំ 2011 (ឬថវិកាសមមូល) ទៅឲ្យរដ្ឋបាលមូលដ្ឋាន ដើម្បីទូទាត់សម្រាប់ការទទួលខុសត្រូវនៃកម្មវិធីដែលបានផ្ទេរ។ វិធានការនេះ ក៏ដកជាអចិន្ត្រៃយ៍នូវប្រាក់ចំណូលពន្ធទំនិញលក់ចេញ ដែលបានប្ដូរទិសដៅទៅឲ្យរដ្ឋបាលមូលដ្ឋាន ចេញពីការគណនារកការធានាការផ្ដល់ថវិកាជាអប្បបរមាសម្រាប់សាលារៀន និងមហាវិទ្យាល័យសហគមន៍ផងដែរ។

***ការរឹតត្បិតដល់អាជ្ញាធររដ្ឋក្នុងការពង្រីកលក្ខខណ្ឌតម្រូវរបស់កម្មវិធី។*** រដ្ឋបាលមូលដ្ឋាន នឹងមិនត្រូវបានតម្រូវឲ្យអនុវត្តច្បាប់រដ្ឋនាពេលអនាគតណាមួយ ដែលបង្កើនខ្ទង់ចំណាយរបស់មូលដ្ឋាន ក្នុងការគ្រប់គ្រងការទទួលខុសត្រូវរបស់កម្មវិធី ដែលបានផ្ទេរនៅក្នុងឆ្នាំ 2011 ឡើយ លុះត្រាណាតែរដ្ឋបានផ្ដល់ប្រាក់បន្ថែម ដើម្បីទូទាត់សម្រាប់ខ្ទង់ចំណាយដែលកើនឡើងប៉ុណ្ណោះ។

***ការតម្រូវឲ្យរដ្ឋចែករំលែកខ្ទង់ចំណាយកម្មវិធី ដែលមិនបានព្រៀងទុកខ្លះ។*** វិធានការនេះ តម្រូវឲ្យរដ្ឋទូទាត់ផ្នែកនៃខ្ទង់ចំណាយថ្មីណាមួយរបស់មូលដ្ឋាន ដែលជាលទ្ធផលនៃបណ្ដឹងមួយចំនួន និងការផ្លាស់ប្ដូរលក្ខន្តិកៈឬបទបញ្ជារបស់សហព័ន្ធ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវនៃកម្មវិធីដែលបានផ្ទេរ។

***ការលុបចោលការទទួលខុសត្រូវផ្ដល់ថវិកាមានសិទ្ធិជាសក្ដានុពល។*** ក្រោមធម្មនុញ្ញ រដ្ឋត្រូវសងដល់រដ្ឋបាលមូលដ្ឋានវិញ នៅពេលខ្លួនដាក់ការទទួលខុសត្រូវ ឬ "សិទ្ធិ" ថ្មី ទៅឲ្យពួកគេ។ ក្រោមច្បាប់បច្ចុប្បន្ន រដ្ឋអាចត្រូវបានតម្រូវឲ្យផ្ដល់ជូនរដ្ឋបាលមូលដ្ឋាន នូវថវិកាបន្ថែម (សំណងមានសិទ្ធិ) ដើម្បីទូទាត់សម្រាប់ការទទួលខុសត្រូវនៃកម្មវិធីដែលបានផ្ទេរ។ វិធានការនេះ បញ្ជាក់លម្អិតថា រដ្ឋនឹងមិនត្រូវបានតម្រូវឲ្យផ្ដល់សំណងមានអាណត្តិទាំងនេះទេ។

***បញ្ឈប់ការផ្ដល់សំណងចំពោះចំណាយនៃច្បាប់ប្រជុំដោយបើកចំហ។*** ច្បាប់ Ralph M. Brown តម្រូវឲ្យរាល់ការប្រជុំទាំងអស់របស់អង្គនីតិបញ្ញត្តិក្នុងមូលដ្ឋាន ត្រូវមានលក្ខណៈបើកចំហជាសាធារណៈ។ កន្លងមក រដ្ឋបានផ្ដល់សំណងជូនរដ្ឋបាលមូលដ្ឋាន សម្រាប់ខ្ទង់ចំណាយដែលបណ្ដាលមកពីខចែងមួយចំនួននៃច្បាប់ Brown (ដូចជា ការតម្រូវឲ្យរៀបចំ និងប្រកាសផ្សាយរបៀបវារៈសម្រាប់ការប្រជុំជាសាធារណៈជាដើម)។ វិធានការនេះ បញ្ជាក់លម្អិតថា រដ្ឋនឹងមិនត្រូវទទួលខុសត្រូវចំពោះការទូទាត់ជូនភ្នាក់ងារក្នុងមូលដ្ឋាន ចំពោះចំណាយទាំងឡាយណាដែលគោរពតាមនីតិវិធីប្រជុំដោយបើកចំហ នៅក្នុងច្បាប់ Brown ឡើយ។

# ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** (ត)

## ការប៉ះពាល់សារពើពន្ធ

***រដ្ឋាភិបាលរដ្ឋ។*** ខ្ទង់ចំណាយរបស់រដ្ឋ ចំពោះកម្មវិធីដែលបានផ្ទេរអាចខ្ពស់ជាងមុន ពីព្រោះវិធានការនេះ (1) ធានាថា រដ្ឋនឹងបន្តផ្ដល់ថវិកាជូនរដ្ឋបាលមូលដ្ឋាន ដើម្បីទូទាត់ជូនពួកគេ (2) តម្រូវឲ្យរដ្ឋចែករំលែកផ្នែកនៃខ្ទង់ចំណាយទាំងឡាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្ដូរច្បាប់សហព័ន្ធ និងរឿងក្ដីនាពេលអនាគត និង (3) អនុញ្ញាតឲ្យរដ្ឋបាលមូលដ្ឋាន បដិសេធមិនអនុវត្តច្បាប់ និងបទបញ្ជាថ្មីរបស់រដ្ឋ ដែលបង្កើនខ្ទង់ចំណាយរបស់ខ្លួន លុះត្រាណាតែរដ្ឋផ្ដល់ថវិកាបន្ថែមទៀត។ ខ្ទង់ចំណាយជាសក្ដានុពលនេះ នឹងប៉ះប៉ូវវិញដោយផ្នែក តាមរយៈខចែងទាំងឡាយរបស់វិធានការ ដោយលុបបំបាត់បំណុលមានសិទ្ធិរបស់រដ្ឋ ដែលមានសក្ដានុពលណាមួយ ចេញពីការផ្ទេរកម្មវិធីឆ្នាំ 2011 និងនីតិវិធីនៃច្បាប់ Brown។ ផលប៉ះពាល់សារពើពន្ធសរុបនៃខចែងទាំងនេះ មិនអាចកំណត់បានឡើយ ហើយនឹងអាស្រ័យទៅលើវិធានការនាពេលអនាគត ដោយមន្ត្រីជាប់ឆ្នោត និងតុលាការ។

***រដ្ឋបាលមូលដ្ឋាន។*** កត្តាទាំងឡាយដែលបានពិភាក្សាខាងលើ នឹងមានផលប៉ះពាល់សារពើពន្ធទៅលើរដ្ឋបាលមូលដ្ឋាន។ នេះមានន័យថា ប្រាក់ចំណូលរបស់រដ្ឋបាលមូលដ្ឋាន អាចខ្ពស់ជាងមុន ពីព្រោះរដ្ឋនឹងត្រូវបានតម្រូវឲ្យ (1) បន្តផ្ដល់ថវិកាជូនរដ្ឋបាលមូលដ្ឋាន ដើម្បីទូទាត់ការទទួលខុសត្រូវនៃកម្មវិធីដែលបានផ្ទេរនៅឆ្នាំ 2011 និង (2) ទូទាត់ទាំងអស់ ឬដោយផ្នែកនៃខ្ទង់ចំណាយទាំងឡាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្ដូរច្បាប់សហព័ន្ធ និងរដ្ឋ និងរឿងក្ដីនាពេលអនាគត។ ប្រាក់ចំណូលរបស់មូលដ្ឋានដែលកើនឡើងទាំងនេះ នឹងប៉ះប៉ូវវិញដោយផ្នែកតាមរយៈខចែងទាំងឡាយរបស់វិធានការ ដោយលុបបំបាត់អំណាចរបស់រដ្ឋបាលមូលដ្ឋាន ក្នុងការទទួលសំណងមានសិទ្ធិ សម្រាប់ការបង្វែរកម្មវិធីឆ្នាំ 2011 និងនីតិវិធីនៃច្បាប់ Brown។ ផលប៉ះពាល់សារពើពន្ធសរុបនៃខចែងទាំងនេះ មិនអាចកំណត់បានឡើយ ហើយនឹងអាស្រ័យទៅលើវិធានការនាពេលអនាគត ដោយមន្ត្រីជាប់ឆ្នោត និងតុលាការ។

## សេចក្ដីសង្ខេប

ប្រសិនបើអ្នកបោះឆ្នោតយល់ព្រមលើវិធានការនេះ អត្រាពន្ធទំនិញលក់ចេញរបស់រដ្ឋ នឹងកើនឡើងរយៈពេលបួនឆ្នាំ ហើយអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន នឹងកើនឡើងប្រាំពីរឆ្នាំ ដែលជាមធ្យមបង្កើតបានប្រាក់ចំណូលបន្ថែមរបស់រដ្ឋប្រមាណ $6 ប្រាំមួយរយកោដិ ប្រចាំឆ្នាំ ចន្លោះឆ្នាំ 2012–13 និង 2016–17។ (ទំនងជាមានការកើនប្រាក់ចំណូលតិចជាងនេះនៅក្នុងឆ្នាំសារពើពន្ធ 2011–12, 2017–18, និង 2018–19។) ប្រាក់ចំណូលទាំងនេះនឹងត្រូវបានប្រើសម្រាប់ជួយផ្ដល់ថវិកាដល់ គំរោងថវិកាឆ្នាំ 2012–13 របស់រដ្ឋ ហើយនឹងមានលទ្ធភាពអាចប្រើប្រាស់ សម្រាប់ជួយធ្វើឲ្យមានតុល្យភាពគំរោងថវិការយៈពេលប្រាំពីរឆ្នាំខាងមុខ។ វិធានការនេះ ក៏នឹងធានាថា រដ្ឋបាលមូលដ្ឋាន បន្តទទួលជាប្រចាំឆ្នាំនូវការចែករំលែកប្រាក់ចំណូលពន្ធរដ្ឋ ដែលបានផ្ទេរក្នុងឆ្នាំ 2011 ដើម្បីទូទាត់សម្រាប់ការបង្វែរការទទួលខុសត្រូវនៃកម្មវិធីរបស់រដ្ឋខ្លះ ទៅឲ្យរដ្ឋបាលមូលដ្ឋាន។

ប្រសិនបើអ្នកបោះឆ្នោតបដិសេធវិធានការនេះ អត្រាពន្ធទំនិញលក់ចេញរបស់រដ្ឋ និងពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន នឹងមិនមានការកើនឡើងទេ។ ដោយសារតែថវិកាដែលបានមកពីការបង្កើនពន្ធទាំងនេះ នឹងមិនអាចមានលទ្ធភាពប្រើប្រាស់ សម្រាប់ជួយផ្ដល់ថវិកាដល់គំរោងថវិកាឆ្នាំ 2012–13 របស់រដ្ឋនោះ ការចំណាយរបស់រដ្ឋនៅក្នុងឆ្នាំ 2012–13 នឹងត្រូវបានកាត់បន្ថយមកត្រឹមប្រមាណជា $6 ប្រាំមួយរយកោដិ ជាមួយនឹងការកាត់ស្ទើរតែទាំងអស់ពាក់ព័ន្ធនឹងវិស័យអប់រំ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ប្រាក់ចំណូលរដ្ឋ នឹងធ្លាក់ចុះរាប់ពាន់លានដុល្លារ ប្រសិនបើវិធានការមិនត្រូវបានអនុម័តទេនោះ។

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 30, សូមអានទំព័រ 80។*

សំណើប្រជាមតិ **30**

# ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 30 ★

*សារមួយពីសម្ព័ន្ធអ្នកបោះឆ្នោតស្ត្រីនៃរដ្ឋកាលីហ្វ័រញ៉ា និងគ្រូបង្រៀននៃរដ្ឋកាលីហ្វ័រញ៉ា និងអ្នកមានវិជ្ជាជីវៈពង្រឹងការអនុវត្តច្បាប់*

ជូនចំពោះសមាជិកនៅរដ្ឋកាលីហ្វ័រញ៉ា,

បន្ទាប់ពីការកាត់អស់រយៈពេលប៉ុន្មានឆ្នាំមកនេះ សាលារៀន សាកលវិទ្យាល័យរដ្ឋ និងសេវាសុវត្ថិភាពសាធារណៈរបស់រដ្ឋកាលីហ្វ័រញ៉ាស្ថិតក្នុងចំណុចប្រេះស្រាំ។

គ្រាន់តែក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ សាលារៀនរបស់យើងទទួលរងការកាត់បន្ថយចំនួន $20 ពីរពាន់កោដិដុល្លារ ខ្វះគ្រូបង្រៀនជាង 30,000 នាក់និងចំនួនសិស្សច្រើនក្នុងមួយថ្នាក់ ដែលស្ថិតក្នុងចំណោមចំនួនច្រើនជាងគេបំផុតនៅក្នុងប្រទេស។ កុមាររបស់យើង សមនឹងទទួលបានថ្នាក់រៀនកាន់តែប្រសើរជាងនេះ។

ដល់ពេលដែលត្រូវបញ្ចេញមតិ និងរក្សាឲ្យរដ្ឋកាលីហ្វ័រញ៉ាស្ថិតនៅក្នុងគន្លងដើមវិញហើយ។

សំណើប្រជាមតិលេខ 30 ច្បាប់ការពារសុវត្ថិភាពសាលារៀន និងទីសាធារណៈតាមមូលដ្ឋាន ត្រូវបានគាំទ្រដោយអភិបាល Jerry Brown សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី និងក្រុមអ្នកដឹកនាំចំរុះទូទាំងប្រទេស ដែលមកពីផ្នែកអប់រំផ្នែកពង្រឹងការអនុវត្តច្បាប់ និងអាជីវកម្ម។

*មានការគាំទ្រទូលំទូលាយចំពោះសំណើប្រជាមតិលេខ 30 ពីព្រោះវាជាការផ្ដួចផ្ដើមតែមួយគត់ ដែលនឹងការពារសាលារៀន និងសុវត្ថិភាពថវិកា និងជួយដោះស្រាយភាពរញ៉េរញ៉ៃនៃគម្រោងថវិការ៉ាំរ៉ៃរបស់រដ្ឋ៖*

- *ទប់ស្កាត់ការកាត់ពីសាលារៀនយ៉ាងច្រើន។* បើគ្មានសំណើប្រជាមតិលេខ30 ទេ សាលារៀន និងមហាវិទ្យាល័យរបស់យើង ប្រឈមនឹងការកាត់ដ៏ច្រើនគឺ $6 ប្រាំមួយរយកោដិ បន្ថែមទៀតនៅឆ្នាំនេះ។ សំណើប្រជាមតិលេខ 30 គឺជាការផ្ដួចផ្ដើម តែមួយគត់ ដែលទប់ស្កាត់ការកាត់ទាំងនោះ និងផ្ដល់ថវិកាថ្មីៗជាច្រើនកោដិដុល្លារ សម្រាប់សាលារៀនរបស់យើងដោយចាប់ផ្ដើមពីឆ្នាំនេះតទៅ គឺថវិកាដែលអាចចំណាយលើ ការធ្វើឲ្យចំនួនសិស្សក្នុងមួយថ្នាក់កាន់តែតិចជាងមុន បន្ទាន់សម័យសៀវភៅសិស្ស និងការជួលគ្រូឲ្យមកបង្រៀនវិញ។
- *ធានាថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន។* សំណើប្រជាមតិលេខ 30 គឺជាវិធានការ តែមួយគត់ ដែលស្ថាបនាការធានាមួយ សម្រាប់ថវិកាខាងសុវត្ថិភាពសាធារណៈនៅក្នុងធម្មនុញ្ញរដ្ឋរបស់យើងដែលគ្មាននរណាអាចប៉ះពាល់វាបានឡើយ បើគ្មានការយល់ព្រមពីអ្នកបោះឆ្នោតទេនោះ។ សំណើប្រជាមតិលេខ 30 រក្សាឲ្យអ្វីៗទាំងអស់មានតម្លាភាពជានិច្ច។ .
- *ជួយធ្វើឲ្យគម្រោងថវិកាមានតុល្យភាព។* សំណើប្រជាមតិលេខ 30 ធ្វើឲ្យគម្រោងថវិការបស់យើងមានតុល្យភាព និងជួយទូទាត់បំណុលរបស់រដ្ឋកាលីហ្វ័រញ៉ា ដែលបង្កើតឡើងដោយសារការបំភាន់ និងការខ្ចីច្រើនឆ្នាំ។ វាគឺជា ជំហានដ៏សំខាន់មួយ ក្នុងការបញ្ឈប់ កង្វះថវិកាដែលញាំញីរដ្ឋកាលីហ្វ័រញ៉ា។

ដើម្បីការពារសាលារៀន និងសុវត្ថិភាព សំណើប្រជាមតិលេខ 30 បានបង្កើនជាបណ្ដោះអាសន្ន នូវពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន ទៅលើអ្នករកប្រាក់ចំណូលខ្ពស់បំផុតគឺប្ដីប្រពន្ធដែលមានប្រាក់ចំណូលលើស $500,000 ក្នុងមួយឆ្នាំ និងស្ថាបនាពន្ធទំនិញលក់ចេញនៅត្រឹមអត្រាមួយ ដែលទាបជាងពីឆ្នាំមុន។

*ពន្ធរបស់សំណើប្រជាមតិលេខ 30 ត្រូវបានធ្វើឲ្យមានតុល្យភាពជាបណ្ដោះអាសន្ន និងមានភាពចាំបាច់ក្នុងការការពារសាលារៀន និងសុវត្ថិភាព ៖*

- *មានតែអ្នករកប្រាក់ចំណូលខ្ពស់បំផុតប៉ុណ្ណោះ ដែលត្រូវបង់ពន្ធប្រាក់ចំណូលច្រើនជាងមុន៖* សំណើប្រជាមតិលេខ 30 ស្នើឲ្យអ្នកដែលរកប្រាក់ចំណូលបានច្រើនជាងគេ បង់ពន្ធប្រាក់ចំណូលច្រើនជាងមុន។ ប្ដីប្រពន្ធដែលរកប្រាក់ចំណូលបានទាបជាង $500,000 ក្នុងមួយឆ្នាំ នឹងមិនត្រូវបង់ពន្ធប្រាក់ចំណូលបន្ថែមឡើយ។
- *ប្រាក់ចំណូលថ្មីទាំងអស់មានលក្ខណៈជាបណ្ដោះអាសន្ន៖* ពន្ធរបស់សំណើប្រជាមតិលេខ 30 មានលក្ខណៈជាបណ្ដោះអាសន្ន ការផ្ដួចផ្ដើមនេះ មិនអាចកែប្រែដោយការបោះឆ្នោតរបស់ប្រជាជនបានឡើយ។ អ្នករកប្រាក់ចំណូលបានខ្ពស់ជាងគេ នឹងត្រូវបង់ច្រើនជាងមុនរយៈពេលប្រាំពីរឆ្នាំ។ ខចែងអំពីពន្ធទំនិញលក់ចេញ នឹងមានសុពលភាពរយៈពេលបួនឆ្នាំ។
- *ថវិកាចូលទៅក្នុងគណនីពិសេស ដែលអង្គនីតិបញ្ញត្តិមិនអាចប៉ះពាល់បាន៖* ថវិកាដែលបានបង្កើនសម្រាប់សាលារៀន ត្រូវបានចាត់ចែងចូលទៅក្នុងថវិកាពិសេស ដែលអង្គនីតិបញ្ញត្តិមិនអាចប៉ះពាល់បាន ហើយមិនអាចប្រើសម្រាប់ការិយាធិបតេយ្យរបស់រដ្ឋបានឡើយ។
- *សំណើប្រជាមតិលេខ 30 អនុញ្ញាតឲ្យមានសវនកម្មមានសិទ្ធិ៖* សវនកម្មមានសិទ្ធិ និងឯករាជ្យ និងធានាថា ថវិកាត្រូវបានចំណាយ តែម្យ៉ាងគត់ សម្រាប់សាលារៀន និងសុវត្ថិភាពសាធារណៈ។

ចូលរួមជាមួយសម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី និងគ្រូបង្រៀនរដ្ឋកាលីហ្វ័រញ៉ា និងអ្នកវិជ្ជាជីវៈសុវត្ថិភាពសាធារណៈ។

បោះឆ្នោត បាទ/ចាសលើសំណើប្រជាមតិលេខ 30។

*ក្រោកឈរដើម្បីសាលារៀននិងសុវត្ថិភាព សាធារណៈ។*

ស្វែងយល់ថែមទៀត សូមទស្សនាគេហទំព័រ *YesOnProp30.com.*

**JENNIFER A. WAGGONER**, ប្រធាន
សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា

**DEAN E. VOGEL**, ប្រធាន
សមាគមគ្រូបង្រៀនកាលីហ្វ័រញ៉ា

**KEITH ROYAL**, ប្រធាន
សមាគមតម្រួតតំបន់រដ្ឋកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 30 ★

អ្នកគាំទ្រសំណើប្រជាមតិលេខ 30 និយាយថា យើងត្រូវតែយល់ព្រមទៅលើការបង្កើនពន្ធដ៏ច្រើន ពុំដូច្នោះទេថវិកាសម្រាប់សាលារៀននឹងត្រូវកាត់បន្ថយ។

យើងទាំងអស់គ្នាចង់បានសាលារៀនដ៏ប្រសើរនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាប៉ុន្តែការបង្កើនពន្ធមិនមែនជាវិធីតែមួយក្នុងការសម្រេចកិច្ចការនេះឡើយ។

អ្នកនយោបាយ ចង់បង្កើនពន្ធជំនួសឲ្យការធ្វើឲ្យមានប្រសិទ្ធភាពកម្មវិធីរាប់ពាន់ដែលផ្ដល់ថវិកាដោយរដ្ឋ ការិយាធិបតេយ្យ និងការខ្ជះខ្ជាយដ៏ច្រើនសន្ធឹកសន្ធាប់។

សូមមើលអ្វីដែលពួកគេទើបនឹងបានធ្វើរួច៖ អ្នកនយោបាយបានអនុញ្ញាតជិត *$5 ប្រាំរយកោដិ* នៃសញ្ញាប័ណ្ណរដ្ឋកាលីហ្វ័រញ៉ាសម្រាប់ "រថភ្លើងលឿនមិនទៅកន្លែងណាមួយ" ដែលអ្នកជាប់ពន្ធទាំងឡាយត្រូវចំណាយ $380 លានក្នុងមួយឆ្នាំ។ យើងនាំគ្នាប្រើថវិកាទាំងនោះសម្រាប់សាលារៀនវិញ!

តែជំនួសវិញអ្នកនយោបាយឱ្យយើងនូវជំរើសខុស—តំឡើងពន្ធលក់ដូររហូតដល់ $1 មួយរយកោដិ ក្នុងមួយឆ្នាំហើយតំឡើងពន្ធប្រាក់ចំណូលពីពាណិជ្ជកម្មខ្នាតតូច ឬកាត់សាលារៀន។

សំណើប្រជាមតិលេខ 30 មិនដូចអ្វីដែលមើលឃើញទេ៖ វាមិនធានាដល់ការផ្ដល់ថវិកាថ្មីសម្រាប់ថ្នាក់រៀន សូម្បីតែមួយដុល្លារឡើយ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាអនុញ្ញាតឲ្យអ្នកនយោបាយយកថវិកា ដែលបច្ចុប្បន្ននេះត្រូវបានរក្សាទុកដោយឡែកសម្រាប់វិស័យអប់រំហើយចំណាយ វាទៅលើកម្មវិធីផ្សេងៗ។ យើងគ្មានថ្ងៃដឹងថាថវិកានោះទៅខាងណា ឲ្យប្រាកដនោះឡើយ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាផ្ដល់ឱ្យអ្នកនយោបាយនៅ Sacramento សន្លឹកសែកចំហមួយដោយគ្មានការតំរូវថវិកា សោធននិវត្តន៍ ឬការកែទម្រង់ផ្នែកអប់រំ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាធ្វើឱ្យឈឺចាប់ដល់ពាណិជ្ជកម្មខ្នាតតូច និងសំឡាប់ការងារ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ គឺវាគ្រាន់តែផ្ដល់ប្រាក់ច្រើនថែមទៀតដល់អ្នកនយោបាយនៅ Sacramento ដើម្បីបន្តចំណាយថែមទៀត។

កុំយល់ខុស សំណើប្រជាមតិលេខ 30 មិនដូចអ្វីដែលមើលឃើញទេ។ វាគ្រាន់តែជាលេស សម្រាប់ឲ្យអ្នកនយោបាយនៅក្រុងសាក្រាម៉ិនតូ យកថវិការបស់អ្នកកាន់តែច្រើនប៉ុណ្ណោះ ខណៈធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ច និងមិនបានធ្វើអ្វីដើម្បីជួយដល់វិស័យអប់រំសោះ។

ពលរដ្ឋកាលីហ្វ័រញ៉ា សុទ្ធតែឆ្លាតៗ មិនល្ងង់ទេ៖ *បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30!*

**JOEL FOX**, ប្រធាន
គណៈកម្មការសកម្មភាពពាណិជ្ជកម្មខ្នាតតូច

**JOHN KABATECK**, នាយកប្រតិបត្តិ
សហព័ន្ធជាតិនៃពាណិជកម្មឯករាជ្យ/ កាលីហ្វ័រញ៉ា

**KENNETH PAYNE**, ប្រធាន
សមាគមអ្នកជាប់ពន្ធ Sacramento



*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

សំណើប្រជាមតិ
# 30

# ពន្ធបណ្ដោះអាសន្ន សំរាប់ផ្ដល់ថវិកា ការអប់រំ។ ការផ្ដល់ថវិកាខាងសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន ដែលអះអាង។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ។



## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ 30 ★

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 ៖ វាគ្រាន់តែជា "ល្បែងបោកបញ្ឆោត" នយោបាយក្នុងទឹកប្រាក់ $50 ប្រាំពាន់កោដិ ប៉ុណ្ណោះ ប៉ុន្តែមិនបានធានាដល់ការផ្ដល់ថវិកាថ្មីសម្រាប់សាលារៀនឡើយ។

អ្នកនយោបាយដែលនៅពីក្រោយសំណើប្រជាមតិលេខ 30 ចង់ឲ្យយើងជឿថា ប្រសិនបើអ្នកបោះឆ្នោតយល់ព្រមចំពោះការបង្កើនពន្ធដ៏ច្រើន ក្នុងរយៈពេលប្រាំពីរឆ្នាំតាមសំណើប្រជាមតិលេខ 30 នោះ ថវិកាថ្មីនឹងបានទៅដល់ថ្នាក់រៀនជាច្រើន។ គ្មានអ្វីអាចបន្ថែមលើសពីការពិតទេ។

សំណើប្រជាមតិលេខ 30 អនុញ្ញាតឲ្យអ្នកនយោបាយលេង "ល្បែងបោកបញ្ឆោត" ជំនួសឲ្យការផ្ដល់ថវិកាថ្មីដល់សាលារៀន៖

- ពួកគេអាចយកថវិកាដែលមានស្រាប់សម្រាប់សាលារៀន ហើយប្រើវាសម្រាប់គោលបំណងផ្សេងៗ រួចហើយជំនួសថវិកានោះជាមួយថវិកាដែលបានមកពីពន្ធថ្មី។ ពួកគេប្រើដៃម្ខាងយកចេញ ហើយប្រើដៃម្ខាងទៀតដាក់មកវិញ។ មិនថាអ្នកយល់យ៉ាងណាឡើយ សំណើប្រជាមតិលេខ 30 មិនបានធានាដល់ការផ្ដល់ថវិកាថ្មីសម្រាប់សាលារៀន សូម្បីតែមួយកាក់មួយសេនឡើយ។
- អ្នកអប់រំជាច្រើនបានផ្សព្វផ្សាយអំពីគុណវិបត្តិនេះ ហើយសូម្បីតែសមាគមគណៈកម្មការសាលារៀននៅរដ្ឋកាលីហ្វ័រញ៉ាបានថ្លែងថា " ...ការផ្ដើមប្រជាសិទ្ធិរបស់អភិបាលមិនបានផ្ដល់ថវិកាថ្មីសម្រាប់សាលារៀនឡើយ។" (20 ឧសភា 2012)។
- កាសែតឈ្មោះ Wall Street បានរកឃើញគុណវិបត្តិដូចគ្នានេះ ដោយបានថ្លែងថា "អភិបាលរដ្ឋកាលីហ្វ័រញ៉ា លោក Jerry Brown កំពុងព្យាយាមលក់កំណើនពន្ធរបស់លោក ទៅឲ្យអ្នកបោះឆ្នោតនៅខែវិច្ឆិកានេះ ដោយនិយាយថា វានឹងបានទៅដល់សាលារៀនទាំងឡាយ។ អាថ៌កំបាំងតូចដ៏កខ្វក់គឺថា ប្រាក់ចំណូលថ្មី នឹងត្រូវការ ដើម្បីបំពេញដល់ប្រាក់សោធននិវត្តន៍របស់គ្រូបង្រៀនដែលមិនទាន់បានសង។" វិចារណកថារបស់កាសែត Wall Street ចេញផ្សាយថ្ងៃទី 22 ខែមេសា ឆ្នាំ 2012។
- សូម្បីតែចំណងជើងផ្លូវការ និងសេចក្ដីសង្ខេបនៃសំណើប្រជាមតិលេខ 30 និយាយថា ថវិកាអាចត្រូវបានប្រើសម្រាប់ "... ទូទាត់សម្រាប់ការប្ដេជ្ញាចំណាយផ្សេងៗ។"

លើសពីនេះទៀត ពុំមានលក្ខខណ្ឌតម្រូវ ឬការធានាថា ថវិកាច្រើនជាងមុនណាមួយពិតជាបានទៅដល់ថ្នាក់រៀនឡើយ ហើយពុំមានអ្វីមួយនៅក្នុងសំណើប្រជាមតិលេខ 30 ធ្វើកំណែទម្រង់ប្រព័ន្ធអប់រំរបស់យើង ដើម្បីកាត់បន្ថយការខ្ជះខ្ជាយ លុបបំបាត់ការិយាធិបតេយ្យ ឬកាត់បន្ថយបន្ទុកចំណាយរដ្ឋបាលឡើយ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30— គ្មានកំណែទម្រង់ទេ។

អ្នកនយោបាយ និងផលប្រយោជន៍ពិសេសនៅពីក្រោយ សំណើប្រជាមតិលេខ 30 ចង់បង្កើនពន្ធ ដើម្បីទូទាត់ចំណាយដែលមិនអាចគ្រប់គ្រងបានរបស់ពួកគេ ប៉ុន្តែបដិសេធមិនព្រមអនុម័តកំណែទម្រង់ដ៏មានន័យ ៖

- ផលប្រយោជន៍ពិសេស និងអ្នកនយោបាយដែលពួកគេគ្រប់គ្រង បានធ្វើឲ្យរាំងស្ទះដល់កំណែទម្រង់ប្រាក់សោធននិវត្តន៍។ យើងមាន $500 ប្រាំរយពាន់កោដិនៅក្នុងបំណុលសោធននិវត្តន៍ ដែលមិនទាន់បានផ្ដល់ថវិកានៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ហើយអ្នកនយោបាយនៅតែបដិសេធមិនព្រមអនុម័តកំណែទម្រង់ជាក់ស្ដែង។
- ក្រុមមនុស្សតែមួយនេះ បានធ្វើឲ្យរាំងស្ទះដល់កំណែទម្រង់គម្រោងថវិកា។ អ្នកនយោបាយបន្តចំណាយច្រើនជាងថវិកាដែលរដ្ឋមាន។ សំណើប្រជាមតិទី 30 បានប្រគល់ការប្រព្រឹត្តដ៏គ្រោះថ្នាក់នេះ ដោយផ្ដល់ឲ្យពួកគេនូវថវិការាប់ពាន់លានដុល្លារថែមទៀត ដើម្បីចំណាយដោយគ្មានកំណែទម្រង់ គ្មានការធានាថាថវិកានឹងមិនខ្ជះខ្ជាយ ឬការធានាថា ថវិកានោះនឹងពិតជាបានទៅដល់ថ្នាក់រៀន។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 30 — បញ្ឈប់ការគំរាមកំហែងពីអ្នកនយោបាយ។

អភិបាល អ្នកនយោបាយ និងផលប្រយោជន៍ពិសេសនៅពីក្រោយសំណើប្រជាមតិលេខ 30 គំរាមកំហែងដល់អ្នកបោះឆ្នោត។ ពួកគេនិយាយថា "បោះឆ្នោតឲ្យការបង្កើនពន្ធដ៏ច្រើនរបស់យើង ពុំដូច្នោះទេ យើងនឹងដកវាចេញពីសាលារៀន" ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ ពួកគេបដិសេធមិនព្រមកែទម្រង់ប្រព័ន្ធអប់រំ ឬសោធននិវត្តន៍ដើម្បីសន្សំសំចៃថវិកាឡើយ។

យើងត្រូវធ្វើឲ្យមានកំណើនសេដ្ឋកិច្ចរបស់យើង ដើម្បីបង្កើតការងារ និងកាត់បន្ថយការខ្ជះខ្ជាយ បោសសម្អាតរដ្ឋាភិបាល កែទម្រង់ដំណើរការគម្រោងថវិការបស់យើង និងធ្វើឲ្យអ្នកនយោបាយទទួលខុសត្រូវ ជំនួសឲ្យការយល់ព្រមចំពោះកំណើនពន្ធ $50 ប្រាំពាន់កោដិ លើអាជីវកម្មខ្នាតតូច និងគ្រួសារការងារ ដែលមិនផ្ដល់គណនេយ្យភាពណាមួយ ឬធានាការផ្ដល់ថវិកាថ្មីសម្រាប់សាលារៀន។

មិនយល់ព្រមចំពោះសំណើប្រជាមតិលេខ 30 — កំណែទម្រង់ និងការងារជាចម្បង មិនមែនពន្ធកាន់តែខ្ពស់ទេ។

**JON COUPAL**, ប្រធាន
សមាគមអ្នកជាប់ពន្ធ Howard Jarvis

**TOM BOGETICH**, នាយកប្រតិបត្តិ (ចូលនិវត្តន៍)
ក្រុមប្រឹក្សាអប់រំកាលីហ្វ័រញ៉ា

**DOUG BOYD**, សមាជិក
ក្រុមប្រឹក្សាអប់រំខោនធី Los Angeles

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 30 ★

ក្រោយពីការកាត់អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកដល់ពេលដែលត្រូវគូសបន្ទាត់មួយ ដើម្បីការពារសាលារៀន និងសុវត្ថិភាពសាធារណៈតាមមូលដ្ឋានហើយ។

ការគ្រប់គ្រងសារពើពន្ធដ៏រឹងមាំរបស់ សំណើប្រជាមតិទី 30 ធានាថា ថវិកាត្រូវបាន ចំណាយ តែម្យ៉ាងគត់ ទៅលើសាលារៀន និងសុវត្ថិភាពសាធារណៈ៖

- ប្រាក់ចំណូលត្រូវបានធានានៅក្នុងធម្មនុញ្ញ ថានឹងចូលទៅក្នុងគណនីពិសេសមួយសម្រាប់សាលារៀន ដែល*អង្គនីតិបញ្ញត្តិមិនអាចប៉ះពាល់បាន*។
- ថវិកានឹងត្រូវបានធ្វើសវនកម្ម *រៀងរាល់ឆ្នាំ* ហើយមិនអាចចំណាយទៅលើការគ្រប់គ្រងរដ្ឋបាល ឬការិយាធិបតេយ្យរបស់ក្រុងសាក្រាម៉ិនតូឡើយ។
- សំណើប្រជាមតិលេខ 30 អនុញ្ញាតឲ្យមានបណ្ដឹងរឿងព្រហ្មទណ្ឌ ចំពោះការប្រើថវិកាខុស។

កូនៗរបស់យើងសមតែទទួលបានថ្នាក់រៀនកាន់តែប្រសើរ ជាជាងថ្នាក់រៀនដែលមានចំនួនសិស្សច្រើនជាងគេបំផុតនៅក្នុងប្រទេស។ សំណើប្រជាមតិលេខ 30 ស្នើឲ្យអ្នកមានទ្រព្យធនច្រើន បង់ចំណែកស្មើ របស់គេ ដើម្បីរក្សាឲ្យថ្នាក់រៀនបើកចំហនិងមានតម្លាភាព។

- ទប់ស្កាត់ការកាត់បន្ថយថវិកាច្រើនពីសាលារៀនឆ្នាំនេះ៖ សំណើប្រជាមតិលេខ 30 គឺជាការផ្ដួចផ្ដើមតែមួយគត់ ដែលទប់ស្កាត់ថវិកាចំនួន $6 ប្រាំមួយរយ កោដិ នៅក្នុងការកាត់ដោយស្វ័យប្រវត្តិពីសាលារៀន និងសាកលវិទ្យាល័យនៅឆ្នាំនេះ។ បើគ្មានសំណើប្រជាមតិលេខ 30 ទេ យើងប្រឈមនឹងឆ្នាំសិក្សាកាន់តែខ្លី ការបញ្ឈប់គ្រូបង្រៀនបណ្ដោះអាសន្ន និងកំណើនការសិក្សាឡើង ឬចុះនៅក្នុងឆ្នាំនេះ។
- ផ្ដល់ថវិការាប់ពាន់លាននៅក្នុងការផ្ដល់ថវិកាថ្មីដល់សាលារៀន៖ សំណើប្រជាមតិលេខ 30 ផ្ដល់ថវិការាប់ពាន់លានបន្ថែមទៀត ដើម្បីកាត់បន្ថយចំនួនសិស្សច្រើនក្នុងមួយថ្នាក់ និងស្ដារកម្មវិធីទាំងឡាយដូចជា សិល្បៈ និងការអប់រំកាយជាដើម។
- ការពារសុវត្ថិភាពសាធារណៈតាមមូលដ្ឋាន៖ សំណើប្រជាមតិលេខ 30 ធានាដល់ការផ្ដល់ថវិកាដល់សុវត្ថិភាពសាធារណៈតាមមូលដ្ឋាន នៅក្នុងរដ្ឋធម្មនុញ្ញ និងជួយសន្សំសំចៃថវិការាប់ពាន់លាន នៅក្នុងខ្ទង់ចំណាយលើពន្ធនាគារនាពេលអនាគត។
- ជួយធ្វើឲ្យគម្រោងថវិកាមានតុល្យភាព៖ សំណើប្រជាមតិលេខ 30 គឺជាផ្នែកនៃដំណោះស្រាយរយៈពេលវែង ដើម្បីធ្វើឲ្យគម្រោងថវិការដ្ឋមានតុល្យភាព។

គ្រូបង្រៀន អ្នកពង្រឹងការអនុវត្តច្បាប់ អ្នកដឹកនាំអាជីវកម្ម និងលោកអភិបាល Jerry Brown ទាំងអស់គ្នាគាំទ្រដល់សំណើប្រជាមតិលេខ 30 ពីព្រោះវាគឺជាវិធានការតែមួយគត់ ដែលនឹងដាក់រដ្ឋកាលីហ្វ័រញ៉ានៅលើផ្លូវមួយ ឆ្ពោះទៅរកការស្ដារឡើងវិញ។

*ស្វែងយល់បន្ថែមទៀតតាមអាសយដ្ឋាន www.YesOnProp30.com ។*

**JENNIFER A. WAGGONER**, ប្រធាន
សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា

**JOSHUA PECHTHALT**, ប្រធាន
សហព័ន្ធគ្រូបង្រៀនរដ្ឋកាលីហ្វ័រញ៉ា

**SCOTT R. SEAMAN**, ប្រធាន
សមាគមនាយកប៉ូលិសកាលីហ្វ័រញ៉ា

សំណើប្រជាមតិ

# 31 គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

**ចំណាងជើងជាផ្លូវការ និងសេចក្តីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

31

**គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។**

- ស្ថាបនាគំរោងថវិការដ្ឋ រយៈពេលពីរ-ឆ្នាំ។
- ហាមឃាត់អង្គនីតិបញ្ញត្តិ ពីការបង្កើតការចំណាយលើសពី $25 លាន លុះត្រាតែមានការទូទាត់ប្រាក់ចំណូល ឬបានកត់សំគាល់ការកាត់បន្ថយនូវការចំណាយ។
- អនុញ្ញាតឲ្យអភិបាលរដ្ឋ កាត់បន្ថយគំរោងថវិកាជាឯកតោភាគី ក្នុងពេលបានប្រកាសភាពអាសន្នហិរញ្ញវត្ថុ បើអង្គនីតិបញ្ញត្តិអាក់ខានប្រព្រឹត្ត។
- ជំរុំឲ្យមានការពិនិត្យមើលឡើងវិញ នូវកម្មវិធីទាំងអស់របស់រដ្ឋ។
- ជំរុំឲ្យមានការបំពេញគោលដៅ ក្នុងគំរោងថវិការដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន។
- ជំរុំឲ្យមានការបោះពុម្ពកំរងច្បាប់ យ៉ាងហោចបំផុតចំនួនបីថ្ងៃ មុនពេលឲ្យអង្គនីតិបញ្ញត្តិបោះឆ្នោត។
- អនុញ្ញាតឲ្យរដ្ឋាភិបាលមូលដ្ឋាន ប្តូរលក្ខណៈច្បាប់ការគ្រប់គ្រងកម្មវិធីរដ្ឋបានផ្តល់ថវិកា ដែលពាក់ព័ន្ធដល់គេ លុះត្រាតែអង្គនីតិបញ្ញត្តិ ឬភ្នាក់ងាររដ្ឋមានអត្តនោសិទ្ធិផ្លាស់ប្តូរក្នុងពេល 60 ថ្ងៃ។

**សេចក្តីសង្ខេបនៃអ្នកវិភាគនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន៖**

- ពន្ធប្រាក់ចំណូលរដ្ឋនៃការលក់ដូរចុះថយ ប្រហែល $200 លានជាប្រចាំឆ្នាំ ដោយមានការកើនឡើងស្របគ្នា នៃការផ្តល់ថវិកាឲ្យរដ្ឋាភិបាលមូលដ្ឋានខ្លះ។
- ផ្សេងៗទៀត អាចនឹងមានការផ្លាស់ប្តូរខ្លាំងច្រើនទៀត ក្នុងការចំណាយ និងប្រាក់ចំណូលរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានដ៏សន្ធឹកសន្ធាប់ ដែលអាស្រ័យទៅលើការសំរេចនៅអនាគតដោយមន្ត្រីសាធារណៈ។

---

ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

## ទិដ្ឋភាពទូទៅ

វិធានការនេះ កែប្រែការទទួលខុសត្រូវជាក់លាក់របស់រដ្ឋបាលមូលដ្ឋាន អង្គនីតិបញ្ញត្តិ និងអភិបាល។ ហើយវាថែមទាំងកែប្រែទិដ្ឋភាពមួយចំនួននៃប្រតិបត្តិការរបស់រដ្ឋ និងរដ្ឋបាលមូលដ្ឋានផងដែរ។ តារាងទី 1 សង្ខេបអំពីខចែងសំខាន់ៗនៃវិធានការនេះ ហើយដែលខចែងនីមួយៗត្រូវបានពិភាក្សាយ៉ាងលម្អិតដូចខាងក្រោម។

## ការអនុញ្ញាត និងផ្តល់មូលនិធិសំរាប់ផែនការរដ្ឋបាលមូលដ្ឋាន

## សេចក្តីស្នើច្បាប់

***អនុញ្ញាតឲ្យរដ្ឋបាលមូលដ្ឋានបង្កើតផែនការថ្មីៗ។*** នៅក្រោមវិធានការនេះ ខោនធីទាំងឡាយ និងរដ្ឋបាលមូលដ្ឋានដទៃទៀត (ដូចជាទីក្រុងការិយាល័យអប់រំស្រុក មហាវិទ្យាល័យសហគមន៍ក្នុងស្រុក និងស្រុកពិសេស) អាចបង្កើតផែនការនានា សម្រាប់សម្របសម្រួលលក្ខណៈដែលពួកគេផ្តល់សេវាផ្សេងៗជូនសាធារណជន។ ផែនការទាំងឡាយអាចបង្ហាញរបៀបដែលរដ្ឋបាលមូលដ្ឋានផ្តល់សេវាផ្សេងៗនៅក្នុងផ្នែកជាច្រើន រួមមានការអភិវឌ្ឍសេដ្ឋកិច្ច ការអប់រំ សេវាសង្គមកិច្ច សុវត្ថិភាពសាធារណៈ និងសុខភាពសាធារណៈ។ ផែនការនីមួយៗ ចាំបាច់ត្រូវតែអនុម័តដោយគណៈគ្រប់គ្រងនៃ (1) ខោនធី (2) ការិយាល័យអប់រំស្រុក ដែលបម្រើដល់សិស្សភាគច្រើននៅក្នុងខោនធី និង (3) រដ្ឋបាលមូលដ្ឋានផ្សេងទៀតដែលតំណាងឲ្យប្រជាពលរដ្ឋភាគច្រើននៅក្នុងខោនធី។ ទីភ្នាក់ងារមូលដ្ឋាននឹងទទួលបានថវិកាមួយចំនួនពីរដ្ឋសម្រាប់អនុវត្តផែនការទាំងនោះ (ដូចមានបរិយាយខាងក្រោម)។

***អនុញ្ញាតឲ្យរដ្ឋបាលមូលដ្ឋានធ្វើការកែប្រែការគ្រប់គ្រងកម្មវិធីដែលរដ្ឋផ្តល់ថវិកា។*** ប្រសិនបើរដ្ឋបាលមូលដ្ឋានយល់ឃើញថា ច្បាប់ ឬបទបញ្ជារបស់រដ្ឋរឹតត្បិតសមត្ថភាពរបស់ពួកគេ ក្នុងការអនុវត្តផែនការរបស់ខ្លួន ពួកគេអាចបង្កើតនីតិវិធីក្នុងមូលដ្ឋានដែលមាន "មុខងារសមមូល" នឹងគោលបំណងនៃច្បាប់ ឬបទបញ្ជាជាធរមានរបស់រដ្ឋដែរ។ រដ្ឋបាលមូលដ្ឋានអាចគោរពតាម នីតិវិធីក្នុងមូលដ្ឋានទាំងនេះ - ជំនួសឲ្យច្បាប់ ឬបទបញ្ជារបស់រដ្ឋ

សំណើប្រជាមតិ
# 31 គំរោងថវិការរដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

## ការវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ (ត)

-ក្នុងការ គ្រប់គ្រងកម្មវិធីរបស់រដ្ឋ ដែលផ្តល់ថវិកាចេញពីថវិការបស់រដ្ឋ។ អង្គនីតិបញ្ញត្តិ (ក្នុងករណីច្បាប់របស់រដ្ឋ) ឬក្រសួងពាក់ព័ន្ធរបស់រដ្ឋ (ក្នុងករណីបទបញ្ជា របស់រដ្ឋ) នឹងមានឱកាសប្រានចោលនីតិវិធីជំនួសក្នុងមូលដ្ឋានទាំងនេះ។ នីតិវិធីដែលបានបង្កើតឡើងក្នុងមូលដ្ឋាន នឹងអស់សុពលភាពក្រោយរយៈពេលបួនឆ្នាំ ប្រសិនបើវាមិនត្រូវបានបន្តទៅតាមដំណើរការដូចគ្នានេះទេនោះ។

***អនុញ្ញាតឲ្យផ្ទេរពន្ធលើទ្រព្យសម្បត្តិក្នុងមូលដ្ឋាន។*** អ្នកជាប់ពន្ធក្នុងរដ្ឋកាលីហ្វ័រញ៉ាបង់ប្រាក់ប្រហែល $50 ហាសិបពាន់កោដិដុល្លារ សម្រាប់ពន្ធអចលនទ្រព្យ ជូនរដ្ឋបាលមូលដ្ឋានក្នុងមួយឆ្នាំៗ។ ច្បាប់របស់រដ្ឋ គ្រប់គ្រងលើវិធីដែលពន្ធអចលនទ្រព្យត្រូវបានបែងចែក ក្នុងចំណោមអង្គភាពរដ្ឋបាលមូលដ្ឋានក្នុងខោនធីនីមួយៗ។ វិធានការនេះអនុញ្ញាតឲ្យរដ្ឋបាលមូលដ្ឋាន ដែលចូលរួមនៅក្នុងផែនការនេះ ធ្វើការផ្ទេរពន្ធអចលនទ្រព្យ ដែលត្រូវបានបែងចែកទៅឲ្យពួកគេនៅក្នុងចំណោមពួកគេតាមមធ្យោបាយណាមួយដែលពួកគេជ្រើសរើស។ រដ្ឋាភិបាលនីមួយៗដែលប៉ះពាល់ត្រូវតែអនុម័តការផ្លាស់ប្តូរនោះ ដោយសំឡេងឆ្នោតគាំទ្រពីរភាគបីនៃគណៈអភិបាលរបស់ខ្លួន។

***បង្វែរប្រាក់ចំណូលពន្ធលក់ដូរមួយចំនួនរបស់រដ្ឋទៅឲ្យរដ្ឋបាលមូលដ្ឋាន។*** បច្ចុប្បន្ននេះ អត្រាពន្ធទំនិញលក់ចេញជាមធ្យមរបស់រដ្ឋ គឺមានចំនួនជាង 8%។ ថវិកាដែលកើនឡើង $42.2 បួនពាន់ពីររយពីរកោដិដុល្លារ ក្នុងឆ្នាំ 2009–10 ជាមួយនឹងប្រាក់ចំណូល ដែលបានបែងចែកស្មើរតែស្មើគ្នាទៅឲ្យរដ្ឋ និងរដ្ឋបាលមូលដ្ឋាន។ ចាប់ផ្តើមនៅក្នុងឆ្នាំសារពើពន្ធ 2013–14 វិធានការនេះនឹងបង្វែរថវិកាមួយផ្នែកតូចនៃចំណែករបស់រដ្ឋទៅឲ្យខោនធីទាំងឡាយដែលអនុវត្តផែនការថ្មីៗ។ ការធ្វើបែបនេះនឹងមិនធ្វើឲ្យប្រែប្រួលដល់ពន្ធទំនិញលក់ចេញ ដែលបានបង់ដោយអ្នកជាប់ពន្ធឡើយ។ ការបង្វែរនេះនឹងធ្វើឲ្យកើនប្រាក់ចំណូលរបស់រដ្ឋបាលមូលដ្ឋាន ដែលបានចូលរួមនៅក្នុងខោនធីនានា ជាមួយនឹងគម្រោងទឹកប្រាក់សរុបប្រហែល $200 លាន ក្នុងមួយឆ្នាំៗក្នុងពេលឆាប់ៗខាងមុខនេះ។ រដ្ឋាភិបាលរដ្ឋនឹងបាត់បង់ថវិកាក្នុងចំនួនមួយប្រហាក់ប្រហែលគ្នានេះ ដែលធ្វើឲ្យលែងមានថវិកាសម្រាប់ផ្គត់ផ្គង់កម្មវិធីនានារបស់រដ្ឋ។ ពន្ធលក់ដូរនឹងត្រូវធ្វើការបែងចែកទៅឲ្យខោនធីទាំងឡាយ ដែលបានចូលរួម ដោយផ្អែកលើចំនួនប្រជាពលរដ្ឋរបស់គេ។ វិធានការនេះតម្រូវឲ្យផែនការមូលដ្ឋានចែងច្បាស់អំពីការចែកចាយថវិកាទាំងនេះ និងថវិកាផ្សេងទៀតណាមួយដែលមានគោលបំណងឧបត្ថម្ភដល់ការអនុវត្តផែនការមូលដ្ឋាន។

### តារាងទី 1
### ខមាត្រាសំខាន់ៗនៃសំណើប្រជាមតិលេខ 31

✓ **ការអនុញ្ញាត និងផ្តល់មូលនិធិសំរាប់ផែនការរដ្ឋបាលមូលដ្ឋាន**
- ផ្ទេរប្រាក់ចំណូលរដ្ឋមួយចំនួនទៅឱ្យខោនធីដែលរដ្ឋបាលមូលដ្ឋានអនុវត្តន៍ផែនការសំរួលសេវាកម្មសាធារណៈរបស់គេ។
- អនុញ្ញាតឱ្យរដ្ឋបាលមូលដ្ឋានទាំងនោះអភិវឌ្ឍន៍និតិវិធីរបស់គេដោយផ្ទាល់ដើម្បីមើលខុសត្រូវលើកម្មវិធីមានមូលនិធិពីរដ្ឋ។
- អនុញ្ញាតឱ្យរដ្ឋបាលមូលដ្ឋានទាំងនោះផ្ទេរពន្ធអចលនវត្ថុក្នុងចំណោមពួកគេ។

✓ **កំណត់សមត្ថភាពអង្គនិតិបញ្ញត្តិអនុម័តសេចក្តីព្រាងច្បាប់មួយចំនួន**
- កំណត់សមត្ថភាពអង្គនិតិបញ្ញត្តិអនុម័តសេចក្តីព្រាងច្បាប់មួយចំនួនដែលបង្កើនថ្លៃចំណាយដល់រដ្ឋ ឬបន្ថយប្រាក់ចំណូល ពុំនោះទេទាល់តែមានប្រភពធនធានថវិកាថ្មី/ឬការកាត់បន្ថយចំណាយត្រូវបានគេសំគាល់ឃើញ។
  — ឧទាហរណ៍ សេចក្តីព្រាងច្បាប់ច្រើនប្រភេទពីការតំរូវខាងលើ
- តំរូវស្មើតែគ្រប់សេចក្តីព្រាងច្បាប់ទាំងអស់ និងវិសោធនកម្មទាំងឡាយមានសំរាប់សាធារណៈយ៉ាងហោចណាស់បីថ្ងៃមុនអង្គនិតិបញ្ញត្តិធ្វើសេចក្តីសំរេច។

✓ **ពង្រឹងសមត្ថភាពអភិបាលរដ្ឋក្នុងការកាត់បន្ថយការចំណាយរបស់រដ្ឋ។**
- អនុញ្ញាតឱ្យអភិបាលរដ្ឋបន្ថយការចំណាយក្នុងរយៈពេលឆ្នាំសារពើពន្ធបន្ទាន់របស់រដ្ឋក្នុងស្ថានភាពមួយចំនួន។

✓ **ផ្លាស់ប្តូរថវិកាសាធារណៈ និងនិតិវិធីមើលគ្រប់គ្រង។**
- ផ្លាស់ប្តូរដំណើរការថវិការដ្ឋប្រចាំឆ្នាំទៅជារបៀបថវិការដ្ឋពីរឆ្នាំម្តង។
- តំរូវឱ្យអង្គនិតិបញ្ញត្តិលៃពេលមួយផ្នែកនៃសម័យប្រជុំពីរឆ្នាំរបស់គេសំរាប់អង្គនិតិបញ្ញត្តិមានឱកាសមើលគ្រប់គ្រងកម្មវិធីសាធារណៈ។
- តំរូវឱ្យរដ្ឋាភិបាល និងរដ្ឋបាលមូលដ្ឋានធ្វើការវាយតំលៃប្រសិទ្ធិភាពនៃកម្មវិធី ហើយពិពណ៌នា របៀបដែលថវិការបស់គេជួបតាមកម្មវត្ថុផ្សេងខុសៗគ្នា។

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 31, សូមអានទំព័រ 84។*

## ឥទ្ធិពលសារពើពន្ធ

បន្ថែមទៅលើការបង្វែរលុយ $200 លានដុល្លារដែលបានរៀបរាប់ពីខាងដើម នឹងមានផលប៉ះពាល់សារពើពន្ធដល់រដ្ឋាភិបាលរបស់រដ្ឋនិងតាមមូលដ្ឋាន។ ជាឧទាហរណ៍ ការអនុញ្ញាតឲ្យរដ្ឋាភិបាលមូលដ្ឋានបង្កើតនូវនីតិវិធីផ្ទាល់ របស់ពួកគាត់សំរាប់ចាត់ចែងកម្មវិធីដែលផ្តល់ថវិកាដោយរដ្ឋ អាចបណ្តាល ឲ្យមានជាសក្តានុពលនូវលទ្ធផលកម្មវិធីខុសៗគ្នា និងការចំណាយរបស់ រដ្ឋឬតាមមូលដ្ឋាន ជាជាងនឹងកើតឡើងផ្សេងពីនោះ។ ការអនុញ្ញាតឲ្យរដ្ឋាភិបាលមូលដ្ឋានផ្ទេរពន្ធអចលនទ្រព្យអាចប៉ះពាល់លើចំនួនទឹកប្រាក់ ប៉ុន្មានដែលត្រូវឲ្យទៅរដ្ឋាភិបាលមូលដ្ឋាន ប៉ុន្តែនឹងមិនផ្លាស់ប្តូរនូវទឹកប្រាក់ សរុបដែលបង់ដោយអ្នកបង់ពន្ធអចលនទ្រព្យទេ។ រដ្ឋាភិបាលមូលដ្ឋាន ក៏នឹងប្រហែលចំណាយទឹកប្រាក់បន្ថែមតិចតួចទៀត ដើម្បីបង្កើតនិងចាត់ចែងគំរោងថ្មីៗរបស់ពួកគាត់។ ការផ្លាស់ប្តូរដែលនឹងផ្តល់ជាលទ្ធផល ពីផ្នែកនេះនៃវិធានការ អាស្រ័យលើ (1) ខោនធីប៉ុន្មានដែលបង្កើតគំរោង (2) រដ្ឋបាលមូលដ្ឋានប៉ុន្មានដែលកែប្រែវិធីដែលពួកគេចាត់ចែងកម្មវិធីដែលផ្តល់ ថវិកាដោយរដ្ឋនិង (3) លទ្ធផលរបស់សកម្មភាពរបស់ពួកគេ។ ដោយហេតុផលទាំងនេះហើយ លទ្ធផលសារពើពន្ធសរុបនៃវិធានការនេះសំរាប់ រដ្ឋាភិបាលរបស់រដ្ឋនិងមូលដ្ឋានមិនអាចប៉ាន់ស្មានបានឡើយ។ ចំពោះខោនធីខ្លះ ផលប៉ះពាល់ទាំងនេះអាចមានភាពចាំបាច់។

## កំណត់សមត្ថភាពអង្គនិតិបញ្ញត្តិអនុម័តលើសេចក្តីព្រាងច្បាប់មួយចំនួន

### ច្បាប់បច្ចុប្បន្ន

***ថវិកា និងសេចក្តីព្រាងច្បាប់ផ្សេងៗទៀត។*** ជារៀងរាល់ឆ្នាំ អង្គនីតិបញ្ញត្តិ និងអភិបាលអនុម័តសេចក្តីព្រាងច្បាប់ថវិការដ្ឋ និងសេចក្តីព្រាងច្បាប់ដទៃទៀត។ សេចក្តីព្រាងច្បាប់ថវិកាអនុញ្ញាតឲ្យធ្វើការចំណាយថវិកាចេញពីកញ្ចប់ថវិកាទូទៅ និងគណនីដទៃទៀតយ៉ាងច្រើនរបស់រដ្ឋ។ (កញ្ចប់ថវិកាទូទៅ គឺជាគណនីប្រតិបត្តិការដ៏សំខាន់របស់រដ្ឋដែលផ្តល់ថវិកាដល់វិស័យអប់រំ សុខភាព សេវាសង្គមកិច្ច ពន្ធនាគារ និងកម្មវិធីដទៃទៀត)។ ជាទូទៅ សំឡេងឆ្នោតភាគច្រើនរបស់សភាទាំងពីរនៃអង្គនីតិបញ្ញត្តិ (ព្រឹទ្ធសភា និង សភា) គឺតម្រូវឲ្យមានសម្រាប់ការអនុម័តសេចក្តីព្រាងច្បាប់ថវិកា និងសេចក្តីព្រាងច្បាប់ដទៃទៀតយ៉ាងច្រើន។ ក៏ប៉ុន្តែ សំឡេងឆ្នោតពីរភាគបីនៅក្នុងសភាទាំងពីរ គឺតម្រូវឲ្យមានដើម្បីតំឡើងពន្ធដាររបស់រដ្ឋ។

ជាផ្នែកមួយនៃដំណើរការធម្មតារបស់ពួកគេ សម្រាប់ពិចារណាទៅលើច្បាប់ថ្មីៗ អង្គនីតិបញ្ញត្តិ និងអភិបាលធ្វើការពិនិត្យមើលឡើងវិញ លើការប៉ាន់ប្រមាណពីផលប៉ះពាល់នានារបស់ច្បាប់ដែលបានស្នើឡើងនីមួយៗ ទៅលើការចំណាយ និងប្រាក់ចំណូលរបស់រដ្ឋ។ នៅពេលរដ្ឋធម្មនុញ្ញមិនតម្រូវឲ្យ រដ្ឋកំណត់ពីវិធីដែលត្រូវផ្តល់ថវិកាដល់ច្បាប់ថ្មីនីមួយៗ នោះនឹងមានការតម្រូវថា គម្រោងថវិការួមរបស់រដ្ឋត្រូវតែមានតុល្យភាព។ ជាក់លាក់ជាងនេះទៅទៀត នៅក្នុងឆ្នាំនីមួយៗ នៅពេលរដ្ឋ អនុម័តគម្រោងថវិការបស់ខ្លួន រដ្ឋត្រូវតែបង្ហាញថា ប្រាក់ចំណូលក្នុងកញ្ចប់ថវិកាទូទៅដែលបានប៉ាន់ប្រមាណ នឹងឆ្លើយតប ឬលើសពីការចំណាយនៅក្នុងកញ្ចប់ថវិកាទូទៅដែលបានអនុម័តនោះ។

### សេចក្តីស្នើច្បាប់

***កំណត់សមត្ថភាពរបស់អង្គនីតិបញ្ញត្តិក្នុងការបង្កើនការចំណាយរបស់រដ្ឋ។*** វិធានការនេះតម្រូវឲ្យអង្គនីតិបញ្ញត្តិ បង្ហាញពីរបៀបដែលសេចក្តីព្រាងច្បាប់មួយចំនួនដែលបង្កើនការចំណាយរបស់រដ្ឋលើសពី $25លាន នៅក្នុងឆ្នាំសារពើពន្ធណាមួយនឹងត្រូវសងដោយការកាត់បន្ថយការចំណាយ កំណើនប្រាក់ចំណូល ឬការរួមបញ្ចូលគ្នាទាំងពីរនេះ។ លក្ខខណ្ឌតម្រូវ ត្រូវអនុវត្តចំពោះសេចក្តីព្រាងច្បាប់ទាំងឡាយ ដែលបង្កើតក្រសួង ឬកម្មវិធីថ្មីៗរបស់រដ្ឋ ពង្រីកក្រសួង ឬកម្មវិធីបច្ចុប្បន្នរបស់រដ្ឋ ឬ បង្កើតកម្មវិធីក្នុងមូលដ្ឋានដែលផ្តល់សិទ្ធិដោយរដ្ឋ។ ការលើកលែងពីលក្ខខណ្ឌតម្រូវទាំងនេះ គឺសម្រាប់សេចក្តីព្រាងច្បាប់ទាំងឡាយ ដែល អនុញ្ញាតឲ្យមានការចំណាយតែមួយលើកសម្រាប់ក្រសួង ឬកម្មវិធីមួយរបស់រដ្ឋ ដោយសារតែកំណើនបន្ទុកការងារ ឬប្រាក់ទ្រទ្រង់ជីវភាព ផ្តល់ការផ្គត់ផ្គង់ថវិកាដែលតម្រូវដោយច្បាប់សហព័ន្ធ ឬបង្កើនប្រាក់ខែ ឬប្រាក់សំណងដទៃទៀតដល់និយោជិករដ្ឋ ស្របទៅតាម កិច្ចព្រមព្រៀងចចារួមគ្នា។ វិធានការនេះក៏លើកលែងដល់សេចក្តីព្រាងច្បាប់នានា ដែលស្តារឡើងវិញនូវថវិកាសម្រាប់កម្មវិធីរបស់រដ្ឋ ដែលត្រូវបាន

សំណើប្រជាមតិ **31** គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្ដួចផ្ដើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** (ត)

កាត់បន្ថយដើម្បីជួយធ្វើឲ្យគម្រោងថវិការបស់រដ្ឋមានតុល្យភាព នៅក្នុងឆ្នាំណាមួយបន្ទាប់ពីឆ្នាំ 2008–09 ផងដែរ។

***កំណត់សមត្ថភាពរបស់អង្គនីតិបញ្ញត្តិក្នុងការបន្ថយប្រាក់ចំណូលរបស់រដ្ឋ។*** វិធានការនេះក៏តម្រូវផងដែរ ឲ្យអង្គនីតិបញ្ញត្តិបង្ហាញពីរបៀបដែលត្រូវចំណាយទៅលើសេចក្ដីព្រាងច្បាប់នានា ដែលបន្ថយពន្ធរដ្ឋ ឬប្រាក់ចំណូលដទៃទៀតលើសពី $25 លាន នៅក្នុងឆ្នាំសារពើពន្ធណាមួយ ជាមួយគ្នានឹងការកាត់បន្ថយការចំណាយ កំណើនប្រាក់ចំណូល ឬ ការរួមបញ្ចូលគ្នាទាំងពីរនេះ។

***កែប្រែនៅពេលដែលអង្គនីតិបញ្ញត្តិអាចអនុម័តសេចក្ដីព្រាងច្បាប់នានា។*** វិធានការនេះធ្វើការកែប្រែផ្សេងៗ ដែលអាចធ្វើឲ្យប៉ះពាល់នៅពេលដែល អង្គនីតិបញ្ញត្តិអាចធ្វើការអនុម័តសេចក្ដីព្រាងច្បាប់នានា។ ឧទាហរណ៍ វិធានការនេះ តម្រូវឲ្យអង្គនីតិបញ្ញត្តិធ្វើសេចក្ដីព្រាងច្បាប់ និងធ្វើវិសោធនកម្មទៅលើសេចក្ដីព្រាងច្បាប់ទាំងនោះ ដោយធ្វើការផ្សព្វផ្សាយទៅដល់សាធារណជន យ៉ាងតិចបំផុតបីថ្ងៃនៅមុនពេលបោះឆ្នោតអនុម័តសេចក្ដីព្រាងច្បាប់ទាំងនោះ (លើកលែងតែសេចក្ដីព្រាងច្បាប់ជាក់លាក់មួយចំនួនដែលឆ្លើយតបទៅនឹងគ្រោះធម្មជាតិ ឬការវាយប្រហារភេរវកម្មប៉ុណ្ណោះ)។

## ឥទ្ធិពលសារពើពន្ធ

វិធានការនេះ នឹងធ្វើឲ្យមានការលំបាកកាន់តែខ្លាំងចំពោះអង្គនីតិបញ្ញត្តិ ក្នុងការអនុម័តច្បាប់មួយចំនួនដែលបង្កើនការចំណាយរបស់រដ្ឋ ឬបន្ថយប្រាក់ចំណូលរបស់រដ្ឋ។ ការរឹតត្បិតសមត្ថភាពរបស់អង្គនីតិបញ្ញត្តិតាមមធ្យោបាយនេះ អាចធ្វើឲ្យថវិការបស់រដ្ឋដែលចំណាយទៅលើសេវាសាធារណៈកាន់តែតិចជាងមុន- ឬពន្ធ និងថ្លៃសេវាឡើងកាន់តែខ្ពស់- បើមិនដូច្នេះទ វានឹងកើតមានករណីបែបនេះ។ ដោយសារតែផលប៉ះពាល់នៃសារពើពន្ធក្នុងផ្នែកនៃវិធានការនេះ ពឹងផ្អែកទៅលើសេចក្ដីសម្រេចដោយអង្គនីតិបញ្ញត្តិនាពេលអនាគត ផលប៉ះពាល់នេះ គឺមិនអាចព្យាករណ៍ទុកមុនបានឡើយ ក៏ប៉ុន្តែវាអាចមានច្រើនតាមពេលវេលា។ ដោយសារតែរដ្ឋផ្ដល់ថវិកាយ៉ាងច្រើនដល់រដ្ឋបាលមូលដ្ឋាន ពួកគេក៏អាចនឹងរងការប៉ះពាល់ទៅតាមពេលវេលាផងដែរ។

## ពង្រឹងសមត្ថភាពអភិបាលរដ្ឋក្នុងការកាត់បន្ថយការចំណាយរបស់រដ្ឋ

### ច្បាប់បច្ចុប្បន្ន

ក្រោមសំណើប្រជាមតិលេខ 58 (2004) បន្ទាប់ពីសេចក្ដីព្រាងច្បាប់ថវិកាត្រូវបានអនុម័ត អភិបាលអាចប្រកាសស្ថានភាពអាសន្នផ្នែកសារពើពន្ធរបស់រដ្ឋបាន ប្រសិនបើគាត់កំណត់ច្បាស់ថា រដ្ឋកំពុងតែប្រឈមនឹងការធ្លាក់ចុះប្រាក់ចំណូលយ៉ាងច្រើន ឬការចំណាយហួសកម្រិត។ នៅពេលស្ថានភាពអាសន្នសារពើពន្ធ ត្រូវបានប្រកាស អភិបាលរដ្ឋត្រូវកោះហៅអង្គនីតិបញ្ញត្តិឲ្យបើកសម័យប្រជុំពិសេស និងស្នើសុំឲ្យមានចំណាត់ការផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពអាសន្នសារពើពន្ធនោះ។ អង្គនីតិបញ្ញត្តិមានពេលចំនួន 45 ថ្ងៃសម្រាប់ធ្វើការពិចារណាអំពីការឆ្លើយតបរបស់ខ្លួន។ ទោះបីជាយ៉ាងណា បច្ចុប្បន្ននេះ អំណាចរបស់អភិបាលរដ្ឋក្នុងការកាត់បន្ថយការចំណាយរបស់រដ្ឋនៅមានកម្រិត ទោះបីជាអង្គនីតិបញ្ញត្តិមិនចាត់វិធានការនៅក្នុងអំឡុងពេល 45 ថ្ងៃក៏ដោយ។

### សេចក្ដីស្នើច្បាប់

***អនុញ្ញាតឲ្យអភិបាលរដ្ឋកាត់បន្ថយការចំណាយនៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។*** ស្ថិតក្រោមវិធានការនេះ ប្រសិនបើអង្គនីតិបញ្ញត្តិ មិនអនុម័តច្បាប់សម្រាប់ដោះស្រាយស្ថានភាពអាសន្នសារពើពន្ធក្នុងអំឡុងពេល 45 ថ្ងៃទេ អភិបាលអាចកាត់បន្ថយការចំណាយមួយចំនួនក្នុងកញ្ចប់ថវិកាទូទៅ។ អភិបាលមិនអាចកាត់បន្ថយការចំណាយដែលតម្រូវដោយរដ្ឋធម្មនុញ្ញ ឬច្បាប់សហព័ន្ធបានឡើយ ដូចជាការចំណាយរបស់សាលារៀនភាគច្រើន សេវាបំណុល ប្រាក់សោធននិវត្តន៍ និងការចំណាយមួយចំនួនទៀតសម្រាប់កម្មវិធីនានាខាងសុខភាពនិងសេវាសង្គម។ (ប្រភេទចំណាយទាំងនេះ មានទំហំមួយភាគធំនៃការចំណាយក្នុងកញ្ចប់ថវិកាទូទៅ។) ទឹកប្រាក់សរុបនៃការកាត់បន្ថយ មិនអាចលើសពីទឹកបាក់ដែលចាំបាច់សម្រាប់ធ្វើឲ្យគម្រោងថវិកាមានតុល្យភាពឡើយ។ អង្គនីតិបញ្ញត្តិ អាចមានសិទ្ធិបដិសេធរាល់ ឬផ្នែកនៃការកាត់បន្ថយបានតាមរយៈសំឡេងឆ្នោតគាំទ្រពីរភាគបី នៅក្នុងសភាទាំងពីររបស់ខ្លួន។

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 31, សូមអានទំព័រ 84.*

សំណើប្រជាមតិ
# 31 គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** **(ត)**

31

## ឥទ្ធិពលសារពើពន្ធ

ការពង្រីកសមត្ថភាពរបស់អភិបាល ក្នុងការកាត់បន្ថយការចំណាយ អាចធ្វើឲ្យការចំណាយរួមរបស់រដ្ឋធ្លាក់ចុះទាបជាងការដែលមិនបានធ្វើអ្វីសោះ។ ផលប៉ះពាល់ផ្នែកសារពើពន្ធនៃការផ្លាស់ប្តូរនេះ គឺមិនអាចព្យាករណ៍បានទេ ក៏ប៉ុន្តែអាចមានចំនួនច្រើនក្នុងឆ្នាំមួយចំនួន។ គម្រោងថវិការបស់ រដ្ឋបាលមូលដ្ឋាន ក៏ទទួលរងផលប៉ះពាល់ពីការចំណាយទាបរបស់រដ្ឋនេះផងដែរ។

## ផ្លាស់ប្តូរថវិកាសាធារណៈ និងនិតិវិធីមើលគ្រប់គ្រង

## សេចក្តីស្នើច្បាប់

***កែប្រែដំណើរការគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋទៅជាដំណើការរយៈពេលពីរឆ្នាំ។*** វិធានការនេះកែប្រែដំណើរការគម្រោងថវិការដ្ឋ ពីដំណើរការរយៈពេលមួយឆ្នាំ (មួយឆ្នាំម្តង) ទៅជាដំណើរការរយៈពេលពីរឆ្នាំ (ពីរឆ្នាំម្តង)។ រៀងរាល់ពីរឆ្នាំម្តង ដោយចាប់ផ្តើមនៅក្នុងឆ្នាំ 2015 តទៅ អភិបាលរដ្ឋ អាចបញ្ជូនសំណើគម្រោងថវិកាសម្រាប់ឆ្នាំសារពើពន្ធពីពីរឆ្នាំបន្ទាប់។ ឧទាហរណ៍ ក្នុងខែមករា ឆ្នាំ 2015 អភិបាលនឹងស្នើសុំគម្រោងថវិកាសម្រាប់ឆ្នាំសារពើពន្ធនោះដោយចាប់ផ្តើមនៅក្នុងខែកក្កដា ឆ្នាំ 2015 និងឆ្នាំសារពើពន្ធចាប់ផ្តើមក្នុងឆ្នាំ 2016។ រៀងរាល់ពីរឆ្នាំម្តង ដោយចាប់ផ្តើមនៅក្នុងឆ្នាំ 2016 អភិបាលអាចបញ្ជូនបច្ចុប្បន្នភាពគម្រោងថវិកាដែលបានស្នើឡើង។ វិធានការនេះ មិនកែប្រែកាលកំណត់នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្នក្នុងការអនុម័តសេចក្តីព្រាងច្បាប់ថវិកានៅថ្ងៃទី 15 ខែមិថុនាឡើយ។

***កំណត់រយៈពេលជាក់លាក់សម្រាប់ការត្រួតពិនិត្យដោយអង្គនីតិបញ្ញត្តិទៅលើកម្មវិធីសាធារណៈ។*** បច្ចុប្បន្ននេះ អង្គនីតិបញ្ញត្តិត្រួតពិនិត្យ និងពិនិត្យមើលឡើងវិញទៅលើសកម្មភាពនានារបស់រដ្ឋ និងកម្មវិធីក្នុងមូលដ្ឋានក្នុង ពេលវេលាផ្សេងៗគ្នា នៅក្នុងអំឡុងអាណត្តិពីរឆ្នាំរបស់ខ្លួន។ វិធានការនេះ តម្រូវឲ្យអង្គនីតិបញ្ញត្តិរក្សាផ្នែកមួយនៃអាណត្តិពីរឆ្នាំរបស់ខ្លួន-ដោយចាប់ផ្តើមនៅក្នុងខែកក្កដានៃឆ្នាំទីពីរនៃអាណត្តិនោះ សម្រាប់ធ្វើការត្រួតពិនិត្យ និងពិនិត្យមើលឡើងវិញទៅលើកម្មវិធីសាធារណៈនានា។ កាន់តែជាក់លាក់ទៅទៀត វិធានការនេះ តម្រូវឲ្យអង្គនីតិបញ្ញត្តិបង្កើតដំណើរការ និងប្រើប្រាស់ដំណើរការនេះ ដើម្បីពិនិត្យមើលឡើងវិញទៅលើកម្មវិធីនីមួយៗដែលរដ្ឋផ្តល់ថវិកា - មិនថាកម្មវិធីនោះត្រូវបានគ្រប់គ្រងដោយរដ្ឋ ឬ រដ្ឋបាលមូលដ្ឋាននោះទេ - យ៉ាងតិចបំផុតម្តងក្នុងរៀងរាល់ប្រាំឆ្នាំម្តង។ ក្នុងអំឡុងពេលធ្វើការត្រួតពិនិត្យ អង្គនីតិបញ្ញត្តិមិនអាចអនុម័តសេចក្តីព្រាងច្បាប់នានាបានឡើយ លើកលែងតែសេចក្តីព្រាងច្បាប់ទាំងនោះ (1) មានសុពលភាពភ្លាមៗ (ដែលជាទូទៅតម្រូវឲ្យមានសំឡេងឆ្នោតគាំទ្រពីរភាគបីនៅក្នុងសភាទាំងពីរ) ឬ (2) ប្រានចោលការជំទាស់របស់អភិបាល (ដែលតម្រូវឲ្យមានសំឡេងឆ្នោតគាំទ្រពីរភាគបី នៅក្នុងសភាទាំងពីរ)។

***ដាក់លក្ខខណ្ឌតម្រូវទៅលើការរៀបចំគម្រោងថវិកាថ្មីរបស់រដ្ឋ និងរដ្ឋបាលមូលដ្ឋាន។*** បច្ចុប្បន្ននេះ រដ្ឋ និងរដ្ឋបាលមូលដ្ឋាន មានភាពបត់បែនបានយ៉ាងទូលាយ ក្នុងការកំណត់អំពីរបៀបវាយតម្លៃទៅលើដំណើរការរបស់កម្មវិធីសាធារណៈរបស់ពួកគេ។ វិធានការនេះដាក់លក្ខខណ្ឌតម្រូវទូទៅមួយចំនួនសម្រាប់រដ្ឋ និងរដ្ឋបាលមូលដ្ឋាន ឲ្យដាក់បញ្ចូលចំណុចថ្មីៗទៅក្នុងគម្រោងថវិការរបស់ខ្លួន។ ជាក់លាក់ជាងនេះទៅទៀត រដ្ឋាភិបាលត្រូវវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីរបស់ខ្លួន និងបរិយាយអំពីរបៀបដែលគម្រោងថវិការបស់ខ្លួនបំពេញទៅតាមគោលបំណងផ្សេងៗ។ រដ្ឋ និងរដ្ឋបាលមូលដ្ឋានត្រូវរាយការណ៍ពីភាពរីកចម្រើនរបស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងគោលបំណងទាំងនោះ។

## ឥទ្ធិពលសារពើពន្ធ

រដ្ឋ និងរដ្ឋបាលមូលដ្ឋាន ប្រឈមនឹងកំណើនខ្ពង់ចំណាយ ក្នុងការរៀបចំប្រព័ន្ធសម្រាប់អនុវត្តលក្ខខណ្ឌតម្រូវក្នុងការធ្វើគម្រោងថវិកាថ្មីៗ និងសម្រាប់គ្រប់គ្រងតម្រូវការវាយតម្លៃថ្មីៗ។ ការចំណាយទាំងនេះមានលក្ខណៈផ្សេងគ្នាដោយផ្អែកទៅលើវិធីដែលរដ្ឋ និងមន្ត្រីមូលដ្ឋានបានអនុវត្តលក្ខខណ្ឌតម្រូវទាំងនោះ។ នៅក្នុងរដ្ឋទាំងមូល ការចំណាយនេះទំនងជាមាន ចំនួនចាប់ពី **រាប់លានរហូតដល់រាប់សិបលានដុល្លារជារៀងរាល់ឆ្នាំ** រក្សាភាពសមរម្យជាមធ្យមទៅតាមពេលវេលា។ តម្រូវការវាយតម្លៃនិងធ្វើគម្រោងថវិកាថ្មីៗទាំង

# គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។





នេះ អាចប៉ះពាល់ទៅលើការធ្វើសេចក្តីសម្រេចចិត្ត តាមមធ្យោបាយផ្សេងៗជាច្រើន មានដូចជា ការកំណត់អាទិភាពនៃការចំណាយឡើងវិញប្រសិទ្ធភាពនៃកម្មវិធី និងការវិនិយោគបន្ថែមទៅលើផ្នែកមួយចំនួននៃកម្មវិធីនានា។ ផលប៉ះពាល់នៃសារពើពន្ធទៅលើរដ្ឋាភិបាលគឺមិនអាចព្យាករណ៍ទុកមុនបានទេ។

## សេចក្តីសង្ខេបនៃវិធានការលើឥទ្ធិពលសារពើពន្ធ

ដូចបានសង្ខេបនៅក្នុងតារាងទី 2 វិធានការនេះនឹងបង្វែរប្រាក់ចំណូលមួយចំនួនរបស់រដ្ឋពីពន្ធលក់ដូរទៅឲ្យខោនធីទាំងឡាយដែលអនុវត្តផែនការក្នុងមូលដ្ឋាន។ ការបង្វែរនេះ នឹងធ្វើឲ្យធ្លាក់ចុះនូវប្រាក់ចំណូលរបស់រដ្ឋចំនួន $200 លាន ជារៀងរាល់ឆ្នាំ ស្របគ្នានឹងការកើនឡើងនូវការ ផ្តល់ថវិកាក្នុងចំនួនប្រហាក់ប្រហែលគ្នានេះ ទៅឲ្យរដ្ឋបាលមូលដ្ឋានក្នុងខោនធីទាំងនោះ។ ផលប៉ះពាល់សរុបនៃការកែប្រែផ្សេងរបស់រដ្ឋនិងការកែប្រែសារពើពន្ធក្នុងមូលដ្ឋាន នៃវិធានការនេះ នឹងពឹងផ្អែកទៅលើសេចក្តីសម្រេចចិត្តរបស់មន្ត្រីសាធារណៈក្នុងពេលអនាគត ហេតុដូច្នេះហើយ ទើបមានការលំបាកក្នុងការព្យាករណ៍។ សម្រាប់រយៈពេលវែង ការកែប្រែផ្សេងៗទៅលើចំណាយ និងប្រាក់ចំណូលរបស់រដ្ឋ និងរដ្ឋបាលមូលដ្ឋានអាចនឹងមានចំនួនច្រើនលើសពី $200 លាន ផ្លាស់ប្តូរនៃប្រាក់ចំណូលពន្ធលក់ចេញដូចបានពិភាក្សាខាងលើ។

**តារាងទី 2**
**ឥទ្ធិពលសារពើពន្ធសំខាន់ៗនៃសំណើប្រជាមតិលេខ 31**

| | រដ្ឋាភិបាលរដ្ឋ | រដ្ឋបាលមូលដ្ឋាន |
|---|---|---|
| **ការអនុញ្ញាត និង ផ្តល់មូលនិធិសំរាប់ផែនការរដ្ឋបាលមូលដ្ឋាន** | | |
| ផ្តល់មូលនិធិសំរាប់ផែនការនានា | $200 លានកាត់បន្ថយចំណូលប្រចាំឆ្នាំ។ | $200 លានកំណើនប្រចាំឆ្នាំសំរាប់រដ្ឋបាលមូលដ្ឋាន ក្នុងខោនធីនានាដែលអភិវឌ្ឍន៍ផែនការ។ |
| ប្រសិទ្ធិភាពនៃផែនការថ្មី | មិនអាចប៉ាន់ស្មានបានជាមុន តែមានសក្តានុពលសំខាន់។ | មិនអាចប៉ាន់ស្មានបានជាមុន តែមានសក្តានុពលសំខាន់នៅក្នុងខោនធីខ្លះ។ |
| **កំណត់សមត្ថភាពអង្គនិតិបញ្ញត្តិអនុម័តសេចក្តីព្រាងច្បាប់មួយចំនួន** | មានសក្តានុពលបន្ទាបការចំណាយ—ឬប្រាក់ចំណូលខ្ពស់ —ផ្អែកលើសកម្មភាពរបស់អង្គនិតិបញ្ញត្តិនាអនាគត។ | មានសក្តានុពលប្តូរមូលនិធិរបស់រដ្ឋសំរាប់កម្មវិធីតាមមូលដ្ឋានផ្អែកលើសកម្មភាពរបស់អង្គនិតិបញ្ញត្តិ។ |
| **ពង្រឹងសមត្ថភាពអភិបាលរដ្ឋក្នុងការកាត់បន្ថយការចំណាយរបស់រដ្ឋ។** | មានសក្តានុពលបន្ទាបការចំណាយក្នុងឆ្នាំខ្លះៗ។ | មានសក្តានុពលទទួលមូលនិធិរដ្ឋតិចក្នុងឆ្នាំខ្លះៗ។ |
| **ផ្លាស់ប្តូរថវិកាសាធារណៈ និងនិតិវិធីមើលគ្រប់គ្រង។** | | |
| តំលៃសំរាប់ការអនុវត្តន៍ | មានសក្តានុពលប្រែប្រួលប្រចាំឆ្នាំពីមួយលានទៅរាប់សិបលានដុល្លារនាពេលណាមួយ។ | មានសក្តានុពលប្រែប្រួលប្រចាំឆ្នាំពីមួយលានទៅរាប់សិបលានដុល្លារនាពេលណាមួយ។ |
| ប្រសិទ្ធិភាពនៃការតំរូវថ្មី | មិនអាចប៉ាន់ស្មានបានជាមុន។ | មិនអាចប៉ាន់ស្មានបានជាមុន។ |

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 31, សូមអានទំព័រ 84.*

# សំណើប្រជាមតិ 31 គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 31 ★

ក្នុងកាលៈទេសៈល្អ និងមិនល្អ រដ្ឋកាលីហ្វ័រនីញ៉ាជារដ្ឋមួយមានឱនភាពថវិកាយូរមកហើយ ជាមួយនឹងអ្នកនយោបាយចំណាយប្រាក់ច្រើនជាងប្រាក់ចំណូលដែលរដ្ឋរកបាន—ហើយប្រាក់ភាគច្រើនខាតបង់ឥតប្រយោជន៍ លើការរំលោភ និងការខ្ចីលើសកំណត់។ ជារឿយៗ ថវិកាទាំងអស់អាស្រ័យលើឥទ្ធិពលផលប្រយោជន៍ពិសេសជាជាងប្រាក់ចំណូលដែលអ្នករស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាចង់រកបាន។ សំណើប្រជាមតិលេខ 31 បង្ខំឲ្យអ្នកនយោបាយក្នុងរដ្ឋនេះជាចុងក្រោយរស់នៅតាមលទ្ធភាពរបស់ពួកគេ ហើយវាផ្តល់ដល់អ្នកបោះឆ្នោត និងអ្នកបង់ពន្ធនូវព័ត៌មានសំខាន់ៗដើម្បីធ្វើឲ្យអ្នកនយោបាយទទួលខុសត្រូវ។

សវនកររបស់រដ្ឋដែលមិនលម្អៀងបានរាយការណ៍នៅក្នុងការធ្វើសវនកម្មរបស់ភ្នាក់ងារជាច្រើនរបស់រដ្ឋចន្លោះពីឆ្នាំ 2003 ដល់ឆ្នាំ 2010 ថារដ្ឋគួរអាចបានសន្សំប្រាក់ពីអ្នកបង់ពន្ធនូវទឹកប្រាក់ប្រហែល $1.2 មួយរយពីរកោដិដុល្លារ ប្រសិនបើសំណើផ្ទាល់របស់សវនករសំរាប់ធ្វើកំណែទម្រង់ប្រតិបត្តិការ និងបង្កើនប្រសិទ្ធិភាព ត្រូវបានអនុម័ត។ កិច្ចខិតខំប្រឹងប្រែងថ្មីៗនេះ ដើម្បីបង្កើតប្រពន្ធគ្រប់គ្រងករណីតុលាការរួម ដែលអ្នកបង់ពន្ធបានចំណាយលើសពី $500 លានដុល្លារអាមេរិក  លើសពី $200 លានដុល្លារ លើសពីកញ្ចប់ថវិកា ដើម្បីភ្ជាប់តែខោនធី 7 ក្នុង ចំណោមខោនធីទាំង 58 មុនពេលត្រូវបានគេបោះបង់ចោល។

សំណើប្រជាមតិលេខ 31 ទាមទារឲ្យមានថវិកាដែលមានតុល្យភាពពិតប្រាកដមួយ។ វាបញ្ឈប់រាប់ពាន់លានដុល្លារនៃការចំណាយដោយគ្មានការពិនិត្យជាសាធារណៈ ឬការពិនិត្យរបស់ប្រជាពលរដ្ឋ។ ប្រសិនបើយើងមិនអនុម័តសំណើប្រជាមតិលេខ 31 បានទេនោះ ប្រាក់រាប់រយលានដុល្លាររៀងរាល់ឆ្នាំនឹងបន្តចំណាយឥតប្រយោជន៍ដែលការចំណាយនោះគួរប្រើទៅសំរាប់សាលាតាមមូលដ្ឋាន ការអនុវត្តច្បាប់ និងអាទិភាពរបស់សហគមន៍ផ្សេងៗទៀត។

សំណើប្រជាមតិលេខ 31 មិនបានតម្លើងពន្ធ តម្លើងថ្លៃលើអ្នកបង់ពន្ធ ឬបង្កើតការិយាធិបតេយ្យរដ្ឋាភិបាលថ្មីនោះទេ។ សំណើប្រជាមតិលេខ 31 នេះ បង្ហាញយ៉ាងច្បាស់ថា ខថែងនានារបស់ខ្លួនគួរត្រូវបានអនុវត្តគួបផ្សំ នឹងប្រភពដែលមានស្រាប់—ហើយសំណើនេះក៏នឹងសន្សំប្រាក់បានដោយបង្វិលប្រាក់ពន្ធទៅទីក្រុង និងខោនធីនានានោះវិញ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 31 នឹង៖

- *បង្កើនការផ្តល់មតិសាធារណៈជន និងតម្លាភាពសាធារណៈ*—បញ្ឈប់រដ្ឋមិនឲ្យអនុម័តការចំណាយថវិកាដោយគ្មានការពិនិត្យជាសាធារណៈ។ ពេលបច្ចុប្បន្នថវិកា ជាតិមិនមានតម្លាភាពពិតប្រាកដទេ ឬការតម្រូវឲ្យមានរបាយការណ៍សាធារណៈទេ។ សំណើប្រជាមតិលេខ 31 តម្រូវឲ្យរដ្ឋាភិបាលរដ្ឋធ្វើសំណើថវិការដ្ឋឲ្យបានសមរម្យដើម្បីធ្វើការពិនិត្យជាសាធារណៈ *យ៉ាងតិចបំផុត* បីថ្ងៃ មុនពេលអ្នកតែងច្បាប់បោះឆ្នោតលើសំណើនេះ។
- *កំណត់ឲ្យមានការពិនិត្យសារពើពន្ធ និងលក្ខខណ្ឌលើ ការចំណាយថ្មីរបស់រដ្ឋាភិបាល*—សំណើប្រជាមតិលេខ 31 ហាមបាម្ររដ្ឋមិនឲ្យផ្តល់ថវិកាចំណាយថ្មីណាមួយ ឬបន្ថយប្រាក់ចំណូលឲ្យលើសពីទឹកប្រាក់ចំនួន $25 លានដុល្លារ ដោយមិនមានការបញ្ជាក់ពីប្រភពថវិកាជាមុននោះទេ។
- *បង្កើនការគ្រប់គ្រង និងភាពបត់បែនក្នុងមូលដ្ឋាន*—ថវិការដ្ឋប្រចាំឆ្នាំ 2012 បានដកចេញពីរដ្ឋាភិបាលក្នុងមូលដ្ឋានចំនួន$1.4 មួយរយបួនកោដិដុល្លារ។ សំណើប្រជាមតិលេខ 31 សងប្រាក់ចំនួនដល់ទៅ$200 លានដុល្លារ ទៅឲ្យរដ្ឋាភិបាលមូលដ្ឋានដើម្បីប្រើប្រាស់សម្រាប់អទិភាពក្នុងមូលដ្ឋាន. វាក៏ផ្តល់ដល់ទីក្រុង ខោនធីនិងសាលានៅតាមមណ្ឌលនូវភាពបត់បែននិងអំណាចកាន់តែច្រើនទៀតដើម្បីរៀបចំសេវាកម្មដែលជួយកែលម្អលទ្ធផល និងឆ្លើយតបតាមតម្រូវការក្នុងមូលដ្ឋាន។
- *តម្រូវការអនុវត្ត និងលទ្ធផលក្នុងគំរោងថវិកា*—តម្រូវឲ្យរដ្ឋ និងរដ្ឋាភិបាលក្នុងមូលដ្ឋានត្រូវផ្តោតអារម្មណ៍លើថវិកាស្តីពីការសម្រេចបានលទ្ធផល ដែលអាចវាស់បាន និងផ្តល់ទំនួលខុសត្រូវ ដោយតម្រូវឲ្យអង្គនីតិ បញ្ញត្តរដ្ឋ និងរដ្ឋាភិបាលក្នុងមូលដ្ឋានផ្សព្វផ្សាយពីរបាយការណ៍អនុវត្តជាសាធារណៈឲ្យបានទៀងទាត់ និងធ្វើការវាយតម្លៃកម្មវិធីឲ្យមានប្រសិទ្ធភាពមុនពេលធ្វើការសម្រេចចិត្តចំណាយបន្ថែមទៀត។
- *តម្រូវឲ្យមានការពិនិត្យការអនុវត្តនូវកម្មវិធីនានារបស់រដ្ឋាភិបាលរដ្ឋ*—ទាមទារឲ្យមានកម្មវិធីរដ្ឋាភិបាលរដ្ឋទាំងអស់ត្រូវតែបានត្រួតពិនិត្យជាសាធារណៈលើការអនុវត្ត ដើម្បីស្វែងរកមធ្យោបាយកែលម្អលទ្ធផល—ឬប្តូរការផ្តល់ថវិកាទៅឲ្យកម្មវិធីដែលកាន់តែមានសមត្ថភាពនិងមានប្រសិទ្ធភាព។
- *តម្រូវការថវិការដ្ឋរយៈពេលពីរឆ្នាំ*—ហាមអ្នកនយោបាយនានាមិនឲ្យអនុម័តការបន្លំខាងថវិកាក្នុងរយៈពេលខ្លីទេ។ ទាមទារឲ្យអ្នកតែងច្បាប់ ឲ្យបង្កើតដំណោះស្រាយសារពើពន្ធរយៈពេលវែង។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 31 ។ កំណត់ការចំណាយរបស់រដ្ឋាភិបាល—បង្កើនសេចក្តីទុកចិត្តសាធារណៈលើ ថវិការដ្ឋ។

**HON. CRUZ REYNOSO**
ក្រសួងយុត្តិធម៌កាលីហ្វ័រញ៉ា (ចូលនិវត្តន៍

**HON. DELAINE A. EASTIN**
អតីតស្នងការសិក្សាសាធារណៈ

**PROF. JAMES FISHKIN, Ph.D.**
សកលវិទ្យាល័យ Stanford

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 31 ★

សំណើប្រជាមតិលេខ 31 មិនអាចធ្វើឱ្យមានតុល្យភាពថវិកាទេ, បង្កើនការផ្តល់មតិសាធារណៈជន ឬ បំពេញការងារឱ្យកាន់តែប្រសើរឡើង។

តាមពិតទៅ ប្រសិនបើសំណើប្រជាមតិលេខ 31 បានធ្វើតាមការសន្យានៃការអះអាងរបស់ខ្លួន នោះយើងនឹងគាំទ្រសំណើ នោះ។ ប៉ុន្តែសំណើប្រជាមតិនេះ មិនបានធ្វើដូច្នេះទេ។ ជំនួសមកវិញសំណើប្រជាមតិនេះបន្ថែមច្បាប់ លក្ខខណ្ឌ និងការទាមទារថ្មីៗ ដែលបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋ កាលីហ្វ័រនីញ៉ា។ វាធ្វើឲ្យរដ្ឋាភិបាលមានការទើសទែងច្រើន ការចំណាយ ច្រើនហើយ ដំណើរការយឺតនិងមានប្រសិទ្ធភាពកាន់តែតិច។ ខថែងទាំងនេះ មានការភណ្ឌច្រឡំ និងមានភាពមិនច្បាស់លាស់ច្រើនដែលត្រូវចំណាយពេលបន្តរាប់ឆ្នាំសម្រាប់តុលាការធ្វើការជ្រើសរើស តើសំណើនេះមានអត្ថន័យដូចម្តេច។

សំណើប្រជាមតិលេខ 31 នឹងតំឡើងតំលៃ, បង្កើនការត្រួតត្រាការិយាធិបតេយ្យច្រើន។

វាអនុញ្ញាតឱ្យអ្នកនយោបាយតាមមូលដ្ឋានច្រានចោល ឬកែប្រែច្បាប់នានាដែលគេមិនចូលចិត្ត, ធ្វើឱ្យអន្តរាយដល់ការការពារសំរាប់គុណភាពខ្យល់, សុខភាពសាធារណៈ, សុវត្ថិភាពដោយគ្មានការបោះឆ្នោតនៃពលរដ្ឋ។ សំណើប្រជាមតិលេខ 31 នឹងធ្វើឱ្យមានការលំបាកស្ទើរតែមិនអាចកាត់ពន្ធដារបាន ឬតំឡើងមូល និធិសំរាប់ការអប់រំ។

សំណើប្រជាមតិនេះហាមកាត់ពន្ធ លុះត្រាតែពន្ធផ្សេងត្រូវបានតំឡើង ឬកាត់កម្មវិធី និងទប់ស្កាត់ការតំឡើងក្នុងការផ្តល់មូលនិធិដល់សាលាលុះត្រាតែពន្ធផ្សេងត្រូវបានតំឡើង ឬកាត់កម្មវិធី។

សំណើប្រជាមតិលេខ 31 មានគុណវិប្បត្តិច្រើនណាស់ដែលសមាជិកជាច្រើននៃអង្គការធានាគាំទ្របានលាឈប់ក្នុងន័យតវ៉ាចំពោះការសំរេចចិត្តដាក់វាឲ្យអ្នកបោះឆ្នោត។

Bob Balgenorth អតីតសមាជិកគណៈកម្មការនៃមូលនិធិសកម្មភាព រដ្ឋកាលីហ្វ័រញ៉ាឆ្ពោះទៅមុខ ដែលជាអង្គការនៅក្រោយសំណើប្រជាមតិ 31 បាននិយាយថា "មានគុណវិបត្តិធ្ងន់ធ្ងរ...និងបន្តប៉ះពាល់ដល់រដ្ឋកាលីហ្វ័រញ៉ា។" នៅក្នុងសំបុត្រលាលែងរបស់គាត់ គាត់បាន និយាយថាគាត់ "អាក់អន់ចិត្តដែលថារដ្ឋកាលីហ្វ័រញ៉ាឆ្ពោះទៅមុខបានដាក់ហត្ថលេខាទៅឲ្យរដ្ឋលេខាធិការដោយគ្មានការកែតំរូវគុណវិបត្តិនៅក្នុងការផ្តួចផ្តើមនោះ។"

យើងមិនអាចបណ្តោយអោយមានការផ្តួចផ្តើមដែលមិនត្រឹមត្រូវនោះទេ។ បោះឆ្នោត ទេ លើសំណើប្រជាមតិ 31។

**ANTHONY WRIGHT,** នាយកប្រតិបត្តិ
ការទទួលបានសុខភាព កាលីហ្វ័រញ៉ា

**LACY BARNES,** អនុប្រធានជាន់ខ្ពស់
សហព័ន្ធគ្រូបង្រៀនរដ្ឋកាលីហ្វ័រញ៉ា

**LENNY GOLDBERG,** នាយកប្រតិបត្តិ
សមាគមកែទម្រង់ពន្ធដារ កាលីហ្វ័រញ៉ា



*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# សំណើប្រជាមតិ 31 គំរោងថវិការដ្ឋ។ រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ ការផ្តួចផ្តើមការកែប្រែរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ 31 ★

សំណើប្រជាមតិលេខ 31 សរសេរឡើងមិនច្បាស់លាស់សោះនិងមានភាពប្រទឹងប្រទាំងជាច្រើនដែលនាំឱ្យមានការប្តឹងប្តល់ផ្លូវច្បាប់ និងការភាន់ច្រឡំ វាមិនមែនកែទម្រង់ទេ។

យើងទាំងអស់គ្នាចង់កែលម្អ ប៉ុន្តែផ្ទុយមកវិញ សំណើប្រជាមតិលេខ 31 បន្ថែមការិយាធិបតេយ្យ និងបង្កើតបញ្ហាថ្មីៗ។ សំណើប្រជាមតិនេះបន្ថែមលក្ខខណ្ឌបន្តិចម្តងៗ និងកំណត់តម្រូវការតិចតួច ទុកឲ្យអ្នកការិយាធិបតេយ្យដែលមិនបានជាប់ឆ្នោត ធ្វើការសម្រេចចិត្តដូចជា ការកាត់ពន្ធត្រូវបានអនុញ្ញាត ឬកម្មវិធីនេះអាចផ្លាស់ប្តូរ—ការសម្រេចចិត្តដែលមានភាពច្របូកច្របល់ក្នុងតុលាការពីមួយឆ្នាំទៅមួយឆ្នាំ។ យើងត្រូវការកំណែទម្រង់ពិតប្រាកដ មិនត្រូវការមានបណ្តឹងច្រើនទេ។

សំណើប្រជាមតិលេខ 31 នឹងបង្វែរប្រាក់ចំនួន $200 លានដុល្លារពីការអប់រំ និងពីក្រសួងសំខាន់ៗទៀតដើម្បីជួយកម្មវិធីដកពិសោធន៍នានាតាមខោនធី។

ឥឡូវនេះ រដ្ឋស្ទើរតែមិនអាចបង់លើការចំណាយបានទេហើយថវិការបស់រដ្ឋភាគច្រើនចំណាយលើវិស័យអប់រំ។ ប៉ុន្តែវិធីនេះដកប្រាក់ចំនួន $200 លានដុល្លារក្នុងមួយឆ្នាំពីប្រាក់ចំណូលរបស់រដ្ឋចូលក្នុងគណនីពិសេសមួយដើម្បីចំណាយលើកម្មវិធីក្នុងខោនធីដែលជាការសាកល្បង។ នេះមិនមែនជាពេលយកប្រាក់ទៅ លេងល្បែងដែលវាគួរត្រូវបានចំណាយលើអាទិភាពចាំបាច់បំផុត។

សំណើប្រជាមតិលេខ 31 នឹងការពាររដ្ឋពីបង្កើនថវិកាសំរាប់ការអប់រំ លុះត្រាតែវាមានតំឡើងពន្ធ ឬកាត់កម្មវិធីផ្សេងៗទៀត—ទោះបីជាមានប្រាក់ ក៏ដោយ។

វាហាក់ដូចជាចម្លែក តាមពិតទៅសំណើប្រជាមតិលេខ 31 ការពាររដ្ឋពីការអនុវត្តកម្មវិធីកែលម្អទៅកម្មវិធីអប់រំ ឬការបង្កើនថវិកាដល់ សាលា បើទោះបីជារដ្ឋមានថវិកាធ្វើដូច្នេះក៏ដោយ លុះត្រាតែតម្លើងពន្ធ ឬកាត់បន្ថយកម្មវិធីផ្សេងៗ ទៀត។ ខចែងនេះអាចភ្ជាប់ចំណងការផ្តល់ថវិកាបន្ថែម ដល់សាលាសម្រាប់រយៈ ពេលជាច្រើនឆ្នាំ។

សំណើប្រជាមតិលេខ 31 នឹងការពាររដ្ឋពីបង្កើនថវិកាសំរាប់ការអប់រំ លុះត្រាតែវាមានតំឡើងពន្ធ ឬកាត់កម្មវិធីផ្សេងៗទៀត—ទោះបីជារដ្ឋមានថវិកាសល់លើសក៏ដោយ។

សភាពចម្រូងចម្រាស់នៃខចែងនៃពន្ធទាំងនេះ នឹងការពាររដ្ឋពីការកាត់ពន្ធមួយប្រសិនបើវាតម្លើងពន្ធមួយទៀត សូម្បីតែពេលមានថវិកាលើសក៏ដោយ—មិនថានេះជាបំណងការពាររដ្ឋពីការកាត់ពន្ធរបស់លោកអ្នកឬនៅក្នុង ករណីផ្សេង—ករណីធ្ងន់ធ្ងរ—ចំពោះការពង្រៀងច្បាប់ដោយធ្វេសប្រហែស។ សំណើប្រជាមិតលេខ 31 ធ្វើឲ្យបញ្ហានេះជាប់គាំងនៅក្នុងរដ្ឋធម្មនុញ្ញ។

សំណើប្រជាមតិលេខ 31 គំរាមកំហែងសុខភាពសាធារណៈ, គុណភាពទឹក, នឹងសុវត្ថិភាពសាធារណៈដោយអនុញ្ញាតឱ្យខោនធីច្រានចោល ឬកែឆ្នៃច្បាប់រដ្ឋសំខាន់ៗ។

រដ្ឋកាលីហ្វ័រនីញ៉ា បានជ្រើសរើសយកបទដ្ឋានទូទាំងរដ្ឋដើម្បីការពារសុខភាពសាធារណៈ ការពារការបំពុលនៃខ្យល់ និងទឹក ព្រមទាំងផ្តល់សុវត្ថិភាពដល់ប្រជាពលរដ្ឋរបស់ខ្លួន។ សំណើប្រជាមតិលេខ 31 មានខចែងមួយដែលអនុញ្ញាតឲ្យអ្នកនយោបាយក្នុងស្រុកកែប្រែ ឬលុបលើច្បាប់ទាំងនេះដោយគ្មានការបោះឆ្នោតរបស់ប្រជាជន និងដោយគ្មានវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការការពារការរំលោភបំពាន។

សំណើប្រជាមតិលេខ 31 នឹងអស់ថ្លៃប្រហែល រាប់សិបលានដុល្លាក្នុងមួយឆ្នាំៗ សំរាប់ដំណើរការបន្ថែមរបស់រដ្ឋាភិបាល និងការិយាធិបតេយ្យ—ធ្វើអ្វីដែលរដ្ឋាភិបាលគួរត្រូវធ្វើរួចទៅហើយ។

ការរៀបចំថវិកាដោយផ្អែកលើការអនុវត្តគឺជាពាក្យស្លោកមួយដែលពេញ និយមច្រើនជាងអ្វីផ្សេងៗទៀត។ ពីមុនត្រូវបានគេសាកល្បងជាច្រើនដងហើយ។ រឿងមួយដែលយើងដឹងនោះ គឺវាបង្កើនការចំណាយ។ ការធ្វើវិភាគសារពើពន្ធជាផ្លូវការដោយការិយាល័យអ្នកវិភាគអង្គនិតិបញ្ញត្តិមិនលម្អៀងនិយាយថា រដ្ឋាភិបាលនឹងបង្កើនការចំណាយឲ្យដល់ដប់លានដុល្លារក្នុងមួយឆ្នាំសម្រាប់ការអនុវត្តការរៀបចំថវិកាថ្មី ដោយគ្មានការធានាថាការរីកចម្រើននឹងមានលទ្ធផលទេ។ ការចំណាយជាក់លាក់ ប៉ុន្តែ លទ្ធផលមិនច្បាស់លាស់។

យើងទាំងអស់គ្នាចង់ធ្វើកំណែទម្រង់ ប៉ុន្តែសំណើប្រជាមតិលេខ 31 នឹងធ្វើឲ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរទៅ មិនមានអ្វីប្រសើរឡើយ។

ចូលរួមជាមួយយើង ដោយបោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 31។

**SARAH ROSE,** មន្ត្រីនាយកប្រតិបត្តិ
សម្ព័ន្ធអ្នកបោះឆ្នោតអភិរក្សកាលីហ្វ័រញ៉ា

**JOSHUA PECHTHALT,** ប្រធាន
សមាគមមន្ត្រីស្រាវជ្រាវសន្តិភាពកាលីហ្វ័រញ៉ា

**RON COTTINGHAM,** ប្រធាន
សមាគមមន្ត្រីស្រាវជ្រាវសន្តិភាពកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 31 ★

"សំណើប្រជាមតិលេខ 31 បង្កើតឲ្យកាន់តែមានតម្លាភាព ការពិនិត្យមើលសាធារណៈ និងការត្រួតពិនិត្យដ៏ល្អលើរដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន។ វិធានការការទទួលខុសត្រូវរបស់រដ្ឋាភិបាលនេះនឹងការពារការថែរក្សាបរិស្ថាន និងការ ការពារអ្នកធ្វើការក្នុងពេលដែលធ្វើឲ្យច្បាស់ថាអ្នកបង់ពន្ធមិនត្រូវបានកេងប្រយោជន៍ ដោយក្រុមទទួលផលប្រយោជន៍ពិសេស និងក្រុមបញ្ចុះបញ្ចូល។"

—*Hon. Cruz Reynoso, តុលាការកំពូលកាលីហ្វ័រញ៉ា (ចូលនិវត្តន៍)*

"វាដល់ពេលដែលត្រូវបំភ្លឺចំពោះដំណើរការថវិការបស់រដ្ឋកាលីហ្វ័រញ៉ា - គ្មានការភ្ញាក់ផ្អើលនូវ-ឱនភាពថវិការាប់រយកោដិដុល្លារនោះទៀតទេ។ យើងត្រូវការកំណែទម្រង់ដែលនឹងមានប្រសិទ្ធិភាព មិនមែន គ្រាន់តែជាកិច្ចការធម្មតានោះទេ។"

—*Professor James Fishkin, សកលវិទ្យាល័យ Stanford*

"សំណើប្រជាមតិ 31 និងបន្ទុកការប៉ុនប៉ងរបស់រដ្ឋក្នុងការខ្ចី និងចំណាយ។ សំណើប្រជាមតិ 31 ផ្តល់នូវថវិកាលើកទឹកចិត្តដល់ រដ្ឋាភិបាលមូលដ្ឋាននិងសាលារៀនសហគមន៍ដោយផ្តោតលើការកែ លំអវិស័យអប់រំនិងបង្កើនសុវត្ថិភាពសាធារណៈ។ បោះឆ្នោតគាំទ្រលើសំណើប្រជាមតិ 31 គឺគាំទ្រដល់សាលារៀននិង កូនសិស្សនៅរដ្ឋកាលីហ្វ័រញ៉ា។"

—*Hon. Delaine Eastin, អតីតស្នងការរដ្ឋ ផ្នែកអប់រំសាធារណៈ*

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 31 នឹង ៖

- មិនតំឡើងពន្ធ ឬទាមទារឲ្យមានការបង្កើនការចំណាយរបស់រដ្ឋាភិបាលឡើយ។
- ការពាររដ្ឋាភិបាលរបស់រដ្ឋពីការចំណាយលុយដែលយើង មិនមាន។
- បន្ថែមតម្លាភាពទៅលើដំណើរការថវិកាដែលបច្ចុប្បន្នរៀបចំដោយបិទទ្វារ។
- បង្វែរការគ្រប់គ្រងនិងភាពបត់បែនកាន់តែច្រើនពីក្រុង Sacramento ទៅទីក្រុងនិងខោនធីនានា។
- ទាមទារឲ្យរដ្ឋាភិបាលរបស់រដ្ឋនិងរដ្ឋាភិបាលមូលដ្ឋានធ្វើការរាយការណ៍លទ្ធផលជាសាធារណៈមុនពេលចំណាយលុយច្រើនទៀត។

សូមពិនិត្យវិធានការដោយខ្លួនឯងតាមរយៈគេហទំព័រ *www.sos.ca.gov* និងជួយការពារការខាតបង់បន្ថែមទៀតនៅក្នុង ការចំណាយរបស់រដ្ឋាភិបាល។

សំណើប្រជាមតិ 31 បំពេញតាមមាត្រដ្ឋានខ្ពស់បំផុតនៃតម្រូវការការ ផ្លាស់ប្តូរនៃរដ្ឋធម្មនុញ្ញ។ វិធានការណ៍ត្រូវបានសរសេរយ៉ាងល្អ សមស្របតាមច្បាប់ ហើយនឹងពិតជាធ្វើឲ្យប្រសើរនូវដំណើរការថវិកា និងអភិបាលកិច្ចនៃរដ្ឋកាលីហ្វ័រញ៉ា។

**BILL HAUCK,** អតីតប្រធាន
គណៈកម្មការកែទម្រង់រដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា

សំណើប្រជាមតិ

# 32 វិភាគទានខាងនយោបាយ តាមរយៈការកាត់ពីប្រាក់ខែ។ វិភាគទានទៅឲ្យបេក្ខជន។ លក្ខន្តិកៈផ្តួចផ្តើម។

**ចំណងជើង និងសេចក្តីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

## វិភាគទានខាងនយោបាយ តាមរយៈការកាត់ពីប្រាក់ខែ។ វិភាគទានចំពោះបេក្ខជន។ លក្ខន្តិកៈផ្តួចផ្តើម។

- ដាក់កំរិតដល់សហជីព ពីការប្រើថវិកាកាត់ពីប្រាក់ខែ សំរាប់គោលបំណងនយោបាយ។ អនុវត្តទៅលើកំរិតការប្រើដូចគ្នា ចំពោះការកាត់ប្រាក់ខែ បើសិនមាន កាត់ដោយសារជីវកម្មឬអ្នកម៉ៅការឲ្យរដ្ឋាភិបាល។
- អនុញ្ញាតឲ្យនិយោជិកធ្វើវិភាគទានដោយស្ម័គ្រចិត្ត ទៅឲ្យគណកម្មាធិការនិយោជក-ឧបត្ថម្ភ ឬសហជីព បើសិនបានអនុញ្ញាតជាលាយល័ក្ខណ៍ អក្សររៀងរាល់ឆ្នាំ។
- ហាមឃាត់សហជីព និងសារជីវកម្ម ធ្វើវិភាគទានដោយផ្ទាល់ ឬមិនដោយផ្ទាល់ ទៅឲ្យបេក្ខជន និងគណកម្មាធិការ ត្រួតត្រាបេក្ខជន។
- ការចំណាយផ្សេងៗទៀតខាងនយោបាយ នៅតែមិនកំរិត រួមទាំងការចំណាយនៃសារជីវកម្ម ដែលមានចេញពីធនធាន មិនបានកំរិតដោយការហាមឃាត់នៃការកាត់ពីប្រាក់ខែ។
- កំរិតដល់អ្នកម៉ៅការឲ្យរដ្ឋាភិបាលធ្វើវិភាគទានដើម្បីជ្រើសរើសនាយកឬគណៈកម្មាធិការត្រួតត្រានាយក។

**សេចក្តីសង្ខេបនៃអ្នកវិភាគនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ៖**

- ការចំណាយបានកើនឡើង ចំពោះរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន—អាចនឹងហួសពី $1 លានជាប្រចាំឆ្នាំ—ដើម្បីប្រតិបត្តិ និងប្រព្រឹត្តតាមសេចក្តីដំរូវរបស់វិធានការ។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### សាវតារ

***ច្បាប់កំណែទម្រង់នយោបាយ។*** ច្បាប់កំណែទម្រង់នយោបាយរបស់រដ្ឋកាលីហ្វ័រញ៉ា ឆ្នាំ 1974 ជាការផ្តួចផ្តើមមួយដែលត្រូវបានសម្របសម្រួលដោយអ្នកបោះឆ្នោត ដែលបានបង្កើតដោយច្បាប់ហិរញ្ញវត្ថុការឃោសនា និងច្បាប់ប្រកាសផ្សាយរបស់រដ្ឋ។ ច្បាប់នេះ អនុវត្តចំពោះបេក្ខជនរដ្ឋ និងមូលដ្ឋាន វិធានការ និងមន្ត្រីបោះឆ្នោត ប៉ុន្តែមិនអនុវត្តចំពោះបេក្ខជន ឬមន្ត្រីសហព័ន្ធទេ។ គណៈកម្មការអនុវត្តនយោបាយយុត្តិធម៌របស់រដ្ឋ (FPPC) (1) ប្រតិបត្តិតម្រូវការនៃច្បាប់ រួមជាមួយការស៊ើបអង្កេតលើការបំពានងាយៗ និង (2) ផ្តល់ការណែនាំរដ្ឋបាលទៅសាធារណៈជនដោយការចេញនូវ ការណែនាំ និងគំនិតដែលទាក់ទងនឹងការបកស្រាយនៃច្បាប់របស់គណៈកម្មការអនុវត្តនយោបាយយុត្តិធម៌។

***ច្បាប់ហិរញ្ញវត្ថុសំរាប់ឃោសនាមូលដ្ឋាន។*** បន្ថែមទៅលើតម្រូវការដែលបានបង្កើតឡើងដោយច្បាប់ រដ្ឋាភិបាលមូលដ្ឋានមួយចំនួនមានតម្រូវការហិរញ្ញវត្ថុឃោសនា និងការចេញផ្សាយសម្រាប់បេក្ខជនមូលដ្ឋាន វិធានការបោះឆ្នោត និងមន្ត្រី។ បទបញ្ញត្តិទាំងនេះត្រូវបានបង្កើត និងប្រតិបត្តិដោយរដ្ឋាភិបាលមូលដ្ឋាន។

***ការចំណាយខាងនយោបាយ។*** បុគ្គល ក្រុម និងអាជីវកម្មជាច្រើនចំណាយថវិកាដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជនរដ្ឋ និងមូលដ្ឋាន ឬវិធានការបោះឆ្នោត។ ការចំណាយខាងនយោបាយនេះអាចមានទម្រង់ផ្សេងៗគ្នា រួមមានការធ្វើវិភាគទានថវិកាទៅដល់បេក្ខជន ឬគណៈកម្មាធិការ ការធ្វើវិភាគទានសេវាកម្មចំពោះការឃោសនា និងការបង្កើតការផ្សាយពាណិជ្ជកម្មដើម្បីទំនាក់ ទំនងនូវគំនិត។ នៅក្រោមច្បាប់ហិរញ្ញវត្ថុឃោសនារបស់រដ្ឋ ការចំណាយខាងនយោបាយមានបីប្រភេទ៖

- ***វិភាគទានខាងនយោបាយ។*** ជាទូទៅពាក្យ "វិភាគទាន" នយោបាយរួមមាន ការផ្តល់ថវិកា របស់របរ ឬសេវាកម្ម (1) ដោយផ្ទាល់ទៅបេក្ខជន (2) តាមសំណើរបស់បេក្ខជន ឬ (3) ទៅគណៈកម្មាធិការដែលប្រើប្រាស់ធនធានទាំងនេះដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬវិធានការឆ្នោត។ ច្បាប់បច្ចុប្បន្នកំណត់ចំនួននៃវិភាគទានខាងនយោបាយ ថា បុគ្គល ក្រុម និងអាជីវកម្មអាចផ្តល់ទៅបេក្ខជនរដ្ឋ (ឬទៅគណៈកម្មាធិការដែលផ្តល់ថវិកាទៅបេក្ខជនរដ្ឋ)។ ជាក់ស្តែង នៅឆ្នាំ 2012 បុគ្គល ក្រុម ឬអាជីវកម្មអាចធ្វើ វិភាគទានបានរហូតដល់ $26,000 ដុល្លារ ចំពោះបេក្ខជនម្នាក់ សម្រាប់អភិបាលរដ្ឋ និងរហូតដល់ $3,900 ដុល្លារចំពោះបេក្ខជនម្នាក់សម្រាប់ការិយាល័យនិតិបញ្ញត្តិ។ លើសពីនេះច្បាប់បច្ចុប្បន្នត្រូវការវិភាគទានខាងនយោបាយដើម្បីផ្សព្វផ្សាយទៅដល់មន្ត្រីបោះឆ្នោតរដ្ឋ ឬមូលដ្ឋាន។
- ***ការចំណាយឯករាជ្យ។*** ជាទូទៅ ប្រាក់ដែលបានចំណាយដើម្បីទំនាក់ទំនងការគាំទ្រ ឬការប្រឆាំងរបស់បេក្ខជន ឬវិធានការឆ្នោតត្រូវបានចាត់ទុកជាការចំណាយឯករាជ្យ ប្រសិនបើមូលនិធិត្រូវបានចំណាយតាមមធ្យោបាយដែលមិនបានសម្របសម្រួលជាមួយ (1) បេក្ខជន ឬ (2) គណៈកម្មាធិការដែលបានបង្កើតឡើងដើម្បីគាំទ្រ ឬប្រឆាំងនឹង បេក្ខជន ឬវិធានការឆ្នោត។ ជាក់ស្តែង ការបង្កើតការផ្សព្វផ្សាយតាម ទូរទស្សន៍ដើម្បីជំរុញអ្នកបោះឆ្នោតឲ្យ"បោះឆ្នោតសំរាប់"បេក្ខជនគឺជាការចំណាយឯករាជ្យ ប្រសិនបើការផ្សព្វផ្សាយត្រូវបានបង្កើតឡើងដោយមិនបានសម្របសម្រួលជាមួយនឹងការឃោសនារបស់បេក្ខជន។ ច្បាប់បច្ចុប្បន្នមិនកំណត់ចំនួននៃថវិការបស់បុគ្គល ក្រុម និងអាជីវកម្មទេ ប៉ុន្តែអាចចំណាយលើការចំណាយឯករាជ្យ។ ប៉ុន្តែ ការចំណាយទាំងនេះត្រូវតែបានបង្ហាញទៅដល់មន្ត្រីបោះឆ្នោត។

សំណើប្រជាមតិ
# 32 វិភាគទានខាងនយោបាយ តាមរយៈការកាត់ពីប្រាក់ខែ។ វិភាគទានទៅឲ្យបេក្ខជន។ លក្ខន្តិកៈផ្តួចផ្តើម។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** **(ត)**

- ***ការចំណាយខាងនយោបាយផ្សេងទៀត។*** ការចំណាយខាងនយោបាយខ្លះគឺមិនត្រូវបានគិតថាការចូលវិភាគទានខាង នយោបាយ ឬការចំណាយឯករាជ្យទេ។ ប្រភេទដ៏ទូលាយនេះ រួមមាន "ទំនាក់ទំនងសមាជិក" -ការចំណាយដោយអង្គការ មួយដើម្បីទាក់ទងការគាំទ្រខាងនយោបាយចំពោះសមាជិក និយោជក ឬអ្នកពាក់ព័ន្ធរបស់ខ្លួន។ ការចំណាយនេះមិនត្រូវ បានកំណត់ដោយច្បាប់របស់រដ្ឋ និងមិនចាំបាច់បង្ហាញទៅមន្ត្រីបោះឆ្នោតឡើយ។

***ការកាត់ប្រាក់ខែ។*** នៅក្រោមលក្ខខណ្ឌកំណត់ និយោជកអាច ដកលុយពីប្រាក់បៀវត្សរ៍របស់និយោជិក។ ថវិកាដែលបានដក ត្រូវបានគេហៅថា "ការកាត់ប្រាក់ខែ។" ការកាត់ប្រាក់ខែទូទៅ មួយចំនួនរួមមានការកាត់សំរាប់សុវត្ថិភាពសង្គម (Social Security) ពន្ធប្រាក់ចំណូល គំរោងសុខាភិបាល និងការបរិច្ចាគ សប្បុរសធម៌ដោយស្ម័គ្រចិត្ត។

***ប្រាក់បង់និងកំរៃឈ្នួលសំរាប់សហជីព។*** និយោជិកក្នុងរដ្ឋកាលីហ្វ័រញ៉ា ប្រមាណ 2.5 លាននាក់ត្រូវបានតំណាងដោយសហជីព ពលកម្ម។ សហជីពតំណាងកម្មករនៅក្នុងដំណើរការចរចារួម ដែលក្នុងនោះពួកគេចរចានូវលក្ខខណ្ឌនិងស្ថានភាពការងារជា មួយនឹងនិយោជក។ ជាទូទៅសហជីពបង់លុយសំរាប់សកម្ម ភាពរបស់ពួកគេជាមួយនឹងថវិកាដែលបានពី (1) ប្រាក់កំណត់ ដែលបង់ដោយសមាជិកសហជីព និង (2) ប្រាក់កំរៃឈ្នួល សំរាប់ភាគលាភស្មើគ្នាដែលបង់ដោយសមាជិកដែលមិនមែនជា សហជីព ហើយដែលសហជីពតំណាងនៅក្នុងដំណើរការចរចា រួម។ ក្នុងករណីជាច្រើន និយោជកទាំងឡាយកាត់ជាស្វ័យប្រវត្តិនូវបាក្រ់បង់និងកំរៃឈ្នួល ទាំងនេះពីបាក្រ់បៀវត្សរ៍របស់និយោជិកពួកគេនិងផ្ទេរលុយទៅឲ្យ សហជីព។

***ការកាត់ប្រាក់ខែដើម្បីផ្គត់ផ្គង់ការចំណាយខាងនយោបាយ។*** សហជីពជាច្រើនប្រើផ្នែកខ្លះនៃថវិកាដែលពួកគេទទួលបានពីការកាត់ប្រាក់ខែដើម្បីគាំទ្រសកម្មភាពនានាដែលមិនទាក់ទងដោយផ្ទាល់នឹង ដំណើរការចរចារួម។ ការចំណាយទាំងនេះអាចរួមមានការចូលវិភាគ ទានខាងនយោបាយ និងការចំណាយឯករាជ្យទេ - ព្រមទាំងការចំណាយដើម្បីទាក់ទងការយល់ឃើញខាងនយោបាយទៅកាន់សមាជិកសហជីព។ សមាជិកដែលមិនមែនជាសហជីពអាចដកខ្លួនចេញពី ការដែលបាក្រ់កំរៃឈ្នួលសំរាប់ភាគលាភស្មើគ្នា ត្រូវបានប្រើសំរាប់បង់ ការចំណាយខាងនយោបាយនេះ និងការចំណាយផ្សេងទៀតដែលមិន ទាក់ទងនឹងការចរចារួម។ ក្រៅពីសហជីពមានអង្គការពីរ បីដែរដែល បច្ចុប្បន្នប្រើប្រាស់ការកាត់បាក្រ់ខែដើម្បីផ្គត់ផ្គង់ការចំណាយខាងនយោបាយនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

## សេចក្តីស្នើច្បាប់

វិធានការផ្លាស់ប្តូរច្បាប់ហិរញ្ញវត្ថុឃោសនារដ្ឋដើម្បីដាក់កម្រិតការចំណាយយុទ្ធនាការរដ្ឋ និងមូលដ្ឋានតាមរយៈ៖

- សហជីពពលករវិស័យសាធារណៈ និងឯកជន។
- សាជីវកម្ម។
- អ្នកម៉ៅការឲ្យរដ្ឋាភិបាល។

លក្ខខណ្ឌទាំងនេះមិនប៉ះពាល់ដល់ការចំណាយលើការឃោសនាសម្រាប់ការិយាល័យសហព័ន្ធដូចជា ប្រធានាធិបតីសហរដ្ឋអាមេរិកនិងសមាជិកសភាទេ។

***ហាមឃាត់ការប្រើបាស្រ់នៃការកាត់ប្រាក់ខែចំពោះការចំណាយហិរញ្ញវត្ថុសម្រាប់គោលបំណងខាងនយោបាយ។*** វិធានការទប់ស្កាត់សហជីព សាជីវកម្ម អ្នកម៉ៅការរដ្ឋាភិបាល និងនិយោជករដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានពីការចំណាយថវិកាដែលបានកាត់ពីបាក្រ់បៀវត្សរ៍របស់និយោជកសម្រាប់ "គោលបំណងខាងនយោបាយ។" នៅក្រោមវិធានការពាក្យនេះនឹងបូករួមទាំងវិភាគទានខាងនយោបាយ ការចំណាយឯករាជ្យការទំនាក់ទំនងរបស់សមាជិកដែលទាក់ទងនឹងការឃោសនា និងការចំណាយផ្សេងទៀតដើម្បីជះឥទ្ធិពលដល់អ្នកបោះឆ្នោត។ វិធានការនេះនឹងមិនប៉ះពាល់ដល់សិទ្ធិអំណាចដែលមានស្រាប់របស់សហជីពដើម្បីប្រើការកាត់ប្រាក់ខែសម្រាប់ចំណាយលើសកម្មភាពផ្សេងទៀត បូករួមទាំងការចរចារួម និងការចំណាយខាងនយោបាយនៅក្នុងការឃោសនាសហព័ន្ធ។

***ហាមឃាត់វិភាគទានខាងនយោបាយ តាមរយៈសាជីវកម្ម និងសហជីព។*** វិធានការនេះហាមឃាត់សាជីវកម្ម និងសហជីពពីការធ្វើវិភាគទានខាងនយោបាយចំពោះ បេក្ខជន។ នោះមានន័យថា ពួកគេមិនអាចធ្វើវិភាគទាន (1)ទៅបេក្ខជនដោយផ្ទាល់ ឬ (2) ចំពោះគណកម្មាធិការ ដែលបន្ទាប់មកធ្វើវិភាគទានដល់បេក្ខជន។ ទោះបីជាយ៉ាងណា ការហាមឃាត់នេះ មិនមាន ប៉ះពាល់ដល់លទ្ធភាពរបស់សាជីវកម្ម ឬសហជីពក្នុងការចំណាយប្រាក់លើការចំណាយដោយឯករាជ្យទេ។

***ការកំណត់សិទ្ធិអំណាចនៃអ្នកម៉ៅការខាងរដ្ឋាភិបាល ក្នុងការធ្វើវិភាគទានដល់មន្ត្រីជាប់ឆ្នោត។*** វិធានការនេះហាមឃាត់អ្នកម៉ៅការខាងរដ្ឋាភិបាល រួមមាន (សហជីពពលករវិស័យសាធារណៈដែលមានកិច្ចសន្យាចរចារួម) ពីការធ្វើវិភាគទានទៅដល់មន្ត្រីជាប់ឆ្នោតទាំងនេះ ដែលដើរតួនាទីក្នុងការផ្តល់នូវកិច្ចសន្យារបស់ពួកគេ។ ជាបាក្រដ អ្នកម៉ៅការខាងរដ្ឋាភិបាល មិនអាចធ្វើវិភាគទានទៅដល់មន្ត្រីជាប់ឆ្នោតទាំងនេះចាប់ពីពេលដែលកិច្ចសន្យាពួកគេកំពុងត្រូវបានពិចារណារហូតដល់កិច្ចសន្យាពួកគេផុតកំណត់។

## ឥទ្ធិពលសារពើពន្ធ

រដ្ឋគួរធ្លាប់បានពិសោធន៍ខាងការចំណាយដែលកើនឡើងដើម្បីអង្កេតទៅលើការបំពានច្បាប់ និងដើម្បីឆ្លើយតបទៅនឹងសំណើសុំការណែនាំ។ លើសពីនេះ រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានគួរធ្លាប់មានបទពិសោធន៍ទៅលើការកើនឡើងនៃការចំណាយរដ្ឋបាល។ ដោយបូកបញ្ចូល ការចំណាយទាំងនេះអាចលើសពី **$1 លានដុល្លារជារៀងរាល់ឆ្នាំ។**

សំណើប្រជាមតិ

# 32

## វិភាគទានខាងនយោបាយ តាមរយៈការកាត់ពីប្រាក់ខែ។ វិភាគទានទៅឲ្យបេក្ខជន។ លក្ខន្តិកៈផ្តួចផ្តើម។

### ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 32 ★

បោះឆ្នោត បាទ/ចាស គាំទ្រលើសំណើប្រជាមតិលេខ 32៖ កាត់ចំណងថវិការវាងអ្នកទទួលផលប្រយោជន៍ពិសេស និងអ្នកនយោបាយនានា

អ្នកនយោបាយទាញយកលុយរាប់លានដុល្លារក្នុងការ ធ្វើវិភាគទានយុទ្ធាការណ៍បោះឆ្នោតពីក្រុមហ៊ុន និងសហជីព រដ្ឋាភិបាល ហើយបន្ទាប់មក បោះឆ្នោតទៅតាមតែអ្នកទទួល បានផលប្រយោជន៍ពិសេសប្រាប់គេ។ អ្នកនយោបាយទីបញ្ចប់ទៅធ្វើការឲ្យអ្នកទទួលផលប្រយោជន៍ពិសេស ពោលគឺមិនមែនអ្នកបោះឆ្នោតនោះឡើយ។ លទ្ធផល ៖ ឱនភាពថវិកាដ៏ធំ និងការរំលោភបំពានដូចជាប្រាក់សោធនិវត្តន៍ដ៏ខ្ជះខ្ជាយ និងគ្រូបង្រៀនអសមត្ថភាពដែលយើងមិនអាចបញ្ឈប់បាន។

សំណើប្រជាមតិលេខ 32 ហាមឃាត់ការធ្វើវិភាគទាន របស់ក្រុមហ៊ុន និងអ្នកទទួលផលប្រយោជន៍ពិសេសរបស់សហជីពទៅឲ្យអ្នកនយោបាយនោះទេ។ គ្មានការរួចខ្លួន។ គ្មានការបញ្ចៀសឱ្យរួចពីច្បាប់។ ពលរដ្ឋរដ្ឋកាលីហ្វ័រនីញ៉ាគ្រប់ៗរូបអាចចូលរួមឧបត្ថម្ភបាន តែមិនមែនជាអ្នកទទួលផលប្រយោជន៍ពិសេសឡើយ! អ្នកបោះឆ្នោតត្រូវដឹងថា ៖

អ្នកទទួលផលប្រយោជន៍ពិសេសបានចំណាយលុយរាប់ សិបលានដុល្លារដើម្បីការពារសំណើប្រជាមតិលេខ 32 ពីការ កាត់ផ្តាច់ចំណងនៃប្រាក់រវាងពួកគេ និងអ្នកនយោបាយ។ គេនឹងនិយាយអ្វីៗដើម្បីការពារស្ថានភាពបច្ចុប្បន្ននេះ។ ពួកគេបង្កើតទឡ្ហីករណ៍ខុសឆ្គង ក្លែងក្លាយ ទុច្ចរិត ៖

ពួកគេអះអាងថា សំណើប្រជាមតិលេខ 32 មានការបញ្ចៀសឱ្យរួចពីច្បាប់ដែលផ្តល់ផលប្រយោជន៍ដល់អ្នកមាន និងក្រុមហ៊ុន ក្នុងការគាំទ្រ PACs ដែលឯករាជ្យ។ ការពិតគឺថា ទាំងសហជីព និងក្រុមហ៊ុនគាំទ្រគណៈកម្មាធិការនយោបាយឯករាជ្យដែលត្រូវបានការពារដោយច្បាប់រដ្ឋធម្មនុញ្ញដែលមិនត្រូវបានគេហាមឃាត់នោះ។

> "សំណើប្រជាមតិលេខ 32 បញ្ឈប់ក្រុមហ៊ុន និងការឧបត្ថម្ភ របស់សហជីពដល់អ្នកនយោបាយរដ្ឋកាលីហ្វ័រនីញ៉ា។ ក្នុងរយៈកាល។ គ្មានការលើកលែង។ វាមានប្រសិទ្ធិភាពល្អិកណាច្បាប់រដ្ឋធម្មនុញ្ញអាមេរិកអនុញ្ញាតឲ្យបញ្ឈប់ឥទ្ធិពលរបស់អ្នកទទួលផលប្រយោជន៍ពិសេសក្នុងអភិបាលរដ្ឋ។ ខ្ញុំសូមទទូចឲ្យអ្នកបោះឆ្នោតបាទ/ទេ លើសំណើប្រជាមតិលេខ 32 ។"
>
> *—មន្ត្រីតុលាការ ជាន់ខ្ពស់រដ្ឋកាលីហ្វ័រញ៉ាដែលបានចូលនិវត្តន៍ លោក John Arguelles ។*

បោះឆ្នោតបាទ/ទេ លើសំណើប្រជាមតិលេខ 32៖ កំណែទម្រង់ សាមញ្ញចំៗ មិនស្មុគ្រស្មាញ បី

- ហាមឃាត់ការឧបត្ថម្ភរបស់ក្រុមហ៊ុន និងសហជីពដល់អ្នកនយោបាយ
- បញ្ឈប់អ្នកម៉ៅការមិនឲ្យផ្តល់អ្វីទៅអ្នកនយោបាយដែល យល់ព្រមនូវកិច្ចសន្យារបស់ពួកគេឡើយ
- ធ្វើវិភាគទានខាងនយោបាយជាការស្ម័គ្រចិត្ត និងការពារ ថវិកាសម្រាប់គោលបំណងនយោបាយពីការ រកាត់ចេញពីប្រាក់ខែរបស់បុគ្គលិកឡើយ

ផ្តាច់ចំណងថវិការវាងអ្នកទទួលផលប្រយោជន៍ពិសេស និងអ្នកនយោបាយ

អ្នកនយោបាយបារព្ធពិធីរែអង្គាសតំលៃសំបុត្រថ្លៃៗ មានតំលៃខ្ពស់ៗ នៅតាមក្លឹបតំបន់ ការសាកល្បងផឹកស្រាដែលមានរសជាតិ និងអ្នកជក់បារីស៊ីហ្គា។ អ្នកបញ្ចុះបញ្ចូលមានៗ ចូលរួមការរែអង្គាសទាំងនេះ និងផ្តល់ថវិកាដប់រាប់សិបលានដុល្លារក្នុងការរួមចំណែកយុទ្ធនាការណ៍ឃោសនាបោះឆ្នោត។ ភាគច្រើនព្រឹត្តិការណ៍នេះកើតឡើង នៅពេលសេចក្តីព្រាងច្បាប់រាប់រយសន្លឹករួចរាល់សម្រាប់ការបោះឆ្នោត ដោយអនុញ្ញាតឲ្យអ្នកនយោបាយ និងអ្នកទទួលផលប្រយោជន៍ពិសេសធ្វើការផ្លាស់ប្តូរការអនុគ្រោះគ្នាទៅវិញទៅមក៖

- ការផ្តល់នូវភាពចន្លោះប្រហោងខាងពន្ធដារជាច្រើនលានដុល្លារដល់អ្នកផលិតធំៗ អ្នកផលិតភាពយន្តដែលមានទ្រព្យសម្បត្តិធូរធារ និងក្រុមហ៊ុនដែលនៅ រដ្ឋផ្សេង
- លើកលែងអ្នកជួយឧបត្ថម្ភឲ្យរួចពីច្បាប់បរិស្ថានរបស់រដ្ឋ
- ផ្តល់នូវដំណោះស្រាយនូវប្រាក់សោធនដ៏សមរម្យដល់បុគ្គលិក របស់រដ្ឋាភិបាល
- ការពារការផ្គត់ផ្គង់ថវិកាសំរាប់កម្មវិធីខ្ជះខ្ជាយដូចជា ការចំណាយទៅលើរថភ្លើងដែលមានល្បឿនលឿន គ្មានបានទៅណាសោះ ទោះជាពួកគេកំពុងកាត់បន្ថយថវិកាសំរាប់សាលារៀន និងការអនុវត្តច្បាប់ ខណៈពេលពួកគេកំពុងស្នើសុំឲ្យមានការតំឡើងពន្ធឲ្យកាន់តែខ្ពស់ក៏ដោយ

បញ្ឈប់ក្រុមមានផលប្រយោជន៏ពិសេសពីការយកប្រាក់ខែកាត់ពីនិយោជិកសំរាប់វិភាគទាននយោបាយឱ្យធានាថារាល់ប្រាក់ដុល្លារដែលត្រូវបានផ្តល់ឱ្យសំរាប់នយោបាយគឺដោយស្ម័គ្រចិត្តសុទ្ធសាធ។

តុលាការកំពូលនាពេលថ្មីៗនេះបាននិយាយថាការអនុវតន្តន៏រែអង្គាសថវិការបស់សហជីពដ៏ធំមួយនៅកាលីហ្វ័រញ៉ាគឺ "មិនអាចការពារបាន". *(Knox vs. SEIU)*

សំណើប្រជាមតិលេខ 32 នឹងធានាថាអ្នកធ្វើការនៅកាលីហ្វ័រញ៉ាមានសិទ្ធិក្នុងការសំរេចរបៀបចាយលុយដែលគេរកបាន។ គេមិនគួរត្រូវបានបង្ខំឱ្យធ្វើវិភាគទានទៅឱ្យអ្នកនយោបាយ ឬមូលហេតុវិភាគទានដែលគេមិនយល់ស្របជាមួយ។ បញ្ឈប់អ្នកម៉ៅការពីការធ្វើវិភាគទានទៅឱ្យអ្នកនយោបាយដែលយល់ព្រមលើកិច្ចសន្យាការងាររបស់គេ។

ថ្ងៃនេះ អ្នកនយោបាយអាចផ្តល់កិច្ចសន្យាការងារទៅឱ្យអ្នកធ្វើវិភាគទាននយោបាយបានស្របច្បាប់, បិតទ្វារហាងពាណិជ្ជកម្មខ្នាតតូចរបស់យើងដែលកំពុងមានដំណើរការ។ សំណើប្រជាមតិលេខ 32 និងបញ្ចប់ការព្យាបាលពិសេសនេះ និងភាពខ្ជះខ្ជាយដែលជាលទ្ធផលពីសំណើនេះដូចជាទឹកប្រាក់ចំនួន $95 លានសំរាប់ប្រព័ន្ធកុំព្យូទ័រដែលមិនដែលប្រ*ការបាន*។ *(CNET, June 12, 2002)*

ការពុករលួយនៃក្រុមមានផលប្រយោជន៏ពិសេសនេះនឹងបន្តដោយគ្មានការបោះឆ្នោតរបស់អ្នក។ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 32!

*www.stopspecialinterestmoney.org*

**GLORIA ROMERO**, នាយករដ្ឋ
ប្រជាធិបតេយ្យសំរាប់កែទម្រង់ការអប់រំ

**GABRIELLA HOLT**, ប្រធាន
ពលរដ្ឋសំរាប់កែទម្រង់កាលីហ្វ័រញ៉ា

**JOHN KABATECK**, នាយកប្រតិបត្តិ
សហព័ន្ធជាតិនៃពាណិជ្ជកម្មឯករាជ្យ—កាលីហ្វ័រញ៉

### ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 32 ★

មុនពេលអ្នកបោះឆ្នោតលើសំណើប្រជាមតិលេខ 32 សូមឆ្លើយសំណួរពីរ៖តើមហាសេដ្ឋីនឹងចំណាយប្រាក់ដើម្បី បានដាក់សំណើនេះនៅលើសន្លឹកបោះឆ្នោតឬទេ ប្រសិនបើពួកគេមិនទទួលបានការលើកលែងនោះ? តើពេលណាជា ពេលចុងក្រោយដែលសំណើមួយដែលបានគាំទ្រដោយអ្នក ទទួលផលប្រយោជន៍ពិសេសនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា មិនមានការបញ្ចៀសឱ្យរួចពីច្បាប់ និងការលើកលែង?

វាតែងតែមានអន្ទាក់ ហើយសំណើប្រជាមតិលេខ 32 មិនមានភាពខុសគ្នាទេ។

អ្នកអភិវឌ្ឍន៍ផ្នែកអចលនទ្រព្យ ក្រុមហ៊ុនធានារ៉ាប់រង និងនាយទុនជាមហាសេដ្ឋី គឺគ្រាន់តែជាក្រុមបីដែលបានលើកលែងពីខចែងនៃសំណើប្រជាមតិលេខ 32 ខណៈពេលដែលសហជីពនឹងមិនអាចបរិច្ចាគដល់បេក្ខជន ទៀតទេ។ លើសពីនេះ អ្នកទទួលផលប្រយោជន៍ពិសេសនៃក្រុមហ៊ុនធំៗអាចបន្តចំណាយថវិកាគ្មានកំណត់ទៅលើនយោបាយ។

អ្នកគាំទ្រសំណើប្រជាមតិលេខ 32 អះអាងថា បុគ្គលិកត្រូវបានត្រូវបង្ខំឲ្យចូលរួមវិភាគទានដល់នយោបាយ ឬបុព្វហេតុ ដែលពួកគេមិនយល់ព្រមជាមួយ។ ពួកគេមិនត្រូវបានបង្ខំទេ។ ច្បាប់បច្ចុប្បន្នការពារបុគ្គលិកពីការបង្ខំឲ្យចូលរួមជាមួយសហជីព ឬបង់ថ្លៃដល់សហជីពសម្រាប់នយោបាយ។

តើមានរឿងអ្វីកំពុងកើតឡើង?

- អ្នកផ្តល់វិភាគទានសំខាន់ៗទៅលើសំណើប្រជាមតិលេខ 32 គឺជាអតីតអ្នកវិនិយោគ Wall Street នាយកប្រតិបត្តិក្រុមហ៊ុនធានារ៉ាប់រង អ្នកគ្រប់គ្រងថវិកាវិនិយោគ- ពួកគេត្រូវបានលើកលែងពីខចែងនៃសំណើប្រជាមតិលេខ 32 ។ សួរខ្លួនអ្នកមើល ថាតើមកពីហេតុអ្វី។
- អ្នកផ្តល់ថវិកាដល់សំណើប្រជាមតិលេខ 32 ផ្សេងទៀត កាន់កាប់ក្រុមហ៊ុនអភិវឌ្ឍន៏ផ្ទាល់ខ្លួនដែលបានស្នើសុំការលើកលែងពីច្បាប់ដែលការពារបរិស្ថាននិងតំបន់ដីតខាង។ សំណើប្រជាមតិលេខ 32 លើកលែងក្រុមហ៊ុនទាំងនោះផងដែរ។ សួរខ្លួនឯងថាហេតុអ្វី។
- ពាណិជ្ជកម្ម Super PACs និងគណៈកម្មាធិការចំណាយឯករាជ្យត្រូវបានលើកលែងពីខចែងរបស់សំណើប្រជាមតិលេខ 32 ។
- សំណើប្រជាមតិលេខ 32 បន្ថែមទៅលើការិយាធិបតេយ្យរដ្ឋដ៏ធំ ហើយពលរដ្ឋរដ្ឋកាលីហ្វ័រញ៉ាចំណាយលើសពីមួយលានដុល្លារចំពោះកំណែទម្រង់ដែលក្លែងបន្លំ។

សំណើប្រជាមតិលេខ 32 បន្ថែមទៅលើការិយាធិបតេយ្យរដ្ឋដ៏ធំ ហើយពលរដ្ឋរដ្ឋកាលីហ្វ័រញ៉ាចំណាយលើសពីមួយលានដុល្លារចំពោះកំណែទម្រង់ដែលក្លែងបន្លំ។

**JO SEIDITA**, ប្រធាន
យុទ្ធនាការលុយស្អាតកាលីហ្វ័រញ៉ា

**JOHN BURTON**, ប្រធាន
គណបក្សនយោបាយរដ្ឋកាលីហ្វ័រញ៉ា

**ROBBIE HUNTER**, លេខាធិការប្រតិបត្តិ
ក្រុមប្រឹក្សាជំនួញ សំណង់ និង អគារ នៃខោនធី Los Angeles/Orange

សំណើប្រជាមតិ

# 32

# វិភាគទានខាងនយោបាយ តាមរយៈការកាត់ពីប្រាក់ខែ។ វិភាគទានទៅឲ្យបេក្ខជន។ លក្ខន្តិកៈផ្តួចផ្តើម។



## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 32 ★

សម្ព័ន្ធអ្នកបោះឆ្នោតជាស្ត្រីរដ្ឋកាលីហ្វ័រញ៉ា បុព្វហេតុសាធារណៈរដ្ឋកាលីហ្វ័រញ៉ា និងយុទ្ធនាការដើម្បីលុយស្អាតស្អំនៅរដ្ឋកាលីហ្វ័រញ៉ា សុទ្ធតែជំទាស់នឹងសំណើប្រជាមតិលេខ 32។

នោះដោយសារតែសំណើប្រជាមតិលេខ 32 មិនមែនជាសំណើប្រជាមតិពិតនោះទេ។ សំណើប្រជាមតិលេខ 32 ធានាលើ "កំណែទម្រង់នយោបាយ" ប៉ុន្តែវាពិតជាបានរៀបចំឡើងដោយក្រុមអ្នកទទួលផល ប្រយោជន៍ពិសេសដើម្បីជួយពួកគេ និងធ្វើឲ្យអន្តរាយដល់អ្នកប្រឆាំងរបស់ខ្លួន។ ដូច្នេះហើយ យើងជំរុញឲ្យមានការបោះឆ្នោតបដិសេធ។

*នឹងមិនយកលុយចេញពីនយោបាយទេ*

- ពាណិជ្ជកម្ម Super PACs និងគណៈកម្មាធិការការចំណាយឯករាជ្យគឺត្រូវបានលើកលែងរួចផុតពីការគ្រប់គ្រងរបស់សំណើប្រជាមតិលេខ 32។ អង្គការទាំងនេះធ្វើការជ្រើសរើស ឬយកឈ្នះបេក្ខជន និងវិធានការរបស់សន្លឹកឆ្នោត ប៉ុន្តែមិនអាស្រ័យលើលក្ខខណ្ឌវិភាគទាន និងតម្រូវការតម្លាភាពដូចគ្នាសម្រាប់យុទ្ធនាការនោះទេ។
- សេចក្តីសម្រេចរបស់តុលាការកំពូលថ្មីមួយអនុញ្ញាតឲ្យក្រុមទាំងនេះចំណាយទឹកប្រាក់ដោយមិនកំណត់។ សំណើប្រជាមតិលេខ 32 មិនបានធ្វើអ្វីដើម្បីជួយដោះស្រាយបញ្ហា នោះទេ។
- បើសំណើប្រជាមតិលេខ 32 បានជោគជ័យ ពាណិជ្ជកម្ម Super PACs ដែល គាំទ្រដោយក្រុមទទួលផលប្រយោជន៍ពិសេសរបស់ក្រុមហ៊ុន នឹងក្លាយជាវិធីសំខាន់ដែលយុទ្ធនាការត្រូវបានផ្តល់ជំនួយដល់។ ក្រុមទាំងនេះបានចំណាយប្រាក់ច្រើនជាង $95,000,000 ដុល្លាររួចហើយក្នុងការបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ាតាំងពីឆ្នាំ 2004 មកម្ល៉េះ។ ទូរទស្សន៍របស់យើងនឹងពេញទៅដោយការផ្សាយពាណិជ្ជកម្មអវិជ្ជមាន។

*មិនមែនជាកំណែទម្រង់ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាពិតប្រាកដទេ*

កំណែទម្រង់សម្រាប់យុទ្ធនាការដែលពិតប្រាកដផ្តល់ភាពស្មើគ្នាដល់មនុស្សគ្រប់គ្នាដោយគ្មានការលើកលែងពិសេសដល់បុគ្គលណាម្នាក់ឡើយ។ សំណើប្រជាមតិលេខ 32 ត្រូវបានសរសេរឡើងដោយមានចេតនាដើម្បីអនុគ្រោះដល់អាជីវកម្មធំៗរាប់ពាន់ ដូចជា ក្រុមហ៊ុនវិនិយោគ Wall Street មូលនិធិការពារការខាតបង់ ក្រុមហ៊ុនអភិវឌ្ឍន៍ និងក្រុមហ៊ុនធានារ៉ាប់រងជាដើម។ ក្រុមហ៊ុនជាង 1000 ដែលបានអនុគ្រោះតាមរយៈវិធានការនេះ ត្រូវបានចុះបញ្ជីជាម្ចាស់ជំនួយសំខាន់ៗដោយរដ្ឋលេខាធិការកាលីហ្វ័រញ៉ា។ ក្រុមហ៊ុនទាំងនោះបានផ្តល់វិភាគទានលើសពី $10,000,000 ដុល្លារដល់យុទ្ធនាការនយោបាយ ត្រឹមឆ្នាំ 2009 មកប៉ុណ្ណោះ។

*មិនមានតុល្យភាព និងគ្មានយុត្តិធម៌*

វិធានការនេះចែងថា វាហាមសហជីពពីការប្រើថវិកាដែលកាត់ពីប្រាក់ខែ សម្រាប់គោលបំណងនយោបាយឡើយ។ វិធានការនេះចែងថា គេក៏អាចយកទៅអនុវត្តចំពោះសាជីវកម្មផងដែរ។ ដូច្នេះហើយ ស្តាប់ទៅវាមានតុល្យភាព។ ប៉ុន្តែ 99% ក្រុមហ៊ុនរដ្ឋកាលីហ្វ័រញ៉ាមិនប្រើការកាត់ប្រាក់ខែសម្រាប់ការផ្តល់ឲ្យខាងនយោបាយពួកគេក៏នៅតែត្រូវបានអនុញ្ញាតឲ្យប្រើប្រាក់ចំណេញរបស់ខ្លួនដើម្បីមានឥទ្ធិពលលើការបោះឆ្នោត។ នោះមិនយុត្តិធម៌ ឬមិនមានតុល្យភាពសោះ។

គ្រាន់តែក្រឡេកមើលសេចក្តី សង្ខេបជាផ្លូវការ។ អ្នកអាចមើលឃើញពីភាពមិនស្មើគ្នាពី ប្រយោគនេះ៖ "ការចំណាយផ្នែកនយោបាយផ្សេងៗត្រូវតែមិន ទាន់បានរឹតបន្តឹង រួមមានការចំណាយរបស់ក្រុមហ៊ុនមកពីប្រភពដែលមានរួចហើយ និងមិនត្រូវបានកំណត់ដោយការហាមឃាត់នៃការកាត់ប្រាក់ខែទេ។"

*រកមើលនរណាគាំទ្រខាងក្រោយនេះ*

អ្នកផ្តល់វិភាគទានកំពូលៗជាច្រើនចំពោះសំណើប្រជាមតិលេខ 32 គឺជាអតីតនាយកប្រតិបត្តិក្រុមហ៊ុនធានារ៉ាប់រង នាយកប្រតិបត្តិក្រុមហ៊ុនវិនិយោគ Wall Street អ្នកអភិវឌ្ឍន៍ និងម្ចាស់ជំនួយផ្តល់ថវិកាធំៗដល់បុព្វហេតុដែលបាន ប្រយោជន៍ពីការលើកលែងពិសេសរបស់សំណើប្រជាមតិលេខ 32។

Sacramento មានការប្រកាន់បក្សពួកដែលមានជំលោះ និងការមិនយល់ស្របគ្នា។ ថវិកាដែលបានចំណាយលើយុទ្ធនាការណ៍ឃោសនានយោបាយដែលបានបណ្តាលឲ្យយើងទាំង អស់គ្នាបាត់បង់ទំនុកចិត្តលើប្រព័ន្ធយុទ្ធនាការណ៍ឃោសនានយោបាយ។ អ្នកឧបត្ថម្ភលើសំណើប្រជាមតិលេខ 32 កំពុងព្យាយាមប្រើកំហឹង និងការបាត់ទំនុកចិត្តរបស់យើងដើម្បីផ្លាស់ប្តូរច្បាប់សម្រាប់ជាផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

*សំណើប្រជាមតិលេខ 32 នឹងធ្វើឲ្យបញ្ហាកាន់តែធ្ងន់ធ្ងរឡើង*

មនុស្សមួយចំនួននិយាយថា "នេះមិនស្មើភាពគ្នាទេ ប៉ុន្តែវាជាជំហានមួយឆ្ពោះទៅមុខ។" នេះជាបញ្ហារបស់សំណើនេះ។ ការរឹតបន្តឹងទៅលើ សហជីពនិងបុគ្គលិករបស់ពួកគេ ខណៈពេលដែលមិនបញ្ឈប់អ្នកទទួលផលប្រយោជន៍ពិសេសនឹងផ្តល់ជាលទ្ធផលនៅក្នុងប្រព័ន្ធនយោបាយ ដែលគាំទ្រអនុគ្រោះដល់អ្នកទទួលផលប្រយោជន៍ពិសេសនៃក្រុមហ៊ុនជាងអ្នករាល់គ្នាទៀត។ ប្រសិនបើអ្នកមិនចង់ឲ្យអ្នកទទួលផលប្រយោជន៍ពិសេស គ្រប់គ្រងសុវត្ថិភាពទឹកនិងខ្យល់ ព្រមទាំងការពារអ្នកប្រើប្រាស់ សូមបោះឆ្នោតបដិសេធលើសំណើប្រជាមតិលេខរៀង 32។

ចូលទៅកាន់ *http://www.VoteNoOn32.com* ហើយសូមមើលដោយផ្ទាល់ថាហេតុអ្វីសំណើប្រជាមតិលេខ 32 គឺមិនដូចអ្វីដែលគេមើលឃើញនោះទេ ហើយនឹងធ្វើឲ្យប៉ះពាល់ដល់ពលរដ្ឋកាលីហ្វ័រញ៉ាកំរិតមធ្យម។ សូមបោះឆ្នោតបដិសេធលើសំណើប្រជាមតិលេខ 32 ។

**JENNIFER A. WAGGONER,** ប្រធាន
សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា

**DEREK CRESSMAN,** នាយកប្រចាំតំបន់
មូលហេតុសាមញ្ញកាលីហ្វ័រញ៉ា

**DAN STANFORD,** អតីតប្រធាន
គណៈកម្មការអនុវត្តន៍នយោបាយយុត្តិធម៌កាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 32 ★

កម្រពួកមានផលប្រយោជន៍ពិសេសមិនប្រាប់ការពិតដល់អ្នកទេ។

ពួកគេនិយាយថា ពួកគេប្រឆាំងនឹងសំណើប្រជាមតិលេខ 32 សម្រាប់អ្វីដែលវាមិនបានធ្វើ។ ប៉ុន្តែពួកគេកំពុងតែព្យាយាមបញ្ឈប់វាចំពោះអ្វីដែលវាធ្វើ។

តាមពិតទៅសំណើប្រជាមតិលេខ 32 មានសុពលភាព ដរាបណាតុលាការកំពូលអនុញ្ញាត៖ វាបញ្ឈប់ទាំងក្រុមហ៊ុន និងសហជីពពីការផ្តល់លុយទៅឲ្យអ្នកនយោបាយ។ *គ្មានការលើកលែង។ ការបញ្ចៀសឱ្យរួចពីច្បាប់។*

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 32៖ កំណែទម្រង់ធម្មតា បី

- សម្រាប់ការបោះឆ្នោតឆ្នាំ 2010 ក្រុមហ៊ុន និងសហជីពបានផ្តល់លុយ $48 លានដុល្លារទៅឲ្យអ្នកនយោបាយរដ្ឋ។ ប្រសិនបើសំណើប្រជាមតិលេខ 32 បានដាក់នៅទីនេះស្រាប់ នោះលុយ *$48លានដុល្លារអាចមិនត្រូវបានផ្តល់ឲ្យបេក្ខជននយោបាយទេ។*
- គ្មានលើកក្រោយទៀតទេ ដែលអ្នកម៉ៅការនឹងផ្តល់លុយឲ្យអ្នកនយោបាយដែលព្រមព្រៀងលើកិច្ចសន្យារបស់ពួកគេ។
- គ្មានទៀតទេ ដែលក្រុមហ៊ុន ឬសហជីពយកលុយពីប្រាក់ខែ កម្មករទៅចំណាយលើរឿងនយោបាយ។ ក្រោមសំណើលេខ 32 រាល់និយោជិក និងសហជីពទាំងអស់នឹងត្រូវសុំការអនុញ្ញាត ហើយរាល់កម្មករទាំងអស់ក៏អាចនិយាយបដិសេធបានដែរ។

អ្នកទទួលផលប្រយោជន៍ពិសេសដែលមានចំនួនទឹកប្រាក់ច្រើនៗកំពុងតែចំណាយលុយ*រាប់លានដុល្លារ*ដើម្បីបញ្ឈប់ សំណើប្រជាមតិលេខ 32។ ពួកគេបដិ សេធមិនឲ្យបាត់អំណាចពួកគេចំពោះទីក្រុង Sacramento។គ្រាន់តែជាឧទាហរណ៍ មួយ៖

នៅពេលសាលាមូលដ្ឋានរបស់ LA មិនអាចចាត់វិធានការភ្លាមៗដើម្បីបញ្ឈប់គ្រូបង្រៀនណាម្នាក់ដែលបានចាប់ រំលោភកូនសិស្សរបស់គាត់ វាត្រូវបានគេស្នើសុំឲ្យសមាជិកសភាធ្វើការអនុម័តច្បាប់ឲ្យកាន់តែងាយស្រួល។ ប៉ុន្តែសហជីពគ្រូបង្រៀនយ៉ាងធំរបស់រដ្ឋ—ដែលបានផ្តល់ប្រាក់ចំនួន $1លានដុល្លារទៅឲ្យអ្នកនយោបាយកាលពី ពីរ ឆ្នាំមុន— បានកោះហៅក្រុមអ្នកបញ្ចុះបញ្ចូលរបស់ខ្លួន។ ពួកគេបានបំបាត់ការកែទម្រង់។

លោកចៅហ្វាយក្រុង LA គឺលោក Antonio Villaraigosa បានហៅវាថា "ការបោកបញ្ឆោតខាងផ្នែកនយោបាយដ៏ អាក្រក់។" ទៅកាន់កាសែត *San Francisco Chronicle* គឺជា "ការស្អប់ខ្ពើម។"

ជំនួញតាមធម្មតាបានធ្វើឲ្យប៉ះពាល់ដល់អ្នករដ្ឋកាលីហ្វ័រញ៉ា។ ដកលុយចេញពីដៃអ្នកនយោបាយ។ គាំទ្រសំណើ ប្រជាមតិលេខ 32 ។

**MARIAN BERGESON**
អតីតលេខាធិការអប់រំរដ្ឋកាលីហ្វ័រញ៉ា

**JON COUPAL,** ប្រធាន
សមាគមអ្នកជាប់ពន្ធ Howard Jarvis

**HON. JOHN ARGUELLES**
តុលាការកំពូលកាលីហ្វ័រញ៉ា (ចូលនិវត្តន៍)

# សំណើប្រជាមតិ 33 ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ តំលៃបុព្វលាភរ៉ាប់រងផ្អែកលើប្រវត្តិការរ៉ាប់រងរបស់អ្នកបើកបរ។ ច្បាប់ផ្តើមប្រជាសិទ្ធិ។

**ចំណងជើងជាផ្លូវការ និងសេចក្តីសង្ខេប** — **រៀបចំដោយអគ្គមេធាវី**

## ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ តំលៃបុព្វលាភរ៉ាប់រងផ្អែកលើប្រវត្តិការរ៉ាប់រងរបស់អ្នកបើកបរ។ ច្បាប់ផ្តើមប្រជាសិទ្ធិ។

- ប្តូរច្បាប់បច្ចុប្បន្ន ដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងកំណត់តម្លៃ ដោយផ្អែកលើ ថាតើអ្នកបើកបរនោះពីមុនមកមានធានារ៉ាប់រងយានយន្តជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយដែរ ឬទេ។
- អនុញ្ញាតឲ្យក្រុមហ៊ុន ផ្តល់ការបញ្ចុះតម្លៃជាសមាមាត្រដល់អ្នកបើកបរ ដែលមានប្រវត្តិខ្វះៗនៃការគ្របដណ្តប់ខាងការធានារ៉ាប់រងពីមុនមក។
- នឹងអនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រង បង្កើនថ្លៃធានារ៉ាប់រង ចំពោះអ្នកបើកបរទាំងឡាយណាដែលមិនបានរក្សាការគ្របដណ្តប់ជាបន្ត។
- ចាត់ទុកអ្នកបើកបរជាមួយនឹងរយៈកាលកន្លងទៅ ដែលបានគ្របដណ្តប់ជាបន្ត ប្រសិនបើរយៈកាលកន្លងទៅ បណ្តាលមកពីសេវាកងទ័ព ឬប្រសិនបើរយៈកាលកន្លងទៅតិចជាង 90 ថ្ងៃ។

33 **សេចក្តីសង្ខេបនៃការប៉ាន់ស្មានរបស់អ្នកវិភាគអង្គនិតិបញ្ញត្តិនៃផលប៉ះពាល់សារពើពន្ធលើចំណូលសុទ្ធរបស់រដ្ឋ និងមូលដ្ឋាន**

- ប្រហែលគ្មានឥទ្ធពលសារពើពន្ធក្នុងប្រាក់ចំណូលពន្ធបុព្វលាភធានារ៉ាប់រងរបស់រដ្ឋ។

---

### ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

## សាវតារ

ការធានារ៉ាប់រងយានយន្ត គឺជាប្រភេទការធានារ៉ាប់រងដ៏សំខាន់ ដែលជាវដោយពលរដ្ឋនៅរដ្ឋកាលីហ្វ័រញ៉ា។ វាមានចំនួនប្រហែល $21 ពាន់លានដុល្លារ (40 ភាគរយ) នៃបុព្វលាភទាំងអស់ ដែលប្រមូលដោយអ្នកធានារ៉ាប់រងនៅរដ្ឋកាលីហ្វ័រញ៉ាក្នុងឆ្នាំ 2011។

***និយ័តកម្មរដ្ឋស្តីពីការធានារ៉ាប់រងយានយន្ត។*** នៅឆ្នាំ 1988 អ្នកបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ាបានអនុម័តសំណើប្រជាមតិលេខ 103 ដែលតម្រូវឲ្យស្នងការធានារ៉ាប់រងពិនិត្យឡើងវិញ និងឯកភាពលើការផ្លាស់ប្តូរអត្រាសម្រាប់ប្រភេទនៃការធានារ៉ាប់រងមួយចំនួន រួមទាំងការធានារ៉ាប់រងយានយន្ត មុននឹងការផ្លាស់ប្តូរអត្រាទាំងនោះអាចចូលជាធរមាន។ សំណើប្រជាមតិលេខ 103 ក៏តម្រូវឲ្យកំណត់អត្រា និងបុព្វលាភសម្រាប់គោលការណ៍ធានារ៉ាប់រងយានយន្ត ដោយអនុវត្តកត្តាកំណត់លំដាប់ខាងក្រោមក្នុងការកាត់បន្ថយលំដាប់នៃភាពសំខាន់៖ (1) កំណត់ត្រាសុវត្ថិភាពបើកបរដែលបានធានារ៉ាប់រង (2) ចំនួនម៉ៃដែលពួកគេបើកបរក្នុងមួយឆ្នាំ និង (3) ចំនួនឆ្នាំដែលពួកគេបានបើកបរផងដែរ។

ស្នងការធានារ៉ាប់រងអាចអនុម័តកត្តាកំណត់លំដាប់បន្ថែមទៀតឲ្យចូលជាធរមាន ដើម្បីកំណត់អំពីអត្រា និងបុព្វលាភយានយន្ត។ បច្ចុប្បន្ននេះជម្រើសកត្តាកំណត់លំដាប់ចំនួន16 អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងទាំងនេះ។ ឧទាហរណ៍ក្រុមហ៊ុនធានារ៉ាប់រងអាចផ្តល់ការបញ្ចុះតម្លៃជូនបុគ្គលទាំងឡាយ ទៅលើការរក្សាការគ្របដណ្តប់ ជាមួយនឹងពួកគេ។ ទោះបីជាយ៉ាងណា ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបានហាមឃាត់ពីការផ្តល់ការបញ្ចុះតម្លៃប្រភេទនេះជូនអតិថិជនថ្មី ដែលបានប្តូរមកពីអ្នកធានារ៉ាប់រងដទៃទៀត។

***ពន្ធបុព្វលាភធានារ៉ាប់រង។*** ក្រុមហ៊ុនធានារ៉ាប់រង ដែលធ្វើអាជីវកម្មនៅកាលីហ្វ័រញ៉ា បច្ចុប្បន្ននេះ បង់ពន្ធបុព្វលាភធានារ៉ាប់រង ជំនួសឲ្យពន្ធប្រាក់ចំណូលសាជីវកម្មរដ្ឋ។ ពន្ធបុព្វលាភគឺ ផ្អែកទៅលើចំនួននៃបុព្វលាភធានារ៉ាប់រងដុល ដែលរកបាននៅក្នុងរដ្ឋមួយឆ្នាំៗ សម្រាប់ការធានារ៉ាប់រងយានយន្តក៏ដូចជាសម្រាប់ការគ្របដណ្តប់ធានារ៉ាប់រងប្រភេទផ្សេងៗ។ នៅឆ្នាំ 2011 ក្រុមហ៊ុនធានារ៉ាប់រង បង់ប្រហែល $500 លានដុល្លារ នៅក្នុងប្រាក់ចំណូលពន្ធបុព្វលាភ ទៅលើគោលការណ៍យានយន្តនៅកាលីហ្វ័រញ៉ា។ ប្រាក់ចំណូលទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិកាទូទៅរបស់រដ្ឋ។

## សេចក្តីស្នើច្បាប់

វិធានការនេះ អនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងមួយផ្តល់ការបញ្ចុះតម្លៃ "ការគ្របដណ្តប់ជាបន្ត" លើគោលការណ៍ធានារ៉ាប់រងយានយន្តចំពោះអតិថិជនថ្មី ដែលប្តូរការគ្របដណ្តប់របស់ខ្លួនមកពីអ្នកធានារ៉ាប់រងមួយផ្សេងទៀត។ ក្រោមវិធានការនេះ ការគ្របដណ្តប់ធានារ៉ាប់រងមានន័យជាទូទៅថា ការគ្របដណ្តប់ធានារ៉ាប់រងយានយន្តគ្មានការផ្អាកជាមួយអ្នកធានារ៉ាប់រងណាមួយក៏ដោយ។ ទោះបីជាយ៉ាងណា អ្នកប្រើប្រាស់ដែលមានរយៈកាល

# សំណើប្រជាមតិ 33 ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ តំលៃបុព្វលាភរ៉ាប់រងផ្អែកលើប្រវត្តិការរ៉ាប់រងរបស់អ្នកបើកបរ។ ច្បាប់ផ្តើមប្រជាសិទ្ធិ។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** (ត)

កន្លងទៅនៅក្នុងការគ្របដណ្ដប់ នឹងនៅតែមានសិទ្ធិទទួលបានការបញ្ចុះតម្លៃនេះ ប្រសិនបើរយៈកាលកន្លងទៅ៖

- មិនច្រើនជាង ៩០ ថ្ងៃ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក ដោយមូលហេតុណាមួយក៏ដោយ។
- ច្រើនជាង 18 ខែ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកដោយសារការបាត់បង់ការងារ ដែលបណ្ដាលមកពីការផ្អាកឲ្យឈប់ធ្វើការ ឬការអនុញ្ញាតឲ្យឈប់សម្រាកបណ្ដោះអាសន្ន ។
- បណ្ដាលមកពីសេវាកងទ័ពដែលកំពុងសកម្ម។

ដូចគ្នានេះដែរ កុមារដែលស្នាក់នៅជាមួយឪពុកម្ដាយក៏អាចមានគុណវុឌ្ឍិគ្រប់គ្រាន់ ក្នុងការទទួលបានការបញ្ចុះតម្លៃនេះដែរ ដោយផ្អែកលើសិទ្ធិទទួលបានរបស់ឪពុកម្ដាយរបស់ពួកគេ។

ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រង ជ្រើសរើសផ្ដល់ការបញ្ចុះតម្លៃបែបនេះនោះ ការបញ្ចុះតម្លៃនឹងត្រូវផ្ដល់តាមសមាមាត្រ។ ការបញ្ចុះតម្លៃ នឹងផ្អែកលើចំនួនឆ្នាំនៅក្នុងរយៈពេលប្រាំឆ្នាំភ្លាមៗ (វិលជុំដល់ចំនួនទាំងមូល) ដែលអតិថិជនត្រូវបានធានារ៉ាប់រង។ ឧទាហរណ៍ ប្រសិនបើអតិថិជនអាចបង្ហាញឲ្យឃើញថា គាត់មានការគ្របដណ្ដប់រយៈពេលបីឆ្នាំ ក្នុងចំណោមប្រាំឆ្នាំមុននោះ អតិថិជននោះនឹងទទួលបាន ៦០ ភាគរយនៃការបញ្ចុះតម្លៃការគ្របដណ្ដប់បន្ត។

## ឥទ្ធិពលសារពើពន្ធ

វិធានការនេះ
អាចបណ្ដាលឲ្យមានការផ្លាស់ប្ដូរចំនួនសរុបនៃបុព្វលាភធានារ៉ាប់រងយានយន្តសរុប ដែលរកបានដោយក្រុមហ៊ុនធានារ៉ាប់រងនៅរដ្ឋកាលីហ្វ័រញ៉ា និងចំនួនប្រាក់ចំណូលពន្ធបុព្វលាភដែលបានទទួលដោយរដ្ឋ។ ឧទាហរណ៍ ការណែនាំអំពីការបញ្ចុះតម្លៃការគ្របដណ្ដប់បន្តអាចកាត់បន្ថយចំនួនបុព្វលាភដែលបង់ដោយអ្នកដែលមានសិទ្ធិទទួលបានការបញ្ចុះតម្លៃ។ ទោះបីជាយ៉ាងណា ជាទូទៅចំនួននេះ នឹងបង្កើតបានដោយបុព្វលាភបន្ថែម ដែលបង់ដោយអ្នកដែលមិនមានសិទ្ធិទទួលបានការបញ្ចុះតម្លៃបែបនេះ។ ការប៉ះពាល់សរុបទៅលើប្រាក់ចំណូលពន្ធបុព្វលាភរដ្ឋដែលបណ្ដាលមកពីវិធានការនេះ នឹងប្រហែលជាមិនធំធេងទេ។

33

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 33, សូមអានទំព័រ 94។*

# សំណើប្រជាមតិ 33

## ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ ដំឡើងថ្លៃនៃការធានារ៉ាប់រង យោងទៅលើប្រវត្តិរបស់អ្នកបើកបរ។ លក្ខន្តិក:ផ្តួចផ្តើម។

## ★ ទទ្បហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 33 ★

អ្នកប្រើប្រាស់នៅកាលីហ្វ័រញ៉ាសមទទួលរង្វាន់មួយសំរាប់ការអនុវត្តន៏តាមច្បាប់ហើយទិញការធានារ៉ាប់រងរថយន្ត។ សំណើប្រជាមតិលេខ 33 អនុញ្ញាតឱ្យអ្នករកទិញទ្បានចុះថ្លៃសំរាប់តំលៃដែលអ្នកអាចទិញបាន។

ច្បាប់រដ្ឋកាលីហ្វ័រញ៉ា តម្រូវឲ្យអ្នកបើកបរទាំងអស់ទិញការធានារ៉ាប់រងយានយន្ត។ ប្រហែល 85% នៃអ្នកបើកបរនៅរដ្ឋកាលីហ្វ័រញ៉ាគោរពច្បាប់នេះ ហើយបានទិញការធានារ៉ាប់រង។ ប្រសិនបើអ្នកគោរពច្បាប់នេះ ហើយរក្សាការគ្របដណ្តប់នូវការធានារ៉ាប់រងបន្តនោះ បច្ចុប្បន្នអ្នកមានសិទ្ធិទទួលបានការបញ្ចុះតម្លៃ *ប៉ុន្តែសម្រាប់តែករណីដែលអ្នកស្ថិតនៅជាមួយក្រុមហ៊ុនធានារ៉ាប់រងដដែលប៉ុណ្ណោះ។*

ច្បាប់បច្ចុប្បន្ន ផាកពិន័យអ្នក សំរាប់ការស្វែងរកការធានារ៉ាប់រងកាន់តែប្រសើរ ឬព្យាយាមទទួលបានដំណោះស្រាយកាន់តែប្រសើរ ដោយដកចេញនូវការបញ្ចុះតម្លៃរបស់អ្នក ចំពោះការត្រូវបានធានារ៉ាប់រងបន្ត។

*សំណើប្រជាមតិលេខ 33 កែតម្រូវបញ្ហានេះ ហើយបានផ្តល់ការបញ្ចុះតម្លៃនេះជូនអតិថិជនដែលរក្សាការធានារ៉ាប់រងយានយន្តជាមួយក្រុមហ៊ុនណាមួយក៏ដោយ។ សំណើប្រជាមតិលេខ 33 អនុញ្ញាតឲ្យអ្នកស្វែងរកដំណោះស្រាយធានារ៉ាប់រងកាន់តែប្រសើរមួយ។*

អ្នកដឹកនាំមកពីគណបក្សទាំងពីរគឺ អ្នកប្រជាធិបតេយ្យ និងអ្នកសាធារណរដ្ឋអតីតយុទ្ធជននៃសង្គ្រាមបរទេស (VFW) វេទិកា GI អាមេរិកនៃរដ្ឋកាលីហ្វ័រញ៉ា (American GI Forum of California) អ្នកពន្លត់អគ្គីភ័យ ម្ចាស់អាជីវកម្មខ្នាតតូច អ្នកប្រើប្រាស់ជាបុគ្គល និងសភាពាណិជ្ជកម្ម បានចូលរួមគាំទ្រសំណើប្រជាមតិលេខ 33។ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 33។ វាផ្តល់រង្វាន់ជូនអ្នកដែលគោរពច្បាប់។

រង្វាន់ដែលអ្នកទទួលបាន សម្រាប់ការទទួលខុសត្រូវ និងគោរពច្បាប់នៅតែជារង្វាន់របស់អ្នកដដែល ដើម្បីរក្សានៅក្រោមសំណើប្រជាមតិលេខ 33 បើទោះបីជាអ្នកប្រើសិទ្ធិរបស់អ្នកក្នុងការផ្លាស់ប្តូរទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀតក៏ដោយ។ ហេតុនេះហើយ ទើបក្រុមហ៊ុនធានារ៉ាប់រងមួយចំនួនចូលចិត្តសំណើប្រជាមតិលេខ 33 ហើយក្រុមហ៊ុនផ្សេងទៀតមិនចូលចិត្ត។ វាបង្កើតឲ្យមានការប្រកួតប្រជែង។ ភ្នាក់ងារធានារ៉ាប់រងជិតខាងរបស់អ្នក គាំទ្រសំណើប្រជាមតិលេខ 33 ពីព្រោះវានឹងបង្ខំឲ្យក្រុមហ៊ុនធានារ៉ាប់រងប្រកួតប្រជែងគ្នា ដើម្បីការរកស៊ីរបស់អ្នក។

យើងលើកទឹកចិត្តឲ្យអ្នកអានសំណើប្រជាមតិលេខ 33។ វាមានលក្ខណៈសាមញ្ញ។ វាមានន័យស្តាប់បាន។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 33 ពីព្រោះអ្នកគួរទទួលបាននូវការបញ្ចុះតម្លៃដែលអ្នកបានសន្សំ មិនថាអ្នកជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងណាមួយឡើយ។

សំណើប្រជាមតិលេខ 33 ក៏លើកទឹកចិត្តដល់អ្នកដែលមិនមានការធានារ៉ាប់រងឲ្យទទួលបានវាផងដែរ ពីព្រោះសំណើប្រជាមតិលេខ 33 ធ្វើឲ្យវាកាន់តែងាយស្រួលក្នុងការទទួលបានការបញ្ចុះតម្លៃនៃការគ្របដណ្តប់ជាបន្ត។ អ្នកទទួលនឹងបានចំណែកនៃការបញ្ចុះតម្លៃ សម្រាប់រាល់ពេញមួយឆ្នាំដែលអ្នកត្រូវបានធានារ៉ាប់រង។ កាលណាអ្នកត្រូវបានធានារ៉ាប់រងកាន់តែយូរ ការបញ្ចុះតម្លៃកាន់តែច្រើន។ ការនេះ លើកទឹកចិត្តដល់អ្នកបើកបរដែលមិនមានការធានារ៉ាប់រង ឲ្យទទួលបានការធានារ៉ាប់រង ហើយធ្វើឲ្យផ្លូវថ្នល់របស់យើងកាន់តែមានសុវត្ថិភាពថែមទៀត។

សំណើប្រជាមតិលេខ 33 ក៏ផ្តល់នូវការការពារផ្សេងៗទៀតផងដែរ ដូចជា៖

- ប្រសិនបើអ្នកជាកងទ័ពសកម្ម សំណើប្រជាមតិលេខ 33 ចែងថា អ្នកនឹងមិនបាត់បង់ការបញ្ចុះតម្លៃរបស់អ្នកឡើយ។ហេតុនេះហើយទើបក្រុមគ្រួសារកងទ័ពរបស់យើង ដែលដឹកនាំដោយវេទិកា GI អាមេរិក និងអតីតយុទ្ធជននៃសង្គ្រាមបរទេស យល់ព្រម ចំពោះសំណើប្រជាមតិលេខ 33។
- ប្រសិនបើអ្នកត្រូវបានផ្អាកពីការងារ ឬត្រូវបានអនុញ្ញាតឲ្យសម្រាកពីការងារជាបណ្តោះអាសន្ន សំណើប្រជាមតិលេខ 33 អនុញ្ញាតឲ្យរក្សាឋានៈរបស់អ្នកជាអ្នកបើកបរ ដែលត្រូវបានគ្របដណ្តប់ជាបន្ត រហូតដល់ 18 ខែ។
- ក្រោមសំណើប្រជាមតិលេខ 33 កូនៗដែលស្ថិតក្នុងវ័យបើកបរបាន ទទួលបានការបញ្ចុះតម្លៃ មិនថាពួកគេកំពុងរស់នៅជាមួយឪពុកម្តាយពួកគេ ឬទៅរៀននៅឆ្ងាយ ឡើយ។
- សំណើប្រជាមតិលេខ 33 អនុញ្ញាតឲ្យអ្នកខកខានការបង់ប្រាក់រយៈពេល 90 ថ្ងៃ ទោះមូលហេតុអ្វីក៏ដោយ ហើយនៅតែមានសិទ្ធិទទួលបានការបញ្ចុះតម្លៃនេះដដែល។

សំណើប្រជាមតិលេខ 33 នឹងនាំមកនូវការប្រកួតប្រជែងកាន់តែខ្លាំង រវាងក្រុមហ៊ុនធានារ៉ាប់រង ហើយធ្វើឲ្យអត្រាធានារ៉ាប់រងកាន់តែប្រសើរឡើង ពីព្រោះអ្នកនឹងអាចរកទិញការធានារ៉ាប់រងដោយមិនបាត់បង់ការបញ្ចុះតម្លៃរបស់អ្នកឡើយ។

ក្នុងរដ្ឋកាលីហ្វ័រញ៉ា អ្នកត្រូវតែមានការធានារ៉ាប់រងរថយន្ត។ អ្នកសមទទួលរង្វាន់ក្នុងការធ្វើតាមច្បាប់។ បោះឆ្នោត បាទ/ចាសលើសំណើប្រជាមតិលេខ 33.

**ROBERT T. WOLF**, ប្រធាន
អ្នកពន្លត់អគ្គិភ័យ CDF

**ESTERCITA ALDINGER**
ម្ចាស់អាជីវកម្មខ្នាតតូច

**DEAN LEE**
អតីតយុទ្ធជននៃសង្គ្រាមបរទេស (VFW)

## ★ ការឆ្លើយបដិសេធលើទទ្បហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 33 ★

ពលរដ្ឋដែលកំពុងបម្រើការងារនៅរដ្ឋកាលីហ្វ័នីញ៉ាបច្ចុប្បន្ននេះ មានការលំបាកល្មមណាស់ហើយ។ យើងមិនគួរត្រូវបង់ប្រាក់ច្រើនជាងមុន សម្រាប់ការធានារ៉ាប់រងយានយន្ត ដោយសារតែល្បិចមួយផ្សេងទៀតរបស់ឧស្សាហកម្មធានារ៉ាប់រងនោះទេ។

សំណើប្រជាមតិលេខ 33 ទទួលបានការឧបត្ថម្ភថវិកា 99% ដោយមហាសេដ្ឋីឧស្សាហកម្មធានារ៉ាប់រងម្នាក់ ដែលបាននិយាយថា គាត់ចង់សន្សំសំចៃប្រាក់របស់អ្នកបើកបរ ចំពោះការធានារ៉ាប់រងយានយន្តរបស់ពួកគេ។

*តើពេលណាដែលជាលើកចុងក្រោយ ដែលប្រធានប្រតិបត្តិក្រុមហ៊ុនធានារ៉ាប់រងមួយបានចំណាយ $8 លានដុល្លារ ទៅលើការផ្តួចផ្តើមបោះឆ្នោត ដើម្បីសន្សំសំចៃប្រាក់របស់អ្នក?*

សំណើប្រជាមតិលេខ 33 នឹងបង្កើនអត្រាទៅលើអ្នកបើកបរដែលមានប្រវត្តិបើកបរល្អឥតខ្ចោះ។ ការផ្តួចផ្តើមនេះ ផាកពិន័យយ៉ាងអយុត្តិធម៌ ចំពោះប្រជាពលរដ្ឋដែលបានឈប់បើកបរដោយមូលហេតុស្របច្បាប់- ដូចជាការទៅរៀននៅមហាវិទ្យាល័យ ការសំរាកព្យាបាលពីរបួសធ្ងន់ធ្ងរ ឬប្រើសេវាដឹកជញ្ជូនសាធារណៈជាដើម- នៅពេលពួកគេត្រឡប់មកផ្សារធានារ៉ាប់រងវិញ។

ច្បាប់រដ្ឋកាលីហ្វ័រញ៉ា ទប់ស្កាត់ក្រុមហ៊ុនធានារ៉ាប់រងមិនឲ្យយកប្រាក់ពីប្រជាពលរដ្ឋដោយស្រួលៗឡើយ ដោយសារតែពីមុនមក ពួកគេមិនធ្លាប់បានបើកបរ ឬពីមុនមកការបើកបររបស់ពួកគេនៅខ្សោយពេក។ សំណើប្រជាមតិលេខ 33 នឹងអនុញ្ញាតឲ្យ ក្រុមហ៊ុនធានារ៉ាប់រងចាប់ផ្តើមយកប្រាក់បន្ថែមពីប្រជាពលរដ្ឋកាលីហ្វ័រញ៉ារាប់លាន នាក់។

*អ្នកបោះឆ្នោតបានបដិសេធរួចមកហើយនៅឆ្នាំ 2010* នៅពេលក្រុមហ៊ុនធានារ៉ាប់រងរបស់មហាសេដ្ឋីរូបនេះ បានចំណាយប្រាក់ $16 លានដុល្លារ ដើម្បីអនុម័តការផ្តួចផ្តើមស្រដៀងគ្នានេះ។ ឥឡូវនេះ គាត់ធ្វើរឿងនេះម្តងទៀតហើយ។

ប្រជាពលរដ្ឋដែលប្រើសេវាដឹកជញ្ជូនសាធារណៈទៅធ្វើការ មិនគួរត្រូវបង់ប្រាក់ច្រើនជាងមុន សម្រាប់ការធានារ៉ាប់រងយានយន្តរបស់ពួកគេឡើយ នៅពេលពួកគេចាប់ផ្តើមបើកបរម្តងទៀត។

ពលរដ្ឋកាលីហ្វ័នីញ៉ាដែលគ្មានការងារធ្វើ មិនគួរត្រូវបង់ប្រាក់ច្រើនជាងមុននៅពេលពួកគេទទួលបានការងារផ្សេងធ្វើ ហើយចាប់ផ្តើមបើកបរម្តងទៀតឡើយ។

ប្រជាពលរដ្ឋដែលត្រូវតែបោះបង់ចោលការធានារ៉ាប់រងរបស់ខ្លួន ដោយសារមានជំងឺធ្ងន់ធ្ងរ មិនគួរត្រូវបង់ប្រាក់ច្រើនជាងមុន នៅពេលពួកគេជាសះស្បើយ ហើយត្រឡប់មកបើកបរម្តងទៀតឡើយ។

*សំណើប្រជាមតិលេខ 33 នឹងតំឡើងអត្រាថ្លៃការធានារ៉ាប់រងរថយន្ត។* ប្រាប់មហាសេដ្ឋីក្រុមហ៊ុនធានារ៉ាប់រងនេះថា មិនមែន អូខេ ទេក្នុងការធ្វើអនិយតកម្មការធានារ៉ាប់រងរងយន្ត។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 33.

**DeANN McEWEN, RN**, ប្រធាន
សមាគមគិលានុបដ្ឋាកយកាកាលីហ្វ័រញ៉ា

**RICHARD HOLOBER**, នាយកប្រតិបត្តិ
សហព័ន្ធអ្នកប្រើប្រាស់ កាលីហ្វ័រញ៉ា

**JAMIE COURT**, ប្រធាន
អង្គការឃ្លាំមើលអ្នកប្រើប្រាស់



*ទទ្បហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

សំណើប្រជាមតិ

# 33 ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត។ ដំឡើងនៃការធានារ៉ាប់រង យោងទៅលើប្រវត្តិរបស់អ្នកបើកបរ។ លក្ខន្តិក:ផ្តួចផ្តើម។

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 33 ★

អ្នកតស៊ូមតិរបស់អ្នកប្រើប្រាស់យល់ស្របៈ បោះឆ្នោត ទេ លើសំណើប្រជាមតិ លេខ 33 — វាគឺជាល្បិចបំភ័ន្តមួយទៀតរបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលធ្វើឲ្យគេ យល់ខុស ដើម្បីបង្កើនអត្រាធានារ៉ាប់រងយានយន្ត សម្រាប់អ្នកបើកបរដែលមានការទទួលខុសត្រូវនៅរដ្ឋកាលីហ្វ័រញ៉ារាប់លាននាក់។

ក្រុមហ៊ុនធានារ៉ាប់រងឈ្មោះ Mercury Insurance បានចំណាយ $16 លានដុល្លារ ទៅលើការផ្តួចផ្តើមស្រដៀងគ្នានេះកាលពីឆ្នាំ 2010។ ពលរដ្ឋកាលីហ្វ័រញ៉ាបានច្រានចោលការផ្តួចផ្តើមនេះ។

ឥឡូវនេះ ពួកគេធ្វើរឿងនេះម្តងទៀតហើយ។ ប្រធានក្រុមហ៊ុន Mercury Insurance ដែលជាមហាសេដ្ឋី George Joseph បានចំណាយ $8 លានដុល្លាររួច ហើយ ដើម្បីផ្តល់ថវិកាដល់សំណើប្រជាមតិលេខ 33។ តើពេលណាជាលើកចុងក្រោយ ដែលមហាសេដ្ឋីក្រុមហ៊ុនធានារ៉ាប់រងមួយបានចំណាយធនធានដើម្បីសន្សំសំចៃប្រាក់ របស់អ្នក?

សំណើប្រជាមតិលេខ 33 ផាកពិន័យយ៉ាងអយុត្តិធម៌ចំពោះអ្នកដែលបានឈប់បើកបរ ដោយមានមូលហេតុត្រឹមត្រូវ ប៉ុន្តែឥឡូវត្រូវការសេវាធានារ៉ាប់រងមកវិញ។ យោងតាមសេចក្តីសង្ខេបជាផ្លូវការរបស់អគ្គមេធាវី សំណើប្រជាមតិលេខ 33 "នឹងអនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងបង្កើនថ្លៃធានារ៉ាប់រង" - សូម្បីតែចំពោះអ្នកបើកបរយានយន្តដែលមានប្រវត្តិបើកបរល្អឥតខ្ចោះក៏ដោយ។

សំណើប្រជាមតិលេខ 33 គឺជាការផ្តួចផ្តើមប្រកបដោយពាក្យពេចន៍ដ៏វៃឆ្លាត ដែលបាននិយាយអំពីរឿងមួយ ហើយធ្វើរឿងមួយផ្សេងទៀត។ សូមប្រយ័ត្នៈ ក្រសួងធានារ៉ាប់រងរដ្ឋកាលីហ្វ័រញ៉ា បានថ្លែងអំពីគ្រោងការឈ្មោះ "ការបញ្ចុះតម្លៃចំពោះការគ្របដណ្តប់ជាបន្ត" ថា *"នឹងនាំមកនូវការយកថ្លៃបន្ថែម"* សម្រាប់អ្នកបើកបរនៅរដ្ឋកាលីហ្វ័រញ៉ាជាច្រើននាក់។ ហេតុដូច្នេះហើយ ទើបសហជីពអ្នកប្រើប្រាស់ ដែលជាអង្គភាពគោលនយោបាយ និងការតស៊ូមតិនៃរបាយការណ៍អ្នកប្រើប្រាស់ បានជំទាស់នឹងសំណើប្រជាមតិលេខ 33។

សំណើប្រជាមតិលេខ 33 បង្កើនអត្រាធានារ៉ាប់រងសម្រាប់និស្សិតដែលរៀនចប់មហាវិទ្យាល័យ ដែលបច្ចុប្បន្នត្រូវការបើកបរដើម្បីធ្វើការងារថ្មីមួយ។

សំណើប្រជាមតិលេខ 33 បង្កើនអត្រាធានារ៉ាប់រងសម្រាប់ប្រជាពលរដ្ឋដែលបានបោះបង់ចោលការគ្របដណ្តប់របស់ខ្លួន ខណៈពេលជាសះស្បើយពីជំងឺ ឬរបួសធ្ងន់ធ្ងរ ដែលធ្វើឲ្យពួកគេមិនអាចបើកបរបាន។

សំណើប្រជាមតិលេខ 33 ធ្វើអនិយ័តកម្មដល់ឧស្សាហកម្មធានារ៉ាប់រង ដោយធ្វើឲ្យក្រុមហ៊ុនធានារ៉ាប់រងធំៗមានការទទួលខុសត្រូវកាន់តែតិចជាងមុន - ដែលជាមូល ហេតុបណ្តាលឲ្យវិធានការនេះត្រូវបានឧបត្ថម្ភថវិកា 99% ដោយមហាសេដ្ឋីក្រុមហ៊ុនធានារ៉ាប់រងម្នាក់ ដែលក្រុមហ៊ុនរបស់គាត់ឈ្មោះ Mercury Insurance មានប្រវត្តិ យកប្រាក់ពីអ្នកប្រើប្រាស់ច្រើនហួសហេតុ។ ក្រសួងធានារ៉ាប់រងរដ្ឋកាលីហ្វ័រញ៉ាបាន ថ្លែងថា ក្រុមហ៊ុន Mercuryមាន "កិត្តិស័ព្ទដែលសមនឹងទទួលបានចំពោះការរំលោភលើអ្នកប្រើប្រាស់របស់ខ្លួននិងការរំលោភច្បាប់ជាអន្តរជាតិមានការអួតអាងនិងព្រងើយកន្តើយ។" *បោះឆ្នោតទេ លើសំណើប្រជាមតិលេខ33ៈវាផាកពិន័យដល់អ្នកបើកបរដែលមានការទទួលខុសត្រូវដែលមិនត្រូវការសេវាធានារ៉ាប់រងយានយន្ត កាលពីអតីតកាល។*

សំណើប្រជាមតិលេខ 33 អនុញ្ញាតឲ្យក្រុមហ៊ុនធានារ៉ាប់រងយកថ្លៃកាន់តែខ្ពស់កប់ពពក ពីអ្នកប្រើប្រាស់ដែលមានប្រវត្តិ បើកបរល្អឥតខ្ចោះ ក៏ព្រោះតែពួកគេមិនបានទិញសេវាធានារ៉ាប់រងយានយន្តពេលខ្លះ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកប៉ុណ្ណោះ។ អ្នកបើកបរត្រូវតែបង់ការផាកពិន័យដ៏អយុត្តិធម៌នេះ ទោះបីជាកាលពីមុនពួកគេគ្មានរថយន្ត ឬមិនត្រូវការសេវាធានារ៉ាប់រងក៏ដោយ។ *បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 33៖ វាប៉ះពាល់ដល់គ្រួសារលំដាប់មធ្យមរបស់រដ្ឋកាលីហ្វ័រញ៉ា។*

ក្នុងបណ្តារដ្ឋទាំងឡាយ ដែលការយកថ្លៃដ៏ច្រើនរបស់សំណើប្រជាមតិលេខ 33 ជារឿងស្របច្បាប់ ជាលទ្ធផលគឺការបង់ប្រាក់បុព្វលាភរ៉ាប់រងកាន់តែខ្ពស់ជាងមុន៖

- ពលរដ្ឋនៅ Texas អាចបង់ 61% បន្ថែមទៀត។
- ពលរដ្ឋនៅ Nevada អាចបង់ 79% បន្ថែមទៀត។
- ពលរដ្ឋនៅ Florida អាចបង់ 103% បន្ថែមទៀត។

*បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 33៖ វាធ្វើឲ្យមានកាន់តែច្រើននូវអ្នកបើកបរគ្មានការធានារ៉ាប់រង ធ្វើឲ្យយើងទាំងអស់គ្នាត្រូវចំណាយប្រាក់កាន់តែច្រើន។*

យោងតាមក្រសួងធានារ៉ាប់រងរដ្ឋកាលីហ្វ័រញ៉ា ការផាកពិន័យហិរញ្ញវត្ថុ ដែលក្រុមហ៊ុនធានារ៉ាប់រងចង់ឲ្យបង់ *"បង្អួចទឹកចិត្ត [ប្រជាពលរដ្ឋ] មិនឲ្យទិញសេវាធានារ៉ាប់រងដែលអាចបន្ថែមទៅលើចំនួននៃអ្នកបើកបរទោចក្រយានយន្តដែលគ្មានការធានារ៉ាប់រង ហើយចុងក្រោយធ្វើឲ្យបាត់បង់ថ្លៃគ្របដណ្តប់អ្នកបើកបរទោចក្រយានយន្តដែលគ្មានការធានារ៉ាប់រងសម្រាប់រាល់អ្នកមានការធានារ៉ាប់រង។"*

មានអ្នកបើកបរគ្មានការធានារ៉ាប់រងកាន់តែច្រើន ធ្វើឲ្យប៉ះពាល់ដល់អ្នកបង់ពន្ធ និងរដ្ឋ។ *បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 33៖ ពលរដ្ឋកាលីហ្វ័រញ៉ាបានច្រានចោល សំណើច្បាប់ដែលស្ទើរតែដូចគ្នាបេះបិទនេះ កាលពីឆ្នាំ 2010 រួចមកហើយ។* យើងនាំគ្នាធ្វើឲ្យវាមានភាពច្បាស់លាស់ ចំពោះអ្នកទទួលផលប្រយោជន៍ពិសេសដ៏មាន អំណាចទាំងនេះថា ទេ គឺមានន័យថា ទេ។

កុំឱ្យក្រុមហ៊ុនធានារ៉ាប់រងមានអំណាចសំរាប់តំឡើងអត្រាបង់ប្រាក់របស់យើង។ *បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 33.* វាល្អខ្លាំងណាស់គួរឱ្យជឿ ស្វែងយល់ថែមទៀត ចូរទស្សនាគេហទំព័រ *http://www.StopTheSurcharge.org*

**HARVEY ROSENFIELD**, អ្នកបង្កើត
អង្គការឃ្លាំមើលអ្នកប្រើប្រាស់

**ELISA ODABASHIAN**, នាយក
ការិយាល័យឆ្នេរខាងលិច និងការឃោសនារដ្ឋ, ក្រុមអ្នកប្រើប្រាស់
នាយកដ្ឋាននយោបាយ និងគាំទ្រនៃរបាយការណ៍អ្នកប្រប្រាស់

**NAN BRASMER**, ប្រធាន
សម្ព័ន្ធកាលីហ្វ័រញ៉ាសំរាប់អាមេរិកាំងចូលនិវត្តន៍

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 33 ★

ពលរដ្ឋកាលីហ្វ័រញ៉ា ដែលមានការធានារ៉ាប់រងរថយន្ត ទទួលបានការបញ្ចុះតម្លៃសម្រាប់ការគោរពច្បាប់ ប៉ុន្តែក្រោមច្បាប់បច្ចុប្បន្ននេះ ប្រសិនបើអ្នកប្តូរក្រុមហ៊ុន អ្នកនឹងបាត់បង់ការបញ្ចុះតម្លៃរបស់អ្នក។

សំណើប្រជាមតិលេខ 33 កែតម្រូវបញ្ហានេះ ដោយអនុញ្ញាតឲ្យអ្នករក្សាបាននូវរង្វាន់នេះ ហើយស្វែងរកដំណោះស្រាយកាន់តែប្រសើរជាមួយក្រុមហ៊ុនមួយផ្សេងទៀត។

អ្នកប្រឆាំងកំពុងប្រើល្បិចដ៏កម្រ និងភាពកខ្វក់។ មែនហើយ អ្នកគាំទ្រសំណើប្រជាមតិលេខ 33 និងអតីតទាហាន កាលពីសម័យសង្គ្រាមលោកលើកទី II លោក George Joseph បានកសាងក្រុមហ៊ុនដ៏ជោគជ័យមួយ ដោយផ្តល់សេវាអតិថិជន និងអត្រាទាបដែលពលរដ្ឋកាលីហ្វ័រញ៉ាគាំទ្រ។

សូមអានសំណើប្រជាមតិលេខ 33 ដើម្បីដឹងការពិត។

អ្នកពន្លត់អគ្គីភ័យ និងសមាគមតម្រួតមហាវិថីរដ្ឋកាលីហ្វ័រញ៉ា គាំទ្រសំណើប្រជាមតិលេខ 33 ពីព្រោះពួកគេចង់ឲ្យមនុស្សគ្រប់រូបមានការធានារ៉ាប់រង និងឱកាសសម្រាប់ពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ស្វែងរកដំណោះស្រាយសេវាធានារ៉ាប់រងយានយន្តកាន់តែប្រសើរមួយ។

វិទ្យាស្ថាន Greenlining - ដែលជាក្រុមអ្នកប្រើប្រាស់ ដែលត្រូវបានស្ថាបនាឡើង ដើម្បីប្រយុទ្ធប្រឆាំងនឹងទម្លាប់ធ្វើអាជីវកម្មអយុត្តិធម៌- គាំទ្រសំណើប្រជាមតិលេខ 33 ពីព្រោះវាការពារអ្នកប្រើប្រាស់ និងអនុញ្ញាតឲ្យមានការបញ្ចុះតម្លៃនេះ ដល់មនុស្សគ្រប់រូប ដែលបានគោរពច្បាប់។

- សំណើប្រជាមតិលេខ 33 អនុញ្ញាតឲ្យអ្នកបើកបរប្តូរក្រុមហ៊ុនធានារ៉ាប់រង និងរក្សាការបញ្ចុះតម្លៃគ្របដណ្តប់ជាបន្តរបស់ពួកគេ។
- សំណើប្រជាមតិលេខ 33 ផ្តល់រង្វាន់ជូនអ្នកបើកបរ សម្រាប់ការគោរពច្បាប់ និងរក្សាការធានារ៉ាប់រងរថយន្តជាមួយក្រុមហ៊ុនណាមួយដែលអ្នកជ្រើសរើសក៏បាន។
- សំណើប្រជាមតិលេខ 33 ធ្វើឲ្យកាន់តែងាយស្រួលក្នុងការប្តូរក្រុមហ៊ុនធានារ៉ាប់រង ដែលនាំឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំង និងអត្រាទាបសម្រាប់មនុស្សគ្រប់រូប។
- សំណើប្រជាមតិលេខ 33 ការពារអ្នកប្រើប្រាស់ និងអនុវត្តការបញ្ចុះតម្លៃគ្របដណ្តប់ជាបន្ត ចំពោះមនុស្សគ្រប់រូបដែលគោរពច្បាប់។
- សំណើប្រជាមតិលេខ 33 ការពារគ្រួសារទាហាន អ្នកប្រើប្រាស់ដែលគ្មានការងារធ្វើ ឬត្រូវបានអនុញ្ញាតឲ្យសម្រាកពីការងារបណ្តោះអាសន្ន និងអ្នករៀនបើកបរ ហើយនឹងផ្តល់គ្រឿងលើកទឹកចិត្តដល់អ្នកបើកបរដែលគ្មានការធានារ៉ាប់រង ឲ្យទិញសេវាធានារ៉ាប់រង។

ក្រុមអតីតយុទ្ធជន រួមមានអតីតយុទ្ធជនសង្គ្រាមបរទេស និងវេទិកា GI គាំទ្រសំណើប្រជាមតិលេខ 33។

*បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 33*

**ROBERT T. WOLF**, ប្រធាន
អ្នកពន្លត់អគ្គិភ័យ CDF

**JULIAN CANETE**, ប្រធាន
សភាពាណិជ្ជកម្មហ៊ីស្ប៉ានិកកាលីហ្វ័រញ៉ា

**SAMUEL KANG**, General Counsel
ស្ថាប័ន Greenlining

សំណើប្រជាមតិ
# 34 ទោសប្រហារជីវិត។ លក្ខន្តិកៈផ្តួចផ្តើម។

**ចំណាងជើងជាផ្លូវការ និងសេចក្ដីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

## ទោសប្រហារជីវិត។ លក្ខន្តិកៈផ្តួចផ្តើម។

- លុបចោលទោសប្រហារជីវិត ជាការដាក់ទណ្ឌកម្មអតិបរិមា សំរាប់មនុស្សដែលបានរកឃើញកំហុសបទឃាតកម្ម និងជំនួសវាជាមួយនឹងការជាប់គុកមួយជីវិត ដោយមិនអាចមានលក្ខខ័ណ្ឌការដោះលែងឡើយ។
- អនុវត្តបកក្រោយ ទៅលើមនុស្សដែលបានកាត់ទោសឲ្យស្លាប់រួចហើយ។
- ថ្លែងថា មនុស្សដែលបានរកឃើញកំហុសបទឃាតកម្ម ត្រូវតែធ្វើការក្នុងពេលនៅក្នុងគុក ដូចបានចែងដោយក្រសួង កែខៃខ្លួន និងស្តារលទ្ធភាព ដែលប្រាក់ថ្លៃឈ្នួលរបស់គេត្រូវកាត់ចេញ ដើម្បីឲ្យបានអនុវត្តទៅលើការផាកពិន័យសំណង ចំពោះជនរងគ្រោះណាមួយ ឬបទបញ្ជាប្រឆាំងនឹងគេ។
- ផ្តល់ប្រាក់ $100 លាន ទៅឲ្យភ្នាក់ងារនគរបាល សំរាប់ការសើបអង្កេតឃាតកម្ម និងករណីការរំលោភផ្លូវភេទ។

**សេចក្ដីសង្ខេបនៃអ្នកវិភាគនីតិបញ្ញត្តិ ប្រមាណនូវផលប៉ះពាល់ហិរញ្ញវត្ថុទាំងស្រុងរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ៖**

- ការសន្សំប្រាក់របស់រដ្ឋ និងខោនធី ជាប់ទាក់ទងចំពោះការវិនិច្ឆ័យទោសឃាតកម្ម ការតវ៉ាទោសប្រហារជីវិត និងការកែ ខៃខ្លួន ប្រហែល $100លានជាប្រចាំឆ្នាំ ក្នុងពេលពីរបីឆ្នាំដំបូង ដែលកើនឡើងប្រហែល $130 លានជាប្រចាំឆ្នាំ បន្ទាប់ ពីនោះមក។ ការប្រមាណនេះអាចនឹងខ្ពស់ជាង ឬទាបជាងដោយដប់លានដុល្លារ អាស្រ័យយ៉ាងធំទៅលើវិធានការបាន ប្រតិបត្តិជាយ៉ាងណា និងបើមិនដូច្នោះទេ យោងទៅលើកំរិតទុរជនដែលត្រូវបានកាត់ទោសឲ្យស្លាប់ និងត្រូវបានប្រតិបត្តិ នៅអនាគត។
- រដ្ឋចំណាយមួយដង សរុបទាំងអស់ $100 លាន សំរាប់ប្រាក់សម្បទានទៅឲ្យភ្នាក់ងារនគរបាលមូលដ្ឋាន ដែលត្រូវបើកឲ្យក្នុងពេលបួនឆ្នាំខាងមុខ។

34

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### សាវតារ

***ឃាតកម្ម និងទោសប្រហារជីវិត។*** ជាទូទៅឃាតកម្មកម្រិតទីមួយត្រូវបានកំណត់ថា ជាការសម្លាប់មនុស្សខុសច្បាប់ ដែល (1) បានគិតទុកជាមុន និងគ្រោងទុកជាមុន ឬ (2) កើតឡើងនៅពេលតែមួយ ដូចបទឧក្រិដ្ឋពិតប្រាកដផ្សេងទៀត ដូចជា ការចាប់ជំរិត។ វាអាចត្រូវដាក់ទោសបានឲ្យជាប់ពន្ធនាគារអស់មួយជីវិតដោយមិនមានលក្ខខណ្ឌដោះលែង ដោយគណៈកម្មការរដ្ឋទទួលបន្ទុកលក្ខខណ្ឌដោះលែង បន្ទាប់ពីជាប់ពន្ធនាគារយ៉ាងតិចរយៈពេល 25 ឆ្នាំ។ ទោះយ៉ាងណា ច្បាប់របស់រដ្ឋពេលបច្ចុប្បន្នកំណត់ការដាក់ទណ្ឌកម្មបទឃាតកម្មកម្រិតទីមួយ ឲ្យជាប់ពន្ធនាគារអស់មួយជីវិតឬហូតដល់ពេលស្លាប់ ដោយមិនអាចមានលក្ខខណ្ឌដោះលែង នៅពេលដែលបានបញ្ជាក់ "កាលៈទេសៈពិសេស" នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់និងបង្ហាញឲ្យឃើញនៅក្នុងតុលាការ។ ច្បាប់របស់រដ្ឋដែលមានស្រាប់កំណត់ចំនួនកាលៈទេសៈពិសេសដែលអាចចោទប្រកាន់ ដូចជា ក្នុងករណី នៅពេលដែលឃាតកម្មត្រូវបានធ្វើឡើងដោយសារតែទទួលបាន ផលប្រយោជន៍ហិរញ្ញវត្ថុ ជាពិសេសរឿងឃោឃៅ ឬត្រូវបានប្រព្រឹត្ត ក្នុងខណៈពេលដែលចុងចោទ ត្រូវបានពាក់ព័ន្ធក្នុងសកម្មភាពឧក្រិដ្ឋដែលបានបញ្ជាក់ផ្សេងទៀត។ ជាទូទៅក្រុមប្រឹក្សាតុលាការកំណត់ថាតើទោសមួយណាត្រូវបានអនុវត្តនៅពេលដែលកាលៈទេសៈពិសេសត្រូវបានចោទប្រកាន់ និងបង្ហាញឲ្យឃើញ។

***ការអនុវត្តន៍ទោសប្រហារជីវិតនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។*** ការជំនុំជម្រះក្តីឃាតកម្ម ដែលត្រូវការការកាត់ទោសប្រហារជីវិតត្រូវបានបែងចែកជាពីរដំណាក់កាល។ ដំណាក់កាលទីមួយពាក់ព័ន្ធនឹងការកំណត់ថាតើចុងចោទមានកំហុសបទឃាតកម្ម និងកាលៈទេសៈពិសេសដែលបានផ្លាស់ប្តូរ ខណៈពេលដែល ដំណាក់កាលទីពីរ ពាក់ព័ន្ធនឹងការកំណត់ ថាតើការដាក់ទោសប្រហារជីវិតត្រូវបានអនុវត្តឬអត់។ ដោយអនុលោម ទៅតាមច្បាប់របស់រដ្ឋដែលមានស្រាប់ សាលក្រមដាក់ទោសប្រហារជីវិតត្រូវបានប្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ នៅតុលាការកំពូលរដ្ឋកាលីហ្វ័រញ៉ា។ ក្នុង"បណ្តឹងឧទ្ធរណ៍ដោយផ្ទាល់" ទាំងនេះ មេធាវីរបស់ចុងចោទ ចោទទាមទារថា ការបំពានច្បាប់រដ្ឋ ឬច្បាប់ធម្មនុញ្ញសហព័ន្ធបានកើតឡើងអំឡុងពេលជំនុំជម្រះក្តី ដូចជាភស្តុតាងមិនសមរម្យដែលត្រូវរួមបញ្ចូល ឬមិនបានរួមបញ្ចូលក្នុងការជំនុំជម្រះក្តីនេះ។ ប្រសិនបើ តុលាការកំពូលរដ្ឋកាលីហ្វ័រញ៉ាបញ្ជាក់ពីសាលក្រម និងការកាត់ទោសប្រហារជីវិត ចុងចោទអាចស្នើឲ្យតុលាការកំពូលអាមេរិកវាយតម្លៃការសម្រេចចិត្ត។ បន្ថែមទៅលើបណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ជាធម្មតាករណីកាត់ទោសប្រហារជីវិតពាក់ព័ន្ធនឹងបញ្ហាប្រយុទ្ធខាងផ្នែកច្បាប់ទ្រង់ទ្រាយធំទាំងនៅឯតុលាការរដ្ឋ និងតុលាការសហព័ន្ធ។ បញ្ហាប្រយុទ្ធទាំងនេះពាក់ព័ន្ធនឹងកត្តាផ្សេងៗគ្នាពីអ្វី ដែលបានពិចារណាក្នុងបណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ (ដូចជាការអះអាងដែលថាការប្រឹក្សារបស់ចុងចោទមិនមានប្រសិទ្ធិភាព) ហើយជាធម្មតា សំដៅថាជាញត្តិ "ដីការឱ្យយកខ្លួនមកតុលាការ- "habeas corpus" ។ ជាទីបញ្ចប់ អ្នកជាប់ឃុំឃាំងដែលបានទទួលការកាត់ទោសប្រហារជីវិត អាចស្នើសុំផងដែរថាពី អភិបាលរដ្ឋឲ្យកាត់បន្ថយការកាត់ទោសរបស់ពួកគេ។ បច្ចុប្បន្ននេះ ដំណើរការដែលអនុវត្តតាមការកាត់ទោសប្រហារជីវិតអាចចំណាយពេលច្រើនទសវត្ស ដើម្បីធ្វើឲ្យច្បាប់នេះចប់ជាស្ថាពរក្នុងរដ្ឋកាលីហ្វ័រញ៉ា។

ទាំងការចំណាយរបស់រដ្ឋ និងរដ្ឋាភិបាលខោនធីដែលពាក់ព័ន្ធនឹងការជំនុំជម្រះក្តីឃាតកម្ម រួមមានតម្លៃសម្រាប់តុលាការ និងព្រះរាជអាជ្ញា ព្រមទាំងសម្រាប់ការពារជនដែលជាប់ចោទពីបទឃាតកម្មដែលមិនអាចរកអ្នកតំណាងបាន។ លើសពីនេះ ការចំណាយរបស់រដ្ឋសម្រាប់មេធាវី ដែលបានផ្តល់ដោយក្រសួងយុត្តិធម៌របស់រដ្ឋដែលស្វែងរកការលើកទោសប្រហារជីវិតក្នុងដំណើរការបណ្តឹងឧទ្ធរណ៍។ ភ្នាក់ងាររបស់រដ្ឋផ្សេងៗទៀត [ រួមមាន ការិយាល័យអ្នកការពារក្តីសាធារណៈរបស់រដ្ឋ និងមជ្ឈមណ្ឌលធនធានផ្នែកដីកាឲ្យយកខ្លួនមកតុលាការ (Habeas Corpus Resource Center)] ត្រូវមានភារៈផ្តល់ការធ្វើបទបង្ហាញទៅបុគ្គលដែលបានទទួលការកាត់ទោសប្រហារជីវិត ប៉ុន្តែមិនអាចមានលទ្ធភាពរកអ្នកតំណាងបាន។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ (ត)

ចាប់តាំងពីច្បាប់ កាត់ទោសប្រហារជីវិតពេលបច្ចុប្បន្នត្រូវបានអនុម័តក្នុងរដ្ឋកាលីហ្វ័រញ៉ាក្នុងឆ្នាំ 1978 មក មនុស្សប្រហែលជា 900 នាក់បានទទួលការកាត់ទោសប្រហារជីវិត។ ក្នុងចំណោយអ្នកទាំងអស់នេះ មានមនុស្ស 14 អ្នកត្រូវបានប្រហារជីវិត 83 នាក់បានស្លាប់មុនពេលប្រហារជីវិតហើយប្រហែលជា 75 នាក់ តុលាការបានកាត់បន្ថយការជាប់ទោសរបស់ពួកគេ។ គិតមកត្រឹមខែកក្កដា ឆ្នាំ 2012 រដ្ឋកាលីហ្វ័រញ៉ាមានជនល្មើសចំនួន 725 នាក់ក្នុងពន្ធនាគាររបស់រដ្ឋដែលបានកាត់ទោសប្រហារជីវិត។ ភាគច្រើននៃពួកជនល្មើស ស្ថិតនៅដំណាក់កាលផ្សេងៗនៃបណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ ឬនីតិវិធីត្រួតពិនិត្យកំរង habeas corpus។ អ្នកជាប់ឃុំឃាំងភេទប្រុសដែលបានថ្កោលទោស ជាធម្មតាត្រូវបានផ្តល់កន្លែងឲ្យស្នាក់នៅពន្ធនាគាររបស់រដ្ឋ San Quentin (នៅជួរមរណៈ) ខណៈពេលដែលអ្នកជាប់ឃុំឃាំងភេទស្រីត្រូវបានថ្កោលទោសត្រូវបានផ្តល់កន្លែង ឲ្យស្នាក់នៅមជ្ឈមណ្ឌលស្ត្រីកាលីហ្វ័រញ៉ា នៅ Chowchilla។ បច្ចុប្បន្ននេះ រដ្ឋមានបទបញ្ជាសន្តិសុខ និងនីតិវិធីផ្សេងៗគ្នាដែលផ្តល់ជាលទ្ធផលនូវតម្លៃសន្តិសុខកើនឡើងសម្រាប់អ្នកជាប់ឃុំឃាំងទាំងនោះ។ ឧទាហរណ៍ អ្នកជាប់ឃុំឃាំងក្រោមការកាត់ទោសប្រហារជីវិតជាទូទៅ ត្រូវបានដាក់ខ្នោះ និងការពារគ្រប់ពេលវេលាដោយមន្ត្រីម្នាក់ ឬពីរនាក់ ខណៈពេលដែលនៅខាងក្រៅបន្ទប់គុករបស់ពួកគេ។ លើសពីនេះ ជនល្មើសទាំងនេះ បច្ចុប្បន្ន ត្រូវតម្រូវឲ្យនៅក្នុងពន្ធនាគារដាច់ដោយឡែកពីគ្នា ប៉ុន្តែអ្នកជាប់ឃុំឃាំងផ្សេងទៀតភាគច្រើនចែកកន្លែងគ្នាដេក។

## សេចក្តីស្នើច្បាប់

វិធានការនេះ លុបចោលច្បាប់កាត់ទោសប្រហារជីវិតពេលបច្ចុប្បន្នរបស់រដ្ឋ។ លើសពីនេះ ជាទូទៅវិធានការនេះ តម្រូវឲ្យឃាតករធ្វើការងារអំឡុងពេលនៅក្នុងពន្ធនាគារ ហើយផ្តល់ថវិកាថ្មីរបស់រដ្ឋសម្រាប់ការអនុវត្តច្បាប់តាមមូលដ្ឋានតាមលក្ខខណ្ឌដែលបានកំណត់អណត្តិ។

***កាលុបបំបាត់ការកាត់ទោសប្រហារជីវិត។*** ក្រោមវិធានការនេះ មិនមានជនល្មើសណាត្រូវបានរដ្ឋកាត់ទោសប្រហារជីវិតនោះទេ។ វិធានការនេះបញ្ជាក់ផងដែរថា ពេលបច្ចុប្បន្ន ជនល្មើសក្រោមច្បាប់កាត់ទោសប្រហារជីវិតនឹងមិនត្រូវបានប្រហារជីវិត ហើយផ្ទុយទៅវិញ នឹងត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតជាថ្មី ដោយមិនអាចមានលក្ខខណ្ឌដោះលែង។ វិធានការនេះអាចឲ្យតុលាការកំពូលកាលីហ្វ័រញ៉ា ផ្ទេរឧទ្ធរណ៍ការកាត់ទោសប្រហារជីវិតដែលមានស្រាប់ដោយផ្ទាល់ និងញត្តិកំរង habeas corpus ទៅតុលាការឧទ្ធរណ៍ ឬតុលាការកំពូលរបស់រដ្ឋ។ តុលាការទាំងនេះត្រូវដោះស្រាយបញ្ហាដែលមាន ថ្មីបើបន្ទាប់ពីមានការផ្លាស់ប្តូរការកាត់ទោសទាំងនេះឲ្យជាប់ ពន្ធនាគារអស់មួយជីវិតដោយមិនអាចមានលក្ខខណ្ឌដោះលែង។

***លក្ខខណ្ឌតម្រូវការងាររបស់អ្នកជាប់ឃុំឃាំង។*** ច្បាប់របស់រដ្ឋនាពេលបច្ចុប្បន្នជាទូទៅ តម្រូវឲ្យអ្នកជាប់ឃុំឃាំង ដូចជា ឃាតករដែលធ្វើការនៅពេលពួកគេជាប់ពន្ធធនាគារ។ បទបញ្ជារបស់រដ្ឋកាលីហ្វ័រញ៉ាអនុញ្ញាតឲ្យលើកលែងទោសអ្នកជាប់ឃុំឃាំងខ្លះ ដើម្បីធ្វើការតាមលក្ខខណ្ឌតម្រូវការងារទាំងនេះ រួមមាន ចំពោះអ្នកជាប់ឃុំឃាំងដែលមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្នុងការចូលរួមក្នុងកម្មវិធីការងារ។ លើសពីនេះ អ្នកជាប់ឃុំឃាំងត្រូវតម្រូវឲ្យធ្វើការទូទាត់សងជនរងគ្រោះ ដោយសារបទល្មើសទៅតាមដីការបស់តុលាការ។ វិធាននេះបានបញ្ជាក់ថាអ្នកដែលបានរកឃើញថាមានកំហុសធ្វើឃាតគេត្រូវធ្វើការ និងកាត់ប្រាក់ខែរបស់ពួកគេ ដើម្បីយកទៅសងបំណុលដែលគេបានជំពាក់ជនរងគ្រោះដោយសារបទល្មើស ខណៈពេលពួកគេធ្វើការនៅក្នុងពន្ធធនាគារ របស់រដ្ឋដែលយោងទៅតាមបទបញ្ជារបស់រដ្ឋ។ ព្រោះវិធាននេះមិនបានកែប្រែបទបញ្ជារបស់រដ្ឋទេ ដែលការអនុវត្តពន្ធធនាគារដែលមានស្រាប់នោះត្រូវទាក់ទងនឹងលក្ខខណ្ឌតម្រូវការងាររបស់ អ្នកជាប់ឃុំឃាំង ចាំបាច់ណាស់បទបញ្ជានេះមិនត្រូវបានគេកែប្រែឡើយ។

***ការបង្កើតមូលនិធិសម្រាប់ការអនុវត្តច្បាប់ក្នុងតំបន់។*** វិធាននេះបានបង្កើតមូលនិធិពិសេសថ្មីមួយ ដែលគេហៅថា មូលនិធិ SAFE របស់រដ្ឋកាលីហ្វ័រញ៉ា ដើម្បីផ្តល់ជំនួយឲ្យនាយកដ្ឋាននគរបាល ស្នងការនគរបាល ការិយាល័យមេធាវីក្នុងស្រុក ក្នុងគោលបំណងបង្កើនការកាត់បន្ថយអត្រាឃាតកម្ម និងការចាប់រំលោភ។ ឧទាហរណ៍ វិធាននេះបានបញ្ជាក់ថា លុយត្រូវប្រើដើម្បីបង្កើនការកាត់បន្ថយអត្រាឃាតកម្ម និងការធ្វើការស៊ើបអង្កេតជនល្មើសរំលោភសេពសន្ថវៈ ឬអង្គភាពបណ្តឹងចោទប្រកាន់។ នៅក្នុងវិធាននេះ ចំនួនលុយសរុប $100 លានដុល្លារ ត្រូវផ្ទេរពីថវិកាទូទៅរបស់រដ្ឋ ទៅសុវត្ថិភាពមូលនិធិ SAFE របស់រដ្ឋកាលីហ្វ័រញ៉ាដែលមានរយៈពេលជាងបួនឆ្នាំ — ថវិកា $10 លានដុល្លារក្នុងឆ្នាំ 2012-13 និងថវិកា $30 លានដុល្លារក្នុងឆ្នាំនីមួយៗ ពីឆ្នាំ 2013-14 ដល់ឆ្នាំ 2015-16។ លុយនៅក្នុងមូលនិធិរបស់រដ្ឋកាលីហ្វ័រញ៉ា SAFE នឹងត្រូវចូលរួមចំណែកក្នុងភ្នាក់ងារការអនុវត្តច្បាប់ក្នុងស្រុកដោយផ្អែកលើរូបមន្តដែលបានកំណត់ដោយអគ្គមេធាវីរបស់រដ្ឋ។

## ឥទ្ធិពលសារពើពន្ធ

វិធាននេះនឹង មានឥទ្ធិពលសារពើពន្ធមួយចំនួនទៅលើ រដ្ឋាភិបាលរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន។ ផលប៉ះពាល់ សារពើពន្ធសំខាន់ៗនៃវិធានការនេះ នឹងត្រូវលើកយកមកពិភាក្សា ដូចខាងក្រោមនេះ។

## ការជំនុំជម្រះក្តីឃាតកម្ម

***និតិវិធីតុលាការ។*** វិធានការនេះអាចកាត់បន្ថយការចំណាយរបស់រដ្ឋ និងខោនធីទាក់ទងនឹងករណីឃាតកម្មមួយចំនួន បើពុំនោះសោតទេអាចត្រូវបានកាត់ទោសប្រហារជីវិតស្ថិតក្រោមច្បាប់បច្ចុប្បន្ន។ ករណីទាំងនេះ អាចនឹងត្រូវចំណាយតិច ប្រសិនបើទោសប្រហារជីវិតមិនមានជម្រើស សម្រាប់ហេតុផលសំខាន់ពីរ។ ទីមួយ រយៈពេលនៃការ ជំនុំជម្រះក្តីមួយចំនួនអាចត្រូវបានបង្រួមឲ្យខ្លី។ ការបង្រួមនេះ ដោយសារតែមិនមានជំហានដាច់ពីគ្នាដើម្បីកំណត់

ថាតើទោសប្រហារជីវិតត្រូវបានគេដាក់ឲ្យអនុវត្តដែរឬទេ។ ទិដ្ឋភាពផ្សេងទៀតនៃការជំនុំជម្រះក្តីឃាតកម្ម ក៏អាចត្រូវបានបង្រួមឲ្យខ្លីដែរ។ ឧទាហរណ៍ រយៈពេលជ្រើសរើសគណៈវិនិច្ឆ័យសម្រាប់ការជំនុំជម្រះក្តីមួយចំនួន អាចត្រូវបានកាត់ចេញ នៅពេលមិនមានភាពចាំបាច់ដើម្បីដកអ្នកវិនិច្ឆ័យ ដែលមិនមានបំ

34

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ (ត)

ណងអនុវត្តទោសប្រហារជីវិត។ ទីពីរ ការលុបទោសប្រហារជីវិត អាចកាត់បន្ថយការចំណាយរបស់ខោនធីទៅលើព្រះរាជអាជ្ញា និងអ្នកការពារសាធារណៈសម្រាប់ករណីឃាតកម្មមួយចំនួន។ ការចំណាយនេះ ដោយសារតែជាទូទៅភ្នាក់ងារទាំងនេះប្រើមេធាវីក្នុងករណីដែលតម្រូវឲ្យមានការកាត់ទោសប្រហារជីវិត និងការចំណាយយ៉ាងច្រើន ដែលទាក់ទងទៅនឹងការស៊ើបអង្កេត និងការរៀបចំផ្សេងៗសម្រាប់ដំណាក់កាលនៃការកាត់ទោស ក្នុងករណីបែបនេះ។

***ពន្ធនាគាររបស់ខោនធី។*** ការចំណាយលើពន្ធនាគារ របស់ខោនធីក៏អាចត្រូវបានកាត់បន្ថយដែរ ដោយសារ តែប្រសិទ្ធភាពរបស់វិធានការលើការជំនុំជម្រះក្តី ឃាតកម្ម។ អ្នកដែលទទួលបន្ទុកការជំនុំជម្រះក្តីឃាតកម្មជាពិសេសករណីដែលឈានដល់ការកាត់ ទោសប្រហារជីវិត ដែលជាទូទៅនៅមាននៅក្នុង ពន្ធនាគាររបស់ខោនធីរហូតដល់ចប់ការជំនុំជម្រះក្តីនិងការកាត់ទោសរបស់ពួកគេ។ នៅពេលករណីឃាត កម្មមួយចំនួនត្រូវបានគេបង្រួមឲ្យខ្លី ដោយសារតែ ការលុបចោលនូវការកាត់ទោសប្រហារជីវិតអ្នកដែលជាប់ចោទពីបទឃាតកម្មអាចចំណាយពេលតិចនៅក្នុងពន្ធនាគាររបស់ខោនធីមុនពេលបញ្ជូនទៅពន្ធនាគាររដ្ឋ។ លទ្ធផលដូចនេះ នឹងកាត់បន្ថយការចំណាយរបស់ពន្ធធានាខោនធី និងបង្កើនការចំណាយរបស់ពន្ធនាគាររបស់រដ្ឋ។

***ប្រាក់សន្សំ។*** រដ្ឋនិងខោនធីអាចទទួលបានប្រាក់ជាច្រើនរយលានដុល្លារពីការសន្សំប្រចាំឆ្នាំទូទាំងរដ្ឋ ដែលទទួលបានពីការកាត់បន្ថយការចំណាយដែលទាក់ទង នឹងការជំនុំជម្រះក្តីឃាតកម្ម។ ទឹកប្រាក់សន្សំជាក់ស្តែងអាចអាស្រ័យលើកត្តាជាច្រើនដូចជា ចំនួននៃការជំនុំជម្រះការកាត់ទោសប្រហារជីវិត ដែលអាចធ្វើឡើងដោយមិនមានវិធានការ។ វាក៏អាចផងដែរ ដែលរដ្ឋនិងខោនធីនឹងប្តូរទិសដៅខ្លះនៃធនធានដែលទាក់ទងនឹង តុលាការរបស់ពួកគេទៅសកម្មភាពតុលាការផ្សេងទៀត។ ដូចគ្នានោះដែរការសន្សំរបស់ពន្ធនាគារខោនធីអាច ទូទាត់ទៅលើចំនួនគ្រែរបស់ពន្ធនាគារដែលលែងត្រូវការសម្រាប់ចុងចោទក្នុងការជំនុំជម្រះការកាត់ទោស ប្រហារជីវិតដែលបានប្រើសម្រាប់ជនល្មើសផ្សេងៗ ដូចជាអ្នក ដែលសព្វថ្ងៃត្រូវបានដោះលែងមុនកំណត់ ដោយសារតែពន្ធនាគារ នៅខោនធីខ្លះមិនមានកន្លែងគ្រប់គ្រាន់។

ប្រាក់សន្សំខាងលើអាចទូទាត់បានមួយផ្នែកទៅលើវិសាលភាពដែលការលុបទោសប្រហារជីវិតបានកាត់បន្ថយការលើកទឹកចិត្តសម្រាប់ជនល្មើសឲ្យឆ្លើយទទួលកំហុសជាថ្នូរនឹងការកាត់ទោស ស្រាលក្នុងករណីឃាតកម្មមួយចំនួន។ ប្រសិនបើ ទោសប្រហារជីវិតត្រូវបានហាមឃាត់ ហើយមានករណីបន្ថែមឈានដល់ការជំនុំជម្រះជំនួសឲ្យការដោះស្រាយ តាមរយៈការយល់ព្រមទទួលកំហុស ការចំណាយរបស់រដ្ឋ និងខោនធីបន្ថែមទៅលើការគាំពារតុលាការ ការកាត់ទោស ប្រឹក្សាខាងដើមចោទ ក៏ដូចជាពន្ធនាគារខោនធីអាចនឹងកើតមានជាលទ្ធផល។ វិសាលភាពចំពោះការចំណាយនេះអាចកើតឡើង នោះមិនមានអ្នកណាដឹងឡើយ។

### បណ្តឹងវិវាទឧទ្ធរណ៍

កន្លងទៅនេះ វិធានអាចកាត់បន្ថយការចំណាយរបស់រដ្ឋតាមរយៈតុលាការកំពូលរបស់រដ្ឋកាលីហ្វ័រញ៉ា និងភ្នាក់ងារ របស់រដ្ឋ ដែលចូលរួមក្នុងដំណើរការបណ្តឹងឧទ្ធរណ៍នៃការកាត់ទោស ប្រហារជីវិត។ ការសន្សំរបស់រដ្ឋទាំងនេះអាចកើន ដល់ $50 លានដុល្លារជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាងណា ការសន្សំទាំងនេះ ទំនងជាអាចទូទាត់ដោយផ្នែកក្នុងរយៈពេលខ្លីប៉ុណ្ណោះ ដោយសារតែការចំណាយមួយចំនួនរបស់រដ្ឋសម្រាប់បណ្តឹងឧទ្ធរណ៍ អាចបន្តរហូតដល់តុលាការបានដោះសាស្រ្ត រាល់បណ្តឹងឧទ្ធរណ៍ដែលមិនទាន់បានសម្រេចសម្រាប់អ្នកជាប់ឃុំឃាំងដែលបានទទួលការកាត់ទោសប្រហារជីវិតពីមុនៗមក។ ក្នុងរយៈពេលវែង អាចនឹងមានការចំណាយរបស់រដ្ឋ និងមូលដ្ឋានតិចតួច—ដែលសរុបប្រហែល $1 លានដុល្លារជារៀងរាល់ឆ្នាំ — សម្រាប់ទទួលសវនាការបណ្តឹងឧទ្ធរណ៍ ពីជនល្មើសបន្ថែមទៀតដែលទទួលការកាត់ទោសឲ្យជាប់ពន្ធនាគារមួយជីវិត ដោយគ្មានថ្ងៃដោះលែងដោយមានលក្ខខណ្ឌ។

### មន្ទីរកែប្រែរដ្ឋ

ការលុបចោលទោសប្រហារជីវិត នឹងមានឥទ្ធិពលដល់ការចំណាយលើពន្ធនាគាររបស់រដ្ឋដោយវិធីផ្សេងៗ។ ម្យ៉ាង ការលុបចោលទោស ប្រហារជីវិតអាចបណ្តាលឲ្យមានចំនួនជនជាប់ឃុំឃាំង និងខ្ទង់ចំណាយលើពន្ធនាគារខ្ពស់ជាងមុនបន្តិចបន្តួចដូចជាការកាត់ទោសអ្នកជាប់ឃុំឃាំងដែលផ្តន្ទាទោសពីមុនឲ្យជាប់ពន្ធនាគារអស់មួយជីវិតដោយមិនអាចមានលក្ខខណ្ឌដោះលែង។ ពាក់ព័ន្ធទៅនឹងរយៈពេលដែលជនជាប់ឃុំឃាំង ចំណាយពេលជាប់ឃុំឃាំងដ៏យូររហូតដល់ស្លាប់នេះការចំណាយទាំងនេះទំនងជាមិនមានចំនួនច្រើនទេ។ ម្យ៉ាងទៀត ខ្ទង់ចំណាយចេះតែកើននេះ ទំនងជាច្រើនជាងការទូទាត់ដោយប្រាក់សន្សំដែលបានពីការមិនផ្តល់កន្លែងស្នាក់នៅដល់ជនជាប់ឃុំឃាំងរាប់រយអ្នក ដែលរង់ចាំការប្រហារជីវិត។ ដូចបានពិភាក្សាពីមុន ជាទូទៅការចំណាយលើការផ្តល់កន្លែងស្នាក់នៅដល់ជនជាប់ឃុំឃាំងដែលស្ថិតក្នុងការកាត់ទោសអស់មួយជីវិតវាថ្លៃជាងការចំណាយ លើជនជាប់ដែលប្រឈមនឹងការកាត់ទោសមួយជីវិតដោយមិនអាចមានលក្ខខណ្ឌដោះលែង ដោយសារវិធានការសន្តិសុខកាន់ តែថ្លៃចំពោះការផ្តល់កន្លែងស្នាក់នៅ និងគ្រប់គ្រងជនជាប់ឃុំឃាំងដែលកាត់ទោសប្រហារជីវិត។

ប្រសិទ្ធភាពសរុបនៃផលប៉ះពាល់សារពើពន្ធទាំងនេះទំនងជាកាត់បន្ថយលើខ្ទង់ចំណាយសរុបរបស់រដ្ឋ សម្រាប់ដំណើរការប្រព័ន្ធពន្ធនាគាររដ្ឋ ដោយមានចំនួនទឹកប្រាក់ប្រចាំឆ្នាំប្រហែលរាប់លានដុល្លារ។ ទោះបីជាការសន្សំទាំងនេះអាចច្រើន ឬ តិចដោយសារហេតុផលខុសៗគ្នាក៏ដោយ។ ឧទាហរណ៍ ប្រសិនបើអត្រាការកាត់ទោសប្រហារជីវិតដែលមាននៅពេលអនាគតដោយមិនមានការបង្កើនវិធានការ ខ្ទង់ចំណាយផ្តល់ការស្នាក់នៅដល់ជនជាប់ឃុំឃាំងនៅពេលអនាគតដែលបានកាត់ទោសប្រហារជីវិតនឹងត្រូវបានកាត់បន្ថយ។ ហេតុដូច្នេះ នឹងមានការកែប្រែការសន្សំទាបដែលបណ្តាលមកពីវិធានការលប់ចោលការកាត់ទោសប្រហារជីវិត។ ប្រសិនបើចំនួនការកាត់ទោសប្រហារជីវិតចំពោះបុគ្គលនៅពេលអនាគតដោយគ្មានការបង្កើនវិធានការ ខ្ទង់ចំណាយសម្រាប់ផ្តល់កន្លែងស្នាក់នៅ ដល់បុគ្គលទាំងនេះនៅក្នុងពន្ធនាគារក៏កើនឡើងដែរ។ ស្ថិតក្រោមសេណារីយ៉ូនេះការលុបចោលការកាត់ទោសប្រហារជីវិតនឹងបណ្តាលឲ្យការកែប្រែការសន្សំខ្ពស់ជាងការប៉ាន់ស្មានរបស់យើង។

### ថវិកាទូទៅបញ្ជូនទៅថវិការបស់ SAFE កាលីហ្វ័រញ៉ា

វិធានការនេះតម្រូវឲ្យផ្ទេរទឹកប្រាក់សរុបចំនួន $100 លានដុល្លារអាមេរិកពីថវិការដ្ឋទូទៅទៅឲ្យ មូលនិធិរដ្ឋកាលីហ្វ័រញ៉ា SAFE ចាប់ពីឆ្នាំ 2012-13 រហូតដល់ឆ្នាំ 2015-16។ ជាលទ្ធផល ប្រភពធនធានថវិកាទូទៅតិចតួចនឹង

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ



មានដើម្បីឧបត្ថម្ភកម្មវិធីរបស់ រដ្ឋផ្សេងៗក្នុងឆ្នាំទាំងនោះ ប៉ុន្តែមូលនិធិបន្ថែមនឹងមានសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន ជាអ្នកទទួលជំនួយទាំងនេះ។ ដោយហេតុថា មូលនិធិដែលបានផ្ដល់ពីមូលនិធិរដ្ឋកាលីហ្វ័រញ៉ា SAFE ទៅទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានបណ្ដាលឲ្យមានការចាប់ខ្លួន និងការកាត់ទោសបន្ថែម ហេតុនេះវិធានការនេះអាចបង្កើនការចំណាយរបស់រដ្ឋ និងខោនធីសំរាប់ដំណើរការជំនុំជម្រះក្ដីនិងពន្ធនាគារ។

### ឥទ្ធិពលសារពើពន្ធ ផ្សេងទៀត

***ការសាងសង់ពន្ធនាគារ។*** វិធានការនេះក៏អាចធ្វើឲ្យមានផលប៉ះពាល់ដល់ការចំណាយទៅលើការសាងសង់ពន្ធធនាគារនាពេលអនាគត ដោយសារតែការអនុញ្ញាតអោយរដ្ឋចៀសវាងការចំណាយទៅលើសម្ភារៈពាក់ព័ន្ធទៅនឹងការផ្ដល់កន្លែងស្នាក់នៅដែលមានចំនួនកើននៃអ្នកជាប់ឃុំឃាំងរងចាំប្រហារជីវិត។ ប៉ុន្តែវិសាលភាពនៃការសន្សំបែបនេះនឹងផ្អែកទៅលើកំណើននៃចំនួនអ្នកជាប់ពន្ធនាគារដែលបានផ្ដន្ទាទោសក្នុងពេលអនាគត ថាតើរដ្ឋគួតែជ្រើសរើសកន្លែងស្នាក់នៅប្រភេទណាសម្រាប់អ្នកជាប់ពន្ធនាគារដែលបានផ្ដន្ទាទោស និងកំណើនចំនួនអ្នកទោសទូទៅនាពេលអនាគត។

***ផលប៉ះពាល់លើអត្រាឃាតកម្ម។*** ដល់កំរិតដែលថាការហាមឃាត់ការប្រើប្រាស់ទោសប្រហារជីវិតអាចបង្កឲ្យមានឧបទ្ទវហេតុឃាតកម្មនៅរដ្ឋកាលីហ្វ័រញ៉ា ហេតុនេះ វិធានការអាចប៉ះពាល់ដល់ការចំណាយរកយុត្តិធម៌ខាងឧក្រិដ្ឋកម្មរបស់រដ្ឋាភិបាលរដ្ឋនិងមូលដ្ឋាន។ ប្រសិនបើមានផលប៉ះពាល់សារពើពន្ធគឺគ្មាននរណាដឹង ឡើយ។

### សេចក្ដីសង្ខេប

សរុបមក វិធានការនេះអាចបណ្ដាលឲ្យមានការសន្សំប្រាក់ចំពោះរដ្ឋាភិបាលរដ្ឋនិងមូលដ្ឋានដែលទាក់ទងទៅនឹងការជំនុំជម្រះក្ដីឃាតកម្ម បណ្ដឹងវិវាទឧទ្ធរណ៍ និងមន្ទីរកែប្រែរដ្ឋ។ ការសន្សំប្រាក់សន្សំទាំងនេះទំនងជាមានទឹកប្រាក់ប្រហែល $100 លានដុល្លារជារៀងរាល់ឆ្នាំ ក្នុងរយៈពីរបីឆ្នាំដំបូង និងកើនដល់ទៅប្រហែលជា $130 លានដុល្លារជានៅពេលក្រោយៗទៀត។ ចំនួនពិតប្រាកដនៃការសំន្សំប្រាក់ប្រចាំឆ្នាំអាចមានកម្រិតខ្ពស់ឬទាបរហូតដល់ទៅរាប់សិបលានដុល្លារ ដោយផ្អែកទៅលើកត្តាផ្សេងៗដែលរួមមានរបៀបអនុវត្តវិធានការ និងអត្រានៃកាត់ទោសប្រហារជីវិត និងការប្រហារជីវិតដែលអាចនឹងកើតមានឡើងនៅពេលអនាគត ប្រសិនបើវិធានការនេះមិនត្រូវបានអនុម័តដោយអ្នកបោះឆ្នោត។ លើសពីនេះទៅទៀត វិធានការនេះនឹងតម្រូវឲ្យរដ្ឋផ្ដល់ជំនួយជាទឹកប្រាក់សរុបចំនួន $100 លានដុល្លារអាមេរិកទៅឲ្យទីភ្នាក់ងារអនុវត្តច្បាប់តាមមូលដ្ឋានក្នុងរយៈពេលបួនឆ្នាំក្រោយៗនេះ។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 34 ★

ភស្តុតាងបង្ហាញថា ជន*គ្មានទោស* ច្រើនជាង 100 នាក់ ត្រូវបានកាត់ទោសអស់មួយជីវិត នៅសហរដ្ឋអាមេរិក ហើយអ្នកខ្លះទៀតត្រូវបានប្រហារជីវិត!

សំណើប្រជាមតិលេខ 34 មានន័យថា យើងនឹងមិនប្រហារជីវិតជនគ្មានទោសនៅរដ្ឋកាលីហ្វ័រញ៉ាទ្បើយ។

Franky Carrillo មានអាយុ 16 ឆ្នាំ នៅពេលគាត់ត្រូវបានចាប់ខ្លួន ហើយត្រូវបានសម្រេចដាក់ទោសពីបទឃាតកម្មដោយពុំត្រឹមត្រូវនៅក្រុង Los Angeles។ វាត្រូវចំណាយពេល 20 ឆ្នាំក្នុងការបង្ហាញអំពីភាពគ្មានទោសរបស់គាត់! Cameron Willingham ត្រូវបានកាត់ទោសប្រហារជីវិតនៅឆ្នាំ 2004 នៅរដ្ឋតិចសាស់ ចំពោះការបង្កអគ្គីភ័យ ដែលបានធ្វើឲ្យកូនៗរបស់គាត់ត្រូវបាត់បង់ជីវិត។ អ្នកស៊ើបអង្កេតមិនលម្អៀង បានសន្និដ្ឋានថា គ្មានការបង្កអគ្គីភ័យទេ។

"ប្រសិនបើជនណាម្នាក់ត្រូវបានកាត់ទោសប្រហារជីវិត ហើយក្រោយមកទៀត ត្រូវបានរកឃើញថាគ្មានទោសនោះ យើងមិនអាចត្រឡប់ក្រោយវិញបានទេ។"—ចៅក្រម LaDoris Cordell, Santa Clara (ចូលនិវត្តន៍)

ទោសប្រហារជីវិតរបស់រដ្ឋកាលីហ្វ័រញ៉ា ត្រូវចំណាយច្រើនហួសហេតុ ហើយធ្វើឲ្យខូចខាតដែលមិនអាចជួសជុលវិញបាន។

- មានមនុស្សតែ 13 នាក់ប៉ុណ្ណោះ ត្រូវបានប្រហារជីវិតតាំងពីឆ្នាំ 1967—គ្មានការប្រហារជីវិតជនណាម្នាក់ទេ តាំងពីឆ្នាំ 2006។ អ្នកទោសរង់ចាំប្រហារជីវិតភាគច្រើន ស្លាប់ដោយសារភាពចាស់ជរា។
- យើងខាតបង់លុយពន្ធជាច្រើនលានដុល្លារ ទៅលើការផ្តល់ការស្នាក់នៅ ពិសេស និងបណ្តឹងតវ៉ាដែលផ្តល់ហិរញ្ញវត្ថុដោយអ្នកជាប់ពន្ធ ដែលអាចមានអាយុកាល 25 ឆ្នាំ។
- បច្ចុប្បន្ននេះ អ្នកទោសរង់ចាំប្រហារជីវិត អាចអង្គុយលេង ដោយគ្មានធ្វើអ្វីបន្តិចណាសោះ។

សំណើប្រជាមតិលេខ 34 ធ្វើឲ្យឃាតករដែលត្រូវបានដាក់ទោសត្រូវធ្វើការ និងបង់ចូលថវិកាបង់សំណងសម្រាប់ជនរងគ្រោះ តាមការបង្គាប់បញ្ជាពីចៅក្រម។

វារក្សាឲ្យឃាតករ ដែលប្រព្រឹត្តបទឧក្រិដ្ឋសាហាវយង់ឃ្នង ឲ្យនៅក្នុងពន្ធនាគាររហូតដល់ពួកគេស្លាប់។

វាធ្វើឲ្យលុយពន្ធដែលខ្ជះខ្ជាយរាប់លានដុល្លារមានលទ្ធភាពអាចប្រើប្រាស់ - សម្រាប់ជួយសាលារៀនកូនយើង និងចាប់ឃាតករ និងអ្នកចាប់រំលោភជាច្រើនថែមទៀត - ដោយគ្មានការបង្កើនពន្ធ។

សំណើប្រជាមតិលេខ 34 សន្សំសំចៃថវិកា។

រដ្ឋកាលីហ្វ័រញ៉ាអស់ប្រាក់ទុន។ មនុស្សជាច្រើនគិតថា ទោសប្រហារជីវិត មានតម្លៃថោកជាងជីវិតដែលគ្មានការដោះលែង—នោះមិនមែនជាការពិតទេ។

ការសិក្សាដោយមិនលម្អៀងមួយបានរកឃើញថា រដ្ឋកាលីហ្វ័រញ៉ានឹង សន្សំថវិកាបានជិត $100 កោដិដុល្លារ ក្នុងរយៈពេលប្រាំឆ្នាំប្រសិនបើយើងជំនួសទោសប្រហារជីវិត ជាមួយនឹងជីវិតនៅក្នុងពន្ធនាគារដែលគ្មានលទ្ធភាពនឹងត្រូវដោះលែង។ ប្រាក់សន្សំបានមកពីការលុបបំបាត់សោហ៊ុយមេធាវី និងការផ្តល់ការស្នាក់នៅពិសេស សម្រាប់អ្នកទោសរង់ចាំប្រហារជីវិត។

*http://media.lls.edu/documents/Executing_the_Will_of_the_Voters.pdf*

ប្រាក់ពន្ធដែលខ្ជះខ្ជាយទាំងនោះ នឹងត្រូវបានចំណាយកាន់តែប្រសើរទៅលើ ការអនុវត្តច្បាប់ និងសាលារៀនរបស់យើង។

យើងមិនអាចឲ្យឃាតករតិរច្ឆាន គេចវេសពីយុត្តិធម៌បានទេ។

ជារៀងរាល់ឆ្នាំ ស្ទើរតែពាក់កណ្តាលនៃឃាតករទាំងអស់និងជាងពាក់កណ្តាលនៃអ្នកចាប់រំលោភទាំងអស់ ពុំបានការដោះស្រាយទេ។ ឃាតករអាចដើរហើរបានដោយសេរី ហើយជាញឹកញាប់នៅតែបន្តចាប់រំលោភ និងសម្លាប់មនុស្សដដែល។ ជនរងគ្រោះរាប់ពាន់នាក់ រង់ចាំយុត្តិធម៌ ខណៈយើងខ្ជះខ្ជាយលុយរាប់លានដុល្លារទៅលើអ្នកទោសរង់ចាំប្រហារជីវិត។

ឃាតករ ដែលប្រព្រឹត្តអំពើខ្មៅងងឹត ត្រូវតែនាំមកកាត់ទោសឲ្យបានឆាប់រហ័ស ឃុំឃាំងជារៀងរហូត និងដាក់ទណ្ឌកម្មឲ្យបានធ្ងន់ធ្ងរ។

- សំណើប្រជាមតិលេខ 34 សន្សំប្រាក់ពន្ធ និងចាត់ចែងប្រាក់ $100 លានដុល្លារទៅក្នុងប្រាក់សន្សំសម្រាប់ការធ្វើតេស្តDNAមន្ទីរពិសោធន៍ឧក្រិដ្ឋកម្មនិងឧបករណ៍ផ្សេងៗ ដែលជួយឲ្យប៉ូលីសដោះស្រាយបញ្ហាចាប់រំលោភ និងឃាតកម្ម។
- សំណើប្រជាមតិលេខ 34 ធ្វើឲ្យឃាតករដែលប្រព្រឹត្តិបទឧក្រិដ្ឋដែលគួរឲ្យស្អប់ខ្ពើម ត្រូវចំណាយពេលមួយជីវិតនៅក្នុងពន្ធនាគារ ដោយគ្មានសង្ឃឹមថាថ្ងៃណាបានចេញមកវិញទ្បើយ។ វាធ្វើឲ្យពួកគេធ្វើការ ដើម្បីឲ្យពួកគេអាចបង់សំណងដល់ជនរងគ្រោះពួកគេវិញ។
- នោះហើយគឺជា យុត្តិធម៌ដែលដំណើរការ។

ជនម្នាក់ៗ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារអស់មួយជីវិតស្មើៗគ្នាដោយគ្មានលទ្ធភាពនឹងត្រូវដោះលែងតាំងពីឆ្នាំ 1977 មក នៅតែត្រូវបានឃុំឃាំង ឬបានស្លាប់នៅក្នុងពន្ធនាគារ។ ជីវិតដែលគ្មានលទ្ធភាពនឹងត្រូវដោះលែង មានប្រសិទ្ធភាព ហើយធានាថា យើងនឹងមិនប្រហារជីវិតជនគ្មានទោសណាម្នាក់នៅរដ្ឋកាលីហ្វ័រ ញ៉ាទ្បើយ។

"ការដាក់ទណ្ឌកម្មដល់ស្លាប់ មិនធ្វើឲ្យយើងកាន់តែមានសុវត្ថិភាពទេ ប៉ុន្តែការដោះស្រាយបញ្ហាឧក្រិដ្ឋកម្មឲ្យកាន់តែប្រសើរទើបមានប្រសិទ្ធភាព"—អតីតអគ្គមេធាវី John Van de Kamp

"ខ្ញុំមានរឿងដោយសាររឿងក្តីទាំងឡាយដូច Willingham អញ្ចឹងដែរ - គឺរឿងមនុស្សគ្មានទោស ដែលអាចត្រូវបានកាត់ទោសប្រហារជីវិត។ ខ្ញុំគាំទ្រសំណើប្រជាមតិលេខ 34 ពីព្រោះវាធានាថា យើងនឹងមិនប្រហារជីវិតជនគ្មានទោសណាម្នាក់នៅរដ្ឋកាលីហ្វ័រញ៉ាទ្បើយ។"—Bishop Flores, San Diego Diocese

បោះឆ្នោត បាទ/ចាស ចំពោះសំណើប្រជាមតិលេខ 34។

**GIL GARCETTI,** មេធាវីមណ្ឌល
ខោនធី Los Angeles, 1992–2000

**JEANNE WOODFORD,** មេគុក
គុកសំរាប់អ្នកទោសប្រហារជីវិតកាលីហ្វ័រញ៉ា, 1999–2004

**JENNIFER A. WAGGONER,** ប្រធាន
សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 34 ★

JERRY BROWN និយាយថា គ្មានអ្នកទោសដែលរកឃើញគ្មានទោសណាម្នាក់ស្ថិតនៅក្នុងបញ្ជីរង់ចាំប្រហារជីវិតរបស់រដ្ឋកាលីហ្វ័រញ៉ាទ្បើយ។—*កាលប្បវត្តិ San Francisco 3/7/12*។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 34 គឺជារឿងអស់សង្ឃឹមយ៉ាងខ្លាំងដែលពួកគេនឹងនិយាយអ្វីៗ ដើម្បីទទួលបានសន្លឹកឆ្នោតរបស់អ្នក។ ការបោះឆ្នោតស្ទង់មតិមហាជន បានបង្ហាញអំពីការគាំទ្រដ៏លើសលប់ចំពោះទោសប្រហារជីវិត ដូច្នេះពួកគេមានបំណងប្រើពាក្យដែលនាំឲ្យយល់ខុសដូចជា ភាពគ្មានទោស ការដោះស្រាយឧក្រិដ្ឋកម្ម និងការសន្សំប្រាក់ជាដើម។

សូមកុំចាញ់បោកគេ។

"សំណើប្រជាមតិលេខ 34 យកលុយ $100 លានដុល្លារពីកញ្ចប់ថវិកាទូទៅរបស់រដ្ឋកាលីហ្វ័រញ៉ា។ អ្នកប្រឆាំងបានតវ៉ាថា លុយដែលបានមកពីប្រាក់សន្សំដែលត្រូវបានគេចោទនោះ គឺជារឿងមិនពិត។ លើសពីនេះទៀត សំណើប្រជាមតិលេខ 34 នឹងធ្វើឲ្យអ្នកជាប់ពន្ធត្រូវចំណាយលុយរាប់លានដុល្លារជារៀងរាល់ឆ្នាំ តាមរយៈការធានាផ្តល់កន្លែងស្នាក់នៅសម្រាប់ឃាតករ និងអត្ថប្រយោជន៍សុខភាពអស់មួយជីវិត។"—Mike Genest, ប្រធានផ្នែកហិរញ្ញវត្ថុរដ្ឋកាលីហ្វ័រញ៉ាឆ្នាំ 2005–2009។

អ្នកគាំទ្រសំណើប្រជាមតិលេខ 34 មិនអាចការពារការផ្តួចផ្តើមគំនិតរបស់ពួកគេបានទ្បើយ។ ជំនួសមកវិញ ពួកគេបោកបញ្ឆោត។

សំណើប្រជាមតិលេខ 34 តែងតែហៅថា "លក្ខខណ្ឌតម្រូវការងារ?" ធ្វើឲ្យឃាតករដែលរៀនផ្នែកអប់រំកាយ ឆ្លើយតបនឹងលក្ខខណ្ឌនេះ។

អ្នករួចទោស Franky Carrillo . . . គាត់មិនដែលបានទទួលទោសប្រហារជីវិត ម្តងណាទេ។

គ្មាន "ពន្ធនាគារសម្រាប់អ្នកទោសរង់ចាំប្រហារជីវិតរបស់រដ្ឋកាលីហ្វ័រញ៉ាទេ។" វាជា San Quentin។

អ្នកបោះឆ្នោតឆ្លាត ហើយដឹងថា អ្នកគាំទ្រសំណើប្រជាមតិលេខ 34 បានធ្វើការជាច្រើនទសវត្សរ៍ ដើម្បីលុបបំបាត់ការដាក់ទោសដល់ជីវិត។ ពួកគេមិនមែនជាអ្នកឃ្លាំមើលរបស់អ្នកជាប់ពន្ធទេ —ផ្ទុយស្រទ្បះ។ ពួកគេធ្វើឲ្យយុត្តិធម៌កាន់តែមានតម្លៃថែមទៀត។

"សំណើប្រជាមតិលេខ 34 ដាក់ទោសគ្រួសារដែលទទួលរងការស្លាប់យ៉ាងរន្ធត់ដោយសារឃាតករដែលត្រូវបានផ្តន្ទាទោស។ ដូច្នេះហើយទើប រាល់អង្គភាពអនុវត្តច្បាប់រដ្ឋកាលីហ្វ័រញ៉ាធំៗ ជំទាស់នឹងសំណើប្រជាមតិលេខ 34។"—Scott Seaman, ប្រធានសមាគមមេប៉ូលីសរដ្ឋកាលីហ្វ័រញ៉ា។

កុំបណ្តោយឲ្យឃាតករដែលមានទោសឈ្នះ។ Scott Peterson បានសម្លាប់ប្រពន្ធគាត់ឈ្មោះ Laci និងកូនប្រុសក្នុងពោះរបស់គាត់យ៉ាងសាហាវ។ គាត់ទទួលបានការកាត់ទោសប្រហារជីវិត។ LACI គ្មានទោសទេ។ ទារកឈ្មោះ CONNER នោះគ្មានអ្នកណាជួយទេ។

សូមចងចាំអំពីជនរងគ្រោះ រួមទាំង មន្ត្រីប៉ូលីសចំនួន 43 នាក់ដែលត្រូវបានសម្លាប់ដោយសារតែការពារពួកយើង។ សូមក្រោកឈរទ្បើង ដើម្បីឲ្យរដ្ឋកាលីហ្វ័រញ៉ាកាន់តែមានសុវត្ថិភាពថែមទៀត។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ34។

**CARL V. ADAMS,** ប្រធាន
សមាគមមេធាវីមណ្ឌលកាលីហ្វ័រញ៉ា

**KERMIT ALEXANDER**
គ្រួសារត្រូវបានសំឡាប់ដោយសមាជិកក្រុមជនពាលនៅខោនធី Los Angeles

**RON COTTINGHAM,** ប្រធាន
សមាគមមន្ត្រីស្រាវជ្រាវសន្តិភាពកាលីហ្វ័រញ៉ា



*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយទ្បើយ។*

# សំណើប្រជាមតិ ទោសប្រហារជីវិត។ លក្ខន្តិកៈផ្តួចផ្តើម។
# 34

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 34 ★

រដ្ឋកាលីហ្វ័រញ៉ាអស់ប្រាក់ទុន។ ការលុបចោលទោសប្រហារជីវិត ធ្វើឲ្យអ្នកជាប់ពន្ធត្រូវចំណាយ $100 លានដុល្លារក្នុងរយៈពេលបួនឆ្នាំខាងមុខ និងជាច្រើនលានថែមទៀតនៅពេលអនាគត។ ជំនួសឲ្យយុត្តិធម៌ ឃាតករទទួលបានការស្នាក់នៅ/អត្ថប្រយោជន៍គាំពារសុខភាពអស់មួយជីវិត។

សំណើប្រជាមតិលេខ 34 មិនមែនជាការសន្សំប្រាក់ទេ។ វាគឺជារបៀបវារៈរបស់ ACLU ក្នុងការធ្វើឲ្យខ្សោយនូវច្បាប់ស្តីពីសុវត្ថិភាពសាធារណៈ។ ពួកគេអស់សង្ឃឹមក្នុងការធ្វើឲ្យអ្នកមានជំនឿចិត្តថា ការសង្គ្រោះឃាតករពីយុត្តិធម៌គឺជារឿងត្រឹមត្រូវ។ ឬប្រសិនបើអ្នកពុំជឿទេនោះ ពួកគេអះអាងថា វាសន្សំប្រាក់!

ការខំប្រឹងប្រែងរបស់ ACLU គឺជារឿងមិនអាចការពារ សាហាវយង់ឃ្នងចំពោះមនុស្សជាទីស្រឡាញ់របស់ជនរងគ្រោះ ធ្វើឲ្យមានការយល់ខុស និងប្រមាថមើលងាយអ្នកបោះឆ្នោត និងមានគ្រោះថ្នាក់សម្រាប់រដ្ឋកាលីហ្វ័រញ៉ា។

សំណើប្រជាមតិលេខ 34 បណ្តោយឲ្យអ្នកសម្លាប់ជាលំដាប់ អ្នកសម្លាប់ប៉ូលីស អ្នកសម្លាប់កុមារ និងអ្នកដែលសម្លាប់មនុស្សចាស់ គេចផុតពីសំណាញ់យុត្តិធម៌។ អ្នកគាំទ្រមិនទទួលស្គាល់ថា នៅពេលទោសប្រហារជីវិតរបស់រដ្ឋកាលីហ្វ័រញ៉ាត្រូវបានលុបបំបាត់ជាមុន ឧក្រិដ្ឋជនដែលបានដាក់ទោសត្រូវបានដោះលែងដើម្បីឲ្យទៅចាប់រំលោភ និងសម្លាប់ម្តងទៀតប៉ុណ្ណោះ!

អ្នកបោះឆ្នោត ត្រូវតែស្តារទោសប្រហារជីវិត ដើម្បីស្តារយុត្តិធម៌ឡើងវិញ។

នេះគឺជាការពិត។ ទោសប្រហារជីវិត ត្រូវបានផ្តន្ទាចំពោះឃាតករតិចជាង 2% ដែលបទឧក្រិដ្ឋរបស់ពួកគេមានលក្ខណៈគួរឲ្យតក់ស្លុតខ្លាំង ដែលគណៈវិនិច្ឆ័យនៃពលរដ្ឋគោរពច្បាប់បានថ្កោលទោសនោះជាឯកច្ឆ័ន្ទរួចហើយ។

Richard Allen Davis ៖ បានចាប់ជម្រិត ចាប់រំលោភ និងសម្លាប់ Polly Klaas ដែលមានអាយុ 12 ឆ្នាំ។

Richard "អ្នកឈ្លបចាប់ពេលយប់" Ramirez ៖ បានចាប់ជម្រិត ចាប់រំលោភ ធ្វើទារុណកម្ម កាត់អវៈយវៈមនុស្ស 14 នាក់ និងបានធ្វើទារុណកម្មមនុស្ស 11 នាក់ទៀត រួមមាន កុមារ និងមនុស្សចាស់។

សមាជិកក្រុមជនពាល Ramon Sandoval៖ បានពួនស្ទាក់វាយ និងបាញ់មន្ត្រីប៉ូលីសឈ្មោះ Daryle Black (ជាអតីតទាហានជើងទឹកអាមេរិក) និងឈ្មោះ Rick Delfin ដោយប្រើកាំភ្លើងម៉ាក AK-47 សម្លាប់ Black បាញ់ Delfin ចំក្បាល និងធ្វើឲ្យស្ត្រីមានផ្ទៃពោះម្នាក់រងរបួស។

ឃាតករសំឡាប់តៗគ្នា ឈ្មោះ Robert Rhoades ដែលជាអ្នកចាប់រំលោភកុមារ បានចាប់ជម្រិតក្មេងមានអាយុ 8 ឆ្នាំម្នាក់ឈ្មោះ Michael Lyons។ Rhoades បានចាប់រំលោភ និងធ្វើទារុណកម្ម Michael អស់រយៈពេល 10 ម៉ោង ចាក់ក្មេងនោះ 70 ដង មុននឹងអារផ្តាច់បំពង់ក និងបោះសពក្មេងនោះចូលទៅក្នុងទន្លេ។

Alexander Hamilton ៖ បានសម្លាប់មន្ត្រីប៉ូលីសឈ្មោះ Larry Lasater (ជាអតីតយុទ្ធជនក្នុងសមរភូមិជើងទឹក)។ នៅពេលនោះ ប្រពន្ធរបស់ Lasater កំពុងតែមានផ្ទៃពោះប្រាំពីរខែ។

ជនរងគ្រោះនៃឃាតកម្មដែលមានទោសប្រហារជីវិតរួមមាន៖

កុមារ 225 នាក់
មន្ត្រីប៉ូលីស 43 នាក់
អ្នកត្រូវបានចាប់រំលោភ/សម្លាប់ 235 នាក់
អ្នកត្រូវបានធ្វើទារុណកម្ម/សម្លាប់ 90 នាក់

ACLU គឺជាបញ្ហា៖ ពួកគេអះអាងថា ទោសប្រហារជីវិត ធ្វើឲ្យខាតបង់ច្រើន និងថ្លៃ។ អ្វីក៏ពូកែលាក់ពុតម្លេះ! គឺ ACLU និងអ្នកគាំទ្រ ដែលបានរារាំងដល់ការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌ ដោយគ្មានការពន្យារពេល។ រដ្ឋផ្សេងៗ រួមមាន រដ្ឋ Ohio និង Arizona ផ្តល់សិទ្ធិពេញលេញដល់ឧក្រិដ្ឋជន និងអនុវត្តទោសប្រហារជីវិតដោយយុត្តិធម៌។ រដ្ឋកាលីហ្វ័រញ៉ាក៏អាចធ្វើបានដែរ។

ល្បែងនយោបាយ៖ ការផ្សព្វផ្សាយសំណើប្រជាមតិលេខ 34 អ្នកគាំទ្រធ្វើការអះអាង ដោយផ្អែកលើអត្ថបទកាសែត និង "ការសិក្សា" ដែលសរសេរដោយ ACLU ឬអ្នកប្រឆាំងនឹងទោសប្រហារជីវិតដទៃទៀត។

ផ្នែកកែតម្រូវទិន្នន័យ បានផ្តល់ជាយោបល់ថា ការលុបបំបាត់ទោសដល់ជីវិត នឹងនាំមកនូវកំណើនចំណាយរាប់សិបលានដុល្លារក្នុងរយៈពេលយូរ ដោយគ្រាន់តែសម្រាប់ការផ្តល់ការស្នាក់នៅ/ការគាំពារសុខភាពប៉ុណ្ណោះ។ អ្នកជាប់ពន្ធ នឹងត្រូវចំណាយយ៉ាងហោចណាស់ $50,000 ដុល្លារក្នុងមួយឆ្នាំ ដើម្បីយកចិត្តទុកដាក់ចំពោះឃាតករ ដែលត្រូវបានផ្តន្ទាទោស ដែលមិនបានគិតល្អិតល្អន់ អំពីការសម្លាប់កុមារ ប៉ូលីស ម្តាយ និងឪពុកដែលគ្មានទោស។

តើអ្នកគិតថា ការផ្តល់ឲ្យឃាតករកាចសាហាវ នូវការស្នាក់នៅ និងអត្ថប្រយោជន៍សុខភាពអស់មួយជីវិត ជាការសន្សំប្រាក់មែនទេ? ប្រាកដណាស់គឺមិនមែនទេ!

នោះគឺជារឿងអាថ៌កំបាំង ដែលអ្នកគាំទ្រសំណើប្រជាមតិលេខ 34 មិនចង់ឲ្យអ្នកដឹង។ វាមិនមែនជារឿងលុយទេ . . . វាគឺជារបៀបវារៈនយោបាយរបស់ពួកគេ។

រដ្ឋអាជ្ញា ប៉ូលីស ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងអ្នកដឹកនាំសហគមន៍ទូទាំងរដ្ឋកាលីហ្វ័រញ៉ា កំពុងតែទទូចសុំឲ្យអ្នកបោះឆ្នោត មិនយល់ព្រម ចំពោះសំណើប្រជាមតិលេខ 34។ បញ្ឈប់ ACLU។ ថែរក្សាទុកទោសប្រហារជីវិត។ ការពាររដ្ឋកាលីហ្វ័រញ៉ា។

សូមចូលមើល *waitingforjustice.net*។ សូមចូលរួមជាមួយពួកយើងទាំងអស់គ្នា។ បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 34។

**HON. PETE WILSON**
អតីតអភិបាលរដ្ឋកាលីហ្វ័រញ៉ា

**MARC KLAAS**
ជាឪពុកកុមាររងគ្រោះដោយឃាតកម្មអាយុ 12 ឆ្នាំ Polly Klaas

**KEITH ROYAL**, ប្រធាន
សមាគមតម្រួតតំបន់រដ្ឋកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 34 ★

យើងនឹងមិនប្រហារជីវិតជនគ្មានទោស ជាមួយសំណើប្រជាមតិលេខ 34 ទេ។ ទោសប្រហារជីវិតរបស់រដ្ឋកាលីហ្វ័រញ៉ា ត្រូវចំណាយច្រើន និងធ្វើឲ្យខូចខាត ដែលមិនអាចជួសជុលវិញបាន។

ពិនិត្យមើលការពិតទាំងនេះ ៖

- ការវិភាគទៅលើចំណាយដោយមិនលម្អៀង នៅក្នុងសេចក្តីណែនាំសម្រាប់អ្នកបោះឆ្នោត បាននិយាយថា សំណើប្រជាមតិលេខ 34 សន្សំប្រាក់រាប់លានដុល្លារ ជារៀងរាល់ឆ្នាំ។ សូមអានវាដោយខ្លួនអ្នក។
- អ្នកដឹកនាំការអនុវត្តច្បាប់ និងព្រះរាជអាជ្ញាយល់ឃើញថា ទោសប្រហារជីវិតរបស់រដ្ឋកាលីហ្វ័រញ៉ា មានការខូចខាត និង ត្រូវចំណាយរាប់លានដុល្លារថែមទៀតជារៀងរាល់ឆ្នាំ ច្រើនជាងជីវិតនៅក្នុងពន្ធនាគារដោយគ្មានការដោះលែងទៅទៀត។ សូមអានទីនេះ ៖*http://ccfaj.org/rr-dp-official.html*។
- សំណើប្រជាមតិលេខ 34 បញ្ចប់ការផ្តល់ការស្នាក់នៅពិសេស មេធាវី និងបន្ទប់ឯកជនដែលមានតម្លៃថ្លៃ សម្រាប់អ្នកទោសរង់ចាំការប្រហារជីវិត។ យើងត្រូវការប្រាក់ពន្ធដែលខ្វះខាតទាំងនោះ សម្រាប់សាលារៀនរបស់យើង។

"គ្មានឱកាសណា ដែលទោសប្រហារជីវិតរបស់រដ្ឋកាលីហ្វ័រញ៉ា អាចកែប្រែបានទេ។ លុយរាប់លានដុល្លារ ដែលបានខ្វះខាតទៅលើប្រព័ន្ធដែលខូចខាតនេះ យកល្អគួរតែចំណាយទៅលើគ្រូបង្រៀន ប៉ូលីស អ្នកពន្លត់អគ្គីភ័យ ដើម្បីឲ្យពួកគេធ្វើការងាររបស់ពួកគេវិញប្រសើរជាង។" —តុលាការឈ្មោះ Carlos Moreno ធ្វើការនៅតុលាការជាន់ខ្ពស់រដ្ឋកាលីហ្វ័រញ៉ា (ចូលនិវត្តន៍)

សំណើប្រជាមតិលេខ 34 ជួយចាប់ និងដាក់ទោសឃាតករ។ វានឹង៖

- ធ្វើឲ្យឃាតករសាហាវយង់ឃ្នង នៅក្នុងពន្ធនាគាររហូតដល់ពួកគេស្លាប់ ដោយគ្មានសង្ឃឹមថាថ្ងៃណាបានចេញមកវិញឡើយ។
- ធ្វើឲ្យពួកគេ ធ្វើការ និង ទូទាត់សង ជនរងគ្រោះតាមការបង្គាប់បញ្ជាពីតុលាការ។
- សន្សំប្រាក់រាប់រយលានដុល្លារ និងចាត់ចែងប្រាក់ $100 លានដុល្លារ ទៅក្នុងការអនុវត្តច្បាប់ ដើម្បីដោះស្រាយបញ្ហាចាប់រំលោភ និងឃាតកម្ម។ 46% នៃឃាតកម្ម និង 56% នៃការចាប់រំលោភ ពុំមានការដោះស្រាយទេ ខណៈយើង ចំណាយលុយរាប់លានឥតប្រយោជន៍ ទៅលើឧក្រិដ្ឋជនមួយក្តាប់ ដែលនៅពីក្រោមការឃុំឃាំងរួចទៅហើយនោះ។

ជនម្នាក់ៗ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារអស់មួយជីវិតដោយយុត្តិធម៌ ដោយគ្មានលទ្ធភាពនឹងត្រូវដោះលែង តាំងពីឆ្នាំ 1977 មក នៅតែត្រូវបានឃុំឃាំង ឬបានស្លាប់នៅក្នុងពន្ធនាគារ។

សូមចងចាំភស្តុតាងបង្ហាញថា ជនគ្មានទោស ច្រើនជាង 100 នាក់ត្រូវបានកាត់ទោសអស់មួយជីវិត នៅសហរដ្ឋអាមេរិក ហើយអ្នកខ្លះទៀតត្រូវបានប្រហារជីវិត!

យើងនឹងមិនប្រហារជីវិតជនគ្មានទោស ជាមួយនឹងសំណើប្រជាមតិលេខ34ឡើយ។

នោះហើយគឺជា យុត្តិធម៌ដែលមានប្រសិទ្ធភាព។

បោះឆ្នោត បាទ/ទេ លើសំណើប្រជាមតិលេខ34។

**MAYOR ANTONIO R. VILLARAIGOSA**
ក្រុង Los Angeles

**HON. JOHN VAN DE KAMP**, អគ្គមេធាវី
រដ្ឋកាលីហ្វ័រញ៉ា, 1983–1991

**JUDGE LADORIS CORDELL** (ចូលនិវត្តន៍)
តុលាការកំពូលខោនធី Santa Clara

សំណើប្រជាមតិ

# 35 ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

**ចំណងជើងជាផ្លូវការ និងសេចក្តីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

## ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

- បង្កើនការផាកពិន័យបទឧក្រិដ្ឋ សំរាប់ការជួញមនុស្ស រួមទាំងការកាត់ទោសឲ្យជាប់ព័ន្ធនាគារ ដល់ទៅ 15 ឆ្នាំ រហូតដល់ មួយជីវិត និងផាកពិន័យដល់ទៅ $1,500,000។
- ប្រាក់ផាកពិន័យដែលបានប្រមូលមក ត្រូវបានប្រើសំរាប់សេវាជនរងគ្រោះ និងខាងនគរបាល។
- អ្នកជាប់ទោសបទការជួញមនុស្ស ដំរូវឲ្យចុះបញ្ជីជាទុរជនផ្លូវភេទ។
- ទុរជនផ្លូវភេទ ដំរូវឲ្យផ្តល់ព័ត៌មានស្តីពីការចូលអ៊ិនទ័រណិត និងភិនភាគដែលគេប្រើ នៅក្នុងសកម្មភាពអ៊ិនទ័រណិត។
- ហាមឃាត់ការបង្ហាញភស្តុតាង ដែលជនរងគ្រោះបានប្រព្រឹត្តិក្នុងផ្លូវភេទ ដោយបានប្រើប្រឆាំងនឹងជនរងគ្រោះ នៅក្នុងដំណើរការតុលាការឡើយ។
- ដំរូវឲ្យមានការហ្វឹកហ្វឺនពីការជួញមនុស្ស សំរាប់មន្ត្រីនគរបាល។

**អ្នកវិភាគសេចក្តីសង្ខេបនៃនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ៖**

- រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន បង្កើនការចំណាយ ប្រហែលមិនហួសពី ពីរបីលានដុល្លារជាប្រចាំឆ្នាំ សំរាប់សកម្មភាព យុត្តិធម៌នៃបទឧក្រិដ្ឋ ជាប់ទាក់ទងចំពោះការចោទលទោស និងពោធនកម្ម (ការដាក់គុក) នៃទុរជនការជួញមនុស្ស។
- រដ្ឋាភិបាលមូលដ្ឋាន អាចនឹងចំណាយមួយដង ដល់ទៅពីរបីលានដុល្លារ នៅទូទាំងរដ្ឋ និងចំណាយតិចតួចជាងបន្ថែមទៀត ជារៀងរាល់ឆ្នាំ ដោយព្រោះសេចក្តីដំរូវនៃការហ្វឹកហ្វឺនថ្មីដែលជាចាំបាច់ ជាប់ទាក់ទងការជួញមនុស្ស សំរាប់មន្ត្រីនគរបាល។
- ប្រាក់ចំណូលអាចនឹងមានបន្ថែម ចេញពីការផាកពិន័យថ្មីនៃបទឧក្រិដ្ឋ ប្រហែលជាពីរបីលានដុល្លារជាប្រចាំឆ្នាំ ដែលនឹង ផ្តល់ជាថវិកា សំរាប់សេវាជនរងគ្រោះនៃការជួញមនុស្ស និងសកម្មភាពនគរបាល ជាប់ទាក់ទងចំពោះការជួញមនុស្ស

35

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### សាវតារ

***ច្បាប់សហព័ន្ធ។*** ច្បាប់សហព័ន្ធមានចែងបទបញ្ញត្តិផ្សេងៗអំពីការហាមឃាត់ការធ្វើចរាចរមនុស្ស។ ច្បាប់សហព័ន្ធការពារជនរងគ្រោះដោយការធ្វើចរាចរមនុស្សជាទូទៅកំណត់ ការជួញដូរមនុស្សជាពីរប្រភេទ៖

- ***ការការជួញដូរផ្លូវភេទ***—ជាសកម្មភាពដែលមនុស្សត្រូវបានជ្រើសរើស ដឹកជញ្ជូន ឬទទួលយកសម្រាប់ធ្វើសកម្មភាពអាជីវកម្មខាងផ្លូវភេទ ដោយបង្ខំ ឬ ការបោកប្រាស់ ឬដែលជនរងគ្រោះដោយអំពើនេះនៅក្រោមអាយុ 18 ឆ្នាំ។ ឧទាហរណ៍មួយនៃការជួញដូរផ្លូវភេទគឺការបង្ខំឲ្យមនុស្សម្នាក់ក្លាយជាពេស្យាចារ។
- ***ការជួញដូរពលកម្ម***—ជាសកម្មភាពដែលមនុស្សត្រូវបានជ្រើសរើស ដឹកជញ្ជូន ឬទទួលយកដោយបង្ខំ ឬការបោកប្រាស់ដើម្បីធ្វើពលកម្ម ឬសេវាកម្មដទៃទៀត។ ឧទាហរណ៍មួយពីសកម្មភាពនេះគឺការបង្ខំជនបរទេសឲ្យធ្វើការដោយមិនគិតថ្លៃដោយគំរាមកំហែងដោយការនិរទេសចេញ។

អាជ្ញាធរមានសមត្ថកិច្ចសហព័ន្ធត្រូវអនុវត្តច្បាប់ទាំងនេះដែលនឹងប្រព្រឹត្តដោយឯករាជ្យ ឬជាមួយនឹងរដ្ឋ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងតំបន់។

***ច្បាប់រដ្ឋ។*** ច្បាប់រដ្ឋដែលមានស្រាប់ក៏មានការហាមឃាត់បទល្មើសស្រដៀងគ្នាដែលប្រឆាំងនឹងការជួញដូរមនុស្សដែរ។ ជាពិសេសច្បាប់រដ្ឋកំណត់ថាការធ្វើចរាចរមនុស្សជាការរំលោភបំពានលើសេរីភាពរបស់មនុស្សដោយចេតនាចំពោះ (1) ការប្រព្រឹត្តបទមជ្ឈឹមជាក់ស្តែង (ដូចជា ពេស្យាកម្ម) ឬ (2)ទទួលការបង្ខំពលកម្ម ឬសេវាកម្ម។ ការជួញដូរមនុស្សអនុលោមតាមច្បាប់គឺត្រូវដាក់ទោសឲ្យជាប់ពន្ធនាគាររហូតដល់ ប្រាំ ឆ្នាំ ឬរដ្ឋនឹងដាក់ទោសឲ្យជាប់ពន្ធនាគាររហូត ដល់ ប្រាំបី ឆ្នាំប្រសិនបើជនរងគ្រោះនៅក្រោមអាយុ 18 ឆ្នាំ។ ជនល្មើសដែលជាប់ចោទពីបទធ្វើការជួញដូរមនុស្ស ដែលបណ្តាលឲ្យមានរបួសលើរាងកាយជនរងគ្រោះ យ៉ាងធ្ងន់ធ្ងរអាចត្រូវបានពិន័យបន្ថែមរហូតដល់ ប្រាំមួយ ឆ្នាំ។ នៅប៉ុន្មានឆ្នាំថ្មីៗនេះមានមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលបានបញ្ជូនទៅក្នុងពន្ធនាគាររដ្ឋជារៀងរាល់ឆ្នាំពីបទឧក្រិដ្ឋនៃការជួញដូរមនុស្ស។ គិតត្រឹមខែ មីនា ឆ្នាំ 2012 មានជនល្មើស 18 នាក់នៅក្នុងពន្ធនាគាររដ្ឋ។

អនុលោមតាមច្បាប់អ្នកប្រព្រឹត្តបទល្មើសភាគច្រើនដែលចោទពីបទឧក្រិដ្ឋផ្លូវភេទ (ដូចជាបទឧក្រិដ្ឋមួយចំនួនដែលទាក់ទងនឹងការធ្វើចរាចរមនុស្ស) ត្រូវបានចុះបញ្ជីជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដោយប៉ូលិសក្នុងតំបន់របស់ពួកគេ ឬនាយកដ្ឋាននគរបាល។

# ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

(ត)

### សេចក្តីស្នើច្បាប់

វិធានការនេះធ្វើការកែតម្រូវមួយចំនួនលើច្បាប់របស់រដ្ឋដែលទាក់ទងនឹងការជួញដូរមនុស្ស។ ជាក់លាក់ជាងនេះទៀត វិធានការនេះ (1) ពង្រីកនិយមន័យនៃការជួញដូរមនុស្ស (2) បង្កើនការដាក់ទណ្ឌកម្មចំពោះបទល្មើសនៃការជួញដូរមនុស្ស (3) ដាក់ការផាកពិន័យថ្មីៗបន្ថែមដើម្បីផ្តល់សេវាកម្មមូលនិធិដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស (4) កែតម្រូវភស្តុតាងដែលអាចប្រើប្រឆាំងនឹងជនរងគ្រោះដោយសារការជួញដូរមនុស្ស និង (5) តម្រូវឲ្យមានការបណ្តុះបណ្តាលពីការអនុវត្តច្បាប់បន្ថែមលើការដោះស្រាយករណីនៃការជួញដូរមនុស្សនេះ។ វិធានការនេះក៏កំណត់លក្ខខណ្ឌបន្ថែមស្តីពីអ្នកចុះបញ្ជីជនល្មើសផ្លូវភេទផងដែរ។

***ពង្រឹងអត្ថន័យនៃចារាចរមនុស្សខុសច្បាប់។*** វិធានការនេះកែប្រែនិយមន័យនៃការធ្វើចរាចរមនុស្សស្ថិតក្រោមច្បាប់របស់រដ្ឋ។ ជាក់លាក់ជាងនេះទៀត វិធានការនេះកំណត់បទឧក្រិដ្ឋបន្ថែមដែលទាក់ទងនឹងការបង្កើត និងការចែកចាយឯកសារអាសអាភាសដែលបង្ហាញពីអនីតិជនដែលជាទម្រង់មួយនៃការជួញដូរមនុស្ស។ ឧទាហរណ៍ ការចម្លង ឬការលក់ឯកសារអាសអាភាសទាំងនេះអាចត្រូវបានចាត់ទុកជាការជួញដូរមនុស្ស ទោះបីជា អ្នកប្រព្រឹត្តបទល្មើសមិនជាប់ទាក់ទងជាមួយអនីតិជនក៏ដោយ។ លើសពីនេះទៀត ពាក់ព័ន្ធនឹងករណីនៃការជួញដូរផ្លូវភេទទាក់ទងនឹងអនីតិជន ព្រះរាជអាជ្ញានឹងមិនត្រូវបង្ហាញការបង្ខំ ឬការបង្ខិតបង្ខំបានកើតឡើងទេ។ (វិធានការនេះ នឹងធ្វើឲ្យច្បាប់របស់រដ្ឋដូចទៅនឹងច្បាប់សហព័ន្ធ។)

***ទណ្ឌកម្មនៃបទឧក្រិដ្ឋធ្ងន់ធ្ងរខ្លាំងចំពោះការជួញដូរមនុស្ស។*** វិធានការនេះបង្កើនទណ្ឌកម្មនៃបទឧក្រិដ្ឋបច្ចុប្បន្នចំពោះការជួញដូរមនុស្សដែលស្ថិតក្រោមច្បាប់របស់រដ្ឋ។ ឧទាហរណ៍ វិធានការនេះ បង្កើនការកាត់ទោសឲ្យជាប់ពន្ធនាគារចំពោះបទឧក្រិដ្ឋនៃការជួញដូរកម្លាំងពលកម្មរហូតដល់ 12 ឆ្នាំសម្រាប់អ្នកប្រព្រឹត្តបទល្មើសម្នាក់ ហើយចំពោះការជួញដូរផ្លូវភេទលើមនុស្សពេញវ័យរហូតដល់ 20 ឆ្នាំសម្រាប់បទល្មើសមួយ។ ការជួញដូរផ្លូវភេទលើអនីតិជនដែលទាក់ទងនឹងការបង្ខំ និងការបន្លំនឹងត្រូវដាក់ទណ្ឌកម្មឲ្យជាប់ពន្ធនាគារមួយជីវិត។ តារាងទី 1 រាយបញ្ជីនៃការកើនឡើងរបស់វិធានការក្នុងការកាត់ទោសឲ្យជាប់ពន្ធនាគារ  ការពង្រឹងការកាត់ទោស និងការពិន័យលើបទឧក្រិដ្ឋជាអតិបរមា។

លើសពីនេះទៀត វិធានការនេះ បញ្ជាក់លម្អិតថាអ្នកប្រព្រឹត្តបទល្មើសដែលបានជាប់ទោសពីការជួញដូរមនុស្សបូករួមជាមួយការកាត់ទោសពីមុនចំពោះការជួញដូរមនុស្សនឹងជាប់ពន្ធធនាគារប្រាំឆ្នាំបន្ថែមទៀតចំពោះការកាត់ទោសមុន។ ស្ថិតក្រោមវិធានការនេះ អ្នកប្រព្រឹត្តបទល្មើសដែលត្រូវបានជាប់ចោទពីការជួញដូរមនុស្សដែលធ្វើឲ្យមានរបួសរាងកាយដល់ជនរងគ្រោះអាចត្រូវបានដាក់ទណ្ឌកម្មបន្ថែមទៀតរហូតដល់ទៅដប់ឆ្នាំ។ វិធានការនេះ ក៏អនុញ្ញាតឲ្យតុលាការព្រហ្មទណ្ឌដាក់ពិន័យជាប្រាក់រហូតដល់ $1.5 លានដុល្លារអាមេរិកចំពោះបទល្មើសនៃការជួញដូរមនុស្សផងដែរ។

**តារាងទី 1**

**វិធានការបង្កើនទណ្ឌកម្មឧក្រឹដ្ឋកម្មកំរិតខ្ពស់បំផុត សំរាប់ការធ្វើចរាចរមនុស្សខុសច្បាប់**

| | ច្បាប់បច្ចុប្បន្ន | សំណើប្រជាមតិលេខ 35 |
|---|---|---|
| **ការកាត់ទោសជាប់ពន្ធធនាគារ[a]** | | |
| ចរាចរពលកម្ម | 5 ឆ្នាំ | 12 ឆ្នាំ |
| ចរាចរផ្លូវភេទលើ មនុស្សធំ, ដោយការបង្ខិត | 5 ឆ្នាំ | 20 ឆ្នាំ |
| ចរាចរផ្លូវភេទលើ អនិតិជន, ដោយគ្មាន ការបង្ខិត | គ្មាន[b] | 12 ឆ្នាំ |
| ចរាចរផ្លូវភេទលើ អនិតិជន, ដោយការបង្ខិតបង្ខំ | 8 ឆ្នាំ | ទោសមួយ ជីវិត |
| **ការធ្វើប្រពលភាពនៃការកាត់ទោស[a]** | | |
| ធ្វើឱ្យមានគ្រោះថ្នាក់រាងកាយធ្ងន់ធ្ងរ | 6 ឆ្នាំ | 10 ឆ្នាំ |
| ការល្មើសនៃចរាចរមនុស្សខុសច្បាប់គ្រាមុន | គ្មាន | 5 ឆ្នាំសំរាប់ ការជាប់ទោសមុនម្តង |
| **ការផាកពិន័យ** | រហូតដល់ $100,000 សំរាប់ការធ្វើចរាចរលើអនិតិជនម្នាក់ | រហូតដល់ $1.5 សំរាប់បទ ល្មើសការធ្វើ ចរាចរមនុស្សខុសច្បាប់ |

[a] ការដាក់ទណ្ឌកម្មពិតប្រាកដរួ។

[b] សកម្មភាពដែលពិចារណាក្រោមវិធានការគឺជាការធ្វើចរាចរផ្លូវភេទលើ អនិតិជនដោយគ្មានការបង្ខិតបង្ខំគឺខុសច្បាប់ក្រោមច្បាប់បច្ចុប្បន្ន តែមិនត្រូវបានសំគាល់ថាជាការធ្វើចរាចរមនុស្សទេ។ ការដាក់ទណ្ឌកម្មសំរាប់ឧក្រិដ្ឋកម។

35

សំណើប្រជាមតិ

# 35 ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

(ត)

***កម្មវិធីសម្រាប់ជនរងគ្រោះដោយសារការជួញដូរមនុស្ស។*** វិធានការនេះតម្រូវឲ្យមូលនិធិដែលប្រមូលបានពីការផាកពិន័យខាងលើ ឧបត្ថម្ភសេវាសម្រាប់ជនរងគ្រោះដោយសារការជួញដូរមនុស្ស។ មូលនិធិ 70 ភាគរយនឹងត្រូវបែងចែកទៅឲ្យទីភ្នាក់ងារសាធារណៈនិងអង្គការមិនស្វែងរកប្រាក់ ចំណេញដែលផ្តល់សេវាដោយផ្ទាល់ដល់ជនរងគ្រោះដោយសារបញ្ហានេះ។ វិធានការនេះ តម្រូវឲ្យប្រគល់ចំនួនដែលនៅសល់ 30 ភាគរយទៅឲ្យទីភ្នាក់ងារអនុវត្តច្បាប់ និងដាក់ទោសទៅតាមយុត្តាធិការរបស់គេ នៅកន្លែងដែលបានដាក់ពាក្យបណ្តឹង និងប្រើសម្រាប់បង្កាការជួញដូរមនុស្ស ការការពារសាក្សី និងប្រតិបត្តិការសង្គ្រោះ។

***ការផ្លាស់ប្តូរដែលប៉ះពាល់ដល់នីតិវិធីតុលាការ។*** វិធានការនេះក៏ប៉ះពាល់ដល់ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងបណ្តឹងការជួញដូរមនុស្សខុសច្បាប់ផងដែរ។ ជាក់ស្តែង វិធានការនេះហាមការប្រើភស្តុតាងដែលអ្នកជាប់ពាក់ព័ន្ធនឹងបទល្មើសខាងផ្លូវភេទ (ដូចជាពេស្យាចារ) ដើម្បីកាត់ទោសបុគ្គលនោះពីការប្រព្រឹត្តបទល្មើស ប្រសិនបើការប្រព្រឹត្តនោះគឺជាលទ្ធផលនៃការជាប់ជាជនរងគ្រោះដោយសារការជួញដូរមនុស្ស។ វិធានការនេះក៏ធ្វើឲ្យភស្តុតាងនៃការប្រព្រឹត្តផ្លូវភេទរបស់ជនរងគ្រោះដោយសារការជួញដូរមនុស្សមិនអាចទទួលយកបានសម្រាប់គោលបំណងប្រឆាំងនឹងភាពគួរឲ្យជឿជាក់ ឬលក្ខណៈចរិតរបស់ជនរងគ្រោះក្នុងតុលាការ។ បន្ថែមពីនេះទៀត វិធានការនេះ មិនអនុញ្ញាតឲ្យមានការការពារក្នុងករណីជួញដូរមនុស្សពាក់ព័ន្ធនឹងអនីតិជនទេ។ ឧទាហរណ៍ ចុងចោទមិនអាចអះអាងថា ជាការការពារខ្លួនដោយសារមិនដឹងអំពីអាយុរបស់អនីតិជនទេ។



***ការបណ្តុះបណ្តាលពីការអនុវត្តច្បាប់។*** វិធានការនេះតម្រូវឲ្យមន្ត្រីរក្សាសន្តិភាពបម្រើការឲ្យនាយកដ្ឋាននគរបាល និងនាយកដ្ឋានតម្រួត និងក្រុមល្បាតតាមដងវិថីរដ្ឋកាលីហ្វ័រញ៉ា (CHP) ដែលចុះអនុវត្តការងារជាក់ស្តែង ឬការងារស៊ើបអង្កេតធ្វើការបណ្តុះបណ្តាលអំពីរបៀបដោះស្រាយបណ្តឹងការជួញដូរមនុស្សយ៉ាងហោចណាស់ពីរម៉ោង។ ការបណ្តុះបណ្តាលនេះត្រូវបញ្ចាប់នៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2014 ឬក្នុងរយៈពេលប្រាំមួយខែដែលគេកំណត់មន្ត្រីចុះទៅកន្លែងជាក់ស្តែង ឬចុះធ្វើការស៊ើបអង្កេត។

***តម្រូវការបន្ថែមសម្រាប់ការចុះបញ្ជីជនល្មើសផ្លូវភេទ។*** វិធានការនេះតម្រូវឲ្យជនល្មើលផ្លូវភេទដែលបានចុះបញ្ជីប្រគល់ឈ្មោះអ្នកផ្តល់ និងអ្នកកំណត់សេវាអ៊ីនធឺណិតរបស់ខ្លួនទៅឲ្យនាយកដ្ឋាននគរបាល និងនាយកដ្ឋានតម្រួត។ វត្ថុកំណត់នេះ រួមមានអាស័យដ្ឋានអ៊ីមែល ,ឈ្មោះអ្នកប្រើប្រាស់ឈ្មោះលើអេក្រង់ និងវត្ថុកំណត់អត្តសញ្ញាណផ្សេងទៀតសម្រាប់ទំនាក់ទំនងនិងសកម្មភាពអ៊ីនធឺណិត។ ប្រសិនបើអ្នកចុះបញ្ជីផ្លាស់ប្តូរគណនីសេវាអ៊ីនធឺណិតរបស់ខ្លួន ឬប្តូរ ឬបន្ថែមអ្នកកំណត់អ៊ីនធឺណិត បុគ្គលនោះត្រូវជូនដំណឹងការអនុវត្តច្បាប់ក្នុងរយៈពេល 24 ម៉ោងអំពីការផ្លាស់ប្តូរបែបនោះ។

### ***ឥទ្ធិពលសារពើពន្ធ***

បច្ចុប្បន្ននេះ ករណីនៃការជួញដូរមនុស្សជារឿយៗត្រូវបានកាត់ទោសដោយច្បាប់សហព័ន្ធ ជាជាងច្បាប់រដ្ឋកាលីហ្វ័រញ៉ា ទោះបីជាអាជ្ញាធរមានសមត្ថកិច្ចរដ្ឋកាលីហ្វ័រញ៉ាត្រូវបានពាក់ព័ន្ធក្នុងការអង្កេតលើករណីនេះក៏ដោយ។ នេះគ្រាន់តែជាផ្នែកខ្លះ ព្រោះឧក្រិដ្ឋកម្មប្រភេទនេះជារឿយៗជាប់ពាក់ព័ន្ធនឹងយុត្តាធិការជាច្រើន ហើយក៏ដោយសារតែមុខងារនាំមុខជាប្រវត្តិសាស្ត្ររបស់រដ្ឋាភិបាលសហព័ន្ធក្នុងករណីទាំងនេះ។ គេមិនទាន់ប្រាកដនៅឡើយថាតើការពង្រីកនិយមន័យនៃការជួញដូរមនុស្ស និងការផ្លាស់ប្តូរផ្សេងៗដែលត្រូវបានស្នើឡើងក្នុងវិធានការនេះនឹងមានការកើនឡើងគួរឲ្យកត់សម្គាល់នូវចំនួននៃការចាប់ខ្លួន និងការកាត់ទោសការជួញដូរមនុស្សក្នុងរដ្ឋ ឬថាតើករណីភាគច្រើននឹងបន្តដោះស្រាយជាបឋមដោយអាជ្ញាធរអនុវត្តច្បាប់សហព័ន្ធ។ ជាក់ស្តែង ឥទ្ធិពលសារពើពន្ធនៃវិធានការនេះទៅលើរដ្ឋាភិបាលរដ្ឋ  និង មូលដ្ឋានដែលត្រូវបានពិភាក្សាខាងក្រោមអាស្រ័យទៅតាមភាពមិនប្រាកដមួយចំនួន។

***មានកំណើនតិចតួចក្នុងការចំណាយរបស់រដ្ឋ និងក្រសួងយុត្តិធម៌តាមមូលដ្ឋាន ពីកំណើននៃទណ្ឌកម្ម។*** វិធានការនេះនឹងធ្វើឲ្យកើនឡើងនូវការចំណាយលើការស្វែងរកយុត្តិធម៌ចំពោះបទល្មើសនៅថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានដោយបង្កើនទណ្ឌកម្មនៃឧក្រិដ្ឋកម្មចំពោះការជួញដូរមនុស្ស។ ជាពិសេស បង្កើនការកាត់ទោសឲ្យជាប់ពន្ធធនាគារក្នុងវិធានការនេះនឹងបង្កើនរយៈពេលដែលជនល្មើសត្រូវជាប់ក្នុងពន្ធធនាគាររដ្ឋ។ លើសពីនេះទៀតអាចទៅរួចដែលបទបញ្ញត្តិនៃវិធានការនេះបង្កើនលក្ខខណ្ឌតម្រូវថវិការ និងការបណ្តុះបណ្តាលសម្រាប់ការអនុវត្តច្បាប់មូលដ្ឋានអាចធ្វើឲ្យមានការរឹតបន្តឹងលើការចាប់ខ្លួន បណ្តឹងចោទប្រកាន់ និងការកាត់ទោសចំពោះការជួញដូរមនុស្ស។ វិធានការនេះក៏អាចធ្វើឲ្យកើនឡើងនូវការចំណាយលើការស្វែងរកយុត្តិធម៌ចំពោះបទល្មើសនៅថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានផងដែរ។ សរុបមក ការចំណាយថ្មីទាំងនេះ**គឺមិនទំនងជាលើសពីពីរ-បីលានដុល្លារប្រចាំឆ្នាំទេ។**

សំណើប្រជាមតិ
# 35 ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ (ត)

***កំណើនដែលមានសក្តានុពលនៅក្នុងខ្ទង់ចំណាយលើការបណ្តុះបណ្តាលពីការអនុវត្តច្បាប់មូលដ្ឋាន។*** ដូចដែលបានកត់សម្គាល់ពីខាងដើម វិធានការនេះត្រូវឲ្យរដ្ឋ និងមន្ត្រីមានសមត្ថកិច្ចមូលដ្ឋានទទួលបានការបណ្តុះបណ្តាលជាក់លាក់ស្តីពីការជួញដូរមនុស្ស។ ដោយសារតែមន្ត្រី CHP បានទទួលការបណ្តុះបណ្តាលទាំងនេះរួចរាល់ហើយ ដូច្នេះនឹងមិនមានខ្ទង់ចំណាយរបស់រដ្ឋបន្ថែមទៀតទេ។ ផលប៉ះពាល់សារពើពន្ធនៃតម្រូវការទៅលើភ្នាក់ងារមូលដ្ឋាននេះអាចផ្អែកទៅលើវិសាលភាពដែលមន្ត្រីមូលដ្ឋានកំពុងទទួលបានការបណ្តុះបណ្តាលទាំងនេះក្នុងពេលបច្ចុប្បន្ន និងផ្អែកទៅលើរបៀបដែលភ្នាក់ងារមានសមត្ថកិច្ចមូលដ្ឋានជ្រើសរើសដើម្បីបំពេញទៅតាមតម្រូវការបណ្តុះបណ្តាលរបស់វិធានការ។ ខោនធី និងទីក្រុងអាចមានចំណាយរួមរហូតដល់ **ពីរ-បីលានដុល្លារក្នុងរយៈពេលម្តង**ដើម្បីបណ្តុះបណ្តាលបុគ្គលិកដែលមានស្រាប់ និងផ្តល់បុគ្គលិកបម្រុងទៅឲ្យមន្ត្រីដែលកំពុងបណ្តុះបណ្តាល ដោយមានការចំណាយតិចដែលបានរ៉ាប់រងនៅក្នុងឆ្នាំបន្តបន្ទាប់នីមួយៗដើម្បីបណ្តុះបណ្តាលមន្ត្រីដែលបានជួលថ្មីៗ។

***បង្កើនប្រាក់ចំណូលពីការផាកពិន័យសម្រាប់សេវាកម្មជួយជនរងគ្រោះ។*** ការពិន័យលើបទឧក្រិដ្ឋថ្មីៗដែលបានបង្កើតដោយវិធានការនេះនឹងធ្វើឲ្យមានចំណូលបន្ថែមខ្លះទៀតដែលមិនលើសពី ពីរបីលានដុល្លារ ជារៀងរាល់ឆ្នាំទេ។ ប្រាក់ចំណូលជាក់ស្តែងនឹងផ្អែកលើចំនួនបុគ្គលដែលបានជាប់ចោទពីបទអំពើចរាចរមនុស្ស។ កម្រិតនៃការផាកពិន័យត្រូវបានកំណត់ដោយតុលាការ និងចំនួននៃការទូទាត់ជាក់ស្តែងត្រូវបង់ដោយជនជាប់ចោទ។ ចំណូលទាំងនេះនឹងត្រៀមទុកជាបឋមដើម្បីបម្រើសេវាកម្មឲ្យជនរងគ្រោះដោយសារការជួញដូរមនុស្ស ប៉ុន្តែក៏ត្រូវបានប្រើប្រាស់សម្រាប់បង្កាការជួញដូរមនុស្ស ការការពារសាក្សី និងប្រតិបត្តិការជួយសង្គ្រោះផងដែរ។

35

# សំណើប្រជាមតិ ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។
# 35

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 35 ★

បញ្ឈប់ការជួញដូរមនុស្ស—បាទ/ចាសលើសំណើប្រជាមតិ 35។

នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ស្ត្រី និងកុមារដែលងាយរងគ្រោះត្រូវបានគេឃុំឃាំងប្រឆាំងទៅនឹងឆន្ទៈរបស់ពួកគេ និងត្រូវបានបង្ខំឲ្យចូលរួមក្នុងពេស្យាកម្មដើម្បីផលប្រយោជន៍ហិរញ្ញវត្ថុរបស់ក្រុមអ្នកជួញដូរមនុស្ស។ ជនរងគ្រោះជាច្រើន គឺជាក្មេងស្រីដែលមានវ័យត្រឹមតែ 12 ឆ្នាំប៉ុណ្ណោះ។

ការជួញដូរមនុស្ស គឺជាសហគ្រាសមួយក្នុងចំណោមសហគ្រាសឧក្រិដ្ឋកម្មដែលរីកលូតលាស់លឿនបំផុតនៅក្នុងពិភពលោក ហើយវាកំពុងតែកើតឡើងជាក់ស្តែងនតាមផ្លូវនានាក្នុងរដ្ឋកាលីហ្វ័រញ៉ា និងតាមប្រព័ន្ធអ៊ីនធឺណិតជាកន្លែងដែលក្មេងស្រីៗត្រូវបានទិញ និងលក់។

ការសិក្សាថ្នាក់ជាតិមួយបានផ្តល់ឲ្យរដ្ឋកាលីហ្វ័រញ៉ានូវចំណាត់ថ្នាក់អក្សរ "F" ទៅលើ ច្បាប់របស់ខ្លួន សម្រាប់ដោះស្រាយបញ្ហាការជួញដូរផ្លូវភេទកុមារ។

ហេតុនេះហើយ យើងត្រូវការសំណើប្រជាមតិ 35។

*បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 35 នឹង ៖*

- បង្កើនរយៈពេលដាក់ពន្ធធនាគារសម្រាប់អ្នកជួញដូរមនុស្ស ដើម្បីចាប់ពួកឧក្រិដ្ឋជនទាំងនេះឲ្យទទួលខុសត្រូវ។
- តម្រូវឲ្យអ្នកជួញដូរមនុស្សដែលមានទោសទាំងឡាយចុះបញ្ជីជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដើម្បីទប់ស្កាត់បទល្មើសក្នុងពេលអនាគត។
- តម្រូវឲ្យអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលបានចុះបញ្ជីទាំងអស់បង្ហាញគណនីអ៊ីនធឺណិតរបស់ពួកគេ ដើម្បីបញ្ឈប់ការកេងប្រវ័ញ្ចលើកុមារតាមអ៊ីនធឺណិត។
- តំឡើងថ្លៃផាកពិន័យពីអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលមានទោស ហើយប្រើប្រាស់ថវិកាទាំងនេះសម្រាប់បង់ថ្លៃសេវាផ្សេងៗរបស់ជនរងគ្រោះដូច្នេះអ្នកដែលនៅរស់អាចកែលម្អជីវិតរបស់ពួកគេវិញបាន។

*សំណើប្រជាមតិ 35 ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ។*

ជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទជាច្រើន គឺជាក្រុមកុមារដែលងាយរងគ្រោះ។ ពួកគេព្រួយបារម្ភចំពោះអាយុជីវិតរបស់ពួកគេ និងត្រូវរងការរំលោភបំពានផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត។ ការិយាល័យស៊ើបអង្កេតសហព័ន្ធ (FBI) ទទួលស្គាល់ថាទីក្រុងចំនួន បី នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាគឺ - ទីក្រុង Los Angeles, San Francisco និង San Diego - គឺជាតំបន់មានការជួញដូរផ្លូវភេទកុមារក្នុងដង់ស៊ីតេខ្ពស់។ ហេតុនេះហើយ ទើបយើងត្រូវការសំណើប្រជាមតិ 35 ដើម្បីការពារកុមារពីការកេងប្រវ័ញ្ច។

*សំណើប្រជាមតិ 35 ចាប់អ្នកជួញដូរមនុស្សឲ្យទទួលខុសត្រូវចំពោះបទល្មើសដ៏គួរឲ្យភ័យខ្លាចរបស់ពួកគេ។*

" ក្រុមអ្នកជួញដូរផ្លូវភេទសម្លឹងរកមើលអ្នកដែលងាយរងគ្រោះបំផុតនៅក្នុងសង្គមរបស់យើង។ ពួកគេក្លាយជាអ្នកមាន ហើយបន្ទាប់មកបោះបង់ជនរងគ្រោះរបស់ពួកគេចោល។ សំណើប្រជាមតិ 35 នឹងចាប់ឧក្រិដ្ឋជនទាំងនោះឲ្យទទួលខុសត្រូវ។ តាមការអនុម័តសំណើប្រជាមតិ 35 ពលរដ្ឋកាលីហ្វ័រញ៉ានឹងធ្វើសេចក្តីថ្លែងការណ៍មួយបញ្ជាក់ថាពួកយើងនឹងមិនអត់ឱនចំពោះការរំលោភបំពានផ្លូវភេទលើកូនចៅរបស់យើងឡើយ ហើយយើងគាំទ្រដល់ជនរងគ្រោះក្នុងបទល្មើសដ៏អាក្រក់នេះជានិច្ច។"

—Nancy O'Malley, Alameda ខោនធី មេធាវីមណ្ឌល និងអ្នកគាំទ្រសិទ្ធិជនរងគ្រោះជាតិ។

*សំណើប្រជាមតិ 35 ជួយបញ្ឈប់ការកេងប្រវ័ញ្ចកុមារដែលចាប់ផ្តើមតាមអ៊ិនធឺណិត។*

ប្រព័ន្ធអ៊ិនធឺណិតផ្តល់ឲ្យក្រុមអ្នកជួញដូរមនុស្សនូវមធ្យោបាយរក កុមារដែលងាយរងគ្រោះ។ សំណើប្រជាមតិ 35 តម្រូវឲ្យអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលមានទោសផ្តល់នូវព័ត៌មានដល់អាជ្ញាធរអំពីវត្តមានអ៊ីនធឺណិតរបស់ពួកគេដែលនឹងជួយការពារកុមាររបស់យើង និងទប់ស្កាត់ការជួញដូរមនុស្ស។

*ក្រុមអ្នកអនុវត្តច្បាប់ធំៗបំផុតក្នុងរដ្ឋកាលីហ្វ័រញ៉ាជំរុញឲ្យមានការបោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិ លេខ 35។*

"ខណៈអ្នកទាំងនោះស្ថិតនៅជួរមុខក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស យើងជំរុញដោយទទូចឲ្យគាំទ្រទៅលើសំណើប្រជាមតិ 35 ដើម្បីជួយដល់ពួកយើងក្នុងការកាត់ទោសអ្នកជួញដូរផ្លូវភេទទាំងនោះ និងការពារជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ។"

— លោក Ron Cottingham ប្រធានសមាគមស្រាវជ្រាវមន្ត្រីរក្សាសន្តិភាពរដ្ឋកាលីហ្វ័រញ៉ាដែលតំណាងឲ្យសមាជិកសុវត្ថិភាពសាធារណៈចំនួន 64,000 នាក់មានប្រសាសន៍។

*ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងអ្នកតស៊ូមតិរបស់ពួកគេជំរុញឲ្យបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 35។*

"សំណើប្រជាមតិ 35 នឹងជួយការពារកុមារពីអ្នកជួញដូរមនុស្សដែលស្វែងរកប្រាក់ចំណេញតាមរយៈការលក់ពួកគេនៅតាមដងផ្លូវ និងតាមអ៊ិនធឺណិត។"

— លោក Marc Klaas ជាអ្នកតស៊ូមតិរបស់ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងជាឪពុករបស់ Polly Klaas ដែលត្រូវបានគេចាប់ជំរិត ហើយសម្លាប់ចោលនៅក្នុងឆ្នាំ 1993 មានប្រសាសន៍"

"កាលពីអាយុ 14 ឆ្នាំ ខ្ញុំបានរត់ចេញពីផ្ទះដែលកើតមានបញ្ហា ហើយបានធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់អ្នកជួញដូរមនុស្សម្នាក់។ អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំត្រូវបានគេជួញដូរ និងរំលោភបំពាននៅក្នុងអំឡុងពេលដែលខ្ញុំនៅជាកុមារនៅឡើយ។ ក្នុងនាមជាអ្នករស់រានម្នាក់ពីការជួញដូរ ខ្ញុំស្នើសុំដល់ពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ឲ្យក្រោកឈរប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងបោះឆ្នោតគាំទ្រសំណើប្រជាមតិ 35 នេះ។

—Leah Albright-Byrd, អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ។ បញ្ឈប់ការធ្វើចរាចរមនុស្សខុសច្បាប់។

*បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 35។* *VoteYeson35.com*

**LEAH ALBRIGHT-BYRD**
អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

**MARC KLAAS,** ប្រធាន
មូលនិធិ KlaasKids

**SCOTT R. SEAMAN,** ប្រធាន
សមាគមនាយកប៉ូលិសកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 35 ★

តាមពិតទៅ វិធានការដែលអះអាងថាផ្តោតគោលដៅទៅលើការជួញដូរមនុស្សនេះគំរាមកំហែងដល់ពលរដ្ឋស្លូតត្រង់ជាច្រើន៖

ប្រសិនបើសំណើប្រជាមតិ 35 ត្រូវបានអនុម័ត នោះអ្នកទាំងឡាយដែលទទួលការឧបត្ថម្ភថវិកាពីពេស្យាកម្មធម្មតា និងដោយព្រមព្រៀងគ្នាក្នុងចំណោមមនុស្សពេញវ័យដូចជា - កូនៗរបស់អ្នករកស៊ីផ្លូវភេទ ឪពុកម្តាយ ប្តី/ប្រពន្ធ ដៃគូនៅក្នុងផ្ទះជាមួយគ្នា មិត្តរួមបន្ទប់ ម្ចាស់ផ្ទះឈ្នួល ឬអ្នកដទៃទៀត-អាចត្រូវកាត់ទោសពីបទធ្វើជាអ្នកជួញដូរមនុស្ស ហើយប្រសិនបើពួកគេត្រូវបានកាត់ទោស នោះពួកគេនឹងត្រូវបង្ខំឲ្យចុះបញ្ជីជាអ្នកប្រព្រឹត្តបទ ល្មើសផ្លូវភេទអស់មួយជីវិត។

"កូនប្រុសរបស់ខ្ញុំ ដែលបានបម្រើប្រទេសរបស់យើងនៅក្នុងជួរយោធាសហរដ្ឋអាមេរិក ហើយឥឡូវនេះចូលរៀននៅមហាវិទ្យាល័យនោះអាចត្រូវបានលាបពណ៌ថាជាអ្នកជួញដូរមនុស្ស ហើយត្រូវចុះបញ្ជីជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ ប្រសិនបើខ្ញុំឧបត្ថម្ភដល់គេនូវប្រាក់ដែលខ្ញុំរកបានតាមរយៈការផ្តល់សេវាផ្នែកផ្លូវភេទនោះ។"

—Maxine Doogan មានប្រសាសន៍។

ក្រៅពីធ្វើការជាមួយសហគមន៍អ្នករកស៊ីផ្លូវភេទដើម្បីបញ្ឈប់អ្នកជួញដូរមនុស្សពិតប្រាកដ ក្រុមអ្នកគាំទ្រស្ត្រីប្រឆាំងនឹងការរួមភេទដែលនិយមឆ្វេង និងក្រុមអភិរក្សសាសនាដែលនិយមស្តាំ ដែលគាំទ្រសំណើប្រជាមតិ 35 សង្ឃឹមថា អ្នកបោះឆ្នោតដែលបានស្តាប់ឮ "ការជួញដូរមនុស្ស" នឹងត្រូវគេបោកបញ្ឆោតឲ្យគាំទ្រយុទ្ធនាការឥតប្រយោជន៍របស់ពួកគេប្រឆាំងទៅនឹង "របរចំណាស់ បំផុតរបស់ពិភពលោក" តាមរយៈការដាក់ទោសឧក្រិដ្ឋបន្ថែមទៅលើមនុស្សទាំងឡាយដែលពាក់ព័ន្ធនឹងពេស្យាកម្មមនុស្សពេញវ័យដោយមានការព្រមព្រៀងគ្នានោះ។ ការអះអាងរបស់អ្នកគាំទ្រដែលថារដ្ឋកាលីហ្វ័រញ៉ា គឺជា "តំបន់មានដង់ស៊ីតេខ្ពស់" ពីព្រោះការជួញដូរនោះ គឺមានភាពដូចគ្នាដែលគួរឲ្យសង្ស័យទៅនឹងការអះអាងមិនត្រឹមត្រូវមួយចំនួន

ដែលធ្វើឡើងនៅកន្លែងផ្សេងទៀតដែរ ៖ *http://www.oregonlive.com/portland/index.ssf/2011/01/portland_child_sex_trafficking.html*

សំណើប្រជាមតិ 35 នឹងបង្កើតទំនួលខុសត្រូវគ្មានថវិកាថ្មីមួយសម្រាប់រដ្ឋរបស់យើង ចំពេលដែលរដ្ឋាភិបាលរដ្ឋកាលីហ្វ័រញ៉ាកំពុងតែស្ថិតក្នុងវិបត្តិសារពើពន្ធ ហើយទីក្រុងយ៉ាងច្រើនក៏បានប្រកាសក្ស័យធនរួចហើយដែរ។ នាយកប្រតិបត្តិដ៏មានស្តុកស្តម្ភម្នាក់បានឧបត្ថម្ភថវិកាលើសពី 90% នៃថវិកាបរិច្ចាគសម្រាប់យុទ្ធនាការសំណើប្រជាមតិ 35៖

*http://www.huffingtonpost.com/2012/07/07/californians-against-sexual-exploitation-act_n_1656311.html*

ប៉ុន្តែថវិកានេះនឹងមិនមានសម្រាប់ផ្គត់ផ្គង់ការពង្រឹងច្បាប់ឡើយ។ អ្នកជួញដូរដែលបង់ប្រាក់មានជំនឿចិត្តថា - ការរឹបអូសយកទ្រព្យសម្បត្តិមិនបានផ្តល់ថវិកាបង់គ្រប់សម្រាប់ "សង្គ្រាមប្រឆាំងគ្រឿងញៀន" ទេ ហើយក៏នឹងមិនផ្តល់ថវិកាគ្រប់គ្រាន់ដល់ "សង្គ្រាមប្រឆាំងពេស្យាកម្ម" ដែរ។

បោះឆ្នោត ទេ លើសំណើប្រជាមតិ 35!

**MANUAL JIMENEZ,** CFO
អ្នកផ្តល់សេវាសម្រើប ស្របច្បាប់,
កម្រោងអប់រំ, និងស្រាវជ្រាវ, Inc.

**NORMA JEAN ALMODOVAR**

**STARCHILD**



*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# សំណើប្រជាមតិ 35 ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 35 ★

សំណើប្រជាមតិ 35 ខ្វះខាតមិនបានបំពេញតាមការសន្យារបស់ខ្លួន ហើយអ្នកបោះឆ្នោតគួរតែបញ្ជូនវាត្រឡប់ទៅធ្វើការពិចារណាឡើងវិញ។

ការដាក់ឲ្យទៅជាបទឧក្រិដ្ឋមិនបាននាំមកនូវការការពារឡើយ។

ប្រសិនបើវាត្រូវបានអនុម័ត រដ្ឋកាលីហ្វ័រញ៉ានឹងត្រូវសរសេរមូលប្បទានបត្រចំហថ្មីមួយផ្សេងទៀតទៅឲ្យអ្នកគាំទ្រសំណើប្រជាមតិ 35។ វិធានការបោះឆ្នោតដោយមិនគិតវែងឆ្ងាយនេះ គឺពឹងផ្អែកទៅលើនិយមន័យដ៏ទូលំទូលាយនៃពាក្យថា ការផ្តល់សេវាផ្លូវភេទ។ ក្នុងនោះមានដូចជា ឪពុកម្តាយ កូន មិត្តរួមបន្ទប់ ដៃគូរស់នៅក្នុងផ្ទះជាមួយគ្នា និងម្ចាស់ផ្ទះឈ្នួលរបស់អ្នករកស៊ីផ្លូវភេទទាំងឡាយត្រូវបានកំណត់ថា ជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ។ គោលដៅពិតប្រាកដ គឺធ្វើយ៉ាងណាឲ្យមានលទ្ធភាពធ្វើការដកហូតទ្រព្យសម្បត្តិទុកជាប្រយោជន៍សម្រាប់ភ្នាក់ងារអនុវត្តច្បាប់ និងការមិនស្វែងរកប្រាក់ចំណេញ។ សំណើប្រជាមតិ 35 មិនមានការត្រួតពិនិត្យមើល និងការទទួលខុសត្រូវឡើយ។ ប្រការនេះនឹងបើកឲ្យមានការអនុវត្តដោយពុករលួយដូចដែលយើងបានឃើញពីមុនមកហើយនៅក្នុងការអនុវត្តប្រឆាំងនឹងគ្រឿងញៀន។ *http://www.contracostatimes.com/news/ci_20549513/defendant-cnet-corruption-scandal-gets-federal-prison-sentence*

ប្រសិនបើវាត្រូវបានអនុម័ត នឹងមានឥទ្ធិពលអាក្រក់បង្កគ្រោះថ្នាក់ទៅលើថវិកាជាតិ។ ច្បាប់នេះពឹងផ្អែកលើធនធាននានាដែលធ្វើឱ្យមនុស្សធំទៅជាឧក្រិដ្ឋជនពេលគេត្រូវបានចាប់ចងដោយសារពេស្យាចារដោយមិនរើសមុខនៅក្នុងកិច្ចប្រតិបត្តិសំងាត់ដែលធ្វើឡើងក្រោមការលាក់កំបាំងជាអ្នកសង្គ្រោះជាកុមារ។ *http://www.sfgate.com/default/article/Bay-Area-sweep-nets-child-prostitute-pimp-suspects-3661229.php*

ការស្រាវជ្រាវបង្ហាញថាស្ទើរតែគ្រប់យុវវ័យដែលត្រូវគេចាប់ដោយពេស្យាចារគឺមិនមាន មេបនទេ។ដូច្នេះគំនិតដែលថាច្បាប់នេះនឹងបង់ថ្លៃខ្លួនឯងគឺមិនមានការគាំទ្រដោយភ័ស្តុតាងទេ។ បាត់ក្មេងប្រុស៖ ការស្រាវជ្រាវថ្មីលុបបំបាត់ភាពជាតួយ៉ាង *http://www.riverfronttimes.com/2011-11-03/news commercial-sexual-exploitation-of-children-john-jay-college-ric-curtis-meredith-dank-underage-prostitution-sex-trafficking-minors/*

សំណើប្រជាមតិ 35 ពឹងផ្អែកទៅលើគោលនយោបាយគ្មានប្រសិទ្ធភាពដែលប្រើប្រាស់ការធ្វើឲ្យទៅជាបទឧក្រិដ្ឋធ្វើទៅជាមធ្យោបាយដើម្បីចាប់ខ្លួនក្មេងមិនទាន់គ្រប់អាយុទាំងអស់ ក៏ប៉ុន្តែបានហៅទង្វើនោះថាជា "ការជួយសង្គ្រោះ" ទៅវិញ។

Cheryl Overs ជាសមាជិកក្រុមផ្តល់ប្រឹក្សាអង្គការសហប្រជាជាតិខាងដោះស្រាយបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទជាលក្ខណៈអាជីវកម្មលើកុមារ *http://www.plri.org/story/tackling-child-commercial-sexual-exploitation កុំពង្រីកពួកប៉ូលិសដែលបានបរាជ័យរួចទៅហើយនេះតទៅទៀត។* *http://www.traffickingpolicyresearchproject.org/*

ប្រសិនបើវាត្រូវបានអនុម័តរដ្ឋទំនងជាតំរូវឱ្យការពារច្បាប់នេះនៅក្នុងតុលាការពីព្រោះវាប្រហែលជានឹងត្រូវប្រឈមនឹងផ្លូវច្បាប់ដោយមកពីមានការចោទជាសំណួរជាច្រើន និងវាអាចជាមាត្រាអធមនុញ្ញភាពដោយរួមនូវនិយមន័យមិនច្បាស់លាស់ផុយពីរដ្ឋធម្មនុញ្ញនៃពាក្យ "ការជួញដូរមនុស្ស" រួមទាំង"បំណងចែកចាយរឿងអាសអាភាស" ដែលអាចជាអធមនុញ្ញភាពក្នុងការដាក់ទោសមានលក្ខណៈ "ឃោរឃៅ និងមិនធម្មតា" រួមទាំងរយៈពេលដាក់ពន្ធនាគារ និងប្រាក់ផាកពិន័យច្រើនហួសកម្រិតអាចជាការហាមឃាត់ផុយពីរដ្ឋធម្មនុញ្ញទៅលើសិទ្ធិរបស់ចុងចោទក្នុងការណែនាំភ័ស្តុតាងនៅក្នុងការជំនុំជម្រះក្តីការពារខ្លួន។

ច្បាប់នេះ នឹងតម្រូវឲ្យរដ្ឋចំណាយថវិកាបន្ថែមក្នុងចំនួនមិនជាក់លាក់: វានឹងបង្កើនបន្ទុកការងារបន្ថែមទៅលើនាយកដ្ឋានសាកល្បងដែលមានបន្ទុកការងារច្រើនលើសលប់ទៅហើយនោះ។ សូមពិចារណាទៅលើករណីរបស់ Jaycee Dugard និងទឹកប្រាក់ចំនួន $20,000,000 ដុល្លារ ដែលរដ្ឋកាលីហ្វ័រញ៉ា បានបង់ទៅឲ្យនាងសម្រាប់ការដែលមិនការពារនាង ប្រឆាំងនឹងជនប្រព្រឹត្តល្មើសផ្លូវភេទដោយហិង្សាម្នាក់។ កិច្ចការនេះនឹងតម្រូវឲ្យមានការហ្វឹកហ្វឺនដល់មន្ត្រីនគរបាលដើម្បីអនុវត្តខចែងបន្ថែមនៅក្នុងច្បាប់នេះ។ *http://www.sfbg.com/politics/2012/06/16/bringing-heat*

សំណើប្រជាមតិដែលណែនាំខុសនេះ ប្រើប្រាស់នូវការភ័យខ្លាចដែលគ្មានការពិតដោយបញ្ឆះបញ្ឆូលអ្នកបោះឆ្នោតឲ្យធ្លាក់ទៅក្នុងការលេងល្បែងទាក់ទងនឹងប្រាក់ផាកពិន័យ និងថ្លៃសេវានានាក្នុងពេលអនាគត ដោយបង្វែរទិសធនធានដ៏ខ្សត់ខ្សោយរបស់រដ្ឋចេញឆ្ងាយពីកម្មវិធីអន្តរាគមន៍ផ្អែកសេវាសង្គមដែលមានស្រាប់។

ច្បាប់នានាកំពុងត្រូវបានអនុវត្ត *http://blog.sfgate.com/incontracosta/2012/06/25concord-police-assist-with-multi-agency-operation-targeting-child-prostitution/*

គោលនយោបាយដែលជាមូលដ្ឋាននៃសំណើប្រជាមតិ 35 នេះ ត្រូវបានបង្កើតឡើងនៅខាងក្រៅចំណោមប្រជាជនដែលរងផលប៉ះពាល់។ ក្រុមអ្នកគាំទ្ររង់ចាំទទួលផលប្រយោជន៍ហិរញ្ញវត្ថុ តាមរយៈការទទួលបានប្រាក់ខែដើម្បី "ផ្តល់សេវាផ្សេងៗ" ដល់អ្នករកស៊ីផ្លូវភេទដែលធ្វើការងារដោយព្រមព្រៀង។ អ្នករកស៊ីផ្លូវភេទទាំងឡាយមិនចង់ឲ្យគេបង្ខំឲ្យចាកចេញពីការងារតាមច្បាប់ព្រហ្មទណ្ឌឡើយ ហើយក៏មិនចង់ឲ្យគេបង្ខំឲ្យទទួលយកសេវាផ្សេងៗពីអ្នកគាំទ្រដែរ។ អ្នករកស៊ីផ្លូវភេទទាមទារឲ្យមានសំលេងដែរ។

សូមឱ្យច្បាស់។ ការធ្វើជាឧក្រិដ្ឋកម្មនៃពេស្យាចារគឺជាលក្ខខណ្ឌដែលអនុញ្ញាតឱ្យមានការកេងប្រវ័ញ្ច។ ចូរយើងជាជាងលើកឡើងអំពីបញ្ហានេះ។

បោះឆ្នោត ទេ លើនយោបាយបរាជ័យទាំងនេះ។

បោះឆ្នោត ទេ លើសំណើប្រជាមតិ លេខ 35។

**MAXINE DOOGAN,** ប្រធាន
អ្នកផ្តល់សេវាសម្រើប ស្របច្បាប់,
កម្រោងអប់រំ, និងស្រាវជ្រាវ, Inc.

**MANUAL JIMENEZ, CFO**
អ្នកផ្តល់សេវាសម្រើប ស្របច្បាប់,
កម្រោងអប់រំ, និងស្រាវជ្រាវ, Inc.

35

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 35 ★

*"ខ្ញុំមានអាយុត្រឹមតែ 10ឆ្នាំប៉ុណ្ណោះនៅពេលដែលខ្ញុំត្រូវបានកេងប្រវ័ញ្ចជាលើកដំបូងបង្អស់ដោយអ្នកជួញដូរម្នាក់។ ខ្ញុំបានរងការឈឺចាប់ពីការរំលោភបំពានអស់រយៈពេលរាប់ឆ្នាំក្នុងអំឡុងពេលដែលអ្នកជួញដូរនោះបានទទួលប្រាក់ចំណេញ។ សូមក្រោកឈរឡើងដើម្បីស្ត្រី និងកុមារដែលកំពុងត្រូវបានគេជួញដូរនៅតាមផ្លូវ និងតាមអ៊ិនធឺណិត។ សូមបោះឆ្នោតគាំទ្រសំណើប្រជាមតិ លេខ 35 ដើម្បីបញ្ឈប់ការជួញដូរមនុស្ស។"* —*Withelma Ortiz, អ្នករស់រានពីការជួញដូរមនុស្ស មានប្រសាសន៍ថា។*

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 35 នឹងប្រយុទ្ធតបនឹងការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចលើស្ត្រី និងកុមារ។

ការសិក្សាមួយថ្មីៗនេះបានផ្តល់ចំណាត់ថ្នាក់អក្សរ "F" ដល់រដ្ឋកាលីហ្វ័រញ៉ាសម្រាប់ច្បាប់ប្រឆាំងការជួញដូរផ្លូវភេទកុមារដែលមានភាពទន់ខ្សោយរបស់ខ្លួន។ ការិយាល័យស៊ើបអង្កេតសហព័ន្ធ (FBI) បានកំណត់ទីក្រុង San Francisco, Los Angeles និង San Diego ថាជាតំបន់ជួញដូរផ្លូវភេទកុមារក្នុងកំរិតខ្ពស់។

អាយុជាមធ្យមនៅពេលដែលក្មេងស្រីត្រូវបានគេជួញដូរលើកដំបូង គឺពី 12 ទៅ 14 ឆ្នាំ។ ក្មេងៗទាំងនេះគួរតែកំពុងគិតគូរអំពីកិច្ចការសាលា របស់ពួកគេ មិនមែនគិតគូពីវិធីដើម្បីរស់រានក្នុងយប់មួយទៀតដែលកំពុងត្រូវបានគេលក់នោះទេ។

សំណើប្រជាមតិ 35 នឹងការពារកូនក្មេងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ដោយបង្កើនការផ្តន្ទាទោសប្រឆាំងនឹងការជួញដូរមនុស្សធ្វើឲ្យអ្នកជួញដូរដែលបានជាប់ទោសត្រូវចុះបញ្ជីជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ ហើយទាមទារឲ្យអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលចុះបញ្ជីទាំងអស់ត្រូវផ្តល់ព័ត៌មានដល់អាជ្ញាធរអំពីវត្តមានតាមអ៊ិនធឺណិតរបស់ពួកគេ ដើម្បីជួយការពារការជួញដូរមនុស្សតាមអ៊ិនធឺណិត។

សំណើប្រជាមតិ 35 ជួយជនរងគ្រោះឲ្យទាញជីវិតរបស់ពួកគេបាន មកវិញដោយបង្កើនការពិន័យប្រឆាំងនឹងការជួញដូរមនុស្ស និង តំកល់ថវិកាទាំងនេះសំរាប់សេវាជនរងគ្រោះ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 35 គឺត្រូវបានគាំទ្រដោយសម្ព័ន្ធដ៏ទូលំទូលាយ ដែលរួមមាន៖

- អ្នកគាំទ្រកូនក្មេងនិងជនរងគ្រោះ ដូចជាមូលនិធិ KlaasKids និងជនរងគ្រោះឧក្រិដ្ឋកម្មដែលរួមគ្នា
- អង្គការពង្រឹងច្បាប់រដ្ឋកាលីហ្វ័រញ៉ាដែលតំណាងឲ្យមន្ត្រីដែល មានឋានន្តរសក្តិនិងពង្រឹងច្បាប់ឯកសារចំនួនច្រើនជាង 80,000 នាក់
- អ្នករស់រានពីការជួញដូរមនុស្ស

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 35 បញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ។

**WITHELMA ORTIZ**
អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

**CARISSA PHELPS**
អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

**NANCY O'MALLEY**
មេធាវីមណ្ឌល ខោនធី Alameda

*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# សំណើប្រជាមតិ 36 ច្បាប់ប្រព្រឹត្តិល្មើសបីដង។ ទុរជនបទឧក្រិដ្ឋច្រំដែលៗ។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

**ចំណងជើងជាផ្លូវការ និងសេចក្តីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

## ច្បាប់ប្រព្រឹត្តិល្មើសបីដង។ ទុរជនបទឧក្រិដ្ឋច្រំដែលៗ។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

- ការកែប្រែច្បាប់ ដើម្បីកាត់ទោសអស់មួយជីវិត លុះត្រាតែនៅពេលជាប់ទោសបទឧក្រិដ្ឋថ្មី គឺធ្ងន់ធ្ងរ ឬឃោរឃៅ។
- អនុញ្ញាតការកាត់ទោសសាថ្មី សំរាប់ទុរជនដែលនៅពេលបច្ចុប្បន្ននេះកំពុងជាប់ទោសអស់មួយជីវិត បើកីរាជាប់ទោសប្រព្រឹត្តិ ល្មើសបីដង មិនជាធ្ងន់ធ្ងរ ឬឃោឃៅ ហើយចៅក្រមអនុម័តថាការកាត់ទោសមិនបង្ហាញគ្រោះថ្នាក់គតសមហេតុផល ចំពោះ សុវត្ថិភាពរបស់សាធារណជន។
- បន្តកាត់ទោសឲ្យជាប់ទោសបញ្ញត្តិអស់មួយជីវិត បើការជាប់ទោសប្រព្រឹត្តិបទល្មើសបីដង សំរាប់បទល្មើសខ្លះដែលមិនធ្ងន់ធ្ងរ ការប្រព្រឹត្តិល្មើសផ្លូវភេទមិនឃោឃៅ ឬគ្រឿងញៀន ឬជាប់ពាក់ព័ន្ធការមានកាំភ្លើង។
- រក្សាការជាប់ទោសបញ្ញត្តិអស់មួយជីវិត សំរាប់បទឧក្រិដ្ឋដែលមិនធ្ងន់ធ្ងរ ការប្រព្រឹត្តិល្មើសបីដងមិនឃោឃៅ បើការជាប់ទោសពីមុន គឺសំរាប់ការចាប់រំលោភ សំឡាប់មនុស្ស ឬការធ្វើបាបក្មេង។

**អ្នកវិភាគសេចក្តីសង្ខេបនៃនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានៈ**

- រដ្ឋសន្សំប្រាក់ជាប់ទាក់ទងចំពោះពន្ធនាគារ និងចំណាយលើលក្ខខ័ណ្ឌការដោះលែង ចំនួន $70 លានជាប្រចាំឆ្នាំ ជាហូរហែ ហើយអាចសន្សំប្រាក់—ដល់ទៅ $90 លាន ជាប្រចាំឆ្នាំ—ក្នុងរយៈពេលពីរបីទសវត្សរ៍ខាងមុខ។ ការប្រមាណទាំងនេះ អាចនឹងខ្ពស់ជាង ឬទាបជាង ដោយដប់លានដុល្លារ អាស្រ័យទៅលើវិធានការរបស់រដ្ឋនៅពេលអនាគត។
- រដ្ឋ និងខោនធីចំណាយប្រាក់មួយដង ពីរបីលានដុល្លារ ក្នុងពេលពីរបីឆ្នាំខាងមុខ សំរាប់សកម្មភាពតុលាការ ជាប់ទាក់ទង ការកាត់ទោសសាថ្មីនៃទុរជនខ្លះ។

---

ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### សាវតារ

36

មានបទឧក្រិដ្ឋបីប្រភេទដាច់ពីគ្នាគឺៈ បទឧក្រិដ្ឋធ្ងន់ធ្ងរ បទល្មើសជាមជ្ឈឹម និងការប្រព្រឹត្តល្មើសច្បាប់ស្រាលៗ។ ឧក្រិដ្ឋកម្មគឺជាប្រភេទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ហើយបុគ្គលដែលកាត់ ទោសពីបទឧក្រិដ្ឋអាចត្រូវកាត់ទោសឲ្យជាប់គុករដ្ឋនៅក្រោមលក្ខខណ្ឌ ជាក់លាក់នានា។ បុគ្គលដែលកាត់ទោសពីបទឧក្រិដ្ឋ ហើយដែលមិន បានត្រូវកាត់ទោសឲ្យជាប់គុករដ្ឋត្រូវតែកាត់ទោសឲ្យជាប់គុកខោនធី ដែលពិនិត្យដោយនាយកដ្ឋានសាកល្បងរបស់ខោនធីនៅក្នុងសហគមន៍ ឬទាំងពីរ។

ច្បាប់ដែលមានស្រាប់បែងចែកបទឧក្រិដ្ឋខ្លះជា "ហិង្សា" ឬ "ធ្ងន់ធ្ងរ" ឬទាំងពីរ ។ ឧទាហរណ៍នៃបទឧក្រិដ្ឋធ្ងន់ធ្ងរដែលបានកំណត់ថាហិង្សា រួមមានឃាតកម្ម ឆក់ប្លន់ និងចាប់រំលោភ។ ពេលដែលបទឧក្រិដ្ឋហិង្សា ស្ទើរទាំងអស់ត្រូវចាត់ទុកថាធ្ងន់ធ្ងរ បទឧក្រិដ្ឋផ្សេងទៀតត្រូវបានកំណត់ ថាធ្ងន់ធ្ងរតែចំពោះករណីដូចជា ការវាយប្រហារដោយបំណងប្រព្រឹត្តអំ ពើឆក់ប្លន់។ បទឧក្រិដ្ឋដែលមិនត្រូវបានបែងចែកថាហិង្សា ឬធ្ងន់ធ្ងររួមមានការចោរកម្មដ៏សម្បើម (មិនពាក់ព័ន្ធនឹងការប្រើប្រាស់កាំភ្លើង) និង ការកាន់កាប់សារធាតុហាមឃាត់។

នៅខែឧសភា ឆ្នាំ2012 មានអ្នកទោសជាប់ឃុំប្រហែល 137,000 នាក់ ក្នុងប្រព័ន្ធពន្ធនាគារនៃរដ្ឋការលីហ្វ័រញ៉ា។ ប្រព័ន្ធពន្ធនាគាររដ្ឋក្នុងឆ្នាំ 2012-2013 គឺផ្តល់គំរោងថវិកាស្ទើរតែ $9 ប្រាំបួនរយកោដិដុល្លារ។

***ការកាត់ទោសបទល្មើសបីដង។*** សំណើប្រជាមតិ លេខ184 (តាមធម្មតាសំដៅលើច្បាប់ "ចែងពីបទល្មើសបីដង") ត្រូវបានអនុវត្តដោយអ្នក បោះឆ្នោតក្នុងឆ្នាំ1994។ វាជំរុញឲ្យដាក់ពន្ធនាគារឲ្យបានយូរសំរាប់អ្នកប្រព្រឹត្តបទល្មើសដដែលៗ។ ជាពិសេស ច្បាប់តម្រូវអោយមនុស្សម្នាក់ ដែលដាក់ទោសពីបទឧក្រិដ្ឋ និងអ្នកដែលពីមុនត្រូវបានដាក់ទោសពីបទឧក្រិដ្ឋហិង្សា ឬធ្ងន់ធ្ងរមួយឬច្រើន ដើម្បីកាត់ទោសឲ្យជាប់ពន្ធនាគារ របស់រដ្ឋដូចខាងក្រោមៈ

- ***បទល្មើសជាលើកទីពីរ។*** ប្រសិនបើមនុស្សនោះមានការកាត់ទោសពីបទឧក្រិដ្ឋធ្ងន់ធ្ងរឬហិង្សា *មួយពីមុន* ការកាត់ទោសលើការ ដាក់ទោសបទឧក្រិដ្ឋថ្មីណាមួយ (មិនថាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ឬហិង្សា) គឺ*ពីរដង*នៃរយៈពេលកំណត់ដែលតម្រូវនៅក្រោមច្បាប់សំរាប់ការជាប់ ទោសថ្មីខុសពីនោះ។ អ្នកប្រព្រឹត្តិបទល្មើសដែលកាត់ទោសដោយ តុលាការក្រោមខចែងនេះត្រូវបានសំដៅថាជា "ជនប្រព្រឹត្តបទល្មើសលើកទីពីរ។" គិតមកត្រឹមខែមិនាឆ្នាំ 2012 មានអ្នកទោសប្រព្រឹត្តបទល្មើសលើកទីពីររស់នៅជាមួយគ្នាប្រហែល 33,000 នាក់។

# ច្បាប់ប្រព្រឹត្តិល្មើសបីដង។ ទុរជនបទឧក្រឹដ្ឋច្រំដែលៗ។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ (ត)

- ***បទល្មើសលើកទីបី។*** ប្រសិនបើមនុស្សណាធ្លាប់មានការ កាត់ទោសពីបទឧក្រិដ្ឋធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋហិង្សាកាលពីពេល*មុនពីរដងឬច្រើនដង* ការកាត់ទោសសំរាប់ការដាក់ទោសពីបទឧក្រិដ្ឋថ្មី*ណាមួយ*(មិនថាគ្រាន់តែជាបទឧក្រិដ្ឋធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋហិង្សា) គឺត្រូវជាប់មួយជីវិតជាមួយការដោះលែងដែលអាចទៅរួចឆាប់បំផុត បន្ទាប់ពីជាប់ពន្ធនាគារ 25 ឆ្នាំ។ អ្នកប្រព្រឹត្តបទល្មើសកាត់អោយជាប់ទោសក្រោម ខចែងនេះគឺសំដៅលើ "ជនជាប់ទោសលើកទីបី ។" មកត្រឹមខែមិនាឆ្នាំ 2012 មានជនជាប់ទោសជាលើកទីបីរស់នៅក្នុងពន្ធនាគារចំនួនប្រហែល 9,000 នាក់។

ខណៈដែលច្បាប់តម្រូវឲ្យការកាត់ទោសដែលបានរៀបរាប់ខាងលើ ចំពោះករណីខ្លះ តុលាការប្រហែលជាជ្រើសរើសមិនពិចារណាលើបទ ឧក្រិដ្ឋពីមុនៗនៅពេលកំពុងធ្វើការកាត់សេចក្ដី។ នៅពេលដែលការ នេះកើតឡើងជនល្មើសដែលមិនដូច្នេះទេនឹងត្រូវបានកាត់ទោសជាអ្នកប្រព្រឹត្តបទល្មើសលើកទីពីរ ឬទីបី អាចនឹងត្រូវកាត់សេចក្ដីមានរយៈពេលខ្លីជាងដូចដែលតម្រូវតាមក្រោមច្បាប់ចែងពីបទល្មើសបីដង។

***ការកំណត់ការដោះលែងពីពន្ធនាគារ។*** ក្រោមច្បាប់បច្ចុប្បន្ន អ្នកប្រព្រឹត្តបទល្មើសជាលើកទីពីរភាគច្រើន គឺត្រូវដោះលែងវិញដោយស្វ័យប្រវត្តិ បន្ទាប់ពីបំពេញចប់សព្វគ្រប់តាមការកាត់ទោសរបស់ពួក។ ផ្ទុយមកវិញ ជនជាប់ទោសជាលើកទីបី នឹងត្រូវដោះលែងវិញ ទាល់តែមានការ យល់ព្រមដោយគណៈកម្មការរបស់រដ្ឋខាងសវនាការ ខាងការដោះលែង (BPH)។ បន្ទាប់ពីជនជាប់ទោសលើកទីបីបាន បំពេញតាមចំនួនឆ្នាំអប្បរមាដែលតម្រូវដោយការដាក់ទោសរបស់ពួកការកំណត់ការដោះលែងពីពន្ធនាគារ។ ក្រោមច្បាប់បច្ចុប្បន្ន អ្នកប្រព្រឹត្តបទល្មើសជាលើកទីពីរភាគច្រើន គឺត្រូវដោះលែងវិញដោយស្វ័យប្រវត្តិ បន្ទាប់ពីបំពេញចប់សព្វគ្រប់តាមការកាត់ទោសរបស់ពួក។ ផ្ទុយមកវិញ ជនជាប់ទោសជាលើកទីបី នឹងត្រូវដោះលែងវិញទាល់តែមានការយល់ព្រមដោយគណៈកម្មការរបស់រដ្ឋខាងសវនាការ ខាងការដោះលែង (BPH)។ បន្ទាប់ពីជនជាប់ទោសលើកទីបីបាន បំពេញតាមចំនួនឆ្នាំអប្បរមារដែលតម្រូវដោយការដាក់ទោសរបស់ពួកគេ គណៈកម្មការ BPH ដឹកនាំសវនាការពិចារណាការដោះលែង ដើម្បីពិនិត្យលើលទ្ធភាព ដែលអាចដោះលែងពួកគេ។ ឧទាហរណ៍ គណៈកម្មការ BPH នឹងដឹកនាំសវនាការបែបនេះមួយសំរាប់ជនល្មើស លើកទីបី ដែលបានកាត់ទោសពី 25 ឆ្នាំដល់មួយជីវិត បន្ទាប់ពីជន ល្មើសលើកទីបីបានជាប់គុក 25 ឆ្នាំហើយ។ ប្រសិនបើ គណៈកម្មការ BPH សំរេចថាមិនដោះលែងជនល្មើសលើកទីបីនៅឯសវនាការនោះទេ គណៈកម្មការនឹងដឹកនាំសវនាការជាបន្តបន្ទាប់នៅពេលអនាគត។ ដោយសារតែច្បាប់បទល្មើសបីដងបានចូលជាធរមាននៅឆ្នាំ 1994 ជនល្មើសបីដងដំបូងនឹងមានសិទ្ធិចូលសវនាការចំពោះការដោះលែងពីពន្ធនាគារដែលអាចទៅរួចរបស់ពួកគេ នៅជិតដំណាច់ទសវត្សនេះ។

### ការត្រួតពិនិត្យក្រោយការដោះលែង។

គ្រប់ជនប្រព្រឹត្តបទល្មើសពីរដងនិងបីដងទាំងអស់គឺតម្រូវឲ្យគោរពតាមច្បាប់បច្ចុប្បន្ន ដើម្បីឲ្យគេត្រួតពិនិត្យនៅក្នុងសហគមន៍បន្ទាប់ពីដោះ លែងចេញពីពន្ធនាគារ។ ប្រសិនបើការជាប់ទោសថ្មីៗរបស់ជនប្រព្រឹត្ត បទល្មើសទីពីរ គឺជាឧក្រិដ្ឋកម្មមិនធ្ងន់ធ្ងរ អហិង្សា ជាទូទៅគាត់នឹងត្រូវឃ្លាំមើលនៅក្នុងសហគមន៍ដោយមន្ត្រីតាមដានរបស់ខោនធី។ ម្យ៉ាងវិញទៀត ជនប្រព្រឹត្តបទល្មើសទីពីរ នឹងត្រូវឃ្លាំមើលនៅក្នុងសហគមន៍ដោយភ្នាក់ងារឃ្លាំមើលការដោះលែង។ គ្រប់ជនប្រព្រឹត្តបទល្មើសទីបី ត្រូវឃ្លាំមើលនៅក្នុងសហគមន៍ដោយភ្នាក់ងារឃ្លាំមើលការដោះលែង ក្រោយការដោះលែងរបស់ពួកគេ។ នៅពេលជនប្រព្រឹត្តបទល្មើសទីពីរ ឬទីបីរំលោភលក្ខខណ្ឌនៃការឃ្លាំមើលរបស់សហគមន៍ពួកគេ ឬប្រព្រឹត្តបទល្មើសថ្មីមួយទៀត ពួកគេ អាចត្រូវបានដាក់ចូលក្នុងពន្ធនាគារខោនធី ឬពន្ធនាគាររបស់រដ្ឋ អាស្រ័យលើស្ថានការណ៍ជាក់ស្តែង។

## សេចក្តីស្នើច្បាប់

វិធានការនេះកាត់បន្ថយការកាត់ទោសជាប់ពន្ធនាគារ ក្រោមច្បាប់ចែងពីបទល្មើសបីដងដោយជនប្រព្រឹត្តបទល្មើសខុសបីដងជាក់លាក់ ដែលបទល្មើសបច្ចុប្បន្នគឺជាបទឧក្រិដ្ឋមិនធ្ងន់ធ្ងរ និងអហិង្សាវិធានការនេះក៏អនុញ្ញាតឲ្យមានកាត់ទោសជនប្រព្រឹត្តបទល្មើសខុសបីដងជាក់លាក់ណាដែលបច្ចុប្បន្នកំពុងជាប់ទោសអស់មួយជីវិតចំពោះបទឧក្រិដ្ឋមិនធ្ងន់ធ្ងរ និងអហិង្សាដែលបានបញ្ជាក់។ ការផ្លាស់ប្តូរទាំង ពីរនេះត្រូវបានរៀបរាប់ដូចខាងក្រោម

***ការកាត់ទោសកាន់តែខ្លីសំរាប់ជនប្រព្រឹត្តល្មើសបីដង។*** វិធានការនេះទាមទារឲ្យជនល្មើសណាម្នាក់ដែលមានការចោទប្រកាន់បទឧក្រិដ្ឋមិនធ្ងន់ធ្ងរ និង*អហិង្សាពីមុនពីរឬច្រើនជាងនេះ* ហើយដែលជនល្មើស*ថ្មី*របស់ពួកគេគឺជាបទឧក្រិដ្ឋមិនធ្ងន់ធ្ងរ និងអហិង្សា ឲ្យទទួលទោសជាប់គុកដែលមានរយៈពេលពីរដងនៃរយៈពេលធម្មតាសំរាប់បទល្មើសថ្មី ជាជាងការជាប់ទោសអប្បបរមា 25 ឆ្នាំទៅមួយជីវិត ដូចដែលតម្រូវនាពេលបច្ចុប្បន្ននេះ។ ជាឧទាហរណ៍ជនប្រព្រឹត្តបទល្មើសជាលើកទីបីម្នាក់ដែលបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ដែលការកាត់ទោសធម្មតាមានរយៈពេលពីរទៅបួនឆ្នាំ នឹងជំនួសដោយការកាត់ទោសពីរវាងបួនទៅបាំប្រីឆ្នាំវិញ - គឺពីរដង នៃរយៈពេលដែលនឹងអនុវត្តផ្សេងពីនេះជាជាងរយៈពេល 25 ឆ្នាំទៅ មួយជីវិត។

ក៏ប៉ុន្តែ វិធានការនេះផ្តល់ការលើកលែងខ្លះចំពោះការកាត់ទោសខ្លីៗ។ ជាក់ស្តែង ប៉ុន្តែវិធានការនេះតម្រូវថា ប្រសិនបើជនល្មើសបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីៗ ឬបទឧក្រិដ្ឋពីមុនៗជាក់លាក់ រួមមានបទ ឧក្រិដ្ឋខ្លះៗពាក់ព័ន្ធនឹងថ្នាំញៀន ផ្លូវភេទ និងកាំភ្លើង ហើយគាត់នឹងប្រឈមនឹងការកាត់ទោសមួយជីវិតក្រោមច្បាប់ចែងពីបទល្មើសបីដង។

36

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 36, សូមអានទំព័រ 105។*

# សំណើប្រជាមតិ ច្បាប់ប្រព្រឹត្តិល្មើសបីដង។ ទុរជនបទឧក្រិដ្ឋច្រំដែលៗ។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។ 36



## ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

(ត)

***ការកាត់ទោសឡើងវិញលើជនប្រព្រឹត្តបទល្មើសទីបីពេលបច្ចុប្បន្ន។*** វិធានការនេះ អនុញ្ញាតឲ្យជនប្រព្រឹត្តបទល្មើសទីបីពិតប្រាកដអាចដាក់ ពាក្យស្នើសុំធ្វើការកាត់ទោសជាថ្មីទៅតុលាការ។ វិធានការនេះកំរិតលើភាពមានសិទ្ធិទទួលបានការកាត់ទោសជាថ្មីលើជនល្មើសជាលើក ទីបី ដែលបទល្មើសបច្ចុប្បន្នរបស់ពួកគេគមិនធ្ងន់ធ្ងរ និងអហិង្សា ហើយ ដែលពួកគេមិនបានប្រព្រឹត្តបទឧក្រិដ្ឋបច្ចុប្បន្ន និងពីមុនៗដូចដែលបាន បញ្ជាក់ ដូចជា បទឧក្រិដ្ឋទាក់ទងនឹងថ្នាំញៀន ផ្លូវភេទ និងកាំភ្លើង។ តុលាការដឹកនាំសវនាការកាត់ទោសទាំងនេះឡើងវិញ នឹងកំណត់ជា ដំបូង ថាតើប្រវត្តិឧក្រិដ្ឋកម្មរបស់ជនល្មើស ធ្វើឲ្យពួកគេមានសិទ្ធិទទួលបានការកាត់ទោសជាថ្មី។តុលាការអាចត្រូវបានតម្រូវឲ្យធ្វើការកាត់ទោសជនល្មើសដែលមានសិទ្ធិ ដរាបណាវាមិនបានកំណត់ថាការកាត់ទោសឡើងវិញនឹងនាំឲ្យមានគ្រោះថ្នាក់មិនសមហេតុផលដល់សុវត្ថិភាពសាធារណៈ។ ក្នុងការ កំណត់ថាតើជនល្មើសម្នាក់នាំឲ្យមានគ្រោះថ្នាក់ដូច្នោះ តុលាការ អាច ពិចារណាលើភស្តុតាងមួយចំនួនដែលវាអាចបញ្ជាក់ថា ទាក់ទង ដូចជា ប្រវត្តិឧក្រិដ្ឋកម្ម អាកប្បកិរិយាក្នុងពន្ធនាគារ និងការចូលរួមក្នុងកម្មវិធី ស្តារនីតិសម្បទារបស់ជនល្មើស។ វិធានការនេះតម្រូវឲ្យជនល្មើស ដែលបានកាត់ទោសឡើងវិញឲ្យទទួលពីរដងនៃរយៈពេលធម្មតា សំរាប់បទល្មើសចុងក្រោយបំផុតរបស់ពួកគេ ជំនួសឲ្យការកាត់ទោសដែលបានកាត់កាលពីមុន។ ជនល្មើសដែលការស្នើសុំឲ្យមានការកាត់ ទោសជាថ្មីរបស់ពួកគេត្រូវបានបដិសេធដោយតុលាការ  គួរតែបន្តរយៈពេលឃុំឃាំងអស់មួយជីវិតឲ្យពួកគេដូចដែលពួកគេត្រូវបានកាត់ទោសពីដំបូង។

### ឥទ្ធិពលសារពើពន្ធ

***ប្រាក់សន្សំនៃការកែប្រែរបស់រដ្ឋ។*** វិធានការនេះនឹងមានផលប៉ះពាល់ សារពើពន្ធមួយចំនួនលើប្រព័ន្ធកែប្រែរបស់រដ្ឋ។ សំខាន់បំផុត វិធានការនេះ នឹងកាត់បន្ថយការចំណាយលើពន្ធនាគាររបស់រដ្ឋ តាមវិធីពីរយ៉ាង។ ទីមួយ អ្នកជាប់ឃុំតិចទៅនឹងជាប់ពន្ធនាគារចំពោះការ កាត់ទោសមួយជីវិត នៅក្រោមច្បាប់ប្រព្រឹត្តបទល្មើសបីដង ដោយសារតែខចែងរបស់វិធានការនេះទាមទារឲ្យការកាត់ទោសដូច្នោះ ត្រូវអនុវត្តតែចំពោះជនល្មើសប្រព្រឹត្តបីដង ដែលបទល្មើសបច្ចុប្បន្ន របស់ពួកគាត់គឺធ្ងន់ធ្ងរ ឬហិង្សា។ វិធីនេះនឹងបន្ថយការកាត់ទោសលើ ជនល្មើសខាងបទឧក្រិដ្ឋខ្លះៗក្នុង ពេលអនាគត។ ទីពីរការកាត់ទោសជាថ្មីលើជនប្រព្រឹត្តបទល្មើសបីដងអាចផ្តល់លទ្ធផលឲ្យមានជនជាប់ឃុំដែលមានស្រាប់ជាច្រើនទទួលបាននូវការជាប់ពន្ធនាគារយៈពេលខ្លី។ វិធីនេះ នឹងផ្តល់លទ្ធផលឲ្យមានការកាត់បន្ថយចំនួនអ្នកជាប់ឃុំដោយចាប់ផ្តើមក្នុងរយៈពេលឆាប់ៗនេះ។

វិធានការនេះ ក៏នឹងផ្តល់លទ្ធផលឲ្យមានការបន្ថយការចំណាយលើការដោះលែងរបស់រដ្ឋ។  វិធីនេះ នឹងកើតឡើងពីព្រោះជនល្មើស ដែលប៉ះពាល់ដោយវិធានការនេះ ជាទូទៅនឹងត្រូវឃ្លាំមើលដោយការ ត្រួតពិនិត្យសាកល្បងរបស់ខោនធី - ជាជាងការដោះលែងដែលមាន លក្ខខណ្ឌរបស់រដ្ឋ-បន្ទាប់ពីការដោះលែងចេញពីគុករបស់ពួកគេ។ នេះក៏ព្រោះបទល្មើសបច្ចុប្បន្នរបស់ពួកគេគឺមិនធ្ងន់ធ្ងរនិងអហិង្សា។ បន្ថែមលើសនេះទៀតការកាត់បន្ថយចំនួនអ្នកប្រព្រឹត្តបទល្មើសបីដង នឹងបន្ថយចំនួនសវនាការពិចារណាការដោះលែងដែលមានលក្ខខណ្ឌ ដែលគណៈកម្មការ BPH នឹងត្រូវការដើម្បីរៀបចំទៀតក្នុងពេល អនាគត។

ប្រាក់សន្សំនៃការកែប្រែរបស់រដ្ឋដែលបានមកពីការផ្លាស់ប្តូរខាងលើ នឹងមានចំនួនប្រហែល $70 លានដុល្លារជារៀងរាល់ឆ្នាំជាមួយការសន្សំកាន់តែខ្ពស់ - អាចដល់ $90 លានដុល្លារជារៀងរាល់ឆ្នាំ - ក្នុងរយៈកាលពីរបីទសវត្សទៀត។។ ទោះជាយ៉ាងនេះក្តី ការសន្សំជារៀងរាល់ឆ្នាំទាំងនេះអាចទឹកប្រាក់រាប់សិបលានដុល្លារ គឺខ្ពស់ជាង ឬទាបជាង អាស្រ័យលើកត្តាជាច្រើន។ ជាពិសេស កំរិតជាក់ស្តែងនៃការសន្សំ នឹងអាស្រ័យលើចំនួននៃជន ល្មើសបីដងដែលត្រូវបានកាត់ទោសជាថ្មីដោយតុលាការ និងកំរិត ដែលគណៈកម្មការ BPH នឹងគួរត្រូវបានដោះលែងជន ប្រព្រឹត្តបទល្មើសបីដង នៅពេលអនាគតក្រោមច្បាប់បច្ចុប្បន្ន។

***ការចំណាយលើការកាត់ទោសជាថ្មី។*** វិធានការនេះនឹងផ្តល់លទ្ធផលឲ្យមានការចំណាយមួយពេលចំពោះរដ្ឋនិងខោនធីដែលទាក់ទងនឹងខចែងនៃការកាត់ទោសឡើងវិញរបស់វិធានការនេះ។ខចែងទាំងនេះនឹងបង្កើនចំនួនករណីបណ្តឹង ដែលជាលទ្ធផលអាចនឹងនាំឲ្យមានការចំណាយបន្ថែមសំរាប់មេធាវីតំបន់ អ្នកការពារ សាធារណៈ និងនាយកដ្ឋានតម្រួតខោនធី ដែលនឹងចាត់ចែងបន្ទុក ការងារ និងបែងចែកបុគ្គលិកសំរាប់នីតិវិធីការកាត់ទោសឡើងវិញទាំងនេះ។ បន្ថែមលើសនេះ ខោនធីនឹងធ្វើឲ្យមានការចំណាយលើពន្ធនាគារដើម្បីផ្តល់កន្លែងស្នាក់នៅសំរាប់អ្នកជាប់ឃុំក្នុងពេលដំណើរ ការការកាត់ទោសឡើងវិញ។ ការចំណាយទាំងនេះអាចមានចំនួនពីរបីលានដុល្លារទូទាំងរដ្ឋក្នុងរយៈពេលពីរបីឆ្នាំ។

សំណើប្រជាមតិ **36** ច្បាប់ប្រព្រឹត្តិល្មើសបីដង។ ទុរជនបទឧក្រិដ្ឋច្រំដែលៗ។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** **(ត)**

***ការប៉ះពាល់សារពើពន្ធផ្សេងទៀត*** នឹងមានការចំណាយបន្ថែមខ្លះទាក់ទងនឹងតុលាការ ការអង្កេត សាកល្បង និងពន្ធនាគារ សំរាប់រដ្ឋនិងខោនធី។ នេះដោយសារតែ ជនល្មើសខ្លះត្រូវបានដោះលែងពីពន្ធនាគារដោយសារតែវិធានការនេះនឹងត្រូវបានឃ្លាំមើលដោយនាយកដ្ឋានអង្កេតសាកល្បង ជំនួសឲ្យការដោះលែងមានលក្ខខណ្ឌរបស់រដ្ឋ ហើយនឹងមានសវនាការ តុលាការ និងទទួលការកាត់ទោសឲ្យជាប់ពន្ធនាគារ ប្រសិនបើពួកគេរំលោភលើលក្ខខណ្ឌនៃការឃ្លាំមើល ឬប្រព្រឹត្តបទល្មើសថ្មីៗ។ យើងធ្វើការប៉ាន់ស្មានថាការចំណាយរយៈពេលវែងបែបនេះ គឺមិនមានច្រើនទេ។

វិធានការនេះនឹងផ្តល់ជាលទ្ធផលនូវភាពចំរុះនៃផលប៉ះពាល់ សារពើពន្ធលើរដ្ឋាភិបាលរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន។ ឧទាហរណ៍ រដ្ឋាភិបាលនឹងធ្វើឲ្យមានការចំណាយបន្ថែមរហូតដល់ កំរិតដែលជនល្មើសបានដោះលែងពីពន្ធនាគារ ដោយសារតែវិធានការ នេះទាម ទារឲ្យមាននូវសេវារដ្ឋាភិបាល (ដូចជា ការថែទាំសុខភាព ដែល បង់ដោយរដ្ឋាភិបាល សំរាប់បុគ្គលទាំងឡាយណាដែលគ្មានការ គ្របដណ្តប់ធានារ៉ាប់រងឯកជន) ឬប្រព្រឹត្តបទល្មើសបន្ថែមទៀត។ វាក៏នឹងមានផងដែរនូវប្រាក់ចំណូលរដ្ឋាភិបាលរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានបន្ថែមខ្លះទៀត រហូតដល់កំរិតដែលជនល្មើសទាំងបានដោះលែងពីពន្ធនាគារ ដោយសារតែវិធានការនេះបានចូលជាធរមាន។ ទំហំនៃផលប៉ះពាល់គឺគ្មាននរណាដឹងទេ។

36

## ★ ទទ្បហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 36 ★

ច្បាប់កំណែទម្រង់ពីបទល្មើសបីដង(សំណើប្រជាមតិ36 ត្រូវបានគាំទ្រដោយសម្ព័ន្ធទ្វេគាគីដ៏ទូលាយនៃមេដឹកនាំអនុវត្តច្បាប់ អង្គការសិទ្ធមនុស្ស និងអ្នកគាំទ្រអ្នកបង់ពន្ធព្រោះច្បាប់កែទម្រង់ថ្មីនេះនឹង៖

- ធ្វើការផាកពិន័យអោយសមនឹងបទឧក្រិដ្ឋ

ធនធានដែលមានតម្លៃខាងហិរញ្ញវត្ថុ និងខាងអនុវត្តច្បាប់មិនគួរបង្ហៃរដោយមិនសមរម្យ ក្នុងការដាក់ទោសមួយជីវិតទៅលើបទល្មើសដោយអហិង្សាមួយចំនួនខ្លះ។ សំណើប្រជាមតិ36នឹងធានាថាអ្នកប្រព្រឹត្តបទល្មើសហិង្សាដដែលៗ គឺត្រូវបានផាកពិន័យនិងមិនដោះលែងមុនពេលកំណត់ឡើយ។

- ជួយសន្សំរដ្ឋកាលីហ្វ័រញ៉ាច្រើនជាង $100 លានដុល្លារជារៀងរាល់ឆ្នាំ

អ្នកបង់ពន្ធអាចសន្សំប្រាក់ច្រើនជាង $100 លានដុល្លារក្នុងមួយឆ្នាំ - ប្រាក់ដែលអាចយកទៅប្រើដើម្បីផ្តត់ផ្គង់ថវិកាដល់សាលារៀន ប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្ម និងកាត់បន្ថយឱនភាពរបស់រដ្ឋ។ ច្បាប់ចែងពីបទល្មើសបីដងនេះនឹងបន្តធ្វើការដាក់ទោសដល់ឧក្រិដ្ឋជនដែលជាមុខរបរដែលមានគ្រោះថ្នាក់ ដែលប្រព្រឹត្តបទល្មើសហិង្សាធ្ងន់ធ្ងរ - ដោយកំចាត់ពួកគេចេញ ក្នុងរយៈពេល 25 ឆ្នាំ ទៅមួយជីវិត។

- រៀបចំបន្ទប់ក្នុងគុកសំរាប់ឧក្រិដ្ឋជនដ៏ឃោរឃៅ

សំណើ 36នឹងជួយបញ្ឈប់ឲ្យមានការកកស្ទះដល់ពន្ធនាគារ ដែលចង្អៀតណែនដោយអ្នកប្រព្រឹត្តបទល្មើសអហិង្សា ដូច្នេះយើងនឹងមានបន្ទប់សំរាប់ឃុំឃាំងឧក្រិដ្ឋជនដ៏ឃោឃៅចេញពីផ្លូវ។

- ការគាំទ្រការអនុវត្តច្បាប់

ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីប៉ូលីសគាំទ្រសំណើប្រជាមតិ 36 ពីព្រោះសំណើប្រជាមតិ 36 ជួយធានាថាពន្ធនាគារអាចទុកឧក្រិដ្ឋជនឃោរឃៅឲ្យនៅក្នុងការឃុំឃាំងរយៈពេលមួយជីវិត។ សំណើប្រជាមតិ 36 នឹងឃុំឃាំងឧក្រិដ្ឋជនឃោរឃៅចេញពីផ្លូវ។

- ការគាំទ្រអ្នកបង់ពន្ធ

សំណើប្រជាមតិ 36 អាចសន្សំបាន $100 លានដុល្លារជារៀងរាល់ឆ្នាំ។ ប្រធាននៃជនជាតិអាមេរិកាំងសំរាប់កំណែ ទម្រង់ពន្ធ លោក Grover Norquist និយាយថា "ច្បាប់កែទម្រង់ពីបទល្មើសបីដង មានភាពតឹងតែងលើឧក្រិដ្ឋកម្ម ដោយគ្មានភាពតឹងតែងលើអ្នកបង់ពន្ធទេ។ ច្បាប់នេះនឹងបញ្ឈប់ការខ្ជះខ្ជាយប្រាក់រាប់រយលានដុល្លាដោយមិនចាំបាច់ នៃប្រាក់ចំណូលដែលរកបានយ៉ាងលំបាកពីអ្នកជាប់បង់ពន្ធ ក្នុងកំឡុងពេលការពារប្រជាជនពីឧក្រិដ្ឋកម្មដោយហិង្សា។" អ្នកត្រួតពិនិត្យនៃរដ្ឋការលីហ្វ័រញ៉ាបានប៉ាន់ប្រមាណថា អ្នកបង់ ពន្ធនឹងចំណាយប្រាក់រាប់លានដុល្លាលើផ្ទះនិងចំណាយលើការ ថៃរក្សាសុខភាពសំរាប់មនុស្សអ្នកដេកគុកប្រព្រឹត្តបទល្មើសបីដងដោយអហិង្សាប្រសិនបើច្បាប់នោះមិនទាន់ត្រូវបានផ្លាស់ប្តូរនោះ។ សំណើ 36 នឹងជួយសន្សំប្រាក់របស់អ្នកបង់ពន្ធ។

- តឹងតែងនិងឆ្លាសវ៉ៃ លើឧក្រិដ្ឋកម្ម

អ្នកជំនាញយុត្តិធម៌ខាង ឧក្រិដ្ឋកម្ម និងមេដឹកនាំមានសមត្ថកិច្ចធ្វើការយ៉ាងប្រុងប្រយ័ត្នលើសំណើ 36 ដើម្បីឲ្យឧក្រិដ្ឋជនដែលមានគ្រោះថ្នាក់ពិតបាក្រដ នឹងមិនទទួលបាន នូវអត្ថប្រយោជន៏អ្វីពីកំណែទំរង់ ឡើយ។ ឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀតនឹងរស់នៅក្នុងពន្ធនាគារចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ រឺបទឧក្រិដ្ឋបីដងដែលហិង្សា។ អ្នកប្រព្រឹត្តបទល្មើសអហិង្សាម្តងហើយម្តងទៀតនឹងទទួលការកាត់ទោសលើសពីទ្វេដងនៃកំហុសធម្មតា។គ្រប់ជនចុងចោទដែលធ្លាប់បានផ្តន្ទាទោសពីបទឧក្រិដ្ឋ ហិង្សាខ្លាំងបំផុត- ដូចជា អំពើចាប់រំលោភ ឃាតកម្ម ឬការរំលោភ បៀតបៀនកុមារ- នឹងទទួលការកាត់ទោស 25 ឆ្នាំ ទៅមួយជីវិត ទោះបីបទល្មើសបីដងនោះមានសភាពតិចតួចប៉ុណ្ណាក៏ដោយ។

*ចូលរួមជាមួយយើង*

ជាមួយនឹងសារនៃសំណើប្រជាមតិ លេខ 36, រដ្ឋកាលីហ្វ័រញ៉ា និងរក្សាទុកសកម្មជនដែលម័តធ្យ័តបំផុត។ ច្បាប់ស្តីពីបទល្មើសបីដងនៅក្នុងប្រទេស តែវានឹងមានភាពស្មើគ្នាជាងដោយការសង្កត់នូវសមាមាត្រក្នុងការកាត់ក្តី ហើយនឹងផ្តល់ពាក្យសុំហុចដោយដៃផ្ទាល់នៃច្បាប់ដ៏សំខាន់នេះ។

សូមចូលរួមជាមួយយើងដោយការបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 36។ ស្វែងយល់ថែមទៀតនៅឯ *www.FixThreeStrikes.org*

**STEVE COOLEY**, មេធាវីមណ្ឌល
ខោនធី Los Angeles
**GEORGE GASCON**, មេធាវីមណ្ឌល
ក្រុង San Francisco និងខោនធី
**DAVID MILLS**, សាស្ត្រាចារ្យ
សាលាច្បាប់ Stanford



## ★ ការឆ្លើយបដិសេធលើទទ្បហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 36 ★

ខាងក្រោមនេះគឺអ្វីដែលអ្នកគាំទ្រសំណើប្រជាមតិ លេខ 36 ដែលគេមិនប្រាប់អ្នក ៖

- ខចែងដែលលាក់បាំងក្នុងសំណើ 36 នឹងអនុញ្ញាត្តិឲ្យ ឧក្រិដ្ឋជនដ៏មានគ្រោះថ្នាក់រាប់ពាន់នាក់ដែលទទួលការកាត់ទោសអោយជាប់ពន្ធនាគាររបស់ខ្លួនឲ្យត្រូវបន្ធូរបន្ថយការ ហើយបន្ទាប់មកត្រូវដោះលែងពីពន្ធនាគារមុនពេលកំណត់។ យោងតាម Fresno Bee បានឲ្យ ដឹងថា៖

*"ប្រសិនបើសំណើ 36 យល់ព្រមអនុម័ត ជនឧក្រិដ្ឋប្រហែល 3,000 នាក់ ដែលជាប់ទោសអស់មួយជីវិតនៅក្រោមច្បាប់បទល្មើសបីដង អាចដាក់ញត្តិដើម្បីសុំកាត់បន្ថយការជាប់ទោស។..."*

- អ្នកខ្លះនៃអ្នកទោសដ៏គ្រោះថ្នាក់ទាំងនេះ នឹងត្រូវបានដោះលែងដោយគ្មានលក្ខខណ្ឌមុនកំណត់ដែលត្រូវដោះលែង រឺគ្មានការឃ្លាំមើលពីអាជ្ញាធរមានសមត្ថកិច្ច។ យោងទៅតាម អ្នកវិភាគអង្គនីតិបញ្ញត្តិ ឯករាជ្យបានឲ្យដឹងថា៖

*អ្នកជាប់ទោសជាលើកទីបី ដែលជាអ្នកត្រូវបានកាត់ទោសម្តងទៀត ក្រោម វិធានការនេះនឹងក្លាយជាការស្របច្បាប់ សំរាប់ការឃ្លាំមើល ពីសហគមន៍ខោនធី នៅពេលមានការដោះលែងពីពន្ធនាគារ ជាជាងការដោះលែងអោយនៅក្រៅឃុំដោយមានលក្ខខ័ណ្ឌ...អ្នកកខ្លះអាចនឹងត្រូវបានដោះលែងពីពន្ធនាគាដោយគ្មានការឃ្លាំមើលពីសហគមន៍ឡើយ។"*

- សំណើប្រជាមតិ 36សរុបទៅគឺមិនចាំបាច់ទេ។ រដ្ឋអាជ្ញា និងចៅក្រមមានអំណាចរួចជាស្រេចដើម្បីអនុវត្តច្បាប់ ចែងបទល្មើសបីដងយ៉ាងយុត្តិធម៌។ នេះជាសំដីរបស់ប្រធានសមាគមមេធាវីក្នុងតំបន់ ៖

*"ចៅក្រមនិងរដ្ឋអាជ្ញាមិនត្រូវការសំណើប្រជាមតិលេខ 36។ តាមពិតទៅវាបន្ថយនូវសមត្ថភាពរបស់យើងក្នុងការប្រើបទល្មើសបីដងដើម្បីសំដៅទៅរកជនប្រព្រឹត្តបទល្មើសច្រំដែលៗដ៏គ្រោះថ្នាក់ ហើយយកគេចេញពីផ្លូវតែម្តងគឺឱ្យអស់។"*

- សំណើប្រជាមតិ 36 ត្រូវបានជំទាស់ដោយអង្គការអាជ្ញាធរមានសមត្ថកិច្ចធំៗនិងក្រុមសិទ្ធិរបស់អ្នករងគ្រោះ។ រួមទាំងពួកអ្នកតំណាងមេប៉ូលិសកាលីហ្វ័រញ៉ា, តម្រួតតំបន់, រដ្ឋអាជ្ញា, និងភ្នាក់ងារប៉ូលិសជាច្រើនទៀត។ សូមកត់ចំណាំ អ្នកគាំទ្រសំណើប្រជាមតិ 36 មិនអាចរកឈ្មោះអង្គការអាជ្ញាធរមានសមត្ថកិច្ចមួយនៅជាមួយគេក៏មិនបានផង!
- សំណើប្រជាមតិ 36 មិនបន្ថយពន្ធដារទេ។ រដ្ឋាភិបាលមិនបានចំណាយប្រាក់ច្រើនសំរាប់ប្រយុទ្ធនឹងឧក្រិដ្ឋកម្មទេ។ គេចំណាយតិចណាស់។ ឧក្រិដ្ឋកម្មច្រើនអស់ថ្លៃសំរាប់អ្នកជាប់ពន្ធផងដែរ!

យើងជំរុញឱ្យអ្នក រក្សាទុកច្បាប់ស្តីពីបទល្មើសបីដង។ សូមបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 36.

**CHIEF RICK BRAZIEL**, ប្រធាន
សមាគមមន្ត្រីសន្តិភាពកាលីហ្វ័រញ៉ា
**HENRY T. NICHOLAS, III, Ph.D.**, អ្នកនិព្ធ
កម្រងសិទ្ធិអ្នករងគ្រោះកាលីហ្វ័រញ៉ា
**CHRISTINE WARD**, នាយកប្រតិបត្តិ
សម្ព័ន្ធសកម្មភាពអ្នករងគ្រោះឧក្រិដ្ឋកម្ម


*ទទ្បហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 36 ★

ក្នុងឆ្នាំ1994 អ្នកបោះឆ្នោតបានយល់ព្រមអនុម័តយ៉ាងលើសលុប លើច្បាប់ចែងពីបទល្មើសបីដង -ជាច្បាប់ដែលបានបង្កើនការកាត់ទោសដាក់គុកសំរាប់ឧក្រិដ្ឋជនប្រព្រឹត្តម្តងហើយម្តងទៀត។ ហើយវាបានដំណើរការ!ស្ទើរតែភ្លាមៗនោះអត្រាឧក្រិដ្ឋកម្មក្នុងរដ្ឋ របស់យើងបានធ្លាក់ចុះយ៉ាងខ្លាំង និងស្ថិតនៅកំរិតទាប ទោះបីជានៅក្នុងស្ថានភាពធ្លាក់ចុះខាងសេដ្ឋកិច្ចនាបច្ចុប្បន្ន។ ហេតុផលគឺសាមញ្ញបំផុត។ ឧក្រិដ្ឋជនដូចគ្នាបានកំពុងប្រព្រឹត្តបទល្មើស ស្ទើរគ្រប់បទល្មើសទាំងអស់ - ឆ្លងកាត់តាមតុលាការ និងពន្ធនាគារបស់ យើង- ម្តងហើយម្តងទៀត។ អ្នកបោះឆ្នោតបាននិយាយគ្រប់គ្រាន់ហើយ - ប្រព្រឹត្តបទល្មើសបីដង អ្នកឯងចេញទៅភ្លាម!

ក្នុងឆ្នាំ2004 ACLU និងអ្នកប្រឆាំងច្បាប់ឧក្រិដ្ឋកម្មដ៏តឹងតែងផ្សេងទៀតបានព្យាយាមប្តូរច្បាប់បទល្មើសបីដងនេះ។ តែអ្នកបោះឆ្នោតបាននិយាយថា ទេ។ ឥឡូវពួកគេត្រលប់មកម្តងទៀតជាមួយសំណើប្រជាមតិ 36។ ពួកគេមិនអាចបំភ័ន្តយើងពីមុន ហើយក៏មិនអាចបំភ័ន្តយើងនាពេលនេះបានឡើយ។

ដូចពីមុន សំណើប្រជាមតិ 36 អនុញ្ញាត្តិឲ្យឧក្រិដ្ឋជនដ៏គ្រោះថ្នាក់ដែលទទួលការកាត់ទោសឲ្យជាប់គុកនោះបានត្រូវបន្ថយហើយបន្ទាប់មកដោះលែងពីពន្ធនាគារវិញ!
តើសំណើប្រជាមតិ 36 សំដៅទៅនរណា?

- ឧក្រិដ្ឋជនដែលពិតជាមានគ្រោះថ្នាក់ដល់សង្គមដែលមេធាវីក្នុងស្រុកជ្រើសរើសដើម្បីចោទប្រកាន់ពួកគេជាមួយការប្រព្រឹត្តបទល្មើសបីដង។
- ឧក្រិដ្ឋជនដែលពិតជាមានភាពគ្រោះថ្នាក់ ដែលចៅក្រមបានយល់ព្រមជាមួយការសំរេចចិត្តចោទប្រកាន់របស់ DA:
- ឧក្រិដ្ឋជនដ៏គ្រោះដែលក្រុមប្រឹក្សាតុលាការបានកាត់ទោសពួកគេលើបទល្មើសនោះ។
- ឧក្រិដ្ឋជនដែលពិតជាមានភាពគ្រោះថ្នាក់ ដែលចៅក្រមបង្គំ ឲ្យមានការកាត់ទោសដាក់គុក25ឆ្នាំទៅមួយជីវិត និង
- ឧក្រិដ្ឋជនដែលបណ្តឹងឧទ្ធរណ៍ផ្អែកច្បាប់របស់ពួកគេត្រូវបានបដិសេធ។

បន្ទាប់ពីនេះមក សំណើប្រជាមតិ 36នឹង អនុញ្ញាតឲ្យឧក្រិដ្ឋជនដូចគ្នាទាំងនោះស្នើសុំ តុលាការផ្សេងទៀត ឲ្យដោះលែងពួកគេ។ នៅមិនទាន់អាក្រក់ពេកទេ អ្នកខ្លះនៃឧក្រិដ្ឋជនទាំងនេះ នឹងត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយគ្មានលក្ខខ័ណ្ឌមុនកំណត់ដែលត្រូវដោះលែង ឬ គ្មានការឃ្លាំមើលណាមួយឡើយ!

នេះជាអ្វីដែលអ្នកវិភាគខាងអង្គនីតិបញ្ញត្តិឯករាជ្យនិយាយអំពីការដោះលែងអ្នកជាប់គុកមុនពេលកំណត់ ក្រោមសំណើប្រជាមតិ 36៖ *"មួយចំនួននៃអ្នកជាប់គុកទាំងនោះអាចត្រូវបានដោះលែងពីពន្ធនាគារដោយគ្មានការឃ្លាំមើលពីសហគមន៍។"*

គ្មានការងឿងឆ្ងល់ឡើយដែលសំណើប្រជាមតិ 36 នេះត្រូវបានជំទាស់ដោយមន្ត្រីប៉ូលីស តម្រួត និងក្រុមអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋកាលីហ្វ័រញ៉ា រួមមានៈ

សមាគមប្រធានប៉ូលីសរដ្ឋកាលីហ្វ័រញ៉ាផងដែរ។
សមាគមតម្រួតតំបន់រដ្ឋកាលីហ្វ័រញ៉ា
សមាគមមេធាវីមណ្ឌលកាលីហ្វ័រញ៉ា
សមាគមមន្ត្រីស្រាវជ្រាវសន្តិភាពនៃរដ្ឋកាលីហ្វ័រញ៉ា
សម្ព័ន្ធការពារប៉ូលីស Los Angeles

តើអ្នកគិតថាឧក្រិដ្ឋជនក្បាលរឹងដែលត្រូវបានដោះលែងថ្មីៗនិងប្រព្រឹត្តបទល្មើសនៅពេលពួកគេចេញពីគុកទៀតទេ? យើងដឹងចំលើយជាស្រេចថា៖ ពួកគេនឹងព្រឹត្តបទល្មើសច្រើនទៀត បង្កគ្រោះថ្នាក់ ឬសំលាប់ជនរង គ្រោះស្លូតត្រង់ និងបំផុតទៅគឺត្រូវត្រលប់ចូលកន្លែងពួកគេរស់នៅសព្វថ្ងៃ - ចូលក្នុងពន្ធនាគារវិញដដែល។ ទង្វើទាំងនេះនឹងធ្វើឲ្យមានការចំណាយ លើអ្នកបង់ពន្ធច្រើនជាងឃុំឃាំងឧក្រិដ្ឋជននៅកន្លែងដែលពួកគេគួរនៅ។

គ្មានអ្វីគួរឱ្យងឿងឆ្ងល់សំណើប្រជាមតិ 36 ត្រូវបានជំទាស់ដោយក្រុមសិទ្ធិអ្នករងគ្រោះ។ រួមមាន ៖

សហជនរងគ្រោះដោយឧក្រឹដ្ឋកម្មនៃរដ្ឋកាលីហ្វ័រញ៉ា
សម្ព័ន្ធសកម្មភាពជនរងគ្រោះដោយអំពើឧក្រឹដ្ឋកម្ម
ពលរដ្ឋប្រឆាំងនឹងឃាតកម្ម
មូលនិធិស្របច្បាប់សំរាប់យុត្តិធម៌ឧក្រឹដ្ឋកម្ម

នៅពេលដែលច្បាប់បទល្មើសបីដងត្រូវបានអនុម័តដោយអ្នកបោះឆ្នោត អ្នកខ្លះគិតថាវាប្រហែលជាសាហាវឃោឃៅ និងចំណាយច្រើនពេក ណាស់។ អ្នកបោះឆ្នោតបានបដិសេធនូវគំនិតនេះក្នុងឆ្នាំ2004។ ប៉ុន្តែសូម្បីតែខ្លួនអ្នកជឿថាច្បាប់ចែងពីបទល្មើសបីដងគួរតែធ្វើកំណែទំរង់ឡើងវិញ សំណើប្រជាមតិ 36គឺមិនមែនជាចំលើយនោះទេ។ រាល់ការផ្លាស់ប្តូរលើច្បាប់កាត់ទោសគួរស្នើតម្រូវសំរាប់តែឧក្រិដ្ឋកម្មនៅពេលអនាគតដែលបានប្រព្រឹត្ត - វាមិនគួរអនុវត្តសំរាប់តែឧក្រិដ្ឋជនដែល ជាប់ឃុំឃាំងរួចហើយនោះទេ - ដោយកាត់បន្ថយការជាប់ទោសរបស់ ពួកគេឲ្យខ្លី។ វាហាក់ដូចជាមិនយុត្តិធម៌ចំពោះជនរងគ្រោះនៃឧក្រិដ្ឋកម្មដើម្បីរស់ក្នុងការឈឺចាប់នៃការកាត់សេចក្តីឡើងវិញ និងការដោះលែងឧក្រិដ្ឋជនជនដ៏គ្រោះថ្នាក់ទាំងនេះមុនពេលកំណត់។ ពួកយើងស្នើសុំអ្នកអស់ពីចិត្ត សូមបោះឆ្នោត ទេ លើសំណើប្រជាមតិ 36។

*www.save3strikes.com*

**SHERIFF KEITH ROYAL**, ប្រធាន
សមាគមតម្រួតតំបន់រដ្ឋកាលីហ្វ័រញ៉ា
**DISTRICT ATTORNEY CARL ADAMS,** ប្រធាន
សមាគមមេធាវីមណ្ឌលកាលីហ្វ័រញ៉ា
**HARRIET SALERNO**, ប្រធាន
សហភាពជនរងគ្រោះឧក្រឹដ្ឋកម្មកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 36 ★

កុំជឿល្បិចកលបំភ័យដែលប្រើដោយពួកជំទាស់នឹងសំណើប្រជាមតិលេខ 36។ ខាងក្រោមនេះជាហេតុការពិត ៖

- សំណើប្រជាមតិលេខ 36 តំរូវឱ្យឃាតករ, អ្នករំលោភគេ, អ្នករំលោភបំពានកុមារ, និងឧក្រឹដ្ឋជនគ្រោះថ្នាក់ដ៏ទៃទៀត*ជាប់ទោសតាមការកំណត់របស់គេ។*
- សំណើប្រជាមតិលេខ 36 *សន្សំប្រាក់ឱ្យអ្នកជាប់ពន្ធរាប់រយលានដុល្លារ។*
- សំណើប្រជាមតិលេខ 36 *នៅតែដាក់ទណ្ឌកម្មដល់ជនប្រព្រឹត្តបទល្មើសច្រំដែលៗ*នៃអំពើឧក្រឹដ្ឋអហឹង្សាដោយការឱ្យកាត់ជាប់ទោសស្ទួនក្នុងពន្ធធនាគាររដ្ឋ។

សព្វថ្ងៃនេះ ឧក្រឹដ្ឋជនគ្រោះថ្នាក់ត្រូវបានបញ្ចេញពីពន្ធធនាគារឆាប់ពីព្រោះគុកចង្អៀត ដោយជនប្រព្រឹត្តបទល្មើសអហិង្សាដែលពុំបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សាធារណជនឡើយ។ សំណើប្រជាមតិលេខ 36 ការពារមិនឱ្យឧក្រឹដ្ឋជនគ្រោះថ្នាក់ដោះលែងឆាប់បានទេ។ មនុស្សដែលត្រូវជាប់ទោសពីការលួចរបស់តាមផ្សារដូចជាស្រោមជើងមួយគូ, លួចនំបុ័ង ឬទឹកដោះហ្វ័រមូឡាសំរាប់ទារកពុំសមនឹងទទួលការជាប់ទោសមួយជីវិតឡើយ។

សំណើប្រជាមតិលេខ 36 គឺត្រូវបានគាំទ្រដោយប្រធានអាជ្ញាធរមានសមត្ថកិច្ច រួមទាំង ៖

- Steve Cooley, មេធាវីមណ្ឌល នៃខោនធី Los Angeles
- Jeffrey Rosen, មេធាវីមណ្ឌល នៃខោនធី Santa Clara
- George Gascon, មេធាវីមណ្ឌល នៃក្រុង San Francisco និងខោនធី
- Charlie Beck, មេបញ្ជាការប៉ូលិស ក្រុង Los Angeles

ពួកគេដឹងថា សំណើប្រជាមតិលេខ 36:

- *តំរូវ ៖* កាត់ទោសមួយជីវិតសំរាប់ឧក្រឹដ្ឋជនគ្រោះថ្នាក់ដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ និងហឹង្សា។
- *ដាក់ទណ្ឌកម្មសមនឹងអំពើបានប្រព្រឹត្ត ៖* ឈប់ខ្ជះខ្ជាយធនធានប៉ូលិស និងធនធានគុកដ៏មានតំលៃសំរាប់ជនប្រព្រឹត្តបទល្មើសអហិង្សា។
- សន្សំបានលើសពី *$100 លានដុល្លារ រៀងរាល់ឆ្នាំ។*

**STEVE COOLEY,** មេធាវីមណ្ឌល
ខោនធី Los Angeles
**JEFFREY F. ROSEN,** មេធាវីមណ្ឌល
ខោនធី Santa Clara
**CHARLIE BECK**
មេបញ្ជាការប៉ូលិសក្រុង Los Angeles

សំណើប្រជាមតិ **37**

# អាហារដែលបានបំភ្លែពូជ។ ការដាក់ស្លាក។ លក្ខន្តិកៈផ្តួចផ្តើម។

**ចំណងជើងជាផ្លូវការ និងសេចក្តីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

## អាហារដែលបានបំភ្លែពូជ។ ការដាក់ស្លាក។ លក្ខន្តិកៈផ្តួចផ្តើម។

- ជំរុំឲ្យមានការដាក់ស្លាកអាហារឆៅ ឬបានធ្វើ សំរាប់លក់ទៅឲ្យអតិថិជន បើសិនបានធ្វើមកពីដំណាំ ឬសត្វ ដែលបានផ្លាស់ប្តូរសំភារៈសំគាល់ពូជក្នុងរបៀបណាមួយ។
- ហាមឃាត់ការដាក់ស្លាក ឬការផ្សាយលក់នូវអាហារបែបនោះ ឬអាហារបានធ្វើ ថាជា "ធម្មជាតិ"។
- អាហារដែលលើកលែងគឺ : សរីរូបធាតុបានបញ្ជាក់; បានផលិតដោយអចេតនា ដោយមានសំភារៈដែលបំភ្លែពូជ; បានធ្វើមកពីសត្វដោយបំបៅចំណី ឬបានចាក់សំភាៈដែលបំភ្លែពូជ ប៉ុន្តែមិនបានបំភ្លែពូជរបស់វាទេ; បានធ្វើដោយមាន ឬមានចំនួនតិចតួច នៃគ្រឿងផ្សំបានបំភ្លែពូជ; បានចាក់ថ្នាំសំរាប់ព្យាបាលលក្ខណៈសុខភាព; បានលក់សំរាប់ប្រើប្រាស់ ភ្លាមៗ ដូចជានៅភោជនីយដ្ឋាន; ឬគេសជ្ជៈស្រវឹង។

### សេចក្តីសង្ខេបនៃអ្នកវិភាគនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ៖

- ការចំណាយរបស់រដ្ឋកើនឡើង ចាប់តាំងពី ពីរបីរយពាន់ដុល្លារ រហូតដល់ទៅជាង $1 លាន ដើម្បីដាក់បញ្ញត្តិការដាក់ស្លាក នៃអាហារដែលបំភ្លែពូជ។
- អាចនឹងមាន ប៉ុន្តែប្រហែលមិនខ្លាំងក្លាទេ ការចំណាយរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ដោយព្រោះកិច្ចការខាងច្បាប់ ដែលបណ្តាលមកពីការប្រព្រឹត្តិល្មើសដែលអាចមាន នូវសេចក្តីជំរុំនៃវិធានការនេះ។ ការចំណាយទាំងនេះនឹងបានគាំទ្រ ដោយថ្លៃឈ្នួលការប្តឹងតុលាការ ដែលភាគីជាប់ពាក់ព័ន្ធនៅក្នុងករណីច្បាប់និមួយៗ នឹងបានជំរុំឲ្យបង់ប្រាក់ នៅក្រោម ច្បាប់ជាធរមាន។

---

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### សាវតារ

***ចំណីអាហារដែលបានបំភ្លែពូជ (GE)។*** វិស្វកម្មពន្ធុគឺជាដំណើរការកែប្រែសារធាតុពន្ធុរបស់សរីរៈមានជីវិតដើម្បីបង្កើតឲ្យមានការផ្លាស់ប្តូរមួយចំនួនតាមការចង់បានទៅលើលក្ខណៈនានារបស់សរីរៈនោះ។ ជារឿយៗ ដំណើរការនេះត្រូវបានប្រើប្រាស់ដើម្បីបង្កើតអំបូររុក្ខជាតិនិងសត្វថ្មីៗដែលក្រោយមកត្រូវបានប្រើប្រាស់ជាប្រភពចំណីអាហារគឺសំដៅថាជាចំណីអាហារដែលកែបំភ្លែពូជ (GE)។ ឧទាហរណ៍ វិស្វកម្មពន្ធុត្រូវបានប្រើប្រាស់ញឹកញាប់ដើម្បីបង្កើនការទប់ទល់របស់រុក្ខជាតិទៅនឹងសត្វល្អិតចង្រៃ ឬ ដើម្បីឲ្យរុក្ខជាតិធន់ទ្រាំទៅនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតផ្សេងៗ។ ដំណាំមួយចំនួនក្នុងចំណោមដំណាំកែច្នៃពន្ធុសំខាន់ៗបំផុត មានពពួកពោត និងសណ្តែកសៀង។ នៅក្នុងឆ្នាំ 2011 ចំនួន 88 ភាគរយ នៃពោតទាំងអស់ និង 94 ភាគរយ នៃសណ្តែកសៀងទាំងអស់ដែលបានផលិតនៅក្នុងសហរដ្ឋអាមេរិកត្រូវបានដាំចេញពីគ្រាប់ពូជដែលកែច្នៃពន្ធុ។ ប្រភេទដំណាំកែច្នៃពន្ធុសំខាន់ៗមួយចំនួនទៀត មានដូចជា alfalfa, canola, កប្បាស, ល្ហុង, ស្ករផ្អែចាវ និង zucchini។ លើសពីនេះទៀត ដំណាំបំភ្លែពូជត្រូវបានប្រើដើម្បីធ្វើជាគ្រឿងផ្សំចំណីអាហារ (ដូចជា ទឹកពោតដែលមានជាតិស្ករខ្ពស់) ដែលជារឿយត្រូវបានដាក់បញ្ចូលទៅក្នុងចំណីអាហារកែច្នៃ (សំដៅលើចំណីអាហារដែលមិនមែនជាដំណាំកសិកម្មឆៅ)។ យោងតាមការប៉ាន់ស្មានមួយចំនួន ពី 40% ទៅ 70% នៃផលិតផលចំណីអាហារដែលដាក់លក់នៅតាមហាងលក់គ្រឿងទេសក្នុងរដ្ឋកាលីហ្វ័រញ៉ាមានផ្ទុកគ្រឿងផ្សំដែលកែច្នៃពន្ធុខ្លះៗ។

***បទបញ្ញាសហព័ន្ធ*** ច្បាប់សហព័ន្ធមិនតម្រូវដាក់លាក់ឲ្យមានបទបញ្ញាលើចំណីអាហារ វិស្វកម្មពន្ធុឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រសួងកសិកម្មសហរដ្ឋអាមេរិក តាមរយៈការវិភាគដែលធ្វើឡើងដោយអ្នកវិភាគផ្នែកនីតិបញ្ញត្តិ ពេលបច្ចុប្បន្ននេះបានដាក់ការហាមឃាត់មួយចំនួនទៅលើការប្រើប្រាស់ដំណាំកែច្នៃពន្ធុដែលត្រូវបានគេបង្ហាញឲ្យដឹងថា បានបង្កផលប៉ះពាល់ដល់រុក្ខជាតិ ផ្សេង ទៀត។ មិនតែប៉ុណ្ណោះ រដ្ឋបាលគ្រប់គ្រងចំណីអាហារ និងឱសថ សហរដ្ឋអាមេរិកទទួលខុសត្រូវក្នុងការធានាថាចំណីអាហារភាគច្រើនបំផុត (ដោយមិនគិតថាតើចំណីអាហារទាំងនោះជាចំណីអាហារដែលត្រូវបានកែច្នៃពន្ធុឬយ៉ាងណានោះទេ) និងសារធាតុជំនួយរសជាតិចំណីអាហារមានសុវត្ថិភាព និងត្រូវបានបិទស្លាកយ៉ាងត្រឹមត្រូវ។

***បទបញ្ញារបស់រដ្ឋ*** យោងតាមច្បាប់រដ្ឋដែលមានស្រាប់ ទីភ្នាក់ងារក្នុងរដ្ឋកាលីហ្វ័រញ៉ាមិនត្រូវបានតម្រូវដាក់លាក់ឲ្យបញ្ញត្តិអំពីចំណីអាហារកែច្នៃពន្ធុឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងសុខាភិបាលសាធារណៈ (DPH) ទទួលខុសត្រូវក្នុងការបញ្ញត្តិអំពីសុវត្ថិភាព និងការបិទស្លាកលើចំណីអាហារភាគច្រើនបំផុត។

### សេចក្តីស្នើច្បាប់

វិធានការនេះ ធ្វើការកែប្រែជាច្រើនទៅលើច្បាប់របស់រដ្ឋដើម្បីតម្រូវ ជាក់លាក់ឲ្យមានបទបញ្ញាសម្រាប់ចំណីអាហារកែច្នៃពន្ធុ។

កាន់តែជាក់លាក់ជាងនេះទៀត វិធានការនេះ (1) តម្រូវថាចំណីអាហារបំភ្លែពូជភាគច្រើនបំផុតដែលលក់ ត្រូវបិទស្លាកឲ្យបានត្រឹមត្រូវ (2) តម្រូវឲ្យនាយកដ្ឋានសុខាភិបាលសាធារណៈបញ្ញត្តិអំពីការបិទស្លាកលើចំណីអាហារប្រភេទនេះ និង (3) អនុញ្ញាតឲ្យបុគ្គលទាំងឡាយធ្វើការប្តឹងក្រុមហ៊ុនផលិតចំណីអាហារដែលរំលោភលើខចែងស្តីពីការបិទ ស្លាកនៅក្នុងវិធានការនេះ។

***ការបិទស្លាកចំណីអាហារ។*** វិធានការនេះតម្រូវថា ចំណីអាហារកែច្នៃពន្ធុដែលដាក់លក់នៅកន្លែងលក់រាយក្នុងរដ្ឋត្រូវបិទស្លាកឲ្យបានច្បាស់លាស់ថាបានកែច្នៃពន្ធុ។ កាន់តែជាក់លាក់ទៀត វិធានការនេះតម្រូវថា ចំណីអាហារឆៅទាំងឡាយ (ដូចជា ផ្លែឈើ និងបន្លែផ្សេងៗ) ដែលត្រូវបានផលិតទាំងស្រុង ឬជាផ្នែកតាមរយៈការកែច្នៃពន្ធុត្រូវសរសេរបញ្ជាក់នៅលើកញ្ចប់ផ្នែក

37

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

(ត)

ខាងមុខ ឬ លើស្លាក។ ប្រសិនបើទំនិញនោះមិនត្រូវបានវេចខ្ចប់ដាច់ដោយឡែកពីគ្នា ឬ មិនមានបិទស្លាកទេ ត្រូវសរសេរពាក្យទាំងនេះនៅលើធ្នើរ ឬ ធុងដែលដាក់បង្ហាញទំនិញនោះសម្រាប់លក់។ វិធានការនេះក៏តម្រូវផងដែរថា ចំណីអាហារកែច្នៃទាំងឡាយដែលត្រូវបានផលិតទាំងស្រុង ឬ ជាផ្នែកតាមរយៈកែច្នៃពន្ធុត្រូវបិទស្លាកដោយសរសេរពាក្យថា "មួយផ្នែកត្រូវបានផលិតដោយធ្វើការកែច្នៃពន្ធុ" ឬ "អាចមួយផ្នែកផលិតដោយធ្វើវិស្វកម្មពន្ធុ"។

កន្លែងលក់រាយ (ដូចជា ហាងលក់គ្រឿងទេស) នឹងទទួលខុសត្រូវជាចម្បងចំពោះការអនុវត្តតាមវិធានការនេះតាម រយៈធ្វើការធានាថា ផលិតផលចំណីអាហាររបស់ពួកគេត្រូវបានបិទស្លាកយ៉ាងត្រឹមត្រូវ។ ផលិតផលទាំងឡាយដែលត្រូវបានបិទស្លាកថា កែប្រែសេនេទិក ត្រូវតែអនុលោមតាមវិធានការនេះ។ សម្រាប់ផលិតផលនីមួយៗដែលមិនត្រូវបានបិទស្លាកថា កែច្នៃពន្ធុជាទូទៅកន្លែងលក់រាយត្រូវតែអាចកត់ត្រាបានពីមូលហេតុដែលផលិតផលនោះត្រូវបានលើកលែងពីការបិទស្លាក។ មានមធ្យោបាយសំខាន់ចំនួនពីរដែលកន្លែងលក់រាយអាចធ្វើលិខិតស្នាមបញ្ជាក់ថា ផលិតផលមួយត្រូវបានលើកលែង ៖ (1) តាមរយៈការទទួលយកឯកសារបញ្ជាក់អះអាងពីអ្នកផ្គត់ផ្គង់ផលិតផលនោះ (ដូចជា អ្នកលក់ដុំ ជាដើម) ដែលបង្ហាញថា ផលិតផលនោះមិនត្រូវបានកែច្នៃពន្ធុដោយចេតនា ឬ ដោយដឹងច្បាស់ (2) តាមរយៈការទទួលបានសេចក្ដីបញ្ជាក់ឯករាជ្យដែលថា ផលិតផលនោះគ្មានផ្ទុកគ្រឿងផ្សំដែលកែច្នៃពន្ធុទេ។ អង្គភាពដទៃទៀតទូទាំងបណ្ដាញផ្គត់ផ្គង់ចំណីអាហារ (ដូចជាកសិករ និងក្រុមហ៊ុនផលិតចំណីអាហារ) ក៏ត្រូវទទួលខុសត្រូវផងដែរចំពោះ ការរក្សាទុកកំណត់ត្រាទាំងនេះ។ វិធានការនេះក៏ផាត់ចេញផងដែរនូវផលិតផលចំណីអាហារជាក់លាក់មួយចំនួនពីល័ក្ខខ័ណ្ឌតម្រូវឲ្យបិទស្លាកដូចលើកឡើងខាងលើ។ ឧទាហរណ៍ ភេសជ្ជៈមានជាតិអាល់កុល ចំណីអាហារសរីរាង្គ និងចំណីអាហារនៅក្នុងភោជនីដ្ឋាន និងចំណី អាហារដែលចម្អិនសម្រាប់ទទួលទានភ្លាមៗ នឹងមិនតម្រូវ ឲ្យធ្វើការបិទស្លាកទេ។ ផលិតផលធ្វើពីសាច់សត្វ - ដូចជា សាច់គោ ឬ សាច់មាន់ - ដែលមិនត្រូវបានផលិតដោយផ្ទាល់តាមរយៈការកែច្នៃពន្ធុក៏ត្រូវបានលើកលែងផងដែរ ដោយមិនគិតថាតើសត្វនោះត្រូវបានចិញ្ចឹមដោយឲ្យស៊ីដំណាំកែច្នៃពន្ធុ ឬ យ៉ាងណានោះទេ។

ក្រៅពីនេះ វិធានការនេះហាមឃាត់ការប្រើប្រាស់ពាក្យថា "តាមធម្មជាតិ" "ផលិតឡើងតាមធម្មជាតិ" "ដាំតាមធម្មជាតិ" និង "មានលក្ខណៈធម្មជាតិទាំងអស់" នៅក្នុងស្លាក និងការផ្សព្វផ្សាយពាណិជ្ជកម្មអំពីចំណីអាហារបំភ្លែពូជ។ ទាក់ទងនឹងមធ្យោបាយដែលវិធានការនេះត្រូវបានសរសេរឡើង គឺមានលទ្ធភាពមួយដែលថា ការហាមឃាត់ទាំងនេះ នឹងត្រូវបកស្រាយដោយតុលាការដើម្បីយកទៅអនុវត្តទៅលើចំណីអាហារកែច្នៃមួយចំនួន ដោយមិនគិតថាតើវាត្រូវបានកែច្នៃពន្ធុឬអត់នោះទេ។

***បទបញ្ញារបស់រដ្ឋ*** ។ ល័ក្ខខ័ណ្ឌតម្រូវឲ្យបិទស្លាកសម្រាប់ចំណីអាហារ វិស្វកម្មពន្ធុស្ថិតក្រោមវិធានការនេះ នឹងត្រូវចែងដោយក្រសួងសុខាភិបាលសាធារណៈដែលជាផ្នែកមួយនៃទំនួលខុសត្រូវរបស់ខ្លួនស្រាប់ក្នុងការបញ្ញត្តិអំពីសុវត្ថិភាព និងការបិទស្លាកចំណីអាហារនានា។ វិធានការនេះអនុញ្ញាតឲ្យក្រសួងអនុម័តបទបញ្ញាទាំងឡាយដែលខ្លួនកំណត់ ដែលមានភាពចាំបាច់សម្រាប់អនុវត្តវិធានការនេះ។ ឧទាហរណ៍ ក្រសួងសុខាភិបាលសាធារណៈនឹងចាំបាច់ត្រូវបង្កើតបទបញ្ញាផ្សេងៗដែលបរិយាយអំពីនីតិវិធីគំរូសម្រាប់កំណត់ថាតើចំណីអាហារទាំងឡាយមានផ្ទុកគ្រឿងផ្សំដែលកែច្នៃពន្ធុដែរឬយ៉ាងណា។

***បណ្ដឹងទាមទារឲ្យអនុវត្តវិធានការនេះ។*** ការរំលោភបំពានទាំងឡាយ ទៅលើវិធានការនេះអាចនឹងត្រូវកាត់ទោសដោយភាគីរដ្ឋ ភាគីក្នុងមូលដ្ឋាន ឬ ភាគីឯកជន។ វិធានការនេះអនុញ្ញាតឲ្យតុលាការផ្ដល់ឲ្យភាគីទាំងនេះនូវរាល់ការចំណាយសមស្របទាំងអស់ដែលបានចំណាយក្នុងការស៊ើបអង្កេត និងការដោះស្រាយបណ្ដឹង។ បន្ថែមពីលើនេះ វិធានការនេះបញ្ជាក់ថា អ្នកប្រើប្រាស់ទាំងឡាយអាចប្ដឹងប្រឆាំងនឹងការរំលោភបំពានទៅលើល័ក្ខខ័ណ្ឌតម្រូវរបស់វិធានការនេះ នៅក្រោមច្បាប់ដោះស្រាយករណីអ្នកប្រើប្រាស់របស់រដ្ឋដែលផ្ដល់សិទ្ធិឲ្យអ្នកប្រើប្រាស់ធ្វើការប្ដឹងដោយមិនចាំបាច់បង្ហាញពីការខូចខាតជាក់លាក់ណាមួយដែលបានកើតឡើងដោយសារតែការរំលោភដែលបានចោទប្រកាន់នោះទេ។

## ឥទ្ធិពលសារពើពន្ធ

***ការបង្កើនការចំណាយលើការគ្រប់គ្រងរបស់រដ្ឋ*** វិធានការនេះនឹងធ្វើឲ្យកើនឡើងនូវការចំណាយរបស់រដ្ឋសំរាប់ ក្រសួងសុខាភិបាលសាធារណៈ សម្រាប់បង្កើតបទបញ្ញត្តិអំពីការបិទស្លាកលើចំណីកែច្នៃពន្ធុ ដូចជាការពិនិត្យមើលឯកសារ និងធ្វើអធិការកិច្ចតាមពេលកំណត់ដើម្បីកំណត់ថាតើចំណីអាហារទាំងឡាយពិតជាកំពុងត្រូវបានលក់ដោយមានបិទស្លាកយ៉ាងត្រឹមត្រូវឬយ៉ាងណា។ វាអាស្រ័យលើវិធី និងវិសាលភាពដែលក្រសួងជ្រើសរើសអនុវត្តបទបញ្ញាទាំងនេះ (ដូចជា តើត្រូវជ្រើសរើសធ្វើការត្រួតពិនិត្យហាងលក់គ្រឿងទេសញឹកញាប់បែបណា) ការចំណាយទាំងនេះអាចមាន**ចាប់ពី ពីរបីសែនដុល្លាររហូតដល់ជាង $1 លានដុល្លារជារៀងរាល់ឆ្នាំ។**

***កំណើនទ្រព្យកប្រែដោយសក្ដានុពលនៃការចំណាយទាក់ទងនឹងបណ្ដឹងវិវាទ។*** ដូចបានលើកឡើងខាងលើ វិធានការនេះផ្ដល់សិទ្ធិឲ្យបុគ្គលទាំងឡាយប្ដឹងប្រឆាំងនឹងការរំលោភបំពានលើល័ក្ខខ័ណ្ឌតម្រូវស្ដីពីការបិទស្លាក។ ដោយសារប្រការនេះនឹងធ្វើឲ្យកើនឡើងនូវចំនួនសំណុំរឿងដែលដាក់ទៅតុលាការរដ្ឋ នោះ រដ្ឋ និងខោនធីទាំងឡាយនឹងត្រូវចំណាយបន្ថែមសម្រាប់ដំណើរការ និងជំនុំជម្រះសំណុំរឿងបន្ថែមទៀត។ វិសាលភាពនៃការចំណាយទាំងនេះនឹងពឹងផ្អែកទៅលើចំនួនសំណុំរឿងដែលបានបញ្ជូនមក ចំនួនសំណុំរឿងដែលជំនុំជម្រះដោយរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាននិងលក្ខណៈដែលសំណុំរឿងទាំងនោះត្រូវបានសម្រេចដោយតុលាការ។ ការចំណាយដែលកើនឡើងខ្លះៗរបស់តុលាការ នឹងត្រូវឧបត្ថម្ភដោយប្រាក់ថ្លៃដាក់ពាក្យបណ្ដឹងទៅតុលាការ ដែលភាគីពាក់ព័ន្ធត្រូវបានតម្រូវឲ្យបង់អនុលោមតាមច្បាប់ដែលមានស្រាប់។ នៅក្នុងបរិបទនៃការចំណាយសរុបរបស់តុលាការការចំណាយទាំងនេះមិន ទំនងជាមានចំនួនច្រើននោះទេនៅក្នុងដំណើរវែងឆ្ងាយទៅមុខ។



*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 37, សូមអានទំព័រ 110។*

## ★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ លេខ 37 ★

បាទ/ចាស គាំទ្រសំណើប្រជាមតិ លេខ 37 - ពីព្រោះអ្នកគួរមានសិទ្ធិដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក។

*ការបោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិ 37 មានន័យ 3 យ៉ាង ៖*

- អ្នកនឹងមានសិទ្ធិដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក និង ថាតើចំណីអាហាររបស់អ្នកត្រូវបានផលិតដោយប្រើវិស្វកម្មពន្ធុយ៉ាងណា។
- ចំណីអាហារនឹងត្រូវបិទស្លាកយ៉ាងត្រឹមត្រូវ។ ស្លាកទាំងឡាយនៅលើចំណីអាហារ ត្រូវតែបង្ហាញឲ្យដឹងប្រសិនបើផលិតផលនោះត្រូវបានផលិតតាមរយៈវិស្វកម្មពន្ធុ។
- ការការពារសុខភាពគ្រួសាររបស់អ្នកនឹងកាន់តែមានភាពងាយស្រួលជាងមុន។ អ្នកនឹងទទួលបានព័ត៌មានដែលអ្នកត្រូវការអំពីចំណីអាហារដែលពេទ្យ និងអ្នកវិទ្យាសាស្ត្រអះអាងថា មានទំនាក់ទំនងទៅនឹងប្រតិកម្ម និងគ្រោះថ្នាក់ធំៗដទៃទៀតចំពោះសុខភាព។

ចំណីអាហារដែលយើងទិញមានព័ត៌មានអំពីសារធាតុចិញ្ចឹមរួចទៅហើយនៅលើស្លាករបស់វា។ ជាមួយនឹងសំណើប្រជាមតិ 37 យើងនឹងមានព័ត៌មានដែលសរសេរជាភាសាសាមញ្ញ ប្រសិនបើចំណីអាហារនោះត្រូវបានផលិតឡើងដោយវិស្វកម្មពន្ធុ ដែលមានន័យថាចំណីអាហារនោះមាន DNA (អាស៊ីដឌីអុកស៊ីរីបូនុយក្លេអ៊ិច) ដែលត្រូវបានធ្វើការកែប្រែបែបសិប្បនិម្មិតនៅក្នុងមន្ទីរពិសោធន៍ដោយប្រើប្រាស់ពន្ធុពីវីរុស បាក់តេរី ឬ រុក្ខជាតិ ឬសត្វផ្សេងៗទៀត។

ដោយសារតែចំណីអាហារកែច្នៃពន្ធុមានភាពចម្រូងចម្រាស មានប្រទេស*ជាង 40 ជុំវិញពិភពលោកត្រូវការឲ្យមានស្លាកសម្រាប់ចំណីអាហារវិស្វកម្មពន្ធុ* ក្នុងនោះមានប្រទេសភាគច្រើនបំផុតនៅក្នុងទ្វីបអឺរ៉ុប ប្រទេសជប៉ុន និងសូម្បីតែប្រទេសចិន និងឥណ្ឌា។ តើក្រុមហ៊ុនអាមេរិកទាំងឡាយមិនគួរផ្តល់ឲ្យពលរដ្ឋអាមេរិកនូវព័ត៌មានដូចគ្នាទៅនឹងអ្វីដែលពួកគេផ្តល់ទៅឲ្យជនបរទេសមែនឬទេ?

មិនមានការសិក្សារយៈពេលវែងអំពីសុខភាពដែលបានបង្ហាញថា ចំណីអាហារវិស្វកម្មពន្ធុមានសុវត្ថិភាពចំពោះមនុស្សនោះទេ។ មិនថាអ្នកទិញចំណីអាហារវិស្វកម្មពន្ធុ ឬអត់នោះទេ អ្នកមានសិទ្ធិដឹងអំពីអ្វីដែលអ្នកកំពុងតែទិញ និងមិនត្រូវប្រថុយប្រថានចំពោះសុខភាពគ្រួសាររបស់អ្នកឡើយ។ ការបិទស្លាកជួយឲ្យអ្នកដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់យើង ដូច្នេះយើងអាចធ្វើការពិចារណាសម្រាប់ខ្លួនយើងផ្ទាល់។

សំណើប្រជាមតិ 37 គឺជាវិធានការសាមញ្ញប្រកបដោយសុភវិនិច្ឆ័យមួយ។ វាមិនចំណាយប្រាក់អ្វីឡើយសម្រាប់ការដាក់បញ្ចូលព័ត៌មានទៅក្នុងស្លាកមួយ ហើយវាត្រូវបានអនុវត្តដោយផ្តល់ពេលវេលាឲ្យផលិតករធ្វើការព្រីនចេញនូវស្លាកថ្មីៗដែលប្រាប់អ្នកពីអ្វីដែលនៅក្នុងចំណីអាហារនោះ ឬ ធ្វើការផ្លាស់ប្តូរផលិតផលរបស់ពួកគេ ប្រសិនបើពួកគេមិនចង់លក់ចំណីអាហារដែលកែច្នៃពន្ធុនោះ។

លើសពីនេះទៅទៀត សំណើប្រជាមតិ 37 ទប់ស្កាត់ការប្រើប្រាស់ខុសនូវពាក្យ "ធម្មជាតិ" ទៅលើផលិតផលកែច្នៃពន្ធុ។

ក្រុមហ៊ុនផលិតចំណីអាហារ និងក្រុមហ៊ុនកសិគីមីធំៗ និងអ្នកផ្សព្វផ្សាយបញ្ចុះបញ្ចូលរបស់ពួកគេប្រឆាំងនឹងវិធានការនេះ។ ក្រុមហ៊ុនជាច្រើនក្នុងចំណោមនេះ គឺជាក្រុមហ៊ុនដូចគ្នាទៅនឹងក្រុមហ៊ុនដែលបានកុហកពួកយើងអំពីផលប៉ះពាល់របស់ថ្នាំសម្លាប់សត្វល្អិត ឬ បានតស៊ូមិនបង្ហាញព័ត៌មានផ្សេងទៀតនៅលើស្លាកចំណីអាហារ ដូចជាចំនួនកាឡូរី ឬ បរិមាណជាតិខ្លាញ់ ឬ អំបិលដែលមាននៅក្នុងផលិតផលរបស់ពួកគេ។ បច្ចុប្បន្ននេះ ពួកគេចង់ឃាំងយើងឲ្យនៅទីងងឹតមិនឲ្យដឹងពីវិស្វកម្មពន្ធុរបស់ពួកគេនៅក្នុងចំណីអាហាររបស់យើងឡើយ។

មិនថាអ្នកចង់ទទួលទានចំណីកែច្នៃពន្ធុ ឬអត់នោះទេ សំណើប្រជាមតិ 37 ផ្តល់ឲ្យអ្នកនូវអំណាចក្នុងការជ្រើសរើសចំណីអាហារអ្វីខ្លះសម្រាប់ទទួលទានក្នុងគ្រួសាររបស់អ្នក។ ក្រុមហ៊ុនគីមីធំៗមិនគួរធ្វើការសម្រេចចិត្តសម្រាប់អ្នកនោះទេ។

អ្នកប្រើប្រាស់ គ្រួសារកសិករ វេជ្ជបណ្ឌិត គិលានុបដ្ឋាក និងគិលានុបដ្ឋាយិកា អ្នកឯកទេសអាហារូបត្ថម្ភ និងពាណិជ្ជករខ្នាតតូច និងពលរដ្ឋកាលីហ្វ័រញ៉ាជិតមួយលាននាក់បានចេញមុខចុះហត្ថលេខារួចរាល់ហើយទៅលើញត្តិដែលផ្តល់ឲ្យអ្នកនូវសិទ្ធិដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់យើង? តើអ្នកនឹងចូលរួមជាមួយពួកគេដែរ ឬទេ?

ចង់ដឹងព័ត៌មានបន្ថែម ឬ ចូលរួមជាមួយពួកគេឥឡូវនេះ សូមចូលទៅកាន់គេហទំព័រ *www.CARightToKnow.org.*

នៅពេលអ្នកបោះឆ្នោតសម្រេចលើសំណើប្រជាមតិ 37 សូមសួរខ្លួនឯងតែមួយសំណួរប៉ុណ្ណោះ ៖ តើខ្ញុំមានសិទ្ធិដឹងពីអ្វីដែលនៅក្នុងចំណីអាហារដែលខ្ញុំទទួលទាន និងចិញ្ចឹមគ្រួសារខ្ញុំបានដែរឬទេ? ចម្លើយ គឺបោះឆ្នោត *បាទ/ចាស លើសំណើប្រជាមតិ លេខ 37* ។

*www.CARightToKnow.org.*

**DR. MICHELLE PERRO**, វេជ្ជបណ្ឌិតផ្នែកកុមារ
**REBECCA SPECTOR**, នាយក West Coast
មជ្ឈមណ្ឌល សំរាប់សុវត្ថិភាពចំណីអាហារ
**GRANT LUNDBERG**, មន្ត្រីនាយកប្រតិបត្តិ
កសិកម្ម គ្រួសារ Lundberg

37

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 37 ★

សំណើប្រជាមតិ 37 និយត្តកម្មអំពី "សិទ្ធិដើម្បីដឹង" គឺពិតជាផែនការឆបោកមួយពោរពេញដោយការលើកលែងចំពោះ អ្នកទទួលបានផលប្រយោជន៍ពិសេស និងតំលៃលាក់បាំងសំរាប់ អ្នកប្រើបាស្រ់និងអ្នកបង់ពន្ធ។

សំណើប្រជាមតិ 37 លើកលែង ទឹកដោះគោ ឈីស្ស និង សាច់ពីតម្រូវការឲ្យបិទស្លាកឈ្មោះ។ វាលើកលែងស្រាបៀរ សាទំពាំងបាយជូរ ស្រា អាហារដែលបានលក់នៅតាមភោជនីយដ្ឋាន និងអាហារផ្សេងទៀតដែលមានសារធាតុកែប្រែពន្ធុ។

តាមពិត វាលើកលែងពីរភាគបីនៃម្ហូបអាហារដែលពលរដ្ឋរដ្ឋ កាលីហ្វ័រញ៉ាប្រើប្រាស់ - រួមមានផលិតផលដែលផលិតដោយក្រុមហ៊ុន ដែលផ្តល់ថវិកាដល់យុទ្ធនាការសំណើប្រជាមតិ 37។

បង្កើតឲ្យមានបណ្តឹងទារយកប្រាក់ថ្មី

សំណើប្រជាមតិ 37 ត្រូវបានសរសេរដោយមេធាវីជំនុំជម្រះដែលជំនាញ ខាងការដាក់ពាក្យបណ្តឹងប្រឆាំងនឹងអាជីវកម្មនានា។ វាបង្កើតប្រភេទ ថ្មីមួយ នៃបណ្តឹងទារយកប្រាក់ដែលអនុញ្ញាតឲ្យមេធាវីទាំងឡាយអាច ប្តឹងអ្នកចំការ អ្នកលក់ឥវ៉ាន់ និងក្រុមហ៊ុនម្ហូបអាហារ - ដោយគ្មាន ភស្តុតាងនៃការរំលោភបំពាន ឬការបំផ្លាញឡើយ។

អ្នកប្រើប្រាស់នឹងទទួលបាននូវព័ត៌មានដែលធ្វើឲ្យយល់ខុស។

មានការសិក្សាជាលក្ខណៈវិទ្យាសាស្ត្រជាង 400 បានបង្ហាញពីចំណីអាហារដែលបានធ្វើដោយវិស្វកម្មពន្ធុ គឺមានសុវត្ថិភាព។ អង្គការសុខភាពនាំមុខគេនានាដូចជា
សមាគមវេជ្ជសាស្ត្រអាមេរិក អង្គការ សុខភាពពិភពលោក បណ្ឌិតសភាជាតិផ្នែកវិទ្យាសាស្ត្រ អ្នកវិទ្យាសាស្ត្រ ដែលបានឈ្នះរង្វាន់ណូបែល 24 នាក់ និងរដ្ឋបាលគ្រប់គ្រងខាងចំណីអាហារ និងឱសថសហរដ្ឋអាមេរិក ក៏យល់ស្រប។

*"មិនមានយុត្តិកម្មផ្នែកវិទ្យាសាស្ត្រសម្រាប់ការបិទស្លាកពិសេសនៅលើចំណីអាហារផលិតតាមការកែច្នៃជីវសាស្ត្រឡើយ"* - សមាគមវេជ្ជសាស្ត្រអាមេរិក

តំលៃកាន់តែខ្ពស់សំរាប់អ្នកប្រើបាស្រ់និងអ្នកជាប់ពន្ធ

ការសិក្សាបង្ហាញថា ដោយការបង្ខំឲ្យផលិតផលចំណីអាហារទូទៅ ជាច្រើនមានការវេចខ្ចប់ឬធ្វើឡើងវិញជាមួយគ្រឿងផ្សំតំលៃកាន់តែថ្លៃ សំណើប្រជាមតិ 37 នឹងធ្វើឲ្យគ្រួសាររដ្ឋកាលីហ្វ័រញ៉ាកំរិតមធ្យម ចំណាយលុយរាប់រយដុល្លារបន្ថែមក្នុងមួយឆ្នាំសំរាប់គ្រឿងទេស។

ការវិភាគផលប៉ះពាល់សារពើពន្ធរបស់រដ្ឋជាផ្លូវការ សន្និដ្ឋានថាការចាត់ ចែងការិយាល័យធិបតេយ្យ និងពាក្យបណ្តឹងនឹងធ្វើឲ្យមានការចំណាយ ដល់អ្នកបង់ពន្ធរាប់លានដុល្លារ។

សូម្បីអ្នកផ្តល់ថវិកាដ៏ធំបំផុតរបស់សំណើប្រជាមតិ 37 សារភាពថា វា *"នឹងជាសុបិនអាក្រក់មួយខាងការរៀបចំទីកន្លែងដែលមានតំលៃថ្លៃ។"*

សំណើប្រជាមតិ 37 គឺជាល្បិចកលបោកនិងមានតំលៃថ្លៃមួយ។

បោះឆ្នោត ទេ!

*www.NoProp37.com*

**JONNALEE HENDERSON**
សហព័ន្ធការិយាល័យកសិដ្ឋាននៃរដ្ឋកាលីហ្វ័រញ៉ា
**DR. HENRY I. MILLER**, នាយកស្ថាបនិក
ការិយាល័យជីវបច្ចេកវិទ្យានៃរដ្ឋបាលគ្រប់គ្រងចំណីអាហារនិងឱសថ
**TOM HUDSON**, នាយកប្រតិបត្តិ
គណៈកម្មការការពារអ្នកបង់ពន្ធរដ្ឋកាលីហ្វ័រញ៉ា



*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# 37

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 37 ★

សំណើប្រជាមតិ 37 គឺមិនមែនជាវិធានការសាមញ្ញដូចដែលអ្នកផ្សព្វផ្សាយអះអាងនោះទេ។ វាជាការឆបោកមួយ មានគុណវិបត្តិនៃការបិទស្លាកលើចំណីអាហារដែលធ្វើឲ្យយល់ខុស និងខូចគុណភាពធ្ងន់ធ្ងរ ដែលនឹងបន្ថែមការចំណាយកាន់តែច្រើនទៅលើការិយាធិបតេយ្យរដ្ឋាភិបាល និងអ្នកបង់ពន្ធ បង្កើតជាបណ្ដឹងគ្មានប្រយោជន៍ថ្មីៗទៀត និងបង្កើនការចំណាយលើចំណីអាហាររាប់ពាន់លានដុល្លារ- ដោយគ្មានផ្តល់ផលប្រយោជន៍ខាងសុខភាព និងសុវត្ថិភាពសោះ។ មិនតែប៉ុណ្ណោះ វាពោរពេញទៅដោយការលើកលែងសំរាប់ផលប្រយោជន៍ពិសេស។

សំណើប្រជាមតិលេខ 37 ប្រឆាំងជាមួយនឹងវិទ្យាសាស្ត្រ។

បច្ចេកវិទ្យាជីវសាស្ត្រ ដែលត្រូវបានហៅផងដែរថា ការកែច្នៃពន្ធុ (GE) ត្រូវបានគេប្រើប្រាស់ជិតពីរទសវត្សរ៍មកហើយសម្រាប់ដាំដំណាំប្រភេទផ្សេងៗ ដូចជា ពោត សណ្តែកសៀង និងដំណាំដទៃទៀតដែលធន់នឹងជំងឺ និងសត្វល្អិត និងត្រូវការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតកាន់តែតិច។ ចំណីអាហារទូទៅរាប់ពាន់មុខត្រូវបានផលិតជាមួយនឹងគ្រឿងផ្សំដែលបានមកពីដំណាំដាំដោយបច្ចេកវិទ្យាជីវសាស្ត្រ។

សំណើប្រជាមតិ 37 ហាមឃាត់ចំណីអាហារដែលមានសុវត្ថិភាពបំផុតទាំងនេះនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ប្រសិនបើវាមិនត្រូវបានបិទស្លាកយ៉ាងពិសេស ឬ ផលិតឡើងវិញដោយប្រើប្រាស់គ្រឿងផ្សំដែលមានតម្លៃខ្ពស់ជាងមុនទេ។

រដ្ឋបាលគ្រប់គ្រងខាងចំណីអាហារនិងឱសថសហរដ្ឋអាមេរិកចែងថា គោលនយោបាយបិទស្លាកបែបនេះនឹងនាំឲ្យមាន *"ការកុហកដែលមិនអាចចៀសផុត"។*

អង្គការខាងវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រដែលទទួលបានការគោរព បានធ្វើសេចក្តីសន្និដ្ឋានថា ចំណីអាហារប្រើបច្ចេកវិទ្យាជីវសាស្ត្រ គឺមានសុវត្ថិភាព ដែលរួមមាន៖

- បណ្ឌិតសភាជាតិផ្នែកវិទ្យាសាស្ត្រ (NAS)
- ក្រុមប្រឹក្សាអាមេរិកផ្នែកវិទ្យាសាស្ត្រ និងសុខភាព (ACSH)
- បណ្ឌិតសភាផ្នែកអាហារូបត្ថម្ភ និងចំណីអាហារ (AND)
- អង្គការសុខភាពពិភពលោក (WHO)

*"មិនមានយុត្តិកម្មផ្នែកវិទ្យាសាស្ត្រសម្រាប់ការបិទស្លាកពិសេសនៅលើចំណីអាហារផលិតតាមការវិស្វកម្មពន្ធុឡើយ"* ។ —សមាគមវេជ្ជសាស្ត្រអាមេរិក ខែមិថុនា ឆ្នាំ 2012 ។

សំណើប្រជាមតិលេខ 37 ៖ ពោរពេញទៅដោយនិយត្តិកម្មតាមអំពើចិត្ត និងការលើកលែងដើម្បីផលប្រយោជន៍ពិសេស

*"បទបញ្ញា និងការលើកលែងតាមទំនើងចិត្តនៅក្នុងសំណើប្រជាមតិ 37 នេះនឹងផ្តល់នូវផលប្រយោជន៍ពិសេសជាក់លាក់មួយចំនួន ក៏ប៉ុន្តែមិនធ្លាក់ដល់ដៃអ្នកប្រើប្រាស់នោះទេ"* ។ — Dr. Christine Bruhn ក្រសួងវិទ្យាសាស្ត្រចំណីអាហារ និងបច្ចេកវិទ្យា នៃសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា UC Davis

សំណើប្រជាមតិ 37 គឺពោរពេញទៅដោយការលើកលែងដែលមិនសមហេតុផល និងមានការលើកទឹកចិត្តផ្នែកនយោបាយ។ វាតម្រូវឲ្យបិទស្លាកពិសេសនៅលើទឹកដោះគោ ផ្សំជាមួយសណ្តែកសៀង ក៏ប៉ុន្តែលើកលែងចំពោះទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះគោ។ ទឹកផ្លែឈើ គឺតម្រូវឲ្យមានស្លាក ប៉ុន្តែលើកលែងចំពោះគ្រឿងស្រវឹង។ ចំណីសត្វដែលមានផ្ទុកជាតិសាច់ តម្រូវឲ្យមានស្លាក ក៏ប៉ុន្តែលើកលែងចំពោះសាច់ផ្សេងៗសម្រាប់មនុស្សទទួលទាន។

ចំណីអាហារនាំចូលពីប្រទេសចិន និងប្រទេសមួយចំនួនផ្សេងទៀត ត្រូវបានលើកលែងប្រសិនបើអ្នកលក់ទាំងឡាយអះអាងជាសាមញ្ញថា ផលិតផលរបស់ពួកគេ "មិនពាក់ព័ន្ធនឹងវិស្វកម្មពន្ធុ"។ ក្រុមហ៊ុនបរទេសនានាដែលមិនស្មោះត្រង់ អាចទាញយកផលប្រយោជន៍ពីប្រព័ន្ធនេះ។

សំណើប្រជាមតិលេខ 37 អនុញ្ញាតឲ្យមានបណ្តឹងទារយកប្រាក់សំណើនេះត្រូវបានសរសេរដោយមេធាវីជំនុំជម្រះម្នាក់ដើម្បីផ្តល់ផលប្រយោជន៍ដល់មេធាវីជំនុំជម្រះទាំងឡាយ។ វាបង្កើតនូវប្រភេទថ្មីមួយនៃ "រឿងក្តីជ្រើសរើសពិសេស" ដែលអនុញ្ញាតឲ្យមេធាវីធ្វើការប្តឹងគ្រួសារកសិករ និងអ្នកលក់គ្រឿងទេសដោយមិនមានភ័ស្តុតាងណាមួយអំពីភយន្តរាយ។

*ពលរដ្ឋកាលីហ្វ័រញ៉ាដែលប្រឆាំងនឹងការរំលោភបំពានរឿងក្តីលើកឡើងថា "សំណើប្រជាមិត 37 អនុញ្ញាតឲ្យមេធាវីជំនុំជម្រះទាំងឡាយប្រើប្រាស់រឿងក្តីទាមទារយកប្រាក់ដើម្បីជំរិតយកប្រាក់ពីគ្រួសារកសិករ និងអ្នកលក់គ្រឿងទេស - ដែលធ្វើឲ្យតុលាការក្នុងរដ្ឋកាលីហ្វ័រញ៉ា អាជីវកម្ម និងអ្នកបង់ពន្ធចំណាយប្រាក់រាប់លានដុល្លារ"។*

សំណើប្រជាមតិ 37 ៖ ការិយាធិបតេយ្យកាន់តែច្រើននិងការចំណាយ សម្រាប់អ្នកបង់ពន្ធកាន់តែច្រើន

សំណើប្រជាមតិ 37 តម្រូវឲ្យការិយាលេខានុការរដ្ឋគ្រប់គ្រងល័ក្ខខ័ណ្ឌតម្រូវដ៏ស្មុគស្មាញរបស់ខ្លួនតាមរយៈធ្វើការពិនិត្យតាមដានមើលស្លាកចំណីអាហារចំនួនរាប់សិបពាន់។ វាមិនបានកំណត់ពីចំនួនទឹកប្រាក់ប៉ុន្មានលានដែលត្រូវចំណាយទៅលើការិយាធិបតេយ្យ ច្បាប់ទម្លាប់ការិយាធិបតេយ្យស្មុគស្មាញ និងរឿងក្តីនានានោះទេ។ វាគឺជាសែកចំហ………ដែលបង់ប្រាក់ដោយអ្នកបង់ពន្ធ។

សំណើប្រជាមតិ 37 មានន័យថា ថ្លៃចំណីអាហារកាន់តែខ្ពស់

សំណើប្រជាមតិ 37 បង្ខំកសិករ និងក្រុមហ៊ុនផលិតចំណីអាហារឲ្យអនុវត្តប្រតិបត្តិការថ្មីដែលមានតំលៃខ្ពស់ ឬ ឲ្យប្តូរទៅប្រើគ្រឿងផ្សំដែលមានតម្លៃខ្ពស់ មិនធ្វើវិស្វកម្មពន្ធុ ឬសរីរាង្គសម្រាប់លក់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

ការសិក្សាផ្នែកសេដ្ឋកិច្ចបង្ហាញថា ប្រការនេះនឹងបង្កើនការចំណាយទៅលើចំណីអាហារសម្រាប់គ្រួសារជាមធ្យមរាប់រយដុល្លារជារៀងរាល់ឆ្នាំ-ដែលជាពន្ធចំណីអាហារមើលមិនឃើញដែលនឹងធ្វើឲ្យប៉ះពាល់ យ៉ាងខ្លាំងដល់មនុស្សចាស់ និងគ្រួសារដែលមានប្រាក់ចំណូលទាបដែលអាចមានលទ្ធភាពតិចតួចបំផុតក្នុងការទិញវា។

*"សំណើប្រជាមតិ 37 នឹងធ្វើឲ្យប៉ះពាល់ដល់គ្រួសារកសិករ និងអ្នកប្រើប្រាស់យ៉ាងអយុត្តិធម៌។ ដូច្នេះត្រូវតែបញ្ឈប់វា។"* —សហព័ន្ធការិយាល័យកសិដ្ឋានរដ្ឋកាលីហ្វ័រញ៉ាដែលតំណាងឲ្យកសិករចំនួន 80,000 នាក់។

ចូលរួមជាមួយអ្នកវិទ្យាសាស្ត្រ អ្នកជំនាញវេជ្ជសាស្ត្រ គ្រួសារកសិករ អ្នកតស៊ូមតិរបស់អ្នកបង់ពន្ធ អាជីវកម្មខ្នាតតូច។

បោះឆ្នោត ទេ លើសំណើប្រជាមតិ លេខ 37។

បញ្ឈប់ការកលល្បិច បិទផ្លាកចំណីអាហារ ឆរបោក អស់ថ្លៃចំណាយដ៏ច្រើននេះ។

*www.NoProp37.com*

**DR. BOB GOLDBERG**, សមាជិក
បណ្ឌិតសភាជាតិនៃវិទ្យាសាស្ត្រ
**JAMIE JOHANSSON**
គ្រួសារកសិករកាលីហ្វ័រញ៉ា
**BETTY JO TOCCOLI**, ប្រធាន
សមាគមអាជីវកម្មខ្នាតតូចកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 37 ★



*សំណើប្រជាមតិ 37៖ និយាយ "យល់ព្រម" ដើម្បីដឹងពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក។*

*សំណើប្រជាមតិ 37 មានន័យយ៉ាងសាមញ្ញថា អ្នកមានសិទ្ធិដឹងពីអ្វីនៅក្នុងចំណីអាហាររបស់អ្នក។ មធ្យោបាយសម្រាប់ធ្វើការងារនោះ គឺត្រូវធ្វើឲ្យប្រាកដថាស្លាកបិទលើចំណីអាហារ គឺពិតជាត្រឹមត្រូវ។*

*សំណើប្រជាមតិ 37 ដាក់អ្នកឲ្យទទួលខុសត្រូវ។* គ្មានការិយាធិបតេយ្យរដ្ឋាភិបាល អ្នកនយោបាយ ឬ ក្រុមហ៊ុនកសិគីមីណាមួយនឹងអាចមានលទ្ធភាពបិទបាំងបានឡើយប្រសិនបើចំណីអាហាររបស់អ្នកត្រូវបានផលិតឡើងតាមការកែច្នៃពន្ធុនោះឬក៏អត់។ ការអនុវត្ត គឺជាកិច្ចការតែមួយគត់ ប្រសិនបើក្រុមហ៊ុនទាំងឡាយនោះរំលោភច្បាប់! អ្វីគ្រប់យ៉ាងដែលពួកគេត្រូវធ្វើ គឺត្រូវប្រាប់អ្នកអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក ដូចដែលពួកគេបានធ្វើរួចមកហើយនៅក្នុងប្រទេសផ្សេងៗជាង 40 ទូទាំងទ្វីបអឺរ៉ុប ប្រទេសអូស្ត្រាលី ជប៉ុន និងសូម្បីប្រទេសចិន និងរុស្ស៊ី។

*សំណើប្រជាមតិ 37 មិនហាមឃាត់ចំណីអាហារវិស្វកម្មពន្ធុនោះទេ។* ក្រុមហ៊ុនអាជីវកម្មកសិកម្ម និងកសិគីមីធំៗ និងអ្នកបញ្ចុះបញ្ចូលរបស់ពួកគេចង់បន្លាចអ្នក។ ក្រោមសំណើប្រជាមតិ 37 អ្នកអាចបន្តទិញចំណីអាហារក្នុងពេលបច្ចុប្បន្នរបស់អ្នក ឬ អ្នកអាចជ្រើសរើសអាហារផ្សេងៗដែលមិនកែច្នៃពន្ធុ។ វាគឺជាជម្រើសរបស់អ្នក។

*សំណើប្រជាមតិ 37 មិនបង្កើនតម្លៃចំណីអាហារ ឬពន្ធដារនោះទេ។* ព្រោះតែក្រុមហ៊ុនចំណីអាហារបោះពុម្ពស្លាកឡើងវិញជាទៀងទាត់ និងមានជំហានសមស្របនៅក្នុងអំឡុងពេលមួយ សំណើប្រជាមតិ 37 នឹងមិនបង្កើនតម្លៃឡើយ។

*សំណើប្រជាមតិ 37 នឹងជួយការពារសុខភាពគ្រួសាររបស់អ្នក។* រដ្ឋបាលគ្រប់គ្រងចំណីអាហារ និងឱសថ (FDA) និយាយថា "ការផ្តល់ព័ត៌មានច្រើនដល់អ្នកប្រើប្រាស់អំពីអាហារដែលផលិតដោយកែប្រែជីវសាស្ត្រនឹងមានអត្ថប្រយោជន៍"។ ប្រសិនមិនមានការបិទស្លាកចំណីអាហារច្បាស់លាស់ទេ អ្នកនឹងប្រថុយប្រថានទទួលទានអាហារដែលអ្នកប្រតិកម្មជាមួយវា។ ហេតុអ្វីក្រុមហ៊ុនចំណីអាហារធំៗមិនចង់ឲ្យអ្នកដឹងអំពីអ្វីដែលនៅក្នុងចំណីអាហាររបស់អ្នក? ដោយមានវិទ្យាសាស្ត្រដ៏ចម្រូងចម្រាស់ និងមិនប្រាកដប្រជាអំពីផលប៉ះពាល់ផ្នែកសុខភាពនៃចំណីអាហារកែច្នៃពន្ធុ ការបិទស្លាក គឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការពារសុខភាពគ្រួសាររបស់អ្នក។

យើងមានសិទ្ធិដឹងពីអ្វីនៅក្នុងចំណីអាហាររបស់យើង។ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 37។

*www.Carighttoknow.org*

**JAMIE COURT**, ប្រធាន
ក្រុមឃ្លាំមើលអ្នកប្រើប្រាស់
**JIM COCHRAN**, អគ្គនាយក
កសិដ្ឋាន បែរី Swanton
**DR. MARCIA ISHII-EITEMAN**, អ្នកវិទ្យាសាស្ត្រ ជាន់ខ្ពស់
បណ្តាញសកម្មភាព ថ្នាំសំឡាប់សត្វចង្រៃ

សំណើប្រជាមតិ

# 38 ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំដូង។ លក្ខន្តិកៈផ្តួចផ្តើម។

**ចំណងជើងជាផ្លូវការ និងសេចក្តីសង្ខេប** | **រៀបចំដោយអគ្គមេធាវី**

## ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំដូង។ លក្ខន្តិកៈផ្តួចផ្តើម។

- ការបង្កើនកំរិតពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន លើប្រាក់រកបានប្រចាំឆ្នាំ ច្រើនជាង $7,316 ដោយប្រើខ្នាតរំកឹល ពី .4% សំរាប់បុគ្គលដែលរកប្រាក់បានទាបបំផុត ទៅ 2.2% សំរាប់បុគ្គលដែលរកប្រាក់បានច្រើនជាង $2.5 លាន ចំនួនដប់ពីរឆ្នាំ។
- នៅក្នុងពេលបួនឆ្នាំដំបូង ការបែងចែកប្រាក់ចំណូល 60% សំរាប់សាលារៀនថ្នាក់ K-12 ហើយ30% សំរាប់សង បំណុលរដ្ឋ, និង 10% សំរាប់កម្មវិធីកុមារវ័យដំបូង។ បន្ទាប់ពីនោះមក ការបែងចែកប្រាក់ចំណូល 85% សំរាប់ សាលារៀនថ្នាក់ K-12 និង 15% សំរាប់កម្មវិធីកុមារវ័យដំបូង។
- ផ្តល់ថវិកាសំរាប់ថ្នាក់ K-12 តាមសាលារៀនជាក់លាក់ យោងតាមចំនួនសិស្ស អាស្រ័យលើការត្រួតត្រាតាមមូលដ្ឋាន ការជំរះបញ្ជី និងមតិសាធារណជន។
- ហាមឃាត់រដ្ឋ ពីការផ្តល់ថវិកាថ្មី។

**សេចក្តីសង្ខេបនៃអ្នកវិភាគនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ៖**

- បង្កើនក្នុងពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនរបស់រដ្ឋ ចាប់តាំងពីឆ្នាំ 2013 រហូតដល់ឆ្នាំ 2024។ កំណើននេះនឹងប្រហាក់ប្រហែល $10 កោដិ ក្នុងឆ្នាំ 2013-14 ដែលទំនងនឹងកើនឡើងគ្រឿនៗ។ កំណើនក្នុងឆ្នាំ 2012-13 នឹងប្រហែលជាពាក់កណ្តាល នៃចំនួននេះ។
- នៅក្នុងឆ្នាំជាដំបូងនិមួយៗ ប្រាក់ប្រហែល $6 កោដិ នឹងបានប្រើសំរាប់សាលារៀន ហើយ $1 មួយរយ កោដិ សំរាប់ការមើលថៃ ក្មេង និងមតេយ្យសាលា និង $3 កោដិ សំរាប់ការសន្សំប្រាក់របស់រដ្ឋ ដើម្បីសងបំណុល។ ចំនួនសំរាប់ឆ្នាំ 2013-14 ប្រហែលនឹងខ្ពស់ជាង ដោយព្រោះការចែកចាយថវិកាបន្ថែម ដែលបានមកក្នុងឆ្នាំ 2012-13។
- ចាប់តាំងពីឆ្នាំ 2017-18 រហូតដល់ឆ្នាំ 2024-25 ចំណែកដែលចំណាយទៅលើសាលារៀន ការមើលថៃក្មេង និងមតេយ្យសាលា អាចនឹងខ្ពស់ជាង ហើយចំណែកចំណាយលើការសងបំណុលនឹងទាបជាង។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### ទិដ្ឋភាពទូទៅ

វិធានការនេះ បង្កើនពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនទៅលើអ្នកបង់ពន្ធភាគច្រើននៅរដ្ឋកាលីហ្វ័រញ៉ា ចាប់ពីឆ្នាំ 2013 រហូតដល់ឆ្នាំ 2024។ ប្រាក់ចំណូលដែលបានបង្កើនដោយកំណើនពន្ធនេះនឹងត្រូវចំណាយទៅលើសាលារៀនរដ្ឋ កម្មវិធី ថែទាំកុមារ និង មត្តេយ្យសិក្សា ព្រមទាំងការសងបំណុលរបស់រដ្ឋ។ ខថែងសំខាន់ៗនៃវិធានការនីមួយៗ ត្រូវបានពិភាក្សាលម្អិតថែមទៀតដូចខាងក្រោម។

### ពន្ធរដ្ឋ និងប្រាក់ចំណូល

38

### សាវតារ

***ពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន (PIT)***។ PIT គឺជាពន្ធទៅលើប្រាក់ឈ្នួល អាជីវកម្ម ការវិនិយោគ និងប្រាក់ចំណូលផ្សេងៗរបស់បុគ្គល និងគ្រួសារ។ អត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួនរបស់រដ្ឋ មានចាប់ពី 1 ភាគរយ ដល់ 9.3 ភាគរយ ទៅលើភាគនៃប្រាក់ចំណូលរបស់អ្នកជាប់ពន្ធម្នាក់ នៅក្នុងក្រុមនីមួយៗនៃក្រុមប្រាក់ចំណូលជាច្រើន។ (ទាំងនេះសំដៅទៅលើអត្រាពន្ធឯកត្តាបន្ថែម។) អត្រាពន្ធឯកត្តាបន្ថែមដែលខ្ពស់ជាងនេះ ត្រូវបានគិតថ្លៃដូចកំណើនប្រាក់ចំណូលដែរ។ ប្រាក់ចំណូលពន្ធដែលបង្កើតចេញពីពន្ធនេះ-ដែលចំនួនសរុបគឺ $49.4 សែសិបប្រាំបួនពាន់កោដិ និងបួនលាន ដុល្លារ នៅអំឡុងឆ្នាំសារពើពន្ធ 2010–11 - ត្រូវបានដាក់បញ្ចូលចូលក្នុងកញ្ចប់ថវិកាទូទៅរបស់រដ្ឋ។ បន្ថែម ពីលើ នេះទៀត ពន្ធបន្ថែម 1 ភាគរយទៀត ត្រូវបានអនុវត្តចំពោះប្រាក់ចំណូលប្រចាំឆ្នាំ ដែលលើសពី $1 លានដុល្លារ (ជាមួយនឹងប្រាក់ចំណូលពាក់ព័ន្ធ ដែលបានកំណត់ទុកជូនសេវាសុខភាពផ្លូវចិត្ត)។

### សេចក្តីស្នើច្បាប់

***ការបង្កើនអត្រាពន្ធ PIT***។ វិធានការនេះ បង្កើនអត្រា PIT របស់រដ្ឋលើក្រុមទាំងអស់ លើកលែងតែក្រុមប្រាក់ចំណូលទាបបំផុត ដែលមានសុពលភាពលើសពីរយៈពេល 12 ឆ្នាំ ចាប់ពីឆ្នាំ 2013 ដល់ឆ្នាំ 2024។ ដូចបង្ហាញនៅក្នុងតារាងទី 1 អត្រាពន្ធឯកត្តាបន្ថែម នឹងមានការកើនឡើង ជាមួយនឹងក្រុមពន្ធខ្ពស់ជាងមុននីមួយៗ។ ឧទាហរណ៍ សម្រាប់អ្នកប្រកាសពន្ធរួមគ្នា នឹងត្រូវបង់ក្នុងអត្រាពន្ធឯកត្តាបន្ថែម 0.7 ភាគរយថែមទៀត ទៅលើប្រាក់ចំណូលចន្លោះពី $34,692 ដុល្លារ និង $54,754 ដុល្លារ ដែលបង្កើនអត្រាសរុបដល់ 4.7 ភាគរយ។ ស្រដៀងគ្នានេះដែរ អត្រាពន្ធឯកត្តាបន្ថែម 1.1 ភាគរយបន្ថែមនឹងត្រូវតំរូវឲ្យបង់ចំពោះប្រាក់ចំណូលចន្លោះពី $54,754 ដុល្លារ និង $76,008 ដុល្លារ ដែលបង្កើនអត្រាសរុបដល់ទៅ 7.1 ភាគរយ។ អត្រាពន្ធដ៏ខ្ពស់ជាងមុនទាំងនេះ នឹងបណ្តាលឲ្យមានបំណុលពន្ធកាន់តែខ្ពស់ជាងមុន ទៅលើប្រាក់ចំណូល PIT របស់រដ្ឋប្រហែល 60 ភាគរយ។ (ឥណទានពន្ធផ្ទាល់ខ្លួន អ្នកក្នុងបន្ទុក មនុស្សចាស់ និងឥណទានពន្ធផ្សេងៗទៀត ក្នុងចំណោមកត្តាផ្សេងៗ នឹងបន្តលុបបំបាត់បំណុលពន្ធទាំងអស់សម្រាប់អ្នកប្រកាសពន្ធប្រាក់ចំណូលទាបជាច្រើននាក់ សូម្បីតែពួកគេមានប្រាក់ចំណូលនៅក្នុងកំរិតប្រាក់ចំណូល ដែលរងការប៉ះពាល់ដោយការបង្កើនអត្រារបស់វិធានការនេះក៏ដោយ។) អត្រា 1 ភាគរយបន្ថែម សម្រាប់សេវាសុខភាពផ្លូវចិត្ត នឹងនៅតែអនុវត្តចំពោះប្រាក់ចំណូលលើសពី $1 លានដុល្លារដដែល។ ដូច្នេះ ការផ្លាស់ប្តូរអត្រារបស់វិធានការនេះ នឹងបង្កើនអត្រា

# ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំបូង។ លក្ខន្តិកៈផ្តួចផ្តើម។



**តារាងទី 1**

**អត្រាពន្ធប្រាក់ចំណូលបច្ចុប្បន្ន និងគម្រោងសុំក្រោម សំណើប្រជាមតិលេខ 38**

| អ្នកបំពេញពន្ធដារម្នាក់ឯង ប្រាក់ចំណូលជាប់ពន្ធ[a] | អ្នកបំពេញពន្ធដាររួមគ្នា ប្រាក់ចំណូលជាប់ពន្ធ[a] | អ្នកបំពេញពន្ធដារជាមេគ្រួសារ ប្រាក់ចំណូលជាប់ពន្ធ[a] | អត្រាពន្ធកំរិតកំណត់បច្ចុប្បន្ន[b] | គម្រោងសុំបន្ថែមនៃអត្រាពន្ធកំរិតកំណត់[b] |
|---|---|---|---|---|
| $0-$7,316 | $0-$14,632 | $0-$14,642 | 1.0% | - |
| 7,316-17,346 | 14,632-34,692 | 14,642-34,692 | 2.0 | 0.4% |
| 17,346-27,377 | 34,692-54,754 | 34,692-44,721 | 4.0 | 0.7 |
| 27,377-38,004 | 54,754-76,008 | 44,721-55,348 | 6.0 | 1.1 |
| 38,004-48,029 | 76,008-96,058 | 55,348-65,376 | 8.0 | 1.4 |
| 48,029-100,000 | 96,058-200,000 | 65,376-136,118 | 9.3 | 1.6 |
| 100,000,250,000 | 200,000-500,000 | 136,118-340,294 | 9.3 | 1.8 |
| 250,000-500,000 | 500,000-1,000,000 | 340,294-680,589 | 9.3 | 1.9 |
| 500,00-1,000,000 | 1,000,000-2,000,000 | 680,589-1,361,178 | 9.3 | 2.0 |
| 1,000,000-2,500,000 | 2,000,000-5,000,000 | 1,361,178-3,402,944 | 9.3 | 2.1 |
| លើស 2,500,000 | លើស 5,000,000 | លើស 3,402,944 | 9.3 | 2.2 |

[a] ឃ្នៀបនៃប្រាក់ចំណូលបានបង្ហាញគឺត្រូវចូលជាធរមាន សំរាប់ឆ្នាំ 2011 និងត្រូវលៃសំរួលសំរាប់អតិផរណា នៅឆ្នាំអនាគត។ អ្នកបំពេញពន្ធដារម្នាក់ឯង រួមទាំង បុគ្គលបានរៀបការ និងដៃគូភេទដូចគ្នាមានចុះឈ្មោះ (RDPS) ដែលបំពេញពន្ធដារប្រចាំឆ្នាំដាច់ដោយឡែក។ អ្នកបំពេញពន្ធដាររួមគ្នា រួមទាំងអ្នកបានរៀបការ និង ដៃគូភេទដូចគ្នា RDP ដែលបំពេញពន្ធដាររួមគ្នា ព្រមទាំងជនពោះម៉ាយ ឬមេម៉ាយដែលមានគុណសម្បត្តិ នឹងកូនក្រោមបន្ទុក។

[b] អត្រាពន្ធកំរិតកំណត់អនុវត្តលើប្រាក់ចំណូលជាប់ពន្ធក្នុងឃ្នៀបពន្ធដារដែលមានរាយឈ្មោះ។ ឧទាហរណ៍ អ្នកបំពេញពន្ធដារម្នាក់ឯងដែមានប្រាក់ចំណូលជាប់ពន្ធចំនួន $15,000 នាឆ្នាំ 2011 អាចមានអត្រាពន្ធ $227: ជាចំនួនបូកនៃ $73(ដែលស្មើនឹង 1 ភាគរយនៃចំនួន $7,316 នៃប្រាក់ចំណូលរបស់អ្នកបំពេញ) និង $154 (2 ភាគរយនៃប្រាក់ចំណូលលើសពី $7,316 របស់អ្នកបំពេញពន្ធដារ)។ កាតព្វកិច្ចពន្ធដារនេះនឹងត្រូវបន្ថយចុះ ហើយអាចជាសក្តានុពលនៃការបំបាត់ ដោយអ្នកនៅក្រោមបន្ទុកផ្ទាល់ខ្លួន, ព្រឹទ្ធាចារ្យ, និងឥណទានពន្ធដ៏ទៃទៀត, ក្នុងចំណោមកត្តាសផ្សេងៗទៀត។ គម្រោងសុំអត្រាពន្ធបន្ថែមនឹងត្រូវចូលជាធរមានចាប់ផ្តើមក្នុងឆ្នាំ 2013 ហើយត្រូវចប់នៅឆ្នាំ 2024។ អត្រាពន្ធបច្ចុប្បន្នដែលមានរាយនោះមិនមានបញ្ចូលអត្រាពន្ធសំរាប់សុខភាពផ្លូវចិត្ត នៃ 1 ភាគរយសំរាប់ប្រាក់ចំណូលជាប់ពន្ធដែលលើសពី $1លានដុល្លារ។

PIT លើឯកត្តាបន្ថែម របស់អ្នកជាប់ពន្ធទាំងនេះចាប់ពី 10.3 ភាគរយ ដល់ 12.5 ភាគរយ។ សំណើប្រជាមតិលេខ 30 លើសន្លឹកឆ្នោតនេះ ក៏នឹងបង្កើនអត្រាពន្ធ PIT ផងដែរ។ ប្រអប់ដែលនៅជិត រៀបរាប់ពីអ្វីដែលនឹងកើតឡើង ប្រសិនបើវិធានការទាំងពីរត្រូវបានយល់ព្រម។

***ផ្តល់ថវិកាសម្រាប់សាលារៀនសាធារណៈ ការថែទាំ និងការអប់រំវ័យក្មេង (ECE) និងសេវាផ្តល់បំណុល។*** ហ្យក់ចំណូលដែលត្រូវបានរៃអង្គាសបានតាមវិធានការនេះ នឹងត្រូវដាក់ចូលទៅក្នុងមូលនិធិក្នុងភារៈគ្រប់គ្រងផ្នែកអប់រំរដ្ឋកាលីហ្វ័រញ៉ា (CETF) ដែលទើបបង្កើតថ្មី។ មូលនិធិទាំងនេះ នឹងត្រូវបានប្តេជ្ញាទាងស្រុងចំពោះគោលបំណងតែបីគត់។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី 2 នៅឆ្នាំ 2013–14 និង 2014–15 វិធានការនេះបែងចែក 60 ភាគរយទៅមូលនិធិ CETF សំរាប់សលា, 10 ភាគរយនៃមូលនិធិ CETF

**តារាងទី 2**

**ការលៃទុកប្រាក់ចំណូលដែលតំឡើងដោយសំណើប្រជា មតិលេខ 38**

| | ឆ្នាំ2013-14 និងឆ្ន 2014-15 | ឆ្នាំ2015-16 និងឆ្នាំ 2016-17 | ឆ្នាំ2017-18 រហូតដល់ ឆ្នាំ2023-24 |
|---|---|---|---|
| សាលា | 60% | 60% | 85% |
| ការថៃទាំវ័យ | 10 | 10 | 15 |
| ការបង់ថ្លៃបំណុលរដ្ឋ | 30 | 30[a] | —[a] |
| **សរុប** | **100%** | **100%** | **100%** |
| កំរិតលូតលាស់ លើការលៃទុកប្រាក់ចំណូលទៅសាលា និង កម្មវិធី ECE[a] | ទេ | បាទ/ចាស | បាទ/ចាស |

[a] ឆ្លុះបញ្ចាំងនូវភាគចំណែកមធ្យមដែលបំរុងទុកសំរាប់ការបង់សងលើបំណុលរដ្ឋ។ ប្រាក់ចំណូលលើសពីកំរិតការលូត លាស់ក៏អាចប្រើសំរាប់សងប្រាក់បំណុលបានដែរ។

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 38, សូមអានទំព័រ 113។*

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ (ត)**

ដល់សាលារៀន 10 ភាគរយនៃថវិកាសម្រាប់កម្មវិធី ECE និង 30 ភាគរយនៃថវិកាគឺសម្រាប់ទូទាត់បំណុលរបស់រដ្ឋ។ នៅឆ្នាំ 2015–16 និង 2016–17 ការបែងចែកជាទូទៅដូចគ្នានេះ ត្រូវបានអនុញ្ញាត

**តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកបោះឆ្នោតអនុម័តទៅលើសំណើប្រជាមតិលេខ 30 ផង និងសំណើប្រជាមតិ លេខ 38 ផង?**

***រដ្ឋធម្មនុញ្ញរបស់រដ្ឋបញ្ជាក់លម្អិតអំពីអ្វីដែលនឹងកើតឡើង ប្រសិនបើវិធានការពីរមានទំនាស់នឹងគ្នា។*** ប្រសិនបើខចែងទាំងឡាយនៃវិធានការទាំងពីរ ដែលត្រូវបានអនុម័តនៅលើសន្លឹកឆ្នោតទូទាំងរដ្ឋដូចគ្នា មានទំនាស់នឹងគ្នានោះរដ្ឋធម្មនុញ្ញបញ្ជាក់លម្អិតថា ខចែងទាំងឡាយនៃវិធានការដែលទទួលបានសន្លឹកឆ្នោត"យល់ព្រម" ច្រើនជាងត្រូវឈ្នះ។ សំណើប្រជាមតិ 30 និងសំណើប្រជាមតិ 38 នៅលើសន្លឹកឆ្នោតទូទាំងរដ្ឋនេះ បង្កើនអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន (PIT) ហើយអាចចាត់ទុកថាមានទំនាស់នឹងគ្នា។

***វិធានការបានចែងថា មានតែការបង្កើនពន្ធមួយសំណុំប៉ុណ្ណោះ ដែលចូលជាធរមាន។*** ទាំងសំណើប្រជាមតិលេខ 30 និងសំណើប្រជាមតិលេខ 38 មានផ្នែកទាំងឡាយ ដែលត្រូវបានបម្រុងសម្រាប់បញ្ជាក់ថាខចែងទាំងឡាយនឹងចូលជាធរមាន ប្រសិនបើវិធានការទាំងពីរនេះអនុម័តៈ

- ***ប្រសិនបើសំណើប្រជាមតិលេខ 30 ទទួលបានសន្លឹកឆ្នោតយល់ព្រមច្រើនជាង។*** សំណើប្រជាមតិលេខ 30 មានផ្នែកមួយដែលបញ្ជាក់ថាខចែងរបស់វានឹងឈ្នះទាំងស្រុង ហើយគ្មានខចែងណាមួយនៃវិធានការផ្សេងទៀតដែលបង្កើនអត្រា PIT នោះទេ — ដែលក្នុងករណីនេះសំណើប្រជាមតិលេខ 38 — នឹងចូលជាធរមានឡើយ។
- ***ប្រសិនបើសំណើប្រជាមតិលេខ 38 ទទួលបានសន្លឹកឆ្នោតយល់ព្រមច្រើនជាង។*** សំណើប្រជាមតិលេខ 38 មានផ្នែកមួយ ដែលបញ្ជាក់ថា ខចែងរបស់វានឹងឈ្នះ ហើយខចែងអំពីអត្រាពន្ធនៃវិធានការណាមួយផ្សេងទៀតដែលប៉ះពាល់ដល់អត្រាពន្ធលក់ដូរ និងអត្រា PIT —ដែលក្នុងករណីនេះសំណើប្រជាមតិលេខ 30 —នឹងមិនចូលជាធរមានឡើយ។ ក្រោមសេណារីយ៉ូនេះ ការកាត់បន្ថយចំណាយឈ្មោះ "ការកាត់ដោយគ្មានការឆ្លើយតប" នឹងមានសុពលភាពក្រោយលទ្ធផលនៃការបង្កើនពន្ធ របស់សំណើប្រជាមតិលេខ 30 ដែលមិនចូលជាធរមាន។ (សូមមើលការវិភាគនៃសំណើប្រជាមតិលេខ 30 សម្រាប់ព័ត៌មានបន្ថែមអំពីការកាត់ដោយគ្មានការឆ្លើយតប។)

ប៉ុន្តែចំណែកមួយ ដែលខ្ពស់ជាងមុនបន្តិចបន្តួច អាចត្រូវបានប្រើសម្រាប់ការបង់បំណុលរបស់រដ្ឋ។ នេះដោយសារតែ ចាប់ពីឆ្នាំ 2015–16 តទៅ វិធានការៈ (1) កម្រិតកំណើននៃការបែងចែកសរុប សម្រាប់សាលារៀន និងកម្មវិធី ECE ផ្អែកលើកំណើនជាមធ្យមនៅរដ្ឋកាលីហ្វ័រញ៉ា សម្រាប់ទុនប្រាក់ចំណូលផ្ទាល់ខ្លួន ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក និង (2) ប្តេជ្ញាផ្តល់ថវិកាដែលប្រមូលបានលើសអត្រាកំណើន សម្រាប់ការសងបំណុលរបស់រដ្ឋ។ ចាប់ពីឆ្នាំ 2017–18 រហូតដល់ឆ្នាំ 2023–24 ថវិកា CETF រហូតដល់ទៅ 85 ភាគរយ នឹងបានទៅសាលារៀន និងរហូតដល់ទៅ 15 ភាគរយ នឹងទៅកម្មវិធី ECE ដែលមានប្រាក់ចំណូលលើសអត្រាកំណើន ត្រូវបានបន្តប្រើសម្រាប់ការសងបំណុលរបស់ រដ្ឋ។

***មិនអាចធ្វើវិសោធនកម្មដោយអង្គនីតិបញ្ញត្តិ។*** ប្រសិនបើត្រូវបានអនុម័តដោយអ្នកបោះឆ្នោត វិធានការនេះអាចត្រូវបានធ្វើវិសោធនកម្មដោយវិធានការបោះឆ្នោតនៅពេលអនាគតតែម្យ៉ាងប៉ុណ្ណោះ។ អង្គនីតិបញ្ញត្តិ នឹងត្រូវបានហាមឃាត់មិនឲ្យធ្វើការកែប្រែណាមួយ ទៅលើវិធានការដោយគ្មានការយល់ព្រមពីអ្នកបោះឆ្នោតឡើយ។

## ឥទ្ធិពលសារពើពន្ធ

***ប្រហែល $10 មួយពាន់កោដិដុល្លារ នៃប្រាក់ចំណូលរដ្ឋប្រចាំឆ្នាំបន្ថែមទៀត។*** នៅក្នុងឆ្នាំដំបូងៗ ដែលចាប់ផ្តើមនៅឆ្នាំ 2013–14 - ចំនួនថវិកាប្រចាំឆ្នាំនៃប្រាក់ចំណូលរដ្ឋបន្ថែមដែលរៃអង្គាសបាន នឹងមានប្រហែល $10 មួយពាន់លានដុល្លារ។ (នៅឆ្នាំ 2012–13 វិធានការនេះ នឹងបណ្តាលឲ្យមានប្រាក់ចំណូលរដ្ឋបន្ថែមប្រហែលពាក់កណ្តាលចំនួននេះ។) ប្រាក់ចំណូលសរុបដែលរកបាននឹងមានទំនោរកើនឡើងតាមពេលវេលា។ ទោះបីជាយ៉ាងណា ប្រាក់ចំណូលដែលរកបាននៅឆ្នាំជាក់លាក់ណាមួយ អាចនឹងខ្ពស់ជាងមុន ឬទាបជាងឆ្នាំមុន។ មូលហេតុចម្បងគឺ វិធានការនេះ បង្កើនអត្រាពន្ធបន្ថែមចំពោះអ្នកជាប់ពន្ធប្រាក់ចំណូលកម្រិតខ្ពស់។ ប្រាក់ចំណូលនៃបុគ្គលទាំងនេះ អាចនឹងប្រែប្រួលកាន់តែច្រើន ពីព្រោះវារងការប៉ះពាល់ពីកម្រិតខ្ពស់ជាងមុនខ្លាំង ដោយសារការប្រែប្រួលផ្សារភាគហ៊ុន តម្លៃផ្ទះសម្បែង និងការវិនិយោគផ្សេងៗ។ ដោយសារតែមានការប្រែប្រួលប្រាក់ចំណូល នៃអ្នកជាប់ពន្ធទាំងនេះ និងភាពមិនច្បាស់លាស់នៃការឆ្លើយតបរបស់ពួកគេចំពោះកំណើនអត្រា ប្រាក់ចំណូលដែលរៃបានដោយវិធានការនេះ មានការពិបាកក្នុងការប៉ាន់ស្មាន។

## សាលា

### សាវតារ

***ការផ្តល់ថវិកាដល់សាលារៀនសាធារណៈភាគច្រើនចងភ្ជាប់ទៅនឹងរូបមន្តផ្តល់ថវិការបស់រដ្ឋ។*** រដ្ឋកាលីហ្វ័រញ៉ា ផ្តល់សេវាអប់រំដល់សិស្សសាលារៀនសាធារណៈប្រហែល 6 លាននាក់។ សិស្សទាំងនេះ ត្រូវបានបម្រើតាមរយៈភ្នាក់ងារអប់រំក្នុងមូលដ្ឋានច្រើនជាង 1,000 ភ្នាក់ងារ - ដែលភាគច្រើនគឺការិយាល័យអប់រំស្រុក។ ការផ្តល់ថវិកាដល់សាលារៀនភាគច្រើន ត្រូវបានផ្តល់តាមរយៈរូបមន្តផ្តល់ថវិកាដល់សាលារៀនរបស់រដ្ឋ- ដែលហៅជារួមថាការធានាជាអប្បបរមានៃសំណើប្រជាមតិលេខ 98។ (ការផ្តល់ថវិកាដល់មហាវិទ្យាល័យសហគមន៍ ក៏អនុវត្តចំពោះការឆ្លើយតបនឹងការធានាជាអប្បបរមាផងដែរ។) ការធានាជាអប្បបរមា ត្រូវបានផ្តល់ថវិកាតាមរយៈការរួមបញ្ចូលគ្នានូវកញ្ចប់ថវិកាទូទៅរបស់រដ្ឋ និងប្រាក់ចំណូលពន្ធអចលនទ្រព្យក្នុងមូលដ្ឋាន។ នៅឆ្នាំ 2010–11 សាលារៀនទទួលបាន $43 បួនពាន់បីកោដិដុល្លារពីរូបមន្តផ្តល់ថវិកាដល់សាលារៀន។

***សេចក្តីសម្រេចក្នុងការចំណាយរបស់សាលារៀនភាគច្រើន ត្រូវបានធ្វើឡើងដោយគណៈគ្រប់គ្រងក្នុងមូលដ្ឋាន។*** ប្រហែល 70ភាគរយនៃការផ្តល់ថវិកាដល់សាលារៀនដែលពាក់ព័ន្ធនឹងរដ្ឋ អាចត្រូវបានប្រើសម្រាប់គោលបំណងអប់រំណាមួយក៏បាន។ ក្នុងករណីភាគច្រើនគណៈគ្រប់គ្រងការិយាល័យអប់រំស្រុក សម្រេចទៅលើរបៀបចំណាយថវិការបស់សាលារៀន។ ជា

# សំណើប្រជាមតិ 38 ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំបូង។ លក្ខន្តិកៈផ្តួចផ្តើម។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ (ត)

ទូទៅ គណៈគ្រប់គ្រងនឹងកំណត់អំពីសកម្មភាពជាក់លាក់ សម្រាប់ថវិកាដែលនឹងត្រូវប្រើប្រាស់ ក៏ដូចជា របៀបចែកចាយថវិកាក្នុងចំណោមទីតាំងសាលារៀននៅក្នុងស្រុក។ ថវិកា 30 ភាគរយដែលនៅសេសសល់ ត្រូវតែប្រើសម្រាប់គោលបំណងដែលបានបញ្ជាក់លម្អិត ដូចជា ការបម្រើអាហារនៅតាមសាលារៀន ឬការដឹកជញ្ជូនសិស្សទៅមកសាលារៀនជាដើម។ ជាទូទៅការិយាល័យអប់រំស្រុកមានភាពបត់បែនតិចតួច នៅក្នុងរបៀបប្រើថវិកាដែលមានការរឹតត្បិតនេះ។

### សេចក្តីស្នើច្បាប់

ក្រោមវិធានការនេះ សាលារៀននឹងទទួលបានប្រហែល 60 ភាគរយនៃប្រាក់ចំណូលដែលរដ្ឋបានតាមកំណើនអត្រា PIT រហូតដល់ឆ្នាំ 2016–17 និងក្រោយមកទៀត ប្រហែល 85 ភាគរយប្រចាំឆ្នាំ។ ថវិកា CETF ទាំងនេះ នឹងបន្ថែមទៅលើការគាំទ្រកញ្ចប់ថវិកាទូទៅនៃសំណើប្រជាមតិលេខ 98 សម្រាប់សាលារៀន។ ថវិកាទាំងនេះគាំទ្រដល់កម្មវិធីផ្តល់ជំនួយចំនួនបី។ វិធានការនេះ ក៏បង្កើតការរឹតត្បិតក្នុងការចំណាយ និងលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ដែលទាក់ទងនឹងថវិកាទាំងនេះផងដែរ។ ខចែងចម្បងៗទាំងនេះ ត្រូវបានពិភាក្សាលម្អិតបន្ថែមនៅខាងក្រោម។

***ចែកចាយថវិកាដល់សាលារៀនតាមរយៈកម្មវិធីផ្តល់ជំនួយចំនួនបី។*** សំណើប្រជាមតិលេខ 38 តម្រូវឲ្យបែងចែកថវិកាសាលារៀន CETF ដូចខាងក្រោម៖

- ***ហូក់ជំនួយកម្មវិធីអប់រំ (70 ភាគរយនៃមូលនិធិ)។ ចំណែកធំបំផុតនៃថវិកា*** - 70 ភាគរយនៃថវិកាសាលារៀន CETF - នឹងត្រូវបានចែកចាយ ដោយផ្អែកលើចំនួនសិស្សនៅតាមសាលារៀននីមួយៗ។ ទោះបីជាយ៉ាងណា ជំនួយជាក់លាក់សម្រាប់សិស្សម្នាក់ៗ នឹងអាស្រ័យទៅលើកម្រិតថ្នាក់នៃសិស្សម្នាក់ៗជាមួយនឹងសាលារៀនដែលទទួលបានថវិកាច្រើនជាងមុន សម្រាប់សិស្សថ្នាក់ខ្ពស់។ ជំនួយកម្មវិធីអប់រំអាចចំណាយទៅលើកម្មវិធីនានា រួមមាន ការបង្រៀនណែនាំបុគ្គលិកគាំទ្រសាលារៀន (ដូចជា អ្នកផ្តល់ប្រឹក្សា និងបណ្ណារក្សនិងការចូលរួមរបស់មាតាបិតាសិស្ស។
- ***ប្រាក់ជំនួយសម្រាប់សិស្សមានប្រាក់ចំណូលទាប (18 ភាគរយនៃថវិកា)។*** វិធានការនេះ តម្រូវឲ្យបែងចែក 18 ភាគរយនៃថវិកាសាលារៀន CETF តាមអត្រាមួយទូទាំងរដ្ឋ ដោយផ្អែកទៅលើចំនួនសិស្សមានប្រាក់ចំណូលទាប (ដែលត្រូវបានកំណត់និយមន័យថា ចំនួនសិស្សដែលមានសិទ្ធិទទួលបានអាហារនៅសាលារៀនដោយឥតគិតថ្លៃ) ដែលបានចុះឈ្មោះនៅតាមសាលារៀននីមួយៗ។ ជាមួយនឹងជំនួយកម្មវិធីអប់រំ ជំនួយសម្រាប់សិស្សមានប្រាក់ចំណូលទាប អាចត្រូវបានចំណាយទៅលើប្រភេទផ្សេងៗនៃសកម្មភាពអប់រំយ៉ាងទូលំទូលាយ។
- ***ជំនួយសម្រាប់ការបណ្តុះបណ្តាល បច្ចេកវិទ្យា និងសម្ភារៈឧបទ្ទេស (12 ភាគរយនៃថវិកា)។*** ថវិកា 12 ភាគរយដែលនៅសេសសល់ នឹងត្រូវបានបែងចែកតាមអត្រាមួយទូទាំងរដ្ឋ ដោយផ្អែកលើចំនួនសិស្សនៅតាមសាលារៀននីមួយៗ។ ថវិកានេះ អាចប្រើសម្រាប់តែការបណ្តុះបណ្តាបុគ្គលិក និងការទិញបច្ចេកវិទ្យា និងសម្ភារៈឧបទ្ទេសទាន់សម័យប៉ុណ្ណោះ។

***តម្រូវឲ្យចំណាយថវិកាតាមទីតាំងសាលារៀនដែលឆ្លើយតប។*** ថវិកាដែលការិយាល័យអប់រំស្រុកទទួលបានពីវិធានការនេះ ត្រូវតែចំណាយនៅតាមសាលារៀនជាក់លាក់ ដែលមានសិស្ស បង្កើតថវិកា។ ឧទាហរណ៍ ក្នុងករណីជំនួយសម្រាប់សិស្សមានប្រាក់ចំណូលទាប ប្រសិនបើ 100 ភាគរយនៃសិស្សមានប្រាក់ចំណូលទាបនៅក្នុងការិយាល័យអប់រំស្រុកមួយមានទីតាំងនៅក្នុងសាលារៀនជាក់លាក់មួយនោះថវិកាជំនួយសម្រាប់សិស្សមានប្រាក់ចំណូលទាប នឹងត្រូវចំណាយនៅតាមសាលារៀនជាក់លាក់នោះ។ ទោះបីជាយ៉ាងណាជាមួយនឹងភាគច្រើននៃថវិកាសាលារៀនផ្សេងទៀត គណៈគ្រប់គ្រងក្នុងមូលដ្ឋាន នឹងកំណត់អំពីរបៀបដែលថវិកា CETF ត្រូវបានចំណាយនៅតាមសាលារៀននីមួយៗ។ ដើម្បីធានាថា ថវិការបស់សំណើប្រជាមតិលេខ 38 នឹងផ្តល់នូវកំណើនសរុបនៃថវិកាសម្រាប់សាលារៀនទាំងអស់ វិធានការនេះក៏នឹងតម្រូវឲ្យការិយាល័យអប់រំស្រុក ខិតខំប្រឹងប្រែងដោយសមហេតុផល ដើម្បីចៀសវាងការកាត់បន្ថយថវិកាសម្រាប់សិស្សម្នាក់ៗ ពីប្រភពមិនមែនជាមូលនិធិក្នុងភារៈគ្រប់គ្រងផ្នែកអប់រំរដ្ឋកាលីហ្វ័រញ៉ា នៅតាមទីតាំងសាលារៀននីមួយៗ ក្រោមកម្រិតឆ្នាំ 2012–13។ ប្រសិនបើការិយាល័យអប់រំស្រុក កាត់បន្ថយថវិកាសម្រាប់សិស្សម្នាក់ៗសម្រាប់ទីតាំងសាលារៀនក្រោមកម្រិតឆ្នាំ 2012–13ត្រូវពន្យល់អំពីមូលហេតុនៃការកាត់បន្ថយ នៅក្នុងកិច្ចប្រជុំសាធារណៈ ដែលរៀបចំឡើងនៅសាលារៀន ឬជិតសាលារៀន។

***តម្រូវឲ្យការិយាល័យអប់រំស្រុក ស្វែងរកការចូលរួមពីសាធារណជន មុនពេលធ្វើសេចក្តីសម្រេចចិត្តក្នុងការចំណាយ។*** សំណើប្រជាមតិលេខ 38 ក៏តម្រូវឲ្យគណៈគ្រប់គ្រងការិយាល័យគ្រប់គ្រងអប់រំស្រុកនៅក្នុងសវនាការសាធារណៈឲ្យស្វែងរកការចូលរួមពីសិស្សានុសិស្ស មាតាបិតា គ្រូបង្រៀន អ្នកគ្រប់គ្រងរដ្ឋបាល និងបុគ្គលិកសាលាដទៃទៀត អំពីរបៀបចំណាយថវិកាសាលារៀន CETF។ នៅពេលគណៈគ្រប់គ្រងសម្រេចអំពីរបៀបចំណាយថវិការួចហើយ ត្រូវពន្យល់-ជាសាធារណៈ និងតាមបណ្តាញអ៊ីនធើណិត- អំពីរបៀបដែលចំណាយសាលារៀន CETF នឹងកែលម្អលទ្ធផលនៃការអប់រំ និងរបៀបដែលលទ្ធផលដែលបានកែលម្អនោះ នឹងត្រូវបានវាស់វែង។

***បង្កើតលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ថវិកា សម្រាប់សាលារៀននីមួយៗ។*** វិធានការនេះ ក៏ដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវជាច្រើនក្នុងការរាយការណ៍ សម្រាប់ការិយាល័យអប់រំស្រុកផងដែរ។ អ្វីដែលគួរឲ្យកត់សម្គាល់បំផុតនោះគឺ ចាប់ពីឆ្នាំ 2012–13 វិធានការនេះតម្រូវឲ្យការិយាល័យអប់រំស្រុកទាំងអស់ បង្កើត និងបោះពុម្ពផ្សាយគម្រោងថវិកាតាមបណ្តាញអ៊ីនធើណែត សម្រាប់សាលារៀននីមួយៗរបស់ខ្លួន។ គម្រោងថវិកាត្រូវបង្ហាញអំពីថវិកា និងការចំណាយនៅតាមសាលារៀននីមួយៗពីប្រភពថវិកាទាំងអស់ ដែលបានបែងចែកដោយប្រភេទការចំណាយផ្សេងៗ។ មន្ត្រីមើលការខុសត្រូវខាងការណែនាំសាធារណៈនៃសាលារៀនរដ្ឋ (State Superintendent of Public Instruction) ត្រូវផ្តល់ទ្រង់ទ្រាយឯកសណ្ឋាន មួយ សម្រាប់គម្រោងថវិកាដែលត្រូវរាយការណ៍ ហើយត្រូវធ្វើឲ្យគម្រោងថវិកាទាំងអស់របស់សា

38

លារៀនមានលទ្ធភាពអាចប្រើប្រាស់បានសម្រាប់សាធារណជន រួមមានទិន្នន័យពីឆ្នាំមុនៗជាដើម។ បន្ថែមពីលើនេះទៀត ការិយាល័យអប់រំស្រុក ត្រូវផ្តល់របាយការណ៍មួយស្តីពីរបៀបដែលថវិកា CETF ត្រូវបានចំណាយនៅតាមសាលារៀននីមួយៗរបស់ខ្លួន ក្នុងរយៈពេល 60 ថ្ងៃក្រោយពេលបិទឆ្នាំសិក្សា។

***ប្រាក់ឧបត្ថម្ភ និងការហាមឃាត់ផ្សេងៗ។*** វិធានការនេះ អនុញ្ញាតឲ្យមានការចំណាយរហូតដល់ 1ភាគរយនៃការបែងចែករបស់ការិយាល័យអប់រំស្រុក ទៅលើការធ្វើគម្រោងថវិកា ការធ្វើរបាយការណ៍ និងលក្ខខណ្ឌតម្រូវសម្រាប់សវនកម្ម។ វិធានការនេះ ហាមឃាត់មិនឲ្យប្រើមូលនិធិសាលារៀន CETF ដើម្បីផ្តល់កំណើនប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ឡើយ ប្រសិនបើកំណើននោះមិនត្រូវបានផ្តល់ឲ្យអ្នកដទៃទៀតដូចជានិយោជិកដែលត្រូវបានឧបត្ថម្ភដោយថវិកាមិនមែនជាថវិការបស់ CETF។ វិធានការនេះ ក៏មានខចែងដែលហាមឃាត់មិនឲ្យប្រើថវិកាសាលារៀន CETF ដើម្បីជំនួសឲ្យការផ្តល់ថវិការដ្ឋ មូលដ្ឋាន ឬសហព័ន្ធ ដែលបានផ្តល់ចាប់ពីថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2012 ផងដែរ។

### ឥទ្ធិពលសារពើពន្ធ

***ផ្តល់ថវិកាបន្ថែមសម្រាប់សាលារៀន។*** នៅក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូង សាលារៀននឹងទទួលពីវិធានការនេះ ប្រហែល $6 ពាន់លានដុល្លារប្រចាំឆ្នាំ ឬ $1,000 ដុល្លារ សម្រាប់សិស្សម្នាក់។ ក្នុងចំណោមថវិកាទាំងនោះ $4.2 បួនរយពីរកោដិដុល្លារ នឹងត្រូវផ្តល់សម្រាប់ជំនួយកម្មវិធីអប់រំ, $1.1 មួយរយមួយដុល្លារ សម្រាប់ជំនួយសិស្សមានប្រាក់ចំណូលទាប និង $700 លានដុល្លារ សម្រាប់ជំនួយបណ្តុះបណ្តាល បច្ចេកវិទ្យា និងសម្ភារៈឧបទ្ទេស។ (ថវិកាឆ្នាំ 2013–14 នឹងខ្ពស់ជាងមុន ពីព្រោះថវិកាដែលបង្កើននៅឆ្នាំ 2012–13 ក៏នឹងមានលទ្ធភាពអាចប្រើប្រាស់បានសម្រាប់ការចែកចាយផងដែរ។) ថវិកាដែលមានលទ្ធភាពអាចប្រើប្រាស់បាននៅឆ្នាំខាងមុខ នឹងមានកំណើនទៅតាមពេលវេលា។ ចាប់ផ្តើមពីឆ្នាំ 2017–18 តទៅ ថវិកាដែលចំណាយទៅលើសាលារៀន នឹងកើនឡើងថែមទៀត ពីព្រោះថវិកាដែលត្រូវការប្រើប្រាស់សម្រាប់ការទូទាត់បំណុលរដ្ឋ មានការថយចុះយ៉ាងច្រើន។

## ការមើលថែទាំជាមុន និងការអប់រំ

### សាវតារ

***កម្មវិធី ECE បម្រើកុមារអាយុប្រាំឆ្នាំ និងក្មេងជាងនេះ។*** មុននឹងចូលរៀននៅមត្តេយ្យសិក្សា - ដែលជាធម្មតាចាប់ផ្តើមនៅអាយុប្រាំឆ្នាំ -កុមារភាគច្រើននៅរដ្ឋកាលីហ្វ័រញ៉ា ចូលរួមក្នុងប្រភេទខ្លះនៃកម្មវិធី ECE។ គ្រួសារចូលរួមនៅក្នុងកម្មវិធីទាំងនេះ ដោយសារមូលហេតុផ្សេងៗ រួមមានការគ្រប់គ្រងមើលកុមារ ខណៈមាតាបិតាសិស្សកំពុងធ្វើការ និងការអភិវឌ្ឍជំនាញសង្គម និងបញ្ញាញាណរបស់កុមារ។ កម្មវិធីទាំងឡាយដែលបម្រើកុមារ អាយុចាប់ពីទើបនឹងកើតរហូតដល់អាយុបីឆ្នាំ ជាទូទៅសំដៅទៅលើ ការថែទាំទារក និងកូនក្មេងទើបរៀនដើរ។ កម្មវិធីដែលបម្រើកុមារអាយុចាប់ពីបីទៅប្រាំឆ្នាំ តែងតែហៅថា មត្តេយ្យមជ្ឈឹម ហើយជាទូទៅ មានការផ្តោតជាក់លាក់ទៅលើការជួយត្រៀមឲ្យកុមារចូលរៀនថ្នាក់មត្តេយ្យ។ ចំណែកកម្មវិធីទាំងអស់ ត្រូវតែឆ្លើយតបទៅនឹងបទដ្ឋានសុខភាព និងសុវត្ថិភាពមូលដ្ឋាន ដែលនឹងត្រូវផ្តល់អាជ្ញាប័ណ្ណដោយរដ្ឋ ដែលមានលក្ខណៈជាក់លាក់នៃកម្មវិធី - រួមមាន គុណសម្បត្តិបុគ្គលិក ផលធៀបមនុស្សពេញវ័យទៅនឹងកុមារ កម្មវិធីសិក្សា សោហ៊ុយរបស់គ្រួសារ និងថ្លៃថែទាំ - មានការប្រែប្រួល ។

***កុមារមួយចំនួនមានសិទ្ធិទទួលបានសេវា ECE*** ដែលត្រូវបានគេជួយឧបត្ថម្ភ។ ខណៈគ្រួសារជាច្រើនត្រូវបង់បាក្រដើម្បីចូលរួមកម្មវិធី ECE ថវិកាសាធារណៈ ក៏ឧបត្ថម្ភសេវាសម្រាប់កុមារមួយចំនួនផងដែរ។ ជាទូទៅ ការឧបត្ថម្ភទាំងនេះ ត្រូវបានបម្រុងសម្រាប់គ្រួសារទាំងឡាយណាដែលមានប្រាក់ចំណូលទាប  ចូលរួមកម្មវិធីសុខុមាលភាពដើម្បីការងារ ឬការងារ ឬសកម្មភាពបណ្តុះបណ្តាលផ្សេងៗ និង/ឬមានកូនៗដែលមានតម្រូវការពិសេស។ ជាទូទៅ សិទ្ធិទទួលបានការឧបត្ថម្ភកម្មវិធី ECE ត្រូវកម្រិតចំពោះគ្រួសារទាំងឡាយណា ដែលរកប្រាក់ចំណូលបាន 70 ភាគរយ ឬតិចជាងកម្រិតប្រាក់ចំណូលមធ្យមរបស់រដ្ឋ (ឧទាហរណ៍ បច្ចុប្បន្ននេះ កម្រិតគឺ $3,518 ដុល្លារ ក្នុងមួយខែ សម្រាប់គ្រួសារដែលមានកូនបីនាក់)។ រដ្ឋបង់អត្រាសម្រាប់កុមារម្នាក់ដែលបានកំណត់ ជូនទៅអ្នកផ្គត់ផ្គង់ “កន្លែង” ECE ដែលត្រូវបានឧបត្ថម្ភ។ អត្រានៃការបង់ប្រាក់ប្រែប្រួលទៅតាមរដ្ឋ និងទីកន្លែងថែទាំ។ ជាទូទៅ វាមានប្រហែល $1,000 ដុល្លារ ក្នុងមួយខែ សម្រាប់ការថែទាំពេញម៉ោងចំពោះទារក/កូនក្មេងទើបរៀនដើរ និង $700 ដុល្លារ ក្នុងមួយខែ សម្រាប់មត្តេយ្យមជ្ឈឹមពេញម៉ោង។

***កម្រិតផ្តល់ថវិកាបច្ចុប្បន្ន មិនឧបត្ថម្ភកម្មវិធី ECE សម្រាប់កុមារដែលមានសិទ្ធិទទួលបានទាំងអស់នោះទេ។*** នៅឆ្នាំ 2010–11 ថវិការដ្ឋ និងសហព័ន្ធបានផ្តល់បាក្រប្រហែល $2.6 ពាន់លានដុល្លារ ដើម្បីផ្តល់ដល់កម្មវិធីថែទាំកុមារ និងមត្តេយ្យមជ្ឈឹមជាច្រើន ប្រហែល 500,000 នាក់ ឬប្រហែល 15 ភាគរយនៃកុមារអាយុប្រាំឆ្នាំ និងក្មេងជាងនេះនៅរដ្ឋកាលីហ្វ័រញ៉ា។ ទោះបីជាយ៉ាងណា ប្រហែលពាក់កណ្តាលនៃកុមារទាំងអស់នៅរដ្ឋកាលីហ្វ័រញ៉ា ឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យមានសិទ្ធិទទួលបានកម្មវិធីដែលត្រូវបានឧបត្ថម្ភ។ ដោយសារការផ្តល់ថវិកាកម្មវិធី ECE របស់រដ្ឋ និងសហព័ន្ធ មិនគ្រប់គ្រាន់សម្រាប់ផ្តល់សេវាដែលត្រូវបានឧបត្ថម្ភ សម្រាប់កុមារទាំងអស់ដែលមានសិទ្ធិទទួលបាន ជាទូទៅតែងតែមានបញ្ជីរង់ចាំនៅក្នុងបណ្តាខោនធីភាគច្រើន។

### សេចក្តីស្នើច្បាប់

ដូចបានកត់សម្គាល់ពីខាងដើម កម្មវិធី ECE នឹងទទួលបានប្រហែល 10 ភាគរយនៃប្រាក់ចំណូលដែលបានរៃអង្គាសដោយកំណើនអត្រាពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន (PIT) រហូតដល់ឆ្នាំ 2016–17 និងក្រោយមកទៀត ប្រហែល 15 ភាគរយរៀងរាល់ឆ្នាំ។ វិធានការនេះ ផ្តល់ការបែងចែកជាក់លាក់

38

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ (ត)

នៃថវិកាទាំងនេះ ដូចមានសង្ខេបនៅក្នុងតារាងទី 3។ ដូចមានបង្ហាញនៅផ្នែកខាងលើនៃតារាង ថវិកាដែលរំអង្គាសបានសម្រាប់កម្មវិធី ECE រហូតដល់ 23 ភាគរយ នឹងត្រូវបានប្តេជ្ញាប្រើសម្រាប់ស្តារការកាត់បន្ថយគម្រោងថវិការដ្ឋថ្មីៗនេះ ទៅលើមូលនិធិថែទាំកុមារ និងអត្រាប្រាក់ខែសម្រាប់អ្នកផ្តល់ការថែទាំ ក៏ដូចជាការអនុវត្តសកម្មភាពមួយចំនួនទូទាំងរដ្ឋ ដែលបានបង្កើតឡើង ដើម្បីគាំទ្រប្រព័ន្ធ ECE របស់រដ្ឋ។ ថវិកា ECE ដែលនៅសេសសល់ ដែលមានបង្ហាញនៅផ្នែកខាងក្រោមនៃតារាង នឹងពង្រីកកម្មវិធីថែទាំកុមារ និង មត្តេយ្យមជ្ឈឹម ដើម្បីបម្រើកុមារមកពីគ្រួសារមានប្រាក់ចំណូលទាបកាន់តែច្រើន និងបង្កើនអត្រាប្រាក់ខែសម្រាប់អ្នកផ្តល់កម្មវិធី ECE មួយចំនួន។ វិធានការនេះ ក៏ហាមឃាត់មិនឲ្យរដ្ឋកាត់បន្ថយការគាំទ្រដែលមានស្រាប់ សម្រាប់កម្មវិធី ECE ឡើយ។ ជាក់ស្តែង រដ្ឋនឹងត្រូវបានតម្រូវឲ្យចំណាយសមាមាត្រដូចគ្នានៃប្រាក់ចំណូលកញ្ចប់ថវិកាទូទៅរបស់រដ្ឋសម្រាប់កម្មវិធី ECE នៅក្នុងឆ្នាំខាងមុខៗ ដូចការចំណាយនៅឆ្នាំ 2012–13 (ប្រហែល 1 ភាគរយ)។ ដូចដែលបានបរិយាយកាន់តែលម្អិតនៅខាងក្រោម វិធានការនេះរួមបញ្ចូលនូវខចែងទូលំទូលាយដែលទាក់ទងនឹង៖ (1) ប្រព័ន្ធដាក់ពិន្ទុសម្រាប់ការវាយតម្លៃកម្មវិធី ECE (2) មត្តេយ្យមជ្ឈឹម និង (3) ការថែទាំទារក និងកូនក្មេងទើបរៀនដើរ។

**តារាងទី 3**
**សំណើប្រជាមតិលេខ 38 ខមាត្រានៃការថែទាំវ័យក្មេង និងការអប់រំ (ECE) ។**

| គោលបំណង / ការពិពណ៌នា | ភាគរយនៃមូលនិធិសំរាប់ ECE[a] |
|---|---|
| **"ការស្តារឡើងវិញ និងប្រព័ន្ធបសិដ្ឋកម្ម"** | |
| ***ការស្តារកម្មវិធីឡើងវិញ*—** ស្តារការកាត់បន្ថយថវិការដ្ឋមួយ ផ្នែកដែលបានចំណាយសំរាប់ផ្តល់ឧបត្ថម្ភធនដល់កម្មវិធី ECE តាំងពី ឆ្នាំ 2008–09។ ការស្តារឡើងវិញនឹង មានរួមនូវបំរើកុមារបានច្រើន បង្កើន ចំនួនដែលគ្រួសារនិមួយៗអាចរក បាន ហើយអាចនៅតែមានសិទ្ធិ ទទួលកម្រៃ ហើយបង្កើនអត្រាបង់ប្រាក់សំរាប់កុមារមួយរូបៗក្នុងរដ្ឋ។ | 19.4% |
| ***ប្រព័ន្ធអត្រាបង់ប្រាក់*—** បង្កើតប្រព័ន្ធ វាយតំលៃ និងផ្សព្វផ្សាយអត្រា កម្មវិធី ECE ដោយផ្អែកលើរបៀបដែលគេធ្វើវិភាគទានទៅការរៀបចំ កម្មវិធីសិក្សាអភិវឌ្ឍន៏ផ្លូវចិត្ត/សង្គម របស់កុមារ | 2.6 |
| ***ទិន្នន័យមូលដ្ឋានរបស់ ECE*—** បង្កើតទិន្នន័យមូលដ្ឋានទូទាំងរដ្ឋ ដើម្បីប្រមូល និងរក្សាព័ត៌មានអំពីកុមារដែលចូលរៀនក្នុងកម្មវិធី ECE ឧបត្ថម្ភធនដោយរដ្ឋ។ នឹងមានរួម ភាពពីស្តារអំពីកម្មវិធីកុមារ ECE ព្រមទាំងការវាយតំលៃរបស់គេក្នុងការ ត្រៀមសំរាប់មតេយ្យសាលាផងដែរ។ នឹងតភ្ជាប់ជាមួយទិន្នន័យមូលដ្ឋានៃបណ្តាញអប់ររដ្ឋ K–12 ។ | 0.6 |
| ***អាជ្ញាប័ណ្ណត្រួតពិនិត្យ*—** បង្កើននូវភាព ញឹកញាប់នៃរបៀបដែលកម្មវិធី ECE ទទួលការត្រួតពិនិត្យមើលខាងសុខភាព និងសុវត្ថិភាពពីភ្នាក់ងារអាជ្ញាប័ណ្ណរដ្ឋ។ | 0.3 |
| ចំនួនសរុបតាមផ្នែក | **(23.0%)** |
| **"ពង្រឹងនិងពង្រីកកម្មវិធី ECE"** | |
| ***សេវាកម្មសំរាប់កុមារអាយុពី បីទៅប្រាំឆ្នាំ*—** ពង្រីកកម្មវិធីឧបត្ថម្ភធន សំរាប់មេតយ្យសាលាដើម្បីជួយកុមារពីគ្រួសារមានប្រាក់ចំណូលទាបឱ្យបាន ច្រើន។ | 51.6% |
| ***សេវាកម្មសំរាប់កុមារអាយុពីកំណើត ដល់បីឆ្នាំ*—** បង្កើតកម្មវិធីបឋមវ័យ មតេយ្យថ្មីសំរាប់កាលីហ្វ័រញ៉ាដើម្បីផ្តល់ការថែទាំកុមារនិងការគាំទ្រគ្រួសារសំរាប់ កុមារវ័យក្មេងពីគ្រួសារមានប្រាក់ចំណូល ទាប។ | 16.6 |
| ***អត្រាការបង់ប្រាក់អ្នកផ្តល់ការបំរើ*—** ផ្តល់ ប្រាក់ឧបត្ថម្ភបន្ថែមសំរាប់កុមារម្នាក់ៗ នៅក្នុងកម្មវិធីឧបត្ថម្ភធនរដ្ឋ ECE ដែលទទួលពិន្ទុខ្ពស់ជាងគេលើអត្រាកំរិតថ្មី ដែលមានថវិកាផ្តោតសំខាន់សំរាប់ផ្នែក កម្មវិធីមតេយ្យដ្ឋាន។ ម៉្យាងទៀតបង្កើនអត្រាសំរាប់កុមារម្នាក់ៗដែលមានរួចមក ហើយនោះសំរាប់កម្មវិធីឧបត្ថម្ភធនរដ្ឋ ដែលមានអាជ្ញាប័ណ្ណដល់កម្មវិធី ECE ដែលបំរើកុមារអាយុពីកំណើតដល់ 18 ខែ។ | 8.9 |
| ចំនួនសរុបតាមផ្នែក | **(77.0%[b])** |
| **សរុប** | **100.0%** |

[a] ដោយសារចំនួនត្រូវបានកំណត់សំរាប់ស្តារឡើងវិញ និងប្រព័ន្ធ បសិដ្ឋកម្មត្រូវបានកំរិតខ្ពស់ដល់ $355លាន មូលនិធិមួយផ្នែកដ៏តិច តួចនឹងផ្តល់ទៅជួយពង្រឹង និងពង្រីកកម្មវិធី ECE ពេលណាវិធានការ នៃសេវាបង់ប្រាក់បំណុលចប់នៅឆ្នាំ 2017–18។

[b] មិនត្រូវឱ្យលើសពី 3 ភាគរយនៃមូលនិធិទាំងនេះអាចត្រូវយក ទៅប្រើប្រាស់តំលៃមើលគ្រប់គ្រងកំរិតរដ្ឋឡើយ។ មិនត្រូវឱ្យលើសពី 15 ភាគរយនៃមូលនិធិដែលត្រូវបានកំណត់ទុកសំរាប់អ្នកផ្តល់ការបំរើរបស់កម្មវិធី ECE អាចយកមកប្រើសំរាប់ថ្លៃចំណាយលើអគារ ឡើយ។

38

*សំរាប់អត្ថបទនៃសំណើប្រជាមតិ លេខ 38, សូមអានទំព័រ 113។*

# សំណើប្រជាមតិ 38 ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំបូង។ លក្ខន្តិកៈផ្តួចផ្តើម។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** **(ត)**

***បង្កើតប្រព័ន្ធដាក់ពិន្ទុទូទាំងរដ្ឋ ដើម្បីវាយតម្លៃគុណភាពនៃកម្មវិធី ECE នីមួយៗ។*** វិធានការនេះ តម្រូវឲ្យរដ្ឋអនុវត្ត "ប្រព័ន្ធដាក់ពិន្ទុ និងកែលម្អគុណភាពនៃការសិក្សាពីដំបូង" (QRIS) ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ECE នីមួយៗ។ ការសាងបន្តលើការងារដំបូងដែលរដ្ឋបានចាត់វិធានការរដ្ឋនឹងមានពេលវេលាហូតដល់ខែមករា ឆ្នាំ 2014 ដើម្បីបង្កើតមាត្រដ្ឋានមួយសម្រាប់វាយតម្លៃថាតើ កម្មវិធីរួមចំណែកនៅក្នុងការអភិវឌ្ឍផ្លូវសង្គម និងផ្លូវចិត្ត និងការត្រៀមចូលសិក្សារបស់កុមារបានល្អដល់កម្រិតណាដែរ។ កម្មវិធី ECE ទាំងអស់ អាចជ្រើសរើសឲ្យគេដាក់ពិន្ទុតាមមាត្រដ្ឋាននេះ ហើយការដាក់ពិន្ទុនឹងមានលទ្ធភាពប្រើប្រាស់បានជាសាធារណៈ។ រដ្ឋក៏នឹងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ដើម្បីជួយដល់អ្នកផ្តល់ការថែទាំក្នុងការកែលម្អសេវា និងបង្កើនពិន្ទុរបស់ពួកគេផងដែរ។ បន្ថែមពីលើនេះទៀត សំណើប្រជាមតិលេខ 38 នឹងផ្តល់ប្រាក់ខែបន្ថែម—នៅផ្នែកខាងលើនៃអត្រាឧបត្ថម្ភដែលមានស្រាប់សម្រាប់កុមារម្នាក់—សម្រាប់កម្មវិធីថែទាំកុមារ និងមត្តេយ្យមជ្ឈឹមដែលទទួលបានពិន្ទុខ្ពស់ជាងមុខនៅលើមាត្រដ្ឋានប្រព័ន្ធ QRIS។

***ផ្តល់មត្តេយ្យមជ្ឈឹមដល់កុមារដែលមកពីគ្រួសារមានប្រាក់ចំណូលទាបកាន់តែច្រើន។*** សំណើប្រជាមតិលេខ 38 ពង្រីកចំនួននៃមូលនិធិ ដែលមានលទ្ធភាពអាចប្រើប្រាស់បាននៅក្នុងកម្មវិធីមត្តេយ្យមជ្ឈឹមដែលឧបត្ថម្ភដោយរដ្ឋ ដែលមានទីតាំងនៅក្នុងសង្កាត់ដែលមានការប្រមូលផ្តុំខ្ពស់នៃគ្រួសារមានប្រាក់ចំណូលទាប។ ការផ្តល់ថវិកាដើម្បីផ្តល់មូលនិធិថ្មីៗទាំងនេះ នឹងមានលទ្ធភាពអាចប្រើប្រាស់បាន សម្រាប់អ្នកផ្តល់មត្តេយ្យមជ្ឈឹម ដែលមានពិន្ទុគុណភាពខ្ពស់ប៉ុណ្ណោះ។ ការផ្តល់ថវិកា នឹងត្រូវបានបែងចែកទៅឲ្យអ្នកផ្តល់ការថែទាំ ដោយផ្អែកលើចំនួនប៉ាន់ស្មាននៃកុមារមានសិទ្ធិទទួលបាន ដែលរស់នៅក្នុងសង្កាត់គោលដៅ ដែលបច្ចុប្បន្នមិនទាន់បានចូលរៀននៅមត្តេយ្យមជ្ឈឹម។ (យ៉ាងហោចណាស់ 65 ភាគរយនៃកន្លែងថ្មីៗទាំងនេះ ត្រូវតែស្ថិតនៅក្នុងកម្មវិធី ដែលផ្តល់សេវាពេញមួយថ្ងៃ ពេញមួយឆ្នាំ។) ការចូលរួមក្នុងកម្មវិធី នឹងមានកម្រិតចំពោះកុមារដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបានប្រាក់ចំណូលដែលមានស្រាប់ ឬរស់នៅក្នុងសង្កាត់គោលដៅ មិនថាប្រាក់ចំណូលគ្រួសារ ដែលត្រូវបានផ្តល់អាទិភាពខ្ពស់បំផុត ចំពោះកុមារដែលមានហានិភ័យមួយចំនួន (រួមមាន កុមារទាំងឡាយណាដែលស្ថិតនៅក្នុងការថែទាំនៅតាមមណ្ឌលថែទាំកុមារ)។

***បង្កើតកម្មវិធីថ្មីសម្រាប់ទារក និងកូនក្មេងទើបរៀនដើរដែលមកពីគ្រួសារមានប្រាក់ចំណូលទាប។*** សំណើប្រជាមតិលេខ 38 បង្កើតកម្មវិធី Head Start ជាដំបូង (EHS) របស់រដ្ឋកាលីហ្វ័រញ៉ា ដែលយកគំរូតាមកម្មវិធីសហព័ន្ធមានឈ្មោះដូចគ្នា។ រហូតដល់ 65 ភាគរយនៃការផ្តល់ថវិកាសម្រាប់ កម្មវិធីនេះ នឹងផ្តល់ទាំងសេវាថែទាំកុមារ និងសេវាគាំទ្រគ្រួសារ ដល់គ្រួសារមានប្រាក់ចំណូលទាប ដែលកូនមានអាយុចាប់ពីទើបនឹងកើតរហូតដល់អាយុបីឆ្នាំ។ (យ៉ាងហោចណាស់ 75 ភាគរយនៃមូលនិធិថ្មីៗទាំងនេះ ត្រូវតែសម្រាប់ការថែទាំពេញមួយថ្ងៃ ពេញមួយឆ្នាំ។) យ៉ាងហោចណាស់ 35 នៃការផ្តល់ថវិកា EHS នឹងផ្តល់សេវាគាំទ្រដល់គ្រួសារ និងអ្នកផ្តល់ការថែទាំ ដែលមិនចូលរួមនៅក្នុងសមាសភាពថែទាំកុមាររបស់កម្មវិធី។ នៅក្នុងករណីទាំងពីរនេះ សេវាគាំទ្រគ្រួសារអាចរួមបញ្ចូលទាំងការចុះសួរសុខទុក្ខដោយបុគ្គលិកកម្មវិធី ការវាយតម្លៃការអភិវឌ្ឍរបស់កុមារ កម្មវិធីអក្ខរកម្មគ្រួសារនិងការបណ្តុះបណ្តាលមាតាបិតា និងអ្នកផ្តល់ការថែទាំ។

## ឥទ្ធិពលសារពើពន្ធ

***ផ្តល់ថវិកាបន្ថែម ដើម្បីគាំទ្រ និងពង្រីកកម្មវិធី ECE។*** នៅក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូង ប្រហែល $1 មួយរយកោដិដុល្លារប្រចាំឆ្នាំពីវិធានការនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់ប្រព័ន្ធ ECE របស់រដ្ឋ។ (ថវិកាឆ្នាំ 2013–14 នឹងខ្ពស់ជាងមុន ពីព្រោះថវិកាដែលបានបង្កើននៅឆ្នាំ 2012–13 ក៏អាចមានលទ្ធភាពចែកចាយបានដែរ។) ភាគច្រើននៃការផ្តល់ថវិកា នឹងប្តេជ្ញាសម្រាប់ការពង្រីកកម្មវិធីថែទាំកុមារ និងមត្តេយ្យមជ្ឈឹម ដែលបម្រើទារក/កូនក្មេងទើបរៀនដើរ 10,000 នាក់ និងកុមារដែលរៀននៅមត្តេយ្យមជ្ឈឹម 90,000 នាក់បន្ថែមទៀត នៅក្នុងរយៈពេលចាប់ផ្តើមប៉ុន្មានឆ្នាំដំបូងនៃការអនុវត្តកម្មវិធី។ ចំនួនថវិកាដែលមានលទ្ធភាពអាចប្រើប្រាស់បាននៅក្នុងឆ្នាំខាងមុខ នឹងកើនឡើងតាមពេលវេលា។ ចាប់ផ្តើមពីឆ្នាំ 2017–18 តទៅ ថវិកាដែលចំណាយទៅលើកម្មវិធីថែទាំ និងអប់រំពីចម្ងាយ នឹងកើនឡើងថែមទៀត ពីព្រោះថវិកាដែលត្រូវការប្រើប្រាស់សម្រាប់ការទូទាត់បំណុលរដ្ឋ មានការថយចុះយ៉ាងច្រើន។

38

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

(ត)

# ការបង់សងបំណុលរដ្ឋ

### សារតារ

***ការទូទាត់បំណុលសញ្ញាប័ណ្ណដែលជាកាតព្វកិច្ចទូទៅ។*** ហិរញ្ញប្បទានសញ្ញាប័ណ្ណ គឺជាប្រភេទនៃការខ្ចីប្រាក់រយៈពេលយូរ ដែលរដ្ឋប្រើដើម្បីបង្កើនប្រាក់  ជាចម្បងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធមានអាយុកាលយូរអង្វែង(រួមមានអគារសាលារៀន និងសាកលវិទ្យាល័យ មហាវិថី ផ្លូវថ្នល់ ការអភិរក្សដីធ្លី និងសត្វព្រៃ និងអគារូបវ័ន្តទាក់ទងនឹងទឹក)។ រដ្ឋទទួលបានប្រាក់នេះ តាមរយៈការលក់សញ្ញាប័ណ្ណដល់វិនិយោគិនទាំងឡាយ។ ជាការតបស្នង រដ្ឋសន្យាទូទាត់សងប្រាក់នេះ ដោយមានការប្រាក់ យោងទៅតាមកាលវិភាគដែលបានបញ្ជាក់លម្អិត។ មួយភាគធំនៃសញ្ញាប័ណ្ណរបស់រដ្ឋ គឺជាសញ្ញាប័ណ្ណកាតព្វកិច្ចទូទៅ ដែលត្រូវតែយល់ព្រមដោយអ្នកបោះឆ្នោត និងធានាដោយអំណាចពន្ធអាករទូទៅរបស់រដ្ឋ។ សញ្ញាប័ណ្ណកាតព្វកិច្ចទូទៅ ជាធម្មតាត្រូវបានបង់ផ្តាច់ជាមួយនឹងការទូទាត់ដោយសេវាផ្តល់បំណុលប្រចាំឆ្នាំពីកញ្ចប់ថវិកាទូទៅ។ នៅឆ្នាំ 2010–11 រដ្ឋបានទូទាត់សេវាផ្តល់បំណុលសញ្ញាប័ណ្ណកាតព្វកិច្ចទូទៅចំនួន $4.7 បួនរយប្រាំពីរកោដិដុល្លារ។ ក្នុងចំនួនប្រាក់នេះ $3.2 បីរយពីរកោដិដុល្លារ គឺសម្រាប់ទូទាត់សេវាផ្តល់បំណុលទៅលើអគារូបវ័ន្តសាលារៀន និងសាកលវិទ្យាល័យ។

## សេចក្តីស្នើច្បាប់

***យ៉ាងហោចណាស់ 30ភាគរយនៃប្រាក់ចំណូលសម្រាប់ជំនួយសេវាផ្តល់បំណុលរហូតដល់ឆ្នាំ 2016–17។*** រហូតដល់ចុងឆ្នាំ 2016–17 យ៉ាងហោចណាស់ 30 ភាគរយនៃប្រាក់ចំណូលនៃសំណើប្រជាមតិលេខ 38 នឹងត្រូវបានប្រើប្រាស់ដោយរដ្ឋ ដើម្បីទូទាត់ថ្លៃសេវាផ្តល់បំណុល។ វិធានការតម្រូវឲ្យប្រើថវិកាទាំងនេះ ជាចម្បងសម្រាប់ទូទាត់ថ្លៃសេវាផ្តល់បំណុលផ្នែកអប់រំ (អគារូបវ័ន្តមត្តេយ្យសិក្សាកម្រិតទាប រហូតដល់សាកលវិទ្យាល័យ)។ ទោះបីជាយ៉ាងណា ប្រសិនបើថវិកានៅសេសសល់ ក្រោយពីទូទាត់ថ្លៃសេវាផ្តល់បំណុលផ្នែកអប់រំប្រចាំឆ្នាំរួចនោះ ថវិកាទាំងនេះអាចត្រូវបានប្រើសម្រាប់ទូទាត់ថ្លៃសេវាផ្តល់បំណុលសញ្ញាប័ណ្ណកាតព្វកិច្ចទូទៅផ្សេងទៀតរបស់រដ្ឋ។

***កម្រិតកំណើននៃការបែងចែកសម្រាប់សាលារៀន និងកម្មវិធីថែទាំ និងអប់រំពីចម្ងាយចាប់ផ្តើមពីឆ្នាំ 2015–16 តទៅ ប្រើថវិកាដែលលើសសម្រាប់ទូទាត់សេវាផ្តល់បំណុល។*** ចាប់ផ្តើមពីឆ្នាំ 2015–16 តទៅ ការបែងចែងថវិកា CETF សរុប សម្រាប់សាលារៀន និងកម្មវិធីថែទាំ និងអប់រំពីចម្ងាយ មិនអាចបង្កើនតាមអត្រាច្រើនជាងកំណើនជាមធ្យមនៅក្នុងទុនប្រាក់ចំណូលផ្ទាល់ខ្លួននៅរដ្ឋកាលីហ្វ័រញ៉ា ក្នុងរយៈពេលប្រាំឆ្នាំមុនឡើយ។ លុយ CETF ដែលប្រមូលបានលើសពីអត្រាកំណើននេះ ក៏នឹងត្រូវប្រើសម្រាប់ទូទាត់បំណុលរបស់រដ្ឋផងដែរ។ (វិធានការនេះ ផ្តល់នូវការលើកលែងសម្រាប់ឆ្នាំ 2017–18 ដោយពិចារណាទៅលើការប្រែប្រួលការបែងចែកប្រាក់ចំណូល។)

## ឥទ្ធិពលសារពើពន្ធ

***ប្រាក់សន្សំនៃកញ្ចប់ថវិកាទូទៅប្រហែល 3 បីរយកោដិដុល្លារប្រចាំឆ្នាំ រហូតដល់ឆ្នាំ 2016–17។*** រហូតដល់ចុងឆ្នាំ 2016–17 យ៉ាងហោចណាស់ 30 ភាគរយនៃប្រាក់ចំណូលដែលបង្កើនដោយវិធានការនេះ ប្រហែល $3 បីរយកោដិដុល្លារប្រចាំឆ្នាំ នឹងត្រូវបានប្រើប្រាស់ដើម្បីទូទាត់ថ្លៃសេវាផ្តល់បំណុលកាតព្វកិច្ចទូទៅ និងផ្តល់ប្រាក់សន្សំនៃកញ្ចប់ថវិកាទូទៅរបស់រដ្ឋ។ ការធ្វើបែបនេះ នឹងដោះស្រាយប្រាក់ចំណូលនៃកញ្ចប់ថវិកាទូទៅ សម្រាប់កម្មវិធីសាធារណៈផ្សេងៗ និងធ្វើឲ្យកាន់តែមានភាពងាយស្រួល ក្នុងការធ្វើឲ្យមានតុល្យភាពថវិកានៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។

***ប្រាក់សន្សំនៃកញ្ចប់ថវិកាទូទៅបន្ថែមជាសក្តានុពល ចាប់ផ្តើមពីឆ្នាំ 2015–16 តទៅ។*** ខចែងអំពីកម្រិតកំណើនរបស់វិធានការនេះ ក៏ផ្តល់នូវប្រាក់សន្សំនៃកញ្ចប់ថវិកាទូទៅក្នុងឆ្នាំមួយចំនួនផងដែរ។ ចំនួននៃប្រាក់សន្សំនឹងខុសគ្នាពីមួយឆ្នាំទៅមួយឆ្នាំអាស្រ័យទៅលើកំណើននៃពន្ធប្រាក់ចំណូលផ្ទាល់ខ្លួន និងទុនប្រាក់ចំណូលផ្ទាល់ខ្លួន ប៉ុន្តែអាចមានចំនួនរាប់រយលានដុល្លារប្រចាំឆ្នាំ។

38

# សំណើប្រជាមតិ 38 ពន្ធសំរាប់ផ្តល់ថវិកា ការអប់រំ និងកម្មវិធីកុមារវ័យដំបូង។ លក្ខន្តិកៈផ្តួចផ្តើម។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 38 ★

ការអប់រំគឺជាអនាគតរបស់យើង ព្រោះកុមារគឺជាអនាគតរបស់ពួកយើង។ បើគ្មានសាលារៀនដែលមានគុណភាព រដ្ឋរបស់យើងនឹងខ្វះកំលាំងពលកម្មដែលមានជំនាញចំបាច់សម្រាប់លើកកម្ពស់សេដ្ឋកិច្ច និងបង្កើតការងារ របស់យើង។

ជំនួសឲ្យការវិនិយោគចំពោះសាលារៀនរបស់យើង មេដឹកនាំនយោបាយដែលមកពីគណបក្សទាំងពីរបាននឹងកំពុងកាត់បន្ថយ។ តាំងពីឆ្នាំ 2008 គេ បានកាត់ថវិកា សា លារៀនត្រឹម $20 ពីរពាន់កោដិដុល្លារ។អ្នកបង្រៀនជាង 40,000 នាក់ត្រូវបានគេបញ្ឈប់លែងឲ្យធ្វើការបណ្ដោះអាសន្ន ហើយឥឡូវនេះរដ្ឋកាលីហ្វ័រញ៉ាមាន ថ្នាក់រៀន ដែលមានទំហំធំជាងគេបំផុតនៅក្នុងប្រទេស។

ស្តារ និងពង្រឹងមូលនិធិសាលាឡើងវិញ។

សំណើប្រជាមតិលេខ 38 ធ្វើឲ្យសាលារៀនក្លាយជាអទិភាពម្តងទៀត។ សំណើប្រជាមតិនេះផ្តល់នូវការធានាទទួលការផ្តល់ថវិកា ដើម្បីស្រោចស្រង់ វិស័យអប់រំឲ្យមានគុណភាពល្អដូចដើមវិញនិងលើកកម្ពស់លទ្ធផលនៃការអប់រំ។

សំណើប្រជាមតិនេះធានាបាននូវប្រាក់រាប់កោដិដុល្លារចំពោះសាលារៀន ដែលនៅតាមតំបន់ដោយអាស្រ័យលើការចុះឈ្មោះចូលរៀន ដែលជាមធ្យមមានទឹកប្រាក់ចំនួន $1 មួយពាន់កោដិដុល្លារជារៀងរាល់ឆ្នាំក្នុងរយៈពេលជាងដប់ពីរឆ្នាំ។

កន្លែងសាលារៀនជាច្រើនអាចប្រើលុយ ដើម្បីកាត់បន្ថយទំហំថ្នាក់រៀន ឬស្រោចស្រង់ថ្នាក់រៀនក្នុងមុខវិជ្ជាសិល្បៈ តន្ត្រី គណិតវិទ្យា វិទ្យាសាស្ត្រ ការអប់រំ វិជ្ជាជីវៈ និងពីបច្ចេកទេស និងការត្រៀមប្រលងចូលរៀននៅមហាវិទ្យាល័យ -អាស្រ័យលើតម្រូវការខុសៗគ្នានៃសាលារៀន។

*ស្វែងយល់ឱ្យដឹងថាតើថវិកាថ្មីប៉ុន្មានដែលសំណើប្រជាមតិលេខ 38 ផ្ញើដោយផ្ទាល់ទៅឱ្យសាលានៅក្នុងសហគមន៍របស់អ្នក សូមទស្សនាគេហទំព័រ www.moneyforlocalschools.org/restore.*

ការពារកុំឱ្យកាត់បន្ថយថវិកាថែមទៀត។

សំណើប្រជាមតិលេខ 38 ជួយការពារការកាត់បន្ថយថវិកាបន្ថែម ដោយធ្វើការ លែដោយឡែកនូវទឹកប្រាក់ $3 បីរយកោដិលានដុល្លារជារៀងរាល់ឆ្នាំរហូតដល់ឆ្នាំ 2016-17 ដើម្បីកាត់បន្ថយឱនភាពថវិការបស់រដ្ឋ ដោយធ្វើការសងបំណុលសញ្ញា ប័ណ្ណខាងវិស័យអប់រំរបស់រដ្ឋ។

រៀបចំកុមារឱ្យមានជោគជ័យ

សំណើប្រជាមតិលេខ 38 ផ្តល់ប្រាក់លើសពី $1.1 មួយរយមួយកោដិដុល្លារជារៀងរាល់ឆ្នាំដើម្បីស្តារការកាត់បន្ថយថវិកា សម្រាប់ការអប់រំកុមារវ័យដំបូងលើកកម្ពស់គុណភាព និងពង្រីកលទ្ធភាពដែលអាចទៅដល់សាលាមត្តេយ្យបាន។

មធ្យោបាយចែករំលែកស្មើគ្នាដើម្បីធ្វើវិនិយោគនៅក្នុងសាលារបស់យើង។

ក្នុងនាមជាពលរដ្ឋកាលីហ្វ័រញ៉ា យើងទាំងអស់គ្នាគួរចូលរួមចំណែកធ្វើអ្វីមួយ ដើម្បីលើកកម្ពស់គុណភាពអប់រំរបស់សាលារៀនយើង ព្រោះយើងទាំងអស់គ្នានឹងចូលរួមចំណែកធ្វើឲ្យសាលារៀនទទួលបាន អត្ថប្រយោជន៍ល្អប្រសើរ និងចូលរួមលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រទេសជាតិ និងគុណភាពជីវិត។

សំណើប្រជាមតិលេខ 38 ផ្តល់ប្រាក់លើសពី $10 មួយពាន់កោដិដុល្លារជារៀងរាល់ ឆ្នាំដើម្បីស្តារមូលនិធិសំរាប់សាលាដោយតំឡើងអត្រាពន្ធរដ្ឋលើប្រាក់ចំណូលបន្ទាប់ពីកាត់កងរួចហើយដោយការប្រើប្រាស់ខ្នាតរំកិល ដោយផ្អែកលើលទ្ធភាពបង់។ អ្នកជាប់ពន្ធដែលមាន ជីវភាពធូរធាបំផុតត្រូវបង់ពន្ធច្រើនជាងគេ ក្នុងអត្រាកើនឡើង 2.2% ចំពោះអ្នកដែលមានប្រាក់ចំណូលលើសពី $2.5 លានដុល្លារ។ នៅកំរិតទាប ចំពោះអ្នកជាប់ពន្ធដែលមានប្រាក់ចំណូលក្រោម $25,000 ដុល្លារ នឹងត្រូវបង់ប្រចាំឆ្នាំជាមធ្យម $7.00 ដុល្លារ។

*ស្វែងយល់ឱ្យដឹងថាតើថវិកាថ្មីប៉ុន្មានដែលសំណើប្រជាមតិលេខ 38 ប៉ះពាល់អ្នកជាប់ពន្ធដូចរូបអ្នក សូមទស្សនាគេហទំព័រ www.moneyforlocalschools.org/taxcalculator.*

ការធានាប្រាំយ៉ាងសំរាប់មាតាបិតានិងអ្នកជាប់ពន្ធ៖

- *អង្គនីតិបញ្ញត្តិមិនអាចប៉ះពាល់ប្រាក់នោះបានទេ* សំណើប្រជាមតិ 38 ហាមឃាត់អង្គនីតិបញ្ញត្តិពីបង្វែរប្រាក់នោះ ឬខ្ចីប្រាក់ ហើយគេមិនអាចប្រើប្រាក់ថ្មីដើម្បីជំនួសប្រាក់ដែលសាលាកំពុងទទួលសព្វថ្ងៃទេ។
- *ការផ្តត់ផ្គង់ថវិកាសាលាត្រូវតែចំណាយទៅលើសិស្សម្នាក់ៗនៅគ្រប់សាលា និងត្រូវតែចំណាយនៅសាលាតែប៉ុណ្ណោះ។* ថវិកានឹងត្រូវបានពិនិត្យហើយការបែង ចែកខុសដែលប៉ុនប៉ងណាមួយ គឺជាបទឧក្រិដ្ឋមួយដែលអាចដាក់ទោសដោយឲ្យជាប់ពន្ធនាគារ និងហាមពីការចូលបម្រើការិយាល័យសាធារណៈ។
- *ថវិកា មិនអាចត្រូវបានចំណាយដើម្បីតំឡើងប្រាក់ខែ ឬប្រាក់សោធនិវត្តន៍* ដល់បុគ្គលិកសាលារៀនឡើយ ហើយសំណើ 38 ហាមឃាត់ការចំណាយលើសពី 1% លើការគ្រប់គ្រង។
- *ការសំរេចចិត្តក្នុងការចំណាយត្រូវតែធ្វើឡើងតាមមូលដ្ឋាន បន្ទាប់ពីការចូលរួមពី សាធារណជន។*សាលាតាមតំបន់ត្រូវបើកការប្រជុំនៅកន្លែងសាលារៀងៗខ្លួន ដើម្បីទទួលយោបល់ពីឪពុកម្តាយសិស្ស អ្នកអប់រំ និងសហគមន៍មុនពេល ចំណាយថវិកា។
- *សាលាអប់រំស្រុកទាំងអស់នឹងមានទំនួលខុសត្រូវក្នុងការពង្រឹងគុណភាពអប់រំនៅតាមតំបន់រៀងៗខ្លួន។* សាលាត្រូវតែកំណត់គោលដៅពង្រឹងការអប់រំជារៀងរាល់ឆ្នាំ សម្រាប់សាលានីមួយៗ និងរាយការណ៍ជាសាធារណៈ ពីរបៀបដែល ថវិកាត្រូវបានចំណាយ និងថាតើគោលដៅពង្រឹងបានទទួលជោគជ័យ ឬអត់។

ធ្វើសាលាជាអាទិភាពឡើងវិញ។ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 38។

**CAROL KOCIVAR**, ប្រធាន
សមាគមគ្រូបង្រៀន មាតាបិតារដ្ឋកាលីហ្វ័រញ៉ា

**EDWARD JAMES OLMOS**, អ្នកសម្តែង

**ARUN RAMANATHAN**, នាយកប្រតិបត្តិ
ការអប់រំTrust-West

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 38 ★

យើងទាំងអស់គ្នាចង់បានសាលារៀនមានគុណភាពល្អ។

ប៉ុន្តែការបោះចោលលុយ ពីការបង់ពន្ធថ្មីៗប្រមាណ $120 មួយរយម្ភៃពាន់កោដិដុល្លារចូលទៅក្នុងការិយាធិបតេយ្យរបស់រដ្ឋដែលមិនមានការទទួលខុសត្រូវថ្មីមួយ នឹងមិនអាចផ្តល់គុណភាពអប់រំល្អសម្រាប់កូនរបស់យើងបានទេ។

ជំនួសការកែប្រែប្រព័ន្ធ ការសំអាតកាកសំណល់ និងការបំពាននានា សំណើប្រជា មតិ 38 បានតំឡើងពន្ធ និងចំណាយលុយច្រើនបន្ថែមទៀតលើការិយាធិបតេយ្យដែលមិនមានការទទួលខុសត្រូវមួយ៖

- សំណើប្រជាមតិលេខ 38 គឺជាពន្ធចំណូលដ៏ធំសម្រាប់អ្នកជាប់ពន្ធថ្នាក់កណ្តាល និងអាជីវកម្មខ្នាតតូច។ បើសិនអ្នករកចំណូលបាន $8,000 ដុល្លារ ឬច្រើនជាងនេះក្នុងមួយឆ្នាំដែលបាក្រចំណូល អាចកាត់ពន្ធបាន អត្រាបង់ពន្ធរបស់អ្នកកើនឡើងច្រើនដល់ 21% សម្រាប់ដប់ពីរឆ្នាំក្រោយទៀត។
- សំណើប្រជាមតិលេខ 38 នឹងធ្វើឲ្យខូចខាតដល់អាជីវកម្មខ្នាតតូច ដោយសារការបង្កើនពន្ធលើអាជីវកម្មជាលក្ខណៈគ្រួសារ ដែលរៀបចំសំណុំឯកសារនិងបង់ពន្ធបាក្រចំណូលជាលក្ខណៈបុគ្គលមិនមែនជាក្រុមហ៊ុន។
- សំណើប្រជាមតិលេខ 38 សំលាប់ការងារមួយចំនួននៅក្នុង អាជីវកម្មតូចៗនិងជាលក្ខណៈគ្រួសារដែល ជាកន្លែងការងារកើនឡើងកំពុងដំណើរការ។ រដ្ឋកាលីហ្វ័រញ៉ាមានអត្រាអ្នកអត់ការងារធ្វើខ្ពស់បំផុតទីបីក្នុងប្រទេស។
- សំណើប្រជាមតិលេខ 38 មិនអាចត្រូវបានកែប្រែក្នុងរយៈដប់ពីរឆ្នាំ- សូម្បីក្នុងករណីក្លែងបន្លំ ឬការខ្វះខ្នាយ។
- សំណើប្រជាមតិលេខ 38 ផ្តល់ប្រាក់ចំនួន $3 បីរយកោដិដុល្លារក្នុងមួយឆ្នាំទៅឲ្យអ្នកនយោបាយក្រុង Sacramento ក្នុងរយៈពេលបួនឆ្នាំដើម្បីចំណាយលើអ្វីដែលពួកគេជ្រើសរើស។
- សំណើប្រជាមតិលេខ 38 បង្កើតការិយាធិបតេយ្យថ្មីមួយយ៉ាងថ្លៃដោយ បង្ខំឲ្យសាលារៀនឆ្លងកាត់ការិយាធិបតេយ្យដ៏ស្មុកស្មាញគ្រាន់តែដើម្បីទទួលបានថវិកាមូលដ្ឋាន ហើយប្រគល់អាណត្តិកម្មវិធីថ្មីៗ ខណៈពេលដែលមុខងារសាលារៀនចាំបាច់ត្រូវបានកាត់បន្ថយ។
- សំណើប្រជាមតិលេខ 38 ស្ទើរតែមិនមានការកែលម្អអ្វីសោះដល់ការការរីកចំរើនរបស់សិស្ស។

ចូលរួមជាមួយអ្នកអប់រំ, វេជ្ជបណ្ឌិត, អាជ្ញាធរមានសមត្ថកិច្ច, អង្គការអ្នកជាប់ពន្ធ, និងអ្នកដឹកនាំអាជីវកម្មខ្នាតតូចក្នុងការបោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 38 *www.StoptheMiddleClassTaxHike.com.*

**ANDREW WONG**, សមាជិក
មណ្ឌលសិក្សាធិការ Pomona Unified, ក្រុមប្រឹក្សាអប់រំ

**KEITH ROYAL**, ប្រធាន
សមាគមតម្រួតតំបន់រដ្ឋកាលីហ្វ័រញ៉ា

**RICHARD RIDER**, ប្រធាន
ក្រុមប្រឆាំងពន្ធដារ San Diego




*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 38 ★

*បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 38 ៖ កំណើនពន្ធប្រាក់ចំណូលចំនួន $120 មួយរយម្ភៃពាន់កោដិដុល្លារ ដែលបានមកពីប្រជាជនកាលីហ្វ័រញ៉ាភាគច្រើន*

ប្រសិនបើអ្នករកចំណូលបានចំនួន $17,346 ដុល្លារ ឬច្រើនជាងនេះក្នុងមួយឆ្នាំនៅក្នុងប្រាក់ចំណូលដែលជាប់ពន្ធ។ សំណើប្រជាមតិលេខ 38 បង្កើនអត្រាពន្ធប្រាក់ចំណូលម្នាក់ៗច្រើនបំផុតត្រឹម 21% លើអ្វីដែលអ្នកបានបង់ទៅឲ្យ រដ្ឋាភិបាលសហព័ន្ធ។

ការតំឡើងពន្ធរបស់សំណើប្រជាមតិលេខ 38 បន្តរហូតដល់ឆ្នាំ 2024។ ប្រសិនបើអ្នកមានកូនចូលរៀនថ្នាក់ទីមួយ អ្នកត្រូវបង់ពន្ធប្រាក់ចំណូលខ្ពស់ជាងនេះ រហូតដល់កូនរបស់អ្នករៀនចប់វិទ្យាល័យ។

ថ្វីបើសេដ្ឋកិច្ចរីកចំរើន ហើយមនុស្សជាច្រើនមានធ្វើការវិញ ការតំឡើងពន្ធនៅតែបន្ត។ សូម្បីមិនមានការកែទម្រង់ចាំបាច់ចំពោះប្រព័ន្ធអប់រំរបស់ពួកយើង ដូចជាលទ្ធភាពអាចដេញគ្រូបង្រៀនមិនល្អចេញពីការងារ ការតំឡើងពន្ធនៅតែបន្ត។ សំណើប្រជាមតិលេខ 38 បង្ខាំងពួកយើងឲ្យស្ថិតក្នុងអត្រាពន្ធប្រាក់ចំណូលខ្ពស់ ក្នុងរយៈពេលដប់ពីរឆ្នាំខាងមុខ—ទោះបីយ៉ាងណាក៏ដោយ!

អ្នកនយោបាយ និងការិយាធិបតេយ្យទទួលបានប្រាក់រាប់ពាន់លានដុល្លារពីពន្ធថ្មីនេះ ដោយស្ទើរតែមិនមានការទទួលខុសត្រូវលើរបៀបចំណាយលុយ និងចំនួនទឹកប្រាក់ប៉ុន្មានប្រគល់ទៅដល់ថ្នាក់រៀនពិតប្រាកដ។

*សំដៅទៅជំនួញខ្នាតតូច និងសំលាប់ការងារជាច្រើនជំនួញខ្នាតតូច*

ក្នុងរដ្ឋកាលីហ្វ័រញ៉ាចំនួនប្រហែលជា 3.8 លាន បង់ពន្ធប្រាក់ចំណូលជាបុគ្គលចំពោះប្រាក់ចំណូលរបស់ពួកគេ ជាជាងពន្ធក្រុមហ៊ុន។ ជាលទ្ធផល ជំនួញខ្នាតតូចនឹងត្រូវបំផ្លាញដោយការបង់ពន្ធខ្ពស់ទាំងនេះ—ទោះបីជាជំនួញមានចំណូលតិចតួចដូចជា $30,000 ឬ $40,000 ដុល្លារក្នុងមួយឆ្នាំក៏ដោយ។

ជំនួសឲ្យការបង្កើតការងារ ហើយធ្វើឲ្យសេដ្ឋកិច្ចរីកចំរើន សំណើប្រជាមតិលេខ 38 នឹងបង្ខំឲ្យជំនួញលក្ខណៈគ្រួសារកាត់បន្ថយការងារ ផ្លាស់ចេញពីរដ្ឋ ឬបិទតែម្តង។ ប្រសិនបើពួកគេអាចបន្តជំនួញនេះ ពួកគេត្រូវតម្លើងថ្លៃដើម្បីបង់ពន្ធដ៏ខ្ពស់នេះ ដែលជាចុងក្រោយអ្នកប្រើប្រាស់ក៏ទទួលរងនូវតំលៃដ៏ខ្ពស់នេះដែរ។

*មិនមានតម្រូវការដើម្បីកែលម្អដំណើរការសាលារៀន។*

ក្រោមសំណើប្រជាមតិ លេខ 38 មិនតំរូវការឱ្យមានការពង្រឹងប្រតិបត្តិការរបស់សាលា ឬបណ្តេញគ្រូអាក្រក់ចេញពីសាលាទេ។ ប្រាក់ច្រើនបំផុតនឹងត្រូវចំណាយលើបន្តលើការគ្រប់គ្រង, ការប្រឹក្សា, សោធននិវត្តន៏, ផលប្រយោជន៏ និងការចំណាយផ្សេងៗពីលើទៀត ដូច្នេះប្រាក់តិចតួចប៉ុណ្ណោះនឹងត្រូវចំណាយលើថ្នាក់រៀន។ នាពេលថ្មីៗនេះ សិស្សានុសិស្សនៃរដ្ឋកាលីហ្វ័រញ៉ាចំនួន 24% មិនបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យទេ។ សំណើប្រជាមតិលេខ 38 បានដាក់លុយកាន់តែច្រើនចូលទៅក្នុងប្រព័ន្ធមួយដែលកំពុងធ្វើឲ្យក្មេងប្រលងធ្លាក់ដោយពុំមានការទាមទារឲ្យមានការពង្រឹងលទ្ធផលសម្រាប់សិស្ស។

*គ្មានការផ្លាស់ប្តូរអ្វីទាំងអស់ ទោះបីជាមានការបន្លំ ឬការខ្ជះខ្ជាយ ក្នុងរយៈពេលដប់ពីរឆ្នាំនេះ។*

សំណើប្រជាមតិលេខ 38 រួមមានខចែងដ៏ពិសេសមួយដែលលាក់ទុកជាឯកសារចំនួនម្ភៃប្រាំពីរទំព័ររបស់ខ្លួនដែលសរសេរជាអក្សរតូចៗ ដែលហាមមិនឲ្យមានការ កែប្រែណាមួយក្នុងវិធានការរហូតដល់ឆ្នាំ 2024 (ដោយគ្មានការបោះឆ្នោតរបស់ ជនណាឡើយ) ទោះបីជានៅក្នុងការខូចបង់ ការបន្លំ ឬការ រំលោភបំពានណាមួយ ក៏ដោយ។

*ប្រាក់ពន្ធដារថ្មីៗចំនួន $120 មួយរយម្ភៃពាន់កោដិដុល្លារ ប៉ុន្តែមិនមានអ្វីអាចកាត់បន្ថយឱនភាពរបស់យើងបានឡើយ*

សំណើប្រជាមតិលេខ 38 អនុញ្ញាតឲ្យអ្នកនយោបាយនៅទីក្រុង Sacramento បន្តការចំណាយ។ ពុំមានចំនុចណាក្នុងសំណើប្រជាមតិ 38 តម្រូវឲ្យមានការប្រើប្រាស់មូនិធិឲ្យបានច្បាស់លាស់ ក្នុងការកាត់បន្ថយឱនភាពឡើយ ហើយក៏គ្មានអ្វីអាចបញ្ឈប់អ្នកនយោបាយក្នុងការដឹកនាំពួកយើងវិលទៅរកស្ថានភាពច្របូកច្របល់ដែលពួកយើងកំពុងជួប្រទះឥឡូវនេះឡើយ សូមម្បីតែប្រាក់ពន្ធដារថ្មីចំនួន $120 មួយរយម្ភៃពាន់កោដិដុល្លារ នេះក៏ដោយ។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 38៖

- 27 ទំព័រនៃអក្សរតូច និង គុណវិបត្តិ
- $120 មួយរយម្ភៃពាន់កោដិដុល្លារនៃពន្ធកម្រិតខ្ពស់
- បង្កើនពន្ធប្រាក់ចំណូលសំរាប់ប្រាក់ចំណូលជាប់ពន្ធលើសពី $17, 346។
- បំផ្លាញអាជីវកម្មខ្នាតូចហើយសំឡាប់ការងារ
- មិនមានការទាមទារឲ្យមានការពង្រឹងប្រតិបត្តិការរបស់សាលា
- មិនអាចផ្លាស់ប្តូរក្នុងរយៈពេលដប់ពីរឆ្នាំ - ទោះបីជាមានការបន្លំ ឬការខូចខាត - ដោយគ្មានការបោះឆ្នោតផ្សេងទៀត។

*បោះឆ្នោត ទេ លើសំណើប្រជាមតិ លេខ 38—ជាគុណវិបត្តិមួយទៀត, ថ្លៃចំណាយ ច្រើន ហើយជាការផ្តើមប្រជាសិទ្ធិមួយដែលនាំឱ្យយល់ខុស។*

**ALLAN ZAREMBERG**, ប្រធាន
សភាពាណិជ្ជកម្មកាលីហ្វ័រញ៉ា

**KEN WILLIAMS**, សមាជិក
ក្រុមប្រឹក្សាអប់រំ ខោនធី Orange

**THOMAS HUDSON**, នាយកប្រតិបត្តិ
គណៈកម្មការការពារអ្នកជាប់ពន្ធកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 38 ★

សាលារបស់យើងកំពុងតែជួបបញ្ហា។ មានការកាត់បន្ថយថវិកាជាទឹកប្រាក់ $20 ពីររយពាន់កោដិដុល្លារ។ រដ្ឋទី 47 ក្នុង ចំណោមរដ្ឋទាំង 50 មានខ្ទង់ចំណាយសំរាប់កូនសិស្សម្នាក់។ មានគ្រូបង្រៀន 40,000 នាក់ត្រូវបានបញ្ឈប់ពីការងារ។ជំនួសឲ្យការអប់រំជាអាទិភាព អ្នកនយោបាយបានកំពុងកាត់បន្ថយ។

សំណើប្រជាមតិលេខ 38 ផ្តល់នូវដំណោះស្រាយមួយ។ អ្នកប្រឆាំងរបស់ខ្លួនមិនមានផ្តល់ជាដំណោះស្រាយណាមួយ ក្រៅពីការវាយប្រហារក្នុងដោយប្រើព័ត៌មាននាំឱ្យយល់ខុស។

- កុំជឿលើយុទ្ធវិធីគួរឲ្យខ្លាចដែលទាក់ទងទៅនឹងពន្ធ។ ក្រោមសំណើប្រជាមតិលេខ 38 អត្រាពន្ធលើប្រាក់ចំណូលកើនឡើងចន្លោះរវាង 0.4% ទៅ 2.2% មិនមែន 21% ទេ។
- អាជីវកម្មខ្នាតតូចដែលមានប្រាក់ចំណូលពី $30,000 ទៅ $40,000 ដុល្លារ នឹងមិនត្រូវបាន ″ បំផ្លាញទេ។″ ការបង្កើនជាមធ្យមរបស់សំណើប្រជាមតិលេខ 38 សំរាប់ប្រាក់ចំណូលនៅចន្លោះរវាង $25,000 ទៅ $50,000 ដុល្លារ គឺមានទឹកប្រាក់ចំនួន $54 ដុល្លារ។
- លុយរបស់សំណើ 38 សម្រាប់បណ្តាសាលានានាត្រូវតែប្រគល់ឲ្យកូនសិស្សម្នាក់ៗ គ្រប់ទីតាំងសាលាមូលដ្ឋានទាំងអស់។ វាត្រូវតែបានចំណាយនៅទីនោះ—ដែលជាកន្លែងសិស្សរៀន—ហើយវាត្រូវតែប្រើ ដើម្បីលើកកម្ពស់លទ្ធផលការសិក្សារៀនសូត្ររបស់សិស្ស។ អ្នកនយោបាយមកពី SACRAMENTO មិនអាចប៉ះថវិកានេះបានទេ។
- សំណើប្រជាមតិលេខ 38 ហាមឃាត់មិនឲ្យប្រើថវិកា សាលារៀន ដើម្បីតំឡើងប្រាក់ខែ ប្រាក់សោធននិវត្តន៍ ឬផលប្រយោជន៍ផ្សេងៗការចំណាយលើផ្នែករដ្ឋបាលមិនអាចលើសពី 1% បានទេ។
- មានការទទួលខុសត្រូវពិតប្រាកដ។ សំណើប្រជាមតិលេខ 38 តម្រូវឲ្យ មានសវនកម្ម និងរបាយការណ៍ឯករាជ្យដែលបង្ហាញជាសាធារណៈអំពីលទ្ធផលខាងវិស័យអប់រំ។ ការបែងចែកថវិកាខុសដោយមានបំណង គឺជាបទឧក្រិដ្ឋមួយ។
- អ្នកបោះឆ្នោតអាចកែប្រែសំណើប្រជាមតិលេខ 38 បាន ប៉ុន្តែមិនមែនអ្នកនយោបាយទេ។ នេះការពារការធានារបស់សំណើប្រជាមតិលេខ 38 ដែលអង្គនីតិបញ្ញត្តិមិនអាចបង្វែរលុយចេញពីសាលារៀនបានទេ។

សំណើប្រជាមតិលេខ 38ធានាដល់សាលានូវការផ្តល់មូលនិធិថ្មីដែលមានទឹកប្រាក់ប្រចាំឆ្នាំមធ្យមចំនួន $10 មួយពាន់កោដិដុល្លារសម្រាប់រយៈពេលដប់ពីរឆ្នាំដើម្បីស្តារឡើងវិញនូវការកាត់ប្រាក់ ហើយធ្វើឲ្យប្រសើឡើងវិញនូវលទ្ធផលនៃការអប់រំ។

យើងពឹងផ្អែកលើសាលារដ្ឋដើម្បីអប់រំកូនៗរបស់ពួកយើង និងផ្តល់ដល់និយោជកនានានូវបុគ្គលិកដែលមានជំនាញ និងផលិតភាព។ ការមិនបានវិនិយោគទៅលើសាលារៀនធ្វើឲ្យប៉ះពាល់ដល់កូនៗ និងសេដ្ឋកិច្ចរបស់យើង។

សូមអានប្រជាមតិលេខ 38 ខ្លួនឯងនៅគេហទំព័រ *prop38forlocalschools.org.*

ធ្វើឲ្យសាលារៀនជាអាទិភាព។ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 38។

**CELIA JAFFE**, ប្រធាន
សមាគមមាតាបិតា គ្រូបង្រៀន មណ្ឌលទី 4 ខោនធី Orange

**ALEX KAJITANI**
គ្រូបង្រៀនឆ្នើមប្រចាំឆ្នាំ 2009 កាលីហ្វ័រញ៉ា

**TINA REPETTI-RENZULLO**
គ្រូបង្រៀនឆ្នើមប្រចាំឆ្នាំ 2010–2011 ខោនធី Los Angeles

សំណើប្រជាមតិ

# 39 លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។



## លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

- ដំរូវឲ្យពាណិជ្ជកម្មពហុរដ្ឋ គិតគូរបំណុលពន្ធដារប្រាក់ចំណូលរដ្ឋកាលីហ្វ័រនីញ៉ារបស់គេ ដោយយោងទៅលើភាគរយ នៃការលក់ដូររបស់គេ ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។
- លុបបំបាត់ច្បាប់ជាធរមាន ដែលផ្តល់ឲ្យពាណិជ្ជកម្មពហុរដ្ឋនូវជំរើសមួយ ដើម្បីជ្រើសរើសរូបមន្តបំណុលពន្ធដារ ដែលផ្តល់លក្ខខ័ណ្ឌពន្ធដារ ជាទីគាប់ចិត្ត សំរាប់ពាណិជ្ជកម្ម ដែលមានទ្រព្យសម្បត្តិ និងបញ្ជីបើកប្រាក់ខែនៅក្រៅ រដ្ឋកាលីហ្វ័រនីញ៉ា។
- ត្រៀមទុក $550 លានជាប្រចាំឆ្នាំ ចំនួនប្រាំឆ្នាំ ចេញពីកំណើនប្រាក់ចំណូលដែលសង្ឃឹម សំរាប់គោលបំណង នៃការផ្តល់ថវិកា ដែលបង្កើតឲ្យមានថាមពលបរិបូរណ៍ និងការងារថាមពលល្អស្អាត ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

### អ្នកវិភាគសេចក្តីសង្ខេបនៃនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ៖

- ប្រហែល $1 កោដិ បន្ថែមលើប្រាក់ចំណូលរបស់រដ្ឋជាប្រចាំឆ្នាំ—កើនឡើងគ្រឿនៗ—ចេញពីការបំបាត់ចោលសមត្ថភាព នៃពាណិជ្ជកម្មពហុរដ្ឋ ដើម្បីជ្រើសរើសរបៀបពន្ធដារលើប្រាក់ចំណូលរបស់គេ នៅរដ្ឋកាលីហ្វ័រនីញ៉ា ត្រូវបានអនុម័តជា យ៉ាងណា។ ការនេះនឹងបណ្តាលឲ្យមានការបង់ពន្ធរដ្ឋច្រើន នៅក្នុងពាណិជ្ជកម្មពហុរដ្ឋខ្លះ។
- ក្នុងបណ្តានៃប្រាក់ចំណូលដែលបានមកតាមរយៈរបៀបនេះ ក្នុងពេលប្រាំឆ្នាំខាងមុខ ប្រហែលជាពាក់កណ្តាល នឹងបានត្រៀមសំរាប់ថាមពលបរិបូរណ៍ និងផែនការថាមពលផ្សេងទៀត។
- ក្នុងបណ្តានៃប្រាក់ចំណូលដែលនៅសល់ មួយផ្នែកធំប្រហែលនឹងបានចំណាយទៅលើសាលារៀនសាធារណៈ និងមហាវិទ្យាល័យតាម សហគមន៍។

---

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### សាវតារ

***ពន្ធលើប្រាក់ចំណូលសាជីវកម្មរបស់រដ្ឋ។*** ចំនួនទឹកប្រាក់ដែលអាជីវកម្មមួយចំពាក់រដ្ឋនៅក្នុងពន្ធប្រាក់ចំណូលក្រុមហ៊ុនក្នុងមួយឆ្នាំៗ គឺអាស្រ័យទៅលើប្រាក់ចំណូលជាប់ពន្ធរបស់អាជីវកម្មនោះ។ ចំពោះអាជីវកម្មមួយដែលដំណើរការទាំងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា និងនៅក្នុងរដ្ឋ ឬ ប្រទេសផ្សេងៗទៀត (អាជីវកម្មពហុរដ្ឋ) ពន្ធរបស់រដ្ឋ គឺគិតទៅលើតែផ្នែកនៃប្រាក់ចំណូលរបស់ខ្លួនដែលពាក់ព័ន្ធជាមួយនឹងរដ្ឋកាលីហ្វ័រញ៉ាប៉ុណ្ណោះ។ ដោយសារមានតែមួយចំណែកតូចប៉ុណ្ណោះនៃក្រុមហ៊ុនមានលក្ខណៈពហុរដ្ឋ ក្រុមហ៊ុនពហុរដ្ឋទាំងឡាយបង់មួយភាគធំនៃពន្ធប្រាក់ចំណូលក្រុមហ៊ុនរបស់រដ្ឋ។ ពន្ធនេះ គឺជាប្រភពប្រាក់ចំណូលនៅក្នុងកញ្ចប់ថវិកាទូទៅធំបំផុតទីបីរបស់រដ្ឋ ដោយប្រមូលបានចំនួន $៩.៦ ប្រាំបួនរយប្រាំមួយកោដិដុល្លារក្នុងឆ្នាំ 2010–11។

***ពាណិជ្ជកម្មពហុរដ្ឋជ្រើសរើសរបៀបការកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គេ។*** ថ្មីៗនេះច្បាប់រដ្ឋអនុញ្ញាតឲ្យអាជីវកម្មពហុរដ្ឋភាគច្រើនធ្វើការជ្រើសរើសយកវិធីសាស្រ្តមួយក្នុងចំណោមវិធីសាស្រ្តចំនួនពីរសម្រាប់កំណត់បរិមាណបាក់ចំណូលរបស់ពួកគេដែលពាក់ព័ន្ធនឹងរដ្ឋកាលីហ្វ័រញ៉ា និងអាចកាត់ពន្ធបាន ដោយរដ្ឋ៖

- ***វិធីសាស្រ្តបីកត្តា" នៃការកំណត់ប្រាក់ចំណូលជាប់ពន្ធ។*** វិធីសាស្រ្តមួយប្រើប្រាស់ទីតាំងលក់ ទ្រព្យសម្បត្តិ និងនិយោជិករបស់ក្រុមហ៊ុន។ នៅពេលប្រើប្រាស់វិធីសាស្រ្តនេះកាលណាអាជីវកម្មពហុរដ្ឋមានការលក់ ទ្រព្យសម្បត្តិ ឬ និយោជិកកាន់តែច្រើននៅក្នុងរដ្ឋកាលីហ្វ័រញ៉ា នោះប្រាក់ចំណូលកាន់តែច្រើនរបស់អាជីវកម្មនោះត្រូវជាប់ពន្ធរដ្ឋ។

39

# សំណើប្រជាមតិ 39 លក្ខខណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្ដល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិប្បូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** **(ត)**

- ***វិធីសាស្ត្រកត្តាលក់តែមួយ" នៃការកំណត់ប្រាក់ចំណូលជាប់ពន្ធ។*** វិធីសាស្ត្រផ្សេងទៀតប្រើប្រាស់តែទីតាំងលក់របស់ក្រុមហ៊ុនប៉ុណ្ណោះ។ នៅពេលប្រើប្រាស់វិធីសាស្ត្រនេះ កាលណាអាជីវកម្មពហុរដ្ឋលក់បានកាន់តែច្រើននៅក្នុងរដ្ឋកាលីហ្វ័រញ៉ា នោះប្រាក់ចំណូលកាន់តែច្រើនរបស់អាជីវកម្មនោះត្រូវជាប់ពន្ធ។ (ឧទាហរណ៍ ប្រសិនបើផលិតផលមួយភាគបួនរបស់ក្រុមហ៊ុនត្រូវបានលក់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ហើយផលិតផលដែលនៅសល់ស្ថិតនៅក្នុងរដ្ឋដទៃទៀត នោះចំនួនមួយភាគបួននៃប្រាក់ចំណេញសរុបរបស់ក្រុមហ៊ុននឹងត្រូវជាប់ពន្ធដាររបស់រដ្ឋកាលីហ្វ័រញ៉ា។)

ជាទូទៅអាជីវកម្មពហុរដ្ឋត្រូវបានអនុញ្ញាតឲ្យជ្រើសរើសវិធីសាស្ត្រមួយដែលផ្តល់ប្រយោជន៍ច្រើនបំផុតដល់ពួកគេសម្រាប់គោលបំណងពន្ធដារ។

***កម្មវិធីថាមពលមានប្រសិទ្ធិភាព។*** ថ្មីៗនេះ មានកម្មវិធីរបស់រដ្ឋយ៉ាងច្រើនត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺមានគោលបំណងកាត់បន្ថយតម្រូវការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធថាមពលថ្មី (ដូចជា រោងចក្រផលិតថាមពល និងប្រព័ន្ធខ្សែភ្លើង) និងជួយបំពេញទៅតាមបទដ្ឋានគុណភាពបរិស្ថាន។ ឧទាហរណ៍ គណៈកម្មការសេវាសាធារណៈរដ្ឋកាលីហ្វ័រញ៉ា (CPUC) ត្រួតពិនិត្យមើលប្រភេទផ្សេងៗនៃការបង្កើនប្រសិទ្ធភាព ថាមពល និងកម្មវិធីផ្តល់ថវិកាទិញគ្រឿងបរិក្ខារដែលត្រូវបានផ្តល់តាមរយៈថវិកាដែលប្រមូលបានពីអ្នកបង់ពន្ធសេវាសាធារណៈ។ លើសពីនេះទៅទៀត គណៈកម្មការថាមពល រដ្ឋកាលីហ្វ័រញ៉ា (CEC) បង្កើតបទដ្ឋានសម្រាប់អាគារ និងគ្រឿងបរិក្ខារក្នុងគោលបំណងកាត់បន្ថយការប្រើប្រាស់ថាមពលនៅក្នុងរដ្ឋ។

***រូបមន្តផ្តល់ថវិកាដល់សាលារៀន។*** សំណើប្រជាមតិ 98 ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតនៅក្នុងឆ្នាំ 1988 និងត្រូវបានធ្វើការកែសម្រួលនៅក្នុងឆ្នាំ 1990 តម្រូវឲ្យមានការផ្តល់ថវិកាកម្រិតអប្បបរមានៃរដ្ឋ និងរដ្ឋបាលមូលដ្ឋានក្នុងឆ្នាំនីមួយៗដល់សាលារៀនរដ្ឋ និងមហាវិទ្យាល័យសហគមន៍ (ដែលសំដៅថាជាសាលារៀន)។ កម្រិតនៃការផ្តល់ថវិកានេះត្រូវបានគេស្គាល់ជាទូទៅថាជាការធានាកម្រិតអប្បបរមានៃសំណើប្រជាមតិ 98។ ទោះបីជាអង្គនីតិបញ្ញត្តិអាចព្យួរការធានា និងផ្តល់ថវិកានៅ កំរិតក្រោមក៏ដោយ ជាធម្មតា អង្គនីតិបញ្ញត្តិអាចសម្រេចផ្តល់ថវិកាស្មើនឹង ឬច្រើនជាងការធានានោះ។ ការធានានៅក្នុងសំណើប្រជាមតិ 98 អាចកើនឡើងស្របពេលមានកំណើនប្រាក់ចំណូលក្នុងកញ្ចប់ថវិកាទូទៅរបស់រដ្ឋ (បូករួមទាំងថវិកាទាំងឡាយដែលប្រមូលបានពីពន្ធប្រាក់ចំណូលក្រុមហ៊ុនរបស់រដ្ឋ)។ ទន្ទឹមគ្នានេះដែរ វិធានការមួយ - ដូចជាវិធានការមួយនេះ - ដែលធ្វើឲ្យប្រាក់ចំណូលមានកម្រិតខ្ពស់ ក៏អាចធ្វើឲ្យការធានាការផ្តល់ថវិកាសម្រាប់សាលារៀនកើនឡើងខ្ពស់ដែរ។ ខ្ទង់ចំណាយក្នុងសំណើប្រជាមតិ 98 គឺជាប្រភេទធំបំផុតនៃការចំណាយនៅក្នុងកញ្ចប់ថវិការបស់រដ្ឋ - ដែលមានចំនួនសរុបប្រហែល 40 ភាគរយនៃខ្ទង់ចំណាយនៅក្នុងកញ្ចប់ថវិកាទូទៅរបស់រដ្ឋ។

## សេចក្តីស្នើច្បាប់

***បញ្ចប់សមត្ថភាពរបស់ពាណិជ្ជកម្មពហុរដ្ឋក្នុងការជ្រើសរបៀបកំណត់ប្រាក់ចំណូលជាប់ពន្ធ។*** ក្រោមវិធានការនេះ ចាប់ផ្តើមនៅក្នុងឆ្នាំ 2013 អាជីវកម្មពហុរដ្ឋទាំងឡាយនឹងមិនត្រូវបានអនុញ្ញាតឲ្យធ្វើការជ្រើសរើសវិធីសាស្ត្រសម្រាប់កំណត់ប្រាក់ចំណូលជាប់ពន្ធរដ្ឋរបស់ពួកគេ ដែលផ្តល់ផលប្រយោជន៍ច្រើនបំផុតដល់ពួកគេទៀតឡើយ។ ផ្ទុយទៅវិញ អាជីវកម្មពហុរដ្ឋភាគច្រើននឹងត្រូវកំណត់ប្រាក់ចំណូលជាប់ពន្ធរដ្ឋកាលីហ្វ័រញ៉ារបស់ពួកគេដោយប្រើប្រាស់វិធីសាស្ត្រកត្តាលក់តែមួយគត់។ អាជីវកម្មទាំងឡាយដែលដំណើការតែនៅក្នុងរដ្ឋកាលីហ្វ័រញ៉ានឹងមិនរងឥទ្ធិពលពីវិធានការនេះឡើយ។

វិធីសាស្ត្រនេះក៏រួមបញ្ចូលផងដែរនូវច្បាប់នានាទាក់ទងនឹងវិធីដែលអាជីវកម្មពហុរដ្ឋទាំងអស់គណនាចំណែកនៃការលក់មួយចំនួនដែលត្រូវបានបែងចែកទៅឲ្យរដ្ឋកាលីហ្វ័រញ៉ាក្នុងគោលបំណងបង់ពន្ធរដ្ឋ។ វិធានការទាំងនេះរួមបញ្ចូលសំណុំច្បាប់ជាក់លាក់មួយចំនួនសម្រាប់ក្រុមហ៊ុនខ្សែកាបធំៗ។

# សំណើប្រជាមតិ 39 លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ (ត)

***ផ្តល់ថវិកាសំរាប់ថាមពលមានប្រសិទ្ធិភាព និងគំរោងថាមពលទូបថ។*** វិធានការនេះបង្កើតថវិកាថ្មីរបស់រដ្ឋ ហៅថាមូលនិធិបង្កើតការងារថាមពលស្អាត សម្រាប់ឧបត្ថម្ភគម្រោងនានាក្នុងគោលបំណងបង្កើនប្រសិទ្ធភាពថាមពល និងពង្រីកការប្រើប្រាស់ថាមពលជំនួស។ វិធានការនេះចែងថា ថវិកានេះអាចប្រើប្រាស់សម្រាប់ឧបត្ថម្ភៈ (1) គម្រោងកែលម្អប្រសិទ្ធភាពថាមពល និងគម្រោងថាមពលជំនួសផ្សេងទៀតនៅក្នុងសាលារៀនសាធារណៈ មហាវិទ្យាល័យ សាកលវិទ្យាល័យ និងអាគារសាធារណៈដទៃទៀត (2) ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការកែលម្អថាមពល និង (3) កម្មវិធីបណ្តុះបណ្តាលការងារ និងអភិវឌ្ឍន៍កម្លាំងពលកម្មទាក់ទងនឹងប្រសិទ្ធផលថាមពល និងថាមពលជំនួសផ្សេងទៀត។ អង្គនីតិបញ្ញត្តិនឹងកំណត់ការចំណាយចេញពីថវិកានេះ ហើយតម្រូវឲ្យប្រើប្រាស់ថវិកានេះសម្រាប់គម្រោងមានប្រសិទ្ធភាពខាងការចំណាយដែលអនុវត្តដោយទីភ្នាក់ងារមានឯកទេសខាងគ្រប់គ្រងគម្រោងថាមពល។ វិធានការនេះក៏ (1)បញ្ជាក់ផងដែរថា រាល់គម្រោងដែលបានផ្តល់ថវិកាទាំងអស់ត្រូវតែសម្របសម្រួលជាមួយ CEC និង CPUC និង (2) បង្កើតក្រុមប្រឹក្សាត្រួតពិនិត្យថ្មីមួយដែលមានសមាជិកប្រាំបួនរូបសម្រាប់ត្រួតពិនិត្យមើលឡើងវិញ និងវាយតម្លៃជារៀងរាល់ឆ្នាំទៅលើការចំណាយចេញពីថវិកានេះ។

មូលនិធិបង្កើតការងារថាមពលស្អាត នឹងត្រូវបានឧបត្ថម្ភដោយថវិកាមួយចំនួននៃប្រាក់ចំណូលថ្មី ដែលប្រមូលបានតាមរយៈការបញ្ចូលទៅជាកត្តាលក់តែមួយគត់ដែលចាំបាច់។ កាន់តែជាក់លាក់ជាងនេះទៀត ប្រាក់ចំណូលពាក់កណ្តាលដែលប្រមូលបាន - ដែលមានចំនួនអតិបរមា $550 លានដុល្លារ - នឹងត្រូវផ្ទេរជារៀងរាល់ឆ្នាំទៅឲ្យមូលនិធិបង្កើតការងារថាមពលស្អាត។ ការផ្ទេរទាំងនេះនឹងកើតឡើងតែក្នុងរយៈពេលប្រាំឆ្នាំសារពើពន្ធប៉ុណ្ណោះ -គិតចាប់ពីឆ្នាំ 2013–14 ដល់ឆ្នាំ 2017–18។

## ឥទ្ធិពលសារពើពន្ធ

***កំណើនក្នុងប្រាក់ចំណូលរដ្ឋ។*** ដូចបានបង្ហាញរួចហើយនៅបន្ទាត់ខាងលើក្នុងតារាងលេខ 1 វិធានការនេះនឹងបង្កើនប្រាក់ចំណូលរបស់រដ្ឋប្រហែល $1 មួយរយកោដិដុល្លារជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ 2013–14 តទៅ។ (វានឹងមានប្រសិទ្ធភាពក្នុងរយៈពេលប្រហែលកន្លះឆ្នាំនៅក្នុងឆ្នាំ 2012–13។) ប្រាក់ចំណូលដែលកើនឡើងនេះនឹងបានមកពីអាជីវកម្មពហុរដ្ឋមួយចំនួនដែលបង់ពន្ធច្រើន។ ចំនួនថវិកាដែលប្រមូលបានតាមរយៈវិធានការនេះនឹងមានការកើនឡើងបន្តិចម្តងៗ។

**តារាងទី 1**
**ការវាយតំលៃឥទ្ធិពលនៃសំណើប្រជាមតិលេខ 39 លើប្រាក់ចំណូលរដ្ឋ និងការចំណាយ**

| | 2012-13 | 2013-14 រហូតដល់ 2017-18 | 2018-19 និងក្រោយៗទៀត |
|---|---|---|---|
| **ប្រាក់ចំណូលប្រចាំឆ្នាំ** | $500 លាន | $1 មួយរយកោដិ កើនរយៈពេលក្រោយៗមក | លើសពី $1មួយរយកោដិ |
| **ការចំណាយប្រចាំឆ្នាំ** | | | |
| ចំនួនកំណត់សំរាប់គំរោងថាមពល | គ្មាន | $500 លានដល់ $550 លាន | គ្មាន |
| កំណើនធានាសំរាប់មូលនិធិជួយសាលា | $200 លាន $500 លាន | $200 លានដល់ $500 លាន កើនរយៈពេលក្រោយៗមក | $500 លានដល់លើសពី $1 មួយរយកោដិ |

# សំណើប្រជាមតិ 39 លក្ខខណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** **(ត)**

***ប្រាក់ចំណូលខ្លះៗត្រូវប្រើសំរាប់គំរោងថាមពលនានា។*** សម្រាប់រយៈពេលប្រាំឆ្នាំ (2013–14 ដល់ 2017–18) ប្រាក់ចំណូលបន្ថែមប្រហែលពាក់កណ្តាល - ពី $500 លានដុល្លារ ដល់ $550 លានដុល្លារជារៀងរាល់ឆ្នាំ - នឹងត្រូវផ្ទេរទៅឲ្យមូលនិធិបង្កើតការងារថាមពលស្អាត សម្រាប់ឧបត្ថម្ភដល់គម្រោងប្រសិទ្ធភាពថាមពល និងគម្រោងថាមពលជំនួសនានា។

***ថវិកាសាលាទំនងជាកើនឡើងដោយមកពីប្រាក់ចំណូលបន្ថែម។*** ជាទូទៅប្រាក់ចំណូលដែលប្រមូលបានតាមរយៈវិធានការនេះនឹងត្រូវធ្វើការពិចារណាដាក់បញ្ចូលទៅក្នុងការធានាអប្បបរមាប្រចាំឆ្នាំរបស់រដ្ឋក្នុងសំណើប្រជាមតិ 98 ។ ទោះជាយ៉ាងណាក៏ដោយ ថវិកាដែលផ្ទេរទៅឲ្យមូលនិធិបង្កើតការងារថាមពលស្អាត នឹងមិនត្រូវបានប្រើប្រាស់សម្រាប់ធ្វើការគណនានេះឡើយ។ ដូចបានបង្ហាញនៅផ្នែកខាងក្រោមនៃតារាងលេខ 1 ប្រាក់ចំណូលកាន់តែខ្ពស់ ទំនងជានឹងបង្កើនការធានាអប្បបរមាយ៉ាងចិតបំផុតត្រឹម $200 លានដុល្លារ សម្រាប់ឆ្នាំ 2012–13 រហូតដល់ឆ្នាំ 2017–18។ ក៏ប៉ុន្តែរយៈពេលប៉ុន្មានឆ្នាំក្នុងអំឡុងពេលនេះ ការធានាអប្បបរមាអាចនឹងកើនឡើងយ៉ាង ខ្ពស់។ សម្រាប់ឆ្នាំ 2018–19 និងបន្ទាប់ពីនេះការធានានេះទំនងជាមានកម្រិតខ្ពស់យ៉ាងតិចបំផុតត្រឹម $500 លានដុល្លារ។ ក្នុងអំឡុងពេលដំបូង ការធានាក្នុងរយៈពេលប៉ុន្មានឆ្នាំអាចមានកម្រិតខ្ពស់ខ្លាំង។ ចំណែកជាក់លាក់នៃប្រាក់ចំណូលដែលនឹងត្រូវបញ្ជូនទៅឲ្យសាលារៀននៅក្នុងឆ្នាំជាក់លាក់ណាមួយនឹងអាស្រ័យទៅលើកត្តាផ្សេងៗ រួមមានកំណើនសរុបនៃប្រាក់ចំណូលរបស់រដ្ឋ និងទំហំជាប់កាតព្វកិច្ចផ្តល់ថវិកាដល់សាលារៀនដែលនៅមិនទាន់ទូទាត់។

39

# សំណើប្រជាមតិ 39 លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 39 ★

ក្នុងឆ្នាំ 2009,ការព្រមព្រៀងនយោបាយមួយបានបង្កើតច្បាប់បញ្ចៀសពន្ធប្រហែលមួយរយកោដិដុល្លារសំរាប់សាជីវកម្មក្រៅរដ្ឋ . . .

ការចរចាពីថវិកានៅចុងឆ្នាំ 2009 នៅ Sacramento នៅពាក់ កណ្តាលអធ្រាត្រ ក្រុមអ្នកបង្កើតច្បាប់ និងអ្នកបញ្ចុះបញ្ចូលរបស់សាជីវកម្មសំរាប់ក្រុមហ៊ុននៅក្រៅរដ្ឋបានធ្វើកិច្ចព្រមព្រៀងមួយ -ដោយគ្មានសវនាការសាធារណៈនិងការពិភាក្សាវែកញែកទេ។ ពួកគេដាក់ឲ្យមានការបញ្ចៀសពន្ធនៅក្នុងច្បាប់រដ្ឋដែលអនុញ្ញាតឲ្យសាជីវកម្មដែលនៅក្រៅរដ្ឋអាចបន្លំប្រព័ន្ធពន្ធដាររបស់យើងជារៀងរាល់ឆ្នាំ ហើយចៀសវាងការបង់ពន្ធភាគលាភស្មើគ្នារបស់ពួកគេទៅឲ្យរដ្ឋកាលីហ្វ័រញ៉ា។

តម្លៃនៃការបញ្ចៀសពន្ធនៃច្បាប់នេះមាន៖ $1 មួយរយកោដិដុល្លារក្នុងមួយឆ្នាំលើប្រាក់ចំណូលដែលបាត់បង់សម្រាប់រដ្ឋកាលីហ្វ័រញ៉ា។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39 បញ្ចប់ច្បាប់បញ្ចៀសពន្ធសំរាប់សាជីវកម្មក្រៅរដ្ឋ។

សំណើប្រជាមតិលេខ 39 គ្រាន់តែលុបបំបាត់ការបញ្ចៀសពន្ធនៃច្បាប់នេះ។ សំណើប្រជាមតិបញ្ឈប់ការបន្លំនៃប្រព័ន្ធពន្ធដាររបស់យើង - ហើយក៏តម្រូវឲ្យក្រុមហ៊ុនទាំងអស់ដែលធ្វើជំនួញនៅរដ្ឋ កាលីហ្វ័រញ៉ា បង់ពន្ធដូចដែលបានកំណត់ដោយការលក់របស់ពួកគេនៅទីនេះ ដោយមិនគិតពីមូលដ្ឋានដែលពួកគេតាំងនៅទេ។

សំណើប្រជាមតិលេខ 39 *ពង្រាបទីលានលេងឲ្យស្មើភាព* ធានាឲ្យក្រុមហ៊ុនពហុរដ្ឋទាំងឡាយលេងដោយប្រើប្រាស់ច្បាប់ដូចគ្នាទៅនឹងនិយោជកនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39 បញ្ចប់ច្បាប់បញ្ចៀសពន្ធ គឺជាការល្អសំរាប់ទីផ្សារការងារនៅរដ្ឋកាលីហ្វ័រញ៉ា

ច្បាប់ការបញ្ចៀសពន្ធដារបច្ចុប្បន្ននេះអនុញ្ញាតឲ្យក្រុមហ៊ុនបង់ពន្ធតិចជាងមុនទៅឲ្យរដ្ឋកាលីហ្វ័រញ៉ា ប្រសិនបើពួកគេមាននិយោជិកតិចតួចនៅទីនេះ - ដែលផ្តល់ឲ្យក្រុមហ៊ុនទាំងឡាយនូវហេតុផលមួយក្នុងការបញ្ជូនការងារចេញពីរដ្ឋ។

ជាក់ស្តែង អ្នកវិភាគផ្នែកនីតិបញ្ញត្តិដែលគ្មានបក្សព័ន្ធ និងឯករាជ្យរបស់រដ្ឋបានទាញអំណះអំណាងពីការសិក្សា ដែលបង្ហាញថាគោលនយោបាយពន្ធដារនៅក្នុងសំណើប្រជាមតិលេខ 39 នឹងនាំមកឲ្យរដ្ឋ កាលីហ្វ័រញ៉ានូវការងារប្រមាណជា 40,000 ការងារ។ នោះគឺជាហេតុផល ដែលអ្នកវិភាគផ្នែកនីតិបញ្ញត្តិឯករាជ្យបានប្រកាសឲ្យលុបចោលច្បាប់ការបញ្ចៀសពន្ធបច្ចុប្បន្ននេះចេញ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39 មានប្រយោជន៍ដល់អ្នកជាប់ពន្ធនៅកាលីហ្វ័រញ៉ា

សាជីវកម្មពហុរដ្ឋដែលផ្តល់ការងារដ៏តិចតួចនៅទីនេះគឺបានប្រើច្បាប់បញ្ចៀសពន្ធដើម្បីជៀសវាងបង់ពន្ធចំណែកស្មើភាពរបស់គេដល់កាលីហ្វ័រញ៉ា វាបណ្តាលឱ្យអស់តំលៃដល់រដ្ឋ $1 មួយរយកោដិដុល្លារក្នុងមួយឆ្នាំ។ សំណើប្រជាមតិ 39 នឹងបិទការបញ្ចៀសពន្ធរបៀបនេះហើយរក្សាថវិកានោះនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាសំរាប់ផ្តល់ជាប្រាក់ចំណូលដែលត្រូវការយ៉ាងសំខាន់សំរាប់សេវាសាធារណៈ។ ពីព្រោះប្រាក់ចំណូលថ្មីទាំងអស់ស្ទើរតែពាក់កណ្តាលគឺតម្រូវដោយច្បាប់ឲ្យចូលទៅក្នុងវិស័យអប់រំ ទឹកប្រាក់រាប់រយលានដុល្លារជារៀងរាល់ឆ្នាំ នឹងត្រូវបានតំកល់ ទុកសំរាប់សាលារៀន។

បន្ថែមលើនេះ សំណើប្រជាមតិលេខ 39 នឹងបង្កើតប្រាក់សន្សំសំរាប់ អ្នកជាប់ពន្ធជាច្រើន។ សំណើប្រជាមតិលេខ 39 នឹងប្រើប្រាស់មួយភាគនៃប្រាក់ចំណូលដែលបានមកពីការលុបបំបាត់ការគេចពីច្បាប់ដើម្បីផ្តល់មូលនិធិសម្រាប់គម្រោងប្រសិទ្ធភាពថាមពលមាននៅ សាលារៀន និងអគារសាធារណៈផ្សេងទៀត។ ប្រើប្រាស់វិធានការបង្ហាញពីប្រសិទ្ធភាពថាមពល ដូចជា ការកែលម្អ អ៊ីសូឡង់ ប្តូរបង្អួច និងដំបូលដែលលេចធ្លាយ និងការដាក់បន្ថែមការតំឡើងបន្ទះសូឡាស្រូបថាមពលព្រះអាទិត្យខ្នាតតូច នឹងកាត់បន្ថយការចំណាយថាមពលរបស់រដ្ឋ—បង្កើនចំនួនប្រាក់ដុល្លារសម្រាប់សេវាកម្មចាំបាច់ដូចជា ការអប់រំ ប៉ូលីស និងអគ្គីភ័យ។

*"ដោយការបង្កើនប្រសិទ្ធភាពថាមពល សំណើប្រជាមតិលេខ 39 នឹងកាត់បន្ថយការបំពុលបរិយាកាសដែលបណ្តាលឲ្យកើតជំងឺហឺត និងជំងឺសួត។ ក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នភាពអគារសាលារៀន សំណើប្រជាមតិលេខ 39 នឹងបំបាត់ជាតិសំណសារធាតុដែលមិនឆេះ សារធាតុផ្សិត និងសារធាតុពុលផ្សេងទៀតចេញពីសាលារៀន។"—*

Jane Warner, ប្រធាន, សមាគមសួតអាមេរិកាំង ក្នុងរដ្ឋកាលីហ្វ័រញ៉ា។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39—គណនេយ្យភាពដ៏ហ្មត់ចត់

សំណើប្រជាមតិលេខ 39 មានខមាត្រាចែងអំពីការទទួលខុសត្រូវដ៏តឹងរឹងមួយ —រួមទាំងការធ្វើសវនកម្មប្រចាំឆ្នាំឯករាជ្យមួយ បន្តការពិនិត្យ និងការវាយតំលៃដោយក្រុមប្រឹក្សាគ្រប់គ្រងពលរដ្ឋ មានគណនេយ្យភាពគ្រប់សព្វសំរាប់ថវិកា និងការចំណាយនានា និងមានការបញ្ចេញជាសាធារណៈដែរ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39—ជារឿងសាមញ្ញមួយ៖ បិទការបញ្ចៀសពន្ធចេញទៅក្រៅរដ្ឋ។ នាំមកវិញនូវប្រាក់ មួយរយកោដិដុល្លារ ក្នុងមួយឆ្នាំ ត្រឡប់មកកាលីហ្វ័រញ៉ាវិញ។

*http://www.cleanenergyjobsact.com/*

**JANE WARNER,** ប្រធាន
សមាគមសួតអាមេរិកាំងនៅកាលីហ្វ័រញ៉ា

**TOM STEYER,** ប្រធាន
ពលរដ្ឋកាលីហ្វ័រញ៉ា សំរាប់ថាមពលស្អាត និងការងារ

**MARY LESLIE,** ប្រធាន
ក្រុមប្រឹក្សាពាណិជ្ជកម្ម Los Angeles

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 39 ★

ពេលណាអ្នកអានការសន្យាឃោសនាសំរាប់សំណើប្រជាមតិ 39 ត្រូវចាំថា Tom Steyer—ដែលទូរទស្សន៍ CNN ហៅគាត់ថា "ស្តេចមូលនិធិហេជ្ជរបស់កាលីហ្វ័រញ៉ា"—គឺចំណាយ $20 លានដុល្លារសំរាប់ ការបោះឆ្នោតសាកល្បងប្រើពាក្យដែលសូរស័ព្ទប្លែកដូចជាពាក្យ "ការបញ្ចៀសពន្ធ," ហើយសន្យា "ការងារស្អាត។"

កាលីហ្វ័រញ៉ាបានបាត់បង់ពាណិជ្ជកម្មតាមអត្រាគួរឱ្យសំគាល់រួចទៅហើយ។ សួរខ្លួនឯងថា តើការតំឡើងពន្ធលើក្រុមហ៊ុនបំរើការងារដល់ពលរដ្ឋកាលីហ្វ័រញ៉ារាប់រយពាន់នាក់ ធ្វើឱ្យសេដ្ឋកិច្ចគ្រាន់បើ ឬទេ?

វាមិនប្រសើរទេ!

កាលីហ្វ័រញ៉ាជំពាក់បំណុលរាប់កោដិរួចទៅហើយ តែសំណើប្រជាមតិ 39 នឹងធ្វើឱ្យអ្វីៗកាន់តែអាក្រក់ឡើង!

កាលីហ្វ័រញ៉ាគឺ*ជារដ្ឋមួយមិនល្អសំរាប់ការធ្វើជំនួញអស់រយៈកាល ប្រាំបីឆ្នាំជាប់ៗគ្នា* ហើយក៏វិតពិន្ទុក្រេឌិតអាក្រក់ជាងគេបំផុតក្នុងសហរដ្ឋអាមេរិក។ ពលរដ្ឋច្រើនលាននាក់ឥតការងារធ្វើ។

ការបញ្ចៀសពន្ធ? បោះឆ្នោត ទេ លើសំណើប្រជាមតិ 39 លប់ចោលច្បាប់ពន្ធដារដែលមានឥទ្ធិពលច្រើនទស្សវត្សបង្កើនថវិកាចំណូលរដ្ឋ។ អ្នកវិភាគអង្គនិតិបញ្ញត្តិមិនចូលបក្សព័ន្ធ និងក្រសួងហិរញ្ញវត្ថុយល់ស្របថា ៖ សំណើប្រជាមតិ 39 គឺកំណើនពន្ធដារ $1 មួយរយកោដិដុល្លារ។

នេះជាការពិត។ កំណើនពន្ធ $1 មួយរយកោដិដុល្លារផ្តល់ឱ្យនិយោជកកាលីហ្វ័រញ៉ានូវមូលហេតុមួយទៀត មិនឱ្យធ្វើវិនិយោគ ឬជួលអ្នកធ្វើការ។ ការងារតិចតួច មានន័យថា ប្រាក់ចំណូលក៏ទាប ហើយថវិកាសាលារៀន, និងអាជ្ញាធរមានសមត្ថកិច្ចក៏ត្រូវកាត់ច្រើនទៀត។ តើនេះវាល្អសំរាប់កាលីហ្វ័រញ៉ា ឬ?

សំណើប្រជាមតិ 39 គឺជាប្រអប់ឆ្នោត គិតគូរថវិកាដ៏អាក្រក់មួយរបស់វា។ វាឆ្មក់យកថវិកា $2.5 ពីររយប្រាំកោដិពីថវិការដ្ឋ—ជាប្រាក់ដែលអាចជួយសាលារៀន សង់ផ្លូវ, ហេដ្ឋារចនាសម្ព័ន្ធ, ឬសុវត្ថិភាពសាធារណៈ។

សំណើប្រជាមតិ 39 ក៏បន្ថែមការិយាធិបតេយ្យថ្មីៗ—ផ្តល់រាប់លានដុល្លារជាបៀវត្សន៍ និងសោធននិវត្តន៍ដល់អ្នកនយោបាយ។ បក្សពួកគេ។ គ្មានការទទួលខុសត្រូវ ហើយគ្មានវិធានការការពារពលរដ្ឋជាប់ពន្ធប្រឆាំងនឹងអំពើពុករលួយ។

ពន្ធដារខ្ពស់, ការងារតិចតួច, ការិយាធិបតេយ្យច្រើន និងខ្ជះខ្ជាយ . . . ការទទួលខុសត្រូវ សូន្យ ឃើគ្មានការការពារពលរដ្ឋជាប់ពន្ធទល់នឹងការប្រទាំងផលប្រយោជន៍។ នេះហើយជារឿងរ៉ាវរបស់សំណើប្រជាមតិ 39។

បក្សប្រជាធិបតេយ្យ, បក្សឯករាជ្យ, បក្សសាធរណរដ្ឋ យល់ស្របតាមe—បោះឆ្នោត ទេ!

**MIKE SPENCE,** ប្រធាន
គណៈកម្មការការពារអ្នកជាប់ពន្ធកាលីហ្វ័រញ៉ា

**ROBERT MING,** ប្រធាន
មិត្តសំរាប់រក្សាការងារនៅកាលីហ្វ័រញ៉ា

**JACK STEWART,** ប្រធា
សមាគមឧស្សាហកម្ម និងបច្ចេកវិទ្យា កាលីហ្វ័រញ៉ា





*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# សំណើប្រជាមតិ 39 លក្ខខណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 39 ★

សំណើប្រជាមតិលេខ 39 គឺជាកំណើនពន្ធដ៏ច្រើនសន្ធឹកមួយរយកោដិដុល្លារ មកលើអ្នកបង្កើតការងារនៅកាលីហ្វ័រញ៉ាដែលនឹងបណ្តាលឱ្យបាត់បង់ការងាររាប់ពាន់សំរាប់ជនថ្នាក់កណ្តាល។ អត្រាឥតការងារធ្វើក្នុងរដ្ឋកាលីហ្វ័រញ៉ាឡើងដល់កំរិតអាក្រក់ទីបីនៅក្នុងប្រទេស គឺជិតដល់កំរិត 11%។ សំណើប្រជាមតិលេខ 39 ធ្វើឱ្យបញ្ហារបស់យើងកាន់តែយ៉ាប់យុឺនឡើង។

សំណើប្រជាមតិលេខ 39 គឺជាបង្កាន់ដៃសំរាប់ការខ្ជះខ្ជាយ និងពុករលួយ។ វាត្រូវចំណាយរហូតដល់ $22 លានសំរាប់ការិយាធិបតេយ្យថ្មី និងគណៈ កម្មការមានផលប្រយោជន៍ពិសេស។ វាផ្តល់ឱ្យអ្នកនយោបាយនៅ Sacramento នូវសន្លឹកសែកចំហរមួយចំណាយប្រាក់រាប់រយកោដិដោយគ្មានការទទួលខុសត្រូវពិតប្រាកដ ឬការការពារអ្នកជាប់ពន្ធដារទល់នឹងការប្រទាំងផលប្រយោជន៍ពិសេស។

ខាងក្រោមនេះជាអង្គហេតុ ៖ មហាសេដ្ឋីម្នាក់ដែលទូរទស្សន៍ CNN ហៅថា "ស្តេចមូលនិធិហេដ្សរបស់កាលីហ្វ័រញ៉ា" គឺនៅពីក្រោយចំណាយទឹកប្រាក់ជួយសំណើប្រជាមតិ 39, ចំណាយប្រាក់ $20 លានដុល្លារសំរាប់ជះឥទ្ធិពលលើការបោះឆ្នោតរបស់អ្នក និងទិញការបោះឆ្នោត។ អ្នកឱ្យឱវាទនយោបាយរបស់គាត់ប្រើវាក្យសព្ទដូចជា "បិទការបញ្ចៀសពន្ធ" តែកុំជឿពួកគេ។

សំណើប្រជាមតិលេខ 39 ជានយោបាយកំពុងធ្វើការ។ កាលីហ្វ័រញ៉ាត្រូវការកែទម្រង់ មិនមែនបង្កើនពន្ធ និងចំណាយខ្ជះខ្ជាយ។ យើងត្រូវតែបោះឆ្នោត ទេ។

ទឹកប្រាក់ $2.5 ពីររយប្រាំកោដិដុល្លារ ដែលអាចចូលទៅសាលារៀន,សុខាភិបាល និងសង្គមកិច្ច, ការពារបរិស្ថាន ឬសុវត្ថិភាពសាធារណៈជាជាងបង្វែរវាទៅឱ្យគណៈកម្មការរដ្ឋាភិបាលថ្មីមួយ ជាមួយនឹងប្រាក់ខែធាត់ៗ ហើយមានការទទួលខុសត្រូវតិច។ ឱនភាពនៃថវិការដ្ឋរបស់យើងថ្ងៃនេះជិតដល់កំរិត $16 មួយពាន់ប្រាំមួយរយកោដិ ហើយសំណើប្រជាមតិលេខ 39 ធ្វើឱ្យការនេះកាន់តែអាក្រក់ថែមទៀតដោយការការចំណាយខ្ជះខ្ជាយលើការិយាធិបតេយ្យដែលពុំចាំបាច់។

កាលីហ្វញ៉ារញ៉ាត្រូវការគ្រូបង្រៀន និងភ្នាក់ងារប៉ូលីស មិនត្រូវការអ្នកការិយាធិប តេយ្យទៀតទេ!

សំណើប្រជាមតិលេខ 39 វាយប្រហារពាណិជ្ជកម្មដែលផ្តល់ការងារថ្នាក់មធ្យមដល់ពលរដ្ឋកាលីហ្វ័រញ៉ា។ ការងារឧស្សាហកម្មដែលផ្តល់ដល់គ្រួសារគឺត្រូវរលាយបាត់អស់។ ពលរដ្ឋកាលីហ្វ័រញ៉ាធ្វើការធ្ងន់ជិតពីរលាននាក់គឺកំពុងជួបប្រទះការលំបាករកងារគ្រប់ប្រភេទធ្វើ។  ប្រាក់ $1 មួយរយកោដិដុល្លារដែលជាកំណើនពន្ធដោយសំណើប្រជាមតិលេខ 39 ប្តូរច្បាប់ពន្ធដារដែលកំពុងមានឥទ្ធិពលជាង 40 ឆ្នាំ ហើយវា និងត្រូវអស់ថ្លៃច្រើនដល់ការងារកម្មករសហជីព និង មិនសហជីព។

សំណើប្រជាមតិលេខ 39 ពង្រីករដ្ឋាភិបាល និង ការិយាធិបតេយ្យ។ អ្នកបានឮពីមុនរួចមកហើយ។ Sacramento មានផែនការបង្កើតការងារ។ យើងផ្តល់ប្រាក់ឱ្យគេបង្កើតគណៈកម្មការនយោបាយចាត់តាំងមួយជាមួយនឹងឈ្មោះដែល ចាប់អារម្មណ៍ដូចជា ក្រុមប្រឹក្សាគ្រប់គ្រងពលរដ្ឋ។ ពួកគេទទួលសន្លឹកសែកចំហរដើម្បីចំណាយ(ឬខ្ជះខ្ជាយ) ប្រាក់ពន្ធ។

ក្រោមសំណើប្រជាមតិលេខ 39 ប្រាក់ត្រូវចំណាយដើម្បីផ្តលកុងត្រាទៅកម្មវិធីដែលហៅថា "ថាមពលបៃតង"។ តើនរណាទំនងជាទទួលបានកុងត្រានេះ? អ្នកធ្វើវិភាគទានយុទ្ធនាការឃោសនាធំៗ ដែលសរសេរតាក់តែង សំណើប្រជាមតិលេខ 39 យ៉ាងអាក្រក់បំផុត សំណើនោះមិនមានហាមឃាត់អ្នកម៉ៅការពីការធ្វើវិភាគទានថវិកាឃោសនាទៅឱ្យអ្នកនយោបាយ SACRAMENTO ដែលផ្តល់កុងត្រានោះឱ្យ។

កាលីហ្វ័រញ៉ាត្រូវការកែទម្រង់, មិនមែនបង្កើនពន្ធដែលបំបាត់ការងារថ្នាក់កណ្តាលនោះទេ។ សំណើប្រជាមតិលេខ 39 តំឡើងពន្ធ $1 មួយរយកោដិដុល្លារលើអ្នកបង្កើត ការងារនៅកាលីហ្វ័រញ៉ាដើម្បីផ្តល់ថវិកាសំរាប់ការិយាធិបតេយ្យក្នុងរដ្ឋាភិបាលកាន់តែ ច្រើននិងបំប៉ោងប្រាក់សោធននិវត្តន៍ថែមទៀត។ វាមិនការពារទប់ទល់នឹងឧនភាពដែលរដ្ឋកំពុងតែជួបប្រទះ, ភាពឥតការងារធ្វើខ្ពស់, និងបន្តសេដ្ឋកិច្ចធ្លាក់ចុះ។

ចងចាំថា មហាសេដ្ឋីម្នាក់មានរបៀបវារៈរបស់ខ្លួនកំពុងនៅពីក្រោយចេញប្រាក់ជួយសំណើប្រជាមតិលេខ 39។ ជាស្រេចតែឆន្ទៈអ្នកបោះឆ្នោតទេក្នុងការការពារពលរដ្ឋជាប់ពន្ធនៅកាលីហ្វ័រញ៉ា។ ដោយបោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 39។ អ្នកនឹងបញ្ឈប់ការសំឡាប់ការងារនៃប្រាក់ពន្ធកំណើន $1 មួយរយកោដិដុល្លារលើអ្នកបង្កើតការងារនៅកាលីហ្វ័រញ៉ា។ អ្នកនឹងគាំទ្រការងារថ្នាក់មធ្យមនៅកាលីហ្វ័រញ៉ាដែល ផ្តល់ដល់គ្រួសារនឹងទ្រទ្រង់ដល់សេដ្ឋកិច្ចយើង។ ហើយអ្នកនឹងប្រាប់អ្នកនយោបាយ Sacramento ថា គ្មានសន្លឹកសែកចំហរសំរាប់ក្រុមមានផលប្រយោជន៍ពិសេស សំរាប់ចំណាយលើការបំប៉ោងរដ្ឋាភិបាល និងសោធននិវត្តន៍របស់គ។

និយាយថា ទេ ទល់នឹងពន្ធដារខ្ពស់ ការចំណាយខ្ជះខ្ជាយ និងនយោបាយជាធម្មតា។ តំរូវឱ្យមានការទទួលខុសត្រូវពីរដ្ឋាភិបាល។ បោះឆ្នោត ទេ សំណើប្រជាមតិលេខ 39។

**JACK STEWART,** ប្រធាន
សមាគមឧស្សាហកម្ម និងបច្ចេកវិទ្យា កាលីហ្វ័រញ៉ា

**LEW UHLER,** ប្រធាន
គណៈកម្មាធិការកំរិតពន្ធដារជាតិ

**PAT FONG KUSHIDA,** ប្រធាន
សភាពាណិជ្ជកម្មអាស៊ីប៉ាស៊ីហ្វិក កាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 39 ★

អង្គហេតុ ៖ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 39 បិទការបញ្ចៀសពន្ធសំរាប់សាជីវកម្មក្រៅរដ្ឋ។

ទឡ្ហីករណ៍ប្រឆាំងគឺមានភាពបោកបញ្ឆោតគួរឲ្យខ្មាស់។ សំណើប្រជាមតិលេខ 39 មិនបានតំឡើងពន្ធទៅលើគ្រួសារដែលរស់នៅរដ្ឋកាលីហ្វ័រញ៉ា សូម្បីតែមួយសេន។ សំណើប្រជាមតិនេះគ្រាន់តែលុបបំបាត់ការគេចពីច្បាប់ដែលផ្តល់ឲ្យក្រុមហ៊ុននៅក្រៅរដ្ឋនូវការលើកលែងពន្ធដែលអយុត្តិធម៌ ប៉ុន្តែដាក់បន្ទុកចំណាយដល់យើងទាំងអស់គ្នា។

ដូច្នេះហើយទើបក្រុមហ៊ុននៅក្រៅរដ្ឋនានា—រួមបញ្ចូលក្រុមហ៊ុននានា ដែលគ្របដណ្តប់ "ក្រុមអ្នកផលិត" ដែលបានចុះហត្ថលេខាលើទឡ្ហីករណ៍ខាងលើ
—កំពុងធ្វើការឃោសនាបោកបញ្ឆោតប្រឆាំងទៅនឹងសំណើប្រជាមតិលេខ 39:
ដើម្បីរក្សាទុកនូវច្បាប់ការបញ្ចៀសពន្ធដដែល។
អង្គនិតិបញ្ញត្តិ និងក្រុមតស៊ូមតិបង្កើតការបញ្ចៀសពន្ធនេះក្នុងកិច្ចព្រមព្រាងសំងាត់កាលពីឆ្នាំ 2009។

ព័ត៌មាន San Jose Mercury បាននិយាយថាអ្នកបញ្ចុះបញ្ចូលរបស់ក្រុមហ៊ុន "បានទាញយ៉ាងលឿននៅរដ្ឋកាលីហ្វ័រញ៉ា" ហើយថា "វាជាប្រភេទនៃការបោកបាស្រ់ដែលផ្តល់ឲ្យក្រុមហ៊ុននូវកេរ្តិ៍ឈ្មោះអាក្រក់ ហើយធ្វើឲ្យមានការចំអកដល់ភាពបើកចំហរបស់រដ្ឋាភិបាល។"

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 39  លុបបំបាត់ច្បាប់បញ្ចៀសពន្ធបោសសម្អាតភាពរញ៉េរញ៉ៃដែលអង្គនីតិបញ្ញត្តិបានបង្កើតឡើង។
អង្គហេតុ ៖ សំណើប្រជាមតិលេខ 39 បង្កើតការងារនៅកាលីហ្វ័រញ៉ា

ទឡ្ហីករណ៍ប្រឆាំងអំពីការយកពន្ធពីនិយោជកគឺជាការកំប្លែងមួយ។ ច្បាប់បញ្ចៀសពន្ធគឺមានផលប្រយោជន៍ដល់សាជីវកម្មដែលរក្សាការងារក្រៅរដ្ឋ។

សំណើប្រជាមតិលេខ 39 នឹងលុបបំបាត់ឧបសគ្គក្នុងការ បង្កើតការងារក្នុងរដ្ឋកាលីហ្វ័រញ៉ា។ លើសពីនេះ សំណើប្រជាមតិលេខ 39 បានបង្កើតការងារថាមពលស្អាតរាប់ពាន់ទៀត។
អង្គហេតុ ៖ តំរូវឱ្យមានការទទួលខុសត្រូវហ្មត់ចត់បំផុត

ទឡ្ហីករណ៍ប្រឆាំងដែលក្លែងក្លាយអំពីការិយាធិបតេយ្យគឺគ្មានន័យ។ សំណើប្រជាមតិលេខ 39 បង្កើតគណៈកម្មការក្រុមប្រឹក្សាប្រជាពលរដ្ឋដើម្បីធានាថាថវិកាដែលបានបរិច្ចាគសំរាប់តែការបង្កើតការងារនិងប្រសិទ្ធិភាពថាមពល ត្រូវបានចំណាយយ៉ាងត្រឹមត្រូវ  រាប់បញ្ចូលទាំងការធ្វើសវនកម្មឯករាជ្យប្រចាំឆ្នាំ។ សាលារៀននឹងទទួលបានទឹកប្រាក់រាប់រយលាននៅក្នុងការផ្គត់ផ្គង់ថវិកា ដែលបានកំណត់ទុក ពោលបានពីការលុបបំបាត់ច្បាប់បញ្ចៀសពន្ធ។
បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 39 បិទច្បាប់បញ្ចៀសពន្ធ
—រក្សាទុកប្រាក់ដុល្លារ និងការងារក្នុងរដ្ឋកាលីហ្វ័រញ៉ា។

**ALAN JOSEPH BANKMAN,** សាស្ត្រាចារ្យ ច្បាប់ផ្នែកពន្ធដារ
សាលាច្បាប់ Stanford

**RUBEN GUERRA,** CEO
សមាគមពាណិជ្ជកម្មឡាទីណូ

**JANE SKEETER**
ម្ចាស់អាជីវកម្មខ្នាតតូច កាលីហ្វ័រញ៉ា

39

# ការដាក់កំរិត។ មណ្ឌលរដ្ឋព្រឹទ្ធសភា។ ប្រជាមតិ។

**ចំណាងជើងជាផ្លូវការ និងសេចក្តីសង្ខេប** **រៀបចំដោយអគ្គមេធាវី**

## ការដាក់កំរិត។ មណ្ឌលរដ្ឋព្រឹទ្ធសភា។ ប្រជាមតិ។

- ការបោះឆ្នោត "បាទ/ចាស" មានន័យថាយល់ព្រម ហើយការបោះឆ្នោត "ទេ" បដិសេធមានន័យថា ដ្បិតមណ្ឌលរដ្ឋព្រឹទ្ធសភាថ្មី ត្រូវបានចាប់ឆ្នោតដោយគណៈកម្មពលរដ្ឋបែងចែកមណ្ឌល។
- បើសិនមណ្ឌលថ្មីបានបដិសេធ ព្រំដែនមណ្ឌលរដ្ឋព្រឹទ្ធសភា នឹងបានកែសំរួលដោយមន្ត្រី ដែលត្រួតមើលដោយតុលាការជាន់ខ្ពស់រដ្ឋកាលីហ្វ័រនីញ៉ា។
- មណ្ឌលរដ្ឋព្រឹទ្ធសភា ត្រូវបានកែប្រែរៀងរាល់ 10 ឆ្នាំ បន្ទាប់ពីការជំរឿនប្រជាជននៃរដ្ឋបាលសហព័ន្ធ។

### សេចក្តីសង្ខេបនៃអ្នកវិភាគនីតិបញ្ញត្តិ ប្រមាណនូវឥទ្ធិពលហិរញ្ញវត្ថុទូទាត់រួចរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ៖

- បើអ្នកបោះឆ្នោត បោះឆ្នោត "បាទ/ចាស" និងយល់ព្រមផែនទីមណ្ឌលរដ្ឋព្រឹទ្ធសភា ដែលបានបញ្ជាក់ដោយគណៈកម្មការ ពលរដ្ឋបែងចែកមណ្ឌល នោះនឹងគ្មានឥទ្ធិពលហិរញ្ញវត្ថុ ចំពោះរដ្ឋ ឬរដ្ឋាភិបាលមូលដ្ឋានទេ។
- បើអ្នកបោះឆ្នោត បោះឆ្នោត "ទេ" ហើយបដិសេធផែនទីមណ្ឌលរដ្ឋព្រឹទ្ធសភា ដែលបានបញ្ជាក់ដោយគណៈកម្មការ ពលរដ្ឋបែងចែកមណ្ឌល រដ្ឋនឹងចំណាយប្រាក់មួយដង ប្រហែល $500,000 ដើម្បីស្ថាបនាមណ្ឌលរដ្ឋព្រឹទ្ធសភាថ្មី។ ខោនធីទាំងឡាយ នឹងចំណាយប្រាក់មួយដង ប្រហែល $500,000 ទូទាំងរដ្ឋ ដើម្បីបង្កើតផែនទីសង្កាត់ថ្មី និងសំភារៈ ជាប់ទាក់ទងការបោះឆ្នោត សំរាប់មណ្ឌលថ្មី។

## ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

### សាវតារ

***អង្គនិតិបញ្ញត្តិកាលីហ្វ័រញ៉ា ៖ ព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ*** រដ្ឋកាលីហ្វ័រញ៉ាត្រូវបានបែងចែកជា 40 មណ្ឌលព្រឹទ្ធសភារបស់រដ្ឋ ដោយមានព្រឹទ្ធសមាជិកម្នាក់តំណាងឲ្យមណ្ឌលព្រឹទ្ធសភានីមួយៗ។ រដ្ឋកាលីហ្វ័រញ៉ាក៏ត្រូវបែងចែកជា 80 មណ្ឌលសភារបស់រដ្ឋ ដោយមានសមាជិកសភាម្នាក់តំណាងឲ្យមណ្ឌលសភានីមួយៗ។ ធម្មនុញ្ញរដ្ឋតម្រូវឲ្យមណ្ឌលព្រឹទ្ធសភា និងសភានីមួយៗរក្សាទុកចំនួនប្រជាជនឲ្យមានចំនួនប្រហាក់ប្រហែលគ្នា ដូចមណ្ឌលព្រឹទ្ធសភា និងសភាផ្សេងទៀតដែរ។

***ការកំណត់ព្រំដែនមណ្ឌល។*** ជារៀងរាល់ 10 ឆ្នាំម្តង បន្ទាប់ពីការជំរឿនប្រជាជន សហព័ន្ធរាប់ចំនួនប្រជាពលរដ្ឋដែលរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ខ្សែបន្ទាត់ព្រំដែនព្រឹទ្ធសភា សភា គណៈកម្មការសមកម្ម និងមណ្ឌលសភាតំណាងរាស្ត្រត្រូវបានកែសំរួល។ មុនឆ្នាំ 2008 អង្គនីតិបញ្ញាតិទទួលខុសត្រូវលើការកែសំរួលខ្សែព្រំដែនរបស់មណ្ឌលទាំងនេះ។ ក្នុងឆ្នាំ 2008 និង 2010 អ្នកបោះឆ្នោតរបស់រដ្ឋបានអនុម័តលើសំណើប្រជាមតិលេខ 11 និង 20 តាមលំដាប់លំដោយ ដោយផ្ទេរការទទួលខុសត្រូវក្នុងការកំណត់អំពីខ្សែព្រំដែនមណ្ឌលទាំងនេះ ទៅឲ្យគណៈកម្មការបែងចែកមណ្ឌល របស់ពលរដ្ឋថ្មីមួយ។

***គណៈកម្មការពលរដ្ឋបែងចែកមណ្ឌល។*** រដ្ឋធម្មនុញ្ញតម្រូវថាគណៈកម្មការ មានសមាជិក 14 រូបដែលរួមមានបីក្រុមនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះ—សមាជិក 5 រូបដែលបានចុះបញ្ជីក្នុងគណបក្សនយោបាយធំបំផុតក្នុងរដ្ឋ សមាជិក 5 រូបដែលបានចុះបញ្ជីក្នុងគណបក្សនយោបាយធំបំផុតទីពីរ និងសមាជិក 4 រូបដែលមិនបានចុះបញ្ជីក្នុងគណបក្សទាំងនេះ។ ប្រអប់ដែលនៅជិតសង្ខេបពី (1) ដំណើរការដែលធ្លាប់ជ្រើសរើសអ្នកតំណាង និង (2) លក្ខណៈវិនិច្ឆ័យដែលរដ្ឋធម្មនុញ្ញតម្រូវឲ្យអ្នកតំណាងធ្វើការពិចារណានៅពេល ដែលមានការកំណត់ព្រំដែនមណ្ឌល។ វិធានការទាំងឡាយតាមរយៈគណកម្មការដើម្បីអនុវត្ត (ឬ"បញ្ជាក់")ព្រំដែនមណ្ឌលតម្រូវឲ្យមានការអនុម័តពីអ្នកតំណាងប្រាំបួននាក់ រួមមាន យ៉ាងតិចបំផុតមានការបោះឆ្នោត "បាទ/ចាស" មកពីក្រុមអ្នកតំណាងនីមួយៗនៃក្រុមទាំងបី។

**ដំណើរការជ្រើសរើសគណៈកម្មការបែងចែកមណ្ឌលរបស់ពលរដ្ឋ**

នៅរៀងរាល់ដប់ឆ្នាំ អ្នកតំណាង 14 នាក់ នឹងត្រូវបានជ្រើសរើសបន្តទៅក្នុងនីតិវិធីបីជំហាននេះ ៖

- ***ការបង្កើតក្រុមអ្នកដាក់ពាក្យសុំ។*** អ្នកបោះ ឆ្នោតរបស់រដ្ឋកាលីហ្វ័រញ៉ាដែលបានចុះឈ្មោះណាក៏ដោយក៏អាចដាក់ពាក្យបាន។ អ្នកពិនិត្យរបស់រដ្ឋនឹងដកអ្នកដាក់ពាក្យសុំពីក្រុមប្រសិនបើពួកគេមានជម្លោះអត្ថប្រយោជន៍ បានប្តូរការ ទាក់ទងជាមួយគណបក្សនយោបាយរបស់ពួកគេនៅអំឡុង ពេលប្រាំឆ្នាំកន្លងទៅ ឬប្រសិនបើពួកគេមិនបានចូលរួមបោះឆ្នោតពីរដងយ៉ាងតិចក្នុងការបោះឆ្នោតសកលបីចុង ក្រោយនេះ។
- ***ការបង្រួញក្រុមអ្នកដាក់ពាក្យសុំ។*** បន្ទាប់ពីបានពិនិត្យជំនាញវិភាគ ភាពមិនលម្អៀតរបស់អ្នកដាក់ពាក្យសុំ និងការវិនិច្ឆ័យនៃភាពចំរុះគ្នារបស់រដ្ឋកាលីហ្វ័រញ៉ា អ្នកពិនិត្យរបស់រដ្ឋបីនាក់នឹងជ្រើសរើសអ្នកដាក់ពាក្យសុំដែលមានគុណសម្បត្តិច្រើនជាងគេចំនួន 60 នាក់។ បន្ទាប់មក មេដឹកនាំខាងអង្គនីតិ បញ្ញាត្តិអាចចំរាញ់យកតែឈ្មោះចំនួន 24 ចេញពីក្រុមអ្នកដាក់ពាក្យសុំ។
- ***ការជ្រើសរើសអ្នកស្នងការ។*** ពីបញ្ជីអ្នកដាក់ពាក្យសុំដែល នៅសល់ អ្នកពិនិត្យរបស់រដ្ឋនឹងចាប់ឈ្មោះរបស់អ្នកតំណាងប្រាំបីអ្នកដំបូងដោយចៃដន្យ។ បន្ទាប់មកអ្នកតំណាងទាំងនេះ នឹងជ្រើសរើសអ្នកតំណាងប្រាំមួយនាក់ចុងក្រោយពីក្រុមអ្នកដាក់ពាក្យសុំដែលបានបង្រួញតូចរួច។

# សំណើប្រជាមតិ 40 ការដាក់កំរិត។ មណ្ឌលរដ្ឋព្រឹទ្ធសភា។ ប្រជាមតិ។

**ការធ្វើវិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ** (ត)

**គន្លឹះនៃលក្ខណៈធម្មនុញ្ញសំរាប់គូសផែនទីមណ្ឌលថ្មី**

នៅពេលគូរផែនទីមណ្ឌលថ្មី ធម្មនុញ្ញរដ្ឋបញ្ជាក់ថាគណៈកម្មការអាចនឹងមិនពិចារណាលើគណបក្សនយោបាយ អ្នកកាន់តំណែង ឬបេក្ខជននយោបាយទេ។ តាមលទ្ធភាពដែលអាចធ្វើបាន ធម្មនុញ្ញត្រូវឲ្យគណៈកម្មការបង្កើតស្រុកដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម (បានរៀបរាប់តាមលំដាប់លំដោយ) ៖

1. មានចំនួនសមមាត្រតាមចំនួនប្រជាជនដោយសមស្រប។
2. គោរពតាមច្បាប់ស្តីពីសិទ្ធិបោះឆ្នោតសហព័ន្ធ។
3. នៅជិតភូមិសាស្ត្រ។
4. កាត់បន្ថយការបែងចែកអត្ថប្រយោជន៍របស់ក្រុងទី ខោនធី ទីក្រុង និងខោនធីណាមួយ សង្កាត់ក្នុងមូលដ្ឋាន ឬសហគមន៍មូលដ្ឋាន។
5. សមស្របនឹងភូមិសាស្ត្រដ៏តូច។
6. រួមមានមណ្ឌលព្រឹទ្ធសភាទាំងពីរ ទាំងស្រុងនិងមណ្ឌលសភាទាំងឡាយដែលនៅជិតគ្នា។

***ប្រជាមតិ។*** រដ្ឋធម្មនុញ្ញអនុញ្ញាតឲ្យអ្នកបោះឆ្នោតសាកសួរពីផែនទីមណ្ឌលដែលបានបញ្ជាក់ដោយគណៈកម្មការតាមរយៈដំណើរការប្រជាមតិ។ ដើម្បីធ្វើឲ្យប្រជាមតិសំរាប់សន្លឹកឆ្នោតមានលក្ខណៈត្រឹមត្រូវ អ្នកគាំទ្រត្រូវដាក់បណ្តឹង ដែលបានចុះហត្ថលេខាដោយអ្នកបោះឆ្នោតបានចុះឈ្មោះមួយចំនួនដែលបានបញ្ជាក់ជាក់លាក់។ ផែនទីដែលមាន លក្ខណៈ ប្រកួតប្រជែង នឹងចូលជាធរមានប្រសិនបើផែនទីនោះត្រូវបានអនុម័តដោយមតិភាគច្រើននៃអ្នកបោះឆ្នោតរបស់រដ្ឋ។ ប្រសិនបើប្រជាមតិមួយត្រូវបដិសេធចោលដោយអ្នកបោះឆ្នោតរបស់រដ្ឋ ផែនទីស្រុកនឹងមិនចូលជាធរមានទេ ហើយតុលាការកំពូលរបស់រដ្ឋកាលីហ្វ័រញ៉ានឹងពិនិត្យមើលលើ ការបង្កើតផែនទីថ្មី។

***ផែនទីស្រុកដែលបានបញ្ជាក់។*** ក្នុងខែ សីហា ឆ្នាំ 2011 គណៈកម្មការបានបញ្ជាក់អំពី កញ្ចប់ផែនទីដែលបានបង្កើតព្រំដែនសំរាប់ព្រឹទ្ធសភា សភាគណៈកម្មការសមធម៌ និងមណ្ឌលសភាតំណាងរាស្ត្រ។ ក្នុងខែ វិច្ឆិកា ឆ្នាំ 2011 អ្នកគាំទ្រទាំងឡាយបានដាក់បញ្ជូនហត្ថលេខាក្នុងការគាំទ្រប្រជាមតិនៃផែនទីមណ្ឌលព្រឹទ្ធសភា ដែលបញ្ជាក់។ អ្នកគាំទ្របានប្តឹងទៅតុលាការកំពូលរដ្ឋកាលីហ្វ័រញ៉ាដើម្បីកំណត់ថា ផែនទីមួយណាដែលនឹងប្រើក្នុងការបោះឆ្នោតសាកល្បង ក្នុងខែមិថុនា និងការបោះឆ្នោតជាសកលក្នុងខែ វិច្ឆិកា ប្រសិនបើប្រជាមតិមានលក្ខណៈគ្រប់គ្រាន់សំរាប់សន្លឹកឆ្នោត។ តុលាការបានរកឃើញថាផែនទីមណ្ឌលព្រឹទ្ធសភា "ហាក់ធ្វើស្របតាមលក្ខណៈវិនិច្ឆ័យដែលតំរូវតាមអាណត្តិ ត្រឹមត្រូវស្របតាមរដ្ឋធម្មនុញ្ញដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋកាលីហ្វ័រញ៉ា" និងបានចេញជាច្បាប់ថាផែនទីទាំងនោះអាចនឹងត្រូវប្រើប្រាស់ក្នុងការបោះឆ្នោតសាកល្បងក្នុងខែ មិថុនា 2012 និង ការបោះឆ្នោតជាសកលក្នុងខែវិច្ឆិកា 2012។

## សេចក្តីស្នើច្បាប់

ការធ្វើប្រជាមតិនេះ អនុញ្ញាតឲ្យអ្នកបោះឆ្នោតទាំងអស់យល់ព្រម ឬបដិសេធព្រំដែនស្រុករបស់ព្រឹទ្ធសភាដែលត្រូវបានបញ្ជាក់ត្រឹមត្រូវ ដោយគណៈកម្មការបែងចែកមណ្ឌលប្រជាពលរដ្ឋ។ (សភា គណៈកម្មការសមកម្ម និងព្រំដែនស្រុករបស់សភាតំណាងរាស្ត្រដែលត្រូវបានបញ្ជាក់ត្រឹមត្រូវ ដោយគណៈកម្មការនេះមិន អាស្រ័យលើប្រជាមតិទេ)។ ឯកសារថតចម្លងនៃផែនទីបែងចែកមណ្ឌលព្រឹទ្ធសភា ដែលបញ្ជាក់ត្រឹមត្រូវត្រូវបានគេបញ្ចូល ពីខាងក្រោយសៀវភៅ ណែនាំខាងព័ត៌មាន នៃអ្នកបោះឆ្នោតនេះ។ ការបោះឆ្នោត "បាទ/ចាស" នឹងយល់ព្រមទៅនឹងការបែងចែកមណ្ឌលទាំងនេះ ហើយការបោះឆ្នោត "ទេ" នឹងបដិសេធការបែងចែកមណ្ឌលទាំងនេះ។

***ប្រសិនបើ អ្នកបោះឆ្នោតបោះឆ្នោត "បាទ/ចាស។"*** ព្រំដែនមណ្ឌលព្រឹទ្ធសភាដែលត្រូវបានបញ្ជាក់ត្រឹមត្រូវ ដោយគណៈកម្មការនេះនឹងត្រូវបានគេប្រើប្រាស់ រហូតដល់គណៈកម្មការនេះបង្កើតព្រំដែនថ្មីផ្អែកទៅលើជំរឿនប្រជាពលរដ្ឋសហព័ន្ធ ឆ្នាំ 2020។

***ប្រសិនបើ អ្នកបោះឆ្នោតបោះឆ្នោត "ទេ។"*** តុលាការជាន់ខ្ពស់ រដ្ឋកាលីហ្វ័រញ៉ា នឹងតែងតាំង "អ្នកជំនាញពិសេស" ដើម្បីបង្កើតព្រំដែនមណ្ឌលព្រឹទ្ធសភាថ្មីស្របទៅតាមលក្ខណៈបែងចែកមណ្ឌលដែលបានកំណត់ជាក់លាក់ក្នុងរដ្ឋធម្មនុញ្ញ។ (កាលពីមុន តុលាការបានតែងតាំងចៅក្រមចូលនិវត្តន៍ឱ្យធ្វើជាអ្នកជំនាញពិសេស)។ តុលាការនេះនឹងបញ្ជាក់ព្រំប្រទល់មណ្ឌលព្រឹទ្ធសភាថ្មី។ ព្រំប្រទល់ថ្មីនឹងត្រូវបានប្រើប្រាស់ក្នុងការបោះឆ្នោតនាពេលអនាគតរហូតដល់គណៈកម្មការនេះ បង្កើតព្រំប្រទល់ថ្មីផ្អែកលើជំរឿនប្រជាពលរដ្ឋសហព័ន្ធ ឆ្នាំ 2020។

## ឥទ្ធិពលសារពើពន្ធ

បើអ្នកបោះឆ្នោតទាំងឡាយបោះឆ្នោត "យល់ព្រម" និងអនុម័តលើផែនទីព្រឹទ្ធសភាប្រចាំមណ្ឌលដែលបញ្ជាក់ដោយ គណៈកម្មាការ នោះ នឹងមិនមានផលប៉ះពាល់ដល់ រដ្ឋាភិ បាលរបស់រដ្ឋ ឬរដ្ឋាភិបាលមូលដ្ឋានទេ។

បើអ្នកបោះឆ្នោត ទាំងឡាយនោះបោះឆ្នោត " មិនយល់ព្រម " និងច្រានចោលផែនទីព្រឹទ្ធសភាប្រចាំមណ្ឌលដែលបញ្ជាក់ដោយគណៈ កម្មាការ តុលាការកំពូលរដ្ឋកាលីហ្វ័រញ៉ានឹងតែងតាំងអ្នក ជំនាញពិសេសដើម្បីបង្កើតព្រំដែនមណ្ឌលព្រឹទ្ធសភាថ្មីៗ។ ការធ្វើបែបនេះនឹងធ្វើឲ្យមានការចំណាយតែម្តងដល់រដ្ឋដែល មានទឹកប្រាក់ប្រហែល **$500,000** ដុល្លារ។ លើសពីនេះទៅទៀត ខោនធី នឹងមានការចំណាយតែម្តង ដែលមានទឹក ប្រាក់ប្រហែល **$500,000** ដុល្លារទូទាំងរដ្ឋដើម្បីបង្កើតផែនទីមណ្ឌលថ្មីៗ និង សម្ភារៈបោះឆ្នោតដែលពាក់ព័ន្ធសំរាប់មណ្ឌលទាំងនេះ។

40

# សំណើប្រជាមតិ 40 ការដាក់កំរិត។ មណ្ឌលរដ្ឋព្រឹទ្ធសភា។ ប្រជាមតិ។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 40 ★

បោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិលេខ 40 ការពារ គណៈកម្មការពលរដ្ឋបែងចែកមណ្ឌលឯករាជ្យ ដែលអ្នកបោះឆ្នោតបានយល់ព្រម។

បោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិលេខ 40 មានន័យថា ការគូសផែនទីព្រឹទ្ធសភារបស់រដ្ឋដោយគណៈកម្មការ បែងចែកឡើងវិញនូវមណ្ឌលពលរដ្ឋដោយឯករាជ្យ ដែលយល់ព្រមដោយអ្នកបោះឆ្នោតនឹងរក្សានៅដដែល។

បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 40 ផ្តល់ឲ្យអ្នកនយោបាយនូវឱកាសដើម្បីបដិសេធមណ្ឌលស្មើភាពគ្នាដែលបានគូសដោយគណៈកម្មការឯករាជ្យ—អ្នកជាប់ពន្ធត្រូវចំណាយរាប់រយពាន់ដុល្លារក្នុងដំណើរការនេះ។

សំណើប្រជាមតិលេខ 40 គឺជាជំរើសដ៏ងាយរវាង គណៈកម្មការពលរដ្ឋបែងចែកមណ្ឌលឯករាជ្យ និងអ្នកនយោបាយមានផលប្រយោជន៍ផ្ទាល់ខ្លួន។

នៅក្នុងឆ្នាំ 2008 អ្នកបោះឆ្នោតនៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា យល់ព្រមលើសំណើប្រជាមតិលេខ 11 ដែលបង្កើតគណៈកម្មការបែងចែកស្រុកឡើងវិញសំរាប់ពលរដ្ឋដើម្បីគូសផែនទីមណ្ឌលសម្រាប់ព្រឹទ្ធសភារដ្ឋ និងសភារដ្ឋ។ មុនសំណើប្រជាមតិលេខ 11 អ្នកនយោបាយនៅក្នុងអង្គនីតិបញ្ញត្តិរដ្ឋបានគូសមណ្ឌលរបស់ពួកគេផ្ទាល់ដែលមិនប្រជែងគ្នា ស្ទើរតែធានាឲ្យមានការបោះឆ្នោតឲ្យពួកគេឡើងវិញ។

សព្វថ្ងៃនេះ ក្រុមតូចមួយនៃអ្នកនយោបាយនៅទីក្រុង Sacramento មិនពេញចិត្តនឹងលទ្ធផលនៃការ ផែនទីព្រឹទ្ធសភារដ្ឋដែលគូសដោយគណៈកម្មការឯករាជ្យទេ។ អ្នកនយោបាយទាំងនេះ កំពុងប្រើប្រាស់ប្រជាមតិនេះដើម្បីសាកល្បងដណ្តើមយកមណ្ឌលដែលមិនមានការប្រកួតប្រជែងរបស់ពួកគេត្រលប់មកវិញ។

អ្នកនយោបាយបានបរាជ័យនៅក្នុងតុលាការរួចទៅហើយ

នៅពេលអ្នកនយោបាយដូចគ្នាបានសាកល្បងបណ្តឹងមួយប្រឆាំងនឹងផែនទីព្រឹទ្ធសភាប្រចាំរដ្ឋ តុលាការជាន់ខ្ពស់ កាលីហ្វ័រញ៉ាបានធ្វើសេចក្តីសម្រេចជាឯកច្ឆន្ទប្រឆាំងនឹងពួកគេ៖

"...មណ្ឌលព្រឹទ្ធសភាដែលបានបញ្ជាក់ដោយគណៈ កម្មការ មិនត្រឹមតែត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យដែលតំរូវ តាមរដ្ឋធម្មនុញ្ញ ដែលមានចែងលម្អិតនៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋកាលីហ្វ័រញ៉ា មាត្រា XXI ប៉ុណ្ណោះទេ មណ្ឌលព្រឹទ្ធសភាដែលបញ្ជាក់ត្រឹមត្រូវដោយគណៈកម្មការក៏ជាផលិតផលមួយនៃអ្វីដែលជាទូទៅជាដំណើរការមានលក្ខណៈបើកចំហ មានតម្លាភាព និងការបែងចែកមណ្ឌលឡើងវិញដោយមិនប្រកាន់បក្សពួកដូចដែលត្រូវបានតម្រូវដោយខចែងបច្ចុប្បន្ននៃមាត្រា XXI ។" *Vandermost v. Bowen* (2012)

យើងស្វាគមន៍អ្នកឱ្យចូលអានសេចក្តីសំរេចទាំងស្រុងនៅ ៖

*www.courts.ca.gov/opinions/archive/S198387.PDF*

បោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិលេខ 40 សំរេចតាមឆន្ទៈអ្នកបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ា។

អ្នកបោះឆ្នោតនៅកាលីហ្វ័រញ៉ាបានបោះឆ្នោតបីដងក្នុងរវាងបួនឆ្នាំចុងក្រោយដើម្បីឱ្យមានការគូសផែនទីមណ្ឌលដោយគណៈកម្មការឯករាជ្យមួយ មិនមែនអ្នកនយោបាយ។

- បោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិលេខ 11 (2008) ៖ បានបង្កើតគណៈកម្មការឯករាជ្យបែងចែកមណ្ឌលពលរដ្ឋឡើងវិញដើម្បីគូសផែនទីឲ្យសភារដ្ឋ និងព្រឹទ្ធសភារដ្ឋ
- បោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិលេខ 20 (2010)៖ ពន្យាកំណែទម្រង់របស់សំណើប្រជាមតិលេខ 11 ដល់មណ្ឌលសភាតំណាងរាស្ត្ររដ្ឋកាលីហ្វ័រញ៉ា
- បោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 27 (2010)៖ បានច្រានចោលបំណងរបស់អ្នកនយោបាយក្នុងការលុបបំបាត់គណៈកម្មការឯករាជ្យ និងផ្តល់អំណាចក្នុងការដកមណ្ឌលអង្គនីតិបញ្ញត្តិរបស់ខ្លួនផ្ទាល់ទៅឲ្យអ្នកនយោបាយវិញ។

បោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិលេខ 40—ធ្វើឱ្យអ្នកនយោបាយប្រកាន់ជំហ៊ រទទួលខុសត្រូវ

ការអនុម័តសំណើប្រជាមតិលេខ 11 និងលេខ 20 និងបរាជ័យនៃសំណើប្រជាមតិលេខ 27 បានបង្កើតឲ្យមានដំណើរការនៃការបែងចែកតំបន់ឡើងវិញប្រកបដោយយុត្តិធម៌ដែលមិនពាក់ព័ន្ធនឹងអ្នកនយោបាយនៅក្រុង Sacramento ឡើយ!

ពីព្រោះតែកំណែទម្រង់ដែលបានអនុម័តដោយអ្នកបោះឆ្នោតទាំងនេះ សម្រាប់លើកដំបូងក្នុងទសវត្សរ៍ គណៈកម្មការឯករាជ្យបានគូសមណ្ឌលសម្រាប់អង្គនីតិបញ្ញត្តិ និងសភា ដែលនឹងចាប់ផ្តើមក្នុងពេលបោះឆ្នោតឆ្នាំ 2012 ។

ការធ្វើកំណែទម្រង់បែងចែកទាំងនេះបានបញ្ចប់ដោយកិច្ចពិភាក្សានយោបាយមួយដែលបានព្រមព្រៀងធានា ឲ្យមានដំណើរការមួយដែលប្រកបដោយតម្លាភាព និងបើកចំហចំពោះសាធារណជន។ លើសពីនេះ អ្នកនយោបាយគឺគ្មាន ការធានាឲ្យមានការជាប់ឆ្នោត ឡើងវិញទៀតទេ តែមន្ត្រីទាំងនេះឲ្យត្រូវទទួលខុសត្រូវចំពោះអ្នកបោះឆ្នោត និងត្រូវឆ្លើយតបនឹងតំរូវការរបស់អ្នកតំណាងរាស្ត្រ។

លោក John Kabateck ដែលជានាយប្រតិបត្តិ នៃសហព័ន្ធជាតិនៃពាណិជ្ជកម្ម/រដ្ឋកាលីហ្វ័រញ៉ាឯករាជ្យបានមានប្រសាសន៍ថា "គណៈកម្មការបានដកអ្នកនយោបាយចេញពីដំណើរការបោះឆ្នោតហើយបានប្រគល់អំណាចជូនអ្នកបោះឆ្នោតទៅវិញ។"

បោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិលេខ 40—បញ្ឈប់អ្នកនយោបាយពីការច្រានចោលកំណែទម្រង់ការបោះឆ្នោតដែលបានយល់ព្រមដោយអ្នកបោះឆ្នោតរួចទៅហើយ។

*www.HoldPoliticiansAccountable.org*

**JENNIFER A. WAGGONER**, ប្រធាន
សម្ព័ន្ធស្ត្រីអ្នកបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា

**DAVID PACHECO**, ប្រធាន
AARP កាលីហ្វ័រញ៉ា

**ALLAN ZAREMBERG**, ប្រធាន
សភាពាណិជ្ជកម្មកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 40 ★

ក្នុងនាមជាអ្នកគាំនៃសំណើប្រជាមតិលេខ 40 គោលបំណងរបស់យើងគឺធ្វើឲ្យប្រាកដថាគុណសម្បត្តិរបស់សំណើប្រជាមតិសម្រាប់សន្លឹកឆ្នោតនឹងបញ្ឈប់ខ្សែបន្ទាត់មណ្ឌលព្រឹទ្ធសភាបច្ចុប្បន្នពីការអនុវត្តក្នុងឆ្នាំ 2012។ តុលាការកំពូលបានពិនិត្យឡើងវិញនូវដំណើរការ ហើយបានធ្វើអន្តរាគមន៍ដើម្បីរក្សាខ្សែបន្ទាត់មណ្ឌលឲ្យនៅដដែល។ ដោយមានចំណាត់ការពីតុលាការ វិធានការនេះមិនត្រូវការទៀត ទេ ហើយយើងនឹងមិនស្វែងរកការបោះឆ្នោត ទេ ទៀតឡើយ។

**JULIE VANDERMOST**, អ្នកឧបត្ថម្ភ
សំណើប្រជាមតិលេខ 40

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 40 ★

ក្នុងនាមជាអ្នកគាំទ្រផ្លូវការនៃសំណើប្រជាមតិលេខ 40 គោលបំណងរបស់យើងគឺធ្វើឲ្យប្រាកដថាគុណសម្បត្តិរបស់សំណើប្រជាមតិសម្រាប់សន្លឹកឆ្នោតនឹងបញ្ឈប់ខ្សែបន្ទាត់មណ្ឌលព្រឹទ្ធសភាបច្ចុប្បន្នពីការអនុវត្តក្នុងឆ្នាំ 2012។ តុលាការកំពូលបានពិនិត្យឡើងវិញនូវដំណើរការ ហើយបានធ្វើអន្តរាគមន៍ដើម្បីរក្សាខ្សែបន្ទាត់មណ្ឌលឲ្យនៅដដែល។ ដោយមានចំណាត់ការពីតុលាការ វិធានការនេះមិនត្រូវការទៀត ទេ ហើយយើងនឹងមិនស្វែងរកការបោះឆ្នោត ទេ ទៀតឡើយ។

**JULIE VANDERMOST,** អ្នកឧបត្ថម្ភ
សំណើប្រជាមតិលេខ 40

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 40 ★

ការបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 40 គឺនៅតែត្រូវការជាចាំបាច់ដើម្បីការពារ គណៈកម្មការពលរដ្ឋបែងចែកមណ្ឌលឯករាជ្យ ដែលអ្នកបោះឆ្នោតបានយល់ព្រម។

អ្នកបោះឆ្នោតនៅតែត្រូវបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 40 ដើម្បីធានាថា ផែនទីព្រឹទ្ធសភាប្រចាំរដ្ឋដែលគូរ ដោយគណៈកម្មការឯករាជ្យបែងចែកមណ្ឌលពលរដ្ឋឡើងវិញដែលអនុម័តដោយអ្នកបោះឆ្នោត នឹងនៅតែមានជាបន្ត—ទោះបីជាអ្នកគាំទ្រប្រជាមតិនេះបានបញ្ជាក់ខាងលើថា ពួកគេឈប់សួររកការបោះឆ្នោត "ប្រឆាំង" ទៀតក៏ដោយ។

នៅពេលប្រជាមតិមួយមានគុណសម្បត្តិសម្រាប់សន្លឹកឆ្នោត វាមិនអាចដកចេញបានទេ - ទោះបីជាអ្នកគាំទ្របោះចោលវិធានការនេះ ដូចដែលពួកគេបានធ្វើខាងលើក៏ដោយ។

សំណើប្រជាមតិលេខ40គឺជាជំរើសដ៏ងាយរវាងជំរើសដំណើរការដ៏មានតំលៃថ្លៃនិងការពារគណៈកម្មការពលរដ្ឋបែងចែកមណ្ឌលឯករាជ្យ

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 40 ៖

- ការពារផែនទីព្រឹទ្ធសភាប្រចាំរដ្ឋដែលគូរដោយគណៈកម្មការឯករាជ្យបែងចែកមណ្ឌលពលរដ្ឋឡើងវិញដែលអនុម័តដោយអ្នកបោះឆ្នោត។
- ជួយសន្សំសំចៃដល់អ្នកបង់ពន្ធរាប់រយពាន់ដុល្លារ។
- ធ្វើឲ្យអ្នកនយោបាយទទួលខុសត្រូវ៖ ជាមួយខ្សែបន្ទាត់មណ្ឌលដែលបានគូសដោយគណៈកម្មាការពលរដ្ឋឯករាជ្យ អ្នកនយោបាយមិនបានធានាឲ្យមានកាជាប់ឆ្នោតសារជាថ្មីទៀតទេ ប៉ុន្តែត្រូវទទួលខុសត្រូវចំពោះអ្នកបោះឆ្នោត និងត្រូវឆ្លើយតបនឹងតំរូវការរបស់អ្នកតំណាងរាស្ត្រ។
- ប្រកាន់ខ្ជាប់ឆន្ទៈរបស់អ្នកបោះឆ្នោត៖ ប្រជាពលរដ្ឋ កាលីហ្វ័រញ៉ាបាន បោះឆ្នោតបីដងក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ ដើម្បីឲ្យមានគណៈកម្មការឯករាជ្យមួយគូសផែនទីមណ្ឌល—មិនមែនអ្នកនយោបាយទេ។

ការបោះឆ្នោត " ទេ" លើសំណើប្រជាមតិលេខ 40 នឹងបដិសេធមណ្ឌលដែលស្មើភាពដែលត្រូវបានគូសដោយគណៈកម្មការឯករាជ្យ—និងផ្តល់ឱកាសឲ្យអ្នកនយោបាយដើម្បីមានឥទ្ធិពលម្តងទៀតលើដំណើរការបែងចែកមណ្ឌល ម្តងទៀតសំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 40

សូមចូលរួមជាមួយពួកយើង និងសម្ព័ន្ធដ៏ទូលំទូលាយនៃរដ្ឋាភិបាលដ៏ល្អ អាជីវកម្មនានា ក្រុមគាំទ្រមនុស្សចាស់ និងសិទ្ធិពលរដ្ឋក្នុងបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 40 ។

*www.HoldPoliticiansAccountable.org*

**KATHAY FENG,** នាយកប្រតិបត្តិ
មូលហេតុសាមញ្ញកាលីហ្វ័រញ៉ា

**JOHN KABATECK,** នាយកប្រតិបត្តិ
សហព័ន្ធជាតិនៃពាណិជ្ជកម្មឯករាជ្យ-កាលីហ្វ័រញ៉ា

**GARY TOEBBEN,** ប្រធាន
សភាពាណិជ្ជកម្ម តំបន់ Los Angeles



*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

# បេក្ខជនប្រធានាធិបតីសហរដ្ឋអាមេរិក

ច្បាប់ការបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ាជំពូក 9084 តំរូវថា ព័ត៌មានពីបេក្ខភាពប្រធានាធិបតីអាចត្រូវឱ្យមាននៅក្នុងគេហទំព័ររបស់រដ្ឋលេខាធិការនៃរដ្ឋកាលីហ្វ័រញ៉ា។ ចូរទៅមើល *www.voterguide.sos.ca.gov* សំរាប់ព័ត៌មានពិស្តារថែមទៀត។

---

# បេក្ខជនអង្គនិតិបញ្ញាត្តិ និងសហសភា

សៀវភៅមគ្គុទ្ទេសក៍ណែនាំអ្នកបោះឆ្នោតនេះមានរួមទាំងព័ត៌មានអំពីវិធានការបោះឆ្នោតទូទាំងរដ្ឋ និងបេក្ខជន ព្រឹទ្ធសភាសហរដ្ឋអាមេរិក។ ការិយាល័យព្រឹទ្ធសភារដ្ឋ, សភា, និងសភាតំណាងរាស្ត្រសហរដ្ឋអាមេរិកនិមួយៗដែលទាក់ទងនឹង អ្នកបោះឆ្នោត នៅក្នុងខោនធីតែមួយឬ ពីរ-បី, ដូច្នេះ សេចក្ដីថ្លែងរបស់បេក្ខជនខ្លះសំរាប់ការិយាល័យទាំងនោះប្រហែលអាចមាននៅក្នុងកូនសៀវភៅគំរូបោះឆ្នោតក្នុងខោនធីរបស់អ្នក។

ច្បាប់រដ្ឋកាលីហ្វ័រញ៉ាដោយមានរួមទាំងការកំរិតចំណាយដោយស្ម័គ្រសំរាប់បេក្ខជនដែលឈរឈ្មោះសំរាប់ការិយាល័យនិតិបញ្ញត្តិ (មិនមែនជាការិយាល័យសហព័ន្ធ ដូចជា សភាតំណាងរាស្ត្រសហរដ្ឋអាមេរិកនិងព្រឹទ្ធសភាសហរដ្ឋអាមេរិក)។ បេក្ខជននិតិបញ្ញត្តិដែលជ្រើសរើសរក្សាការចំណាយក្នុងការឃោសនារបស់ពួកគេឱ្យនៅក្រោមចំនួនប្រាក់ដុល្លាពិតប្រាកដមួយ ប្រហែលអាចទិញកន្លែងផ្សាយពាណិជ្ជកម្មក្នុងកូនសៀវភៅគំរូការបោះឆ្នោតនៃខោនធីសំរាប់សេចក្ដីថ្លែងរបស់បេក្ខជនម្នាក់រហូតទៅដល់ 250 ពាក្យ។

បេក្ខជនព្រឹទ្ធសភារដ្ឋដែលបានស្ម័គ្រចិត្តកំរិតការចំណាយនៃការឃោសនារបស់ពួកគេប្រហែលចំណាយមិនឱ្យលើសពី $1,169,000 នៅក្នុងការបោះឆ្នោតសកល។ បេក្ខជនសភាដែលបានស្ម័គ្រចិត្តកំរិតការចំណាយនៃការឃោសនារបស់ពួកគេប្រហែលចំណាយមិនឱ្យលើសពី $909,000 នៅក្នុងការបោះឆ្នោតសកល។

ដើម្បីមើលបញ្ជីរាយឈ្មោះនៃបេក្ខជនអង្គនិតិបញ្ញត្តិដែលបានយល់ព្រមស្ម័គ្រចិត្តកំរិតការចំណាយការឃោសនាក្នុងរដ្ឋកាលីហ្វ័រញ៉ា សូមទៅមើលគេហទំព័រ *www.sos.ca.gov/elections/elections_cand_stat.htm*។

គ្រប់បេក្ខជននៃសភាតំណាងរាស្ត្រសហរដ្ឋអាមេរិកមានជំរើសដើម្បីទិញកន្លែងផ្សាយពាណិជ្ជកម្មក្នុងកូនសៀវភៅគំរូការបោះឆ្នោតនៃខោនធីសំរាប់សំរាប់សេចក្ដីថ្លែងរបស់បេក្ខជនម្នាក់ៗ។ (សភាតំណាងរាស្ត្រសហរដ្ឋអាមេរិកខ្លះជ្រើសរើសមិនទិញកន្លែងផ្សាយពាណិជ្ជកម្មសំរាប់សេចក្ដីថ្លែងរបស់បេក្ខជនទេ)។

ច្បាប់រដ្ឋកាលីហ្វ័រញ៉ាដែលកំរិតចំណាយលើការឃោសនាដោយស្ម័គ្រមិនអនុវត្តលើបេក្ខជនឈរឈ្មោះសំរាប់ការិយាល័យសហព័ន្ធឡើយ ដោយរួមទាំង ព្រឹទ្ធសភាសហរដ្ឋអាមេរិក។ ដូច្នេះហើយ រាល់បេក្ខជនព្រឹទ្ធសភាសហរដ្ឋមានជំរើសក្នុងការទិញកន្លែងផ្សាយពាណិជ្ជកម្មសរសេរសំរាប់សេចក្ដីថ្លែងរបស់បេក្ខជនម្នាក់ៗនៅក្នុងកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំការបោះឆ្នោតនេះ។ (បេក្ខជនព្រឹទ្ធសភា សហរដ្ឋអាមេរិកខ្លះជ្រើសរើសមិនទិញកន្លែងផ្សាយពាណិជ្ជកម្មសំរាប់សេចក្ដីថ្លែងរបស់បេក្ខជនទេ)។

បេក្ខជនព្រឹទ្ធសភាសហរដ្ឋអាមេរិកមាន ៖

- Dianne Feinstein
- Elizabeth Emken

សំរាប់បញ្ជីរាយឈ្មោះបេក្ខជនដែលបានជ្រើសរើស សូមទៅមើលគេហទំព័រ *www.sos.ca.gov/elections/elections_cand.htm*។

# សេចក្តីថ្លែងនៃបេក្ខជនព្រឹទ្ធសភាសហរដ្ឋអាមេរិក

ព្រឹទ្ធសភាសហរដ្ឋអាមេរិក៖

- បំរើជាព្រឹទ្ធសភាមួយរូបក្នុងចំណោមព្រឹទ្ធសភាពីររូបដែលតំណាងឱ្យផលប្រយោជន៍រដ្ឋកាលីហ្វ័រញ៉ានៅក្នុងព្រឹទ្ធសភាសហរដ្ឋអាមេរិក។
- ធ្វើញត្តិ និងបោះឆ្នោតលើច្បាប់ជាតិថ្មី។
- បោះឆ្នោតលើការអនុម័តយកចៅក្រមសហព័ន្ធ, ក្រសួងយុទ្ធធម៌តុលាការកំពូលសហរដ្ឋអាមេរិក, និងមុខងារមន្ត្រីស៊ីវិលនិងយោធាថ្នាក់ខ្ពស់នានាដែលចាត់តាំងដោយប្រធានាធិបតី។

---

DIANNE FEINSTEIN
គណៈបក្សអាទិភាព៖
ប្រជាធិបតេយ្យ

1801 Avenue of the Stars, Suite 829
Los Angeles, CA 90067

(310) 203-1012
www.diannefeinstein2012.com

ពេលនេះគឺជាពេលវេលាដ៏លំបាកសំរាប់រដ្ឋនិងជាតិរបស់យើង។ សេដ្ឋកិច្ចរបស់យើង, ខណៈដែលធូរស្រាលឆាប់, គឺកំពុងងើបចេញពីសភាពធ្លាក់ដុនដាបនៃសេដ្ឋកិច្ចដ៏អាក្រក់មួយក្នុងប្រវត្តិសាស្ត្រអាមេរិកាំង។ ប្រទេសយើងប្រឈមមុខនឹងសេដ្ឋកិច្ចដ៏គ្រោះថ្នាក់ និងសន្តិសុខជាតិជួបប្រទះការប្រជែងទូទាំងពិភពលោក។ រដ្ឋកាលីហ្វ័រញ៉ាត្រូវការអ្នកដឹកនាំមានបទពិសោធន៍នៅក្នុងព្រឹទ្ធសភាសហរដ្ឋអាមេរិក ដែលត្រូវរៀបចំដើម្បីជួបនឹងការប្រកួតប្រជែងទាំងនោះ។ អាទិភាពទីមួយរបស់ខ្ញុំគឺនាំយកភាពលំនឹងដល់សេដ្ឋកិច្ចរដ្ឋកាលីហ្វ័រញ៉ានិងជាតិ។ ខ្ញុំគាំទ្រវិធានការដែលមានសុភវិនិច្ឆ័យ ដើម្បីធ្វើឱ្យសេដ្ឋកិច្ចលូតលាស់ ដូចជាការកាត់ពន្ធពីបញ្ជីប្រាក់ខែ, ផែនការឱ្យខ្ចីប្រាក់ជាថ្មីដើម្បីជួយដល់ម្ចាស់ផ្ទះដែលជំពាក់ប្រាក់និក្ខេបរបស់គេ និងបញ្ចប់ការរាលដាលនៃការរឹបអូសយកផ្ទះនៅក្នុងរដ្ឋរបស់យើង, ផែនការហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការយ៉ាងខ្លាំងដើម្បីបង្កើតការងារធ្វើ, ធ្វើការគាំទ្រគ្រូបង្រៀននិងប្រាក់ខែរបស់អ្នកឆ្លើយតបទីមួយ, និងផ្តល់ក្រេឌិតពន្ធដារសំរាប់និយោជក ឬហាងពាណិជ្ជកម្ម ដើម្បីជួលអតីតយុទ្ធជនដែលគ្មានការធ្វើ និងអ្នកដែលគ្មានការធ្វើរយៈពេលយូរ។ ខ្ញុំក៏បានប្តេជ្ញាយ៉ាងជ្រាលជ្រៅដើម្បី ការពារសន្តិសុខសង្គម និងកម្មវិធីមេឌីឃែរ ដែលគឺជាកត្តាសំខាន់សំរាប់មនុស្សចាស់ជរារបស់យើង។ គណៈកម្មការស៊ើបការសម្ងាត់ព្រឹទ្ធសភាដែលរូបខ្ញុំជាប្រធាន ឥឡូវនេះគឺប្រតិបត្តិការក្នុងរបៀបគ្មានបក្សព័ន្ធ ការនេះធ្វើឱ្យយើងមានប្រសិទ្ធិភាពខ្លាំងក្នុងការការពារសុវត្ថិភាពរបស់ជាតិ, បង្អាក់ដល់សកម្មភាពភេរវៈជន, និងផ្តល់ការមើលត្រួតត្រាហ្មត់ចត់ដល់ទីភ្នាក់ងារទាំង 16 នៃសហគមន៍ស៊ើបអង្កេត។ ក្នុងនាមជាសមាជិកនៃគណៈកម្មការតុលាការ ខ្ញុំស្ថិតនៅក្នុងភាពប្រុងប្រយ័ត្នជានិច្ចក្នុងការការពារសិទ្ធិពលរដ្ឋដល់ពលរដ្ឋយើងទាំងអស់ ហើយខ្ញុំមិនងាករេក្នុងការការពារសិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើសប្រឆាំងនឹងអំពើប្រើកំលាំងរំលោភបំពាន។ ខ្ញុំឈរឈ្មោះជាព្រឹទ្ធសភាសហរដ្ឋអាមេរិកពីព្រោះខ្ញុំជឿថាខ្ញុំមានជំនាញ មានបទពិសោធន៍, និងប្តេជ្ញាមុះមុតដើម្បីធ្វើរដ្ឋកាលីហ្វ័រនីញ៉ាឱ្យមានការកែប្រែ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់លោកអ្នក។

---

ELIZABETH EMKEN
គណៈបក្សអាទិភាព៖
សាធារណរដ្ឋ

P.O. Box 81
Danville, CA 94526

(925) 395-4475
info@emken2012.com
www.emken2012.com

យើងមិនអាចផ្លាស់ប្តូរវ៉ាស៊ីនតោនបានទេដោយគ្មានការផ្លាស់ប្តូរ មនុស្សខ្លះនៅក្នុងវ៉ាស៊ីនតោន។ នយោបាយគាំងស្ទះដែលយើងមើលឃើញរាល់ថ្ងៃគឺកំពុងធ្វើឲ្យមានការឈឺចាប់ដល់អ្នកកាលីហ្វ័រញ៉ា។ ភាពឥតការងរធ្វើនៅក្នុងរដ្ឋរបស់យើងមានកំរិតខ្ពស់ជាងកំរិតមធ្យមថ្នាក់ជាតិ, ការលូតលាស់ការងារមានកំណើនយឺតៗ នេះគឺមានន័យថាបុរស ស្ត្រីជាអ្នកធ្វើការងារខ្លាំងនៅរដ្ឋកាលីហ្វ័រញ៉ាមានឳកាសតិចតួចណាស់សំរាប់រកងារ។ ក្នុងចំណោមទីក្រុង10ក្នុងសហរដ្ឋអាមេរិកដែលមានេសដ្ឋកិច្ចអាក្រក់ខ្លាំងជាងគេ គឺ9 នៅក្នុងរដ្ឋរបស់យើង។ រដ្ឋកាលីហ្វ័រញ៉ាមានតំណាងដដែលៗនៅក្នុងព្រឹទ្ធសភាសហរដ្ឋអាមេរិកជិតម្ភៃឆ្នាំ, តែការប្រណាំងប្រជែងរបស់យើងកាន់តែអាក្រក់ទៅៗ។ ព្រឹទ្ធសភាបរាជ័យក្នុងការធ្វើសកម្មភាពលើសេចក្តីព្រាងច្បាប់សំខាន់ៗ មានន័យថាពាណិជ្ជកម្មខ្នាតតូចដែលយើងត្រូវការសំរាប់បង្កើតការងារត្រូវបានកំរាមកំហែងដោយការយកពន្ធដារខ្ពស់ នឹងបទបញ្ញត្តិមានភាពស្មុគ្រស្មាញច្រើន។ កសិកររបស់យើងនៅ Central Valleyត្រូវការទឹកធ្វើចំការ។ ក្រុមបច្ចេកទេសខ្ពស់របស់យើងត្រូវការកំណែទម្រង់ពន្ធដារដែលជួយរក្សាការងារទុកនៅទីនេះ។ សន្តិសុខជាតិរបស់យើង និងឧស្សាហកម្មការពារកំពុងតែមានការកំរាមគំហែងធ្ងន់ធ្ងរ។ ស្ថានភាពដដែលៗជាក់ស្តែងត្រូវបរាជ័យ។ យើងត្រូវការភាពដឹកនាំថ្មី, បំពេញថាមពលជាថ្មីឡើងវិញ, និងព្រឹទ្ធសភាមួយរូបដែលចាប់ផ្តើមពីថ្មីស្រឡាង។ ក្នុងនាមជាភរិយា និងជាម្តាយនៃកូនបីនាក់ ខ្ញុំមានការបារម្ភសំរាប់អនាគតរបស់កូនខ្ញុំ។ ខ្ញុំបានប្តេជ្ញាធ្វើឱ្យវ៉ាស៊ីនតោនធ្វើការឡើងវិញដោយធ្វើឱ្យងាយស្រួលក្នុងការបង្កើតការងារនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាជាជាងនៅប្រទេសក្រៅដោយធានាឱ្យរូបអ្នក និងគ្រួសារអ្នកអាចជ្រើសរើសការអប់រំ និងការថែទាំសុខភាពដែលត្រឹមត្រូវចំពោះអ្នក ហើយដែលធ្វើឱ្យយើងអាចជួយដល់អ្នកដែលត្រូវការពិតប្រាកដ។ ខ្ញុំមានកិត្តិយសនឹងទទួលបានការគាំទ្រពីលោកអ្នក។ ចង់ស្វែងយល់ច្រើនថែមទៀតចូរទៅគេហទំព័រ *www.Emken2012.com.*

---

លំដាប់លេខរៀងនៃសេចក្តីថ្លែងរបស់បេក្ខជនឈរឈ្មោះ គឺត្រូវបានកំណត់ដោយការចាប់ឈ្មោះផ្សងសំណាងយកចេញពីតួអក្សរ ។
សេចក្តីថ្លែង នៅក្នុងទំព័រនេះ គឺត្រូវបានឧបត្ថម្ភដោយបេក្ខជនរៀងខ្លួនៗ ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។
សេចក្តថ្លែងនីមួយៗត្រូវបានដាក់បញ្ជូនមកដោយស្ម័គ្រចិត្ត ពីបេក្ខជន ហើយត្រូវបានចំណាយថ្លៃបោះពុម្ពដោយខ្លួនគេ។

## សំណើប្រជាមតិ 30

វិធានការប្រជានុម័តនេះគឺត្រូវបានដាក់ឱ្យប្រជាពលរដ្ឋដោយអនុលោមទៅតាមខដែលមានចែងក្នុងវគ្គទី 8 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រ ញ៉ា។

វិធានការប្រជានុម័តនេះបន្ថែមផ្នែកមួយទៅលើរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា ដូចនេះ ខចែងថ្មី ដែលបានស្នើឡើងដើម្បីបន្ថែមត្រូវបោះពុម្ព ចេញជា *លក្ខណៈអក្សរទ្រេត* ដើម្បីបញ្ជាក់ថាវាថ្មី។

## ច្បាប់ដែលស្នើ

ច្បាប់ការពារសុវត្ថិភាពសាលារៀននិងទីសាធារណៈ
តាមមូលដ្ឋាន ឆ្នាំ2012

វគ្គទី 1. ចំណងជើង

វិធានការនេះគួរត្រូវបានស្គាល់ និងអាចត្រូវបានកំណត់យោងថាជា "ច្បាប់ការពារសុវត្ថិភាពសាលារៀននិងទីសាធារណៈតាមមូលដ្ឋាន ឆ្នាំ2012 ។"

វគ្គទី 2. ការរកឃើញ

(a) ក្នុងរយៈពេលតែបួនឆ្នាំកន្លងទៅប៉ុណ្ណោះ រដ្ឋកាលីហ្វ័រញ៉ាបានកាត់ថវិកាច្រើនជាង $56 ពាន់លានដុល្លារពីវិស័យអប់រំ ប៉ូលីស និងការការពារអគ្គិភ័យ សេវាថែទាំសុខភាព និងសេវាកម្មចាំបាច់ផ្សេងៗនិងសេវាកម្មតាមមូលដ្ឋាន។ ការកាត់បន្ថយថវិកាទាំងនេះបានបង្ខំឱ្យមានការបញ្ឈប់គ្រូបង្រៀនបណ្តោះអាសន្ន ពង្រីកទំហំថ្នាក់រៀន បង្កើនតំលៃមហាវិទ្យាល័យ កាត់បន្ថយការការពាររបស៉ីននូវរយៈ ពេលឆ្លើយតបពីក្រុម សង្គ្រោះអគ្គិភ័យ បង្កឱ្យមានការណែនណាន់តាន់ តាប់ដ៏គ្រោះថ្នាក់ធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ ហើយបានកាត់បន្ថយ យ៉ាងច្រើននូវការពិនិត្យលើអ្នកដែលត្រូវគេដោះលែង។

(b) ការកាត់ថវិកាទាំងឡាយលើសេវាកម្មសំខាន់ៗបានបង្កការលំបាកយ៉ាងខ្លាំងដល់មនុស្សចាស់ៗ គ្រួសារអ្នកធ្វើការវណ្ណៈកណ្តាលកូនក្មេង និស្សិតមហាវិទ្យាល័យនិងពាណិជ្ជកម្មខ្នាតតូចនៃរដ្ឋកាលីហ្វ័រញ៉ា យ៉ាងខ្លាំងបំផុត។ យើងមិនអាចទ្រាំទ្រនូវការកាត់ ថវិកាពីការ អប់រំ និង សេវាផ្សេងៗទៀតដែលយើងត្រូវការបានទៀតឡើយ។

(c) បន្ទាប់ពីការកាត់ថវិកានិងជំរើសដ៏លំបាកជាច្រើនឆ្នាំមក វាជា ការចាំបាច់ដែលត្រូវបង្វែទិសរបស់រដ្ឋ។ ការតំលើងពន្ធបាក្រចំណូល ថ្មីគឺជាការវិនិយោគមួយនៅក្នុងអនាគតរបស់យើងដែលនឹងដាក់រដ្ឋកា លីហ្វ័រញ៉ានៅលើផ្លូវរីកចំរើននិងជោគជ័យឡើងវិញ។

(d) ច្បាប់ការពារសុវត្ថិភាពសាលារៀននិងទីសាធារណៈតាមមូលដ្ឋាន ឆ្នាំ2012នឹងធ្វើឱ្យប្រព័ន្ធពន្ធដារនៃរដ្ឋកាលីហ្វ័រញ៉ាកាន់តែមានយុត្តិធម៌។ជាមួយនឹងគ្រួសារអ្នកធ្វើការកំពុងពុះពារតស៊ូខណៈពេលដែលអ្នកមានបំផុតក្នុងចំណោមពួកយើងរីករាយជាមួយនឹងការកើនឡើងបាក្រចំណូលដែលពុំដែលមានពីមុនមកវាជាការត្រឹមត្រូវដែលត្រូវស្នើអ្នកមានឱ្យបង់នូវចំណែកដ៏យុត្តិធម៌ពួកគេ។

(e) ច្បាប់ការពារសុវត្ថិភាពសាលារៀននិងទីសាធារណៈតាមមូលដ្ឋាន ឆ្នាំ2012 បង្កើនពន្ធបាក្រចំណូលទៅលើពួកអ្នកដែលស្ថិតនៅខាងកំពូលប្រាក់ចំណូលខ្ពស់បំផុត— ពួកអ្នកដែលអាចមាន លទ្ធភាព ខ្ពស់បំផុត។ វាក៏រក្សាជាបណ្តោះអាសន្ននូវពន្ធលក់ដូរខ្លះៗ ដែលមាន សុពលភាពកាលឆ្នាំទៅ ខណៈពេលដែលរក្សាទុកនូវ អត្រាពន្ធលក់ ដូរទាំងមូលឱ្យនៅទាបជាងកាលពីដើមឆ្នាំ2011។

(f) ពន្ធថ្មីនៅក្នុងវិធានការនេះគឺស្ថិតនៅជាបណ្តោះអាសន្ន។ នៅក្រោមរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា ការបង្កើនពន្ធលក់ដូរ 1/4 សេន ផុត កំណត់ក្នុងរយៈពេលបួនឆ្នាំ ហើយការតម្លើងពន្ធបាក្រចំណូល សំរាប់ អ្នកបង់ពន្ធមានបំផុតនឹងបញ្ចប់ក្នុងរយៈពេលប្រាំពីរឆ្នាំ។

(g) បាក្រចំណូលពន្ធថ្មីត្រូវបានធានាតាមរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ាដើម្បីបញ្ចូលដោយផ្ទាល់ទៅមណ្ឌលសាលារៀនតាមមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍។ ទីក្រុងនិងខោនធីនានាត្រូវបាន ធានា ការផ្តត់ផ្គង់ថវិកាជាបន្តបន្ទាប់សំរាប់កម្មវិធីសុវត្ថិភាពសាធារណៈ ដូចជា សេវាកម្មប៉ូលីសតាមមូលដ្ឋាននិងការការពារកុមារ។ ថវិកា របស់រដ្ឋត្រូវ បានបំរុងទុកសំរាប់ជួយឱ្យមានតុល្យភាពថវិកា និងការ ពារការកាត់ដ៏អន្តរាយកាន់តែធ្ងន់ធ្ងរចំពោះសេវាកម្មសំរាប់មនុស្សចាស់ គ្រួសារអ្នកធ្វើការ និងពាណិជ្ជកម្មខ្នាតតូច។ គ្រប់គ្នាទទួលបាន នូវ ផលប្រយោជន៍។

(h) ដើម្បីធានាឱ្យថវិកាទាំងនេះចូលទៅកន្លែងដែលអ្នកបោះឆ្នោតចង់បាន ថវិកាទាំងនោះត្រូវបានទុកក្នុងគណនេយ្យពិសេសដែល អង្គ នីតិបញ្ញត្តិមិនអាចប៉ះពាល់បាន។ គ្មានប្រាក់ចំណូលថ្មីទាំងនេះត្រូវបានចំណាយចំពោះតំលៃការិយាធិបតេយ្យឬរដ្ឋបាលឡើយ។

(i) ថវិកាទាំងនេះនឹងប្រឈមនឹងការត្រួតពិនិត្យដោយឯករាជ្យរៀងរាល់ឆ្នាំដើម្បីធានាថាថវិកាទាំងនេះត្រូវបានចំណាយសំរាប់តែសាលា រៀននិងសុវត្ថិភាពសាធារណៈ។ មន្ត្រីដែលបានជ្រើសរើសនឹងប្រឈម មុខនឹងការកាត់ទោសនិងការដាក់ទោសឧក្រិដ្ឋប្រសិនបើពួកគេប្រើ ថវិកានេះខុស។

វគ្គទី 3. បំណងនិងចេតនា

(a) គោលបំណងចំបងនៃវិធានការនេះគឺដើម្បីការពារសុវត្ថិភាពសាលារៀននិងទីសាធារណៈតាមមូលដ្ឋានដោយស្នើអ្នកមានឱ្យចំណាយចំណែកពន្ធដារដ៏យុត្តិធម៌របស់ពួកគេ។ វិធានការនេះយកថវិកាចេញ ពីការគ្រប់គ្រងរបស់រដ្ឋហើយដាក់ថវិកានោះទៅក្នុងគណនី ពិសេស ដែលត្រូវបានដាក់តំកល់ទាំងស្រុងសំរាប់សាលារៀននឹង សុវត្ថិភាព សាធារណៈតាមមូលដ្ឋានៅក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋ។

(b) វិធានការនេះបង្កើនលើគំរោងថវិការដ្ឋដ៏ទូលាយដែលបានជួយកាត់បន្ថយជាអចិន្ត្រៃយ៍លើការចំណាយរបស់រដ្ឋរាប់ពាន់លានដុល្លារ។

(c) វិធានការនេះធានាការផ្តត់ផ្គង់ថវិកាដ៏រឹងមាំ គួរជាទីទុកចិត្ត សំរាប់សាលារៀន មហាវិទ្យាល័យសហគមន៍ និងសុវត្ថិភាព សាធារ ណៈខណៈពេលជួយឱ្យមានតុល្យភាពថវិកានិងការពារការ កាត់ បន្ថយដ៏ធ្ងន់ធ្ងរថែមទៀតទៅលើសេវាកសំរាប់មនុស្សចាស់ គ្រួសារ អ្នកធ្វើការ ក្មេងៗ និងពាណិជ្ជកម្មខ្នាតតូច។

(d) វិធានការនេះផ្តល់នូវការការពារធម្មនុញ្ញទៅនឹងការផ្លាស់នៃកម្មវិធី សុវត្ថិភាពសាធារណៈតាមមូលដ្ឋានពីរដ្ឋទៅការគ្រប់គ្រងតាម មូល ដ្ឋាន និងការផ្លាស់ប្តូរនៃបាក្រចំណូលរបស់រដ្ឋទៅរដ្ឋាភិបាលមូលដ្ឋាន ដើម្បីចំណាយសំរាប់កម្មវិធីទាំងនោះ។ វាធានាថាសាលា នឹងមិនប៉ះ ពាល់ដោយសារការផ្តល់ថវិកាកាន់តែច្រើនជាងសាលា ដែលបាន ទទួលថវិកាដោយមិនមានការផ្លាស់ប្តូរ។

(e) វិធានការនេះធានាថាបាក្រចំណូលថ្មីដែលប្រមូលបាននឹងត្រូវផ្ញើទៅដោយផ្ទាល់ទៅកាន់មណ្ឌលសាលារៀនសំរាប់ការចំណាយថ្នាក់រៀន មិនមែនការចំណាយរដ្ឋបាលទេ។ ការផ្តត់ផ្គង់ថវិកាសាលា រៀននេះមិនអាចត្រូវបានព្យួរឬដកយកទេ ទោះបីមានអ្វីកើតឡើងដល់ ថវិការដ្ឋក៏ដោយ។

(f) ថវិកាទាំងអស់បានពីវិធានការនេះនឹង ប្រឈមនឹងការត្រួត ពិនិត្យក្នុងតំបន់ជារៀងរាល់ឆ្នាំ និងការត្រួតពិនិត្យដោយអ្នកគ្រប់ គ្រង ឯករាជ្យដើម្បីធានាថាថវិកាទាំងនេះត្រូវបានចំណាយសំរាប់តែ សាលា រៀននិងសុវត្ថិភាពសាធារណៈតាមមូលដ្ឋានប៉ុណ្ណោះ។

វគ្គទី4. វគ្គទី36 ត្រូវបានបន្ថែមទៅកាន់មាត្រា XIII នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា ត្រូវបកស្រាយថា ៖

*វគ្គទី36. (a) គោលបំណងនៃផ្នែកនេះ ៖*

*(1) "សេវាកម្មសុវត្ថិភាពសាធារណៈ" រួមមានដូចខាងក្រោមៈ*

*(A) ការជួលនិងហ្វឹកហ្វឺនមន្ត្រីសុវត្ថិភាពសាធារណៈ ដែលរួមមានបុគ្គលិកពង្រឹងច្បាប់ មេធាវីដែលបានចាត់តាំងសំរាប់នីតិវិធី ព្រហ្មទណ្ឌ និងបុគ្គលិកសន្តិសុខតុលាការ។*

*(B) ការគ្រប់គ្រងពន្ធនាគារតាមមូលដ្ឋាននិងការផ្តល់ទីជំរក ការព្យាបាល និងសេវាកម្មហើយនិងការត្រួតពិនិត្យសំរាប់ជន ប្រព្រឹត្តិបទ ល្មើសជាយុវជននិងនិតិជន។*

*(C) ការការពារការរំលោភបំពានលើកុមារ ការមិនយកចិត្តទុកដាក់ឬការកេងប្រវ័ញ្ចដូចជា ការផ្តល់សេវាកម្មសំរាប់កុមារ និង យុវជនដែលត្រូវបានរំលោភបំពាន មិនត្រូវបានយកចិត្តទុកដាក់ ឬកេងប្រវ័ញ្ច ឬជនដែលស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភបំពានការមិនយក ចិត្តទុក ដាក់ ឬកេងប្រវ័ញ្ចហើយនិងគ្រួសារនៃកុមារទាំងនោះ ការផ្តល់សេវា កម្ម ចិញ្ចឹមនិងការផ្តល់សេវាកម្មការពារនីតិជន។*

*(D) ការផ្តល់សេវាកម្មសុខភាពផ្លូវចិត្តសំរាប់កុមារនិងយុវជនដើម្បីកាត់បន្ថយការធ្លាក់ចុះក្នុងសាលា ភាពគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃភាពគ្មាន*

ទីជំរកនិងការបញ្ចូលលទៅក្នុងពន្ធនាគារដែលអាចការពារបានឬស្ថាបនាកម្ម។

(E) ការការពារ ការព្យាបាល និងការផ្តល់សេវាកម្មសង្គ្រោះមកវិញសំរាប់ការប្រើបាស្រ់សារធាតុញៀន។

(2) "ច្បាប់សំរួលជាថ្មីឆ្នាំ 2011"មានន័យថា ច្បាប់ដែលបានអនុម័តនៅឬមុនថ្ងៃទី 30ខែកញ្ញាឆ្នាំ2012 ដើម្បីអនុវត្ត គំរោងថវិការដ្ឋ ដែលត្រូវបានផ្តល់សិទ្ធិជាការសំរួលឆ្នាំ2011 ហើយផ្តល់សំរាប់កិច្ច ការនៃទំនួលខុសត្រូវនូវសេវាសុវត្ថិភាពសាធារណៈទៅភ្នាក់ងារ មូល ដ្ឋាន រួមមាន ការទទួលខុសត្រូវរាយការណ៍ដែលពាក់ព័ន្ធ។ ច្បាប់គួរ ផ្តល់ដល់ភ្នាក់ងារមូលដ្ឋាននូវភាពងាយស្រួលផ្លាស់ប្តូរយ៉ាងច្រើនបំផុត និងការត្រួតពិនិត្យលើការរៀបចំ រដ្ឋបាលនិងដំនឹកជញ្ជូននៃ សេវាសុវត្ថិភាពសាធារណៈ ដែលស្របទៅតាម តំរូវការច្បាប់សហព័ន្ធ និងការផ្គត់ផ្គង់ថវិកាដូចដែលបានកំណត់ដោយច្បាប់។ តែទោះបីជាយ៉ាងណាក៏ដោយ ច្បាប់សំរួលឆ្នាំ2011 គួរ តែកុំបញ្ចូលឱ្យមាន កម្មវិធីថ្មីដែលដាក់ ទៅឱ្យភ្នាក់ងារមូលដ្ឋានបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ 2012 លើកលែងតែការវិនិច្ឆ័យចំរាញ់ជារឿយៗមុនកាលកំណត់ និងកម្មវិធីព្យាបាល (EPSDT)និងការយកចិត្តទុកដាក់ដែលមានការគ្រប់គ្រងតាមសុខភាពផ្លូវចិត្ត។

(b) (1) លើកលែងដូចដែលបានមានជូននៅក្នុងផ្នែករង (d) ដែលចាប់ផ្តើមនៅក្នុងឆ្នាំសារពើពន្ធ2011-12 និងបន្តបន្ទាប់មកទៀត ទឹកប្រាក់ខាងក្រោមគួរត្រូវដាក់ចូលទៅក្នុងថវិកាចំណូលមូលដ្ឋានឆ្នាំ 2011ដូចដែលបានចែងដោយផ្នែក 30025នៃលេខដូចរដ្ឋាភិបាល ដូចខាងក្រោម ៖

(A) ប្រាក់ចំណូលទាំងអស់ ដកចេញបាក្រ់ដែលបានមកវិញ បានមកពីពន្ធដារដែលបានរៀបរាប់នៅផ្នែកទី6051.15និង6201.15នៃកូដចំណូលនិងពន្ធដារ ដូចដែលផ្នែកទាំងនោះបាន ចែងនៅថ្ងៃទី1ខែ កក្កដាឆ្នាំ2011។

(B) ប្រាក់ចំណូលទាំងអស់ ដកចេញបាក្រ់ដែលបានមកវិញ បានមកពីប្រាក់បង់អាជ្ញាប័ណ្ណរថយន្តដែលបានរៀបរាប់ក្នុងផ្នែកទី 11005 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូលដូចដែលផ្នែកនោះបាន ចែងនៅថ្ងៃទី1ខែ កក្កដាឆ្នាំ 2011។

(2) នៅថ្ងៃ ឬមុនថ្ងៃទី1 ខែកក្កដាឆ្នាំ 2011 ប្រាក់ចំណូលដែលបានដាក់ចូលទៅ ដោយអនុលោមតាមកថាខណ្ឌទី (1) មិនគួរត្រូវបានចាត់ទុកជាប្រាក់ចំណូលថវិកាទូទៅឬប្រាក់ចំណូលនៃពន្ធដារសំរាប់គោលបំណងនៃផ្នែកទី 8នៃមាត្រាទី XVI នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

(c) (1)ប្រាក់ដែលបានដាក់ចូលទៅក្នុងថវិកាចំណូលតាមមូល ដ្ឋានឆ្នាំ 2011 ត្រូវបានធ្វើឱ្យសមរម្យជាបន្ត ដើម្បីផ្គត់ផ្គង់ទាំងស្រុងទៅលើខចែងនៃសេវាកម្មសុវត្ថិភាពសាធារណៈដោយភ្នាក់ងារមូលដ្ឋាន។ ការព្យួរការអនុវត្តន៍ពេញលេញនៃ ច្បាប់សំរួលឆ្នាំ2011ថវិកាក៏ប្រហែលត្រូវបានប្រើដើម្បីសងរដ្ឋវិញនូវថ្លៃ ដែលបានចំណាយទៅលើការផ្តល់សេវា សុវត្ថិភាពសាធារណៈក្នុងនាមភ្នាក់ងារមូលដ្ឋាន។ វិធីសាស្ត្រសំរាប់បែងចែកថវិកាគួរត្រូវបានបញ្ជាក់ក្នុងច្បាប់សំរួលឆ្នាំ 2011។

(2) អ្នកកាន់បញ្ជីខោនធី អ្នកកាន់បញ្ជីក្រុង និង ខោនធី ឬមន្ត្រីសមរម្យដទៃទៀតគួរបង្កើតថវិកចំណូលតាមមូលដ្ឋានខោនធីឆ្នាំ 2011ក្នុងរតនាគារក្នុងខោនធីនីមួយៗ ឬក្រុងនិងខោនធី។ លុយក្នុងថវិកាចំណូលតាមមូលដ្ឋានខោនធី2011 គួរតែត្រូវបានប្រើប្រាស់ទាំងស្រុងដើម្បីផ្គត់ផ្គង់ទាំងស្រុងទៅលើខចែងនៃសេវាកម្មសុវត្ថិភាពសាធារណៈដោយភ្នាក់ងារមូលដ្ឋាន ដូចបានបញ្ជាក់ដោយច្បាប់សំរួលឆ្នាំ 2011។

(3) ថ្វីបើវគ្គទី 6 នៃមាត្រា XIIIB ឬខចែងនៃរដ្ឋធម្មនុញ្ញដទៃ អាណត្តិមួយនៃកម្មវិធីថ្មីឬកំរិតខ្ពស់នៃសេវាកម្មភ្នាក់ងារតាមមូលដ្ឋាន កំណត់ដោយច្បាប់សំរួលឆ្នាំ2011 ឬ ដោយបទបញ្ជាណាដែលបានប្រើប្រាស់ឬបទបញ្ជាខាងនីតិប្រតិបត្តិ ឬ ការបង្គាប់ខាងរដ្ឋបាលដែល បានចេញឡើងដើម្បីអនុវត្តច្បាប់នោះ មិនគួរកំណត់តែងអាណត្តិមួយ ដែលទាមទារ ឱ្យរដ្ឋផ្តល់នូវប្រាក់ជំនួយនៃថវិកាក្នុងអត្ថន័យនៃផ្នែក នោះ។ តំរូវការណាដែលភ្នាក់ងារមូលដ្ឋានណាមួយអនុវត្តន៍តាម ជំពូកទី 9 (ចាប់ផ្តើមជាមួយផ្នែក 54950) នៃវគ្គទី1 នៃភាគ 2 នៃចំណងជើងទី5 នៃលេខកូដរដ្ឋាភិបាល ដោយគោរពតាមការ បំពេញតាមទំនួលខុសត្រូវនៃសេវាសុវត្ថិភាពសាធារណៈឬបញ្ហាផ្សេងទៀត មិនគួរក្លាយជាអាណត្តិដែលអាចសងបាន ក្រោមវគ្គទី 6នៃមាត្រាទី XIIIB។

(4) (A) ច្បាប់ដែលបានអនុម័តក្រោយថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2012 ដែលមានឥទ្ធិពលទាំងស្រុងនៃការបង្កើន តម្លៃដែលបានកើតមានជាស្រេចដោយភ្នាក់ងារមូលដ្ឋាន សំរាប់កម្មវិធីឬកំរិតនៃសេវាកម្មដែលដាក់កំណត់ដោយច្បាប់សំរួលឆ្នាំ2011គួរអនុវត្ត ចំពោះតែភ្នាក់ងារមូលដ្ឋានប៉ុណ្ណោះល្គឹកណាថារដ្ឋផ្តល់ថវិកាប្រចាំឆ្នាំសំរាប់ការកើនឡើងការចំណាយ។ភ្នាក់ងារមូលដ្ឋានមិនគួរមានកាតព្វកិច្ចផ្តល់នូវកម្មវិធីឬកំរិតសេវាកម្មតំរូវដោយច្បាប់ ដែលបានរៀបរាប់នៅក្នុងអនុកថាខណ្ឌនេះ នៅលើកំរិតដែលការផ្គត់ផ្គង់ថវិកាត្រូវបានផ្តល់ឱ្យ។

(B) បទបញ្ញត្តិ សារាចរ ឬសេចក្តីណែនាំដែលបានអនុម័តក្រោយថ្ងៃទី 9 ខែតុលា ឆ្នាំ2011 ដែលមិនចាំបាច់ត្រូវអនុវត្តតាមសេចក្តីកំណត់ឆ្នាំ2011 ហើយដែលច្បាប់នេះ ជះឥទ្ធិពលរួមលើការកើនឡើងនៃតម្លៃ ដែលនៅក្រោមបន្ទុករបស់ទីភ្នាក់ងារមូលដ្ឋាន ប្រើសម្រាប់កម្មវិធីឬកំរិតសេវាកម្មដែលបានផ្តល់អាណត្តិដោយសេចក្តីកំណត់ ឆ្នាំ2011 ច្បាប់នេះ ត្រូវអនុវត្តដោយទីភ្នាក់ងារមូលដ្ឋានតែទៅលើទំហំនៃការផ្តល់មូលនិធិប្រចាំឆ្នាំ សម្រាប់ការកើនឡើងតម្លៃដែលរដ្ឋផ្តល់ឱ្យតែប៉ុណ្ណោះ។ ទីភ្នាក់ងារមូលដ្ឋានមិនគួរមានកាតព្វកិច្ចផ្តល់កម្មវិធី ឬកំរិតសេវាកម្ម អនុលោមទៅតាមបទបញ្ញត្តិ សារាចរ ឬ សេចក្តីណែនាំថ្មី ដែលមានចែងក្នុងអនុកថាខណ្ឌនេះ លើសពីកំរិតមួយដែលមូលនិធិត្រូវបានផ្តល់ឱ្យ។

(C) កម្មវិធីថ្មី ឬសេវាកម្មកម្រិតខ្ពស់ណាមួយ ដែលផ្តល់ឱ្យដោយទីភ្នាក់ងារមូលដ្ឋាន ដូចមានចែងក្នុងអនុកថាខណ្ឌ (A) និង(B) លើសពីកម្រិតដែលមូលនិធិត្រូវបានផ្តល់ឱ្យ កម្មវិធី ឬសេវាថ្មីទាំងនេះ មិនត្រូវតំរូវឱ្យមានការឧបត្ថម្ភធន់ពីមូលនិធិរដ្ឋ ឬទោះជានៅក្រោមវគ្គទី6 នៃមាត្រាXIIIB ឡើយ។ កថា ខ័ណ្ឌនេះមិនត្រូវប្រើប្រាស់ ក្នុងច្បាប់ដែលបានដកចេញពីការឧបត្ថម្ភធននៅក្រោមកថាខណ្ឌ(2) នៃផ្នែករង(a) នៃវគ្គទី 6 នៃមាត្រាទី XIIIB ដូចដែលកថាខណ្ឌបានអានកាលពីថ្ងៃទី 2 ខែមករា ឆ្នាំ2011។

(D) រដ្ឋមិនត្រូវបញ្ជូនផែនការ ឬការបោះបង់សិទ្ធិណាមួយទៅរដ្ឋាភិបាលសហព័ន្ធ ឬធ្វើការធ្វើវិសោធនកម្មច្បាប់ ផែនការ ឬការបោះបង់សិទ្ធិទាំងនោះដែលជះឥទ្ធិពលរួមលើការកើនឡើងនៃតម្លៃ ដែលជាបន្ទុករបស់ទីភ្នាក់ងារមូលដ្ឋានសម្រាប់កម្មវិធី ឬកំរិតនៃសេវាកម្មដែលបានផ្តល់អាណត្តិដោយសេចក្តីកំណត់ឆ្នាំ2011 លើកលែងតែទំហំនៃផែនការ ការបោះបង់សិទ្ធិ ឬការធ្វើវិសោធនកម្មច្បាប់ ជាតំរូវការរបស់ច្បាប់សហព័ន្ធ ឬតំរូវការរដ្ឋដែលផ្តល់មូលនិធិប្រចាំឆ្នាំសម្រាប់ការកើនឡើងនៃតម្លៃ។

(E) រដ្ឋមិនត្រូវបានតំរូវឱ្យផ្តល់នូវការឧបត្ថម្ភធន់ ដោយអនុលោមតាមកថាខ័ណ្ឌនេះ សម្រាប់អាណត្តិដែលបានប្រកាសដោយរដ្ឋ ផ្អែកតាមសំណើរបស់ភ្នាក់ងារមូលដ្ឋាន ឬដើម្បីស្របតាមច្បាប់សហព័ន្ធ។ មូលនិធិរដ្ឋដែលតំរូវការដោយកថាខណ្ឌនេះត្រូវតែមកពីប្រភពមួយ ក្រៅពីប្រភពដែលបានចែងក្នុងផ្នែករង (b) និង(d) ពន្ធលើអចលនទ្រព្យនៃអែតវ៉ាឡូរ៉ែម ឬគណនីរងសេវាសង្គមនៃគណនីពន្ធទំនិញលក់ចេញរបស់មូលនិធិចំណូលក្នុងតំបន់។

(5) (A) សំរាប់កម្មវិធីទាំងឡាយដែលបានរៀបរាប់នៅក្នុងអនុកថាខណ្ឌ (C) ដល់(E)រួមមានកថាខណ្ឌ(1) នៃផ្នែក (a) និងដែលបានបញ្ចូលនៅក្នុងច្បាប់សំរួលឡើងវិញឆ្នាំ2011 ប្រសិនបើមានការផ្លាស់ប្តូរជាបន្តបន្ទាប់នៅក្នុងច្បាប់សហព័ន្ធឬច្បាប់ដែលកែប្រែលក្ខខណ្ឌដែលនៅក្រោមថវិកាបំពេញតំរូវរបស់សហព័ន្ធដូចដែលមានចែងនៅក្នុងច្បាប់សំរួលឡើងវិញឆ្នាំ2011 គឺត្រូវបានទទួលនិងមានឥទ្ធិពលទាំងស្រុងក្នុងការបង្កើនការចំណាយដែលកើតឡើងដោយភ្នាក់ងារមូលដ្ឋាន រដ្ឋគួរផ្តល់ជារៀងរាល់ឆ្នាំយ៉ាងតិចណាស់ 50 ភាគរយនូវចំណែកនៃការចំណាយដែលមិនមែនជាសហព័ន្ធ ដូចដែលបានកំណត់ដោយរដ្ឋ។

(B) នៅពេលរដ្ឋគឺជាភាគីបណ្តឹងណាមួយដែលនាំមកនូវនីតិវិធី តុលាការសហព័ន្ធឬដំណើរការរដ្ឋបាលដែលពាក់ព័ន្ធនឹងកម្មវិធីមួយឬច្រើនដូចដែលបានរៀបរាប់នៅក្នុងអនុកថាខណ្ឌ (C) ដល់(E)រួមមានកថាខណ្ឌ (1) នៃអនុភាគ (a) និងដែលបានបញ្ចូលនៅក្នុងច្បាប់សំរួលឡើងវិញឆ្នាំ 2011 ហើយមានការដោះស្រាយឬដីកាតុលាការឬរដ្ឋបាលដែលទាមទារឱ្យបង់ប្រាក់ជាទំរង់ការពិន័យជាបាក្រ់ឬមានឥទ្ធិពលទាំងស្រុងនៃការបង្កើនការចំណាយដែលកើតដោយភ្នាក់ងារមូលដ្ឋានសំរាប់កម្មវិធីឬកំរិតសេវាកម្មកំណត់ដោយច្បាប់សំរួលឡើងវិញឆ្នាំ2011 រដ្ឋគួរផ្តល់ជារៀងរាល់ឆ្នាំយ៉ាងតិចណាស់ 50

ភាគរយនូវចំណែកនៃការចំណាយទាំងនោះដែលមិនមែនសហព័ន្ធ ដូចដែលបានកំណត់ដោយរដ្ឋ។ ការបង់ដោយរដ្ឋមិនត្រូវ ប្រសិនបើ រដ្ឋកំណត់ថា ដំណោះស្រាយឬដីកាបញ្ជាទាក់ទងនឹងភ្នាក់ងារមូលដ្ឋានមួយឬច្រើនមិនបានធ្វើតាមតួនាទីរដ្ឋបាល មិនបានបំពេញកាតព្វកិច្ចច្បាប់ក្នុងចេតនាល្អ ឬប្រព្រឹត្តដោយកាយវិការព្រងើយកន្តើយឬធ្វេសប្រហែស។

*(C)* ថវិការដ្ឋដែលផ្តល់ជូននៅក្នុងកថាខណ្ឌនេះគួរបានមកពីប្រភពថវិកាផ្សេងក្រៅពីថវិកាដែលបានរៀបរាប់នៅក្នុងអនុផ្នែក *(b)* និង*(d)* ពន្ធអចលនទ្រព្យបន្ថែម ឬគណនីបន្ទាប់បន្សំខាងសេវាសង្គមនៃគណនីពន្ធលក់ដូររបស់ថវិកាចំណូលថ្នាក់មូលដ្ឋាន។

*(6)* ប្រសិនបើរដ្ឋឬភ្នាក់ងារមូលដ្ឋានបរាជ័យមិនបានធ្វើតាមតួនាទីឬកាតព្វកិច្ចនៅក្រោមផ្នែកនេះឬនៅក្រោមច្បាប់សំរួលឡើងវិញឆ្នាំ *2011*ភាគីសមស្របអាចស្វែងរកការសំរួលខាងតុលាការ។ នីតិវិធី ទាំងនេះគួរមានអាទិភាពលើសករណីរដ្ឋប្បវេណីផ្សេងទៀតទាំងអស់។

*(7)* ថវិកាដែលបានដាក់បញ្ចូលទៅក្នុងថវិកាប្រាក់ចំណូលក្នុង ខោនធីឆ្នាំ *2011* គួរត្រូវចំណាយក្នុងរបៀបដែលរៀបចំឡើងដើម្បីរក្សា ភាពមានសិទ្ធិរបស់រដ្ឋសំរាប់ថវិកាបំពេញតំរូវរបស់សហព័ន្ធ និងធានាឱ្យអនុលោមទៅតាមរដ្ឋតាមបទដ្ឋានសហព័ន្ធសមស្របដែលគ្រប់គ្រងលើខចែងនៃសេវាសុវត្ថិភាពសាធារណៈរបស់រដ្ឋ។

*(8)* ថវិកាដែលបានដាក់បញ្ចូលទៅក្នុងថវិកាប្រាក់ចំណូលក្នុង ខោនធីឆ្នាំ *2011* មិនគួរត្រូវបានប្រើដោយភ្នាក់ងារមូលដ្ឋានដើម្បីដាក់ ជំនួសថវិកាផ្សេងទៀតសំរាប់សេវាសុវត្ថិភាពសាធារណៈរបស់រដ្ឋទេ។

*(d)* ប្រសិនបើពន្ធដែលបានចែងនៅក្នុងអនុភាគ *(b)* ត្រូវបានកាត់ បន្ថយ ឬបញ្ឈប់ឱ្យមានដំណើរការ រដ្ឋគួរផ្តល់ជារៀងរាល់ឆ្នាំនូវថវិកា ដល់ថវិកាប្រាក់ចំណូលក្នុងខោនធីឆ្នាំ *2011* ក្នុងទឹកបាក្រ់ស្មើឬច្រើនជាងទឹកបាក្រ់សរុបដែលគួរតែត្រូវបានផ្តល់ដោយពន្ធដែលបានចែងនៅក្នុងផ្នែក*(b)*។ វិធីកំណត់ទឹកបាក្រ់នោះគួរត្រូវបានចែងនៅក្នុងច្បាប់សំរួលឡើងវិញឆ្នាំ*2011*ហើយរដ្ឋគួរមានកាតព្វកិច្ចផ្តល់ទឹកបាក្រ់ល្មឹកណាភ្នាក់ងារមូលដ្ឋានបានតំរូវឱ្យអនុវត្តភារ កិច្ចសេវាសុវត្ថិភាពសាធារណៈដែលដាក់កំណត់ដោយច្បាប់សំរួលឡើងវិញឆ្នាំ*2011*។ប្រសិនបើរដ្ឋបរាជ័យធ្វើឱ្យសមរម្យនូវទឹកបាក្រ់ពីថវិកាទូទៅនៅក្នុងចំណែកប្រចាំខែដែលលៃតាមចំនួនទៅក្នុងថវិកាប្រាក់ចំណូលក្នុងខោនធីឆ្នាំ *2011*។ បន្ទាប់មកអ្នកកាន់កាប់លុយកាក់គួរចំណាយទឹកប្រាក់ទាំងនេះទៅភ្នាក់ងារមូលដ្ឋានក្នុងរបៀបដែលណែនាំដោយច្បាប់សំរួលឡើងវិញឆ្នាំ *2011*។ កាតព្វកិច្ចរដ្ឋនៅក្នុងចំណុចនេះនឹងមានការអះអាងជាអាទិភាព សំរាប់លុយផ្គត់ផ្គង់ទូទៅទាបជាងអាទិភាព ទីមួយ សំរាប់លុយដែលនឹង ត្រូវដាក់ដោយឡែកនៅក្រោមផ្នែក*8* នៃមាត្រា *XVI* និងអាទិភាពទីពីរដើម្បី បង់បំណុលនិងចំណង ដែលអនុម័តដោយអ្នកបោះឆ្នោតដូចដែលមានចែង នៅផ្នែក *1* នៃមាត្រា *XVI*។

*(e)* *(1)* ដើម្បីធានាថាការអប់រំសាធារណៈមិនត្រូវបានប៉ះពាល់ក្នុងដំ ណើរការផ្តល់ជូននូវការការពារដ៏សំខាន់ដល់សេវាសុវត្ថិភាពសាធារណៈតាម មូលដ្ឋាន គណនីការពារការអប់រំត្រូវបានបង្កើតនៅក្នុងថវិកាទូទៅដើម្បីទទួលបាននិងបែងចែកបាក្រ់ចំណូលដែលបានមកពីការបង្កើនជាលំដាប់ទៅលើ ពន្ធដារដែលកំណត់ឱ្យបង់ដោយផ្នែកនេះ ដូចដែលបានបញ្ជាក់នៅក្នុងភាគ *(f)*។

*(2) (A)* មុនថ្ងៃទី *30*ខែមិថុនាឆ្នាំ *2013*និងមុនថ្ងៃទី*30*ខែមិថុនានៃឆ្នាំ នីមួយៗចាប់ពីឆ្នាំ *2014*ដល់ឆ្នាំ *2018* ដោយរួមមាននាយកហិរញ្ញវត្ថុគួរ ប៉ាន់ស្មានទឹកបាក្រ់ចំណូលបន្ថែមសរុប ដកចេញបាក្រ់ដែលបានមកវិញ ដែលនឹងបានមកពីការបង្កើនជាលំដាប់ទៅលើកំរិតពន្ធដារដែលបានធ្វើនៅ ក្នុងអនុភាគ *(f)* ដែលនឹងមានរួចរាល់សំរាប់ការផ្ទេរទៅក្នុងគណនីការពារការ អប់រំក្នុងឆ្នាំសារពើពន្ធក្រោយ។ នាយកហិរញ្ញវត្ថុគួរធ្វើការប៉ាន់ស្មានដូចគ្នាឱ្យ បានត្រឹមថ្ងៃទី *10*ខែមករាឆ្នាំ *2013*សំរាប់បាក្រ់ចំណូលបន្ថែម ដកចេញនូវ ប្រាក់សំណងមកវិញ ដែលនឹងទទួលបានមកត្រឹមដំណាច់ឆ្នាំសារពើពន្ធ *2012-13*។

*(B)* ក្នុងរយៈពេល *10*ថ្ងៃចុងក្រោយនៃត្រីមាសជារៀងរាល់ត្រីមាសបីដំបូងនៃឆ្នាំសារពើពន្ធនីមួយៗចាប់ពីឆ្នាំ *2013-14*ដល់ឆ្នាំ *2018-19*ដែលរួមមាន អ្នកកាន់កាប់លុយកាក់គួរផ្ទេរចូលទៅក្នុងគណនី ការពារការអប់រំនូវមួយភាគបួននៃទឹកបាក្រ់សរុបដែលបានប៉ាន់ស្មានស្របតាមអនុកថាខណ្ឌ *(A)*សំរាប់ឆ្នាំសារពើពន្ធនោះ លើកលែងតែ ទឹកបាក្រ់នេះអាចត្រូវបានកែសំរួលស្របតាមអនុកថាខណ្ឌ *(D)*។

*(C)* ក្នុងឆ្នាំសារពើពន្ធនិមួយៗ ចាប់ពីឆ្នាំ *2012-13* រហូតដល់ឆ្នាំ *2020-21* ដែលរាប់បញ្ចូលនាយកហិរញ្ញវត្ថុត្រូវគណនាលើការកែសម្រួលសម្រាប់គណនីការពារការអប់រំ ដូចបានបញ្ជាក់ច្បាស់ក្នុងអនុកថាខណ្ឌ*(D)* ដោយបូកបន្ថែមចំនួនដូចខាងក្រោម តាមដែលអាចធ្វើបានៈ

*(i)* នៅចុងត្រីមាសនៃឆ្នាំសារពើពន្ធនិមួយៗ ចាប់ពីឆ្នាំ*2012-13* ដល់ឆ្នាំ *2018-19* រាប់បញ្ចូលទាំង នាយក ហរិញ្ញវត្ថុត្រូវគណនានូវចំនួនប៉ាន់ប្រមាណ សម្រាប់ឆ្នាំសារ ពើពន្ធអនុលោមទៅតាមកថាខណ្ឌរង*(A)* និងត្រូវដកចេញទៅតាមការប៉ាន់ប្រមាណថ្មី នូវចំនួនដែលបានផ្ទេរទៅគណនីការពារការអប់រំសម្រាប់ឆ្នាំសារពើពន្ធនោះ។

*(ii)* ក្នុងខែមិថុនា ឆ្នាំ២*2015* និងរៀងរាល់ខែមិថុនា ឆ្នាំ*2016* ដល់ឆ្នាំ *2021* រាប់បញ្ចូលទាំងនាយកហិរញ្ញវត្ថុត្រូវធ្វើការកំណត់ចុងក្រោយនូវចំនួន ប្រាក់ចំណូលបន្ថែម ប្រាក់បដិទានតិច ទទួលបានពីអត្រាពន្ធនៃការតម្លើង ប្រាក់បៀវត្សរ៍តាមកំរិតប្រចាំឆ្នាំ ដែលបានបង្កើតក្នុងផ្នែករង*(f)* សម្រាប់ឆ្នាំ សារពើពន្ធ ដែលបញ្ចប់ពីរឆ្នាំមុន ។ ចំនួននៃការប៉ាន់ស្មានថ្មីបានគណនាក្នុង ប្រការ*(i)* សម្រាប់ឆ្នាំសារពើពន្ធបញ្ចប់ពីរឆ្នាំមុន ត្រូវបានដកចេញពីចំនួននៃការកំណត់សរុបចុងក្រោយនេះ។

*(D)* បើសិនការបូកសរុបដែលបានកំណត់ អនុលោមតាមកថាខណ្ឌរង *(C)* វិជ្ជមាន អ្នកត្រួតពិនិត្យត្រូវផ្ទេរនូវចំនួនដែលស្មើទៅនឹងការបូកសរុបនោះចូលទៅក្នុងគណនីការពារការអប់រំក្នុងរយៈពេល*10* ថ្ងៃ មុននឹងបញ្ចប់ឆ្នាំសារពើពន្ធ។ បើសិនជាចំនួននោះអវិជ្ជមាន អ្នកត្រួតពិនិត្យត្រូវបញ្ឈប់បណ្តោះអាសន្ន ឬកាត់បន្ថយការផ្ទេរប្រចាំត្រីមាស បើសិនជាមាន ទៅក្នុងគណនីការពារការអប់រំ រហូតដល់ការកាត់បន្ថយស្មើនឹងចំនួនអវិជ្ជមានបានចែងក្នុងនោះ។ សម្រាប់គោលបំណងនៃការគណនាណាមួយបង្កើតឡើង អនុលោមទៅតាមប្រការ*(i)* នៃអនុកថាខណ្ឌ *(C)* ចំនួននៃការផ្ទេរប្រចាំត្រីមាស មិនត្រូវកែសម្រួលដើម្បីបង្ហាញពីការបញ្ឈប់បណ្តោះអាសន្ន ឬការកាត់បន្ថយដែលបានធ្វើឡើងអនុលោមតាមអនុកថាខណ្ឌនេះ។

*(3)* ថវិកាទាំងអស់នៅក្នុងគណនីនៃការការពារការអប់រំត្រូវបានផ្តល់តម្លៃជាបន្តបន្ទាប់ដើម្បីការគាំទ្រសាលារៀនក្នុងខោនធីការិយាល័យអប់រំរបស់ខោនធី សាខាសាលារៀន និងមហាវិទ្យាល័យសហគមន៍ក្នុងខោនធី ដូចដែលបានចែងឡើងនៅក្នុងកថាខណ្ឌនេះ។

*(A)* ដប់មួយភាគរយនៃថវិកាដែលបានកែសំរួលដោយអនុលោមទៅតាមកថាខណ្ឌនេះ គួរត្រូវបានបែងចែកជារៀងរាល់ត្រីមាស ដោយគណៈកម្មការអភិបាល នៃមហាវិទ្យាល័យសហគមន៍នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ាទៅឱ្យមហាវិទ្យាល័យសហគមន៍ក្នុងខោនធី ដើម្បីផ្តល់ជាការផ្គត់ផ្គង់ថវិកាសំរាប់គោលបំណង ទូទៅសំរាប់មហាវិទ្យាល័យសហគមន៍ក្នុងខោនធី ដែលសមាមាត្រទៅនឹងចំនួនទឹកបាក្រ់ដែលបានកំណត់ដោយអនុលោមទៅតាមផ្នែក *84750.5* នៃក្រមអប់រំ ដូចដែល ផ្នែកលេខកូដនោះចែងលើការអនុម័តនៃផ្នែកនេះរបស់អ្នកបោះឆ្នោត។ ការបែងចែកដោយគណនាស្របតាមអនុកថាខណ្ឌដែលគួរតែលៃលកទូទាត់ដោយទឹកបាក្រ់ដែលបានបញ្ជាក់ក្នុងអនុភាគ *(a), (c)*និង *(d)*នៃផ្នែក *84751* នៃក្រមអប់រំដូចដែលផ្នែក នោះចែងលើការអនុម័ត នៃផ្នែកនេះរបស់អ្នកបោះឆ្នោតដែលហួសពីចំនួនទឹកប្រាក់ ដែលបានគណនាស្របតាមផ្នែក *84750.5*នៃក្រមអប់រំដូចដែលផ្នែក នោះចែងលើការអនុម័តនៃផ្នែកនេះរបស់អ្នកបោះឆ្នោត ប្រសិនបើគ្មានមហាវិទ្យាល័យសហគមន៍ក្នុងខោនធីណានឹងទទួលបានថវិកាតិចជាងមួយរយដុល្លារ *($100* ដុល្លារ*)*សំរាប់សិស្សដោយស្មោះនឹងពេញម៉ោង។

*(B)* ប៉ែតសិបប្រាំបួនភាគរយនៃថវិកាដែលបានកែសំរួលដោយ អនុលោមទៅតាមទៅតាមកថាខណ្ឌនេះ គួរត្រូវបានបែងចែកជារៀងរាល់ត្រីមាសដោយអ្នកមើលការខុសត្រូវនៃការណែនាំជាសាធារណៈដើម្បីផ្តល់ជាការផ្គត់ផ្គង់ថវិកាសំរាប់គោលបំណង ទូទៅសំរាប់សាលាក្នុងខោនធី ការិយាល័យអប់រំរបស់ខោនធីនិងការផ្គត់ផ្គង់ថវិកាសំរាប់គោលបំណងទូទៅរបស់រដ្ឋសំរាប់សាខាសាលារៀន ដែលសមាមាត្រទៅនឹងកំរិតនៃប្រាក់ចំណូល ដែលបានគណនាដោយអនុលោមតាមផ្នែក *2558*និង *42238* នៃក្រមអប់រំ ហើយទឹកបាក្រ់ដែលបានគណនា ដោយអនុលោមតាមផ្នែក *47633* នៃក្រមអប់រំសំរាប់ការិយាល័យអប់រំរបស់ខោនធី សាសាក្នុងខោនធី និងសាខាសាលារៀន តាមលេខរៀង ដូចដែល ផ្នែកទាំងនោះចែងលើការអនុម័ត នៃផ្នែកនេះ

របស់អ្នកបោះឆ្នោត។ ទឹកប្រាក់ដែលបានគណនាដូចនេះ គួរលៃលកទូទាត់ដោយទឹកប្រាក់ដែលបានបញ្ជាក់ ក្នុងអនុភាគ (c)នៃផ្នែក 2558 កថាខណ្ឌទី (1)ដល់ទី (7)នៃអនុភាគ(h)នៃផ្នែក 42238 និងផ្នែក 47635 នៃក្រមអប់រំ សំរាប់ការិយាល័យអប់រំរបស់ខោនធីសាសាក្នុងខោនធី និងសាខាសាលារៀន តាមលេខរៀងដូចដែល ផ្នែកទាំងនោះចែងលើការអនុម័តនៃផ្នែកនេះរបស់អ្នកបោះឆ្នោត ដែលហួសពីចំនួនទឹកប្រាក់ ដែលបានគណនាស្របតាមផ្នែក 2558 42238 និង 47633 នៃក្រមអប់រំសំរាប់ការិយាល័យអប់រំរបស់ខោនធីសាសាក្នុងខោនធី និងសាខាសាលារៀន តាមលេខរៀងដូចដែលផ្នែកទាំងនោះចែងលើការអនុម័តនៃផ្នែកនេះរបស់ អ្នក បោះឆ្នោត ប្រសិនបើគ្មានសាលាក្នុងខោនធីណាការិយាល័យអប់រំរបស់ខោនធីឬសាខាសាលារៀនណានឹងទទួលបានថវិកាតិចជាងពីររយដុល្លារ ($200 ដុល្លារ) ក្នុងមួយកំរិតនៃវត្តមានប្រចាំថ្ងៃជាមធ្យម។

(4) និងមិនទាមទារនូវវិធានការផ្ទេកច្បាប់ដើម្បីឱ្យមានសុពល ភាពទេ។ ការបែងចែកថវិកាក្នុងគណនីគាំពារការអប់រំ ដោយគណៈកម្មការអភិបាល នៃមហាវិទ្យាល័យសហគមន៍នៃរដ្ឋកាលីហ្វ័រញ៉ា និងអ្នកមើលការខុសត្រូវខាងការណែនាំសាធារណៈ ដែលមិនគួរត្រូវបានពន្យាពេល ឬបើមិនដូច្នោះទេ ត្រូវបានរងផលប៉ះពាល់ដោយការខកខានខាងច្បាប់និងអ្នកគ្រប់គ្រង ដើម្បីអនុម័តច្បាប់ថវិកាប្រចាំឆ្នាំដោយអនុលោមតាមវគ្គទី 12 នៃមាត្រា IV តាមការសំអាងនៃកថាខណ្ឌ(h) នៃវគ្គទី8 នៃមាត្រា XVIឬសកម្មភាពដទៃផ្សេងទៀត ឬការបរាជ័យក្នុងការបំពេញសុពលភាពដោយច្បាប់ ឬអភិបាលរដ្ឋ។

(5) ថ្វីបើមានខចែងនៃច្បាប់ផ្សេងទៀតក៏ដោយ ថវិកាដែលបាន ដាក់បញ្ចូលទៅក្នុងគណនីការពារការអប់រំ មិនគួរត្រូវបានប្រើដើម្បី ចំណាយទៅលើការចំណាយផ្សេងៗដែលកើតឡើងដោយច្បាប់ អភិបាលរដ្ឋ ឬភ្នាក់ងារណាមួយរបស់រដ្ឋាភិបាលរដ្ឋ។

(6) មហាវិទ្យាល័យសហគមន៍ក្នុងខោនធី ការិយាល័យអប់រំរបស់ ខោនធី សាលាក្នុងខោនធី ឬសាខាសាលារៀនគួរមានសិទ្ធិផ្តាច់មុខ ដើម្បីកំណត់ពីរបៀបដែលថវិកាដែលទទួលបានពីគណនី ការការពារការអប់រំត្រូវបានចំណាយទៅលើសាលារៀន ឬសាសាស្ត្រក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ទោះយ៉ាងណា ប្រសិនបើ គណៈកម្មការឬស្ថាប័នគ្រប់គ្រងដ៏ត្រឹមត្រូវ គួរតែធ្វើការកំណត់ការចំណាយទាំងនេះ នៅក្នុងសម័យប្រជុំជាចំហនៃការប្រជុំជាសាធារណៈមួយនៃគណៈកម្មការឬស្ថាប័នគ្រប់គ្រងហើយមិនគួរប្រើប្រាស់ថវិកាពីគណនី ការការពារការអប់រំ សំរាប់ប្រាក់បៀវត្សរ៍ឬផលប្រយោជន៍ នៃអ្នកគ្រប់គ្រង ឬតម្លៃរដ្ឋបាលផ្សេងៗទៀតនោះទេ។ មហាវិទ្យាល័យសហគមន៍ក្នុងខោនធី ការិយាល័យអប់រំរបស់ខោនធី សាលាក្នុងខោនធី និងសាខាសាលារៀននីមួយៗ គួរផ្សព្វផ្សាយជារៀងរាល់ឆ្នាំ លើប្រព័ន្ធអ៊ិនធឺណែតនូវគណនេយ្យ ថាតើថវិកាប៉ុន្មានដែលត្រូវបានទទួលពីគណនីការការពារការអប់រំ ហើយតើថវិកាត្រូវបានចំណាយរបៀបណា។

(7) ការត្រួតពិនិត្យខាងហិរញ្ញវត្ថុនិងការអនុលោមតាមដោយឯករាជ្យប្រចាំឆ្នាំដែលតំរូវឱ្យមហាវិទ្យាល័យសហគមន៍ក្នុងខោនធី ការិយាល័យអប់រំរបស់ខោនធី សាលាក្នុងខោនធី និងសាខាសាលារៀនជាបន្ថែមលើតំរូវការផ្សេងៗដទៃទៀតនៃច្បាប់ គួរតែពិនិត្យ បញ្ជាក់និងផ្ទៀងផ្ទាត់ថាតើថវិកាដែលបានផ្តល់ដោយគណនីការការពារការអប់រំ ត្រូវបានចែកចាយនិងចំណាយដោយសមស្របដូចដែលតំរូវដោយផ្នែកនេះ។ ការចំណាយដែលកើតដោយស្ថាប័នទាំងនោះដើម្បីអនុលោមតាមតំរូវការពិនិត្យបន្ថែមរបស់ផ្នែកនេះអាចត្រូវបានបង់ឱ្យដោយការផ្តល់ថវិកាពីគណនីការការពារការអប់រំ និងមិនគួរត្រូវបានពិចារណាថ្លៃរដ្ឋបាលសំរាប់គោលបំណងរបស់ផ្នែកនេះទេ។

(8) ប្រាក់ចំណូល ដកចេញនូវប្រាក់ដែលឱ្យមកវិញបានមកដោយអនុលោមតាមអនុភាគ (f)សំរាប់តម្កល់ទុកក្នុងគណនីការពារការអប់រំ ស្របតាមផ្នែកនេះគួរត្រូវបានចាត់ជា "ប្រាក់ចំណូលថវិកាទូទៅ" "ប្រាក់ចំណូល នៃពន្ធដារទូទៅ" និង "ថវិកាដែលនឹងត្រូវបានប្រើដោយរដ្ឋសំរាប់ការជួយគាំទ្រ សាលាក្នុងខោនធីនិងមហាវិទ្យាល័យសហគមន៍ក្នុងខោនធីសំរាប់គោលបំណងនៃវគ្គទី 8នៃមាត្រា XVI។

(f) (1) (A) បន្ថែមលើពន្ធដារដែលត្រូវបានតំរូវឱ្យបង់ដោយភាគ 1 (ផ្តើម ដោយផ្នែក 6001)នៃភាគទី 2 នៃលេខកូដប្រាក់ចំណូលនិង ការយកពន្ធសំរាប់សិទ្ធិលក់ដូរទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលអាចប្តូរយកប្រាក់វិញបានក្នុងតំលៃលក់រាយ ពន្ធដារត្រូវបានតំរូវឱ្យបង់ចំពោះអ្នកលក់រាយទាំងអស់នៅអត្រា 1/4 ភាគរយនៃបង្កាន់ដៃប្រាក់ទាំងអស់នៃអ្នកលក់រាយណាក៏ដោយ ពីការលក់ដូរ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់ដែលអាចប្តូរយកប្រាក់វិញបាន នៅកន្លែងលក់រាយ នៅក្នុងរដ្ឋនេះ នៅថ្ងៃឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2013 និងមុនថ្ងៃទី1 ខែមករា ឆ្នាំ 2017។

(B) បន្ថែមលើពន្ធដារដែលត្រូវបានតំរូវឱ្យបង់ដោយភាគ 1 (ផ្តើមដោយផ្នែក6001)នៃអនុផ្នែក 2 នៃលេខកូដប្រាក់ចំណូលនិងការយកពន្ធ ពន្ធអាករត្រូវបានតំរូវឱ្យបង់ចំពោះការផ្ទុកឥវ៉ាន់ ការប្រើបាស្រ់ឬ ការប្រើប្រាស់ដទៃទៀតនៅក្នុងរដ្ឋនេះនៃទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលអាចប្តូរយកប្រាក់វិញបាន ដែលបានទិញពីអ្នកលក់រាយណា នៅថ្ងៃឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2013 និងមុនថ្ងៃទី 1 ខែមករា ឆ្នាំ2017 សំរាប់លើការផ្ទុកឥវ៉ាន់ ការប្រើបាស្រ់ឬ ការប្រើប្រាស់ដទៃទៀតនៅក្នុងរដ្ឋនេះ នៅអត្រា១/៤ភាគរយនៃតម្លៃលក់នៃទ្រព្យសម្បត្តិនោះ។

(C) ច្បាប់លក់ដូរនិងការប្រើប្រាស់ពន្ធដារ រួមមានវិសោធនកម្មណាមួយដែលបានអនុម័តនៅថ្ងៃឬបន្ទាប់ពីថ្ងៃចូលជាធរមាននៃផ្នែកនេះ គួរអនុវត្តទៅលើពន្ធដែលតំរូវឱ្យបង់ស្របតាមកថាខណ្ឌនេះ។

(D) កថាខណ្ឌនេះនឹងមិនដំណើរការនៅថ្ងៃទី 1ខែមករា ឆ្នាំ2017។

(2) សំរាប់ឆ្នាំពន្ធដារចាប់ផ្តើមនៅថ្ងៃឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2012 និងមុន ថ្ងៃទី1 ខែមករា ឆ្នាំ2019 ដោយគោរពតាមពន្ធដែលតំរូវឱ្យបង់ ស្របតាមវគ្គទី 17041 នៃលេខកូដប្រាក់ចំណូលនិងការយកពន្ធ កំរិតពន្ធ ប្រាក់ចំណូល និង អត្រា 9.3 ភាគរយ ដែលបានកំណត់ក្នុងកថាខណ្ឌ (1) នៃអនុភាគ (a)នៃផ្នែក 17041 នៃលេខកូដប្រាក់ចំណូលនិងការយកពន្ធ គប្បីត្រូវបានកែប្រែតាមលំដាប់លំដោយនីមួយៗដូចតទៅ:

(A) (i) សំរាប់ចំណែកនៃប្រាក់ចំណូលដែលអាចកាត់ពន្ធបានដែលលើសពី ពីររយហាសិបពាន់ដុល្លារ (250,000ដុល្លារ) ប៉ុន្តែមិនលើសពី បីរយពាន់ដុល្លារ (300,000ដុល្លារ) អត្រាពន្ធគឺ 10.3 ភាគរយ នៃបាក្រ់លើសពី ពីររយហាសិបពាន់ដុល្លារ (250,000ដុល្លារ)។

(ii) សំរាប់ចំណែកនៃប្រាក់ចំណូលដែលអាចកាត់ពន្ធបានដែល លើសពី បីរយពាន់ដុល្លារ (300,000ដុល្លារ) ប៉ុន្តែមិនលើសពី បាំរូយពាន់ដុល្លារ (500,000ដុល្លារ) អត្រាពន្ធគឺ 11.3 ភាគរយ នៃបាក្រ់លើសពី បីរយពាន់ដុល្លារ (300,000ដុល្លារ) ។

(iii) សំរាប់ចំណែកនៃប្រាក់ចំណូលដែលអាចកាត់ពន្ធបានដែលលើសពី ប្រាំរយពាន់ដុល្លារ (500,000ដុល្លារ) អត្រាពន្ធគឺ 12.3 ភាគរយនៃបាក្រ់លើសពី បាំរូយពាន់ដុល្លារ (500,000ដុល្លារ) ។

(B) កំរិតពន្ធប្រាក់ចំណូលដែលបានបញ្ជាក់នៅក្នុងអនុប្រយោគ (i), (ii), និង(iii)នៃអនុកថាខណ្ឌ (A)គួរត្រូវបានគណនាសារជាថ្មី ដូចដែលមានចែងក្នុងអនុភាគ (h)នៃវគ្គទី17041 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល សំរាប់ តែឆ្នាំពន្ធដារដែលចាប់ផ្តើមនៅថ្ងៃ ឬបន្ទាប់ថ្ងៃទី 1 ខែមករា ឆ្នាំ 2013 ប៉ុណ្ណោះ។

(C) (i) សំរាប់គោលបំណងនៃអនុផ្នែក (g)នៃវគ្គទី 19136 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល កថាខណ្ឌនេះគួរត្រូវបានពិចារណា ឱ្យបែងជាជំពូកនៅថ្ងៃដែលវាមានសុពលភាព។

(ii) សំរាប់គោលបំណងនៃភាគទី 10(ផ្តើមដោយផ្នែក 17001)និងផ្នែកទី10.2 (ផ្តើមដោយវគ្គទី18401)នៃភាគទី2 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល កំរិតពន្ធដែលបានកែប្រែ និងអត្រាពន្ធ ដែលត្រូវបានបង្កើតនិងតំរូវឱ្យបង់ដោយកថាខណ្ឌនេះ គួរតែត្រូវបានចាត់ទុកថា នឹង ត្រូវបានបង្កើតនិងតំរូវឱ្យបង់ក្រោមផ្នែក 17041 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល។

(D) កថាខណ្ឌនេះនឹងមិនដំណើរការនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2019។

(3) សំរាប់ឆ្នាំពន្ធដារដែលចាប់ផ្តើមនៅថ្ងៃឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ 2012 និងមុនថ្ងៃទី1 ខែមករា ឆ្នាំ 2019 ដោយគោរពតាមពន្ធ ដែលតំរូវឱ្យបង់ស្របតាមវគ្គទី 17041 នៃលេខកូដប្រាក់ចំណូលនិងការយកពន្ធកំរិតពន្ធប្រាក់ចំណូលនិងអត្រា 9.3 ភាគរយ ត្រូវបានដាក់កំណត់នៅក្នុងកថាខ័ណ្ឌ (1) នៃអនុភាគ (c)នៃផ្នែក 17041 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល គប្បីត្រូវបានកែប្រែ តាមលំដាប់ លំដោយ ដូចខាងក្រោម ៖

*(A) (i) សំរាប់ចំណែកនៃប្រាក់ចំណូលដែលអាចកាត់ពន្ធបាន ដែលលើសពីបីរយសែសិបពាន់ដុល្លារ (340,000ដុល្លារ) ប៉ុន្តែមិន លើសពីបួនរយបាំប្រីពាន់ដុល្លារ (408,000ដុល្លារ) អត្រាពន្ធគឺ 10.3 ភាគរយ នៃប្រាក់លើសពី បីរយសែសិបពាន់ដុល្លារ (340,000ដុល្លារ)។*

*(ii) សំរាប់ចំណែកនៃប្រាក់ចំណូលដែលអាចកាត់ពន្ធបាន ដែល លើសពីបួនរយបាំប្រីពាន់ដុល្លារ (408,000ដុល្លារ) ប៉ុន្តែមិន លើសពីបាំមួយរយប៉ែតសិបពាន់ដុល្លារ (608,000ដុល្លារ) អត្រាពន្ធគឺ 11.3 ភាគរយ នៃប្រាក់លើសពីបួនរយបាំប្រីពាន់ដុល្លារ (408,000ដុល្លារ)។*

*(iii) សំរាប់ចំណែកនៃប្រាក់ចំណូលដែលអាចកាត់ពន្ធបានដែលលើសពីបាំមួយរយប៉ែតសិបពាន់ដុល្លារ (608,000ដុល្លារ) អត្រា ពន្ធគឺ 12.3 ភាគរយនៃបាក្រ់លើសពីបាំមួយរយប៉ែតសិបពាន់ដុល្លារ (608,000ដុល្លារ) ។*

*(B) កំរិតពន្ធប្រាក់ចំណូលដែលបានបញ្ជាក់នៅក្នុងអនុប្រយោគ (i), (ii), និង(iii)នៃអនុកថាខណ្ឌ (A)គួរត្រូវបានគណនាសារជាថ្មីដូច ដែលមានចែងក្នុងអនុភាគ(h)នៃវគ្គទី 17041 នៃលេខកូដប្រាក់ចំណូលនិងការយកពន្ធ សំរាប់តែឆ្នាំពន្ធដារដែលចាប់ផ្តើមនៅថ្ងៃ ឬបន្ទាប់ថ្ងៃទី 1 ខែមករា ឆ្នាំ2013 ប៉ុណ្ណោះ។*

*(C) (i) សំរាប់គោលបំណងនៃអនុផ្នែក(g)នៃផ្នែក 19136នៃក្រមមស្តីពីពន្ធដារ និងប្រាក់ចំណូល កថាខណ្ឌនេះគួរត្រូវ បានពិចារណាឱ្យបែង ជាជំពូកនៅថ្ងៃដែលវាចូលជាធរមាន ។*

*(ii) សំរាប់គោលបំណងនៃភាគទី 10(ផ្តើមដោយវគ្គ 17001)និងជំពូកទី 10.2 (ផ្តើមដោយផ្នែក 18401)នៃភាគ ទី2 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល កំរិតពន្ធដែលបានកែប្រែ និងអត្រាពន្ធ ដែលត្រូវបានបង្កើតនិងតំរូវឱ្យបង់ដោយកថាខណ្ឌនេះ គួរតែត្រូវបានចាត់ទុកថា នឹងត្រូវបានបង្កើតនិងតំរូវឱ្យបង់ក្រោមផ្នែក 17041 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល។*

*(D) កថាខណ្ឌនេះនឹងមិនដំណើរការនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2019។*

*(g) (1) អ្នកត្រួតពិនិត្យ អនុលោមទៅតាមច្បាប់ដែនអំណាចរបស់គាត់ អាចធ្វើ ការត្រួតពិនិត្យលើការចំណាយពីថវិកាចំណូលមូលដ្ឋានឆ្នាំ 2011 និង ប្រាក់ចំណូលក្នុងខោនធីឆ្នាំ2011 និងគួរពិនិត្យគណនីការការពារការអប់រំ ដើម្បីធានាថាថវិកាទាំងនោះត្រូវបានប្រើនិងមានទំនួលខុសត្រូវ ក្នុងរបៀបមួយដែលស្របជាមួយនឹងផ្នែកនេះ។*

*(2) អគ្គមេធាវីឬ មេធាវីតាមមូលដ្ឋាន គួរតែធ្វើការសើបអង្កេត យ៉ាងរួសរាន់ និងអាចស្វែងរកការដាក់ទោសរដ្ឋប្បវេណី ឬបទឧក្រិដ្ឋសំរាប់ ការប្រើប្រាស់លុយខុសពីថវិកាចំណូលរបស់ខោនធីឆ្នាំ 2011 ឬ គណនីការការពារការ អប់រំ។*

ផ្នែក 5. ថ្ងៃចូលជាធរមាន

អនុភាគ(b)នៃវគ្គទី 36 នៃមាត្រាXIII នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា ដូចដែលបានបន្ថែមដោយវិធានការនេះ គួរតែដំណើរការនៅថ្ងៃទី1 ខែមករា ឆ្នាំ2011។ កថាខណ្ឌទី(2)និង(3) នៃអនុផ្នែក(f) នៃវគ្គទី36 នៃមាត្រា XIII នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា ដូចដែលបានបន្ថែម ដោយវិធានការនេះ គួរតែដំណើរការនៅថ្ងៃទី1 ខែមករា ឆ្នាំ2012។ ខចែងដទៃទៀតទាំងអស់នៃវិធានការនះគួរតែដំណើរការនៅថ្ងៃបន្ទាប់ ពីការបោះឆ្នោតដែលវាត្រូវបានអនុម័តដោយមតិភាគច្រើននៃអ្នកបោះឆ្នោត បោះឆ្នោតអោយវិធានការដែលបាន ផ្តល់ជូន។

វគ្គទី 6. វិធានការចំរូងចំរាស

នៅក្នុងព្រឹត្តិការណ៍ ដែលវិធានការនេះនិងវិធានការមួយទៀត ដែលបង្ខំឱ្យបង់នៃការកើនឡើងជាកំរិតនៃអត្រាពន្ធដារ សំរាប់ប្រាក់ចំណូល ផ្ទាល់ខ្លួនគួរតែមាននៅលើសន្លឹកឆ្នោតនៃរដ្ឋទាំងមូលដូចគ្នា ខចែង នៃវិធានការដទៃផ្សេងទៀត ឬវិធានការនានាគួរត្រូវបានចាត់ទុកថា នៅក្នុងភាពចំរូងចំរាស់ជាមួយនឹងវិធានការនេះ។ នៅក្នុង ព្រឹត្តិការណ៍ដែលវិធានការនេះទទួលបាន ចំនួនច្រើននៃសន្លឹក ឆ្នោតវិជ្ជមាន ជាងវិធានការដែលគួរត្រូវបានជឿថានៅក្នុងភាព ចំរូងចំរាស់ជាមួយវា ខចែងនៃវិធានការនេះ គួរតែឈ្នះទាំងស្រុង ដោយភាពបរិបូរណ៍របស់ពួកគេ ហើយវិធានការដទៃទៀត ឬវិធានការមួយចំនួននឹងក្លាយជាមោឃៈ និងអសាបង់។

វគ្គទី 7. វិធានការនេះបានផ្តល់ថវិកាឱ្យសាលាក្នុងខោនធីនិង មហាវិទ្យាល័យសហគមន៍ក្នុងខោនធីនៅក្នុងទឹកបាក្រ់ស្មើឬលើសពីនោះ ដែលគួរតែត្រូវបានផ្តល់ឱ្យ ប្រសិនបើប្រាក់ចំណូលបានដាក់ បញ្ចូលស្របតាមវគ្គទី 6051.15និង6201.15នៃលេខកូដប្រាក់ ចំណូលនិងពន្ធដាអនុលោមតាមវគ្គ 6051.15 និង6201.15 នៃក្រមស្តីពីពន្ធដារ និងប្រាក់ចំណូលដោយអនុលោមតាមជំពូកទី 43 នៃលក្ខន្តិកៈច្បាប់ឆ្នាំ 2011 ដែលត្រូវបានចាត់ទុកជា "ប្រាក់ចំណូលថវិកាទូទៅ" ឬជា "ថវិកាទូទៅបានពីពន្ធដារ" សំរាប់គោលបំណងនៃវគ្គទី 8 នៃមាត្រា XVI នៃរដ្ឋធម្មនុញ្ញ រដ្ឋកាលីហ្វ័រញ៉ា។

## សំណើប្រជាមតិ 31

វិធានការផ្តើមប្រជាសិទ្ធិគឺត្រូវបានដាក់ស្នើទៅឱ្យប្រជាពលរដ្ឋ នៃរដ្ឋកាលីហ្វ័រញ៉ាដែលបានយល់ស្របគ្នាជាមួយនឹងខចែងនៃវគ្គទី8 មាត្រាទីII នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

វិធានកាផ្តើមប្រជាសិទ្ធិប្រែនិងបន្ថែមផ្នែកខ្លះទៅលើរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ាហើយបន្ថែមផ្នែកខ្លះទៅលើក្រមអប់រំនិងក្រមរដ្ឋាភិបាលដូចនេះខចែងដែលមានរួចមកហើយដែលបានស្នើសុំដើម្បីលុបចោលត្រូវបានបោះពុម្ពឡើងជា~~អក្សរគូសឆូតកាត់~~ និងខចែងថ្មីដែលបានស្នើសុំដើម្បីបន្ថែមត្រូវបានបោះពុម្ពឡើងជា*អក្សរទ្រេត* ដើម្បីចង្អុលប្រាប់ថាវាគឺថ្មី។

## ច្បាប់ដែលស្នើ

ច្បាប់ស្តីពីការអនុវត្តការងារ និងគណនេយ្យភាពរបស់រដ្ឋាភិបាល

វគ្គទី 1. លទ្ធផលរកឃើញ និងសេចក្តីប្រកាសប្រជាជននៃរដ្ឋកាលីហ្វ័រញ៉ាបានរកឃើញ និងប្រកាសថា រដ្ឋាភិបាលត្រូវ ៖

1. មានសេចក្តីទុកចិត្ត។រដ្ឋាភិបាលនៃរដ្ឋកាលីហ្វ័រញ៉ាបានបាត់បង់ទំនុកចិត្តចំពោះពលរដ្ឋរបស់ខ្លួនហើយមិនបានបំពេញតំរូវការរបស់ពលរដ្ឋកាលីហ្វ័រញ៉ានោះទេ។ អ្នកជាប់ពន្ធត្រូវទទួលបានចំណូលខ្ពស់ពីការវិនិយោគរបស់ពួកគេ ហើយសាធារណជនសមនឹងទទួលបាន លទ្ធផលល្អប្រសើរពីសេវារបស់រដ្ឋ។

2. មានគណនេយ្យភាពចំពោះលទ្ធផល។ ក្នុងបំណងស្តារឱ្យមានទំនុកចិត្តឡើងវិញ រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ត្រូវមានគណនេយ្យភាពចំពោះលទ្ធផល។ ប្រជាជនមានសិទ្ធិដឹង ថាតើ ចំណូលពន្ធចំណាយអស់ប៉ុន្មានដុល្លារ និងថាតើ រដ្ឋាភិបាលអនុវត្តការងារបានល្អដល់កម្រិតណា។ ទីភ្នាក់ងាររបស់រដ្ឋ និងរដ្ឋាភិបាលក្នុងមូលដ្ឋាន ត្រូវកំណត់លទ្ធផលដែលអាចវាស់វែងបាន សម្រាប់ចំណាយទាំងអស់ ហើយត្រូវរាយការណ៍ជាទៀងទាត់ និងជាសាធារណៈ អំពីភាពរីកចម្រើននៃលទ្ធផលទាំងនោះ។

3. មានប្រសិទ្ធភាពចំណាយ។ រដ្ឋកាលីហ្វ័រញ៉ា ត្រូវមានភាពវៃឆ្លាត ក្នុងការវិនិយោគធនធានដ៏កម្ររបស់ខ្លួន សំដៅប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចសកល។ អាស្រ័យហេតុនេះ សេវាសាធារណៈសំខាន់ៗត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

4. មានតម្លាភាព។ ប្រការសំខាន់ អាជីវកម្មសារធារណៈត្រូវធ្វើឡើងជាសាធារណៈ។ភាពស្មោះត្រង់និងបើកចំហលើកកម្ពស់និងអភិរក្សសេចក្តីសុចរិតនៃប្រជាធិបតេយ្យ និងទំនាក់ទំនាក់របស់ប្រជាជន និងរដ្ឋាភិបាលរបស់ខ្លួន។

5. ផ្តោតលើលទ្ធផល។ ដើម្បីកែលម្អលទ្ធផល ទីភ្នាក់ងារសាធារណៈ ត្រូវការការយល់ដឹងច្បាស់លាស់ និងមានការចែករំលែកពីគោលបំណងរបស់សាធារណជន។តាមរយៈវិធានការនេះប្រជាជនប្រកាសថាគោលបំណងរបស់រដ្ឋនិងរដ្ឋាភិបាលក្នុងមូលដ្ឋានគឺសំដៅលើកកម្ពស់សេដ្ឋកិច្ចរីកចម្រើនបរិស្ថានមានគុណភាព និងសមធម៌សហគមន៍។ គោលបំណងទាំងនេះ បង្កើតឡើងដើម្បីសម្រេចទិសដៅដូចតទៅ៖ កំណើនចំនួនការងារធ្វើ កែលម្អវិស័យអប់រំ កាត់បន្ថយភាពក្រីក្រ កាត់បន្ថយឧក្រិដ្ឋកម្ម និងកែលម្អវិស័យសុខាភិបាល។

6. មានការសហការ។ ដើម្បីគ្រប់គ្រងប្រាក់កាសបានគ្រប់ជ្រុងជ្រោយ ទីភ្នាក់ងារសាធារណៈ ត្រូវសហការគ្នា ក្នុងបំណងកាត់បន្ថយការិយាធិបតេយ្យ លុបបំបាត់ការងារជាន់គ្នា និងដោះស្រាយជម្លោះ។ ទីភ្នាក់ងារសាធារណៈ ត្រូវផ្ញើសមាហរណកម្មសេវា និងអនុម័តយុទ្ធសាស្ត្រនានាដែលបង្ហាញថាមានប្រសិទ្ធភាព និងអាចផ្លាស់ប្តូរជីវិតរបស់ប្រជាជននៃរដ្ឋកាលីហ្វ័រញ៉ាបាន។

7. កាន់តែជិតស្និទ្ធជាមួយប្រជាជន។ សេវាជាច្រើនរបស់រដ្ឋាភិបាល ត្រូវបានផ្តល់ជូនប្រជាជននៅតាមមូលដ្ឋានបានយ៉ាងល្អបំផុត។ មន្ត្រីសាធារណៈនៅតាមមូលដ្ឋានទាំងនោះដឹងថា សហគមន៍ និងនិវេសនជនបានចូលជួបជាមួយមន្ត្រីជាប់ឆ្នោត។ រដ្ឋាភិបាលក្នុងមូលដ្ឋាន ចាំបាច់ត្រូវរៀបចំកម្មវិធីដែលបំពេញតំរូវការរបស់សហគមន៍ខ្លួន។

8. គាំទ្រដល់ការបង្កើតការងារក្នុងតំបន់។ រដ្ឋកាលីហ្វ័រញ៉ា ផ្សំឡើងពីសេដ្ឋកិច្ចនៅក្នុងតំបន់។ សមាសភាគជាច្រើននៃភាពចាំបាច់ក្នុង វិស័យសេដ្ឋកិច្ចត្រូវបានដោះស្រាយបានល្អបំផុតក្នុងកម្រិតតំបន់។ រដ្ឋកាលីហ្វ័រញ៉ា ត្រូវមានកាតព្វកិច្ចបង្កឱកាសដល់ និងជម្រុញរដ្ឋា ភិបាលក្នុងមូលដ្ឋានឱ្យសហការគ្នាក្នុងតំបន់ ក្នុងបំណងលើកកម្ពស់លទ្ធភាព ដើម្បីទាក់ទាញវិនិយោគទុនសេដ្ឋកិច្ចក្នុងតំបន់សំដៅបង្កើត ការងារដែលទទួលបានបៀវត្សរ៍ខ្ពស់។

9. មានឆន្ទៈក្នុងការស្តាប់។ ការចូលរួមរបស់សាធារណជនមាន សារៈសំខាន់ណាស់ ដើម្បីធានាបាននូវលិទ្ធិប្រជាធិបតេយ្យមួយ ដែលមានភាពរស់រវើក និងមានការឆ្លើយតប និងរដ្ឋាភិបាលមួយដែលភាពរស់រវើក និងមានការឆ្លើយបត។ នៅពេលដែលរដ្ឋាភិបាលស្តាប់មតិ របស់ពួកគេ នោះប្រជាពលរដ្ឋកាន់តែច្រើនឡើង មានឆន្ទៈដើរតួនាទីយ៉ាងសកម្មនៅក្នុងសហគមន៍របស់ពួកគេ និងក្នុងរដ្ឋាភិបាលរបស់ ពួកគេ។

10. ភាពសន្សំសំចៃ និងប្រុងប្រយ័ត្ន។ រដ្ឋ និងរដ្ឋាភិបាលក្នុងមូលដ្ឋានសព្វថ្ងៃនេះ ចំណាយថវិការាប់រយលានដុល្លារ ទៅលើដំណើរការ គម្រោងថវិកា ដោយមិនបានប្រាប់ដល់សាធារណជន ឱ្យដឹងអំពីអ្វី ដែលកំពុងតែសម្រេចបាននោះទេ។ ជាការល្អប្រសើរ ថវិកាដូចគ្នាទាំង នោះអាចប្រើប្រាស់ដើម្បីបង្កើតគម្រោងថវិកា ដែលផ្សារភ្ជាប់ប្រាក់ ដុល្លារ ទៅនឹងទិសដៅនានា និងផ្សារភ្ជាប់ភាពរីកចម្រើនឆ្ពោះទៅរកទិសដៅទាំងនោះ ដែលជាគោលបំណងចម្បងមួយនៃគម្រោងថវិកាសាធារណៈ។

វគ្គទី 2. គោលបំណង និងចេតនា

ក្នុងការអនុម័តវិធានការនេះ ប្រជាពលរដ្ឋក្នុងរដ្ឋកាលីហ្វ័រញ៉ាមានបំណងដូចខាងក្រោម ៖

1. ធ្វើឱ្យប្រសើរឡើងនូវលទ្ធផល និងគណនេយ្យភាពចំពោះ អ្នកជាប់ពន្ធ និងសាធារណជនតាមរយៈការធ្វើឱ្យប្រសើរឡើងនូវ ដំណើរការគម្រោងថវិកាសម្រាប់រដ្ឋ និងរដ្ឋាភិបាលក្នុងមូលដ្ឋានជាមួយនឹងធនធានដែលមានស្រាប់។

2. ធ្វើឱ្យរដ្ឋាភិបាលកាន់តែមានប្រសិទ្ធ ផល ប្រសិទ្ធភាព និងតម្លាភាពថែមទៀតតាមរយៈដំណើរការគម្រោងថវិការបស់រដ្ឋ ដោយ ធ្វើនូវកិច្ចការដូចខាងក្រោម ៖

a. យកចិត្តទុកដាក់ទៅលើសេចក្តីសម្រេចអំពីគម្រោងថវិកាទៅលើកម្មវិធីអ្វីដែលកំពុងតែព្យាយាមសម្រេចឱ្យបាន ហើយថាតើភាព រីកចម្រើនកំពុងត្រូវបានធ្វើឡើងឬយ៉ាងណា។

b. ត្រូវការការបង្កើតគម្រោងថវិកាសម្រាប់រយៈពេលពីរឆ្នាំ ហើយត្រូវត្រួតពិនិត្យឡើងវិញលើគ្រប់កម្មវិធីយ៉ាងតិចបំផុតប្រាំឆ្នាំម្តង ដើម្បីធ្វើឱ្យប្រាកដថាថវិកានោះត្រូវបានចំណាយយ៉ាងត្រឹមត្រូវក្នុងអំឡុងពេលកំណត់។

c. ត្រូវការកម្មវិធីថ្មីសំខាន់ៗ និងការកាត់បន្ថយពន្ធ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ពីប្រភពផ្តល់ថវិកានៅមុនពេលកម្មវិធីទាំងនោះត្រូវបានអនុម័ត។

d. ត្រូវការឱ្យមានច្បាប់ រួមទាំងច្បាប់ថវិកាផងដែរ ដាក់បង្ហាញជាសាធារណៈរយៈពេលបីថ្ងៃ មុនពេលអ្នកធ្វើច្បាប់អាចបោះឆ្នោតសម្រេច។

3. រំកិលរដ្ឋាភិបាលឱ្យខិតកាន់តែជិតប្រជាពលរដ្ឋតាមរយៈការជួយ និងការលើកទឹកចិត្តរដ្ឋាភិបាលក្នុងមូលដ្ឋាន ឱ្យធ្វើការរួមគ្នាដើម្បីសន្សំថវិកា ធ្វើឱ្យលទ្ធផលមានភាពប្រសើរឡើង និងស្តារគណនេយ្យភាពចំពោះសាធារណជន តាមរយៈកិច្ចការដូចខាងក្រោម ៖

a. ផ្តោតសេចក្តីសម្រេចលើគម្រោងថវិកា របស់រដ្ឋាភិបាលក្នុងមូលដ្ឋានទៅលើកម្មវិធីអ្វីដែលកំពុងតែព្យាយាមសម្រេចឱ្យបាន ហើយថាតើភាពរីកចម្រើនកំពុងត្រូវបានធ្វើឡើងឬយ៉ាងណា។

b. ផ្តល់ឱ្យខោនធី ទីក្រុង និងសាលារៀនទាំងឡាយ នូវអំណាចធ្វើការបង្កើតនូវផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ តាមរយៈ ដំណើរការជាសាធារណៈមួយ ដើម្បីឈានឆ្ពោះទៅរកកត្តាអាទិភាព របស់សហគមន៍ដែលពួកគេមិនអាចសម្រេចទៅបានដោយខ្លួនឯង។

c. ផ្តល់ឱ្យរដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលអនុម័តផែនការសកម្មភាពនូវភាពបត់បែន ទាក់ទងនឹងវិធីដែលពួកគេចាយវាយថវិការដ្ឋ ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃកម្មវិធីសាធារណៈ។

d. ដែលអនុម័តផែនការសកម្មភាព នូវសមត្ថភាពធ្វើការកត់សម្គាល់ពីច្បាប់រដ្ឋ ឬបទបញ្ញត្តិនានាដែលរាំងស្ទះដល់ការរីកចម្រើន និងដំណើរការប្រើប្រាស់ច្បាប់ក្នុងមូលដ្ឋានដើម្បីសម្រេចបានតាមលក្ខខណ្ឌតំរូវរបស់រដ្ឋ។

e. លើកទឹកចិត្តរដ្ឋាភិបាលក្នុងមូលដ្ឋាន ឱ្យសហការដើម្បីសម្រេចឱ្យបានកាន់តែមានប្រសិទ្ធភាព នូវទិសដៅដែលបានដាក់ចេញនៅថ្នាក់តំបន់។

f. ផ្តល់ថវិការដ្ឋមួយចំនួន ជារង្វាន់លើកទឹកចិត្តទៅឱ្យរដ្ឋាភិបាលក្នុងមូលដ្ឋាន ដើម្បីបង្កើតផែនការសម្មភាព។

g. តំរូវឱ្យរដ្ឋាភិបាលក្នុងមូលដ្ឋាន រាយការណ៍ពីភាពរីកចម្រើនរបស់ពួកគេ រៀងរាល់មួយឆ្នាំម្តង និងវាយតម្លៃពីកិច្ចខិតខំប្រឹងប្រែង របស់ពួកគេរៀងរាល់បួនឆ្នាំម្តង ដែលជាលក្ខខណ្ឌមួយសម្រាប់ភាពបត់បែនជាបន្ត ដើម្បីស្តារគណនេយ្យភាពរបស់មន្ត្រីជាប់ឆ្នោតក្នុងមូលដ្ឋាន ចំពោះអ្នកបោះឆ្នោត និងអ្នកជាប់ពន្ធក្នុងមូលដ្ឋាន។

4. ដាក់បញ្ចូលប្រជាពលរដ្ឋក្នុងការកំណត់អាទិភាព ការកំណត់ទិសដៅ ការបង្កើតការវាស់វែងពីលទ្ធផល ការបែងចែកធនធានក្នុងគម្រោងថវិកា និងការត្រួតពិនិត្យមើលភាពរីកចម្រើន។

5. អនុវត្តកំណែទម្រង់គម្រោងថវិកា ដោយប្រើប្រាស់ធនធានដែលមានស្រាប់ ដែលទើបត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការគម្រោងថវិការបស់រដ្ឋ និងអង្គភាពរងនយោបាយរបស់ខ្លួន ដោយមិនមានថវិកាបន្ថែមយ៉ាងច្រើន។ ជាងនេះទៅទៀត ត្រូវបង្កើតមូលនិធិមរតកសម្រាប់ការអនុវត្តការងារ និងគណនេយ្យភាព ដោយដកចេញពីមូលដ្ឋានពន្ធ និងប្រាក់ចំណូលដែលមានស្រាប់។ មិនមានបទបញ្ញត្តិណាមួយក្នុងនោះ តំរូវឱ្យបង្កើនពន្ធទាំងឡាយ ឬធ្វើការកែប្រែអត្រាពន្ធ ឬមូលដ្ឋានពន្ធណាមួយឡើយ។

វគ្គទី 3. វគ្គទី 8 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

វគ្គទី 8. (a) នៅក្នុងសម័យប្រជុំទៀងទាត់ មិនមានសេចក្តីព្រាងច្បាប់ណា ក្រៅពីសេចក្តីព្រាងច្បាប់ថវិកាឡើយអាចត្រូវបានលើកមកពិភាក្សា ឬពិចារណាដោយគណៈកម្មាធិការ ឬ ដោយសភាណាមួយរហូតដល់ថ្ងៃទី 31 បន្ទាប់ពីសេចក្តីព្រាងច្បាប់នោះត្រូវបានដាក់ ឱ្យ អនុវត្ត លើកលែងតែសភានោះលុបចោលលក្ខខណ្ឌតំរូវនេះ តាម រយៈការបោះឆ្នោតដោយហៅឈ្មោះដែលបានបញ្ចូលនៅក្នុងទិន្នា នុប្បវត្តិ ដោយមានសំឡេងគាំទ្របីភាគបួននៃសមាជិកដែលចូលរួម។

(b) អង្គនីតិបញ្ញត្តិមិនអាចបង្កើតច្បាប់ណាមួយបានឡើយលើកលែងតែតាមរយៈលក្ខន្តិកៈ ហើយមិនអាចអនុម័តលក្ខន្តិកៈណាមួយ បានឡើយ លើកលែងតែតាមរយៈសេចក្តីព្រាងច្បាប់។មិនមានសេចក្តីព្រាងច្បាប់ណាមួយត្រូវបានអនុម័តឡើយលើកលែងតែសេចក្តីព្រាងច្បាប់នោះត្រូវបានបកស្រាយទៅតាមចំណងជើងក្នុងអំឡុងពេល3ថ្ងៃនៅក្នុងសភានីមួយៗលើកលែងតែសភានោះលុបចោលលក្ខខណ្ឌតំរូវនេះ តាមរយៈ ការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដែលបានបញ្ចូលនៅក្នុងទិន្នា នុប្បវត្តិ ដោយមានសំឡេងគាំទ្រពីរភាគបី នៃសមាជិកដែលចូលរួម។ មិន មានសេចក្តីព្រាងច្បាប់ណាមួយ *ក្រៅពីសេចក្តីព្រាងច្បាប់ដែលមានប្រការ និយាយពីភាពបន្ទាន់ ដែលត្រូវបានអនុម័តនៅក្នុងសម័យប្រជុំពិសេសដែលកោះហៅដោយអភិបាល ដើម្បីដោះស្រាយស្ថានភាពអាសន្នដែលបាន ប្រកាសឡើងដោយអភិបាលទាក់ទងនឹងគ្រោះធម្មជាតិឬការវាយប្រហារភេរវកម្មនោះអាចត្រូវបានអនុម័តឡើយទាល់តែសេចក្តីព្រាងច្បាប់ដែលមាន ការធ្វើវិសោធនកម្មនេះ ត្រូវបានបោះពុម្ពជាអក្សរពុម្ពហើយចែកជូនដល់សមាជិកទាំងឡាយហើយសាធារណជនអាចមានលទ្ធភាពប្រើប្រាស់បាន យ៉ាងហោចណាស់ 3 ថ្ងៃ*។ មិនមានសេចក្តីព្រាងច្បាប់ណាមួយត្រូវបានអនុម័តឡើយ**លុះ**ត្រាតែសមាជិកភាគច្រើនបំផុតនៃសភានីមួយៗបានឯកភាពតាម រយៈការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិដែលបានបញ្ចូលនៅក្នុង ទិន្នានុប្បវត្តិ។

(c) (1) លើកលែងតែមានចែងនៅក្នុងកថាខណ្ឌ (2) និង (3) នៃអនុផ្នែករងនេះ បើមិនដូច្នេះទេ លក្ខន្តិកៈមួយ ដែលបានអនុម័តនៅក្នុងសម័យប្រជុំទៀងទាត់ ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ក្រោយរយៈពេល 90 ថ្ងៃ គិតចាប់ពីថ្ងៃអនុម័តលក្ខន្តិកៈនោះ ហើយលក្ខន្តិកៈមួយ ដែលបានអនុម័តនៅក្នុងសម័យប្រជុំពិសេស ត្រូវចូលជាធរមាននៅថ្ងៃទី 91 បន្ទាប់ពីការលើកពេលនៃសម័យប្រជុំពិសេសដែលបានអនុម័ត សេចក្តីព្រាងច្បាប់នោះ។

(2) លក្ខន្តិកៈមួយ ក្រៅពីលក្ខន្តិកៈដែលបង្កើត ឬកែប្រែព្រំដែននីតិបញ្ញត្តិ សហសភា ឬខោនធីបោះឆ្នោតដទៃទៀត ដែលត្រូវបានអនុម័តដោយសេចក្តី

ព្រាងច្បាប់មួយ ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិ នៅពេល ឬនៅក្រោយកាលបរិច្ឆេទដែលអង្គនីតិបញ្ញត្តិលើកពេលដើម្បីឈប់សម្រាករួមគ្នា ហើយចាប់ផ្ដើមធ្វើការងារឡើងវិញនៅក្នុងឆ្នាំប្រតិទិនទីពីរ ក្នុងរយៈពេលពីរឆ្នាំនៃសម័យប្រជុំនីតិបញ្ញត្តិ ហើយស្ថិតក្នុងដៃរបស់អភិបាលក្រោយកាលបរិច្ឆេទនោះ ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ក្រោយពីថ្ងៃអនុម័តលក្ខន្តិកៈនោះ លើកលែងតែនៅមុនថ្ងៃទី 1 ខែមករានោះ មានបណ្ដឹងប្រជាមតិមួយដែលធ្វើឱ្យប៉ះពាល់ដល់លក្ខន្តិកៈនោះ ត្រូវបានដាក់ជូនទៅអគ្គមេធាវីស្របតាមផ្នែករង (d) នៃវគ្គទី 10 នៃមាត្រា II ក្នុងករណីបែបនេះ លក្ខន្តិកៈនោះ ត្រូវចូលជាធរមាននៅថ្ងៃទី ៩១ ក្រោយពីអនុម័ត ប្រសិនបើមិនមានបណ្ដឹងទាមទារណាមួយត្រូវបានដាក់ជូនទៅរដ្ឋលេខាធិការស្របតាមអនុផ្នែក (b) នៃវគ្គទី 9 នៃមាត្រា II ទេនោះ។

(3) លក្ខន្តិកៈដែលកោះហៅការបោះឆ្នោត លក្ខន្តិកៈដែលចែងអំពីការហូតពន្ធ ឬ ការផ្ដល់វិភាជន៍សម្រាប់ការចំណាយចរន្តធម្មតារបស់រដ្ឋ និងលក្ខន្តិកៈស្ដីពីភាពបន្ទាន់ ត្រូវចូលជាធរមានភ្លាមៗ បន្ទាប់ពីធ្វើការអនុម័ត។

(d) លក្ខន្តិកៈស្ដីពីភាពបន្ទាន់ គឺជាលក្ខន្តិកៈទាំងឡាយណា ដែលចាំបាច់សម្រាប់ធ្វើការការពារភ្លាមៗនូវសន្តិភាព សុខភាព ឬ សុវត្ថិភាពសាធារណៈ។ សេចក្ដីបរិយាយអំពីអង្គហេតុនានាដែលបង្កើតបានជាភាពចាំបាច់ត្រូវចែងនៅក្នុងផ្នែកមួយនៃសេចក្ដីព្រាងច្បាប់នោះ។ នៅក្នុងសភានីមួយៗ ផ្នែក និងសេចក្ដីព្រាងច្បាប់ ត្រូវអនុម័តដាច់ដោយឡែកពីគ្នា តាមរយៈការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដែលបានបញ្ចូលនៅក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រពីរភាគបី នៃសមាជិកភាពដែលចូលរួម។ លក្ខន្តិកៈស្ដីពីភាពបន្ទាន់មិនអាចបង្កើត ឬរំលាយការិយាល័យណាមួយ ឬកែប្រែបៀវត្សរ៍ អាណត្តិ ឬ ភារកិច្ចរបស់ការិយាល័យណាមួយ ឬ ផ្ដល់សិទ្ធិពិសេស ឬឯកសិទ្ធិពិសេសណាមួយ ឬបង្កើតសិទ្ធិប្រទាន ឬ ផលប្រយោជន៍ណាមួយបានឡើយ។

វគ្គទី 4. វគ្គទី 9.5 ត្រូវបានបន្ថែមទៅលើមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ដូចខាងក្រោម ៖

វគ្គទី 9.5. *សេចក្ដីព្រាងច្បាប់មួយដែលបានអនុម័តដោយអង្គនីតិបញ្ញត្តិដែល (1) បង្កើតកម្មវិធីរដ្ឋថ្មីមួយ រួមទាំងកម្មវិធីក្នុងមូលដ្ឋានផ្ដល់អាណត្តិដោយរដ្ឋ ដែលបានរៀបរាប់នៅក្នុងវគ្គទី 6 នៃមាត្រា XIIIB ឬទីភ្នាក់ងារថ្មីមួយ ឬពង្រីកវិសាលភាពនៃកម្មវិធី ឬទីភ្នាក់ងារដែលមានស្រាប់របស់រដ្ឋ ប្រសិនបើបានផ្ដល់មូលនិធិ ដែលផលប៉ះពាល់គឺការកើនឡើងសរុបនូវ ខ្ទង់ចំណាយរបស់រដ្ឋលើសម្ភៃប្រាំលានដុល្លារ (25.000.000 ដុល្លារ) នៅក្នុងឆ្នាំសារពើពន្ធនោះ ឬនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ ឬ (2) កាត់បន្ថយនូវពន្ធរបស់រដ្ឋ ឬប្រភពចំណូលផ្សេងទៀតរបស់រដ្ឋ ដែលផលប៉ះពាល់គឺការថយចុះសរុបនូវ ចំណូលរបស់រដ្ឋលើសម្ភៃប្រាំលានដុល្លារ (25.000.000 ដុល្លារ) នៅក្នុងឆ្នាំសារពើពន្ធនោះ ឬនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ណាមួយនោះ ថវិកាត្រូវស្នើការទូទាត់កម្មវិធីរដ្ឋនូវការកាត់បន្ថយ ឬចំណូលបន្ថែម ឬការរួមបញ្ចូលគ្នានូវចំនួនប្រាក់ដែលស្មើ ឬលើសកំណើនសរុបនៃខ្ទង់ចំណាយរបស់រដ្ឋ ឬការថយចុះសរុបនៃចំណូលរបស់រដ្ឋ។ កម្រិតចាប់ប្រែប្រួលចំនួនម្ភៃប្រាំលានដុល្លារ (25.000.000 ដុល្លារ) នៅក្នុងផ្នែករងនេះ ត្រូវមានការលៃតម្រូវប្រចាំឆ្នាំដើម្បីឱ្យត្រូវនឹងអតិផរណាដែលស្របតាមសន្ទស្សន៍តម្លៃអ្នកប្រើប្រាស់នៅកាលីហ្វ័រញ៉ា។*

វគ្គទី 5. វគ្គទី 10 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោម ៖

វគ្គទី 10. (a) សេចក្ដីព្រាងច្បាប់នីមួយៗ ដែលបានអនុម័តដោយអង្គនីតិបញ្ញត្តិ ត្រូវដាក់ជូនអភិបាលពិនិត្យ។ សេចក្ដីព្រាងច្បាប់នេះនឹងក្លាយទៅជាលក្ខន្តិកៈមួយ ប្រសិនបើវាត្រូវបានចុះហត្ថលេខាដោយអភិបាល។ អភិបាលអាចនឹងជំទាស់ទៅនឹងសេចក្ដីព្រាងច្បាប់នេះ ដោយធ្វើការបញ្ជូនវារួមជាមួយនឹងការជំទាស់នានាទៅឱ្យសភាដើមវិញ ដោយត្រូវកត់ត្រាការជំទាស់ទាំងឡាយនោះ ទៅក្នុងទិន្នានុប្បវត្តិ ហើយបន្តធ្វើការពិចារណាវាឡើងវិញ។ ប្រសិនបើសភានីមួយៗបន្ទាប់មក ធ្វើការអនុម័តសេចក្ដីព្រាងច្បាប់នោះ តាមរយៈការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដោយបានបញ្ចូលក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រពីរភាគបី នៃសមាជិកភាពដែលចូលរួម សេចក្ដីព្រាងច្បាប់នេះក្លាយទៅជាលក្ខន្តិកៈ។

(b) (1) សេចក្ដីព្រាងច្បាប់ណាមួយ ក្រៅពីសេចក្ដីព្រាងច្បាប់ដែលនឹងបង្កើត ឬ កែប្រែព្រំដែននីតិបញ្ញត្តិ សភា ឬខោនធីបោះឆ្នោតដទៃទៀត ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិនៅពេល ឬ នៅក្រោយកាលបរិច្ឆេទដែលអង្គនីតិបញ្ញត្តិលើកពេល ដើម្បីឈប់សម្រាករួមគ្នា ហើយចាប់ផ្ដើមធ្វើការងារឡើងវិញ នៅក្នុងឆ្នាំប្រតិទិនទីពីរ ក្នុងរយៈពេលពីរឆ្នាំនៃសម័យប្រជុំនីតិបញ្ញត្តិ ហើយស្ថិតក្នុងដៃរបស់អភិបាល បន្ទាប់ពីកាលបរិច្ឆេទនោះ ហើយមិនត្រូវបានបញ្ជូនត្រឡប់មកវិញក្នុងអំឡុងពេល 30 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនោះ នឹងក្លាយទៅជាលក្ខន្តិកៈ។

(2) *សេចក្ដីព្រាងច្បាប់ ណាមួយ ដែលបានអនុម័តដោយអង្គនីតិបញ្ញត្តិនៅមុនថ្ងៃទី 30 ខែមិថុនានៃឆ្នាំប្រតិទិនទីពីរ ក្នុងរយៈពេលពីរឆ្នាំនៃសម័យប្រជុំនីតិបញ្ញត្តិ និងស្ថិតក្រោមការពិចារណារបស់អភិបាលនៅពេល ឬ បន្ទាប់ពីថ្ងៃទី 30 ខែមិថុនា ដោយមិនត្រូវបានបញ្ជូនត្រឡប់មកវិញនៅថ្ងៃ ឬ មុនថ្ងៃទី ៣១ ខែកក្កដាក្នុងឆ្នាំនោះ នឹងក្លាយទៅជាលក្ខន្តិកៈមួយ។ ជាងនេះទៅទៀត* សេចក្ដីព្រាងច្បាប់*ណាមួយ* ដែលអនុម័តដោយអង្គនីតិបញ្ញត្តិនៅថ្ងៃ ឬ នៅមុនថ្ងៃទី 1 ខែកញ្ញានៃឆ្នាំប្រតិទិនទីពីរ ក្នុងអំឡុងពេលពីរឆ្នាំនៃសម័យប្រជុំនីតិបញ្ញត្តិ និងស្ថិតក្នុងដៃរបស់អភិបាលនៅថ្ងៃ ឬ នៅមុនថ្ងៃទី 1 ខែកញ្ញា ដោយមិនត្រូវបានបញ្ជូនត្រឡប់មកវិញនៅថ្ងៃ ឬ នៅមុខថ្ងៃទី 30 ខែកញ្ញាក្នុងឆ្នាំនោះ នឹងក្លាយទៅជាលក្ខន្តិកៈ។

(3) សេចក្ដីព្រាងច្បាប់ណាមួយផ្សេង ដែលត្រូវបានដាក់ជូនទៅអភិបាលពិនិត្យ ហើយមិនត្រូវបានបញ្ជូនត្រឡប់មកវិញនៅក្នុងអំឡុងពេល 12 ថ្ងៃនឹងក្លាយទៅជាលក្ខន្តិកៈ។

(4) ប្រសិនបើអង្គនីតិបញ្ញត្តិ តាមរយៈការលើកពេលសម័យប្រជុំពិសេស រារាំងការបញ្ជូនត្រឡប់មកវិញនូវសេចក្ដីព្រាងច្បាប់មួយ ដែលមានសារ ជំទាស់ សេចក្ដីព្រាងច្បាប់នោះក្លាយទៅជាលក្ខន្តិកៈមួយ លើកលែងតែ អភិបាលជំទាស់ទៅនឹងសេចក្ដីព្រាងច្បាប់នោះ នៅក្នុងអំឡុងពេល 12 ថ្ងៃ បន្ទាប់ពីវាត្រូវបានដាក់ជូនពិនិត្យដោយតម្កល់សេចក្ដីព្រាងច្បាប់នោះ និងសារជំទាស់ទុកនៅក្នុងការិយាល័យរបស់រដ្ឋលេខាធិការ។

(5) ប្រសិនបើថ្ងៃទី 12 នៃអំឡុងពេលដែលអភិបាល ត្រូវបានតម្រូវឱ្យអនុវត្តសកម្មភាពស្របតាមកថាខណ្ឌ (3) ឬ (4) នៃផ្នែករងនេះ ត្រូវចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាក អំឡុងពេលនោះ ត្រូវបានបន្តដល់ថ្ងៃបន្ទាប់ ដែលមិនមែនជាថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាក។

(c) (1) សេចក្ដីព្រាងច្បាប់ណាមួយ ដែលបានដាក់ឱ្យធ្វើការពិភាក្សានៅក្នុងអំឡុងឆ្នាំទីមួយក្នុងរយៈពេលពីរឆ្នាំនៃសម័យប្រជុំនីតិបញ្ញត្តិ ហើយមិនត្រូវបានអនុម័តដោយសភាដើម នៅមុនថ្ងៃទី 31 ខែមករានៃឆ្នាំប្រតិទិនទីពីរ ក្នុងរយៈពេលពីរឆ្នាំ មិនត្រូវបានយកមកពិភាក្សាដោយសភាជាបន្តទៀតឡើយ។ មិនមានសេចក្ដីព្រាងច្បាប់ណាមួយ ត្រូវបានអនុម័តនៅថ្ងៃ ឬ នៅក្រោយ ~~ថ្ងៃទី 1 ខែកញ្ញា នៃឆ្នាំដែលមានលេខគូរ~~ *ថ្ងៃទី 30 ខែមិថុនា ក្នុងឆ្នាំទីពីរនៃរយៈពេលពីរឆ្នាំ* នោះឡើយ លើកលែងតែ ~~លក្ខន្តិកៈកោះហៅការបោះឆ្នោត លក្ខន្តិកៈចែងអំពីការហូតពន្ធ ឬការផ្ដល់វិភាជន៍ សម្រាប់ចំណាយជាធម្មតាក្នុងពេលបច្ចុប្បន្នរបស់រដ្ឋ និងលក្ខន្តិកៈស្ដីពីភាពបន្ទាន់~~*សេចក្ដីព្រាងច្បាប់ទាំងឡាយ ដែលចូលជាធរមានភ្លាមៗ* និងសេចក្ដីព្រាងច្បាប់ដែលត្រូវបានអនុម័ត បន្ទាប់ពីត្រូវបានជំទាស់ដោយអភិបាល។

*(2) មិនមានសេចក្ដីព្រាងច្បាប់ណាមួយ ត្រូវបានដាក់ឱ្យពិភាក្សា ឬ ពិចារណានៅក្នុងឆ្នាំទីពីរនៃរយៈពេលពីរឆ្នាំ ដែលមានលក្ខណៈដូចគ្នាខ្លាំង និងមានអានុភាពដូចគ្នាទៅនឹងកំណែថ្មីនៃវិធានការមួយ ដែលត្រូវបានដាក់ឱ្យពិភាក្សា ឬត្រូវបានកែប្រែដោយមិនបានឆ្លងសភាដើមនៅមុនថ្ងៃទី 31 ខែមករានៃឆ្នាំប្រតិទិនទីពីរក្នុងរយៈពេលពីរឆ្នាំ តាមការតម្រូវនៅក្នុងកថាខណ្ឌ (1) នោះឡើយ។*

(d) (1) អង្គនីតិបញ្ញត្តិ មិនអាចដាក់សេចក្ដីព្រាងច្បាប់ណាមួយ ជូនអភិបាលពិនិត្យបានឡើយបន្ទាប់ពីថ្ងៃទី 15 ខែវិច្ឆិកានៃឆ្នាំ ប្រតិទិន ទីពីរ ក្នុងរយៈពេលពីរឆ្នាំនៃសម័យប្រជុំនីតិបញ្ញត្តិ។ *នៅថ្ងៃចន្ទដំបូង បន្ទាប់ពីថ្ងៃទី 4 ខែកក្កដានៃឆ្នាំប្រតិទិនទីពីរក្នុងរយៈពេលពីរឆ្នាំ អង្គ នីតិបញ្ញត្តិត្រូវជួបជុំគ្នាដើម្បីរៀបចំការពិនិត្យ និងការពិនិត្យឡើងវិញលើកម្មវិធីការងារ ដែលជាផ្នែកមួយនៃសម័យប្រជុំទៀងទាត់របស់ខ្លួន។ អង្គនីតិបញ្ញត្តិ ត្រូវបង្កើតដំណើរការត្រួតពិនិត្យ សម្រាប់វាយ តម្លៃ និងពង្រឹងដំណើរការកម្មវិធីនានា ដែលទទួល*

ខុសត្រូវដោយរដ្ឋ និងទីភ្នាក់ងារក្នុងមូលដ្ឋាន ដែលអនុវត្តកម្មវិធីដែលផ្តល់មូលនិធិដោយរដ្ឋក្នុងនាមរដ្ឋ ដោយផ្អែកលើបទដ្ឋានអនុវត្តការងារដែលមានចែងនៅក្នុងលក្ខន្តិកៈ និងនៅក្នុងច្បាប់ថវិការយៈពេលពីរឆ្នាំ។ ក្នុង អំឡុងពេលមួយឆ្នាំនៃថ្ងៃប្រសិទ្ធភាពនៃបទបញ្ញត្តិនេះ កាលវិភាគត្រួតពិនិត្យឡើងវិញ ត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីរដ្ឋទាំងអស់ មិនថាវាត្រូវបានគ្រប់គ្រងដោយរដ្ឋ ឬ ដោយភ្នាក់ងារក្នុងមូលដ្ឋាន ដែលអនុវត្តកម្មវិធីដែលផ្តល់មូលនិធិដោយរដ្ឋ ក្នុងនាមរដ្ឋនោះទេ។ កាលវិភាគនេះ ត្រូវកំណត់ដំណាក់កាលនៃការត្រួតពិនិត្យឡើងវិញ ទៅលើកម្មវិធីដែលស្រដៀងគ្នា ដើម្បីឱ្យទំនាក់ទំនងនានាក្នុងចំណោមគោលបំណងរបស់កម្មវិធីអាចកំណត់ និងពិនិត្យឡើងវិញបាន។ ដំណើរការត្រួតពិនិត្យឡើងវិញ ត្រូវបង្កើតឱ្យមានជាអនុសាសន៍ផ្សេងៗ ក្នុងទម្រង់ជាសំណើច្បាប់ ដែលកែលម្អ និងបញ្ចប់កម្មវិធី។ កម្មវិធីនីមួយៗ ត្រូវធ្វើការត្រួតពិនិត្យឡើងវិញយ៉ាងតិចបំផុត 5 ឆ្នាំម្តង។

(2) ដំណើរការដែលបង្កើតឡើង ដើម្បីពិនិត្យមើលកម្មវិធីស្ថិតក្រោមកថាខណ្ឌ (1) ក៏ត្រូវបញ្ចូលផងដែរ នូវការត្រួតពិនិត្យឡើងវិញ ទៅ លើផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ ដែលត្រូវបានអនុម័តស្របតាមមាត្រា XIA ក្នុងគោលបំណងកំណត់ថាតើលក្ខន្តិកៈ ឬបទបញ្ញត្តិទាំងឡាយ ដែលត្រូវបានកំណត់ដោយទីភ្នាក់ងាររដ្ឋាភិបាលក្នុងមូលដ្ឋានដែលចូលរួមថា ជាឧបសគ្គរបស់រដ្ឋ ក្នុងការធ្វើឱ្យមានលទ្ធផលល្អនោះ គួរ ឬមិនគួរធ្វើវិសោធនកម្ម ឬលុបចោលតាមការស្នើសុំរបស់ទីភ្នាក់ងាររដ្ឋាភិបាលក្នុងមូលដ្ឋានដែលចូលរួម ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញ ដែលមានបទពិសោធន៍យ៉ាងតិចបំផុត 3 ឆ្នាំ ជាមួយនឹងផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍។ ការត្រួត ពិ និត្យ ឡើងវិញគួរប៉ាន់ប្រមាណថា តើ ផែនការសកម្មភាពនោះ បានធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា និងប្រសិទ្ធភាពសេវានៅគ្រប់ផ្នែកក្នុងសហគមន៍ដែលបានកំណត់នៅក្នុងផែនការដែរឬទេ។

(e) អភិបាល អាចកាត់បន្ថយ ឬលុបចំណុចមួយ ឬច្រើននៃការផ្តល់វិភាជន៍ ខណៈពេលអនុម័តផ្នែកផ្សេងៗទៀតនៃសេចក្តីព្រាង ច្បាប់មួយ។ អភិបាល ត្រូវបន្ថែមទៅលើសេចក្តីព្រាងច្បាប់នោះនូវសេចក្តីបរិយាយ អំពីចំណុចដែលបានកាត់បន្ថយ ឬលុបចោល អម ទៅដោយហេតុផលផ្សេងៗសម្រាប់ចាត់វិធានការ។ ចំណុចដែលបានកាត់បន្ថយ ឬលុបចោលនោះ ត្រូវធ្វើការពិចារណាដាច់ដោយឡែកពីគ្នា ហើយអាចនឹងត្រូវបានអនុម័ត ទៅតាមការជំទាស់របស់អភិបាល ក្នុងលក្ខណៈដូចគ្នាទៅនឹងសេចក្តីព្រាងច្បាប់ទាំងឡាយដែរ។

(f) (1) បន្ទាប់ពីការអនុម័តសេចក្តីព្រាងច្បាប់ថវិកា សម្រាប់ឆ្នាំសារពើពន្ធ 2004-05 ឬ ឆ្នាំសារពើពន្ធបន្តបន្ទាប់ណាមួយ ប្រសិន បើ អភិបាល កំណត់ថា សម្រាប់ឆ្នាំសារពើពន្ធនោះ ប្រាក់ចំណូលទូទៅរបស់រដ្ឋនឹងធ្លាក់ចុះខ្លាំង ស្ថិតក្រោមការប៉ាន់ស្មានអំពីប្រាក់ចំណូលទូទៅរបស់រដ្ឋ ដែលសេចក្តីព្រាងច្បាប់ថវិកា ដែលបានអនុម័តសម្រាប់ឆ្នាំសារពើពន្ធនោះ បានពឹងផ្អែកទៅលើ ឬ ខ្ទង់ចំណាយថវិកាទូទៅរបស់រដ្ឋ នឹងកើនឡើងខ្ពស់លើសពីការប៉ាន់ស្មាន អំពីប្រាក់ចំណូលទូទៅរបស់រដ្ឋ ឬ ទាំងពីរនេះ អភិបាលអាចចេញសេចក្តីប្រកាស អំពីភាពអាសន្នផ្នែកសារពើពន្ធ ហើយបន្ទាប់មក ត្រូវកោះហៅអង្គនីតិបញ្ញត្តិឱ្យមកជួបជុំគ្នាក្នុងសម័យប្រជុំពិសេស ដើម្បីដោះស្រាយបញ្ហានេះ។ សេចក្តីប្រកាសនេះ ត្រូវកំណត់ច្បាស់ពីលក្ខណៈនៃភាពអាសន្នផ្នែកសារពើពន្ធ ហើយអភិបាលត្រូវដាក់សេចក្តីប្រកាសនេះ ជូនអង្គនីតិបញ្ញត្តិ អមទៅដោយសំណើច្បាប់ ដើម្បីដោះស្រាយភាពអាសន្នផ្នែកសារពើពន្ធនោះ។ ជាការឆ្លើយតបទៅនឹងសេចក្តីប្រកាស របស់អភិបាល អង្គនីតិបញ្ញត្តិ ត្រូវដាក់សេចក្តីព្រាងច្បាប់មួយ ឬច្រើនជូនអភិបាល ដើម្បីដោះស្រាយភាពអាសន្នផ្នែកសារពើពន្ធនោះ។

(2) ប្រសិនបើអង្គនីតិបញ្ញត្តិមិនបានអនុម័ត និងបញ្ជូនទៅឱ្យអភិបាលនូវសេចក្តីព្រាងច្បាប់មួយ ឬ ច្រើន ដើម្បីដោះស្រាយភាពអាសន្នផ្នែកសារពើពន្ធ នៅមុនថ្ងៃទី 45 បន្ទាប់ពីការចេញសេចក្តីប្រកាសទេនោះ អង្គនីតិបញ្ញត្តិមិនត្រូវពិភាក្សាលើសេចក្តីព្រាងច្បាប់ផ្សេងទៀត ហើយមិនត្រូវលើកពេលសម្រាប់ការឈប់សម្រាករួមគ្នាឡើយ ទាល់តែ សេចក្តីព្រាងច្បាប់នោះ ឬទាំងនោះត្រូវបានអនុម័ត និងបញ្ជូនទៅឱ្យអភិបាលសិន។

(3) សេចក្តីព្រាងច្បាប់ ដែលដោះស្រាយភាពអាសន្នផ្នែកសារពើពន្ធ ដែលត្រូវបានប្រកាសស្រមតាមផ្នែកនេះ ត្រូវបញ្ចូលការបរិយាយ មួយ ទាក់ទងនឹងអានុភាពនោះផងដែរ។ សម្រាប់គោលបំណងនៃកថាខណ្ឌ(2) និង (4) ការដាក់បញ្ចូលសេចក្តីបរិយាយនេះ ត្រូវបានចាត់ទុកថាមានន័យជារួមថា សេចក្តីព្រាងច្បាប់នេះ បានដោះ ស្រាយភាពអាសន្នផ្នែកសារពើពន្ធ។ សេចក្តីព្រាងច្បាប់ដែលដោះស្រាយភាពអាសន្នផ្នែកសារពើពន្ធ ដែលត្រូវបានប្រកាសស្របតាម ផ្នែកនេះ ដែលមានបញ្ចូលការបរិយាយទាក់ទងនឹងអានុភាពនោះ ហើយត្រូវបានអនុម័ត និងបញ្ជូនទៅអភិបាលនៅមុនថ្ងៃទី 45 បន្ទាប់ពីការចេញសេចក្តីប្រកាសអំពីភាពអាសន្នផ្នែកសារពើពន្ធ ត្រូវមានសុពលភាពភ្លាមៗបន្ទាប់ពីអនុម័តរួច។

(4) (A) ប្រសិនបើអង្គនីតិបញ្ញត្តិ មិនបានអនុម័ត និងបញ្ជូនទៅអភិបាលនូវសេចក្តីព្រាងច្បាប់មួយ ឬច្រើន ដើម្បីដោះស្រាយភាពអាសន្នផ្នែកសារពើពន្ធ នៅមុនថ្ងៃទី 45 បន្ទាប់ពីការចេញសេចក្តីប្រកាសអំពីភាពអាសន្នផ្នែកសារពើពន្ធទេនោះ អភិបាល តាមរយៈបទបញ្ជាប្រតិបត្តិ អាចកាត់បន្ថយ ឬលុបចោលការផ្តល់វិភាជន៍ថវិកាទូទៅរបស់រដ្ឋ សម្រាប់ឆ្នាំសារពើពន្ធនោះដល់កម្រិតមួយដែលការផ្តល់វិភាជន៍ថវិកានេះ មិនត្រូវបានតំរូវដោយរដ្ឋធម្មនុញ្ញនេះ ឬដោយច្បាប់សហព័ន្ធ។ បរិមាណសរុបនៃការផ្តល់វិភាជន៍ដែលបានកាត់បន្ថយ ឬលុបចោលដោយអភិបាល ត្រូវបានកំណត់ក្នុងបរិមាណមួយ ដែលចាំបាច់សម្រាប់ធ្វើឱ្យខ្ទង់ចំណាយទូទៅរបស់រដ្ឋ សម្រាប់ឆ្នាំសារពើពន្ធដែលមានបញ្ហានោះ មិនមានកម្រិតលើសពីការប៉ាន់ស្មានចុងក្រោយបង្អស់ អំពីប្រាក់ចំណូលទូទៅរបស់រដ្ឋ ដោយធ្វើឡើងស្របទៅតាមកថាខណ្ឌ (1)។

(B) ប្រសិនបើអង្គនីតិបញ្ញត្តិ កំពុងស្ថិតក្នុងសម័យប្រជុំនោះ ក្នុងរយៈពេល 20 ថ្ងៃ បន្ទាប់ពីអភិបាលបានចេញដីកាអនុវត្តស្របតាមអនុកថាខណ្ឌ (A) អាចមានជ័យជំនះលើផ្នែកទាំងអស់ ឬផ្នែកខ្លះនៃដីកាអនុវត្តដោយការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដែលបានបញ្ចូលទៅក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រពីរភាគបីនៃសមាជិកសភាម្នាក់ៗដែលចូលរួម។ ប្រសិនបើអង្គនីតិបញ្ញត្តិមិនស្ថិតក្នុងសម័យប្រជុំ នៅពេលអភិបាលចេញដីកាអនុវត្តទេនោះ អង្គនីតិបញ្ញត្តិត្រូវមានរយៈពេល 30 ថ្ងៃក្នុងការកោះហៅមកប្រជុំម្តងទៀត និងមានជ័យជំនះលើផ្នែកទាំងអស់ ឬផ្នែកខ្លះនៃដីកាអនុវត្តតាមរយៈសេចក្តីសម្រេច តាមរយៈការបោះឆ្នោតដែលបានបញ្ជាក់ខាងលើ។ ដីកាអនុវត្តមួយ ឬផ្នែកនៃដីកានេះ ដែលមិនត្រូវបានផ្តល់ជ័យជំនះដោយអង្គនីតិបញ្ញត្តិ ត្រូវចូលជាធរមានបន្ទាប់ពីរយៈពេលមានជ័យជំនះលើដីកាអនុវត្តបានផុតកំណត់។ បន្ទាប់ពីថ្ងៃទី 45 ក្រោយពេលចេញសេចក្តីប្រកាសអំពីភាពអាសន្ននៃសារពើពន្ធ ការហាមឃាត់ដែលមានចែងនៅក្នុងកថាខណ្ឌ (2) ត្រូវឈប់អនុវត្តនៅពេល (i) ដីកាអនុវត្តមួយ ឬច្រើនត្រូវបានចេញស្របតាមកថាខណ្ឌនេះបានចូលជាធរមាន ឬ (ii) អង្គនីតិបញ្ញត្តិបានអនុម័ត និងបានផ្ញើទៅកាន់អភិបាលនូវសេចក្តីព្រាងច្បាប់មួយ ឬច្រើនដើម្បីដោះស្រាយភាពអាសន្ននៃសារពើពន្ធ។

(C) សេចក្តីព្រាងច្បាប់សម្រាប់ស្តារសមតុល្យនៃថវិកា ស្របតាមអនុកថាខណ្ឌ (B) អាចអនុម័តបាននៅក្នុងសភានីមួយៗ តាមរយៈការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដែលបានបញ្ចូលនៅក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រភាគច្រើននៃសមាជិកដែលចូលរួម ដើម្បីចូលជាធរមានភ្លាមៗក្រោយពីចុះហត្ថលេខាដោយអភិបាល ឬក្រោយពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងនីតិកម្ម ឱ្យតែសេចក្តីព្រាងច្បាប់ណាមួយដែលដាក់ឱ្យបង់ពន្ធថ្មី ឬធ្វើឱ្យកើនឡើងនូវពន្ធដែលមានស្រាប់ ត្រូវតែអនុម័តដោយសំឡេងពីរភាគបីនៃសមាជិកទាំងឡាយ របស់សភានីមួយៗនៃអង្គនីតិបញ្ញត្តិ។

វគ្គទី 6. វគ្គទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ត្រូវបានធ្វើវិសោធនកម្ម ត្រូវបកស្រាយថា៖

វគ្គទី 12. (a) (1) ក្នុងរយៈពេល 10 ថ្ងៃនៃឆ្នាំប្រតិទិនដែលមានលេខសេសនីមួយៗ អភិបាលត្រូវដាក់ជូនអង្គនីតិបញ្ញត្តិ ជាមួយនឹងសារពន្យល់បកស្រាយនូវថវិកាសម្រាប់ការធានាឆ្នាំសារពើពន្ធរយៈពេលពីរឆ្នាំ ដែលមានរបាយការណ៍ដែលបានរាយមុខ សម្រាប់ចំណាយរបស់រដ្ឋដែលបានផ្តល់អនុសាសន៍ និងធនធាន ~~ចំណុល~~រដ្ឋសរុបដែលបានប៉ាន់ស្មាន ដែលអាចប្រើប្រាស់បាន ដើម្បីឆ្លើយតបទៅនឹងចំណាយទាំងនោះ។ របាយការណ៍ដែលបានរាយមុខអំពីធនធានរដ្ឋសរុបដែលបានប៉ាន់ស្មាន ដែលអាចប្រើប្រាស់បាន ដើម្បីឆ្លើយតបទៅនឹងចំណាយដែលត្រូវបានផ្តល់អនុសាសន៍

ដែលបានដាក់ជូនរួចស្របតាមផ្នែករងនេះ ត្រូវកំណត់អំពីចំនួនប្រាក់ (ប្រសិនបើមាន) នៃធនធនទាំងនោះ ដែលបានប្រមើលមើលជាធនធានតែមួយលើក។ ថវិការយៈពេលពីរឆ្នាំ ដែលត្រូវបញ្ចូលនូវឆ្នាំថវិកា និងថវិកាសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ ត្រូវមានការស្គាល់ជារួមថាជាថវិកាពីរឆ្នាំម្តង។ ក្នុងរយៈពេល 10 ថ្ងៃនៃឆ្នាំប្រតិទិនដែលមានលេខគូនីមួយៗ អភិបាលអាចដាក់ជូនថវិកាបំពេញបន្ថែម ដើម្បីធ្វើវិសោធនកម្ម ឬបន្ថែមថវិការយៈពេលពីរឆ្នាំដែលបានអនុម័តរួច។

(b) ដើម្បីកែលម្អការអនុវត្តការងារ និងគណនេយ្យភាព ថវិការយៈពេលពីរឆ្នាំ ត្រូវមានសមាសភាពទាំងអស់ដូចតទៅ៖

(1) ការប៉ាន់ស្មានអំពីធនធានសរុប ដែលអាចប្រើប្រាស់បានសម្រាប់ចំណាយដែលបានផ្តល់អនុសាសន៍សម្រាប់ឆ្នាំថវិកានិងឆ្នាំសារពើពន្ធបន្ទាប់។

(2) ការប៉ាន់ទុកជាមុនអំពីចំណាយ និងចំណូលដែលបានប្រមើលទុកសម្រាប់ឆ្នាំសារពើពន្ធទាំងបី បន្ទាប់ពីឆ្នាំសារពើពន្ធបន្ទាប់ពីឆ្នាំថវិកា។

(3) របាយការណ៍អំពីរបៀបដែលថវិកា នឹងលើកកម្ពស់គោលបំណងនៃការសម្រេចបាននូវសេដ្ឋកិច្ចរីកចម្រើន បរិស្ថានមានគុណភាព និងសមធម៌សហគមន៍ តាមរយៈការធ្វើការដើម្បីសម្រេចឱ្យបានយ៉ាងហោចណាស់ទិសដៅដូចតទៅ៖ ការបង្កើនការងារ ការកែលម្អការអប់រំ ការកាត់បន្ថយភាពក្រីក្រ ការកាត់បន្ថយឧក្រិដ្ឋកម្ម និងការកែលម្អផ្នែកសុខាភិបាល។

(4) ការបរិយាយអំពីការវាស់វែងលទ្ធផល ដែលនឹងត្រូវយកទៅប្រើក្នុងការវាយតម្លៃភាពរីកចម្រើន និងរាយការណ៍លទ្ធផលជូនសាធារណជន និងបទដ្ឋាននៃការអនុវត្តការងារសម្រាប់ទីភ្នាក់ងារនិងកម្មវិធីទាំងឡាយរបស់រដ្ឋ។

(5) របាយការណ៍អំពីការវាស់វែងលទ្ធផល សម្រាប់ចំណាយចម្បងៗនីមួយៗរបស់រដ្ឋាភិបាល ដើម្បីឱ្យធនធានសាធារណៈ ត្រូវបានស្នើសុំវិភាជន៍នៅក្នុងថវិកា និងទំនាក់ទំនងរបស់វិធានការទាំងនោះជាមួយនឹងគោលបំណងរួម និងទិសដៅទាំងឡាយដែលបានចែងនៅក្នុងកថាខណ្ឌ (3)។

(6) របាយការណ៍អំពីរបៀបដែលរដ្ឋនឹងតម្រឹមចំណាយ និងការវិនិយោគធនធានសាធារណៈរបស់ខ្លួន ជាមួយនឹងអង្គភាពដទៃទៀតរបស់រដ្ឋាភិបាលដែលអនុវត្តមុខងារ និងកម្មវិធីទាំងឡាយរបស់រដ្ឋក្នុងនាមរដ្ឋ ដើម្បីសម្រេចបាននូវគោលបំណង និងទិសដៅដែលមានចែងនៅក្នុងកថាខណ្ឌ (3)។

(7) របាយការណ៍ជាសាធារណៈស្តីពីភាពរីកចម្រើន ក្នុងការសម្រេចបាននូវគោលបំណង និងទិសដៅដែលមានចែងនៅក្នុងកថាខណ្ឌ (3) និងការវាយតម្លៃអំពីប្រសិទ្ធភាពនៅក្នុងការសម្រេចបាននូវគោលបំណងនិងទិសដៅយោងទៅតាមការវាស់វែងលទ្ធផលដែលមានចែងនៅក្នុងថវិការបស់ឆ្នាំបន្ទាប់។

(c) សម្រាប់ឆ្នាំថវិកា និងឆ្នាំសារពើពន្ធបន្ទាប់ ប្រសិនបើចំណាយដែលបានផ្តល់អនុសាសន៍រួម លើសចំណូលដែលបានប៉ាន់ស្មាននោះ អភិបាលត្រូវផ្តល់អនុសាសន៍ការកាត់បន្ថយចំណាយ ឬប្រភពទាំងឡាយ ដែលចំណូលបន្ថែមគួរត្រូវបានផ្តល់ជូន ឬទាំងពីរ។ ដើម្បីឱ្យដល់កម្រិតមួយដែលអាចអនុវត្តបាន អនុសាសន៍ត្រូវរួមបញ្ចូលនូវការវិភាគអំពីផលប៉ះពាល់រយៈពេលវែង ដែលការកាត់បន្ថយចំណាយ ឬចំណូលបន្ថែមនឹងមានលើសេដ្ឋកិច្ចរបស់រដ្ឋ។ ជាមួយគ្នានឹងថវិការយៈពេលពីរឆ្នាំ អភិបាលត្រូវដាក់ជូនអង្គនីតិបញ្ញត្តិនូវនីតិកម្មណាដែលបានតំរូវ ដើម្បីអនុវត្តវិភាជន៍ដែលមាននៅក្នុងថវិការយៈពេលពីរឆ្នាំ ព្រមទាំងផែនការកំណើនហេដ្ឋារចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រមូលធនរយៈពេលប្រាំឆ្នាំដូចដែលបានបញ្ជាក់ដោយលក្ខន្តិកៈ។

(d) ប្រសិនបើគោលបំណងថវិការបស់អភិបាលក្នុងការ (1) បង្កើតកម្មវិធីរដ្ឋថ្មីមួយ រួមទាំងកម្មវិធីក្នុងមូលដ្ឋានផ្តល់អាណត្តិដោយរដ្ឋ ដែលបានរៀបរាប់នៅក្នុងវគ្គទី 6 នៃមាត្រា XIII B ឬទីភ្នាក់ងារថ្មីមួយ ឬពង្រីកវិសាលភាពនៃកម្មវិធី ឬទីភ្នាក់ងារដែលមានស្រាប់របស់រដ្ឋ ប្រសិនបើបានផ្តល់មូលនិធិ ដែលផលប៉ះពាល់គឺការកើនឡើងសរុបនូវ ខ្ទង់ចំណាយរបស់រដ្ឋលើសម្ភៃប្រាំលានដុល្លារ (25.000.000 ដុល្លារ) នៅក្នុងឆ្នាំសារពើពន្ធនោះ ឬនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ ឬ (2) កាត់បន្ថយនូវពន្ធរបស់រដ្ឋ ឬប្រភពចំណូលផ្សេងទៀតរបស់រដ្ឋដែលផលប៉ះពាល់គឺការថយចុះសរុបនូវ ចំណូលរបស់រដ្ឋលើសម្ភៃប្រាំលានដុល្លារ (25.000.000 ដុល្លារ) នៅក្នុងឆ្នាំសារពើពន្ធនោះ ឬនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ណាមួយនោះ ថវិកាត្រូវស្នើការទូទាត់កម្មវិធីរដ្ឋនូវការកាត់បន្ថយ ឬចំណូលបន្ថែម ឬការរួមបញ្ចូលគ្នានូវចំនួនប្រាក់ដែលស្មើ ឬលើសកំណើនសរុបនៃខ្ទង់ចំណាយរបស់រដ្ឋ ឬការថយចុះសរុបនៃចំណូលរបស់រដ្ឋ។ កម្រិតចាប់ប្រែប្រួលចំនួនម្ភៃប្រាំលានដុល្លារ (25.000.000 ដុល្លារ) នៅក្នុងផ្នែករងនេះ ត្រូវមានការលៃតំរូវប្រចាំឆ្នាំ ដើម្បីឱ្យត្រូវនឹងអតិផរណាដែលស្របតាមសន្ទស្សន៍តម្លៃអ្នកប្រើប្រាស់នៅកាលីហ្វ័រញ៉ា។

~~(b)~~ (e) អភិបាលរដ្ឋ និងបេក្ខជនជាអភិបាលរដ្ឋដែលឈ្នះឆ្នោត អាចតំរូវឱ្យទីភ្នាក់ងាររដ្ឋ មន្ត្រី ឬនិយោជិកម្នាក់ធ្វើការផ្តល់ជូននូវព័ត៌មានណាក៏ដោយដែលមានភាពចាំបាច់ក្នុងការរៀបចំថវិការយៈពេលពីរឆ្នាំ និងថវិកាបំពេញបន្ថែមណាមួយ។

~~(c)~~ (f) (1) ថវិការយៈពេលពីរឆ្នាំ និងថវិកាបំពេញបន្ថែមណាមួយ ត្រូវមានភ្ជាប់មកជាមួយនូវសេចក្តីព្រាងច្បាប់ថវិកាមួយ ដែលរាយមុខចំណាយដែលបានផ្តល់អនុសាសន៍សម្រាប់ឆ្នាំថវិកា និងឆ្នាំសារពើពន្ធបន្ត។ សេចក្តីព្រាងច្បាប់ថវិកាបំពេញបន្ថែម ត្រូវមានភ្ជាប់មកជាមួយនូវសេចក្តីព្រាងច្បាប់មួយ ដែលស្នើថវិកាបំពេញបន្ថែម។

(2) សេចក្តីព្រាងច្បាប់ថវិកា និងសេចក្តីព្រាងច្បាប់ផ្សេងៗដែលផ្តល់នូវវិភាជន៍ទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកា ឬសេចក្តីព្រាងច្បាប់ថវិកាបំពេញបន្ថែមដែលអភិបាលបានដាក់ជូនពិនិត្យត្រូវមានការណែនាំភ្លាមៗនៅក្នុងសភានីមួយៗ ដោយបុគ្គលដែលដឹកនាំគណៈកម្មាធិការ ដែលពិចារណាអំពីថវិកា។

(3) នៅថ្ងៃទី ឬមុនថ្ងៃទី 1 ខែឧសភា រៀងរាល់ឆ្នាំ ក្រោយពីគណៈកម្មការវិភាជន៍នៃសភានីមួយៗនៃអង្គនីតិបញ្ញត្តិបានពិចារណាអំពីសេចក្តីព្រាងច្បាប់ថវិការួចហើយ សភានីមួយៗ ត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ថវិកានោះទៅកាន់គណៈកម្មាធិការរួមរបស់អង្គនីតិបញ្ញត្តិ ដែលអាចរួមមានគណៈកម្មាធិការសន្និសីទ ដែលត្រូវពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ថវិកា និងសេចក្តីព្រាងច្បាប់ផ្សេងៗដែលផ្តល់ឱ្យវិភាជន៍ទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកា និងរាយការណ៍អនុសាសន៍របស់ខ្លួនជូនសភានីមួយៗ មុនថ្ងៃទី 1 ខែមិថុនា រៀងរាល់ឆ្នាំ។ ការនេះមិនត្រូវច្រានចោលជាមុននូវការបញ្ជូនសេចក្តីព្រាងច្បាប់ណាមួយក្នុងចំណោមសេចក្តីព្រាងច្បាប់ទាំងនេះ ទៅកាន់គណៈកម្មាធិការគោលនយោបាយ បន្ថែមពីលើគណៈកម្មាធិការរួមឡើយ។

~~(3)~~ (4) អង្គនីតិបញ្ញត្តិ ត្រូវអនុម័តសេចក្តីព្រាងច្បាប់ថវិកា និងសេចក្តីព្រាងច្បាប់ផ្សេងៗដែលផ្តល់ឱ្យវិភាជន៍ទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកាត្រឹមពាក់កណ្តាលយប់ថ្ងៃទី 15 ខែមិថុនា រៀងរាល់ឆ្នាំ។ វិភាជន៍ដែលធ្វើនៅក្នុងសេចក្តីព្រាងច្បាប់ថវិកា ឬនៅក្នុងសេចក្តីព្រាងច្បាប់ផ្សេងៗដែលផ្តល់ឱ្យវិភាជន៍ទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកា សម្រាប់ឆ្នាំសារពើពន្ធបន្ត មិនត្រូវចំណាយនៅក្នុងឆ្នាំថវិកាឡើយ។

~~(4)~~ (5) អង្គនីតិបញ្ញត្តិ មិនត្រូវផ្ញើឱ្យអភិបាលដើម្បីពិចារណាសេចក្តីព្រាងច្បាប់ណាមួយ ដែលផ្តល់ប្រាក់វិភាជន៍សម្រាប់ចំណាយនៅក្នុងឆ្នាំថវិកា ~~សារពើពន្ធ~~ ឬឆ្នាំសារពើពន្ធបន្ត ~~ដែលសេចក្តីព្រាងច្បាប់ថវិកានឹងត្រូវបានអនុម័ត~~ លើកលែងតែសេចក្តីព្រាងច្បាប់អាសន្ន ដែលបានផ្តល់អនុសាសន៍ដោយអភិបាល ឬវិភាជន៍សម្រាប់បៀវត្សរ៍ និងចំណាយរបស់អង្គនីតិបញ្ញត្តិឡើយ ទាល់តែសេចក្តីព្រាងច្បាប់ថវិកាត្រូវបានអនុម័តសិន។

~~(d)~~ (g) គ្មានសេចក្តីព្រាងច្បាប់ណាមួយ លើកលែងតែសេចក្តីព្រាងច្បាប់ថវិកា ឬសេចក្តីព្រាងច្បាប់ថវិកាបំពេញបន្ថែមប៉ុណ្ណោះ ដែលអាចមានរាយមុខវិភាជន៍លើសពីមួយ ហើយនោះគឺសម្រាប់គោលបំណងជាក់លាក់ ដែលមានការបញ្ជាក់។ វិភាជន៍ពីមូលនិធិទូទៅរបស់រដ្ឋ លើកលែងតែវិភាជន៍ទាំងឡាយសម្រាប់សាលារដ្ឋ និងវិភាជន៍ទាំងឡាយនៅក្នុងសេចក្តីព្រាងច្បាប់ថវិកា សេចក្តីព្រាងច្បាប់ថវិកាបំពេញបន្ថែម និងនៅក្នុងសេចក្តីព្រាងច្បាប់ផ្សេងៗដែលផ្តល់ឱ្យវិភាជន៍ទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកាប៉ុណ្ណោះដែលត្រូវចាត់ទុកជាមោឃៈ ដរាបណាមានការអនុម័តនៅក្នុងសភានីមួយៗ តាមរយៈការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដែលបានបញ្ចូលនៅក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រពីរភាគបីនៃសមាជិកដែលចូលរួម។

~~(e)~~ (h) (1) ទោះបីជាមានបទបញ្ញត្តិដទៃទៀតនៃច្បាប់ ឬរដ្ឋធម្មនុញ្ញនេះក៏ដោយ សេចក្តីព្រាងច្បាប់ថវិកា សេចក្តីព្រាងច្បាប់ថវិកាបំពេញបន្ថែម និងសេចក្តីព្រាងច្បាប់ផ្សេងៗដែលផ្តល់ឱ្យវិភាជន៍ទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកា អាចត្រូវបានអនុម័តនៅក្នុងសភានីមួយៗ តាមរយៈការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដែលបានបញ្ចូលនៅក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រភាគច្រើននៃសមាជិកដែលចូលរួម ដើម្បីចូលជាធរមានភ្លាមៗក្រោយពីចុះហត្ថលេខាដោយអភិបាល ឬក្រោយពីកាលបរិច្ឆេទដែល

បានបញ្ជាក់នៅក្នុងនីតិកម្ម។ គ្មានអ្វីមួយនៅក្នុងផ្នែករងនេះ ត្រូវប៉ះពាល់ដល់តំរូវការបោះឆ្នោតសម្រាប់វិភាជន៍សម្រាប់សាលារដ្ឋ ដែលមាននៅក្នុងផ្នែករង (d) *(g)* នៃផ្នែកនេះ និងនៅក្នុងផ្នែករង (b) នៃវគ្គទី 8 នៃមាត្រានេះ។

(2) សម្រាប់គោលបំណងនៃផ្នែកនេះ "សេចក្តីព្រាងច្បាប់ផ្សេងៗដែលផ្តល់វិភាជន៍ទាក់ទងនឹងសេចក្តីព្រាងច្បាប់ថវិកា *ឬសេចក្តីព្រាងច្បាប់ថវិកាបំពេញបន្ថែម*ត្រូវមានតែសេចក្តីព្រាងច្បាប់ទាំងឡាយណាដែលបានកំណត់ទាក់ទងទៅនឹងថវិកានៅក្នុងសេចក្តីព្រាងច្បាប់ថវិកា *ឬនៅក្នុងសេចក្តីព្រាងច្បាប់ថវិកាបំពេញបន្ថែម* ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិប៉ុណ្ណោះ។

*(3) សម្រាប់គោលបំណងនៃផ្នែកនេះ "សេចក្តីព្រាងច្បាប់ថវិកា" ត្រូវមានន័យថា សេចក្តីព្រាងច្បាប់ទាំងឡាយណាដែលមានថវិកាសម្រាប់ឆ្នាំថវិកា និងឆ្នាំសារពើពន្ធបន្ត។*

~~(f)~~ (i) អង្គនីតិបញ្ញត្តិអាចគ្រប់គ្រងការដាក់ជូនពិនិត្យ ការអនុម័ត និងការអនុវត្តថវិកា និងការដាក់ពាក្យបណ្តឹងចំពោះទីភ្នាក់ងាររដ្ឋទាំងអស់។

~~(g)~~ (j) សម្រាប់ឆ្នាំសារពើពន្ធ 2004-05 ឬឆ្នាំសារពើពន្ធណាមួយបន្ទាប់មកទៀត អង្គនីតិបញ្ញត្តិមិន~~ត្រូវ~~ *អាចធ្វើឱ្យអភិបាលធ្វើការពិចារណា ហើយអភិបាលមិនត្រូវ* ~~អាច~~ចុះហត្ថលេខាចូលទៅក្នុងច្បាប់ នូវសេចក្តីព្រាងច្បាប់ថវិកា*សម្រាប់ឆ្នាំថវិកា ឬសម្រាប់ឆ្នាំសារពើពន្ធបន្ត* ដែលនឹងផ្តល់វិភាជន៍ពីមូលនិធិទូទៅ សម្រាប់ឆ្នាំសារពើពន្ធ*នីមួយៗនៃថវិការយៈពេលពីរឆ្នាំនោះ* ចំនួនប្រាក់សរុប ដែលនៅពេលបញ្ចូលគ្នាជាមួយវិភាជន៍ទាំងអស់ពីមូលនិធិទូទៅសម្រាប់ឆ្នាំសារពើពន្ធ~~នោះ~~ ដែលត្រូវបានធ្វើឡើងនៅពេលអនុម័តសេចក្តីព្រាងច្បាប់ថវិកា និងចំនួនប្រាក់នៃមូលនិធិទូទៅ ដែលត្រូវបានផ្ទេរទៅកាន់គណនីស្តេរកម្មថវិកាសម្រាប់ឆ្នាំសារពើពន្ធនោះស្របតាមវគ្គទី 20 នៃមាត្រា XVI លើសពីចំណូលថវិកាទូទៅ *ការផ្ទេរ និងសមតុល្យមូលនិធិទូទៅដែលមានពីឆ្នាំសារពើពន្ធមុន* សម្រាប់ឆ្នាំសារពើពន្ធនោះ ដែលត្រូវបានប៉ាន់ស្មាននៅពេលអនុម័តសេចក្តីព្រាងច្បាប់ថវិកា។ ~~ដែល~~ ការប៉ាន់ស្មានចំណូល *ការផ្ទេរ និងសមតុល្យមូលនិធិទូទៅ* ត្រូវមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ថវិកាដែលអនុម័តដោយអង្គនីតិបញ្ញត្តិ។ *សេចក្តីព្រាងច្បាប់ថវិកាដែលបានអនុម័តដោយអង្គនីតិបញ្ញត្តិក៏ត្រូវមានរបាយការណ៍អំពីកាតព្វកិច្ចមូលនិធិសរុប ដែលមានរៀបរាប់នៅក្នុងផ្នែករងនេះ សម្រាប់ឆ្នាំសារពើពន្ធនីមួយៗនៃថវិការយៈពេលពីរឆ្នាំ ព្រមជាមួយនឹងការពន្យល់បកស្រាយ អំពីមូលដ្ឋានសម្រាប់ការប៉ាន់ស្មានចំណូលមូលនិធិទូទៅ រួមទាំងការពន្យល់បកស្រាយអំពីចំនួនប្រាក់ដែលអង្គនីតិបញ្ញត្តិប៉ាន់ស្មានចំណូលមូលនិធិទូទៅសម្រាប់ឆ្នាំសារពើពន្ធនោះ ដើម្បីញែកឱ្យខុសគ្នាពីចំណូលមូលនិធិទូទៅសម្រាប់ឆ្នាំសារពើពន្ធមុនភ្លាមៗ។*

~~(h)~~ *(k)* ទោះបីជាមានបទបញ្ញត្តិដទៃទៀតនៃច្បាប់ ឬរដ្ឋធម្មនុញ្ញនេះ រួមទាំងផ្នែករង ~~(c)~~ *(f)* នៃផ្នែកនេះ វគ្គទី 4 នៃមាត្រានេះ និងវគ្គទី 4 និង 8 នៃមាត្រា III នៅក្នុងឆ្នាំណាមួយដែលសេចក្តីព្រាងច្បាប់ថវិកាមិនត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិនៅត្រឹមពាក់កណ្តាលយប់ថ្ងៃទី 15 ខែមិថុនាក៏ដោយ មិនត្រូវមានវិភាជន៍ពីថវិកាបច្ចុប្បន្ន ឬថវិកាអនាគតដើម្បីទូទាត់បៀ វត្សរ៍ ឬការសងប្រាក់ដែលបានចំណាយសម្រាប់ការធ្វើដំណើរ ឬសម្រាប់ការរស់នៅ សម្រាប់សមាជិកទាំងឡាយរបស់អង្គនីតិបញ្ញត្តិនៅក្នុងសម័យប្រជុំជាទៀងទាត់ ឬសម័យប្រជុំពិសេសណាមួយ សម្រាប់រយៈពេលចាប់ពីថ្ងៃទី 15 ខែមិថុនា រហូតដល់ថ្ងៃដែលសេចក្តីព្រាងច្បាប់ថវិកាត្រូវបានបង្ហាញជូនអភិបាល។ គ្មានបៀវត្សរ៍ ឬការសងប្រាក់ដែលបានចំណាយសម្រាប់ការធ្វើដំណើរ ឬសម្រាប់ការរស់នៅ ដែលបានដកហូតស្របតាមផ្នែករងនេះ ត្រូវបានទូទាត់ដោយប្រតិសកម្មឡើយ។

វគ្គទី 7. មាត្រា XI A ត្រូវបានបន្ថែមចូលទៅក្នុងរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ាត្រូវបកស្រាយថា៖

*មាត្រា XI A*

*ផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍*

*វគ្គទី 1. (a) អ្នករស់នៅកាលីហ្វ័រញ៉ារំពឹង និងតំរូវឱ្យអង្គភាពរដ្ឋាភិបាលធ្វើការពន្យល់ជាសាធារណៈអំពីគោលបំណងនៃចំណាយ និងថាតើមានការធ្វើឱ្យមានភាពរីកចម្រើនឆ្ពោះទៅរកទិសដៅរបស់ខ្លួនដែរ ឬទេ។ ដូច្នេះ បន្ថែមពីលើតំរូវការបទបញ្ញត្តិដទៃទៀតនៃរដ្ឋធម្ម នុញ្ញនេះ ថវិការបស់អង្គភាពរដ្ឋាភិបាលនីមួយដែលត្រូវបានអនុម័តរួច ត្រូវមានចំណុចទាំងអស់ខាងក្រោម ពីព្រោះវាអនុវត្តចំពោះអំណាច និងករណីយកិច្ចរបស់អង្គភាព៖*

*(1) របាយការណ៍អំពីរបៀបដែលថវិកានឹងលើកកម្ពស់ ដូចដែលអាចអនុវត្តបានចំពោះមុខងារ តួនាទីរបស់អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន និងអាទិភាពដែលបានកំណត់ក្នុងមូលដ្ឋាន សេដ្ឋកិច្ចរីកចម្រើន បរិស្ថានមានគុណភាព និងសមធម៌សហគមន៍ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងទិសដៅដូចតទៅ៖ ការបង្កើនការងារ ការកែលម្អការអប់រំ ការកាត់បន្ថយភាពក្រីក្រ ការកាត់បន្ថយឧក្រិដ្ឋកម្ម ការកែលម្អផ្នែកសុខាភិបាល និងអាទិភាពដទៃទៀតរបស់សហគមន៍។*

*(2) ការបរិយាយអំពីការវាស់វែងលទ្ធផលរួម ដែលនឹងត្រូវយកទៅប្រើក្នុងការវាយតម្លៃភាពរីកចម្រើនគ្រប់ផ្នែកទាំងអស់របស់សហគមន៍ ឆ្ពោះទៅរកទិសដៅដែលបានបង្កើតដោយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានស្របតាមកថាខណ្ឌ (1)។*

*(3) របាយការណ៍អំពីការវាស់វែងលទ្ធផល សម្រាប់ចំណាយចម្បងៗនីមួយៗរបស់រដ្ឋាភិបាល ដើម្បីឱ្យធនធានសាធារណៈ ត្រូវបានផ្តល់វិភាជន៍នៅក្នុងថវិកា និងទំនាក់ទំនងរបស់វិធានការទាំងនោះជាមួយនឹងគោលបំណងរួម និងទិសដៅទាំងឡាយ ដែលបានបង្កើតដោយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានស្របតាមកថាខណ្ឌ (1)។*

*(4) របាយការណ៍អំពីរបៀបដែលអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាននឹងតម្រឹមចំណាយ និងការវិនិយោគធនធានសាធារណៈរបស់ខ្លួន ដើម្បីដើម្បីសម្រេចបាននូវទិសដៅទាំងឡាយទិសដៅទាំងឡាយ ដែលបានបង្កើតដោយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានស្របតាមកថាខណ្ឌ (1)។*

*(5) របាយការណ៍ជាសាធារណៈស្តីពីភាពរីកចម្រើន ក្នុងការ សម្រេចបាននូវទិសដៅទាំងឡាយ ដែលបានបង្កើតដោយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានស្របតាមកថាខណ្ឌ (1) និងការវាយតម្លៃអំពីប្រសិទ្ធភាព នៅក្នុងការសម្រេចបានលទ្ធផល យោងទៅតាមវិធានការដែលមានចែងនៅក្នុងថវិការបស់ឆ្នាំមុន។*

*(b) អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាននីមួយៗ ត្រូវបង្កើត និងអនុវត្តដំណើរការមួយដែលមានលក្ខណៈបើកទូលាយ និងមានតម្លាភាព ដែលលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ទិដ្ឋភាពទាំងអស់នៃសហ គមន៍ នៅក្នុងការបង្កើតថវិកាដែលបានស្នើរបស់ខ្លួន រួមទាំងការកំណត់ អាទិភាពរបស់សហគមន៍ស្របតាមកថាខណ្ឌ (1) នៃផ្នែករង (a)។*

*(c) ផ្នែកនេះ ត្រូវអាចប្រើបាននៅក្នុងឆ្នាំថវិការបស់អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលចាប់ផ្តើមក្នុងឆ្នាំ 2014។*

*(d) បទបញ្ញត្តិទាំងឡាយនៃផ្នែកនេះ មានលក្ខណៈស្វ័យអនុវត្ត ហើយនឹងត្រូវបកស្រាយដើម្បីអនុវត្តតែសម្រាប់សកម្មភាពទាំងឡាយណា ដែលអង្គភាពក្នុងមូលដ្ឋានអនុវត្តអំណាចប៉ុណ្ណោះ។*

*វគ្គទី 2. (a) តាមរយៈចំណាត់ការរបស់គណៈគ្រប់គ្រង ខោនធីមួយអាចផ្តួចផ្តើមឱ្យមានការបង្កើតផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ ដែលចាប់ពីពេលនេះតទៅហៅកាត់ថា ផែនការសកម្មភាព។ ខោនធីនោះ ត្រូវផ្តួចផ្តើមឱ្យមានការចូលរួមពីសំណាក់អង្គភាពរដ្ឋាភិបាល ក្នុងមូលដ្ឋានទាំងអស់នៅក្នុងខោនធី ដែលមុខងារ ឬសេវាដែលមានស្រាប់របស់ពួកគេស្ថិតនៅក្នុងវិសាលភាពដែលបានប៉ាន់ស្មានរបស់ផែនការសកម្មភាព។ អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាននៅក្នុងខោនធី អាចដាក់ញត្តិជូនគណៈគ្រប់គ្រង ដើម្បីផ្តួចផ្តើមផែនការសកម្មភាពមួយ ដែលត្រូវដាក់បញ្ចូលទៅក្នុងដំណើរការរៀបចំផែនការ ឬដើម្បីកែប្រែផែនការសកម្មភាពនោះ។*

*(b) អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានទាំងឡាយដែលបានចូលរួម ត្រូវធ្វើពង្រាងផែនការសកម្មភាព តាមរយៈដំណើរការមួយដែលមានលក្ខណៈបើកទូលាយ និងមានតម្លាភាព ដែលលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់ទិដ្ឋភាពទាំងអស់នៃសហគមន៍ រួមទាំងអ្នកដឹកនាំនៅជិតខាង។ ផែនការសកម្មភាព ត្រូវបញ្ចូលនូវចំណុចទាំងអស់ដូចតទៅ ៖*

*(1) របាយការណ៍ដែល (A) ផ្តល់នូវចំណុចសំខាន់ៗអំពីរបៀបដែលផែនការសកម្មភាព នឹងសម្រេចបាននូវគោលបំណង និងទិសដៅដែលបានចែងនៅក្នុងកថាខណ្ឌ (1) ដល់ (5) រួមបញ្ចូលទាំង ផ្នែករង (a) នៃវគ្គទី 1 នៃមាត្រានេះ (B) បរិយាយអំពីសេវាសាធារណៈដែលនឹងត្រូវផ្តល់ជូនស្របតាម*

ផែនការសកម្មភាព និងតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពចូលរួម (C) ពន្យល់អំពីមូលហេតុដែលសេវាទាំងនោះនឹងត្រូវបានផ្តល់ជូន កាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលថែមទៀតស្របតាមផែនការសកម្មភាព (D) ផ្តល់នូវការលៃចែកធនធាន ដើម្បីគាំទ្រផែនការ រួមមាន មូលនិធិដែលអាចនឹងទទួលបានពីមូលនិធិមរតកការអនុវត្តការងារ និងគណនេយ្យភាព (E) ពិចារណាអំពីភាពខុសគ្នានៅក្នុងសហគមន៍ទាំងឡាយ ដែលបម្រើជូនដោយផែនការសកម្មភាព និង (F) ពន្យល់អំពីរបៀបដែលផែនការសកម្មភាពមានសង្គតភាពជាមួយថវិកាទាំងឡាយ ដែលត្រូវបានអនុម័តដោយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានដែលបានចូលរួម។

(2) លទ្ធផលដែលអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលបានចូលរួមចង់បាន និងវិធីដែលលទ្ធផលទាំងនោះនឹងត្រូវបានវាស់វែង។

(3) វិធីសាស្ត្រសម្រាប់ការរាយការណ៍លទ្ធផលជាទៀងទាត់ ជូនសាធារណៈជន និងជូនរដ្ឋ។

(c) (1) ផែនការសកម្មភាព ត្រូវដាក់ជូនគណៈគ្រប់គ្រងនៃអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលបានចូលរួមនីមួយៗ នៅក្នុងខោនធីនោះ។ ដើម្បីធានានូវកម្រិតអប្បបរមានៃកិច្ចសហប្រតិបត្តិការ ផែនការសកម្មភាព ត្រូវតែមានការអនុម័តពីខោនធី អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ដោយផ្តល់នូវសេវាក្នុងក្រុងស្របតាមផែនការសកម្មភាព យ៉ាងហោចណាស់ប្រជាជនមួយភាគធំនៅក្នុងខោនធីនោះ និងការិយាល័យអប់រំខោនធីមួយ ឬច្រើន ដែលបម្រើយ៉ាងហោចណាស់ សិស្សសាលារដ្ឋមួយភាគធំនៅក្នុងខោនធីនោះ។

(2) ការអនុម័តផែនការសកម្មភាព ឬការកែប្រែផែនការសកម្មភាពដោយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន រួមទាំងខោនធី តម្រូវឱ្យមានសំឡេងឆ្នោតភាគច្រើន នៃសមាជិកភាពរបស់គណៈអភិបាលរបស់ខោនធីនោះ។ ផែនការសកម្មភាព មិនត្រូវអនុវត្តចំពោះអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានណា ដែលមិនអនុម័តផែនការសកម្មភាព ដែលបានចែងនៅក្នុងកថាខណ្ឌនេះឡើយ។

(d) នៅពេលផែនការសកម្មភាពត្រូវបានអនុម័តរួចហើយ ខោនធីអាចចុះកិច្ចសន្យានានា ដែលកំណត់ និងចាត់តាំងករណីយកិច្ច និងកាតព្វកិច្ចទាំងឡាយរបស់អង្គភាពចូលរួមនីមួយៗ ឱ្យតែកិច្ចសន្យាទាំងនោះ មានភាពចាំបាច់សម្រាប់ការអនុវត្តផែនការសកម្មភាព និងត្រូវបានអនុម័តដោយសំឡេងឆ្នោតភាគច្រើននៃគណៈអភិបាល នៃអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាននីមួយៗ ដែលជាភាគីនៃកិច្ចសន្យានោះ។

(e) អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលបានអនុម័តផែនការសកម្មភាពមួយ ស្របតាមផ្នែកនេះ ហើយបានបំពេញតម្រូវការនៃវគ្គទី 3 នៃមាត្រានេះ ប្រសិនបើអាចអនុវត្តបាន អាចរួមបញ្ចូលមូលនិធិរដ្ឋ ឬមូលនិធិក្នុងមូលដ្ឋាន ដែលបានលៃចែកឱ្យពួកគេ សម្រាប់គោលបំណងផ្តល់សេវាទាំងឡាយ ដែលបានកំណត់នៅក្នុងផែនការសកម្មភាព ក្នុងលក្ខណៈមួយដែលនឹងធ្វើឱ្យទិសដៅរបស់ផែនការសកម្មភាពមានការរីកចម្រើនទៅមុខ។

វគ្គទី 3. (a) ប្រសិនបើបណ្តាភាគីនៃផែនការសកម្មភាព ដែលត្រូវបានអនុម័តស្របតាមវគ្គទី 2 នៃមាត្រានេះសន្និដ្ឋានថា លក្ខន្តិកៈ ឬនិយ័តកម្មរបស់រដ្ឋ រួមមាន លក្ខន្តិកៈ ឬនិយ័តកម្មដែលកម្រិតការចំណាយមូលនិធិរារាំងដល់វឌ្ឍនភាពឆ្ពោះទៅរកទិសដៅនៃផែនការសកម្មភាព ឬពួកគេត្រូវការអំណាចតាមលក្ខន្តិកៈបន្ថែមទៀត ដើម្បីអនុវត្តផែនការសកម្មភាព អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន អាចដាក់បញ្ចូលបទបញ្ញត្តិទាំងឡាយទៅក្នុងផែនការសកម្មភាព ដែលមានលក្ខណៈមុខងារស្មើនឹងគោលបំណងមួយ ឬគោលបំណងទាំងឡាយរបស់លក្ខន្តិកៈ ឬនិយ័តកម្ម។ បទបញ្ញត្តិនេះ ត្រូវដាក់បញ្ចូលនូវការបរិយាយ អំពីគោលបំណងដែលបានគ្រោងទុករបស់រដ្ឋ អំពីរបៀបដែលវិធាននោះគឺជាឧបសគ្គចំពោះលទ្ធផលកាន់តែប្រសើរឡើង អំពីវិធានរបស់សហគមន៍ដែលបានស្នើសុំ និងអំពីរបៀបដែលវិធានរបស់សហគមន៍ នឹងរួមចំណែកក្នុងលទ្ធផលកាន់តែប្រសើរ ខណៈពេលធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើន បរិស្ថានមានគុណភាព និងសមធម៌សហគមន៍មានភាពរីកចម្រើនទៅមុខ។ សម្រាប់គោលបំណងនៃផ្នែកនេះ បទបញ្ញត្តិមួយមានលក្ខណៈមុខងារស្មើនឹងគោលបំណងមួយ ឬគោលបំណងច្រើននៃលក្ខន្តិកៈ ឬនិយ័តកម្ម ប្រសិនបើវាអនុលោមតាមគោលការណ៍ និងគោលបំណងនៃលក្ខន្តិកៈ ឬនិយ័តកម្មបានច្រើន។

(b) បណ្តាភាគីត្រូវដាក់ជូនផែនការសកម្មភាពមួយ ដែលមានបទបញ្ញត្តិមានមុខងារស្មើ ដូចដែលបានរៀបរាប់នៅក្នុងផ្នែករង (a) ស្របតាមលក្ខន្តិកៈរបស់រដ្ឋមួយ ឬច្រើន ស្របតាមអង្គនីតិបញ្ញត្តិក្នុងសម័យប្រជុំទៀងទាត់ ឬសម័យប្រជុំពិសេសមួយ។ ក្នុងរយៈពេល 60 ថ្ងៃ ក្រោយពីបានទទួលផែនការសកម្មភាព ប្រសិនបើអង្គនីតិបញ្ញត្តិមិនចាត់វិធានការដំណាលគ្នាដោយសេចក្តីសម្រេច ឬផ្សេងពីនេះ ដើម្បីជំទាស់នឹងបទបញ្ញត្តិនោះ បទបញ្ញត្តិទាំងនោះត្រូវចាត់ទុកថាអាចប្រើបាន ជាមួយនឹងប្រសិទ្ធភាពនៅក្នុងច្បាប់ដែលអនុលោមតាមបទបញ្ញត្តិ ត្រូវចាត់ទុកថាអនុលោមតាមលក្ខន្តិកៈមួយ ឬច្រើនរបស់រដ្ឋ។

(c) ប្រសិនបើបណ្តាភាគីនៃផែនការសកម្មភាព ដែលត្រូវបានអនុម័តស្របតាមវគ្គទី 2 នៃមាត្រានេះ សន្និដ្ឋានថា និយ័តកម្មរារាំងដល់ទិសដៅរបស់ផែនការសកម្មភាព ពួកគេអាចគោរពតាមនីតិវិធីដែលមានរៀបរាប់នៅក្នុងផ្នែករង (a) នៃផ្នែកនេះ តាមរយៈការដាក់សំណើរបស់ពួកគេជូនទីភ្នាក់ងារ ឬក្រសួងដែលទទួលខុសត្រូវចំពោះការប្រកាសឱ្យប្រើ ឬគ្រប់គ្រងនិយ័តកម្ម ដែលត្រូវពិចារណាទៅលើសំណើនោះក្នុងរយៈពេល 60 ថ្ងៃ។ ប្រសិនបើក្នុងរយៈពេល 60 ថ្ងៃ ក្រោយពីបានទទួលផែនការសកម្មភាព ទីភ្នាក់ងារ ឬក្រសួងមិនចាត់វិធានការជំទាស់នឹងបទបញ្ញត្តិទេនោះ បទបញ្ញត្តិទាំងនោះត្រូវចាត់ទុកថាអាចប្រើបាន ជាមួយនឹងប្រសិទ្ធភាពនៅក្នុងច្បាប់ដែលអនុលោមតាមបទបញ្ញត្តិ ត្រូវចាត់ទុកថាអនុលោមតាមនិយ័តកម្មមួយ ឬច្រើនរបស់រដ្ឋ។ រាល់ចំណាត់ការជំទាស់នឹងបទបញ្ញត្តិ ត្រូវរួមបញ្ចូលនូវសេចក្តីថ្លែងការណ៍ ដែលមានចែងនូវហេតុផលសម្រាប់ការជំទាស់នេះ។

(d) ផ្នែកនេះ ត្រូវអនុវត្តតែចំពោះលក្ខន្តិកៈ ឬនិយ័តកម្មទាំងឡាយណា ដែលគ្រប់គ្រងដោយផ្ទាល់លើរដ្ឋបាលនៃកម្មវិធីរបស់រដ្ឋ ដែលបានទទួលហិរញ្ញប្បទានទាំងស្រុង ឬដោយផ្អែកពីមូលនិធិរបស់រដ្ឋ។

(e) រាល់អំណាចដែលត្រូវបានផ្តល់ ស្របតាមផ្នែកនេះត្រូវផុតកំណត់ក្នុងរយៈពេលបួនឆ្នាំ ដោយស្វ័យប្រវត្តិ ក្រោយថ្ងៃប្រសិទ្ធភាព លុះត្រាណាមានការបន្តថ្មី ស្របតាមផ្នែកនេះ។

វគ្គទី 4. (a) មូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព ត្រូវបានបង្កើតឡើងនៅក្នុងរតនាគារជាតិ សម្រាប់គោលបំណងផ្តល់ធនធានរដ្ឋ ដើម្បីអនុវត្តការផ្តល់សេវារួមគ្នា ដែលមាននៅក្នុងផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ ដែលត្រូវបានរៀបចំឡើងស្របតាមមាត្រានេះ។ ទោះបីជាមានវគ្គទី 13340 នៃក្រមរដ្ឋាភិបាលក៏ដោយ ប្រាក់នៅក្នុងមូលនិធិ ត្រូវផ្តល់វិភាជន៍ជាបន្តបន្ទាប់ សម្រាប់គោលបំណងតែមួយគត់ ដែលបានចែងនៅក្នុងមាត្រានេះ។ សម្រាប់គោលបំណងនៃវគ្គទី 8 នៃមាត្រា XVI ចំណូលដែលបានផ្ទេរចូលមូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព ស្របតាមច្បាប់ដែលបន្ថែមមាត្រានេះ ត្រូវចាត់ទុកថាជាចំណូលពន្ធទាំងឡាយនៃមូលនិធិទូទៅ ដែលអាចត្រូវបានផ្តល់វិភាជន៍ស្របតាមមាត្រា XIIIB។

(b) \ប្រាក់នៅក្នុងមូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព ត្រូវចែកចាយទៅឱ្យខោនធីទៅតាមលក្ខន្តិកៈ ដែលផែនការសកម្មភាពរបស់ខោនធីទាំងនោះ បានដាក់បញ្ចូលនូវឱកាសសម្រាប់ចំណាយមូលនិធិដែលបំពេញតាមវគ្គទី 1 និង 2 នៃមាត្រានេះ។

(c) រាល់មូលនិធិដែលលៃចែកទៅឱ្យការិយាល័យអប់រំខោនធី ស្របតាមផែនការសកម្មភាព ត្រូវតែទូទាត់ពីប្រភពចំណូល ក្រៅពីមូលនិធិមរតកនៃការអនុវត្តការងារនិងគណនេយ្យភាពហើយអាចត្រូវបានទូទាត់ពីប្រភពផ្សេងៗទៀតតាមការកំណត់ដោយអង្គភាពចូលរួមក្នុងផែនការសកម្មភាព។ការលៃចែកដែលបានទទួលដោយការិយាល័យអប់រំខោនធីណាមួយស្របតាមផែនការសកម្មភាព មិនត្រូវចាត់ទុកថាជាចំណូលពន្ធនៃមូលនិធិទូទៅ ឬចំណូលពន្ធក្នុងមូលដ្ឋានដែលបានលៃចែក សម្រាប់គោលបំណងនៃវគ្គទី 8 នៃមាត្រា XVI ឡើយ។

វគ្គទី 5. ខោនធីដែលបានអនុម័តផែនការសកម្មភាព ស្របតាមវគ្គទី 2 នៃមាត្រានេះ ត្រូវវាយតម្លៃប្រសិទ្ធភាពនៃផែនការសកម្មភាព យ៉ាងហោចណាស់បួនឆ្នាំម្តង។ ដំណើរការវាយតម្លៃ ត្រូវរួមបញ្ចូលនូវកាលានុវត្តភាពសម្រាប់មតិយោបល់របស់សាធារណជន និងសម្រាប់មតិយោបល់ទាំងឡាយ ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍សម្រេច។ ការវាយតម្លៃត្រូវប្រើដោយអង្គភាពចូលរួម ដើម្បីកែលម្អផែនការសកម្មភាព និងដោយសាធារណជន ដើម្បីវាយតម្លៃការអនុវត្តការងាររបស់រដ្ឋាភិបាលរបស់ខ្លួន។

*ការវាយតម្លៃ ត្រូវដាក់បញ្ចូលនូវការពិនិត្យឡើងវិញនូវកម្រិតមួយ ដែលផែនការសកម្មភាពសម្រេចបាននូវគោលបំណង និងទិសដៅដែលមានចែងនៅក្នុងកថាខណ្ឌ (1) ដល់ (5) រួមទាំង អនុផ្នែក (a) នៃវគ្គទី 1 រួមមាន ៖ ការកែលម្អលទ្ធផលក្នុងចំណោមអង្គភាពចូលរួម ក្នុងការផ្តល់ និងប្រសិទ្ធភាពនៃសេវារដ្ឋាភិបាលដែលអាចអនុវត្តបាន ភាពរីកចម្រើនឆ្ពោះទៅរកការកាត់បន្ថយភាពខុសគ្នាក្នុងសហគមន៍ និងថាតើបុគ្គល ឬសមាជិកសហគមន៍ទទួលសេវាទាំងនោះ ទទួលបានការតំណាងនៅក្នុងការបង្កើត និងការអនុវត្តផែនការសកម្មភាពដែរឬទេ។*

*វគ្គទី 6. (a) រដ្ឋត្រូវពិចារណាអំពីរបៀបដែលខ្លួនអាចជួយ អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ក្នុងការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល តាមរយៈផែនការសកម្មភាពដែលបានអនុម័តស្របតាមវគ្គទី 2។ ស្របជាមួយនឹងទិសដៅនេះ រដ្ឋ ឬក្រសួងណាមួយ ឬទីភ្នាក់ងារណាមួយក្នុងរដ្ឋនេះ អាចចុះកិច្ចសន្យាជាមួយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលជាអ្នកចូលរួមនៅក្នុងផែនការសកម្មភាព ដើម្បីអនុវត្តមុខងារណា ដែលភាគីចុះកិច្ចសន្យាកំណត់ថា អាចអនុវត្តការងារបានកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលនៅថ្នាក់មូលដ្ឋាន។ រាល់កិច្ចសន្យាដែលបានធ្វើឡើង ស្របតាមផ្នែកនេះ ត្រូវអនុលោមតាមផែនការសកម្មភាព ដែលត្រូវបានអនុម័តស្របតាមលក្ខខណ្ឌតំរូវរបស់វគ្គទី 2។*

*(b) រដ្ឋត្រូវពិចារណា និងកំណត់អំពីរបៀបដែលខ្លួនអាចគាំទ្រ តាមរយៈគ្រឿងលើកទឹកចិត្តជាហិរញ្ញវត្ថុ និងនិយ័តភាព កិច្ចខិតខំប្រឹងប្រែងដោយអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន និងតំណាងរបស់សាធារណជន ក្នុងការធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហាប្រឈម និងដោះស្រាយបញ្ហានានា ដែលអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន បានកំណត់ដោយស្ម័គ្រចិត្ត និងដោយកិច្ចសហការថា ដោះស្រាយបានល្អបំផុតនៅកម្រិតភូមិសាស្ត្រតំបន់ ដើម្បីជំរុញឱ្យសេដ្ឋកិច្ចរីកចម្រើន បរិស្ថានមានគុណភាព និងសមធម៌សហគមន៍រីកចម្រើនទៅមុខ។ រដ្ឋត្រូវលើកកម្ពស់ភាពក្លៀវក្លា និងការប្រកួតប្រជែងជាសកល លើសេដ្ឋកិច្ចតំបន់ និងជំរុញឱ្យមានកិច្ចសហការកាន់តែទូលំទូលាយក្នុងចំណោមរដ្ឋាភិបាលក្នុងមូលដ្ឋាន នៅក្នុងតំបន់ តាមរយៈការផ្តល់ការពិចារណាទៅលើអាទិភាព ចំពោះមូលនិធិគ្រប់គ្រងដោយរដ្ឋ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមនុស្សធម៌ តាមដែលអាចអនុវត្តបាន ដល់អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានដែលបានចូលរួម ដែលបានបង្កើតផែនការកិច្ចសហការក្នុងតំបន់ដោយស្ម័គ្រចិត្ត និងកំពុងមានភាពរីកចម្រើនឆ្ពោះទៅរកគោលបំណង និងទិសដៅនៃផែនការរបស់ពួកគេ ដែលត្រូវរួមបញ្ចូលគ្នានូវទិសដៅ និងគោលបំណងដែលមានចែងនៅក្នុងកថាខណ្ឌ (1) ដល់ (5) រួមទាំងអនុផ្នែក (a) នៃវគ្គទី 1។*

*វគ្គទី 7. គ្មានអ្វីមួយនៅក្នុងមាត្រានេះ មានបំណងចាត់ទុកជានិរាករណ៍ ឬជំនួសអំណាចជាធរមានរបស់អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន ឬបង្អួចទឹកចិត្ត ឬហាមឃាត់អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន មិនឱ្យបង្កើត និងចូលរួមក្នុងកម្មវិធី និងផែនការក្នុងតំបន់ ដែលត្រូវបានរៀបចំឡើង ដើម្បីកែលម្អការផ្តល់ និងប្រសិទ្ធភាពនៃ សេវារបស់រដ្ឋាភិបាលឡើយ។*

*វគ្គទី 8. សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យ "អង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋាន" មានន័យថា ខោនធី ក្រុង ក្រុង និងខោនធី និងអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានផ្សេងៗរួមមាន ការិយាល័យអប់រំខោនធី ការិយាល័យអប់រំខោនធី និងការិយាល័យសាកលវិទ្យាល័យសហគមន៍ក្នុងខោនធី។*

វគ្គទី 8. វគ្គទី 29 នៃមាត្រា XIII នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ត្រូវបានធ្វើវិសោធនកម្ម ដើម្បីចែងថា៖

វគ្គទី 29. (a) អង្គនីតិបញ្ញត្តិ អាចអនុញ្ញាតឱ្យខោនធី ក្រុង និងខោនធី និងក្រុង ចុះកិច្ចសន្យាដើម្បីបែងចែងរវាងពួកគេនូវ ចំណូលដែលទទួលបានពីពន្ធលក់ និងពន្ធប្រើប្រាស់ដែលពួកគេតំរូវឱ្យបង់ ដែលត្រូវបានប្រមូលឱ្យពួកគេដោយរដ្ឋ។ មុនពេលកិច្ចសន្យាអាចប្រើប្រាស់បាន វាត្រូវមានការអនុញ្ញាតដោយសំឡេងឆ្នោតភាគច្រើន នៃអ្នកបោះឆ្នោតទៅលើសំណួរនៅក្នុងយុត្តាធិការនីមួយៗ នៅក្នុងការបោះឆ្នោតសាកល ឬបឋមដោយផ្ទាល់។

(b) ទោះបីជាមានផ្នែករង(a) ក៏ដោយ នៅថ្ងៃ ឬក្រោយថ្ងៃអាចប្រើប្រាស់ផ្នែករងនេះបាន ខោនធី ក្រុង និងខោនធី និងក្រុង អាចចុះកិច្ចសន្យា ដើម្បីបែងចែងរវាងពួកគេនូវ ចំណូលដែលទទួលបានពីពន្ធលក់ និងពន្ធប្រើប្រាស់ដែលពួកគេតំរូវឱ្យបង់ ស្របតាមច្បាប់ស្តីពីពន្ធលក់ និងប្រើប្រាស់ឯកសណ្ឋាន Bradley-Burns ក្នុងមូលដ្ឋាន (Bradley-Burns Uniform Local Sales and Use Tax Law) ឬបទបញ្ញត្តិសម្រាប់អ្នកបន្តវេន ដែលត្រូវបានប្រមូលឱ្យពួកគេដោយរដ្ឋ ប្រសិនបើបទបញ្ជា ឬសេចក្តីសម្រេចស្នើកិច្ចសន្យានីមួយៗ ទទួលបានការយល់ព្រមដោយសំឡេងឆ្នោត ពីរភាគបីនៃគណៈអភិបាលនៃយុត្តាធិការនីមួយៗ ដែលជាភាគីនៃកិច្ចសន្យា។

*(c) ទោះបីជាមានផ្នែករង (a) ក៏ដោយ ខោនធី ក្រុង និងខោនធី ក្រុង និងអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានផ្សេងៗ រួមមាន ការិយាល័យអប់រំខោនធីនិងការិយាល័យសាកលវិទ្យាល័យសហគមន៍ក្នុងខោនធី ដែលជាបណ្តាភាគីនៃផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ ដែលត្រូវបានអនុម័តស្របតាមមាត្រា XI A អាចចុះកិច្ចសន្យាដើម្បីបែងចែករវាងពួកគេ និងក្នុងចំណោមពួកគេនូវ ចំណូលដែលពួកគេទទួលបានពីពន្ធយកតាមថ្លៃទំនិញ ដែលត្រូវបានលៃចែកឱ្យពួកគេ ប្រសិនបើបទបញ្ជា ឬសេចក្តីសម្រេចស្នើកិច្ចសន្យានីមួយៗ ទទួលបានការយល់ព្រមដោយសំឡេងឆ្នោត ពីរភាគបីនៃគណៈអភិបាលនៃយុត្តាធិការនីមួយៗ ដែលជាភាគីនៃកិច្ចសន្យា។ កិច្ចសន្យាដែលបានចុះស្របតាមផ្នែកនេះ ត្រូវមានសង្គតភាពជាមួយនឹងថវិការបស់អង្គភាពចូលរួមនីមួយៗ ដែលត្រូវបានអនុម័តស្របតាមវគ្គទី 1 នៃមាត្រា XI A ។*

វគ្គទី 9. ជំពូក 6 (ចាប់ផ្តើមជាមួយផ្នែក 55750) ត្រូវបានបន្ថែមចូលភាគទី 2 នៃផ្នែកទី 2 នៃចំណងជើងទី 5 នៃក្រមស្តីពីរដ្ឋាភិបាល ដើម្បីត្រូវបកស្រាយថា ៖

*ជំពូក 6. ផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍*

*55750. (a) ទោះបីជាមានវគ្គទី 7101 នៃក្រមស្តីពីចំណូល និងពន្ធ ឬបទបញ្ញត្តិផ្សេងទៀតនៃច្បាប់ក៏ដោយ ចាប់ពីឆ្នាំសារពើពន្ធ 2013-14 តទៅ ចំនួនប្រាក់ចំណូល ប្រាក់បង្វិលសងវិញសរុប ដែលត្រូវបានប្រមូលស្របតាមផ្នែក 6051 នៃក្រមស្តីពីចំណូល និងពន្ធ និងអាចកំណត់នៅត្រឹមអត្រា 0.035 ភាគរយ ត្រូវដាក់តម្កល់នៅរតនាគារជាតិ ចូលក្នុងឥណទាននៃមូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព ដែលបានបង្កើតឡើងស្របតាមវគ្គទី 4 នៃមាត្រា XI A នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ហើយត្រូវប្រើតែម្យ៉ាងគត់សម្រាប់គោលបំណងនៃការបង្កើតមូលនិធិ។*

*(b)ដើម្បីឱ្យដល់កម្រិតដែលអង្គនីតិបញ្ញត្តិកាត់បន្ថយមូលដ្ឋានពន្ធលក់ហើយការកាត់បន្ថយនោះបណ្តាលឱ្យចំណូលទៅក្នុង មូលនិធិ ភារៈគ្រប់គ្រងនៃការអនុវត្តការងារនិងគណនេយ្យភាពតិចជាងមូលនិធិដែលទទួលបាននៅក្នុងឆ្នាំសារពើពន្ធ2013-14នោះ អ្នកត្រួត ពិនិត្យត្រូវផ្ទេរពីមូលនិធិទូទៅ ទៅកាន់មូលនិធិភារៈគ្រប់គ្រងនៃការអនុវត្តការងារនិងគណនេយ្យភាពនូវចំនួនប្រាក់ដែលនៅពេលបន្ថែមពីលើចំណូលដែលទទួលបានដោយមូលនិធិភារៈគ្រប់គ្រងនៃការអនុវត្តការងារនិងគណនេយ្យភាពនៅក្នុងឆ្នាំសារពើពន្ធនោះស្មើនឹងចំនួនប្រាក់ចំណូល ដែលបានទទួលនៅក្នុងឆ្នាំសារពើពន្ធ 2013-14។*

*55751. (a) ទោះបីជាមានវគ្គទី 7101នៃក្រមស្តីពីចំណូល និងពន្ធ ឬបទបញ្ញត្តិផ្សេងទៀតនៃច្បាប់ក៏ដោយ ចាប់ពីឆ្នាំសារពើពន្ធ 2013-14 តទៅ ចំនួនប្រាក់ចំណូល ប្រាក់បង្វិលសងវិញសរុប ដែលត្រូវបានប្រមូលស្របតាមផ្នែក 6201 នៃក្រមស្តីពីចំណូល និងពន្ធ និងងអាចកំណត់នៅត្រឹមអត្រា 0.035ភាគរយ ត្រូវដាក់តម្កល់នៅរតនាគារជាតិ ចូលក្នុងឥណទាននៃមូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព ដែលបានបង្កើតឡើងស្របតាមវគ្គទី 4 នៃមាត្រា XI A នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ហើយត្រូវប្រើតែម្យ៉ាងគត់សម្រាប់គោលបំណងនៃការបង្កើតមូលនិធិ។*

*(b) ដើម្បីឱ្យដល់កម្រិតដែលអង្គនីតិបញ្ញត្តិ កាត់បន្ថយមូលដ្ឋានពន្ធលក់ ហើយការកាត់បន្ថយនោះបណ្តាលឱ្យចំណូលក្នុងមូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព តិចជាងមូលនិធិ ដែលទទយលបាននៅក្នុងឆ្នាំសារពើពន្ធ 2013-14 នោះ អ្នកត្រួតពិនិត្យត្រូវផ្ទេរពីមូលនិធិទូទៅ ទៅកាន់មូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព នូវចំនួនប្រាក់ដែលនៅពេលបន្ថែមពីលើចំណូល ដែលទទួលបានដោយ មូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព នៅក្នុងឆ្នាំសារពើពន្ធនោះ ស្មើនឹងចំនួនប្រាក់ចំណូល ដែលបានទទួលនៅក្នុងឆ្នាំសារពើពន្ធ 2013-14។*

*55752. (a) នៅឆ្នាំសារពើពន្ធ 2014-15 និងរាល់ឆ្នាំសារពើពន្ធបន្តបន្ទាប់ អ្នកត្រួតពិនិត្យ ត្រូវចែកចាយមូលនិធិ នៅក្នុងមូលនិធិមរតកនៃការអនុវត្តការងារ*

31

និងគណនេយ្យភាព ដែលបានបង្កើតឡើងស្របតាមវគ្គទី 4 នៃមាត្រា XI A នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ទៅឱ្យខោនធីនីមួយៗ ដែលបានអនុម័តផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ ដែលមានចូលជាធរមាននៅថ្ងៃទី ឬមុនថ្ងៃទី 30 ខែមិថុនា នៃឆ្នាំសារពើពន្ធមុន និងបានដាក់ផែនការសកម្មភាពរបស់ខ្លួន ជូនអ្នកត្រួតពិនិត្យ សម្រាប់គោលបំណងស្នើសុំការផ្តល់មូលនិធិក្រោមផ្នែកនេះ។ ការចែកចាយ ត្រូវធ្វើឡើងនៅក្នុងត្រីមាសទីមួយនៃឆ្នាំសារពើពន្ធ។ ក្នុងចំណោមចំនួនប្រាក់សរុប ដែលមានលទ្ធភាពប្រើប្រាស់បាន សម្រាប់ចែកចាយពី មូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព នៅក្នុងឆ្នាំសារពើពន្ធមួយ អ្នកត្រួតពិនិត្យត្រូវបែងចែកដល់ខោនធីនីមួយៗ នូវមូលនិធិមរតកនៃការអនុវត្តការងារ និងគណនេយ្យភាព ដែលបានបង្កើត ដើម្បីជួយសម្រួលដល់ការផ្តល់មូលនិធិដល់ផែនការសកម្មភាពរបស់ខ្លួន ចំនួនមួយភាគរយដែលស្មើនឹងភាគរយ ដែលបានគណនាសម្រាប់ខោនធីនោះ ក្រោមផ្នែករង (c)។

(b) ដូចដែលប្រើនៅក្នុងផ្នែកនេះ ចំនួនប្រជាជនដែលបម្រើដោយផែន ការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ គឺជាចំនួនប្រជាជននៃតំបន់ភូមិសាស្ត្រ ដែលជាចំនួនសរុបនៃចំនួនប្រជាជន នៃអង្គភាពរដ្ឋាភិបាលក្នុងមូលដ្ឋានដែលបានចូលរួមទាំងអស់ ឱ្យតែប្រជាជនដែលបម្រើដោយអង្គភាពរដ្ឋា ភិបាលក្នុងមូលដ្ឋានមួយ ឬច្រើន ត្រូវបានរាប់តែម្តងគត់។ ផែនការសកម្មភាព ត្រូវដាក់បញ្ចូលនូវការគណនាចំនួនប្រជាជន នៃតំបន់ភូមិសាស្ត្រ ដែលបម្រើដោយផែនការសកម្មភាពយោងតាមទិន្នន័យភូមិសាស្ត្រថ្មីបំផុតរបស់ក្រសួងហិរញ្ញវត្ថុ។

(c) អ្នកត្រួតពិនិត្យ ត្រូវកំណត់ចំនួនប្រជាជន ដែលបម្រើដោយផែនការសកម្មភាពរបស់ខោនធីនីមួយៗ ជាចំនួនមួយភាគរយនៃចំនួនប្រជាជនសរុប ដែលបានគណនាសម្រាប់ផែនការសកម្មភាពទាំងអស់ ដែលមានសិទ្ធិទទួលបានការផ្តល់មូលនិធិ ស្របតាមផ្នែករង (a)។

(d) មូលនិធិដែលបានផ្តល់ ស្របតាមវគ្គទី 4 នៃមាត្រា XIA នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា និងជំពូកនេះ តំណាងជាផ្នែកឱ្យប្រាក់សន្សំ ដែលកំពុងដំណើរការ ដែលផ្តល់ចំណូលដល់រដ្ឋ ដែលអាចកំណត់បានចំពោះការតម្រឹមឡើងវិញក្នុងឆ្នាំ 2011 និងចំពោះការវាស់វែងដែលបានបន្ថែមផ្នែកនេះ។ រយៈពេលបួនឆ្នាំ បន្ទាប់ពីការបែងចែកមូលនិធិលើកទីមួយស្របតាមផ្នែកនេះ ការិយាល័យអ្នកវិភាគនីតិបញ្ញត្តិ ត្រូវវាយតម្លៃផលប៉ះពាល់សារពើពន្ធនៃផែនការសកម្មភាព និងកម្រិតដែលផែនការបានកែលម្អប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្តល់សេវា ឬបានកាត់បន្ថយតំរូវការសេវាដែលផ្តល់មូលនិធិដោយរដ្ឋ។

វគ្គទី 10.វគ្គទី 42246ត្រូវបានបន្ថែមចូលក្នុងក្រមស្តីពីការអប់រំ ដើម្បីចែងថា៖

42246. មូលនិធិដែលបានចូលរួមវិភាគទាន ឬបានទទួលដោយការិយាល័យអប់រំខោនធី ស្របតាមការចូលរួមរបស់ខ្លួននៅក្នុង ផែនការសកម្មភាពយុទ្ធសាស្ត្រសហគមន៍ ដែលបានអនុញ្ញាតដោយមាត្រា XI A នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ាមិនត្រូវយកមកពិចារណានៅក្នុងការគណនាចំណែករបស់រដ្ឋអំពីកម្រិតចំណូលរបស់ខោនធីក្រោមផ្នែក42238ឬលក្ខន្តិកៈអ្នកបន្តវេនណាមួយ។

វគ្គទី11.វគ្គទី9145ត្រូវបានបន្ថែមចូលក្នុងក្រមស្តីពីរដ្ឋាភិបាលដើម្បីចែងថា៖

9145. សម្រាប់គោលបំណងនៃវគ្គទី 9.5 និង 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា និយមន័យខាងក្រោម ត្រូវបានអនុវត្ត ៖

(a) "ពង្រីកវិសាលភាពនៃកម្មវិធី ឬទីភ្នាក់ងារដែលមានស្រាប់របស់រដ្ឋ" មិនរាប់បញ្ចូលចំណុចដូចខាងក្រោមទេ ៖

(1) ការស្តារការផ្តល់និធិដល់ទីភ្នាក់ងារ ឬកម្មវិធីមួយ ដែលត្រូវបានកាត់បន្ថយឬលុបបំបាត់នៅក្នុងឆ្នាំសារពើពន្ធណាមួយបន្តពីឆ្នាំសារពើពន្ធ2008-09 ដើម្បីធ្វើឱ្យមានតុល្យភាពថវិកា ឬដោះស្រាយឱនភាពដែលបានព្យាករទុក។

(2) បង្កើនការផ្តល់មូលនិធិរបស់រដ្ឋដល់កម្មវិធី ឬទីភ្នាក់ងារមួយ ដើម្បីផ្តល់មូលនិធិដល់ការទទួលខុសត្រូវតាមលក្ខន្តិកៈជាធរមានរបស់ខ្លួន រួមមានការកើនឡើងនូវថ្លៃទ្រទ្រង់ជីវភាព ឬបន្ទុកការងារ និងរាល់ការកើនឡើងណាដែលបានអនុញ្ញាតដោយអនុស្សារណៈព្រមព្រៀង ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិ។

(3) កំណើននៃការផ្តល់មូលនិធិរបស់រដ្ឋ សម្រាប់កម្មវិធី ឬទីភ្នាក់ងារមួយ ដូចដែលបានតំរូវដោយច្បាប់សហព័ន្ធ ឬច្បាប់ដែលចូលជាធរមាន ចាប់ពីថ្ងៃប្រសិទ្ធភាពនៃវិធានការដែលបន្ថែមផ្នែកនេះ។

(4) ការផ្តល់មូលនិធិដើម្បីគ្រប់ដណ្តប់លើចំណាយតែមួយលើក សម្រាប់កម្មវិធី ឬទីភ្នាក់ងារមួយរបស់រដ្ឋ ដូចដែលបានកំណត់នៅក្នុងលក្ខន្តិកៈ ដែលផ្តល់វិភាជន៍ដល់ការផ្តល់មូលនិធិ។

(5) ការផ្តល់មូលនិធិសម្រាប់លក្ខខណ្ឌតំរូវ ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ (5) នៃផ្នែករង (b) នៃវគ្គទី 6 នៃមាត្រា XIIIB នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា។

(b) "ខ្ទង់ចំណាយរបស់រដ្ឋ" មិនរួមបញ្ចូលនូវខ្ទង់ចំណាយទាំងឡាយណា ដែលកើតឡើងពីការទូទាត់ប្រាក់ដើម ឬការប្រាក់លើកាតព្វកិច្ចទូទៅរបស់រដ្ឋឡើយ។

(c) "ចំណូលបន្ថែម" រួមបញ្ចូល ប៉ុន្តែមិនកម្រិតចំពោះ ចំណូលចូលរដ្ឋដែលបណ្តាលមកពីការផ្លាស់ប្តូរជាក់លាក់ ដែលធ្វើឡើងដោយច្បាប់សហព័ន្ធ ឬច្បាប់រដ្ឋ ហើយភ្នាក់ងាររដ្ឋដែលទទួលខុសត្រូវចំពោះការប្រមូលចំណូល បានកម្រិតចំនួន និងកំណត់ជាកំណើនមាននិរន្តរភាព។

វគ្គទី 12. វគ្គទី 11802 ត្រូវបានបន្ថែមចូលក្នុងក្រមស្តីពីរដ្ឋាភិបាល ដើម្បីត្រូវបកស្រាយថា៖

11802. មុនថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2013 បន្ទាប់ពីប្រឹក្សាជាមួយនិយោជិករបស់រដ្ឋ និងបណ្តាភាគីដែលមានចំណាប់អារម្មណ៍រួចហើយ អភិបាលត្រូវដាក់ជូនអង្គនីតិបញ្ញត្តិនូវផែនការមួយ ដើម្បីអនុវត្តបទបញ្ញត្តិផ្តល់ថវិកាផ្អែកលើការអនុវត្តការងារ នៃវគ្គទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា។ ផែនការនោះ ត្រូវមានការអនុវត្តពេញលេញ ក្នុងឆ្នាំសារពើពន្ធ 2015-16 និងនៅក្នុងឆ្នាំសារពើពន្ធបន្តបន្ទាប់នីមួយៗ។

វគ្គទី 13. វគ្គទី 13308.03 ត្រូវបានបន្ថែមចូលក្នុងក្រមស្តីពីរដ្ឋាភិបាលដូចខាងក្រោម៖

13308.03. បន្ថែមពីលើលក្ខខណ្ឌតំរូវ ដែលមានចែងនៅក្នុងផ្នែក 13308 ប្រធាននាយកដ្ឋានហិរញ្ញវត្ថុត្រូវ៖

(a) នៅត្រឹមថ្ងៃទី 15 ខែឧសភា ដាក់ជូនអង្គនីតិបញ្ញត្តិ និងធ្វើឱ្យសាធារណជនមានលទ្ធភាពអាចប្រើប្រាស់បាននូវ បច្ចុប្បន្នភាពនៃការគន់គូរជាមុនអំពីចំណូលរបស់រដ្ឋ និងចំណាយរបស់រដ្ឋ សម្រាប់ឆ្នាំថវិកា និងឆ្នាំសារពើពន្ធបន្ត ដូចដែលបានស្នើនៅក្នុងសេចក្តីព្រាងច្បាប់ថវិកាដែលព្យួរចោលនៅក្នុងសភាមួយ ឬទាំងពីរនៃអង្គនីតិបញ្ញត្តិ ឬដូចដែលបានផ្តល់វិភាជន៍នៅក្នុងសេចក្តីព្រាងច្បាប់ថវិកាដែលបានអនុម័តរួច តាមដែលអាចអនុវត្តបាន។

(b) ភ្លាមៗមុនពេលអនុម័តថវិការយៈពេលពីរឆ្នាំ ឬថវិកាបំពេញបន្ថែមណាមួយដោយអង្គនីតិបញ្ញត្តិ ដាក់ជូនអង្គនីតិបញ្ញត្តិនូវរបាយការណ៍ អំពីចំណូលសរុប និងចំណាយសរុប សម្រាប់ឆ្នាំថវិកា និងឆ្នាំសារពើពន្ធបន្ត ដែលត្រូវរួមបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ថវិកា។

(c) ត្រឹមថ្ងៃទី 30 ខែវិច្ឆិកា រៀងរាល់ឆ្នាំ ដាក់ជូនអង្គនីតិបញ្ញត្តិនូវ បច្ចុប្បន្នភាពនៃសារពើពន្ធ ដែលមានចំណូល និងចំណាយជាក់ស្តែងក្នុងឆ្នាំបច្ចុប្បន្ន សម្រាប់ឆ្នាំបច្ចុប្បន្ន ប្រៀបធៀបទៅនឹងចំណូល និងចំណាយដែលមានចែងនៅក្នុងថវិកាដែលបានអនុម័ត។ លក្ខខណ្ឌតំរូវនេះ អាចត្រូវបានបំពេញដោយការបោះពុម្ពផ្សាយនូវ របាយការណ៍ទស្សនវិស័យសារពើពន្ធ ដោយការិយាល័យអ្នកវិភាគរបស់អង្គនីតិបញ្ញត្តិ។

វគ្គទី 14. វិសោធនកម្ម

បទបញ្ញត្តិតាមលក្ខន្តិកៈនៃវិធានការនេះ អាចត្រូវបានធ្វើវិសោធនកម្មជាឯកឆន្ទ ដើម្បីជ្រោមជ្រែងគោលបំណងនៃវិធានការនេះ ដោយសេចក្តីព្រាងច្បាប់មួយដែលអនុម័តដោយ សំឡេងឆ្នោតពីរភាគបីនៃសមាជិកសភានីមួយៗរបស់អង្គនីតិបញ្ញត្តិ និងចុះហត្ថលេខាដោយអភិបាល។

វគ្គទី 15. ឧបំរុង

ប្រសិនបើបទបញ្ញត្តិណាមួយនៃវិធានការនេះ ឬភាពអាចអនុវត្តបាននៃបទបញ្ញត្តិណាមួយ នៃវិធានការនេះ ចំពោះបុគ្គលណាម្នាក់ ឬកាលៈទេសៈនានា ត្រូវបានរកឃើញថាផ្ទុយពីរដ្ឋធម្មនុញ្ញ ឬអសុពលភាព ការរកឃើញនោះមិនត្រូវប៉ះពាល់ដល់បទបញ្ញត្តិ ឬការអនុវត្តវិធានការនេះ ចំពោះបុគ្គល ឬកាលៈទេសៈដទៃទៀតឡើយ ហើយចំពោះកម្រិតនេះ បទបញ្ញត្តិទាំងឡាយនៃវិធានការនេះ ត្រូវបានចាត់ទុកថាជាឧបំរុង។

វគ្គទី 16. ថ្ងៃចូលជាធរមាន

វគ្គទី 4 ទី 5 និងទី 6 នៃច្បាប់នេះ ត្រូវអាចប្រើប្រាស់បាន នៅថ្ងៃច័ន្ទដំបូងនៃ

ខែធ្នូ ឆ្នាំ 2014។ ដរាបណាមានបញ្ហាក់នៅក្នុងច្បាប់ ផ្នែកដទៃទៀតនៃច្បាប់ ត្រូវអាចប្រើប្រាស់បាន នៅក្រោយថ្ងៃបោះឆ្នោត ដែលច្បាប់នេះត្រូវបានអនុម័ត។

វគ្គទី 17. អ្នកប្រឹក្សាអង្គនិតិបញ្ញត្តិ

(a) អ្នកដែលរកឃើញ និងប្រកាសថា វិសោធនកម្មដែលបានស្នើដោយវិធានការនេះ ទៅលើវគ្គទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា មានសង្គតភាពជាមួយនឹងវិសោធនកម្ម ទៅលើទៅលើវគ្គទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ដែលបានស្នើដោយ វិសោធនកម្មរដ្ឋធម្មនុញ្ញលេខ 4 របស់សភា នៃសម័យប្រជុំសាមញ្ញឆ្នាំ 2009-10 (សម័យប្រជុំសាមញ្ញជំពូក 174 ស្ថិតិឆ្នាំ 2010) (ចាប់ពីពេលនេះតទៅហៅថា វិសោធនកម្មរដ្ឋធម្មនុញ្ញលេខ 4 របស់សភា) ដែលនឹងលេចឡើងនៅលើការបោះឆ្នោតសាកលទូទាំងរដ្ឋ នៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2014។

(b) សម្រាប់គោលបំណងនៃការរៀបចំ និងអានកែសម្រួលរបស់ក្រុមប្រឹក្សាច្បាប់ អំពីអត្ថបទ វិសោធនកម្មរដ្ឋធម្មនុញ្ញលេខ 4 (ACA 4)របស់សភា ស្របតាមវគ្គទី 9086 និង 9091 នៃក្រមស្តីពីការបោះឆ្នោត និងវគ្គទី 88002 និង 88005.5 នៃក្រមស្តីពីរដ្ឋាភិបាល បទបញ្ញត្តិជាធរមាននៃវគ្គទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ត្រូវចាត់ទុកថាជាបទបញ្ញត្តិទាំងឡាយរបស់ផ្នែកនោះ ដូចដែលបានធ្វើវិសោធនកម្មដោយវិធានការនេះ។ ក្រុមប្រឹក្សាច្បាប់ ត្រូវរៀបចំ និងអានកែសម្រួលអត្ថបទនៃវិសោធនកម្មរដ្ឋធម្មនុញ្ញលេខ 4 របស់សភា ទៅតាមនោះដែរ ដើម្បីរើកញែកការផ្លាស់ប្តូរដែលបានស្នើដោយ វិសោធនកម្មរដ្ឋធម្មនុញ្ញលេខ 4 របស់សភា ទៅលើវគ្គទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ពីបទបញ្ញត្តិទាំងឡាយនៃវគ្គទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ដូចដែលបានធ្វើវិសោធនកម្មដោយវិធានការនេះ។ រដ្ឋលេខាធិការ ត្រូវដាក់អត្ថបទទាំងស្រុងនៃវិសោធនកម្មរដ្ឋធម្មនុញ្ញលេខ 4 របស់សភា ដូចដែលបានរៀបចំ និងអានកែសម្រួលដោយក្រុមប្រឹក្សាច្បាប់ ស្របតាមផ្នែកនេះ ទៅក្នុងកូនសៀវភៅផ្សព្វផ្សាយការបោះឆ្នោត សម្រាប់ការបោះឆ្នោតសាកលទូទាំងរដ្ឋ នៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ2014។

## សំណើប្រជាមតិ 32

វិធានការប្រជានុម័តនេះត្រូវបានដាក់អោយប្រជាពលរដ្ឋដោយអនុលោមទៅតាម ខដែលមានចែងនៃវគ្គទី 8មាត្រា II នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

វិធានការប្រជានុម័តនេះបន្ថែមផ្នែកខ្លះទៅលើក្រមរដ្ឋាភិបាល ដូចនេះខចែងថ្មីៗដែលបានស្នើដើម្បីបន្ថែម ត្រូវបោះពុម្ពចេញ ជា*លក្ខណៈអក្សរទ្រេត*ដើម្បីបញ្ជាក់ថាវាថ្មី។

## ច្បាប់ដែលស្នើ

វគ្គទី 1. ចំណងជើង លទ្ធផល និងការប្រកាសអំពីគោលបំណង

A. អត្ថប្រយោជន៍ពិសេស មានអំណាចខ្លាំងពេកលើរដ្ឋាភិបាល។ ជារៀងរាល់ឆ្នាំ សាជីវកម្ម និងសហជីព ផ្តល់វិភាគទានប្រាក់រាប់លានដុល្លារដល់អ្នកនយោបាយ ហើយអត្ថប្រយោជន៍សាធារណៈ ត្រូវបានកប់នៅក្រោមភ្នំចំណាយអត្ថប្រយោជន៍ពិសេស។

B. ក៏ប៉ុន្តែ អស់រយៈពេលជាច្រើនឆ្នាំមកហើយ រដ្ឋាភិបាលកាលីហ្វ័រញ៉ា បានធ្វើឱ្យប្រជាជនរបស់ខ្លួនទទួលបរាជ័យ។ រដ្ឋរបស់យើងជាប់បំណុលរាប់ពាន់លានដុល្លារ ហើយរដ្ឋាភិបាលក្នុងមូលដ្ឋានជាច្រើន កំពុងជិតក្ស័យធន។ ជាញឹកញាប់ណាស់មកហើយ ដែលអ្នកនយោបាយព្រងើយកន្តើយនឹងតំរូវការរបស់សាធារណជន ដោយលម្អៀងទៅរកអត្ថប្រយោជន៍ពិសេសដ៏តូចចង្អៀត របស់សាជីវកម្ម សហជីពកម្មករ និងអ្នកម៉ៅការរបស់រដ្ឋាភិបាលដែលបានផ្តល់វិភាគទានដល់យុទ្ធនាការរបស់ពួកគេ។

C. ការផ្តល់វិភាគទានទាំងនេះផ្តល់ផលមកវិញនូវការបញ្ជ្រាប់ពន្ធពិសេស និងកិច្ចសន្យាសាធារណៈសម្រាប់អាជីវកម្មធំៗ និងវិធីរដ្ឋាភិបាលដែលមានចំណាយច្រើន ដែលធ្វើឱ្យមានសហជីពកម្មករឯកជន និងសោធនិវត្តន៍ អត្ថប្រយោជន៍បៀវត្សរ៍គ្មាននិរន្តរភាពសម្រាប់សមាជិកសហជីពនិយោជិកសាធារណៈ ដែលទាំងអស់នេះ គឺជាចំណាយរបស់អ្នកជាប់ពន្ធរបស់រដ្ឋកាលីហ្វ័រញ៉ា។

D. ទោះបីការផ្តល់វិភាគទានមានកម្រិតក៏ដោយ នៅក្នុងយុត្តាធិការខ្លះពុំបានបង្អង់ល្បឿន នៃលំហូរប្រាក់នយោបាយរបស់សាជីវកម្ម និងសហជីពចូលទៅក្នុងដំណើរការនយោបាយទេ។ លុយជាច្រើនដែលលើសលុបទៅលើនយោបាយរបស់កាលីហ្វ័រញ៉ា បានចាប់ផ្តើមជាការកាត់ដោយស្វ័យប្រវត្តិពីមូលប្បទានប័ត្របើកបៀវត្សរ៍របស់បុគ្គលិក។ និយោជកសាជីវកម្ម និងសហជីពតែងតែដាក់សម្ពាធ ជួនកាលដោយប្រើកលល្បិច និងជួនកាលដោយបើកចំហ ឱ្យបុគ្គលិកបោះបង់មួយភាគនៃមូលប្បទានប័ត្របើកបៀវត្សរ៍ របស់ពួកគេ ដើម្បីឧបត្ថម្ភគាំទ្រដល់គោលបំណងនយោបាយរបស់សាជីវកម្ម ឬសហជីព។ គោលបំណងរបស់ពួកគេគឺ ដើម្បីប្រមូលលុយរាប់លានដុល្លារ ដើម្បីទទួលបានឥទ្ធិពលជាមួយអ្នកដឹកនាំឈ្នះឆ្នោតរបស់យើង ដោយគ្មានការទាក់ទិននឹងនិន្នាការនយោបាយ របស់និយោជិកដែលផ្តល់ប្រាក់ឡើយ។

E. ដោយសារមូលហេតុទាំងនេះហើយ និងដើម្បីទប់ស្កាត់អំពើពុករលួយជាក់ស្តែង និងការលេចឡើងនូវអំពើពុករលួយនៃរដ្ឋាភិបាលរបស់យើង ដោយសារការផ្តល់វិភាគទានពីសាជីវកម្ម និងសហជីពកម្មករ ប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ា សូមអនុម័តច្បាប់ស្តីពីការបញ្ឈប់លុយអត្ថប្រយោជន៍ពិសេសឥឡូវនេះ (Stop Special Interest Money Now Act ) ដើម្បី ៖

1. ហាមប្រាមការផ្តល់វិភាគទានពីសាជីវកម្ម និងសហជីពកម្មករដល់បេក្ខជន

2. ហាមឃាត់អ្នកម៉ៅការរបស់រដ្ឋាភិបាល មិនឱ្យផ្តល់វិភាគទានជាលុយទៅឱ្យមន្ត្រីរដ្ឋាភិបាល ដែលផ្តល់កិច្ចសន្យាដល់ពួកគេ

3. ហាមឃាត់សាជីវកម្ម និងសហជីពកម្មករ មិនឱ្យប្រមូលមូលនិធិនយោបាយ ពីនិយោជិក និងសមាជិកសហជីព ដោយប្រើមធ្យោបាយបង្គាប់បញ្ជាឱ្យកាត់បន្ថយប្រាក់ ពីបញ្ជីបើកប្រាក់បៀវត្សរ៍ និង

4. ធ្វើឱ្យការផ្តល់វិភាគទានប្រាក់នយោបាយរបស់និយោជិកទាំងអស់ ធ្វើឡើងដោយមធ្យោបាយផ្សេងៗដែលមានលក្ខណៈស្ម័គ្រចិត្តទាំងស្រុង។

វគ្គទី 2. ច្បាប់ស្តីពីការបញ្ឈប់លុយអត្ថប្រយោជន៍ពិសេសឥឡូវនេះ

មាត្រា 1.5 (ចាប់ផ្តើមដោយវគ្គទី 85150) ត្រូវបានបន្ថែមចូលជំពូក 5 នៃចំណងជើងទី 9 នៃក្រមស្តីពីរដ្ឋាភិបាល ត្រូវបកស្រាយថា៖

*មាត្រា 1.5 ច្បាប់ស្តីពីការបញ្ឈប់លុយអត្ថប្រយោជន៍ពិសេសឥឡូវនេះ*

*85150. (a) ទោះបីជាមានបទបញ្ញត្តិណាមួយផ្សេងទៀតនៃច្បាប់ និងចំណងជើងនេះ មិនត្រូវមានសាជីវកម្ម សហជីពកម្មករ ឬសហ ជីពកម្មករនិយោជិកសាធារណៈណាមួយ ធ្វើការផ្តល់វិភាគទានដល់បេក្ខជនណាម្នាក់ គណៈកម្មាធិការដែលគ្រប់គ្រងដោយបេក្ខជន ឬគណៈកម្មាធិការផ្សេងណាមួយ រួមទាំងគណៈកម្មាធិការគណបក្សនយោបាយឡើយ ប្រសិនបើមូលនិធិនោះ នឹងត្រូវប្រើសម្រាប់ផ្តល់វិភាគទានដល់បេក្ខជនណាម្នាក់ ឬគណៈកម្មាធិការដែលគ្រប់គ្រងដោយបេក្ខជន។*

*(b) ទោះបីជាមានបទបញ្ញត្តិណាមួយផ្សេងទៀតនៃច្បាប់ និងចំណងជើងនេះ មិនត្រូវមានអ្នកម៉ៅការរបស់រដ្ឋាភិបាល ឬគណៈកម្មាធិការដែលឧបត្ថម្ភដោយអ្នកម៉ៅការរបស់រដ្ឋាភិបាល ធ្វើការផ្តល់វិភាគទានដល់មន្ត្រីជាប់ឆ្នោតណាម្នាក់ ឬគណៈកម្មាធិការដែលគ្រប់គ្រងដោយមន្ត្រីជាប់ឆ្នោតណាម្នាក់ ប្រសិនបើមន្ត្រីជាប់ឆ្នោតនោះ បង្កើត ចូលរួមក្នុងការបង្កើត ឬប្រើវិធីណាមួយប៉ុនប៉ងប្រើមុខតំណែងជាមន្ត្រីរបស់ខ្លួន ក្នុងការជះឥទ្ធិពលទៅលើការផ្តល់ការអនុញ្ញាត ឬប្រគល់កិច្ចសន្យាសាធារណៈដល់អ្នកម៉ៅការរបស់រដ្ឋាភិបាល ក្នុងអំឡុងពេលធ្វើការសម្រេចផ្តល់ អនុញ្ញាត ឬប្រគល់កិច្ចសន្យា ឬក្នុងអំឡុងអាណត្តិនៃកិច្ចសន្យា។*

*85151. (a) ទោះបីជាមានបទបញ្ញត្តិណាមួយផ្សេងទៀតនៃច្បាប់ និងចំណងជើងនេះ មិនត្រូវមានសាជីវកម្ម សហជីពកម្មករ និយោជិកសាធារណៈ អ្នកម៉ៅការរបស់រដ្ឋាភិបាល ឬនិយោជករបស់រដ្ឋាភិបាល កាត់ប្រាក់បៀវត្សរ៍ ប្រាក់ចំណូល ឬប្រាក់សំណងសម្រាប់និយោជិក ក្នុងចំនួនណាមួយ ដើម្បីយកទៅប្រើប្រាស់សម្រាប់គោលបំណងនយោបាយឡើយ។*

*(b) ផ្នែកនេះ មិនត្រូវហាមឃាត់និយោជិកណាម្នាក់ មិនឱ្យផ្តល់វិភាគទានដោយស្ម័គ្រចិត្ត ដល់គណៈកម្មាធិការដែលទទួលបានការឧបត្ថម្ភ នៃនិយោជករបស់ខ្លួន សហជីពកម្មករ សហជីពកម្មករនិយោ ជិកសាធារណៈ ក្នុងលក្ខណៈណាមួយ ក្រៅពីអ្វីដែលបានហាមឃាត់ដោយផ្នែករង (a) ឡើយ ឱ្យតែវិភាគទានទាំងអស់នោះ ត្រូវបានផ្តល់ឱ្យដោយមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីនិយោជិក ដែលការយល់ព្រមនេះ ត្រូវមានសុពលភាពមិនលើសពីមួយឆ្នាំឡើយ។*

*(c) ផ្នែកនេះ មិនត្រូវអនុវត្តចំពោះកាត់ទៅលើអត្ថប្រយោជន៍ចូល និវត្តន៍ការធានារ៉ាប់រងផ្នែកសុខភាព ជីវិត មរណៈភាព ឬពិការភាព ឬអត្ថ ប្រយោជន៍ផ្សេងៗស្រដៀងគ្នានេះ ហើយមិនត្រូវអនុវត្តចំពោះការស្ម័គ្រចិត្តឱ្យកាត់ដោយនិយោជិក ទៅលើអត្ថប្រយោជន៍អង្គការមនុស្សធម៌ ដែលត្រូវបានរៀបចំឡើងក្រោមផ្នែក 501 (c)(3) នៃចំណងជើងទី 26 នៃក្រមរបស់សហរដ្ឋលេខ។*

*85152 សម្រាប់គោលបំណងនៃមាត្រានេះ និយមន័យខាងក្រោមត្រូវអនុវត្តៈ*

*(a) "សាជីវកម្ម" មានន័យថា រាល់សាជីវកម្មដែលត្រូវបានរៀបចំឡើងក្រោមច្បាប់របស់រដ្ឋនេះ រដ្ឋដទៃទៀតរបស់សហរដ្ឋ ឬខានធីកូឡុំប៊ី ឬក្រោមច្បាប់សហសភារបស់សហរដ្ឋ។*

*(b) "អ្នកម៉ៅការរបស់រដ្ឋាភិបាល" មានន័យថា បុគ្គលណាក៏ដោយ ក្រៅពីនិយោជិករបស់និយោជករបស់រដ្ឋាភិបាល ដែលជាភាគីនៃកិច្ចសន្យារវាងបុគ្គលនោះ និងនិយោជករបស់រដ្ឋាភិបាល ដើម្បីផ្តល់ទំនិញ អចលនទ្រព្យ ឬសេវាជូននិយោជករបស់រដ្ឋាភិបាល។ អ្នកម៉ៅការរបស់រដ្ឋាភិបាល រួមបញ្ចូលទាំង សហជីពកម្មករនិយោជិកសាធារណៈ ដែលជាភាគីនៃកិច្ចសន្យាជាមួយនិយោជករបស់រដ្ឋាភិបាល។*

*(c) "និយោជករបស់រដ្ឋាភិបាល" មានន័យថា រដ្ឋកាលីហ្វ័រញ៉ា ឬអង្គភាពរងនយោបាយណាមួយរបស់រដ្ឋនេះ រួមមាន ប៉ុន្តែមិនកម្រិតចំពោះ ខោនធីក្រុង ខោនធីធម្មនុញ្ញ ក្រុងធម្មនុញ្ញ ក្រុងធម្មនុញ្ញ និងខោនធី ការិយាល័យអប់រំខោនធី សាកលវិទ្យាល័យកាលីហ្វ័រញ៉ា ខោនធី គណៈកម្មាធិការ គណៈកម្មការ និងទីភ្នាក់ងារពិសេស ប៉ុន្តែមិនរាប់បញ្ចូលរដ្ឋាភិបាលសហរដ្ឋ ឡើយ។*

*(d) "សហជីពកម្មករ" មានន័យថា អង្គភាពគ្រប់ប្រភេទ ឬទីភ្នាក់ងារណាមួយ ឬគណៈកម្មាធិការតំណាងនិយោជិក ឬផែនការ ដែលក្នុងនោះនិយោជិកចូលរួម ហើយដែលមានអត្ថិភាពសម្រាប់គោលបំណងដោះស្រាយជាមួយនិយោជក ទាក់ទងនឹងបណ្តឹងតវ៉ាអំពីលក្ខខណ្ឌការងារ ទំនាស់ការងារ ប្រាក់បៀវត្សរ៍ អត្រាប្រាក់បៀវត្សរ៍ ម៉ោងធ្វើការលក្ខខណ្ឌការងារ។*

*(e) "គោលបំណងនយោបាយ" មានន័យថា ប្រាក់ដែលបានបង់ដើម្បីជះឥទ្ធិពល ឬប៉ុនប៉ងជះឥទ្ធិពលទៅលើសកម្មភាពរបស់អ្នកបោះឆ្នោតជ្រើសរើស ឬប្រឆាំងនឹងការតែងតាំង ឬការបោះឆ្នោតជ្រើសរើសបេក្ខជនម្នាក់ ឬច្រើននាក់ឬគុណវុឌ្ឍិឬការអនុម័តវិធានការណាមួយឬការទូទាត់ប្រាក់ណាមួយដែលទទួលបានដោយឬធ្វើឡើងតាមការបង្គាប់បញ្ជារបស់បេក្ខជនគណៈកម្មាធិការដែលគ្រប់គ្រងដោយបេក្ខជនគណៈកម្មាធិការនៃគណបក្សនយោបាយរួមទាំងគណៈកម្មាធិការកណ្តាលរបស់រដ្ឋ ឬអង្គភាពដែលត្រូវបានបង្កើតឡើង ឬមានអត្ថិភាពជាចម្បងសម្រាប់គោលបំណងនយោបាយរួមមានប៉ុន្តែមិនកម្រិតចំពោះគណៈកម្មាធិការសកម្មភាពនយោបាយដែលត្រូវបានបង្កើតឡើងដោយអង្គភាពសមាជិកភាពសហជីពកម្មករសហជីពកម្មករនិយោជិកសាធារណៈឬសាជីវកម្ម។*

*(f) "សហជីពកម្មករនិយោជិកសាធារណៈ" មានន័យថា សហជីពកម្មករដែលក្នុងនោះ និយោជិកដែលចូលរួមនៅក្នុងសហជីពកម្មរ គឺជានិយោជិករបស់និយោជករបស់រដ្ឋាភិបាល។*

*(g) ពាក្យបច្ចេកទេសផ្សេងៗ ដែលប្រើដោយមាត្រានេះ ដែលត្រូវបានកំណត់និយមន័យដោយ ច្បាប់កំណែទម្រង់នយោបាយឆ្នាំ 1974 ដូចដែលបានធ្វើវិសោធនកម្ម (ចំណងជើងទី 9 (ចាប់ផ្តើមដោយវគ្គទី 81000)) ឬដោយនិយ័តកម្មដែលអនុម័តដោយគណៈកម្មការអនុវត្តនយោបាយយុត្តិធម៌ (Fair Political Practices Commission) ត្រូវមានអត្ថន័យដូចគ្នានឹងទីនេះ ដូចដែលបានចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2011។*

វគ្គទី 3. ការអនុវត្ត

(a) ប្រសិនបើបទបញ្ញត្តិណាមួយនៃវិធានការនេះ ឬផ្នែកណាមួយរបស់វា ឬការអនុវត្តបទបញ្ញត្តិ ឬផ្នែករបស់វា ចំពោះបុគ្គល អង្គភាព ឬកាលៈទេសៈណាមួយ គឺសម្រាប់មូលហេតុណាមួយ ដែលអសុពលភាព ឬផ្ទុយពីរដ្ឋធម្មនុញ្ញនោះបទបញ្ញត្តិផ្នែកនិងការអនុវត្តទាំងឡាយដែលនៅសេសសល់ត្រូវនៅមានសុពលភាពដោយគ្មានបទបញ្ញត្តិផ្នែកឬការអនុវត្តដែលគ្មានសុពលភាព។

(b) វិធានការនេះ មិនមានបំណងជ្រៀតជ្រែកដល់កិច្ចសន្យា ឬកិច្ចព្រមព្រៀងចរចារួមដែលចូលជាធរមានឡើយ។ លើកលែងតែគ្រប់គ្រងដោយច្បាប់ទំនាក់ទំនងការងារជាតិ គ្មានកិច្ចសន្យា ឬកិច្ចព្រមព្រៀងចរចារួមថ្មី ឬធ្វើវិសោធនកម្មរួច មានសុពលភាពឡើយ ប្រសិនបើវារំលោភលើវិធានការនេះ។

(c) វិធានការនេះ ត្រូវអាចបកស្រាយបានដោយសេរី ដើម្បីបន្ថែមគោលបំណងរបស់វា។នៅក្នុងបណ្តឹងដែលប្តឹងដោយនិយោជិកឬសមាជិកសហជីពដើម្បីអនុវត្តបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះបន្ទុកត្រូវស្ថិតនៅលើនិយោជកឬសហជីពកម្មករការបង្ហាញឱ្យឃើញនូវការអនុលោមតាមបទបញ្ញត្តិទាំងនេះ។

(d) ទោះបីជាមានវគ្គទី 81012 នៃក្រមស្តីពីរដ្ឋាភិបាលក៏ដោយ បទបញ្ញត្តិទាំងឡាយនៃវិធានការនេះ អាចនឹងមិនត្រូវបានធ្វើវិសោធនកម្មដោយអង្គនីតិបញ្ញត្តិឡើយ។ វិធានការនេះ អាចនឹងត្រូវបានធ្វើវិសោធនកម្ម ឬលុបចោលដោយវិធានការផ្តួចផ្តើមជាបន្តបន្ទាប់ ឬស្របតាមផ្នែករង (c) នៃវគ្គទី 10 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ាតែប៉ុណ្ណោះ។

## សំណើប្រជាមតិ 33

វិធានការប្រជានុម័តនេះត្រូវបានដាក់អោយប្រជាពលរដ្ឋដោយអនុលោមទៅតាម ខដែលមានចែងនៃវគ្គទី 8មាត្រា II នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រ ញ៉ា។

វិធានការប្រជានុម័តនេះបន្ថែមផ្នែកមួយទៅលើក្រមស្តីពីការធានារ៉ាប់រងដូចនេះខចែងថ្មីៗដែលបានស្នើដើម្បីបន្ថែម ត្រូវបោះពុម្ពចេញជា*លក្ខណៈអក្សរទ្រេត* ដើម្បីបញ្ជាក់ថាវាថ្មី។

## ច្បាប់ដែលស្នើ

វគ្គទី 1. ចំណងជើង

វិធានការនេះត្រូវបានស្គាល់ថាជា ច្បាប់បញ្ចុះតម្លៃធានារ៉ាប់រងយានយន្តឆ្នាំ 2012។

វគ្គទី 2. ប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ាយល់ដឹង និង ប្រកាសថា៖

(a) ក្រោមច្បាប់រដ្ឋកាលីហ្វ័រញ៉ា អ្នកទទួលខុសត្រូវផ្នែកធានារ៉ាប់រងត្រូវចែងពីអត្រាតម្លៃធានារ៉ាប់រង និងកំណត់ពីការបញ្ចុះតម្លៃផ្សេងៗ ដែលក្រុមហ៊ុនធានារ៉ាប់រងយានយន្ត អាចផ្តល់ជូនអ្នកបើកបរបាន។

(b) វាជាផលប្រយោជន៍ដ៏ល្អបំផុត សម្រាប់អតិថិជនប្រើប្រាស់សេវាធានារ៉ាប់រង ក្នុងរដ្ឋកាលីហ្វ័រញ៉ា ដែលត្រូវបានគេអនុញ្ញាតឱ្យទទួលបានការបញ្ចុះតម្លៃផ្សេងៗ ប្រសិនបើពួកគេបានបន្តអនុវត្តតាម ច្បាប់ស្តីពីការធានារ៉ាប់រងចាំបាច់របស់រដ្ឋ ដោយមិនគិតពីក្រុមហ៊ុនធានារ៉ាប់រងណាមួយដែលពួកគេបានប្រើប្រាស់ឡើយ។

(c) ការបញ្ចុះតម្លៃដល់អតិថិជន សម្រាប់ការធានារ៉ាប់រងយានយន្តជាអចិន្ត្រៃយ៍ជួយលើកទឹកចិត្តឱ្យមានឥរិយាបថដែលទទួលខុសត្រូវ ការបញ្ចុះតម្លៃនោះត្រូវបានទៅលើអតិថិជនមិនមែនបានទៅលើក្រុមហ៊ុនធានារ៉ាប់រងនោះទេ។

(d) ការបញ្ចុះតម្លៃផ្ទាល់ខ្លួន ដើម្បីរក្សាការប្រើប្រាស់សេវាធានារ៉ាប់រងអចិន្ត្រៃយ៍ បង្កើតឱ្យមានការប្រកួតប្រជែង នៅក្នុងចំណោមក្រុមហ៊ុនធានារ៉ាប់រងហើយជារង្វាន់មួយ ដែលលើកទឹកចិត្តឱ្យមានអតិថិជនកាន់តែច្រើនទៅទិញនិងរក្សាការប្រើប្រាស់សេវាធានារ៉ាប់រងយានយន្ត។

វគ្គទី 3. គោលបំណង

គោលបំណងនៃវិធានការនេះ គឺដើម្បីជួយដល់អតិថិជនប្រើប្រាស់សេវាធានារ៉ាប់រង ក្នុងរដ្ឋកាលីហ្វ័រញ៉ាឱ្យទទួលបានអត្រាតម្លៃធានារ៉ាប់រងទាបប្រសិនបើពួកគេបានបន្តអនុវត្តតាមច្បាប់ស្តីពីការធានារ៉ាប់រងចាំបាច់។

វគ្គទី 4. វគ្គទី 1861.023 ត្រូវបានបន្ថែមទៅក្នុងក្រមស្តីពីការធានា រ៉ាប់រងដែលមានចែងដូចខាងក្រោម៖

*1861.023. (a) ទោះបីជាមានកថាខណ្ឌ (4) នៃផ្នែករង (a) នៃផ្នែក 1861.02 ក៏ដោយក្រុមហ៊ុនធានារ៉ាប់រងមួយអាចប្រើប្រាស់ការធានារ៉ាប់រងអចិន្ត្រៃយ៍ធ្វើជាកត្តាកំណត់តម្លៃសេវាធានារ៉ាប់រងយានយន្តដែលជាជម្រើសមួយសម្រាប់គោលនយោបាយធានារ៉ាប់រងណាមួយ ដែលស្ថិតក្រោមផ្នែក 1861.02។*

*(b) សម្រាប់គោលបំណងនៃផ្នែកនេះ "ការធានារ៉ាប់រងអចិន្ត្រៃយ៍" មានន័យថា ជាការធានារ៉ាប់រងលើយានយន្ត ដោយគ្មានរអាក់រអួលជាមួយនឹងធានាការីម្នាក់ ឬច្រើននាក់ រួមទាំងការធានារ៉ាប់រងដែលផ្តល់ជូនស្របទៅតាមផែនការហានិភ័យកំណត់លើយានយន្តរបស់រដ្ឋកាលីហ្វ័រញ៉ា (CAARP) ឬកម្មវិធីធានារ៉ាប់រងយានយន្តក្នុងតម្លៃទាបរបស់រដ្ឋកាលីហ្វ័រញ៉ា (CLCA)។*

*(1) ការធានារ៉ាប់រងអចិន្ត្រៃយ៍ ត្រូវចាត់ទុកថាមានអត្ថិភាព ប្រសិនបើមានការអាក់ខាន ក្នុងធានារ៉ាប់រងដោយសារតែការបំពេញការងារកងទ័ពយ៉ាងសកម្មរបស់អ្នកបានការធានា។*

*(2) ការធានារ៉ាប់រងអចិន្ត្រៃយ៍ ត្រូវចាត់ទុកថាមានអត្ថិភាព បើទោះបីជាមានការអាក់ខានក្នុងការធានារ៉ាប់រងរហូតដល់ 18 ខែ នៅក្នុងអំឡុងពេល 5ឆ្នាំ ចុងក្រោយ ដោយសារតែការបាត់បង់ការងារ បណ្តាលមកពីការបញ្ឈប់ពីការងារ ឬ វិស្សមកាលក៏ដោយ។*

*(3) ការធានារ៉ាប់រងអចិន្ត្រៃយ៍ ត្រូវចាត់ទុកថាមានអត្ថិភាព បើទោះបីជាមានការអាក់ខានក្នុងការធានារ៉ាប់រងមិនលើសពី 90 ថ្ងៃក្នុងអំឡុងពេល 5 ឆ្នាំកន្លងទៅ ដោយសារតែមូលហេតុណាមួយក៏ដោយ។*

*(4) កូនដែលកំពុងស្នាក់នៅជាមួយឪពុកម្តាយត្រូវបានផ្តល់ឱ្យនូវការបញ្ចុះតម្លៃសម្រាប់ការធានារ៉ាប់រងអចិន្ត្រៃយ៍ដោយផ្អែកលើសិទ្ធិស្របច្បាប់របស់ឪពុក/ម្តាយ ក្នុងការទទួលបានការបញ្ចុះតម្លៃសម្រាប់ការធានារ៉ាប់រងអចិន្ត្រៃយ៍។*

*(c) អតិថិជនដែលមិនអាចបញ្ជាក់ពីការធានារ៉ាប់រងអចិន្ត្រៃយ៍បាន ត្រូវបានផ្តល់ជូននូវការបញ្ចុះតម្លៃទៅតាមសមាមាត្រមួយ។ ការបញ្ចុះតម្លៃនេះគឺជាសមាមាត្រមួយនៃចំនួនទឹកប្រាក់ តាមអត្រានៃការកាត់បន្ថយ ដែលនឹងត្រូវបានផ្តល់ជូន ប្រសិនបើអតិថិជននោះ បានបញ្ជាក់ពីការធានារ៉ាប់រងអចិន្ត្រៃយ៍។ សមាមាត្រនេះ ឆ្លុះបញ្ចាំងពីចំនួនឆ្នាំសរុបក្នុងអំឡុងពេល 5 ឆ្នាំបន្តបន្ទាប់ចុងក្រោយបង្អស់ ដែលអតិថិជននោះត្រូវបានធានារ៉ាប់រង។*

វគ្គទី 5. វិធានការបោះឆ្នោតចំរូងចំរាស់

ក្នុងករណីដែលវិធានការនេះ និងវិធានការផ្សេងណាមួយ ឬ ច្រើនទាក់ទងនឹងអចិន្ត្រៃយ៍ភាពនៃការធានារ៉ាប់រង លេចចេញនៅលើសន្លឹកឆ្នោត នៃការបោះឆ្នោតទូទាំងរដ្ឋ នោះ បទបញ្ញត្តិនានានៃវិធានការផ្សេងៗទៀត ត្រូវបានចាត់ទុកថា ប្រឆាំងទៅនឹងវិធានការនេះ។ ក្នុងករណី ដែលវិធានការនេះទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាង នោះបញ្ញត្តិនានានៃវិធានការនេះមានអាទិភាពទាំងស្រុង ហើយបញ្ញត្តិនានានៃវិធានការផ្សេងៗទៀត ត្រូវបានចាត់ទុកជានិរាករណ៍។

វគ្គទី 6. វិសោធនកម្ម

បញ្ញត្តិនានានៃច្បាប់នេះ មិនត្រូវបានធ្វើវិសោធនកម្មដោយអង្គនីតិបញ្ញត្តិឡើយ លើកលែងតែចង់បន្ថែមគោលបំណងរបស់វាតាមរយៈលក្ខន្តិកៈ ដែលបានអនុម័តនៅក្នុងសភានីមួយៗ តាមរយៈការបោះឆ្នោតដោយហៅឈ្មោះឱ្យបញ្ចេញមតិ ដែលបានបញ្ចូលនៅក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រពីរភាគបីនៃសមាជិកភាពដែលចូលរួម។

វគ្គទី 7. ឧបំរុង

វាគឺជាបំណងរបស់ប្រជាពលរដ្ឋដែលថា បទបញ្ញត្តិនានានៃច្បាប់នេះមានលក្ខណៈបំរុង ហើយថា ប្រសិនបើបទបញ្ញត្តិណាមួយនៃច្បាប់នេះ ឬ ការអនុវត្តចំពោះបុគ្គលណាម្នាក់ ឬ កាលៈទេសៈណាមួយ ត្រូវបានចាត់ទុកថាអសុពលភាពនោះ អសុពលភាពបែបនេះមិនប៉ះពាល់ដល់បញ្ញត្តិណាមួយផ្សេង ឬ ការអនុវត្តច្បាប់នេះ ហើយអាចត្រូវបានផ្តល់សុពលភាពដោយមិនមានបទបញ្ញត្តិ ឬ ការអនុវត្តដែលមិនមានសុពលភាពនោះឡើយ។

## សំណើប្រជាមតិ 34

វិធានការប្រជានុម័តនេះគឺត្រូវបានដាក់ឱ្យប្រជាពលរដ្ឋដោយអនុលោមទៅតាមខដែលមានចែងក្នុងវគ្គទី 8 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

វិធានការប្រជានុម័តនេះកែប្រែនិងលុបចោលផ្នែកខ្លះនៃក្រមព្រហ្មទណ្ឌ និងបន្ថែមផ្នែកខ្លះទៅលើក្រមរដ្ឋាភិបាល ដូចនេះខចែង មានស្រាប់ដែលបានស្នើឡើងដើម្បីលុបចោល ត្រូវបោះពុម្ពចេញជា~~លក្ខណៈឆ្នូតកាត់~~ ហើយខចែងថ្មីដែលបានស្នើឡើងដើម្បី បន្ថែមត្រូវបោះពុម្ពចេញជា *លក្ខណៈអក្សរទ្រេត* ដើម្បីបញ្ជាក់ថាវាថ្មី។

## ច្បាប់ដែលស្នើ

ច្បាប់រដ្ឋកាលីហ្វ័រញ៉ាសេហ្វ (The SAFE California Act)

វគ្គទី1. ចំណងជើង

ការ ផ្តើមប្រជាសិទ្ធិគួរត្រូវបានគេស្គាល់និងអាចត្រូវបានយោងថាជា "ច្បាប់សំ រា ប់ការសន្សំ ការទទួលខុសត្រូវ និងការពង្រឹងយ៉ាងពេញ លេញសំរាប់រដ្ឋកាលីហ្វ័រញ៉ា។"

វគ្គទី 2. ការរកឃើញ និងសេចក្តីប្រកាស

ប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ាតាមន័យនេះពិតជារកឃើញនិងប្រកាសនូវ ចំនុចដូចខាងក្រោម:

1. ឃាតករ និងអ្នករំលោភត្រូវតែបានបញ្ឈប់ នាំយកទៅតុលាការនិង ដាក់ទោស។ ទោះយ៉ាងណា ជាមធ្យម 46 ភាគរយ នៃមនុស្ស ឃាត និង 56 ភាគរយគួរអោយរន្ធត់នៃការចាប់រំលោភ មិនបានដោះស្រាយ ជារៀងរាល់ឆ្នាំ។ ធនធានពង្រឹងច្បាប់ដែល មានកំណត់របស់យើង គួរត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយបទឧក្រិដ្ឋជាច្រើន កាត់បន្ថយជនឧក្រិដ្ឋជាច្រើនចេញពីផ្លូវរបស់យើង និង ដើម្បីការពារក្រុមគ្រួសាររបស់យើង។

2. មន្ត្រីប៉ូលីស តម្រួតតំបន់ និងមេធាវីក្នុងតំបន់ឥឡូវនេះខ្វះថវិកាដែលពួកគេត្រូវការដើម្បីបន្តដំណើរការភស្តុតាងយ៉ាងឆាប់រហ័សក្នុង សំណុំរឿងចាប់រំលោភនិងករណីមនុស្សឃាត ដើម្បីប្រើនីតិវិទ្យាសាស្ត្រ សម័យទំនើប ដូចជាការពិសោធន៍ DNA ឬសូម្បីតែជួលអ្នកស៊ើប អង្កេតលើសំណុំរឿងមនុស្សឃាតនិងអំពើអនាចារឱ្យបានគ្រប់គ្រាន់។ ការពង្រឹងច្បាប់គួរមានធនធានដែលត្រូវការចាំបាច់សំរប់ ការពង្រឹងយ៉ាងពេញលេញនៃច្បាប់។ ដោយការដោះស្រាយករណីចាប់រំលោភនិងឃាតកម្មកាន់តែច្រើននិងការនាំយកឧក្រិដ្ឋជនទៅតុលាការ យើងរក្សាគ្រួសារ និងសហគមន៍របស់យើងឱ្យកាន់តែមានសុវត្ថិភាព។

3. ផ្អែកលើការសិក្សាមួយដោយអតីតសុភាចារបុរសនិងចៅក្រម (អ្នក កាត់ទោស) Arthur Alarcon និងអ្នកជំនាញច្បាប់ Paula Mitchell បានឱ្យដឹងថាមនុស្សជាច្រើនគិតថា ទោសប្រហារជីវិត គឺថោកជាងជីវិតរស់នៅក្នុងគុកដោយគ្មានលទ្ធភាពអាចដោះលែងមុនពេលកំនត់ ប៉ុន្តែមិនមែនជាការពិតទេ។ ការលីហ្វ័រញ៉ា បានចំណាយ ប្រាក់ $4ពាន់លានដុល្លារ លើទោសប្រហារជីវិតតាំងពីឆ្នាំ1978 ហើយទោសប្រហារជីវិតនេះគឺថ្លៃជាងការកាត់ទោសឱ្យរស់នៅក្នុងគុកដោយគ្មានលទ្ធភាពអាចដោះលែងមុនការកំនត់រហូតដល់20ដងនេះតាមការវិនិច្ឆ័យ។ ដោយការប្តូរពីទោសប្រហារជីវិតទៅជាការកាត់ទោសឱ្យរស់នៅក្នុងគុកដោយគ្មានលទ្ធភាពអាចដោះលែងមុន ការកំនត់។ អ្នកជាប់បង់ពន្ធ កាលីហ្វ័រញ៉ាអាចនិងសន្សំប្រាក់បានច្រើនជាង $100លានដុល្លារជារៀងរាល់ឆ្នាំ។ ប្រាក់ទាំងអស់នោះអាចយកទៅប្រើដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្ការទប់ស្កាត់ និងការកាត់ទោសលើបទ ឧក្រិដ្ឋ។

4. ឃាតករ និងអ្នកចាប់រំលោភដើរដោយសេរីលើផ្លូវ និងគំរាមកំហែងលើសុវត្ថិភាពរបស់យើង ខណៈពេលដែលយើងជាអ្នកជាប់ពន្ធ ចំនាយរាប់រយលានដុល្លាដើម្បីកំនត់លើមនុនស្សពីរ បីនាក់ដែលត្រៀមខ្លួនរួចរាល់ក្នុងការសំលាប់មនុស្ស ធនធានទាំងអស់នេះអាចនិងជាការចំនាយប្រសើរលើការបង្ការទប់ស្កាត់អំពើហិង្សា និងការអប់រំដើម្បីរក្សាក្រុមគ្រួសាររបស់យើងរស់នៅដោយភាពសុខសាន្ត។

5. ដោយការជំនួសទោសប្រហារជីវិតមកជាការដាក់ទោសរស់នៅក្នុងគុកដោយគ្មានលទ្ធភាពអាចដោះលែងមុនការកំនត់ យើងអាចសន្សំប្រាក់រដ្ឋបាន $1 ពាន់លានដុល្លារក្នុងរយៈពេល 5 ឆ្នាំដោយគ្មានដោះលែងអ្នកទោសូម្បីតែមួយនាក់ ហើយប្រាក់ $1ពាន់លានដុល្លារនោះអាចត្រូវបានវិនិយោគក្នុងការធ្វើឱ្យច្បាប់មានប្រសិទ្ធភាព និងដើម្បីរក្សាសង្គមរបស់យើងសុវត្ថិភាព ក្នុងសាលារៀនរបស់កូនៗយើងគ្រប់គ្នា និងក្នុងសេវាកម្មសំរាប់មនុស្សចាស់និងអសមត្ថភាព។ ជីវិតរស់នៅក្នុងគុកដោយគ្មានលទ្ធភាពអាចដោះលែងមុនការកំនត់ ត្រូវប្រាកដថាឧក្រិដ្ឋកម្មអាក្រក់បំផុតស្នាក់នៅក្នុងគុកជារៀងរហូត និងសន្សំប្រាក់។

6. មានមនុស្សគ្មានទោសច្រើនជាង 100នាក់ ត្រូវបានកាត់សេចក្តីមួយជីវិតនៅក្នុងប្រទេសនេះ និងអ្នកគ្មានទោសខ្លះទៀតត្រូវបានប្រហារជីវិត។ អ្នកជំនាញបានសន្និដ្ឋានថា Cameron Todd Willinghamត្រូវបានកាត់ក្តីដោយអយុត្តិធម៌ លើសំនុំរឿង ភ្លើងឆេះសម្លាប់កូនរបស់គាត់បីនាក់។ ការកាត់ទោសប្រហារជីវិត ពួកយើងអាចនឹងជួបគ្រោះថ្នាក់ប្រហារជីវិតមនុស្សអចេតនាក្នុងការធ្វើ។

7. អ្នកជំនាញបានសន្និដ្ឋានថា ការលីហ្វរញ៉ានោសល់បញ្ហាគ្រោះថ្នាក់ច្រើនទៀតនៃការប្រហារជីវិតមនុស្សគ្មានចេតនាក្នុងការធ្វើ។ ទណ្ឌិតជាមនុស្សគ្មានចេតនាក្នុងការធ្វើគឺអយុត្តិធម៌ណាស់ ដោយសារតែកំហុសនៃការ

កំនត់បញ្ជាក់ពីសាក្សីចំពោះមុខ ដែលនេះជា វិជ្ជាសាស្ត្រនិតិក្រមហួសសម័យ និងសកម្មភាពហួសការកាត់ទោស។ យើងមិនធ្វើការការពារនូវអ្វីដែលយើងគួរធ្វើដើម្បីការពារដល់ជនអចេតនា។ ច្បាប់ប្រទេសការពារទាំងសុភាចារបុរស ប្រសិនបើសុភាចារបុរសនោះបញ្ជូនជនប្រព្រឹត្តដោយអចេតនាទៅពន្ធនាគារដោយអយុត្តិធម៌។ ការបង្ការទប់ស្កាត់ភាពអាចទទួលខុសត្រូវបានលើគណនីរបស់អ្នកជាប់បង់ពន្ធ និងជនរងគ្រោះ និងជនរងគ្រោះ។ ការប្តូរទោសប្រហារជីវិតទៅជាទោសជាប់គុករស់នៅដោយមិនមានលទ្ធភាពអាចចេញមិនការកំណត់ និងមានចំនួនតិចតួច ដែលយើងមិនធ្វើការកាត់ទោស ខុសលើមនុស្សអចេតនាម្នាក់។

8. ទណ្ឌិតក្នុងអំពើសំលាប់មនុស្សត្រូវតែទទួលបន្ទុក និងបង់លើឧក្រិដ្ឋកម្មរបស់ខ្លួន។ សព្វថ្ងៃតិចជាង 1ភាគរយនៃជនវិកលចរិតជាអ្នករង់ចាំការប្រហារជីវិតធ្វើការ ដែលជាលទ្ធផល ពួកគេបង់ប្រាក់បដិទានអោយជនរងគ្រោះតិចតួច។ ទណ្ឌិតគ្រប់រូបក្នុងអំពើឃាតកម្មគួរតែតំរូវអោយធ្វើការក្នុងគុកកំរិតខ្ពស់ ហើយប្រាក់ស្វែងរកបានគួរតែត្រូវបានប្រើប្រាស់ដោយជនរងគ្រោះតាមរយះមូលនិធិសំនងជនរងគ្រោះដែលសំអាងដោយសិទ្ធការពារជនរងគ្រោះ ដោយច្បាប់ Marsy.

9. ទោសប្រហារជីវិតក្នុងរដ្ឋការលីហ្វ័រញ៉ា គឺជាពាក្យសន្យាដែលគ្មានន័យ។ រឿងក្តីទោសប្រហារជីវិតអូសប្រលាយពេលជាច្រើន ទសវត្ស។ ការកាត់ទោសអោយរស់នៅក្នុងគុកដោយគ្មានលទ្ធភាពអាចដោះលែងមុនការកំនត់ ផ្តល់ដំណោះស្រាយលឿនសំរាប់ដាក់បន្ទុកសោកសង្រេងដល់ក្រុមគ្រួសារ ហើយនេះទើបជាពិន័យពិតប្រាកដច្រើនជាងការពិន័យ។



10. ជាប្រតិសកម្មនៃការអនុវត្ត សកម្មភាពនេះនិងបិទបញ្ចប់ការ អនុវត្តន៏មានតម្លៃថ្លៃនិងគ្មានប្រសិទ្ធភាពនេះ កាត់បន្ថយធនធានមន្ត្រី ឬភ្នាក់ងារទទួលបន្ទុកការអនុវត្តច្បាប់ និងបង្កើនដោះស្រាយអត្រាមនុស្សឃាត និងការចាប់រំលោភ និងទទួលយុត្តិធម៌ ភាពស្មើមុខគ្នា និងភាពស្មើគ្នាក្នុងការកាត់ក្តី។

ផ្នែក 3. គោលបំណង និងចេតនា

ប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ាប្រកាសពីគោលបំណង និងចេតនា របស់ពួកគេក្នុងការអនុម័តច្បាប់ដូចខាងក្រោមៈ

1. ដើម្បីបញ្ឈប់ក្រុមឃាតករ និងជនចាប់រំលោភសេពសន្ថវៈ និងដើម្បីការពារគ្រួសាររបស់យើង។

2. ដើម្បីសន្សំបាក់ពីការបង់ពន្ធ ចំនួន 1ពាន់លានដុល្លារក្នុងរយៈ ពេល 5ឆ្នាំ ដូច្នេះថវិការទាំងនេះអាចត្រូវប្រើដើម្បីបណ្តាក់ទុនទៅ លើ ការអនុវត្តន៍ច្បាប់ក្នុងមូលដ្ឋាន សាលារៀន និង សេវាសម្រាប់មនុស្ស ចាស់ជរា និងជនពិការ។

3. ដើម្បីប្រើបាស្រ់នូវប្រាក់សន្សំដែលទទួលបាន ពីការកែប្រែឱ្យរួចពីទោសប្រហារជីវិត មកបង្កើតជាមូលនិធិសេហ្វកាលីហ្វ័រញ៉ា ក្នុងគោលបំណងប្រើមូលនិធិសម្រាប់ការពង្រឹងច្បាប់ក្នុងមូលដ្ឋាន ជា ពិសេសសម្រាប់នាយកដ្ឋាននរគបាល   នរគបាលមូលដ្ឋាន និងការិយាល័យមេធាវីខោនធី ដើម្បីបង្កើនអត្រា សំណុំរឿងក្តីមនុស្ស ឃាតនិងការចាប់រំលោភបានដោះស្រាយ។

4. ដើម្បីបំបាត់គ្រោះថ្នាក់នៃការកាត់ទោសប្រជាពលរដ្ឋដែលគ្មានកំហុស។

5. ដើម្បីទាមទារ ឱ្យជនណាដែលជាប់ទោសឃាតកម្មនិងមានលក្ខខណ្ឌពិសេស ត្រូវជាប់ពន្ធធានាគារអស់មួយជីវិត ហើយត្រូវធ្វើការក្នុងពន្ធធានាគារដែលមានសន្តិសុខការពារខ្ពស់ ហើយត្រូវប្រើប្រាក់ចំណូលនោះ ដើម្បីជួយដល់ជនរងគ្រោះ តាមរយៈមូលនិធិសំណងការខូចខាតរបស់ជនរងគ្រោះ។

6. ដើម្បីបញ្ចប់នូវដំណើរការ ដ៏យូរអង្វែងជាង25ឆ្នាំ នៃការពិនិត្យឡើងវិញលើករណីកាត់ទោសប្រហារជីវិត ជាមួយនឹងការត្រូវឡើងសវនការជាច្រើន និងការពន្យាពេល ដែលធ្វើឱ្យក្រុមគ្រួសារ កាន់តែមានការចង់ចាំនូវភាពសោកសង្រេងចំពោះអ្នកដែលខ្លួនស្រឡាញ់។

7. ដើម្បីបញ្ចប់នូវការអនុវត្តន៏ដែលគ្មានប្រសិទ្ធិភាព និងចំណាយ ខ្ពស់ ហើយនិងដើម្បីផ្តល់សេរីភាពដល់ធនធានសម្រាប់ពង្រឹងច្បាប់ ដែលធ្វើឱ្យក្រុមគ្រួសារមានសុវត្ថិភាព។

8. និងការឯកភាពក្នុងការកាត់ទោស តាមរយៈបណ្តឹងប្រតិសកម្ម នៃច្បាប់នេះដើម្បីជំនួសការដាក់ទោសប្រហារជីវិតទៅជាការដាក់ ពន្ធធានាគារអស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង។

វគ្គទី 4. វគ្គទី 190 នៃក្រមព្រហ្មទណ្ឌត្រូវធ្វើវិសោធនកម្មត្រូវបកស្រាយ ថាៈ

190. (a) ជនដែលជាប់ពិរុទ្ធពីបទឃាតកម្មក្នុងថ្នាក់ទីមួយ ជននោះនឹងត្រូវផ្តន្ទាទោសប្រហារជីវិតជាប់ពន្ធធានាគាររដ្ឋអស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង ឬជាប់ពន្ធធានាគាររដ្ឋរយៈពេល 25ឆ្នាំ។ ទោសបញ្ញត្តិដែលត្រូវអនុវត្ត ត្រូវតែកំណត់ដូចបានចែងក្នុងផ្នែក ~~190.1~~, 190.2, ~~190.3~~, 190.4, និង 190.5។

លើកលែងតែដូចបានចែងក្នុងផ្នែករង (b), (c), ឬ (d) ដែលជនជាប់ពិរុទ្ធពីបទឃាតកម្មថ្នាក់ទី 2ត្រូវផ្តន្ទាទោសដោយដាក់ពន្ធ ធានាគាររដ្ឋរយៈពេល 15ឆ្នាំ។

(b) ករណីលើកលែងដូចបានចែងក្នុងផ្នែករង(c) ជនជាប់ពិរុទ្ធពីបទឃាតកម្មថ្នាក់ទី2 ត្រូវផ្តន្ទាទោសដោយដាក់ពន្ធធានាគារ រដ្ឋរយៈ ពេល25ឆ្នាំ បើសិនជាជនរងគ្រោះជាមន្ត្រីការពារសន្តិភាព ដូចបាន ចែងក្នុងផ្នែករង(a) នៃផ្នែក 830.1 ផ្នែករង(a), (b), ឬ (c) នៃផ្នែក 830.2 ផ្នែករង(a) នៃផ្នែក 830.33 ឬផ្នែក 830.5 ដែលអ្នកត្រូវបាន គេសម្លាប់ក្នុង ខណៈពេលដែលគាត់បំពេញតួនាទីរបស់ខ្លួន ហើយ ចុងចោទបានដឹងឬមានហេតុផលសមរម្យនឹងបានដឹងថា ជនរង គ្រោះជាមន្ត្រីការពារសន្តិភាព ដែលកំពុងអនុវត្តតួនាទីរបស់ខ្លួន។

(c) ជនជាប់ពិរុទ្ធពីបទឃាតកម្មថ្នាក់ទី2 ត្រូវផ្តន្ទាទោសដោយដាក់ពន្ធធានាគាររដ្ឋអស់មួយជីវិត ដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង បើសិនជាជនរងគ្រោះជាមន្ត្រីការពារសន្តិភាព ដូចបានចែងក្នុងផ្នែក រង(a) នៃផ្នែក 830.1 ផ្នែករង(a), (b), ឬ (c) នៃផ្នែក 830.2 ផ្នែករង(a) នៃផ្នែក 830.33 ឬផ្នែក830.5 ដែលអ្នកត្រូវបានគេសម្លាប់ ក្នុងខណៈពេលដែលគាត់បំពេញ តួនាទីរបស់ខ្លួន ហើយជនជាប់ចោទ បានដឹង ឬមានហេតុផលសមរម្យនឹង បានដឹងថា ជនរងគ្រោះជាមន្ត្រី ការពារសន្តិភាពដែលកំពុងអនុវត្តតួនាទី របស់ខ្លួន ហើយបានចោទ ប្រកាន់ និងពិនិត្យឃើញការពិតណាមួយដូចខាង ក្រោមៈ

(1) ចុងចោទមានចេតនាយ៉ាងច្បាស់ ចង់សម្លាប់មន្ត្រីការពារសន្តិភាព។

(2) ចុងចោទមានចេតនាយ៉ាងច្បាស់ ចង់បង្ករបួសស្នាមធ្ងន់ធ្ងរ លើរាងកាយ ដូចបានចែងក្នុងផ្នែក 12022.7 ស្តីពីមន្ត្រីការពារសន្តិភាព។

(3) ចុងចោទបានប្រើបាស្រ់អាវុធបង្កគ្រោះថ្នាក់ ឬប្រល័យជីវិតផ្ទាល់ខ្លួន ក្នុងការប្រព្រឹត្តបទល្មើស រំលោភបំពានច្បាប់ក្នុងផ្នែករង (b) នៃផ្នែក12022។

(4) ជនជាប់ចោទប្រើបាស្រ់កាំភ្លើងផ្ទាល់ខ្លួន ក្នុងការប្រព្រឹត្តបទល្មើសរំលោភបំពានច្បាប់នៃផ្នែក 12022.5។

(d) ជនជាប់ពិរុទ្ធពីបទឃាតកម្មថ្នាក់ទី២ ត្រូវផ្តន្ទាទោសដោយដាក់ពន្ធធានាគាររដ្ឋ រយៈពេល 20 ឆ្នាំ បើសិនជាការសម្លាប់ប្រព្រឹត្តឡើងដោយការបាញ់ពីលើរថយន្ត ប៉ុនប៉ងបាញ់បុគ្គលដ៏ទៃទៀតនៅខាងក្រៅរថយន្ត ដោយចង់បង្ករបួសស្នាមធ្ងន់ធ្ងរលើរាងកាយ។

(e) មាត្រាទី 2.5 (ចាប់ផ្តើមពីផ្នែក 2930) នៃជំពូកទី 7 នៃចំណងជើងទី1 នៃចំណែកទី3 មិនត្រូវអនុវត្តដើម្បីកាត់បន្ថយរយៈពេលអប្បបរិមានៃទម្ងន់ទោស  អនុលោមទៅតាមផ្នែកនេះ។ ជនដែល ទទួលទោសអនុលោមតាមផ្នែកនេះ មិនត្រូវបានដោះលែងដោយ ផ្អែកតាមលក្ខខណ្ឌណាមួយ មុនពេលបានជាប់ឃុំឃាំង គ្រប់តាម រយៈពេលអប្បបរិមាដូចបានចែងក្នុងផ្នែកនេះ។

*(f) ជនដែលប្រកាសថាជាប់ពិរុទ្ធពីបទឃាតកម្ម ហើយបានកាត់ ទោសអនុលោមតាមផ្នែកនេះ ត្រូវតំរូវឱ្យធ្វើការនៅក្នុងពន្ធ ធានាគារដែលមានការការពារសន្តិសុខខ្ពស់ ច្រើនម៉ោងទៅតាមពលកម្ម ទៀងពេលក្នុងថ្ងៃនិមួយៗ ហើយរៀងរាល់ថ្ងៃក្នុងអំឡុង ពេលជាប់ ពន្ធធានាគារ ដូចត្រូវបានចែងក្នុងវិធាន និងបទបញ្ញត្តិ នៃនាយក ដ្ឋានអប់រំកែប្រែ និងស្តារនីតិ  សម្បទា ដោយអនុលោមទៅ តាម ផ្នែក2700។ ក្នុងករណីដែលទណ្ឌិតជំពាក់បាក្រ់ពិន័យបដិទាន ឬអធិបញ្ជាបដិទាន លេខាធិការនាយកដ្ឋានអប់រំកែប្រែ និងស្តារនីតិសម្បទា ត្រូវកាត់ប្រាក់ពីប្រាក់ឈ្នួល និងគណនីប្រាក់តំកល់ របស់ទណ្ឌិត ហើយត្រូវផ្ទេរមូលនិធិទាំងនោះ ចូលទៅគណៈកម្មការប្រាក់សំណងជនរងគ្រោះកាលីហ្វ័រញ៉ា និងគណៈកម្មការ ទាម ទារសំណងរបស់រដ្ឋាភិបាល ដោយផ្អែកតាមវិធាន និងបទបញ្ញាត្តិនៃនាយកដ្ឋានអប់រំកែប្រែ និងស្តារនីតិសម្បទា អនុលោមទៅតាម ផ្នែក 2085.5 និង 2717.8។*

ផ្នែក5 -ផ្នែក190.1 នៃក្រមព្រហ្មទណ្ឌ ដែលត្រូវបានទុកជានិរាករណ៍

~~190.1 ករណីដែលត្រូវសម្រេចផ្តន្ទាទោសប្រហាជីវិត អនុលោមតាមជំពូកនេះ ត្រូវជំនុំជម្រះក្នុងដំណាក់កាលដាច់ដោយឡែកដូចខាងក្រោមៈ~~

~~(a) ដំបូង ត្រូវកំណត់សំណួរដែលត្រូវសួរចុងចោទជាប់ពិរុទ្ធភាព។ បើសិនជាអ្នកអ្នកកាត់សេចក្តីលើអង្គហេតុ ពិនិត្យឃើញការពិត ដែល ថាចុងចោទជាប់ពិរុទ្ធនៃបទឃាតកម្មថ្នាក់ទី1 ដូច្នេះត្រូវតែកំណត់អង្គ ហេតុនៃលក្ខខ័ណ្ឌពិសេសទាំងអស់ក្នុងពេលតែមួយ ដែលត្រូវចោទ ប្រកាន់ដូចរៀបរាប់ក្នុងផ្នែក 190.2 លើកលែងតែលក្ខខ័ណ្ឌពិសេស ដែលត្រូវបានចោទប្រកាន់អនុលោមតាមកថាខណ្ឌទី2 នៃផ្នែករង(a) ផ្នែក 190.2ដែលចង្អុលបង្ហាញថាចុងចោទធ្លាប់បានជាប់ទោស មុន ពេលប្រព្រឹត្តបទល្មើសឃាតកម្មថ្នាក់ទី1 ឬទី2។~~

~~(b) បើពិនិត្យឃើញថាមានពិរុទ្ធភាពលើចុងចោទពីបទឃាតកម្ម ថ្នាក់ទី1 ហើយនិងពិនិត្យឃើញលក្ខខណ្ឌពិសេសមួយក្នុងចំណោម លក្ខខណ្ឌទាំងអស់ ដែលបានចោទប្រកាន់អនុលោមតាមកថាខណ្ឌ (2)នៃផ្នែករង (a) នៃផ្នែក 190.2 ដែលចោទប្រកាន់ថាចុង ចោទ ធ្លាប់បានជាប់ទោស មុនពេលប្រព្រឹត្តិបទល្មើសឃាតកម្មថ្នាក់ទី1 ឬ ទី2។ ក្នុងពេលនោះ ត្រូវតែមានការចោទសួរជាបន្ត ដើម្បីដឹងពីការពិត នៃលក្ខខណ្ឌពិសេសដូចនេះ។~~

~~(c) បើពិនិត្យឃើញថាមានពិរុទ្ធភាពលើចុងចោទពីបទឃាតកម្មថ្នាក់ទី1 ហើយមានលក្ខខណ្ឌពិសេសមួយ ឬច្រើនដូចបាន រៀប រាប់ ក្នុងផ្នែក 190.2 ត្រូវបានចោទប្រកាន់ និងពិនិត្យឃើញការពិត ត្រូវ កំណត់ពីវិបត្តិស្មារតីស្តីពីចម្លើយរបស់ចុងចោទថាគ្មានកំហុស ដោយ ហេតុផលថាមានវិបត្តិស្មារតីនៅក្រោមផ្នែក 1026 ដូចបានចែងក្នុង ផ្នែក 190.4។ បើចុងចោទត្រូវបានពិនិត្យឃើញថាវង្វេង ត្រូវបន្ត ដំណាក់កាល ជំនុំជំរះក្តីលើការចោទសួរសំណួរនៃទោសបញ្ញត្តិនៅ ពេលនោះ។ សំណុំរឿងដូចនេះត្រូវអនុវត្តស្របតាមខចែងក្នុងផ្នែក 190.3 និង190.4។~~

វគ្គទី 6. ផ្នែក190.2 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដើម្បីបក ស្រាយថាៈ

190.2 - (a) ទោសបញ្ញត្តិសម្រាប់ចុងចោទ ដែលពិនិត្យឃើញថាមានពិរុទ្ធភាពពីបទឃាតកម្មថ្នាក់ទី1 គឺ~~ការស្លាប់~~ ឬជាប់ពន្ធធានាគាររដ្ឋអស់មួយជីវិត ដោយអាចគ្មានលក្ខខណ្ឌនឹង ដោះលែង បើសិនជាលក្ខខណ្ឌពិសេសមួយ ឬច្រើនដូចខាងក្រោម បានរកឃើញក្រោមផ្នែក 190.4 ថាជាការពិតៈ

(1) ឃាតកម្មគឺមានចេតនា និងប្រព្រឹត្តឡើងដើម្បីចំណេញផ្នែកហិរញ្ញវត្ថុ។

(2) ចុងចោទធ្លាប់មានទោសពាក់ព័ន្ធនឹងឃាតកម្មពីមុនក្នុងថ្នាក់ទី1ឬទី2។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ បទល្មើសដែលបាន ប្រព្រឹត្តិស្ថិតក្នុងយុត្តាធិការផ្សេងដែលថាបើសិនជាប្រព្រឹត្តិក្នុងរដ្ឋកាលីហ្វ័រញ៉ា អាចនឹងទទួលទារុណកម្មដូចជាឃាតកម្មថ្នាក់ទី1 និងទី2ដែរ និងត្រូវតែចាត់ទុកជាឃាតកម្មថ្នាក់ទី1 ឬទី2។

(3) ចុងចោទ ក្នុងសំណុំរឿងនេះ ធ្លាប់បានជាប់ទោសពីបទល្មើស ឃាតកម្មថ្នាក់ទី1ឬទី2ច្រើនជាងមួយដង។

(4) ឃាតកម្មដែលបានប្រព្រឹត្តឡើងដោយប្រើឧបករណ៍បំផ្លាញគ្រាប់បែក ឬបំពាក់ លាក់គ្រឿងផ្ទុះ ឬបិតបាំងនៅកន្លែងណាមួយ ទូរ អាគារ ឬសំណង់ ហើយដែលចុងចោទបានដឹង ឬមានហេតុផលសម ស្របថាបានដឹង ដែលទង្វើរបស់គាត់អាចនឹងបង្កហានិភ័យខ្ពស់ ដល់ ការបាត់បង់ជីវិតដល់មនុស្សម្នាក់ ឬច្រើន។

(5) ឃាតកម្មបានប្រព្រឹត្តិឡើងក្នុងគោលបំណងដើម្បីជៀសវាង ឬ រារាំងការចាប់ខ្លួនស្របច្បាប់ ឬប៉ុនប៉ងដាច់ខាតដើម្បីគេចពីការឃុំខ្លួនស្របច្បាប់។

(6) ឃាតកម្មត្រូវបានប្រព្រឹត្តឡើងដោយប្រើឧបករណ៍បំផ្លាញ គ្រាប់បែក ឬគ្រឿងផ្ទុះដែលចុងចោទបានផ្ញើរឬប្រគល់ បានប៉ុនប៉ងផ្ញើ ឬ ប្រគល់ ឬ បណ្តាលឱ្យផ្ញើរឬប្រគល់ ហើយចុងចោទបានដឹង ឬមាន ហេតុផលសមរម្យថាបានដឹង ដែល ទង្វើរបស់គាត់អាចនឹងបង្កហា និភ័យ ខ្ពស់ដល់ការបាត់បង់ជីវិតដល់មនុស្សម្នាក់ ឬច្រើន។

(7) ជនរងគ្រោះគឺជាមន្ត្រីការពារសន្តិភាព ដូចបានចែងក្នុងផ្នែក 830.1, 830.2, 830.3, 830.31, 830.32, 830.33, 830.34, 830.35, 830.36, 830.37, 830.4, 830.5, 830.6, 830.10, 830.11, ឬ 830.12 អ្នកដែលពាក់ព័ន្ធនឹងបុព្វហេតុនៃការអនុវត្តន៍ភារៈកិច្ចរបស់ខ្លួន ដែល ត្រូវបានគេប៉ុនប៉ងសម្លាប់ ហើយចុងចោទបានដឹង ឬមានហេតុផល សមរម្យថាបានដឹងថាជនរងគ្រោះគឺជាមន្ត្រីការពារសន្តិភាពកំពុងអនុវត្តភារៈកិច្ចរបស់ខ្លួន ឬជនរងគ្រោះគឺជាមន្ត្រីការពារសន្តិភាព ដូចបាន ចែងក្នុងផ្នែកដែលបានរៀបរាប់ខាងលើ ឬជាអតីតមន្ត្រីការពារ សន្តិ ភាពដែលស្ថិតនៅក្រោមផ្នែកទាំងនោះហើយត្រូវបានគេប៉ងសម្លាប់ ដើម្បីសងសឹកដោយសារតែការអនុវត្តន៍ភារៈកិច្ចជាមន្ត្រីរបស់ខ្លួន។

(8) ជនរងគ្រោះជាមន្ត្រី ឬជាភ្នាក់ងារអនុវត្តច្បាប់សហព័ន្ធ ដែល កំពុងអនុវត្តភារៈកិច្ចរបស់ខ្លួន ដែលត្រូវបានគេប៉ុនប៉ងសម្លាប់ ហើយចុងចោទបានដឹង ឬមានហេតុផលសម-រម្យថាបានដឹងថាជនរងគ្រោះជាមន្ត្រីឬភ្នាក់ងារអនុវត្តច្បាប់សហព័ន្ធ កំពុងអនុវត្តភារៈកិច្ចរបស់ខ្លួន ឬជនរងគ្រោះគឺជាមន្ត្រីឬភ្នាក់ងារអនុវត្តច្បាប់សហព័ន្ធ ហើយត្រូវបានគេប៉ុនប៉ងសម្លាប់ដើម្បីសងសឹកដោយសារតែការអនុវត្តន៍ភារៈកិច្ចជាមន្ត្រីរបស់ខ្លួន។

(9) ជនរងគ្រោះជាអ្នកពន្លត់អគ្គីភ័យ ដូចបានចែងក្នុង ផ្នែក 245.1 ដែលកំពុងតែអនុវត្តភារៈកិច្ចរបស់ខ្លួន ដែលត្រូវបានគេប៉ុនប៉ងសម្លាប់ ហើយចុងចោទបានដឹង ឬមានហេតុផលសមរម្យថាបានដឹង ថាជនរងគ្រោះគឺជាអ្នកពន្លត់អគ្គីភ័យ កំពុងអនុវត្តភារៈកិច្ចរបស់ខ្លួន។

(10) ជនរងគ្រោះគឺជាសាក្សីបំភ្លឺបទឧក្រិដ្ឋ ដែលត្រូវបានគេប៉ុនប៉ងសម្លាប់ ក្នុងគោលបំណងរារាំងការធ្វើជាសក្ខីភាពរបស់គាត់ នៅក្នុងដំណាក់កាលជំរះក្តីឧក្រិដ្ឋកម្ម ឬសំណុំរឿងអនីតិជន ហើយការសម្លាប់នេះមិនបានធ្វើក្នុងពេលប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋដែលគាត់បានឃើញ ឬជនរងគ្រោះគឺជាសាក្សីនៃបទឧក្រិដ្ឋកម្ម ហើយត្រូវបានគេប៉ុនប៉ងសម្លាប់ ក្នុងការសងសឹកពីព្រោះការធ្វើជាសាក្សីបំភ្លឺរបស់គាត់ក្នុងដំណាក់កាលជំរះក្តីឧក្រិដ្ឋកម្ម ឬអនីតិជន។ ដូចបានប្រើក្នុងកថាខណ្ឌនេះ៖" សំណុំរឿងអនីតិជន "មានន័យថាជាដំណាក់កាលជំរះក្តីដែលបានលើកឡើងអនុលោមទៅតាមផ្នែក 602 ឬ 707 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា។

(11) ជនរងគ្រោះជាព្រះរាជអាជ្ញា ឬជំនួយការព្រះរាជអាជ្ញា ឬអតីតព្រះរាជអាជ្ញា ឬជាជំនួយការព្រះរាជអាជ្ញានៃការិយាល័យព្រះរាជអាជ្ញារបស់រដ្ឋ ឬមូលដ្ឋាននៅក្នុងរដ្ឋនេះ ឬរដ្ឋដ៏ទៃទៀត ឬការិយាល័យព្រះរាជអាជ្ញាសហព័ន្ធហើយឃាតកម្មនេះបានធ្វើឡើងដើម្បីសងសឹកចំពោះ ឬដើម្បីរារាំងការអនុវត្តភារៈកិច្ចជាមន្ត្រីរបស់ជនរងគ្រោះ។

(12) ជនរងគ្រោះជាចៅក្រម ឬអតីតចៅក្រមនៃតុលាការណាមួយ ដែលមានរបាយការណ៍ក្នុងតំបន់ រដ្ឋ ឬប្រព័ន្ធតុលាការសហព័ន្ធក្នុងរដ្ឋនេះ ឬរដ្ឋដ៏ទៃទៀតហើយឃាតកម្មបានធ្វើឡើងដើម្បីសងសឹកចំពោះ ឬដើម្បីរារាំងការអនុវត្តភារៈកិច្ចជាមន្ត្រីរបស់ជនរងគ្រោះ។

(13) ជនរងគ្រោះជាមន្ត្រីជាប់ឆ្នោត ឬមន្ត្រីដែលគេតែងតាំង ឬអតីតមន្ត្រីរបស់រដ្ឋាភិបាលសហព័ន្ធ ឬជារដ្ឋាភិ- បាលរបស់រដ្ឋ ឬមូលដ្ឋានណាមួយនៃរដ្ឋនេះ ឬរដ្ឋដ៏ទៃទៀត ហើយឃាតកម្មបានធ្វើឡើងដើម្បីសងសឹកចំពោះឬដើម្បីរារាំងការអនុវត្តភារៈកិច្ចជាមន្ត្រីរបស់ជនរងគ្រោះ។

(14) ឃាតកម្មជាអំពើខុសសិលធម៌ ឬជាអំពើសាហាវយង់ឃ្នង ព្រៃផ្សៃ ដែលគួរឱ្យខ្លាច។ ដូចបានប្រើក្នុងផ្នែកនេះ ឃ្លាថា "អំពើខុសសិលធម៌ ឬជាអំពើសាហាវយង់ឃ្នង ព្រៃផ្សៃ ដែលគួរឱ្យខ្លាច" មានន័យជាបទឧក្រិដ្ឋដែលឥតសម្បជញ្ញៈ និងគ្មានមេត្តា ដែលធ្វើបាបជនរងគ្រោះដោយគ្មានសុភវិនិច្ឆ័យ។

(15) ចុងចោទមានចេនាសម្លាប់ជនរងគ្រោះ តាមមធ្យោបាយនៃការដេករងចាំជាមុន។

(16) ជនរងគ្រោះត្រូវបានគេប៉ុនប៉ងសម្លាប់ ដោយសារជាតិសាសន៍ ពណ៌សម្បុរ សាសនា សញ្ជាតិ ឬប្រទេសកំណើត។

(17) ឃាតកម្មត្រូវបានកើតឡើង ខណៈពេលដែលចុងចោទបានពាក់ព័ន្ធ ឬផ្សំគំនិតក្នុងការប្រព្រឹត្ត ការប៉ុនប៉ងប្រព្រឹត្ត ឬជម្លោះភ្លាមបន្ទាប់ពីប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋដូចខាងក្រោម ៖

(A) អំពើចោរកម្ម ដោយរំលោភទៅលើផ្នែក211 ឬ212.5។

(B) អំពើចាប់ជំរិត ដោយរំលោភទៅលើផ្នែក 207, 209, ឬ 209.5។

(C) អំពើរំលោភសេពសន្ថវៈ បំពានលើផ្នែក 261។

(D) ការរួមភេទដូចគ្នា ដោយរំលោភលើផ្នែក 286។

(E) ការអនុវត្តទង្វើអាស ឬលំឱនទៅតាមកាមមុច្ឆា លើក្មេងអាយុក្រោម 14ឆ្នាំ ដោយរំលោភលើផ្នែក 288។

(F) ការរួមសង្វាមតាមមាត់ ដោយរំលោភទៅលើផ្នែក 288a ។
(G) ការលបចូលលួចថ្នាក់ទី1 ឬទី2 ដោយរំលោភទៅលើខណ្ឌ 460។
(H) ការបង្កអគ្គីភ័យ ដោយរំលោភទៅលើផ្នែករង (b) នៃផ្នែក 451។
(I) ការបុករថភ្លើង ដោយរំលោភទៅលើផ្នែក219
(J) កាយវិកលកម្ម ដោយរំលោភទៅលើផ្នែក 203។
(K)ការរំលោភសេពសន្ថវៈដោយប្រើឧបករណ៍ដោយរំលោភទៅលើផ្នែក289។
(L) ការប្លន់រថយន្ត ដូចបានចែងក្នុងផ្នែក 215។
(M) ដើម្បីផ្តល់ភស្តុតាងសម្រាប់លក្ខខណ្ឌពិសេសនៃការចាប់ជំរិត ក្នុងកថាខ័ណ្ឌរង(B) ឬការបង្កអគ្គីភ័យក្នុងកថាខណ្ឌរង(H) បើសិនជាមានចេតនាជាក់លាក់ដើម្បីធ្វើឃាត គ្រាន់តែតំរូវឱ្យមានភស្តុតាង បង្ហាញពីធាតុផ្សំនៃបទឧក្រិដ្ឋទាំងនោះ។ បើសិនជាមានការប៉ុនប៉ងធ្វើឃាតមែន លក្ខខណ្ឌពិសេសទាំងពីរនោះនិងត្រូវបង្ហាញជាភស្តុតាង ទោះបីជាបទឧក្រិដ្ឋនៃការចាប់ជំរិតឬការបង្កអគ្គីភ័យត្រូវបានប្រព្រឹត្តយ៉ាងចម្បងឬតែមួយក្នុងគោលបណងសម្រួលដល់ការធ្វើឃាតកម្ម។

(18) ឃាតកម្មប្រព្រឹត្តដោយចេតនាហើយទាក់ទិននឹងការធ្វើទារុណកម្ម។

(19) ចុងចោទមានចេតនាសម្លាប់ជនរងគ្រោះ ដោយប្រើថ្នាំពុល។

(20) ជនរងគ្រោះជាសមាជិកគណៈវិនិច្ឆ័យនៅក្នុងតុលាក្នុងតំបន់ រដ្ឋ ឬប្រព័ន្ធតុលាសហព័ន្ធ ក្នុងរដ្ឋនេះឬរដ្ឋដ៏ទៃទៀត ហើយឃាតកម្មនេះមានចេតនាធ្វើឡើង ដើម្បីសងសឹកចំពោះ ឬដើម្បីរារាំងការអនុវត្តភារៈកិច្ចជាមន្ត្រីរបស់ជនរងគ្រោះ។

(21) ឃាតកម្មដោយចេតនា និងប្រព្រឹត្តបទឧក្រិដ្ឋដោយការបាញ់កាំភ្លើងពីរថយន្ត ដោយមានចេតនាតៅលើបុគ្គលផ្សេងទៀត ឬបុគ្គលដែលនៅក្រៅរថយន្ត ដោយមានចេតនាដើម្បីធ្វើឱ្យស្លាប់។ សម្រាប់គោលបំណងនៃកថាខ័ណ្ឌនេះ "រថយន្ត" មានន័យថារាល់ប្រភេទ រថយន្ត ដូចបានចែងក្នុងផ្នែក 415 នៃច្បាប់ស្តីពីការប្រើបាស្រ់យានយន្ត។

(22) ចុងចោទមានចេតនាសម្លាប់ជនរងគ្រោះ ខណៈពេលដែលចុងចោទជាអ្នកចូលរួមយ៉ាងសកម្ម ក្នុងក្រុមឧក្រិដ្ឋកម្មជនពាល ដូចបានចែងក្នុងផ្នែករង(f) នៃផ្នែក186.22 ហើយឃាតកម្មនេះ ធ្វើឡើងដើម្បីបន្តសកម្មភាពរបស់ក្រុមឧក្រិដ្ឋកម្មជនពាល។

(b) លុះត្រាតែការប៉ុនប៉ងសម្លាប់ គឺជាតំរូវការយ៉ាងពិសេសនៅ ក្រោមផ្នែករង(a) សម្រាប់លក្ខខណ្ឌពិសេស ដូចបានចែងរៀបរាប់ក្នុងនោះ-ឃាតករពិត- សម្រាប់អ្នកដែលលក្ខខណ្ឌពិសេសត្រូវបានពិនិត្យឃើញថាពិតនៅក្រោមផ្នែក190.4 ដែលមិនចាំបាច់មានចេតនាចង់សម្លាប់នៅពេលប្រព្រឹត្តិបទល្មើស ដែលនេះជាមូលដ្ឋាននៃលក្ខខណ្ឌពិសេស ក្នុងការទទួលទោសដល់~~ស្លាប់~~ ឬជាប់ឃុំក្នុងពន្ធធានាគាររដ្ឋអស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង។

(c) បុគ្គលទាំងអស់ ដែលមិនមែនជាឃាតករពិត ហើយមានចេតនាចង់ធ្វើឃាត ផ្តល់ជំនួយ ញុះញង់ ផ្តល់ប្រឹក្សា បញ្ជាបញ្ចុះបញ្ចូល ល្បួង ស្នើសុំ ឬជួយនូវកត្តាណាមួយក្នុងការប្រព្រឹត្តអំពើឃាតកម្មថ្នាកទី1ត្រូវទទួលទារុណកម្មដល់~~ស្លាប់~~ ឬជាប់ពន្ធធានាគាររដ្ឋអស់មួយជីវិត ដោយគ្មានលក្ខខណ្ឌ បើសិនលក្ខខណ្ឌពិសេសមួយ ឬច្រើនដូចបានចែងក្នុងផ្នែករង(a) បានពិនិត្យឃើញថាជាការពិត នៅក្រោមផ្នែក 190.4។

(d) ថ្វីបើមានផ្នែករង(c)ក៏ដោយ មនុស្សគ្រប់រូបដែលមិនមែនជា ឃាតករពិតដែលជាអ្នកព្រងើយកន្តើយ ព្រហើនគ្មានកោតក្រែង ចំពោះជីវិតមនុស្សជាតិ ហើយជាអ្នកចូលរួមចម្បងក្នុងការ ផ្តល់ជំនួយ ញុះញង់ ផ្តល់ប្រឹក្សា បញ្ជា បញ្ចុះបញ្ចូល ល្បួង ស្នើសុំ ឬជួយនូវកត្តាណាមួយក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដូចបានចែងរៀបរាប់ក្នុងកថាខណ្ឌ(17) នៃផ្នែករង(a)ដែលជាលទ្ធផលបង្កឱ្យមនុស្សស្លាប់ ហើយជាអ្នកត្រូវបានពិនិត្យឃើញថាមានជាប់ពិរុទ្ធភាពពីបទឃាតកម្មថ្នាក់ទី1។ បុគ្គលនេះត្រូវទទួលទារុណកម្ម ដោយការ~~ស្លាប់ ឬ~~ជាប់ពន្ធធនាគាររដ្ឋអស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង បើសិនជាលក្ខខណ្ឌពិសេសដូចបានចែងរៀបរាប់ក្នុង កថាខណ្ឌ(17) នៃផ្នែករង (a) ត្រូវបានពិនិត្យឃើញថាពិត នៅក្រោមផ្នែក190.4។

ទោសបញ្ញាត្តិត្រូវបានកំណត់ដូចបានចែងក្នុងផ្នែកនេះ និងផ្នែក~~190.1 190.3~~ 190.4 និង190.5។

វគ្គទី7 - ផ្នែក190.3 នៃក្រមព្រហ្មទណ្ឌត្រូវនិរាករណ៍

~~190.3.បើសិនជាចុងចោទត្រូវបានពិនិត្យឃើញថាមានកិរុទ្ធភាពពីបទឃាតកម្មថ្នាក់ទី1 ហើយលក្ខខណ្ឌពិសេសត្រូវបានចោទប្រកាន់ និងពិនិត្យឃើញការពិត ឬបើចុងចោទអាចត្រូវទទួលទោសប្រហារជីវិត បន្ទាប់ពីបានរកឃើញថាមានទោសបញ្ញាត្តិដោយរំលោភផ្នែករង(a) នៃផ្នែក1672 នៃច្បាប់យោធា និងអតីតយុទ្ធជន ឬផ្នែក៣៧ 128 219 ឬ4500នៃក្រមនេះ អ្នកកាត់សេចក្តីអង្គហេតុ ត្រូវកំណត់ថាតើជាទោសបញ្ញាត្តិស្លាប់ ឬជាប់ឃុំក្នុងពន្ធធានាគាររដ្ឋអស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង។ ក្នុងដំណាក់កាលចោទសួរសំណួរទោសបញ្ញត្តិ អាចនឹងតំរូវឱ្យបង្ហាញជា ភស្តុតាងទាំងប្រជាពលរដ្ឋនិងចុងចោទ ស្របទៅតាមបញ្ហាជាក់ស្តែង ដើម្បីបង្កើនទម្ងន់ទោស សម្រាលទោស ឬរួមទាំងកាត់ទោសប្រហាជីវិត ប៉ុន្តែដោយគ្មានកំហិតទៅនឹងលក្ខណៈជាក់ស្តែង និងលក្ខខណ្ឌនៃបទល្មើសបច្ចុប្បន្ន ហើយការផ្តន្ទាទោសលើបទឧក្រិដ្ឋពីមុនណាមួយ ឬការដាក់ទោសដែលថាជាឬមិនមែនជាការផ្តន្ទាទោស ឬការដាក់ទោសទាក់ទិនទៅនឹងឧក្រិដ្ឋកម្មរំលោភបំពាន ទោះជាមានវត្តមាន ឬអវត្តមាននៃសកម្មភាពឧក្រិដ្ឋជនប្រព្រឹត្តិដោយចុងចោទដែលជាប់ពាក់ព័ន្ធនឹងការប្រើ ឬប៉ុនប៉ងប្រើការបង្ខិតបង្ខំ ឬហឹង្សា ឬដែលពាក់ព័ន្ធនឹងការបង្ហាញឱ្យឃើញច្បាស់ ឬបញ្ជិតពីការគំរាមកំហែង ដើម្បីបង្ខិតបង្ខំ ឬប្រើហឹង្សា ហើយនិងអត្តចរិក ប្រវត្តិសាវតា ស្ថានភាពស្មារតី និងស្ថានភាពរូបវន្តរបស់ចុងចោទ។~~

~~ទោះជាយ៉ាងណាក៏ដោយ ក៏គ្មានភស្តុតាងណាដែលពាក់ព័ន្ធនឹងសកម្មភាពផ្សេងរបស់ឧក្រិដ្ឋជន ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ដោយចុងចោទ ដែលភស្តុតាងនោះមិនទាក់ទិននឹងការប្រព្រឹត្ត ឬប៉ុនប៉ងធ្វើការបង្ខិតបង្ខំ ឬអំពើហឹង្សា ឬដែលមិនពាក់ព័ន្ធនឹងការបង្ហាញច្បាស់ ឬបញ្ជិតពីការគំរាមកំហែងដោយបង្ខិតបង្ខំ ឬអំពើហឹង្សា។ ដូចបានប្រើក្នុងផ្នែកនេះ សកម្មភាពឧក្រិដ្ឋជនមិនតំរូវឱ្យធ្វើការដាក់ទោសទេ។~~

~~ទោះជាយ៉ាងណាក៏ដោយ នៅក្នុងព្រឹត្តិការណ៍ ក៏ភស្តុតាងនៃសកម្មភាពឧក្រិដ្ឋជនពីមុន មិនត្រូវបានអនុញ្ញាតិឱ្យប្រើសម្រាប់បទល្មើសមួយដែលចុងចោទត្រូវបានកាត់ទោស ឬដោះលែងទោសនោះទេ។ កំហិតនៃការប្រើប្រាស់ភស្តុតាង គឺសម្រាប់តែអនុវត្តក្នុងដំណាក់ជំរះរឿងក្តីប៉ុណ្ណោះ ដែលអនុលោមទៅតាមផ្នែកនេះ ហើយមិនមានចេតនាដើម្បីជះឥទ្ធិពលលើច្បាប់ធម្មនុញ្ញ ឬច្បាប់ស្តីពីការសម្រេចចិត្ត ដែលអនុញ្ញាតិឱ្យប្រើប្រាស់ភស្តុតាងបែបនេះ ក្នុងសំណុំរឿងក្តី ផ្សេងៗ។~~

~~លើកលែងតែភស្តុតាងជាតឹកតាង សម្រាប់បទល្មើស ឬលក្ខខណ្ឌពិសេសដែលចុងចោទត្រូវទទួលទោសប្រហាជីវិត ហើយគ្មានភស្តុតាងណាដែលអាចបង្ហាញដោយព្រះរាជអាជ្ញា ក្នុងបង្កើនទម្ងន់ទោស លុះត្រាតែមានការជូនដំណឹងដល់ចុងចោទអំពីភស្តុតាងនោះ ក្នុងរយៈសមហេតុផលមួយ ដូចបានកំណត់ដោយតុលាមុនពេលការជំនុំជម្រះក្តី។ ភស្តុតាងដែលអាចបង្ហាញឡើង ដោយគ្មានការជូនដំណឹងមុន ជាភស្តុតាងសម្រាប់ដោះសារបស់ចុងចោទ ក្នុងគោលបំណងទទួលបានការសម្រាលទោស។~~

~~អ្នកកាត់សេចក្តីអង្គហេតុត្រូវប្រាប់ថា ការកាត់ទោសដាក់ឃុំឃាំងក្នុងពន្ធធានាគាររដ្ឋអស់មួយជីវិត ដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង បន្ទាប់ពីការកាត់ទោសបានប្រកាសរួច ក៏ប៉ុន្តែទោសអាចនឹងត្រូវកាត់បន្ថយ ឬកែសម្រួល បើសិនជាមានលក្ខខណ្ឌដោះលែងទោសពីអភិបាលនៃរដ្ឋកាលីហ្វ័រញ៉ា។~~

~~ក្នុងការកំណត់ទោសបញ្ញាត្តិ អ្នកកាត់សេចក្តីអង្គហេតុត្រូវពិចារណាលើកត្តាដូចខាងក្រោម បើពាក់ព័ន្ធ:~~

~~(a) លក្ខខណ្ឌនៃបទឧក្រិដ្ឋ ដែលចុងចោទត្រូវបានជាប់ទោស ក្នុងសំណុំរឿងក្តីបច្ចុប្បន្ន និងការពិនិត្យឃើញលក្ខខណ្ឌពិសេស ថាជាការពិត ដោយអនុលោមតាមផ្នែកនេះ។~~

~~(b) វត្តមាន និងអវត្តមាននៃសកម្មភាពឧក្រិដ្ឋជនរបស់ចុងចោទ ដែលទាក់ទិននឹងការប្រព្រឹត្តិ ឬប៉ុនប៉ងប្រើការបង្ខិតបង្ខំ ឬអំពើហឹង្សា ឬការគំរាមកំហែងដែលបង្ហាញច្បាស់ ឬដោយបញ្ជិតក្នុងការប្រើការ បង្ខិតបង្ខំ ឬអំពើហឹង្សា។~~

~~(c) វត្តមាន ឬអវត្តមាននៃការដាក់ទោសដោយសារបទឧក្រិដ្ឋ ពីមុន ។~~

~~(d) ថាតើចុងចោទបានបានប្រព្រឹត្តិបទឧក្រិដ្ឋទេ ខណៈ ពេល ដែលខ្លួន~~

~~ស្ថិតនៅក្រោមការជះឥទ្ធិពលពីបញ្ហាស្មារតី ឬការរំជើប រំជួលខ្លាំង។~~

~~(e) ថាតើជនរងគ្រោះ ជាអ្នកចូលរួមក្នុងការប្រព្រឹត្តអំពើមនុស្ស ឃាត ជាមួយចុងចោទឬយល់ព្រមទៅនឹងសកម្មភាពមនុស្សឃាត នេះ។~~

~~(f) ថាតើបទល្មើស ត្រូវបានប្រព្រឹត្តិនៅក្រោមលក្ខខណ្ឌដែលចុងចោទជឿជាក់ មានហេតុផលសមរម្យប្រកបដោយសិលធម៌ ឬការ របន្ធូបន្ថយកំហុសសម្រាប់ការប្រព្រឹត្តិរបស់ខ្លួន។~~

~~(g) ថាតើចុងចោទ បានប្រព្រឹត្តិក្រោមការបង្ខិតបង្ខំ ឬក្រោមអំណាចកៀបសង្កត់ពីជនណាម្នាក់។~~

~~(h) ថាតើពេលវេលានៃបទល្មើស សមត្ថភាពរបស់ចុងចោទអាច សមទៅនឹងបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្តិដែរឬទេ ឬការប្រព្រឹត្តិ របស់គាត់ស្របតាមតំរូវការរបស់ច្បាប់ ដែលធ្លាក់ចុះខ្សោយ ដោយ សារតែលទ្ធផលនៃជំងឺ ឬបញ្ហាស្មារតីឬឥទ្ធិពលដោយសារជាតិពុល។~~

~~(i) អាយុចុងចោទនៅពេលប្រព្រឹត្តបទឧក្រិដ្ឋ។~~

~~(j) ថាតើចុងចោទជាអ្នកផ្សំគំនិតក្នុងបទល្មើស ហើយការចូលរួមរបស់គេក្នុងការប្រព្រឹត្តបទល្មើស គឺពាក់ព័ន្ធតិចតួច។~~

~~(k) លក្ខខណ្ឌដ៏ទៃផ្សេងទៀត ដែលបន្ធូរបន្ថយទម្ងន់នៃ បទឧក្រិដ្ឋ សូម្បីតែលក្ខខណ្ឌនោះមិនមែនជាហេតុផលស្របច្បាប់ សម្រាប់ ការប្រព្រឹត្តឧក្រិដ្ឋកម្មក៏ដោយ។~~

~~បន្ទាប់ពីបានឮ និងទទួលបានគ្រប់ភស្តុតាង ហើយបន្ទាប់ពីបានឮនិងបានពិចារណាលើជម្លោះប្រឹក្សា អ្នកកាត់សេចក្តីលើអង្គហេតុ ត្រូវ ពិចារណា យកចិត្តទុកដាក់ និងផ្តល់មត្តទេសន៍ដោយការបង្កើនទម្ងន់ និងសម្រាលដល់លក្ខខណ្ឌទាំងអស់ យោងទៅតាមផ្នែកនេះ និងត្រូវ បង្ខំកាត់ទោសប្រហារជីវិត បើសិនជាអ្នកកាត់សេចក្តីលើអង្គហេតុ សម្រេចមតិចុងក្រោយថា លក្ខខណ្ឌបង្កើនទម្ងន់ទោស ធ្ងន់ជាង លក្ខ ខណ្ឌសម្រាលទោស តែបើសិនអ្នកកាត់សេចក្តីអង្គហេតុកំណត់ថា លក្ខខណ្ឌសម្រាលទោស ធ្ងន់ជាងលក្ខខណ្ឌបង្កើនទម្ងន់ទោស អ្នក កាត់សេចក្តីអង្គហេតុត្រូវឱ្យជាប់ឃុំឃាំងក្នុងពន្ធធានាគាររដ្ឋអស់មួយជីវិត ដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង។~~

ផ្នែក8 - ផ្នែក190.4នៃក្រមព្រហ្មទណ្ឌត្រូវធ្វើវិសោធនកម្ម ត្រូវបកស្រាយថា ៖

190.4. (a) 190.4 (a) គ្រប់ពេលដែលលក្ខខណ្ឌពិសេស ដូចបានចែងរៀបរាប់ក្នុងផ្នែក190.2 ត្រូវបានបញ្ជាក់អះអាង ហើយអ្នកជំនុំជម្រះអង្គហេតុបានពិនិត្យឃើញថា ចុងចោទមានទោសបញ្ញាតិថ្នាក់ទី1អ្នកជំនុំជម្រះអង្គហេតុត្រូវធ្វើការពិនិត្យពិសេសមួយ អំពីការពិតនៃលក្ខខណ្ឌពិសេសដែលបានអះអាងនោះផងដែរ។ ការកំណត់ការពិតណាមួយ ឬលើរាល់លក្ខខណ្ឌពិសេសទាំងអស់ ត្រូវបានធ្វើឡើងដោយអ្នកជំនុំជម្រះអង្គហេតុ លើវត្ថុតាងដែលបានបង្ហាញនៅក្នុងអង្គជំនុំជម្រះក្តី ~~ឬនៅសវនាការ ដោយអនុលោមតាមផ្នែករង(b) នៃផ្នែក190.1។~~

ក្នុងករណីមានមន្ទិលសង្ស័យ ថាតើលក្ខខណ្ឌពិសេសជាការពិត ចុងចោទមានសិទ្ធិបដិសេធថាការពិនិត្យមិនត្រឹមត្រូវ។ អ្នកជំនុំជម្រះអង្គហេតុ ត្រូវធ្វើការពិនិត្យពិសេសមួយ ថាតើ លក្ខខណ្ឌពិសេសនីមួយៗដែលបានចោទប្រកាន់ពិត ឬមិន ពិត។ ពេលដែលលក្ខខណ្ឌពិសេសតំរូវការភស្តុតាងបង្ហាញពីការប្រព្រឹត្តិ ឬប៉ុនប៉ងប្រព្រឹត្តិបទឧក្រិដ្ឋ បទឧក្រិដ្ឋដូចនេះត្រូវបានចោទប្រកាន់ និងបញ្ជាក់អះអាង ដោយអនុលោមតាមច្បាប់ទូទៅ អនុវត្តប្រើក្នុងអង្គជំនុំជម្រះក្តី និងការដាក់ទោសលើបទឧក្រិដ្ឋ។

បើសិនចុងចោទត្រូវបានកាត់ទោសដោយតុលាការ ដែលគ្មានសមាជិកគណៈវិនិច្ឆ័យ អ្នកជំនុំជម្រះអង្គហេតុត្រូវតែជាសមាជិកគណៈវិនិច្ឆ័យ លុះត្រាតែសមាជិកគណៈវិនិច្ឆ័យត្រូវបានបោះបង់សិទ្ធដោយចុងចោទ ឬប្រជាពលរដ្ឋ ក្នុងករណីនេះអ្នកជំនុំជម្រះអង្គហេតុត្រូវតែជាតុលាការ។ បើសិនចុងចោទ ត្រូវបានកាត់ទោសដោយការទទួលស្គាល់ពិរុទ្ធភាព អ្នកជំនុំជម្រះអង្គហេតុ ត្រូវជាតែសមាជិកគណៈវិនិច្ឆ័យ លុះត្រាតែសមាជិកគណៈវិនិច្ឆ័យ ត្រូវបានបោះបង់សិទ្ធចោលដោយចុងចោទ ឬដោយប្រជពលរដ្ឋ។

បើសិនជាអ្នកកាត់សេចក្តីអង្គហេតុ បានពិនិត្យឃើញថាលក្ខខណ្ឌពិសេសណាមួយ ឬច្រើនដូចបានចែងរៀបរាប់ក្នុង ផ្នែក190.2 ដូចបានចោទប្រកាន់ជាកាពិត ~~ដូច្នេះត្រូវមានសវនាការទោសបញ្ញាត្តិដាច់ដោយឡែកមួយផ្សេងទៀត~~ *ចុងចោទត្រូវទទួលទារុណកម្មដោយដាក់ពន្ធធានាគាររដ្ឋអស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង* ~~និងទោះបីជាការពិនិត្យដែលថាលក្ខខណ្ឌពិសេសដែលនៅសល់ ដែលបានចោទប្រកាន់ជាការពិតឬអ្នកកាត់សេចក្តីលើអង្គហេតុមិនមែនជាសមាជិកគណៈវិនិច្ឆ័យ ភាពអសមត្ថភាពរបស់សមាជិក គណៈវិនិច្ឆ័យក្នុងការឯកភាពលើភាពពិតឬមិនពិតនៃលក្ខខណ្ឌពិសេសដែលនៅសល់ដែលត្រូវបានចោទប្រកាន់នោះ មិនត្រូវរារាំងការធ្វើសវនាការពិរុទ្ធភាពដាច់ដោយឡែកឡើយ។~~

~~ក្នុងករណីណា ដែលចុងចោទបានពិនិត្យឃើញថាមានពិរុទ្ធភាព ដោយសមាជិកគណៈវិនិច្ឆ័យ ហើយសមាជិកគណៈវិនិច្ឆ័យមិនអាចធ្វើការសម្រេចជាឯកច្ឆន្ទ ដែលថាលក្ខខណ្ឌពិសេសមួយ ឬច្រើនដែលបានចោទប្រកាន់ជាការពិត ហើយមិនអាចសម្រេចជាឯកច្ឆន្ទ ដែលថាលក្ខខណ្ឌពិសេសទាំងអស់គឺមិនពិត តុលាការត្រូវរំលាយចោលសមាជិកគណៈវិនិច្ឆ័យចាស់ ហើយត្រូវរើសសមាជិកគណៈវិនិច្ឆ័យថ្មី បញ្ចូលក្នុងបញ្ជីគណៈវិនិច្ឆ័យដើម្បីជំនំជម្រះបញ្ហាទាំងនេះ ប៉ុន្តែបញ្ហាទោសបញ្ញាត្តិមិនត្រូវជំនុះជម្រះដោយសមាជិកគណៈវិនិច្ឆ័យ ឬសមាជិកគណៈវិនិច្ឆ័យមិនត្រូវជំនុះជម្រះឡើងវិញលើបញ្ហាការពិតនៃលក្ខខណ្ឌពិសេសណាមួយ ដែលបាន ពិនិត្យឃើញ ដោយមានការសម្រេចជាឯកច្ឆន្ទពីសមាជិកគណៈវិនិច្ឆ័យមុនដែលថាមិនពិត។ បើសិនជាសមាជិកគណៈវិនិច្ឆ័យថ្មីមិនអាចឈានទៅរកការសម្រេចជាឯកច្ឆ័ន ដែលលក្ខខណ្ឌពិសេសមួយ ឬច្រើនកំពុងជំនុះជម្រះត្រូវ អនុម័ត តុលាការត្រូវរំលាយចោលសមាជិកគណៈវិនិច្ឆ័យ និងក្នុង ឆន្ទានុសិទ្ធិតុលាការត្រូវជ្រើសរើសសមាជិកគណៈវិនិច្ឆ័យថ្មី បញ្ចូលក្នុងបញ្ជីគណៈវិនិច្ឆ័យដើម្បីជំនុះជម្រះចំណុចវិវាទដែលសមាជិគណៈវិនិច្ឆ័យមុន មិនអាចឈានទៅដល់ការសម្រេចជាឯកច្ឆន្ទបាន ឬប្រកាសទារុណកម្មនៃការឃុំឃាំងក្នុងពន្ធធានាគាររដ្ឋ រយៈពេល 25ឆ្នាំ។~~

~~(b) បើសិនជាចុងចោទ ត្រូវបានកាត់ទោសតាមក្រុមខ័ណ្ឌរបស់តុលាការ ដោយគ្មានសមាជិកគណៈវិនិច្ឆ័យ អ្នកកាត់សេចក្តីលើអង្គហេតុនៅសវនាការទោសបញ្ញាត្តិ ត្រូវជាសមាជិក គណៈវិនិច្ឆ័យ លុះត្រាតែ សមាជិកគណៈវិនិច្ឆ័យត្រូវបានគេបញ្ឈប់សិទ្ធិដោយចុងចោទ និងប្រជាពលរដ្ឋ ដែលជំរុញឱ្យអ្នកកាត់សេចក្តីលើអង្គហេតុ ត្រូវជាតុលាការ។ បើសិនចុងចោទត្រូវបានកាត់ទោស ដោយការសារភាពទទួលពិរុទ្ធភាព អ្នកជំនុំជម្រះអង្គហេតុត្រូវជាសមាជិកគណៈវិនិច្ឆ័យ លុះត្រាតែសមាជិកគណៈវិនិច្ឆ័យត្រូវបានបញ្ឈប់សិទ្ធិ ដោយចុងចោទ និងប្រជាពលរដ្ឋ។~~

~~បើសិនជាអ្នកជំនុំជម្រះអង្គហេតុ ជាសមាជិកគណៈវិនិច្ឆ័យ ហើយមិនអាចឈានទៅរកការសម្រេចជាឯកច្ឆន្ទបាន ដូចអ្វីដែលត្រូវជាទោសបញ្ញាត្តិ តុលាការត្រូវតែរំលាយចោលសមាជិកគណៈវិនិច្ឆ័យ ហើយជ្រើសរើសសមាជិកគណៈវិនិច្ឆ័យថ្មី បញ្ចូលក្នុងបញ្ជីគណៈវិនិច្ឆ័យ ដើម្បីជំនុំជម្រះចំណុចវិវាទដូចទៅនឹងអ្វីដែលជាទោសបញ្ញាត្តិ។ តែប្រសិនបើសមាជិកគណៈវិនិច្ឆ័យថ្មីមិនអាចឈានទៅរកការសម្រេចជាឯកច្ឆន្ទដូចអ្វីដែលជាទោសបញ្ញាត្តិបាន ដូច្នេះឆន្ទានុសិទ្ធិរបស់តុលាការ អាចជ្រើសរើសសមាជិកគណៈវិនិច្ឆ័យថ្មី ឬប្រកាសទារុណកម្ម នៃការដាក់ឃុំឃាំងក្នុងពន្ធធានាគាររដ្ឋ អស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង។~~

~~(c)~~ (b) បើសិនជាអ្នកជំនុំជម្រះអង្គហេតុ ដែលបានដាក់ទោសចុងចោទពីបទឧក្រិដ្ឋណាមួយ ដែលចុងចោទត្រូវជាប់ពន្ធធានាគារអស់មួយជីវិត ដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង ~~ទោសប្រហារជីវិតគឺសមាជិកគណៈវិនិច្ឆ័យ~~ សមាជិកគណៈវិនិច្ឆ័យដដែល ត្រូវពិចារណាចម្លើយរបស់ចុងចោទថាមិនមានពិរុទ្ធភាព ដោយហេតុផលថាមានវិបត្តិស្មារតីដែលអនុលោមតាមផ្នែក1026 និងភាពពិតនៃលក្ខខណ្ឌពិសេសណាមួយ ដែលអាចចាត់ជាទឡ្ហីកម្ម ~~ហើយត្រូវដាក់ទោសបញ្ញាត្តិ~~ លុះត្រាតែសម្រាប់បុព្វហេតុល្អ បង្ហាញថាតុលារបញ្ឈប់សមាជិកគណៈវិនិច្ឆ័យ ហើយត្រូវជ្រើសរើសសមាជិកគណៈវិនិច្ឆ័យថ្មី។ តុលាការត្រូវថ្លែងអង្គហេតុគាំទ្រការពិនិត្យបុព្វហេតុល្អ អាស្រ័យលើកំណត់ត្រា និងចុះបញ្ចូលក្នុងកំណត់ហេតុ។

~~(d) ក្នុងករណីណាក៏ដោយ ដែលចុងចោទអាចទទួលទោសប្រហារជីវិត ការបង្ហាញភស្តុតាងនៅមុនដំណាក់កាលកាត់ក្តី រួមទាំងមុនដំណាក់កាលជំនុំជំរះក្តី ក្រោមចម្លើយរបស់ចុងចោទថាមិនមានពិរុទ្ធភាពដោយហេតុផលថាមានវិបត្តិស្មារតី ដែលអនុលោមតាមផ្នែក១០២៦ ត្រូវតែពិចារណាលើដំណាក់បន្ទាប់នៃការជំនុំជម្រះក្តី បើសិនអ្នកកាត់សេចក្តីលើអង្គហេតុនៃ~~

34

~~ដំណាក់កាលមុន ដូចនឹងអ្នកជំនុំជម្រះអង្គហេតុដំណាក់កាលបន្ទាប់។~~

~~(c) គប្រ់ករណីទាំងអស់ ដែលអ្នកជំនុំជម្រះអង្គហេតុបានប្រគល់ការសម្រេចចិត្ត ឬការពិនិត្យប្រកាសទោសប្រហារជីវិត ចុងចោទត្រូវតែចាត់ទុកថាបានដាក់ពាក្យស្នើសុំសម្រាប់ការកែប្រែ ការសម្រេចចិត្ត ឬការពិនិត្យបែបនេះ ដោយអនុលោមតាមផ្នែករង៧ នៃផ្នែក11។ ក្នុងការសម្រេចពាក្យស្នើសុំ ចៅក្រមត្រូវពិនិត្យភស្តុតាងឡើងវិញ ពិចារណា យកចិត្តទុកដាក់ ហើយផ្តល់មត្តទេសន៍ ដោយបង្កើនទម្ងន់ទោស ឬសម្រាលទោសផ្អែកតាមលក្ខខណ្ឌយោងទៅតាមផ្នែក190.3 ហើយត្រូវធ្វើការកំណត់ ថាតើការពិនិត្យ និងការសម្រេចចិត្តរបស់សមាជិកគណៈវិនិច្ឆ័យដែលថាការទម្ងន់ទោសលើលក្ខខណ្ឌ ឬសម្រាលទោសលើលក្ខខណ្ឌ គឺផ្ទុយពីច្បាប់ ឬភស្តុតាងដែលបានបង្ហាញ។ ចៅក្រមត្រូវថ្លែងនូវកំណត់ហេតុនៃហេតុផលសម្រាប់ការពិនិត្យរបស់ខ្លួន។~~

~~ចៅក្រមត្រូវពន្យល់ឱ្យច្បាស់ពីហេតុផល សម្រាប់ការសម្រេចលើពាក្យស្នើសុំ ហើយប្រាប់ថាហេតុផលទាំងនេះនឹងកត់ត្រាចូលក្នុងកំណត់ហេតុរបស់ស្មៀន។ ការបដិសេដលើការកែសម្រួលការសម្រេចចិត្តទោសប្រហារជីវិតអនុលោមតាមផ្នែករង(7) នៃផ្នែក1181 ត្រូវតែពិនិត្យឡើងវិញលើការប្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិរបស់ចុងចោទ ដោយអនុលោមតាមផ្នែករង(b) នៃផ្នែក 1239។ ការអនុញ្ញាតិពាក្យស្នើសុំ ត្រូវតែពិនិត្យលើបណ្តឹងឧទ្ធរណ៍របស់ប្រជាពលរដ្ឋ ដោយអនុលោមតាមកថាខណ្ឌ(6)។~~

ផ្នែក 9. ជំពូក33 (ចាប់ផ្តើមដោយផ្នែក 7599) គឺត្រូវបានបន្ថែម លើផ្នែក 7 នៃចំណងទី1 នៃក្រមរដ្ឋាភិបាល ត្រូវបកស្រាយថា ៖

*ជំពូកទី33 - មូលនិធិសេហ្វកាលីហ្វ័រញ៉ា ដើម្បីបណ្តាក់លើអំពើរំលោភសេពសន្ថវៈ និងឃាតកម្ម*

*មាត្រាទី1 - ការបង្កើតមូលនិធិសេហ្វកាលីហ្វ័រញ៉ា*

*7599. មូលនិធិពិសេសមួយដែលត្រូវបានគេស្គាល់ថា"មូលនិធិសេហ្វកាលីហ្វ័រញ៉ា" ត្រូវបានបង្កើតឡើងនៅក្នុងរតនាគាររដ្ឋ ហើយបន្តលៃលកទុកសម្រាប់អនុវត្តគោលបំណងនៃផ្នែកនេះ។*

*មាត្រាទី2 - ការលៃទុក និងត្រៀមបំរុងមូលនិធិ*

*7599.1. ការលៃទុកមូលនិធិ*

*នៅថ្ងៃទី 1 ខែមករា ឆ្នាំ2013 ទឹកប្រាក់ដប់លានដុល្លា ($10.000.000) ត្រូវផ្ទេរពីមូលនិធិទូទៅ ទៅមូលនិធិសេហ្វកាលីហ្វ័រញ៉ា សម្រាប់ឆ្នាំសារពើពន្ធ 2012-13 ហើយត្រូវបន្តលៃទុក សម្រាប់គោលបំណងនៃទង្វើដែលបានន្ថែមលើជំពូកនេះ។ នៅថ្ងៃទី01 ខែកក្កដា នៃឆ្នាំសារពើពន្ធនិមួយៗចាប់ពី 2013-14 និង2015-16ទឹកបាក្រ់បូកបន្ថែមចំនួន សាមសិបលានដុល្លា ($30.000.000) ត្រូវផ្ទេរពីមូលនិធិទូទៅ មកមូលនិធិសេហ្វកាលីហ្វ័រញ៉ា ហើយត្រូវបន្តលៃទុកសម្រាប់គោលបំណងនៃទង្វើដែលបានបន្ថែមក្នុងជំពូកនេះ។ មូលនិធិដែលបានផ្ទេរចូលក្នុងមូលនិធិសេហ្វកាលីហ្វ័រញ៉ា ត្រូវបានប្រើតែសម្រាប់គោលបំណងនៃទង្វើដែលបានបន្ថែម ក្នុងជំពូកនេះតែមួយគត់ ហើយមិនត្រូវលៃទុកឬផ្ទេរដោយអង្គនីតិបញ្ញត្តិសម្រាប់គោលបំណងផ្សេងឡើយ។ មូលនិធិនៅក្នុងមូលនិធិសេហ្វកាលីហ្វ័រញ៉ា អាចត្រូវបានប្រើដោយមិនពាក់ព័ន្ធនឹងឆ្នាំសារពើពន្ធ។*

*7599.2. ការបរិច្ចាកលុយពីមូលនិធិសេហ្វកាលីហ្វ័រញ៉ា។*

*(a) ក្រោមការដឹកនាំរបស់អគ្គព្រះរាជអាជ្ញាសវនករ ត្រូវចែកចាយលុយដែលបានសន្សំទុក ក្នុងមូលនិធិសេហ្វកាលីហ្វ័រញ៉ា ទៅនាយកដ្ឋាននរគបាល នរគបាលមូលដ្ឋាន ការិយាល័យមេធាវីខោនធី សម្រាប់គោលបំណងបង្កើនអត្រានៃការដោះស្រាយករណីមនុស្សឃាត និងរំលោភសេពសន្ថវៈ។ គម្រោង និងសកម្មភាពដែលអាចនឹងផ្តល់ថវិការរួមមាន -ប៉ុន្តែមិនមែនកំណត់សម្រាប់តែ- ការពន្លឿនដំណើរការប្រមូលរកវត្ថុតាងរូបវន្តក្នុងករណីរំលោភ សេពសន្ថវៈ លើកកម្ពស់សមត្ថភាពនិងលទ្ធភាពក្នុងការធ្វើកោសល្យវិច្ច័យ រួមទាំងការវិភាគនិងបន្សី DNA បង្កើនចំនួនបុគ្គលិកក្នុងអង្គភាពព្រះរាជ អាជ្ញា និងការស៊ើបអង្កេតបទល្មើសផ្លូវភេទ និងមនុស្សឃាត និងការរើទីតាំង របស់សាក្សី។ ថវិការពីមូលនិធិសេហ្វកាលីហ្វ័រញ៉ា ត្រូវបានលៃបំរុងទុក សម្រាប់នាយកដ្ឋាននរគបាល នរគបាលមូលដ្ឋាន និងការិយាល័យមេធាវី ខោនធី តាមរយៈរូបមន្តបរិច្ចាកយ៉ាងត្រឹមត្រូវ និងស្មើភាព ដែលនឹងកំណត់ដោយអគ្គព្រះរាជអាជ្ញា។*

*(b) រាល់ការចំណាយទាក់ទិននឹង ការលៃទុក និងបរិច្ចាកមូលនិធិទាំងនេះត្រូវបានកាត់ចេញពីមូលនិធិសេហ្វកាលីហ្វ័រញ៉ា។ អគ្គព្រះរាជអាជ្ញានិងសវនាករ ត្រូវតែខិតខំប្រឹងប្រែងដើម្បីរក្សានូវតំលៃនៃការលៃបំរុងទុក និងបរិច្ចាកនៅកំរិតក្បៀសសូន្យ ដើម្បីធានាថាចំនួនអតិប្បរិមានៃមូលនិធិ បានលៃបំរុងទុកសម្រាប់កម្មវិធី និងសកម្មភាពបង្កើនអត្រានៃការដោះស្រាយករណីរំលោភសេពសន្ថវៈ និងមនុស្សឃាត។*

ផ្នែក10 - ច្បាប់បណ្តឹងប្រតិសកម្ម

(a) ដើម្បីទទួលជោគជ័យដ៏ល្អបំផុត លើគោលបំណងនៃច្បាប់នេះដូចបានថ្លែងក្នុងផ្នែក៣ ហើយដើម្បីជោគជ័យលើភាពត្រឹមត្រូវ សមភាព និងឯកភាពលើការកាត់ទោស ច្បាប់នេះត្រូវតែគោរពអនុវត្តយ៉ាងប្រតិសកម្ម។

(b) ក្នុងករណី ដែលចុងចោទ ឬអ្នកទោសត្រូវបានកាត់ទោសប្រហារជីវិតមុននឹងច្បាប់នេះចូលជាធរមាន ការកាត់ទោសត្រូវប្តូរដោយស្វ័យប្រវត្តិ ទៅជាដាក់ពន្ធធានាគាររដ្ឋអស់មួយជីវិតដោយអាចនឹងគ្មានលក្ខខណ្ឌដោះលែង នៅក្រោមខចែង និងលក្ខខណ្ឌនៃច្បាប់នេះ។

(c) បន្ទាប់ពីច្បាប់នេះចូលជាធរមាន តុលាការកំពូលអាច ផ្ទេរាល់បណ្តឹងឧទ្ធរណ៍ទោសប្រហារជីវិត និងបណ្តឹងទាមទារដីការកោះហៅ ដោយព្យួរទុកមុនមកដល់តុលារកំពូល ទៅសាលាឧទ្ធរណ៍មូលដ្ឋាន ក្នុងឆន្ទានុសិទ្ធិតុលាការកំពូល។

វគ្គទី 11. កាលបរិច្ឆេទចូលជាធរមាន

ច្បាប់នេះ ត្រូវចូលធរមាននៅថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដោយអនុលោមតាមផ្នែករង(a) នៃផ្នែក10 នៃមត្រាII នៃច្បាប់រដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ។

ផ្នែក12 - ខបំរុង

ខចែងក្នុងច្បាប់នេះគឺនៅមានចំនុចសេសសល់ប្រសិនបើខចែងក្នុងច្បាប់នេះ ឬពាក្យស្នើសុំរបស់ច្បាប់នេះអស់សុពលភាព រួមទាំង ប៉ុន្តែមិន កំហិតលើវគ្គទី៣ភាពទុកជាមោឃៈមិនត្រូវបានជះឥទ្ធិពលដល់ខចែងឬពាក្យស្នើសុំដ៏ទៃទៀតដែលអាចចូលជាធរមានដោយគ្មានខចែង ឬពាក្យ ស្នើសុំ។



## សំណើប្រជាមតិ 35

វិធានការផ្តើមប្រជាសិទ្ធិនេះគឺត្រូវបានដាក់ឱ្យប្រជាពលរដ្ឋដោយអនុលោមទៅតាមខដែលមានចែងក្នុងវគ្គទី 8នៃមាត្រា IIនៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រ ញ៉ា។

វិធានការ ផ្តើមប្រជាសិទ្ធិនេះកែប្រែនិងបន្ថែមផ្នែកមួយទៅលើក្រមនៃភស្តុតាងនិងកែប្រែនិងបន្ថែមចំណងជើងនិងផ្នែកខ្លះរបស់ជំពូកមួយ ទៅលើក្រមព្រហ្មទណ្ឌដូចនេះខចែងមានស្រាប់ដែលបានស្នើឡើងដើម្បីលុបចោល ត្រូវបោះពុម្ពចេញ ជា~~លក្ខណៈឆ្នូតលុបកាត់~~ ហើយខចែងថ្មីដែលបានស្នើឡើងដើម្បីបន្ថែមត្រូវបោះពុម្ពចេញជា *លក្ខណៈអក្សរទ្រេត* ដើម្បីបញ្ជាក់ថាវាថ្មី។

## ច្បាប់ដែលស្នើ

ច្បាប់អ្នករដ្ឋកាលីហ្វ័រញ៉ាប្រឆាំងនឹងការកេងប្រវ័ញ្ចខាងផ្លូវភេទ ("ច្បាប់ CASE")

វគ្គទី 1. ចំណងជើង

វិធានការនេះគួរត្រូវបានគេស្គាល់ និងអាចត្រូវបានកំណត់ថាជា "ច្បាប់របស់អ្នករដ្ឋកាលីហ្វ័រញ៉ាប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទ"("ច្បាប់ CASE")

វគ្គទី2. ការរកឃើញ និងសេចក្តីប្រកាស

ប្រជាពលរដ្ឋសហរដ្ឋអាមេរិច នៃរដ្ឋកាលីហ្វ័រញ៉ារកឃើញ និង ថ្លែងកាណ៏៖

1. ការគាំពារដល់ជនគ្រប់រូប នៅក្នុងរដ្ឋរបស់យើង ជាពិសេសកុមារពីគ្រប់សណ្ឋាននៃការធ្វើអាជីវកម្មផ្លូវភេទ ដែលនេះជា ចំនុចសំខាន់។

2. ការជួញដូរមនុស្ស គឺជាបទល្មើសប្រឆាំងនិងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងជាការប្រព្រឹត្តល្មើសយ៉ាងធ្ងន់ធ្ងរលើសិទ្ធមូលដ្ឋានរស់នៅរបស់មនុស្ស និង ប្រជាជន។ ការជួញដូរមនុស្សគឺជា ទាសភាព បែបមួយថ្មីជាក់ស្តែងតាមការឆ្លៀតយកប្រយោជន៏ពីអ្នកដទៃ (ភេទនីយ)។

3. យោងតាមក្រសួងសិក្សាយុត្តិធម៏សហរដ្ឋអាមេរិច បានឱ្យដឹងថាកុមារអាមេរិចច្រើនជាង 300.000 នាក់កំពុងប្រឈមមុខនិងការជួញដូរកេងចំណេញខាងផ្លូវភេទ។ភាគច្រើននៃកុមារទាំងនោះត្រូវបានល្បួង ឱ្យជាជំនួយផ្លូវភេទនៅចន្លោះអាយុ12 ដល់14ឆ្នាំ។ ប៉ុន្តែកុមារ ខ្លះបានចរាចរអស់រយះ

ពេល4ឆ្នាំ។ ព្រោះអនិតិជនអសមត្ថភាព និងមិនយល់ស្របធ្វើសកម្មភាពផ្លូវភេទ ដូច្នេះអនិតិជនទាំងនោះជាអ្នករងគ្រោះពីសំណាក់អ្នកធ្វើអាជីវកម្មមនុស្សទោះអត់ពេញចិត្តធ្វើឬអត់និងត្រូវរងការធ្វើទារុណកម្ម។

4. ខណៈនៃកាកើនឡើងនៃអិនធើណែត បានរីករាលដាលដល់កាលីហ្វ័រញ៉ា ពួកបីសាចបានប្រើបច្ចេកទិទ្យានេះដោយអ្នកជួញដូរមនុស្ស និងអ្នកប្រមាទផ្លូវភេទអនុញ្ញាត្តឱ្យកេញចំនេញប្រយោជន៏ក្នុងន័យថា ដើម្បីល្បួងលើជនណាម្នាក់ដែលអាចបោកប្រាស់បាន នៅក្នុងរដ្ឋយើង។

5. យើងត្រូវការពង្រឹងច្បាប់ដើម្បីប្រយុទ្ធរាល់គំនិតគំរាមកំហែងតាមការចោទសួរតាមផ្លូវច្បាប់ ដោយអ្នកជួញដូរមនុស្ស និងពួកបីសាច់មានគោលបំណងស្វែងរកស្ត្រីនិងកុមារសំរាប់អាជីវកម្មផ្លូវភេទ។

6. យើងត្រវពង្រឹងសេចក្តីតំរូវការចុះឈ្មោះជនប្រព្រឹត្តិល្មើសផ្លូវភេទ ដើម្បីបន្ទចបង្អាក់ពួកជញ្ជក់ឈាមក្នុងការប្រើប្រាស់ អិនធើណិត សំរាប់សំរួលការជួញដូរមនុស្សនិងកេងប្រវ័ញ្ចផ្លូវភេទរបស់គេ។

វគ្គទី 3. គោលបំណង និងចេតនា

ប្រជាពលរដ្ឋក្នុងរដ្ឋកាលីហ្វ័រញ៉ា ប្រកាសពីគោលបំណងនិងចេតនារបស់ពួកគេក្នុងការអនុម័តលើច្បាប់ CASE ដូចខាងក្រោម៖

1. ដើម្បីធ្វើការប្រយុទ្ធប្រឆាំងបទល្មើសការជួញដូរមនុស្សនិងធានានូវការដាក់ពិន័យប្រកបដោយយុត្តិធម៏ និងមានប្រសិទ្ធិភាពលើអ្នក ដែលផ្សព្វផ្សាយឬចូលរួមជាមួយបទឧក្រិដ្ឋនៃការជួញដូរមនុស្ស។

2. ដើម្បីទទួលស្គាល់នូវបុគ្គលដែលត្រូវបានគេចរាចរដែលជាជនរងគ្រោះហើយមិនមែនជាឧក្រិដ្ឋជន និងដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះដែលត្រូវបានគេចរាចរ។

3. ដើម្បីពង្រឹងច្បាប់ទាក់ទងនឹងកាកេងប្រវ័ញ្ចផ្លូវភេទ រួមមានតម្រវការការចុះឈ្មោះអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ (sex offender) ដើម្បី ឱ្យអ្នកពង្រឹងច្បាប់អាចតាមដាន និងបង្កាអ្នកប្រព្រឹត្តបទល្មើសនិង ចរាចរផ្លូវភេទតាមប្រព័ន្ធអ៊ីនធើណែត។

វគ្គទី 4. ផ្នែក1161 ត្រូវបានបញ្ចូលទៅក្នុងក្រមភស្តុតាង (Evidence code) ត្រូវបកស្រាយថា៖

*1161. (a) ភស្តុតាងដែលជនរងគ្រោះនៃការរត់ពន្ធមនុស្សដូចកំណត់ក្នុងផ្នែក 236.1 នៃក្រមព្រហ្មទណ្ឌ គឺបានចូលរួមក្នុងសកម្មភាពជួញដូរផ្លូវភេទដែលជាលទ្ធផលក្នុងនាមជនរងគ្រោះនៃការរត់ពន្ធមនុស្សគឺមិនអាចអនុញ្ញាតិដើម្បីបង្ហាញថាការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ជនរងគ្រោះដោយហេតុផលណាដែលទាក់ទងនឹងសកម្មភាពនោះទេ។*

*(b) ភស្តុតាងនៃប្រវត្តិផ្លូវភេទឬ ប្រវត្តិនៃសកម្មភាពអាជីវកម្មផ្លូវភេទណាមួយរបស់ជនរងគ្រោះពីការចរាចរផ្លូវភេទម្នាក់ដែលបានកំណត់ក្នុងផ្នែក 236.1 នៃក្រមព្រហ្មទណ្ឌ គឺមិនអាចអនុញ្ញាតិដើម្បីវាយប្រហារភាពគួរជឿជាក់បានឬចោទប្រកាន់ចរិកលក្ខណៈរបស់ ជនរងគ្រោះនៅក្នុងនីតិវិធីរដ្ឋប្បវេណីឬព្រហ្មទណ្ឌ។*

វគ្គទី5. ចំណងជើងកថាភាគទី8 (ចាប់ផ្តើមជាមួយនឹងផ្នែក236) នៃចំណងជើងទី 8 វគ្គ1នៃក្រមព្រហ្មទណ្ឌគឺបានកែប្រែឱ្យបកស្រាយថាៈ

កថាភាគទី8. ការដាក់គុកដោយភាន់ច្រឡំ និងការចរាចរមនុស្សខុសច្បាប់

វគ្គទី 6. ផ្នែក 236.1 នៃក្រមព្រហ្មទណ្ឌ គឺត្រូវបានកែប្រែឱ្យបកស្រាយថាៈ

236.1. (a) អ្នកណាម្នាក់ដែលដកហូតឬរំលោភសេរីភាពបុគ្គលដទៃដោយចេតនា~~ឱ្យរងផលប៉ះពាល់ឬរក្សាការរំលោភឧក្រិដ្ឋនៃផ្នែក 266, 266h, 266i, 267, 311.4, ឬ 518,~~ ឬ ដើម្បីទទួលបាននូវកំលាំងការងារឬសេវាកម្មដោយបង្ខំគឺជាមានកំហុសខាងការជួញដូរមនុស្ស និង*គួរតែដាក់ទោសដោយការឃុំខ្លួន ក្នុងគុករដ្ឋរយៈពេល 5, 8, ឬ 12 ឆ្នាំ និងពិន័យជាប្រាក់មិនលើសពីប្រាំរយពាន់ដុល្លារ ($500.000)។*

~~(b) លើកលែងតែដូចមានចែងក្នុងអនុផ្នែក(c) ការរំលោភនៃផ្នែក នេះគឺអាចដាក់ទោសដោយការឃុំឃាំងនៅក្នុងពន្ធនាគាររដ្ឋរយៈ ពេលបី បួន ឬបាំឆ្នាំ។~~

~~(c) ការរំលោភនៃផ្នែកនេះដែលជនរងគ្រោះនៃការរត់ពន្ធមនុស្សមានអាយុក្រោម 18 ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស គឺអាចដាក់ទោសដោយការឃុំឃាំងនៅក្នុងពន្ធនាគាររដ្ឋរយៈពេល បួន បាំម្រួយ ឬបាំប្រីឆ្នាំ។~~

~~(d) (1) ការដកហូតមិនស្របច្បាប់ឬការរំលោភសេរីភាពបុគ្គល ដទៃណារួមមានការកំណត់យ៉ាងខ្លាំងនិងជាដរាបលើសេរីភាពរបស់បុគ្គលម្នាក់ដែលសំរេចបានតាមរយៈការបន្លំ ការបំភ័ន្ត ការបង្ខិតបង្ខំ អំពើហិង្សា ការឃុំឃាំង ការគំរាមកំហែងឬការសម្លុតនៃរបួសមិនស្របច្បាប់ទៅលើជនរងគ្រោះ ឬ បុគ្គលណាម្នាក់ទៀតនៅក្រោមកាលៈទេសៈដែលថាមនុស្សទទួលបានឬភ័យបារម្ភពីការសម្លុតដែលជឿដោយសមហេតុផលថាវាមានទំនោរថាបុគ្គលដែលធ្វើការសម្លុតនឹងអនុវត្តជាក់ស្តែង។~~

~~(2) ការឃុំឃាំងរួមមានការបំផ្លាញ ការបិទបាំង ការដកហូត ការរឹបអូសឬការកាន់កាប់លិខិតឆ្លងដែនឬឯកសារជនអន្តោប្រវេសន៍របស់ជនរងគ្រោះដ៏ជាក់ស្តែងឬដោយអះអាង ដោយចេតនា។~~

~~(e) សំរាប់គោលបំណងនៃផ្នែកនេះ "កំលាំងការងារឬសេវាកម្មដោយបង្ខំ"~~ មានន័យថាកំលាំងការងារឬសេវាកម្មដែលត្រូវបានអនុវត្ត ឬផ្តល់ជូនដោយបុគ្គលនិងត្រូវបានទទួលឬរក្សាទុកតាមរយៈកំលាំង ~~ការបន្លំ ឬការបង្ខិតបង្ខំ ឬលក្ខណៈសមមូលគ្នា ដែលបង្ខំឱ្យយល់ព្រមនូវឆន្ទៈរបស់បុគ្គលនោះដោយសមហេតុផល។~~

*(b) អ្នកណាម្នាក់ដែលដកហូតឬរំលោភសេរីភាពបុគ្គលដទៃ ដោយចេតនាឱ្យរងផលប៉ះពាល់ឬរក្សាការរំលោភឧក្រិដ្ឋនៃផ្នែក 266, 266h, 266i, 266j, 267, 311.1, 311.2, 311.3, 311.4, 311.5, 311.6, ឬ 518 គឺមានទោសខាងការជួញដូរមនុស្ស និងគួរតែដាក់ទោសដោយការឃុំខ្លួនក្នុងគុករដ្ឋរយៈពេល 8, 14, ឬ 20 ឆ្នាំនិងពិន័យជាប្រាក់ មិនលើសពីប្រាំរយពាន់ដុល្លារ ($500.000)។*

*(c) បុគ្គលណាក៏ដោយដែលបង្កហេតុ អូសទាញ ឬបញ្ចុះបញ្ចូល ឬ ប៉ុនប៉ងបង្កហេតុអ្វីមួយ ព្យាយាមអូសទាញ ឬបញ្ចុះបញ្ចូលអ្នកដែល ជាអនិតិជននៅពេលប្រព្រឹត្តបទល្មើសដែលចូលរួមក្នុងសកម្មភាពជួញដូរផ្លូវភេទដោយចេតនាបង្កហេតុ ឬរក្សាទុកបទល្មើសក្នុងផ្នែក 266, 266h, 266i, 266j, 267, 311.1, 311.2, 311.3, 311.4, 311.5, 311.6, ឬ 518 គឺមានទោសខាងការជួញដូរមនុស្ស។ ការរំលោភអនុផ្នែកនេះគឺអាចដាក់ទោសបានដោយការឃុំខ្លួនក្នុងពន្ធនាគាររដ្ឋដូចខាងក្រោមៈ*

*(1) ប្រាំ, .8 ឬ 12ឆ្នាំនិងពិន័យជាប្រាក់មិនលើសប្រាំរយពាន់ដុល្លារអាមេរិច ($500.000)។*

*(2) ដប់ប្រាំឆ្នាំទៅមួយជីវិតនិងពិន័យជាប្រាក់មិនលើសប្រាំរយពាន់ដុល្លារ ($500.000)នៅពេលបទឧក្រិដ្ឋជាប់ពាក់ព័ន្ធ និងការប្រើកំលាំង ការគំរាមកំហែង ការបន្លំ ការបោកប្រាស់ ការបង្ខិតបង្ខំ ហិង្សា ឃុំឃាំង បន្ទាច ឬគំរាមធ្វើឱ្យមានរបួសដោយការមិនស្របច្បាប់ទៅលើជនរងគ្រោះឬអ្នកដទៃទៀត។*

*(d) ក្នុងការសម្រេចចិត្តថាតើអនិតិជនត្រូវបានបង្កហេតុ អូសទាញ ឬបញ្ចុះបញ្ចូលអោយចូលរួមក្នុងការធ្វើសកម្មភាពជួញដូរផ្លូវភេទ អ្វីជា ព្រឹត្តិការណ៏ទាំងអស់នោះ រួមមាន អាយុជនរងគ្រោះ ទំនាក់ទនងរវាងពួកគេជាមួយអ្នកជួញដូរ ឬភ្នាក់ងារជួញដូរមនុស្ស ហើយពិការភាពឬអសមត្ថភាពរបស់ជនរងគ្រោះ គួរយកមកពិចារណា។*

*(e) ការយល់ស្របដោយជនរងគ្រោះនៃការជួញដូរមនុស្សដែលជាអនិតិជន នៅពេលប្រព្រឹត្តបទល្មើស គឺមិនមែនជាការការពារដល់ការកាត់ ទោសឧក្រិដ្ឋជន ក្រោមផ្នែកនេះទេ។*

*(f) កំហុសនៃព្រឹត្តិការណ៏ ដូចជាអាយុជនរងគ្រោះនៃការជួញដូរមនុស្សជាអនិតិជន នៅពេលគណកម្មារបទឧក្រិដ្ឋគឺគ្មានសិទ្ធការពារដល់ការ កាត់ទោសឧក្រិដ្ឋជនក្រោមផ្នែកនេះ។*

~~(f)~~ (g) ~~អង្គនីតិបញ្ញាត្តិរកឃើញថា និយមន័យនៃការជួញដូរមនុស្សនៅក្នុងផ្នែកនេះដែលមាននិយស្មើគ្នាទៅនឹងនិយមន័យសហព័ន្ធនៃទម្រង់ដ៏ធ្ងន់ធ្ងរនៃការជួញដូរដែលមានក្នុងផ្នែក 7102(8)ក្នុងចំណងជើងទី 22 នៃក្រមច្បាប់សហរដ្ឋអាមេរិច។~~

~~(g) (l) ជាបន្ថែមទៅលើការដាក់ទោសដូចដែលមានចែងនៅក្នុងអនុផ្នែក (c) បុគ្គលណាក៏ដោយដែលប្រព្រឹត្តការជួញដូរមនុស្សដែល រួមមានសកម្មភាពជួញដូរផ្លូវភេទ ដែលជនរងគ្រោះនៃការរត់ពន្ធមនុស្សមានអាយុតិចជាង~~

35

~~18 ឆ្នាំនៅពេលប្រព្រឹត្តបទល្មើសគួរតែដាក់ទោសដោយការពិន័យជាប្រាក់មិនលើសពីមួយរយពាន់ដុល្លារ ($100.000) ទេ។~~

~~(2) ដូចដែលមានប្រើនៅក្នុងអនុផ្នែក "ច្បាប់ពាណិជ្ជកម្មជួញដូរផ្លូវភេទ" មានន័យថា ការប្រព្រឹត្តផ្លូវភេទណា ខណៈដែលអ្វីៗដែលមានតំលៃត្រូវបានផ្តល់ឱ្យឬទទួលដោយបុគ្គលណាមួយ។~~

~~(h) រាល់ការពិន័យដែលបានដាក់និងប្រមូលស្របតាមផ្នែកនេះ គួរត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិជំនួយសាក្សីជនរងគ្រោះ ដើម្បីអោយមានសំរាប់ការលៃលកទុកផ្គត់ផ្គង់សេវាកម្មសំរាប់ជនរងគ្រោះនៃការជួញដូចរមនុស្ស។ យ៉ាងហោចណាស់ 50 ភាគរយនៃ បាក្រ់ពិន័យដែលប្រមូលបាននិងបានដាក់បញ្ចូលស្របតាមផ្នែកនេះគួរផ្តល់ឱ្យដល់អង្គការដែលមានមូលដ្ឋានលើសហាគម៉ន៍ដែលបំរើ ជនរងគ្រោះពីការជួញដូរមនុស្ស។~~

*(h) គោលបំណងក្នុងជំពូកនេះនិយមន័យខាងក្រោមអនុវត្តចំពោះ៖*

*(1) "ការបង្ខិតបង្ខំ" រួមមានផែនការណ៍ គ្រោងការណ៍នានា ឬគំរូ ដោយចេតនាបង្កធ្វើឲ្យមនុស្សណាម្នាក់មានជំនឿលើការមិនបាន ជោគជ័យនោះដែលសំដែងក្នុងលក្ខណៈថាលទ្ធផលចេញមកនិង មានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រាងកាយ ឬដាក់សំពាធប៉ះពាល់ប្រឆាំង ដល់នរណាម្នាក់ ការបញ្ឆោត ឬគំរាមកំហែង ពីដំណើរការច្បាប់ កូនបំណុលឬផ្តល់ការជួយសំរួលលើភាពជាម្ចាស់កាន់កាប់គ្រប់គ្រង ទៅ នរណាម្នាក់ដោយចេតនាធ្វើឲ្យចុះខ្សោយការវិនិច្ឆ័យរបស់បុគ្គល នោះ។*

*(2) "សកម្មភាពជួញដូរផ្លូវភេទ" មានន័យថាការដឹកនាំរៀបចំនិង ចរចាជារបស់មានតម្លៃអ្វីមួយជាថ្នូរដោយអ្នកបានឲ្យឬអ្នកបាន ទទួលបុគ្គលណាមួយនោះឡើយ។*

*(3) "ការដកសិទ្ធិ ឬការរំលោភបំពានសេរីភាពផ្ទាល់ខ្លួន នៃជនដទៃរួមមានខ្លឹមសារការដាក់កម្រិតលើសេរីភាពរបស់ជនដទៃទៀតបានសំរេចដោយកំលាំង ធ្វើឲ្យភ័យខ្លាច បន្លំបំភាន់ ការបោកប្រាស់ ការបង្ខិតបង្ខំ ហិង្សា ការឃុំឃាំង ការគំរាមគំហែង ឬការសម្លុតគំរាម ដោយការ បង្ករបួសខុសច្បាប់លើជនរងគ្រោះ ឬលើជនផ្សេងទៀត ស្ថិតក្រោមព្រឹត្តិការណ៍កន្លែងដែលជនរងគ្រោះទទួលឬយល់ថាការ គំរាមកំហែងសមហេតុផលជឿបានថារាល់អ្វីដែលជាការគំរាមកំហែងខាងលើប្រហែលជាជនអ្នកបង្ករការគំរាមនោះអាចនឹងធ្វើវា។*

*(4) "ការដាក់គុក" រាប់បញ្ចូល ការគំរាមកំហែងដោយផ្ទាល់ឬប្រយោលដោយកំលាំង ហិង្សា គ្រោះថ្នាក់ សេចក្តីលំបាកវេទនា ប្រសិទ្ធភាព នៃប្រាក់ឈ្នួល ដើម្បីធ្វើឲ្យមនុស្សមានវិចារណញ្ញាណម្នាក់ស្រុះស្រួលក្នុងការធ្វើ សកម្មភាពណាដែលគេចង់ឲ្យកើតផ្សេងពីនេះបើជនណា មិនព្រមចំណុះធ្វើ។ ការគំរាមកំហែងដោយផ្ទាល់ឬប្រយោលធ្វើការបំប្លិចបំផ្លាញ លាក់បាំង ផ្លាស់ប្តូរ រឹបអូសទ្រព្យសម្បត្តិ ឬមានកាន់កាប់ឬដែលអះអាងលើលិខិតឆ្លងដែន ឬឯកសារអន្តោប្រវេសន៏របស់ជន រងគ្រោះ ឬដោយដឹងច្បាស់ពីការបំផ្លាញ លាក់បាំង ផ្លាស់ប្តូរ រឹបអូស យកទ្រព្យសម្បត្តិឬមានការកាន់កាប់ឬដែលអះអាងលើលិខិតឆ្លងដែនឯកសារអន្តោប្រវេសន៏នៃជនរងគ្រោះ។*

*(5) "ការងារឬសេវាកម្មដោយបង្ខិតបង្ខំ" មានន័យថា ការងារ ឬសេវាកម្មដែលបានធ្វើ ឬបានផ្តល់ដោយមនុស្សម្នាក់ បានទទួលនិងបន្តរក្សាទុកដោយកំលាំងបាយ ការបង្ខិតបង្ខំ ការបង្ខាំង ឬការបោកបញ្ឆោតឬមានហេតុផលស្មើគ្នាទៅនិងការជិះជាន់លើឆន្ទៈនៃជននោះ។*

*(6) "ការរងរបួសសំខាន់ដល់រាងកាយ" មានន័យថាអ្វីគួរកត់សំគាល់ ឬចំណុចសំខាន់ដែលរងគ្រោះដល់រាងកាយ។*

*(7) "អនិតិជន" មានន័យថា មនុស្សក្រោមអាយុ18ឆ្នាំ។*

*(8) "គ្រោះថ្នាក់ធ្ងន់ធ្ងរ" រាប់បញ្ចូលទាំង គ្រោះថ្នាក់មិនថាលើរាងកាយ ឬមិនមែនរាងកាយ រួមមានផ្លូវចិត្តហិរញ្ញវត្ថុ ឬបង្កគ្រោះថ្នាក់ ដល់កិត្តិយសកេរ្តិ៍ឈ្មោះ ដែលមានសភាពធ្ងន់ធ្ងរក្រោមការទ្បោមព័ទ្ធ គំនាបពីព្រឹត្តិការណ៍ ជុំវិញ ដើម្បីបង្គាប់បង្ខិតបង្ខំមនុស្សប្រាកដ ដោយវិចារណញ្ញាណ ដោយប្រវត្តិនិងព្រឹត្តិការណ៏ដូចគ្នាពីមុនដើម្បីធ្វើ ឬបន្តការធ្វើការងារ សេវាកម្ម ឬសកម្មភាពជួញដូរផ្លូវភេទជា បន្តបន្ទាប់ដើម្បីចៀសវាងនូវការទទួលរងផលអន្តរាយនោះ។*

*(i) សរុបព្រឹត្តិការណ៏ទាំងអស់ រួមមានអាយុនៃជនរងគ្រោះ ទំនាក់ទំនងរវាងជនរងគ្រោះនិងភ្នាក់ងារចរាចរនៃអ្នកចរាចរ និងសមត្ថភាព ការគិតរបស់ជនរងគ្រោះ គួរជាកត្តារធ្វើការពិចារណា ក្នុងការកំណត់ប្រឈមមុខលើភាពខូចខាត ឬការរំលោភលើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់ជនដទៃ ការដាក់គុក និង ការបង្ខិតបង្ខំ ដូចបានបរិយាយក្នុងវគ្គនេះ។*

វគ្គទី7. វគ្គ 236.2 នៃក្រមព្រហ្មទណ្ឌគឺបានកែប្រែដើម្បីចែងថាៈ

236.2. ភ្នាក់ងារមន្ត្រីទទួលបន្ទុកជំរុញច្បាប់ គួរប្រើកំណត់ពេលព្យាយាមយកចិត្តទុកដាក់ ដើម្បីកំណត់ជនរងគ្រោះទាំងអស់ពីការចរាចរ មនុស្ស ថ្វីបើនេះភាពជាពលរដ្ឋរបស់មនុស្សម្នាក់ៗ។ នៅពេលមន្ត្រីសន្តិភាពមកធ្វើការទំនាក់ទំនងជាមួយជនដែលត្រូវបានដកហូតសេរីភាពរបស់គេ(អនិតិជនដែលត្រូវបានបញ្ចាំក្នុងសកម្មភាពជួញដូរផ្លូវភេទ)ជនសង្ស័យក្នុងអំពើប្រព្រឹត្តល្មើសក្នុងវគ្គតូចនេះ (a) ឬ (b) នៃវគ្គ 647 (ឬជនរងគ្រោះពីអំពើឧក្រិដ្ឋឬអំពើហិង្សា ក្នុងគ្រួសារ ឬចាប់រំលោភ បៀតបៀនកេរ្តិ៍ខ្មាស់) មន្ត្រីសន្តិភាពគួរតែ ពិចារណានូវចំណុចចង្អុលបង្ហាញពីការជួញដូរមនុស្សនៅមានដែរឬទេៈ

(a) សញ្ញារបួសផ្លូវចិត្ត ការអស់កំលាំង របួស ឬភស្តុតាងដែលមានការមិនសូវមានការយកចិត្តទុកដាក់។

(b) មនុស្សត្រូវដកចេញ ភ័យខ្លាចក្នុងការនិយាយស្តី ឬ ទំនាក់ទនងរបស់គាត់មានការត្រួតពិនិត្យដោយជនដទៃ។

(c) មនុស្សគ្មានសិទ្ធិសេរីភាពក្នុងការដើរហើរ។

(d) មនុស្សរស់នៅនិងធ្វើការក្នុងកន្លែងតែមួយ។

(e) មនុស្សជំពាក់បំណុលដើម្បីចៅហ្វាយរបស់គាត់។

(f) វិធានការសន្តិសុខ បានត្រូវប្រើដើម្បីគ្រប់គ្រងអ្នកណាដែលមានទំនាក់ទំនងជាមួយជននោះ។

(g) មនុស្សពុំមានការគ្រប់គ្រងលើប័ណ្ណសំគាល់ខ្លួនដែលចេញដោយរដ្ឋាភិបាលរបស់គេ ឬលើឯកសារអន្តោប្រវេសន៏ធ្វើការរបស់ពួកគេ។

វគ្គទី 8. វគ្គ 236.4 គឺត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌសំរាប់បកស្រាយថា៖

*236.4. (a) ផ្អែកខាងការកាត់មនុស្សប្រព្រឹត្តបទល្មើសក្នុងវគ្គ 236.1 (តុលាការ អាចនឹង បូកទៅនឹងក្រមព្រហ្មទណ្ឌផ្សេងទៀត ការពិន័យ ឬឲ្យសងបង់ឡើងវិញឲ្យដូចដើម បញ្ជាឲ្យចុងចោទសង មួយគុណជាពីរជាការពិន័យមិនលើសមួយលានដុល្លារ ($1.000.000)។ ក្នុងការចាត់ការចំនួននៃប្រាក់ពិន័យតុលាការអាចនិងពិចារណាកត្តាជាប់ពាក់ព័ន្ធផ្សេងៗរួមមាន, ប៉ុន្តែមិនមាន ដែនកំណត់,ប្រាកដប្រជានិងភាពគរ,ការអាក់អន់ចិត្ត,ព្រឹត្តិការនានា និងរយៈពេលបេសកកម្មរបស់វា,ចំនួននៃសេដ្ឋកិច្ចទទួលបានពីចុងចោទ បានទាញយកពីលទ្ធផលបទឧក្រិដ្ឋ និងទំហំដែលអ្នករងគ្រោះទទួលភាពឈឺចាប់គឺជាលទ្ធផលនៃការប្រព្រឹត្តធ្វើបទឧក្រិដ្ឋ។*

*(b) នរណាម្នាក់ដែលធ្វើឲ្យមានស្នាកស្នាមលើអ្នករងគ្រោះក្នុងបេសកកម្មឬព្យាយាមប្រព្រឹត្តល្មើសក្នុងវគ្គ236.1 គួរតែពិន័យដោយ ការបូកបន្ថែមនិងប្រឈមនិងការដាក់គុកពេលពី 5, 7, 10 ឆ្នាំ។*

*(c) នរណាម្នាក់ដែលធ្លាប់បានកាត់ទោសពីមុនពីបទប្រព្រិត្តល្មើសលើច្បាប់ឧក្រិតនានាដែលមានយ៉ាងច្បាស់ក្នុងវគ្គ236.1 គួរតែ ទទួលការបូកបន្ថែមនិងការជាប់គុកពេលកំណត់ក្នុងរដ្ឋ អ្នកទោសនោះរស់នៅពី 5 ឆ្នាំសំរាប់រាល់ការបូកបន្ថែមការកាត់ទោសនោះ បន្ទុកបង់ប្រាក់គឺញែកដាច់ពីគ្នា។*

*(d) រាល់ប្រាក់ពិន័យដាក់ឲ្យបង់និងបានប្រមូលនិង អនុលោមទៅតាមវគ្គ 236.1 និងវគ្គនេះគួរតែដាក់ប្រាក់តំកល់ទុកក្នុងមូលនិធិ Victim-Witness Assistance Fund សំរាប់ចាត់ចែងដោយភ្នាក់ងារ គ្រប់គ្រងបន្ទាន់ រដ្ឋកាលីហ្វ័រញ៉ា(CalEMA) ផ្តល់មូលនិធិសំរាប់ សេវាកម្មដល់ជនរងគ្រោះដោយការជួញដូរមនុស្ស។ ចិតសិបភាគរយ 70%នៃប្រាក់ពិន័យដែលប្រមូលបាននិងប្រាក់កក់ទុក គួរត្រូវបានផ្តល់ ឲ្យទៅភ្នាក់ងារសារធារណៈ។ ហើយការរួមសហការគ្នាដោយមិន យក កម្រៃ ដែលផ្តល់ឲ្យនូវទីជម្រក ការពិភាក្សា ឬសេវាកម្មផ្ទាល់ ផ្សេងទៀត សំរាប់អ្នករងគ្រោះដោយការចរាចរ។ សាមសិបភាគរយ 30% នៃ ប្រាក់ពិន័យប្រមូលបាន ឬប្រាក់កក់ទុក គួរតែឲ្យទៅក្រុមអ្នកជំរុញច្បាប់ និងភ្នាក់ងារការកាត់ទោសក្នុងសាលាក្តី ដែលជាតម្លៃយកទៅ ចូលការបង្កាការចរាចរមនុស្ស ការពារមនុស្សអាចត្រូវគេបោក និង ប្រតិបត្តិ*

*ការជួយសង្គ្រោះ។*

វគ្គទី9.វគ្គទី290នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មឱ្យបកស្រាយថា៖

290. (a) វគ្គទី 290 រហូតដល់ ~~290.023~~ 290.024 រួមគ្នា គួរត្រូវគេស្គាល់និងអាចហៅបានថាជាច្បាប់ចុះបញ្ជីជនល្មើសផ្លូវភេទ។ រាល់ខ្លឹមសារយោងទៅលើ "ច្បាប់" នេះនៅក្នុងវគ្គទាំងនោះ គឺទាក់ទងនឹងច្បាប់ចុះបញ្ជីជនល្មើសផ្លូវភេទ។

(b) ជនទាំងឡាយដែលត្រូវបានបរិយាយនៅក្នុងអនុផ្នែក (c) សម្រាប់មួយជីវិតរបស់គាត់ដែលកំពុងស្នាក់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ឬកំពុងសិក្សា ឬធ្វើការងារនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ដូចមានបរិយាយនៅក្នុងវគ្គ 290.002 និង 290.001 ត្រូវបានតំរូវឲ្យចុះបញ្ជីជាមួយនឹងនាយនគរបាលក្រុងដែលខ្លួនកំពុងស្នាក់នៅ ឬជាមួយប្រធានចៅក្រមខោនធី ប្រសិនបើខ្លួនកំពុងស្នាក់នៅក្នុងតំបន់ ឬ ទីក្រុងដាច់ស្រយាល ដែលមិនមានក្រសួងនគរបាល ព្រមទាំងចុះបញ្ជីជាមួយនាយនគរបាលក្នុងបរិវេណសាកលវិទ្យាល័យក្នុងរដ្ឋកាលីហ្វ័រនីញ៉ា សាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា ឬមហាវិទ្យាល័យក្នុងសហគមន៍ ប្រសិនបើខ្លួនកំពុងស្នាក់នៅក្នុងបរិវេណនោះ ឬក្នុងអាគារណាមួយនៅក្នុងអំឡុងពេលប្រាំថ្ងៃ នៃការចូលមកស្នាក់នៅ ឬផ្លាស់ប្តូរទីកន្លែងស្នាក់នៅក្នុងទីក្រុង ឬខោនធីណាមួយ ឬក្នុងទីក្រុង និងខោនធី ឬក្នុងបរិវេណដែលខ្លួនស្នាក់នៅបណ្តោះអាសន្ន និងត្រូវបានតំរូវឲ្យចុះបញ្ជីនៅពេលបន្ទាប់មក ដោយអនុលោមទៅតាមច្បាប់នេះ។

(c) បុគ្គលទាំងឡាយខាងក្រោមនេះត្រូវបានតំរូវឲ្យចុះបញ្ជី ៖

បុគ្គលណាម្នាក់ ដែលចាប់តាំងពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ1944 មក ត្រូវបានដាក់ទោស ឬ ក្រោយមកត្រូវបានដាក់ទោសនៅក្នុងតុលាការណាមួយនៅក្នុងរដ្ឋនេះ ឬនៅក្នុងតុលាការសហព័ន្ធ ឬតុលាការយោធាណាមួយ ពីបទរំលោភលើវគ្គទី 187 ដោយបានប្រព្រឹត្តបទឧក្រិដ្ឋ ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋរំលោភសេពសន្ថវៈ ឬទង្វើណាមួយដែលត្រូវបានដាក់ទោសក្រោមវគ្គទី 286, 288, 288a, ឬ 289 វគ្គទី207 ឬ 209 ដោយបានប្រព្រឹត្តក្នុងគោលបំណងរំលោភលើវគ្គទី 261, 286, 288, 288a, ឬ 289, វគ្គទី 220 លើកលែងតែការបំពារបំពានដើម្បីប្រព្រឹត្តកាយវិកលកម្មក្នុង អនុផ្នែក (b) និង (c) នៃវគ្គទី 236.1 វគ្គទី 243.4 កថាខណ្ឌ (1), (2), (3), (4) ឬ កថាខណ្ឌ (6) នៃអនុផ្នែក (a) នៃវគ្គទី 261 កថាខណ្ឌ (1) នៃអនុផ្នែក (a) នៃវគ្គទី 262 ពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំង ឬ អំពើហិង្សា ជាហេតុធ្វើឲ្យបុគ្គលនោះត្រូវបានគេកាត់ទោសឲ្យជាប់ពន្ធនាគាររដ្ឋ ក្នុងវគ្គទី 264.1, 266, ឬ 266c វគ្គរង (b) នៃវគ្គទី 266h អនុផ្នែក (b) នៃវគ្គទី 266i វគ្គទី 266j, 267, 269, 285, 286, 288, 288a, 288.3, 288.4, 288.5, 288.7, 289 ឬ 311.1 អនុផ្នែក (b), (c), ឬ (d) នៃវគ្គទី 311.2 វគ្គទី 311.3, 311.4, 311.10, 311.1, ឬ 647.6 អតីតវគ្គ 647a អនុផ្នែក (c) នៃវគ្គទី 653f អនុផ្នែក 1 ឬ 2 នៃវគ្គទី 314 សម្រាប់បទល្មើសណាមួយទាក់ទងនឹងការប្រព្រឹត្តដោយមិនអៀនខ្មាស់ ឬមានទំនោរផ្លូវភេទស្ថិតក្រោមវគ្គទី 272 ឬ ការរំលោភបំពានធ្ងន់ធ្ងរណាមួយទៅលើវគ្គទី 288.2 នីតិជនណាម្នាក់ខាងលើដែលបានប្រព្រឹត្តបទល្មើសមួយ
ក្នុងចំណោមបទល្មើសទាំងឡាយខាងលើ ឬបុគ្គលណាម្នាក់ ដែលចាប់តាំងពីកាលបរិច្ឆេទនោះមក ត្រូវបានដាក់ទោស ឬបន្ទាប់មកត្រូវបានដាក់ទោសពីបទប៉ុនប៉ង ឬឃុបឃិតប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងឡាយលើកឡើងខាងលើ។

វគ្គទី 10. វគ្គទី 290.012 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មឱ្យបកស្រាយថា ៖

290.012. (a) ចាប់ពីថ្ងៃខួបកំណើតលើកទីមួយរបស់គាត់បន្ទាប់ការចុះបញ្ជីឬការផ្លាស់ប្តូរអាស័យដ្ឋានរស់នៅ បុគ្គលម្នាក់ត្រូវបានតំរូវឲ្យធ្វើការចុះបញ្ជី ជារៀងរាល់ឆ្នាំនៅក្នុងអំឡុងពេល 5 ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ថ្ងៃវិលត្រឡប់របស់គាត់ ដើម្បីធ្វើបច្ចុប្បន្នភាពការចុះបញ្ជីរបស់គាត់ ជាមួយនឹងអង្គភាពនានា ដូចបានបញ្ជាក់នៅក្នុងវគ្គរង (b) នៃវគ្គទី 290។ នៅពេលធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ បុគ្គលម្នាក់ត្រូវផ្តល់នូវព័ត៌មានចុងក្រោយ តាមការតំរូវនៅលើទម្រង់បច្ចុប្បន្នភាពប្រចាំឆ្នាំ របស់ក្រសួងយុត្តិធម៌ រួមទាំងព័ត៌មានដូចមានបញ្ជាក់នៅក្នុងកថាខណ្ឌ (1) ដល់ (3) និង (5) រួមទាំងអនុផ្នែក (a) នៃវគ្គទី 290.015។ ភ្នាក់ងារចុះបញ្ជី ត្រូវផ្តល់ឲ្យអ្នកទៅចុះបញ្ជី នូវឯកសារស៊ីពីតំរូវការចុះបញ្ជីមួយច្បាប់ ស្រង់ចេញពីទម្រង់បែបបទរបស់ក្រសួងយុត្តិធម៌។

(b) លើសពីនេះទៀត បុគ្គលទាំងឡាយ ដែលធ្លាប់ត្រូវបានវិនិច្ឆ័យទោសឲ្យក្លាយទៅជាជនប្រព្រឹត្តអំពើហិង្សាផ្លូវភេទ ដូចបានកំណត់នៅក្នុងវគ្គទី 6600 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា បន្ទាប់ពីគាត់ត្រូវបានដោះលែងពីឃុំឃាំង ត្រូវបញ្ជាក់អំពីអាស័យដ្ឋានរបស់ខ្លួនយ៉ាងតិច 90 ថ្ងៃម្តង និងកន្លែងធ្វើការ រួមទាំងឈ្មោះ និងអាស័យដ្ឋានរបស់និយោជក ទៅតាមបែបបទដែលបង្កើតឡើងដោយក្រសួងយុត្តិធម៌។ បុគ្គលទាំងឡាយដែលជាជនប្រព្រឹត្តអំពើហិង្សាផ្លូវភេទ ត្រូវបានតំរូវឲ្យបញ្ជាក់ពីការចុះបញ្ជីរបស់ខ្លួនរៀងរាល់ 90 ថ្ងៃម្តង នឹងត្រូវបានជូនដំណឹងពីពេលដែលគាត់ត្រូវចុះបញ្ជី ទៅតាមកាតព្វកិច្ចចុះបញ្ជីបន្ថែមរបស់គាត់នៅពេលក្រោយ។ ការជូនដំណឹងនេះ ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរដោយភ្នាក់ងារចុះបញ្ជីអត្រានុកូលដ្ឋានម្នាក់ ឬច្រើននាក់។ ការខកខានទទួលសេចក្តីជូនដំណឹងនេះ គឺជាការការពារមួយចំពោះការដាក់ទោស ដូចបានបញ្ជាក់នៅក្នុងវគ្គរង (f) នៃវគ្គទី 290.018។

(c) មិនតែប៉ុណ្ណោះ គ្រប់បុគ្គលដែលស្ថិតក្រោមច្បាប់នេះ ក្នុងអំឡុងពេលរស់នៅជាបណ្តោះអាសន្នក្នុងរដ្ឋកាលីហ្វ័រញ៉ា ត្រូវធ្វើបច្ចុប្បន្នភាពការចុះបញ្ជីរបស់ខ្លួន យ៉ាងតិចបំផុតរៀងរាល់ 30ថ្ងៃម្តង ដោយអនុលោមទៅតាមវគ្គទី 290.011។

(d) មិនមានអង្គភាពណាមួយតំរូវឲ្យបុគ្គលម្នាក់បង់ប្រាក់ថ្លៃចុះ បញ្ជី ឬ ថ្លៃធ្វើបច្ចុប្បន្នភាពការចុះបញ្ជីរបស់គាត់ ស្របទៅតាមវគ្គនេះឡើយ។ ភ្នាក់ងារចុះបញ្ជី ត្រូវបញ្ចូលដោយផ្ទាល់នូវឯកសារចុះបញ្ជីផ្សេងៗ រួមទាំងការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ឬការផ្លាស់ប្តូរអាស័យដ្ឋានទៅក្នុងបណ្តាញព័ត៌មានបទល្មើសអំពើហិង្សា (VCIN) របស់ក្រសួងយុត្តិធម៌។

វគ្គទី 11. វគ្គទី 290.014 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

290.014. (a) ប្រសិនបើបុគ្គលណាម្នាក់ ដែលត្រូវបានតំរូវឲ្យចុះបញ្ជីស្របតាមច្បាប់នេះ ធ្វើការកែប្រែឈ្មោះរបស់ខ្លួន បុគ្គលនោះ ត្រូវជូនដំណឹងដោយផ្ទាល់ទៅភ្នាក់ងារអនុវត្តច្បាប់មួយ ឬ ច្រើនដែលខ្លួនទើបបានចុះបញ្ជីជាមួយនៅក្នុងអំឡុងពេល 5 ថ្ងៃនៃថ្ងៃធ្វើការ។ ភ្នាក់ងារអនុវត្តច្បាប់មួយ ឬ ច្រើនទាំងឡាយត្រូវបញ្ជូនព័ត៌មាននេះមួយច្បាប់ទៅក្រសួងយុត្តិធម៌ក្នុងអំឡុងពេល 3 ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីខ្លួនបានទទួលព័ត៌មាននោះ។

*(b) ប្រសិនបើបុគ្គលម្នាក់ ដែលត្រូវបានតំរូវឲ្យចុះបញ្ជីស្របទៅតាមច្បាប់នេះ ធ្វើការបន្ថែម ឬ កែប្រែគណនីរបស់ខ្លួនជាមួយនឹងអ្នកផ្គត់ផ្គង់សេវាអ៊ីនធើណិត ឬ ធ្វើការបន្ថែម ឬ កែប្រែគ្រឿងសម្គាល់លើអ៊ីនធើណិត បុគ្គលនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបន្ថែម ឬការកែប្រែនោះទៅភ្នាក់ងារអនុវត្តច្បាប់មួយ ឬ ច្រើនដែលខ្លួនទើបនឹងបានចុះបញ្ជីជាមួយនៅក្នុងអំឡុងពេល 24 ម៉ោង។ ភ្នាក់ងារអនុវត្តច្បាប់មួយ ឬទាំងឡាយ ត្រូវបញ្ជូនព័ត៌មាននេះបន្តទៅក្រសួងយុត្តិធម៌។ បុគ្គល ដែលស្ថិតក្រោមវគ្គរងនេះ ក្នុងពេលដែលវាមានសុពលភាព ត្រូវផ្តល់ព័ត៌មានបែបនេះភ្លាមៗតាមការតំរូវនៃវគ្គរងនេះ។*

វគ្គទី 12. វគ្គទី 290.015 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មឱ្យបកស្រាយថា ៖

290.015. (a) បុគ្គលដែលស្ថិតក្រោមច្បាប់នេះ ត្រូវចុះបញ្ជី ឬ ចុះបញ្ជីឡើងវិញ ប្រសិនបើខ្លួនធ្លាប់បានចុះបញ្ជីពីមុនហើយ បន្ទាប់ពីការដោះលែងចេញពីពន្ធនាគារ បន្ទាប់ពីដាក់ឃុំឃាំង ការប្រព្រឹត្តល្មើស ឬការដោះលែងជាបណ្តោះអាសន្នដោយអនុលោមទៅតាមវគ្គរង (b) នៃវគ្គទី 290។

វគ្គនេះ មិនត្រូវអនុវត្តចំពោះបុគ្គលម្នាក់ ដែលត្រូវបានដាក់ពន្ធនាគារក្រោមរយៈពេល 30 ថ្ងៃឡើយ ប្រសិនបើបុគ្គលនោះបានចុះបញ្ជីតាមការតំរូវនៃច្បាប់នេះរួចហើយ។ ក្រោយពីដាក់ពន្ធនាគាររួច បុគ្គលនោះត្រឡប់ទៅកាន់អាស័យដ្ឋានដែលបានចុះបញ្ជីចុងក្រោយបង្អស់ ហើយការធ្វើបច្ចុប្បន្នភាពការចុះបញ្ជីប្រចាំឆ្នាំ ដែលតំរូវឲ្យធ្វើនៅក្នុងអំឡុងពេល 5 ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីការវិលត្រឡប់របស់គាត់ ស្របទៅតាមវគ្គរង (a) នៃវគ្គទី 290.012 មិនបានស្ថិតនៅក្នុងអំឡុងពេលជាប់ពន្ធនាគារនោះទេ។ ការចុះបញ្ជីត្រូវមានចំណុចទាំងអស់ខាងក្រោម៖

(1) សេចក្តីបរិយាយជាលាយលក្ខណ៍អក្សរមួយដែលចុះ ហត្ថលេខាដោយបុគ្គលនោះ ដោយបង្ហាញនូវព័ត៌មានដែលតំរូវដោយក្រសួងយុត្តិធម៌

និងផ្តល់នូវឈ្មោះ និងអាស័យដ្ឋានរបស់និយោជក និងអាស័យដ្ឋានកន្លែងធ្វើការងាររបស់បុគ្គលនោះ ប្រសិនបើវាស្ថិតនៅផ្សេងពីអាស័យដ្ឋានគោលរបស់និយោជកនោះ។

(2) ស្នាមម្រាមដៃ និងរូបថតថ្មីរបស់បុគ្គលនោះដែលថតដោយមន្ត្រីចុះបញ្ជី។

(3) ស្លាកលេខអាជ្ញាប័ណ្ណយានយន្តណាមួយ ដែលបានកាន់កាប់ដោយ ឬបើកបរជាទៀងទាត់ដោយបុគ្គលនោះ ឬចុះបញ្ជីក្នុងនាមបុគ្គលនោះ។

*(4) បញ្ជីគ្រឿងសម្គាល់អ៊ិនធើណែតណាមួយនិងទាំងអស់ដែល ត្រូវបានបង្កើត ឬ ប្រើប្រាស់ដោយបុគ្គលនោះ។*

*(5) បញ្ជីឈ្មោះអ្នកផ្គត់ផ្គង់សេវាអ៊ិនធើណែតណាម្នាក់ ឬ ទាំងអស់ដែលត្រូវបានប្រើប្រាស់ដោយបុគ្គលនោះ។*

*(6) សេចក្តីបរិយាយជាលាយលក្ខណ៍អក្សរមួយដែលចុះហត្ថលេខាដោយបុគ្គលនោះ ដោយទទួលស្គាល់ថាបុគ្គលនោះត្រូវបានតំរូវ ឲ្យចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងកថាខណ្ឌ (4) និង (5) ទៅតាមការតំរូវក្នុងជំពូកនេះ។*

~~(4)~~ (7) លិខិតជូនដំណឹងទៅបុគ្គលនោះ និងបន្ថែមពីលើលក្ខខណ្ឌតំរូវនៅក្នុងច្បាប់នេះ បុគ្គលនោះ ត្រូវមានភារកិច្ចចុះបញ្ជីនៅក្នុងរដ្ឋមួយផ្សេងទៀត ដែលខ្លួនត្រូវរើទៅទីនោះ។

~~(5)~~ (8) ឯកសារបញ្ជាក់លំនៅដ្ឋានគ្រប់គ្រាន់ ដែលមានដូចជា ប័ណ្ណបើកបររដ្ឋកាលីហ្វ័រញ៉ា អត្តសញ្ញាណប័ណ្ណរដ្ឋកាលីហ្វ័រនីញ៉ា បង្កាន់ដៃជួល ឬ បង្កាន់ដៃបង់ប្រាក់ថ្លៃទឹកភ្លើងចុងក្រោយ ឯកសារមូលប្បទានបត្រផ្ទាល់ខ្លួន ឬ ឯកសារធនាគារចុងក្រោយ ដែលបង្ហាញ ពីឈ្មោះ និងអាស័យដ្ឋាន ឬព័ត៌មានផ្សេងទៀតដែលមន្ត្រីចុះបញ្ជី ជឿជាក់ថា អាចយកជាការបាន។ ប្រសិនបើបុគ្គលនោះមិនមានលំនៅដ្ឋាន និងមិនមានការរំពឹងទុកដោយសមហេតុថានឹងទទួលបាន លំនៅដ្ឋាននៅក្នុងពេលអនាគតដែលអាចដឹងបាន បុគ្គលនោះត្រូវ ប្រាប់ទៅមន្ត្រីចុះបញ្ជី ហើយត្រូវចុះហត្ថលេខាលើសេចក្តីបញ្ជាក់អះអាងដែលបានផ្តល់ឲ្យដោយមន្ត្រីចុះបញ្ជី ដែលបញ្ជាក់អំពីតថភាពនោះ។ បន្ទាប់ពីបង្ហាញភ័ស្តុតាងអំពីលំនៅដ្ឋានដល់មន្ត្រីចុះបញ្ជី ឬសេចក្តីបញ្ជាក់អះអាងដែលបានចុះហត្ថលេខាថា បុគ្គលនោះពិតជាមិនមានលំនៅដ្ឋាន បុគ្គលនោះនឹងត្រូវបានអនុញ្ញាតឲ្យធ្វើការចុះ បញ្ជី។ ប្រសិនបើបុគ្គលនោះអះអាងថា ខ្លួនមានលំនៅដ្ឋាន ក៏ប៉ុន្តែមិនមានភ័ស្តុតាងណាមួយអំពីលំនៅដ្ឋាននោះ នោះគាត់ត្រូវបានអនុញ្ញាតឲ្យចុះបញ្ជី ក៏ប៉ុន្តែត្រូវប្រគល់ភ័ស្តុតាងអំពីលំនៅដ្ឋាននោះ ក្នុងអំឡុងពេល 30ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលគាត់ត្រូវបានអនុញ្ញាតឲ្យចុះបញ្ជី។

(b) ក្នុងអំឡុងពេល 3ថ្ងៃបន្ទាប់ ភ្នាក់ងារអនុវត្តច្បាប់មួយ ឬ ទាំងឡាយត្រូវបញ្ជូនសេក្តីបញ្ជាក់អះអាង ស្នាមម្រាមដៃ រូបថត និងស្លាកលេខអាជ្ញាប័ណ្ណយានយន្ត ប្រសិនបើមាន ទៅឲ្យក្រសួងយុត្តិធម៌។

(c) (1) ប្រសិនបើបុគ្គលម្នាក់ខកខានមិនបានចុះបញ្ជី ស្របទៅតាមអនុផ្នែក (a) បន្ទាប់ពីការដោះលែង មេធាវីស្រុកស្ថិតក្នុងយុត្តាធិការ ដែលបុគ្គលនោះត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឬដោះលែងជាបណ្តោះអាសន្ន អាចស្នើសុំឲ្យចេញដីកាចាប់ខ្លួនបុគ្គលនោះ ហើយត្រូវមានសិទ្ធិកាត់ទោសបុគ្គលនោះ ដោយអនុលោមទៅតាមវគ្គទី 290.018។

(2) ប្រសិនបើបុគ្គលនោះ មិនស្ថិតក្រោមការដោះលែងដោយមានលក្ខខណ្ឌ ឬ ការដោះលែងជាបណ្តោះអាសន្ន នៅពេលដែលធ្វើការដោះលែង មេធាវីស្រុកស្ថិតក្នុងយុត្តាធិការ ដែលអាចអនុវត្តបានដូចខាងក្រោម ត្រូវមានសិទ្ធិកាត់ទោសបុគ្គលនោះដោយអនុលោមទៅតាមវគ្គទី 290.018 ៖

(A) ប្រសិនបើបុគ្គលនោះត្រូវបានចុះបញ្ជីពីមុនរួចហើយ នៅក្នុងយុត្តាធិការ ដែលបុគ្គលនោះបានចុះបញ្ជីចុងក្រោយបង្អស់។

(B) ប្រសិនបើមិនមានការចុះបញ្ជីជាមុន ក៏ប៉ុន្តែបុគ្គលនោះបានបញ្ជាក់នៅក្នុងទម្រង់តំរូវការចុះបញ្ជីជនល្មើសផ្លូវភេទ របស់ក្រសួងយុត្តិធម៌ អំពីកន្លែងដែលគាត់បានរំពឹងថានឹងទៅស្នាក់នៅ ស្ថិតក្នុងយុត្តាធិការដែលគាត់បានរំពឹងថានឹងទៅស្នាក់នៅ។

(C) ប្រសិនបើទាំងកថាខណ្ឌរង (A) និង (B) មិនអាចអនុវត្តបាននៅក្នុងយុត្តាធិការមួយ ដែលបទល្មើសនៃការដាក់បុគ្គលឲ្យស្ថិតក្រោម ការចុះបញ្ជីស្របទៅតាមច្បាប់នេះ ត្រូវបានប្រព្រឹត្ត។

វគ្គទី 13. វគ្គទី 290.024 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌមឱ្យបកស្រាយថា ៖

*290.024. សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យខាងក្រោមនេះត្រូវបានប្រើប្រាស់ ៖*

*(a) "អ្នកផ្តល់សេវាអ៊ិនធើណែត" សំដៅលើអាជីវកម្ម ក្រុមហ៊ុន ឬអង្គភាពដទៃទៀតដែលផ្តល់កុំព្យូទ័រ និងបរិក្ខារទំនាក់ទំនងនានា ដោយផ្ទាល់ទៅដល់អតិថិជន ដែលតាមរយៈនោះបុគ្គលម្នាក់អាចប្រើប្រាស់អ៊ិនធើណិតបាន។ អ្នកផ្គត់ផ្គង់សេវាអ៊ិនធើណិត មិនរួមបញ្ចូលអាជីវកម្ម ក្រុមហ៊ុនឬអង្គភាពដទៃទៀត ដែលផ្តល់តែសេវាទំនាក់ទំនង សេវាតាមប្រព័ន្ធខ្សែកាប ឬសេវាខ្សែភាពយន្ត ឬប្រព័ន្ធណាមួយដែលដំណើរការដោយ ឬ សេវាផ្សេងៗដែលផ្តល់ដោយបណ្ណាល័យ ឬគ្រឹះស្ថានអប់រំឡើយ។*

*(b) "គ្រឿងសម្គាល់លើអ៊ិធឺណិត" សំដៅលើអាស័យដ្ឋានសារអេឡិចត្រូនិច ឈ្មោះអ្នកប្រើប្រាស់ ឈ្មោះអេក្រង់ ឬ គ្រឿងសម្គាល់ស្រដៀងគ្នានេះ ដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងធ្វើការពិភាក្សាគ្នាតាមអ៊ិនធើណិត ការពិភាក្សាក្នុងបន្ទប់ជជែកកម្សាន្តតាមអ៊ិនធើណែត ការផ្ញើសារទៅវិញទៅមក ការបង្កើតបណ្តាញសង្គម ឬ ការទំនាក់ទំនងស្រដៀងគ្នានេះតាមអ៊ិនធើណែត។*

វគ្គទី 14. វគ្គទី 13519.14 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

13519.14. (a) គណៈកម្មការត្រូវអនុវត្តនៅមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2007 នូវវគ្គអប់រំមួយ ឬ ច្រើនទាក់ទងនឹងការបណ្តុះបណ្តាល មន្ត្រីអនុវត្តច្បាប់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា អំពីការដោះស្រាយពាក្យ បណ្តឹងទាក់ទងនឹងការជួញដូរមនុស្ស ហើយត្រូវបង្កើតផងដែរនូវគោលការណ៍ណែនាំសម្រាប់ការឆ្លើយតប តាមរយៈការអនុវត្តច្បាប់ទាក់ទងទៅនឹងការជួញដូរមនុស្ស។ វគ្គអប់រំមួយ ឬច្រើន និងគោលការណ៍ណែនាំទាំងនោះ សង្កត់ធ្ងន់ទៅលើភាពស្រួចស្រាវ និងការផុសចេញនូវការជួញដូរមនុស្ស ការកត់សម្គាល់ និងការទំនាក់ទំនងជាមួយជនរងគ្រោះ ការផ្តល់ឯកសារបំពេញតាមតំរូវការរបស់~~ភ្នាក់ងារអនុវត្តច្បាប់(LEA)~~ភ្នាក់ងារអនុវត្តច្បាប់ *(LEA)* តាមការតំរូវរបស់ច្បាប់សហព័ន្ធ ការសហការជាមួយមន្ត្រីអនុវត្តច្បាប់សហព័ន្ធបច្ចេកទេសស៊ើបអង្កេតសមស្របបែបព្យាបាល លទ្ធភាពរកបានដំណោះស្រាយបែបស៊ីវិល និងអន្តោប្រវេសន៍ ធនធានសហគមន៍ និងការការពារជនរងគ្រោះ។ ក្នុងករណីដែលសមស្រប អ្នកធ្វើការបណ្តុះបណ្តាល ត្រូវរួមបញ្ចូលអ្នកជំនាញវគ្គជួញដូរមនុស្ស ដែលមានបទពិសោធន៍ក្នុងការផ្តល់ សេវាដោយផ្ទាល់ដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស។ ភាពគ្រប់គ្រាន់នៃវគ្គបណ្តុះបណ្តាល អាចធ្វើឡើងតាមរយៈទូរគមនាគមន៍ ការសែតបណ្តុះបណ្តាលតាមវីដេអូ ឬការអប់រំផ្សេងទៀត។

(b) ដូចបានប្រើប្រាស់នៅក្នុងវគ្គនេះ "មន្ត្រីអនុវត្តច្បាប់" សំដៅលើមន្ត្រីណាម្នាក់ ឬ បុគ្គលិកក្រសួងនគរបាលមូលដ្ឋាន ឬ ប្រធានចៅក្រមសង្កាត់ និងមន្ត្រីរក្សាសន្តិភាពណាម្នាក់នៅក្នុងក្រសួងល្បាត មហាវិថីរដ្ឋកាលីហ្វ័រញ៉ា ដូចបានកំណត់នៅក្នុងវគ្គរង (a) នៃវគ្គទី 830.2។

(c) វគ្គអប់រំ ការរៀនសូត្រ គោលដៅអនុវត្តការងារ បទដ្ឋានសម្រាប់ការបណ្តុះបណ្តាល និងគោលការណ៍ណែនាំ ត្រូវបង្កើតឡើងដោយគណៈកម្មាធិការ ដោយមានការប្រឹក្សាជាមួយក្រុម និងបុគ្គលសមស្របនានា ដែលមានចំណាប់អារម្មណ៍ និងឯកទេសក្នុងវិស័យការជួញដូរមនុស្ស។

(d) តាមរយៈការប្រឹក្សាជាមួយក្រុម និងបុគ្គលទាំងអស់នេះ គណៈកម្មាធិការត្រូវពិនិត្យលើកម្មវិធីបណ្តុះបណ្តាលដែលមានស្រាប់ ដើម្បីកំណត់ពីវិធីផ្សេងៗ ដែលអាចដាក់បញ្ចូលការបណ្តុះបណ្តាល អំពីការជួញដូរមនុស្សជាវគ្គមួយនៃកម្មវិធីដែលកំពុងដំណើរការ។

~~(e) ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយ ឬវគ្គទាំងឡាយ ដែលបានបញ្ជាក់នៅក្នុងវគ្គនេះ ដោយមន្ត្រីសន្តិភាព ឬទីភ្នាក់ងារនានាដែលជួលពួកគេ គឺជាការស្ម័គ្រចិត្ត~~ *គ្រប់មន្ត្រីអនុវត្តច្បាប់ ដែលត្រូវបានផ្តល់ភារកិច្ចតាមវគ្គ ឬ ភារកិច្ចស៊ើបអង្កេត ត្រូវបញ្ចប់ការបណ្តុះបណ្តាលក្នុងរយៈពេលយ៉ាងតិចបំផុត 2 ម៉ោងក្នុងវគ្គអប់រំមួយ ឬ នីមួយៗទាក់ទងនឹងការដោះស្រាយពាក្យបណ្តឹងការជួញដូរមនុស្ស ដូចបានបរិយាយនៅក្នុងអនុផ្នែក(a)*

*នៅមុនថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2014 ឬ ក្នុងអំឡុងពេល 6 ខែ នៃការចាត់តាំងឲ្យកាន់តួនាទីនោះ។*

វគ្គទី 15. ការធ្វើវិសោធនកម្ម

ច្បាប់នេះអាចត្រូវបានធ្វើវិសោធនកម្មដោយលក្ខន្តិកៈ ដើម្បីជំរុញគោលដៅរបស់ខ្លួនដែលបានអនុម័តនៅក្នុងសភានីមួយៗ នៃអង្គនីតិបញ្ញត្តិ តាមរយៈការបោះឆ្នោតដោយហៅឈ្មោះឲ្យបញ្ចេញ មតិ ដែលបានបញ្ចូលនៅក្នុងទិន្នានុប្បវត្តិ ដោយមានសំឡេងគាំទ្រ ភាគច្រើននៃសមាជិកភាពក្នុងសភានីមួយៗ។

វគ្គទី 16. ខបំរុង។

ប្រសិនបើខចែងណាមួយ ក្នុងចំណោមបញ្ញត្តិទាំងឡាយនៃវិធានការនេះ ឬ ភាពដែលអាចអនុវត្តបាននៃបញ្ញត្តិណាមួយ នៃវិធានការនេះចំពោះបុគ្គលណាម្នាក់ ឬកាលៈទេសៈនានាត្រូវបានរក ឃើញថាផ្ទុយនឹងរដ្ឋធម្មនុញ្ញឬអសុពលភាព លទ្ធផលនៃការរកឃើញនោះ មិនត្រូវមិនប៉ះពាល់ដល់ខចែង ឬការអនុវត្តផ្សេងទៀតនូវវិធានការនេះចំពោះបុគ្គល ឬកាលៈទេសៈផ្សេងៗទៀតឡើយ ហើយក្នុងករណីបែបនេះ បទបញ្ញត្តិទាំងឡាយនៃវិធានការនេះ ត្រូវបានចាត់ទុកថាជាខចែងបំរុង។

## សំណើប្រជាមតិ 36

វិធានការផ្តើមប្រជាសិទ្ធិនេះគឺត្រូវបានដាក់ឲ្យប្រជាពលរដ្ឋដោយអនុលោមទៅតាមខដែលមានចែងក្នុងវគ្គទី 8នៃមាត្រា II នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

វិធានការប្រជានុម័តនេះកែប្រែនិងបន្ថែមវគ្គខ្លះទៅលើក្រមព្រហ្ម ទណ្ឌ ដូចនេះខចែងមានស្រាប់ដែលបានស្នើឡើងដើម្បីលុបចោល ត្រូវបោះពុម្ពចេញជា~~លក្ខណៈឆ្នូតលុបកាត់~~ ហើយខចែងថ្មីដែលបានស្នើឡើងដើម្បី បន្ថែមត្រូវបោះពុម្ពចេញជាលក្ខណៈ*អក្សរទ្រេត ដើម្បីបញ្ជាក់ថាវាថ្មី។*

## ច្បាប់ដែលស្នើ

កំណែទម្រង់ច្បាប់ចែងពីបទល្មើសបីដង នៃឆ្នាំ 2012

វគ្គទី1. ការរកឃើញនិងសេចក្តីប្រកាស

ប្រជាពលរដ្ឋអនុម័តច្បាប់កំណែទំរង់ការសំរេច3 នៃឆ្នាំ 2012 ដើម្បីធ្វើឲ្យមានដូចដើមនូវគោលបំណងដើមនៃច្បាប់ចែងពីបទល្មើសបីដងរបស់រដ្ឋកាលីហ្វ័រញ៉ា—ការសំរេចឲ្យជាប់គុកអស់មួយជីវិត ចំពោះឧក្រិដ្ឋ ជនដែលប្រកបដោយគ្រោះថ្នាក់ដូចជាជនចាប់រំលោភ ឃាតករ អ្នកចាប់រំលោភកុមារ។

ច្បាប់នេះនឹង៖

(1) តំរូវឲ្យជនចាប់រំលោភ ឃាតករ អ្នកចាប់រំលោភកុមារ បំពេញការកាត់ទោសទាំងស្រុង—ពួកគេនឹងទទួលការសំរេចឲ្យជាប់គុកអស់ មួយជីវិតបើទោះជាពួកគេត្រូវបានផ្តន្ទាទោសចំពោះការជាប់ទោសបទឧក្រិដ្ឋទី3ដែលជាអនិតិជន។

(2) ធ្វើឲ្យដូចដើមនូវច្បាប់ចែងពីបទល្មើសបីដងដើម្បីការយល់ភាពដើមរបស់សាធារណជនដោយការតំរូវឲ្យមានការសំរេចឲ្យជាប់គុកអស់មួយជីវិតប៉ុណ្ណោះដែលការជាប់ទោសបច្ចុប្បន្នរបស់អ្នកជាប់ចោទគឺសំរាប់បទឧក្រិដ្ឋឃោរឃៅឬធ្ងន់ធ្ងរ។

(3) រក្សាទុកនូវអ្នកប្រព្រឹត្តបទល្មើសដដែលដែលត្រូវបានថ្កោលទោសនៃបទល្មើសមិនឃោរឃៅឬមិនធ្ងន់ធ្ងរដូចជាការលួចអីវ៉ាន់ក្នុងហាងការកាន់មានជារបស់ខ្លួននូវគ្រឿងញៀនធម្មតានឹងទទួលបានទទួលទោសធម្មតាទ្វេមួយជាពីជំនួសឲ្យទោសជាប់គុកអស់មួយជីវិត។

(4) ជួយសន្សំសំចៃប្រាក់រាប់លានដុល្លារនៃអ្នកដែលបង់ពន្ធរាល់ឆ្នាំសំរាប់យ៉ាងហោចណាស់10ឆ្នាំ។ រដ្ឋនឹងមិនចំណាយទៅលើការផ្តល់នូវទីសំណាក់ឬការថែទាំសុខភាពរយៈពេលវែងសំរាប់មនុស្សចាស់ ការប្រថុយគ្រោះថ្នាក់មានកំរិតទាបការឃុំឃាំងដែលគ្មានអំពើហិង្សាសំរាប់ការកាត់ទោសឲ្យជាប់គុកមួយជីវិតចំពោះបទល្មើសដែលជាអនិតិជន។

(5) ទប់ស្កាត់ការដោះលែងមុនពេលកំណត់នៃឧក្រិដ្ឋជនដែលប្រកបដោយគ្រោះថ្នាក់ដែលបច្ចុប្បន្នត្រូវបានដោះលែងមុនកាលកំណត់ពីព្រោះតែគុកនិងពន្ធនាគារមានអ្នកទោសច្រើនហួសជាមួយនឹងការប្រថុយគ្រោះថ្នាក់មានកំរិតទាបការឃុំឃាំងដែលគ្មានអំពើហិង្សាសំរាប់ ការកាត់ទោសឲ្យជាប់គុកមួយជីវិតចំពោះបទល្មើសតូចតាច។

ផ្នែកទី 2. ផ្នែកទី677នៃក្រមព្រហ្មទណ្ឌគឺត្រូវបានកែប្រែឱ្យបកស្រាយថា៖

667. (a) (1) នៅក្នុងការអនុលោមតាមជាមួយនឹងអនុផ្នែក(b)នៃវគ្គទី 1385 រាល់បុគ្គលណាម្នាក់ដែលបានកាត់ទោសនៃបទឧក្រិដ្ឋ កំរិតធ្ងន់ក្នុងរដ្ឋនេះឬបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងសំណាញ់ច្បាប់ដែលរួមមានរាល់ធាតុទាំងឡាយនៃរាល់បទឧក្រិដ្ឋធ្ងន់ធ្ងរនឹងទទួលជាការបន្ថែមទៅកាន់ការកាត់ទោសបង្ខំដោយតុលាការសំរាប់កាត់សេចក្តីទៅលើបទល្មើសការធ្វើឲ្យមានមានភាពប្រសើរឡើងក្នុងរយៈកាលប្រាំឆ្នាំសំរាប់នីមួយៗដូចជាការកាត់ទោសមុនក្នុងការចោទប្រកាន់ដែលបាននាំយកមកនិងបានព្យាយាមដោយឡែកពីគ្នា។ លក្ខខណ្ឌនៃការកាត់ក្តីលើបទល្មើសនិងរាល់ការធ្វើឲ្យមានភាពប្រសើរ ឡើងនឹងដើរតាមលំដាប់លំដោយ។

(2) អនុផ្នែកនេះ នឹងមិនគួត្រូវបានស្នើសុំពេលដែលការធ្វើទណ្ឌកម្ម ដោយ បង្ខំក្រោមការផ្តល់ឲ្យដោយច្បាប់នឹងមានលទ្ធផលក្នុងរយៈពេលវែងក្នុងការជាប់គុក។ ពុំមានការទាមទារនៃការបង្កើតឡើង ជារូបភាពជាក់ស្តែងឬការសន្យានឹងធ្វើសំរាប់អនុផ្នែកដើម្បីស្នើសុំ។

(3) អង្គនិតិបញ្ញាត្តិប្រហែលជាតម្លើងរយៈពេលនៃការធ្វើឲ្យប្រសើរឡើងនៃការកាត់ទោសដែលបានផ្តល់ក្នុងចំណែកតូចៗដោយលខន្តិកៈច្បាប់ដែលឆ្លងកាត់ដោយការបោះឆ្នោតសម្លេងភាគច្រើននៃគ្រឹះស្ថាននីមួយៗនៃឬពីវគ្គនោះ។

(4) ដូចជាបានប្រើនូវក្នុងអនុផ្នែកនេះ "បទឧក្រិដ្ឋធ្ងន់ធ្ងរ" មានន័យថាបទឧក្រិដ្ឋធ្ងន់ធ្ងរមួយបានចុះបញ្ជីក្នុងចំណែកតូចៗ(c) នៃវគ្គ 1192.7។

(5) អនុផ្នែកនេះនឹងមិនអាចអនុវត្តទៅកាន់មនុស្សដែលបានចោទប្រកាន់ពីការលក់,ការផ្តល់,ការត្រួតត្រា,ការផ្តល់, ឬមានបំណងដាក់ លក់,ការផ្តល់, ការត្រួតត្រា,ទៅកាន់អនិតិជននូវរាល់ថ្នាំមេតាំហ្វេតាមីន-ដែលទាក់ទងនឹងថ្នាំញៀនឬរាល់ប្រផ្នូលនៃមេតាំហ្វេតាមីន ប្រសិនបើ បទល្មើសមុនមិនមែនជាបទឧក្រិដ្ឋធ្ងន់ធ្ងរដែលបានពិពណ៌នាក្នុងអនុផ្នែក(24)នៃអនុផ្នែក (C) នៃវគ្គ1992.7។

(b) វាគឺជាចេតនានៃអង្គនិតិបញ្ញាតិក្នុងការអនុម័តអនុផ្នែក(b)ទៅ(i) រួមមាន, ធ្វើឲ្យប្រកដការកាត់ទោសដាក់គុករយៈពេលវែងនិង ការដាក់ទណ្ឌកម្មធំសំរាប់អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋនិងមានការជាប់ទោសពីមុននៃបទល្មើសហិង្សានិង/ឬធ្ងន់ធ្ងរថ្នាក់ឧក្រិដ្ឋមួយឬច្រើន។

(c) យ៉ាងណាក៏ដោយរាល់ច្បាប់ផ្សេងៗ បើសិនជាចុងចោទម្នាក់ បានចោទប្រកាន់នៃបទឧក្រិដ្ឋមួយនិងវាបានជជែកការពារ និងបានបង្ហាញថាចុងចោទមានការជាប់ទោសពីមុននៃបទល្មើសហិង្សានិង/ឬធ្ងន់ធ្ងរ ថ្នាក់ឧក្រិដ្ឋមួយឬច្រើនដូចដែលបានកំណត់ក្នុងអនុផ្នែក (d), តុលាការនឹងប្រកាន់ខ្ជាប់រាល់អ្វីៗជាបន្តបន្ទាប់:

(1) ត្រង់នេះនឹងមិនមែនជាការកំណត់លក្ខខណ្ឌរួមផ្សំសរុបសំរាប់គោលបំណងនៃការកាត់ទោសតាមលំដាប់សំរាប់រាល់បទល្មើសថ្នាក់ឧក្រិដ្ឋលទ្ធផលដែលមានមក។

(2) ការសាកល្បងចំពោះបទល្មើសបច្ចុប្បន្ននឹងមិនយល់ព្រមឬប្រតិបត្តិការឬការដាក់បន្ទុកលើនៃការកាត់ទោសនឹងមិនត្រូវបានព្យួរសំរាប់រាល់បទល្មើសមុន។

(3) ថេរវេលាចន្លោះការជាប់ទោសពីមុននៃបទល្មើសហិង្សានិង/ឬធ្ងន់ធ្ងរថ្នាក់ឧក្រិដ្ឋនិងបទល្មើសថ្នាក់ឧក្រិដ្ឋបច្ចុប្បន្ននឹងមិនមានឥទ្ធិពលលើការដាក់បន្ទុកនៃការការកាត់ទោស។

(4) ត្រង់នេះនឹងមានការសន្យានឹងធ្វើមួយទៅកាន់រាល់បរិក្ខារផ្សេងពីពន្ធនាគាររបស់រដ្ឋ។ ការប្តូរទិសដៅនឹងមិនយល់ព្រមឬចុងចោទនឹងមិនមានសិទ្ធិសំរាប់ការសន្យានឹងធ្វើទៅកាន់មជ្ឈមណ្ឌលផ្តល់សម្បទារដ្ឋកាលីហ្វ័រញ៉ាថាពុដូចដែលបានផ្តល់ឲ្យក្នុងមាត្រា 2 (ចាប់ផ្តើមជាមួយវគ្គ 3050) នៃជំពូកទី1 នៃវគ្គទី 3នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា។

(5) ចំនួនសរុបនៃឥណទានបានប្រគល់ឲ្យអនុលោមទៅតាមលក្ខន្តិកៈ 2.5 (ចាប់ផ្តើមជាមួយនិងវគ្គ2930)នៃជំពូក7ចំណងជើងទី 1 នៃភាគ 3នឹងមិនត្រូវលើសពីមួយភាគប្រាំនៃលក្ខខណ្ឌសរុបនៃការជាប់គុកដែលបានឲ្យ

បង់និងនឹងមិនបន្ថែមលើរហូតដល់ចុង ចុងចោទត្រូវបានដាក់បញ្ចូលដោយរូបរាងទៅក្នុងពន្ធនាគាររដ្ឋ។

(6) ប្រសិនបើបើមានការចោទប្រកានើបច្ចុប្បន្នចំពោះច្រើនជាងបទល្មើសមួយ ការរាប់បញ្ចូលមិនប្រព្រឹត្តទៅនូវឱកាសនិងមិនកើតឡើងពីការរៀបដូចគ្នានៃការអនុវត្តភាពពិត តុលាការនឹងកាត់ទោសចុងចោទជាលំដាប់លើការរាប់បញ្ចូលអនុលោមទៅតាមអនុផ្នែក(e)។

(7) ប្រសិនបើមានការចោទប្រកាន់បច្ចុប្បន្នចំពោះបទលឧក្រិដ្ឋធ្ងន់ធ្ងរឬហិង្សាមួយឬច្រើនដូចដែលបានពិពណ៌នាក្នុងកថាខណ្ឌ (6), តុលាការនឹងបង្ខំលើការកាត់ទោសសំរាប់បទល្មើសនីមួយៗតាមលំដាប់លំដោយការកាត់ទោសសំរាប់រាល់បទល្មើសដែលចុងចោទប្រហែលជាត្រូវបានកាត់ទោសជាបន្តបន្ទាប់ក្នុងរបៀបដាក់កម្រិតដោយច្បាប់។

(8) រាល់ការកាត់ទោសស្របទៅលើអនុលោមទៅតាមអនុផ្នែក (e) នឹងត្រូវបានគ្រប់ទៅលើរៀងៗគ្នាទៅរាល់ការកាត់ទោសផ្សេងៗ ទៀតដែលចុងចោទគឺកំពុងតែបំពេញមុខងារ លុះត្រាតែ បើមិនដូច្នោះ ទេទើបបានផ្តល់ដោយច្បាប់។

(d) យ៉ាងណាក៏ដោយរាល់ច្បាប់ទាំងឡាយផ្សេងៗទៀតនិងសំរាប់គោលបំណងនៃអនុផ្នែក(b) ទៅ (i) ដែលរួមមានបទល្មើសមុន នៃ*បទឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សា*និងត្រូវកំណត់ដូចជាៈ

(1) រាល់បទល្មើសបានកំណត់ដោយអនុផ្នែក(c)នៃវគ្គ 667.5 ដូចជាបទឧក្រិដ្ឋហិង្សាមួយឬរាល់បទល្មើសដែលបានកំណត់ ក្នុងអនុផ្នែក(c) នៃវគ្គ 1192.7 ជាបទឧក្រិដ្ឋធ្ងន់ធ្ងរមួយក្នុងរដ្ឋ។ ការប្តេជ្ញានៃថាតើការកាត់ទោសមុនគឺជាបទល្មើសថ្នាក់ឧក្រិដ្ឋមុន សំរាប់គោលបំណងនៃអនុផ្នែក(b)ទៅកាន់ (i) រួមមាននឹងត្រូវបាន បង្កើតដោយផ្អែកលើកាលបរិច្ឆេទនៃការកាត់ទោសជាមុននោះនិងមិនត្រូវបានជះឥទ្ធិពលដោយការកាត់ទោសដែលបានធ្វើឡើងលុះត្រាតែការកាត់ទោសជាស្វ័យប្រវត្តិលើការកាត់ទោសពីខាងដើមបម្លែងបទឧក្រិដ្ឋទៅកាន់បទល្មើសមជ្ឈឹម។ គ្មានការចែកចាយជាបន្តបន្ទាប់នឹងមានឥទ្ធិពលលើការប្តេជ្ញាដែលការកាត់ទោសមុនគឺជាបទឧក្រិដ្ឋមុនសំរាប់គោលបំណងនៃអនុផ្នែក(b) ទៅ (i) រួមមានៈ

(A) ការព្យួរនៃការបង់ពិន័យនៃការវិនិច្ឆ័យឬការកាត់ទោស។

(B) ការពន្យាពេលនៃការកាត់ទោសប្រហារជីវិត។

(C) ការសន្យានឹងធ្វើនាយកដ្ឋានរដ្ឋនៃវគ្គសេវាសុខភាពដូចជា អ្នកប្រព្រឹត្របទល្មើសខាងផ្លូវភេទដែលមិនប្រក្រតីខាងផ្លូវចិត្តទៅតាមការចោទប្រកាន់នៃបទឧក្រិដ្ឋ។

(D) ការសន្យានឹងធ្វើទៅកាន់មជ្ឈមណ្ឌលនីតិសម្បទានៃរដ្ឋកាលីហ្វ័រញ៉ាឬរាល់បរិក្ខាផ្សេងៗដែលមុខងាររបស់វាគឺការប្តូរទិសពីពន្ធនាគាររដ្ឋ។

(2) ការចោទប្រកាន់ជាមុនមួយក្នុងសំណាញ់ច្បាប់មួយផ្សេងទៀតសំរាប់បទល្មើសមួយថា បើបានប្រព្រឹត្តក្នុងរដ្ឋកាលីហ្វ័រញ៉ា គឺអាចដាក់ទណ្ឌកម្មដោយការឲ្យជាប់ក្នុងពន្ធនាគាររដ្ឋ-*គួរតែងតាំងឡើងការ ចោទប្រកាន់ពីមុននៃបទឧក្រិដ្ឋធ្ងន់ធ្ងរនឹង/ឬអំពើហិង្សា*ណាមួយ គួររួមបញ្ចូល ប្រសិនបើការចោទប្រកាន់ពីមុននៅក្នុងយុត្តាធិការ *មួយទៀត* ផ្សេងទៀតគឺសំរាប់បទល្មើសដែលរួមមានកត្តាទាំងអស់នៃបទឧក្រិដ្ឋធ្ងន់ធ្ងរណាមួយ ដូចដែលបានកំណត់ក្នុងអនុផ្នែក (c) នៃ វគ្គ 667.5 ឬ*បទឧក្រិដ្ឋធ្ងន់ធ្ងរ* ដូចដែលបានកំណត់ក្នុងអនុផ្នែក (c) នៃអនុផ្នែក 1192.7។

(3) ការវិនិច្ឆ័យជាមុនសំរាប់ជនវ័យក្មេងនឹងប្រកាសការចោទប្រកាន់មុនថ្នាក់ឧក្រិដ្ឋ *ហិង្សានិង/ឬធ្ងន់ធ្ងរ*មួយសំរាប់គោលបំណងនៃភាពធ្វើឲ្យប្រសើរឡើងក្នុងការកាត់ទោសបើៈ

(A) យុវជនអាយុ 16 ឆ្នាំ ឬច្រើនជាងនេះគិតត្រឹមពេលដែលគាត់ ឬនាងប្រពឹត្តបទល្មើសមុន។

(B) បទល្មើសមុនគឺត្រូវបានចុះបញ្ជីក្នុងអនុផ្នែក(b)នៃវគ្គ 707 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានាភាពោរត្រូវបានពណ៌នាក្នុងកថាខណ្ឌ (1) ឬ(2)ដូចជា*បទឧក្រិដ្ឋហិង្សានិង/ឬធ្ងន់ធ្ងរមួយ*។

(C) អ្នកដែលមានវ័យក្មេងត្រូវបានរកឃើញថាគឺជាកម្មវត្ថុមួយដ៏សត្រូវល្មមនិងសមរម្យដើម្បីរកផ្លូវដោះស្រាយក្រោមច្បាប់តុលាការ នីតិជន។

(D) ជនដែលមានវ័យក្មេងត្រូវបានវិនិច្ឆ័យមនុស្សដែលគេគ្រប់គ្រងនៃតុលាការអនីតិជនជាមួយនឹងអត្ថន័យនៃវគ្គ 602 នៃក្រមផ្នែកសុខមាលភាពនិងស្ថាប័ននានា ពីព្រោះមនុស្សដែលប្រព្រឹត្តបទល្មើសបានចុះ

បញ្ជីកក្នុងអនុផ្នែក (b) នៃវគ្គ 707 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា។

(e) សំរាប់គោលបំណងនៃអនុផ្នែក (b) ទៅ (i) រួមមាននិងជាការបន្ថែមរាល់ការធ្វើឲ្យប្រសើរឡើងផ្សេងៗឬកិច្ចសន្យាដែលមានចែងក្នុងការដាក់ទណ្ឌកម្មដែលប្រហែលជាអនុវត្ត អ្វីៗជាបន្តបន្ទាប់នឹងអនុវត្តកន្លែងដែលចុងចោទមានបទល្មើសមុនថ្នាក់ឧក្រិដ្ឋធ្ងន់ធ្ងរ និង/ឬហិង្សាមួយឬ*ច្រើនៈ*

(1) ប្រសិនបើចុងចោទមានបទល្មើសមុនថ្នាក់ឧក្រិដ្ឋ*ធ្ងន់ធ្ងរនិង/ឬហិង្សា*មួយ ឬ*ច្រើន*ដូចដែលបានកំណត់ក្នុង*អនុផ្នែក(d)*ដែលបានជជែកការពារនិងបានបង្ហាញលក្ខខណ្ឌជាដាច់ខាតនឹងជាលក្ខខណ្ឌទ្វេជាពីបើមិនដូច្នោះទេបានផ្តល់ជាការដាក់ទណ្ឌកម្មសំរាប់បទល្មើសថ្នាក់ឧក្រិដ្ឋបច្ចុប្បន្ន។

(2) (A) ~~មើសិន~~ លើកលែងដូចបានផ្តល់ក្នុងកថាខណ្ឌរង(C) បើសិន

ចុងចោទម្នាក់មានពីរឬច្រើនបទល្មើសមុនថ្នាក់ឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សាដូចដែលបានកំណត់ក្នុងចំណែកតូចៗបន្តទៀត(d)ដែលបានជជែកវែកញែកនិងបានបង្ហាញលក្ខខណ្ឌសំរាប់ការចោទប្រកាន់ពីបទឧក្រិដ្ឋបច្ចុប្បន្ននឹងត្រូវជាលក្ខខណ្ឌមិនច្បាស់មួយនៃការដាក់គុកមួយជីវិតជាមួយនឹងលក្ខខណ្ឌអប្បបរិមាមួយនៃការកាត់ទោសគ្មានកំណត់ដែលបានគណនាជា~~ធំផាង~~ *ធំបំផុត*នៃៈ

(i) លក្ខខណ្ឌបីដងបើមិនដូច្នោះទេបានផ្តល់ជាការដាក់ទណ្ឌកម្ម សំរាប់រាល់បទឧក្រិដ្ឋដែលមានមកទៅកាន់បទល្មើសពីមុនថ្នាក់ឧក្រិដ្ឋ*ធ្ងន់ធ្ងរឬហិង្សា*ពីរឬច្រើន។

(ii) ការជាប់គុកក្នុងពន្ធនាគាររដ្ឋរយៈពេល 25 ឆ្នាំ។

(iii) លក្ខខណ្ឌបានកំណត់ដោយតុលាការអនុលោមទៅតាមវគ្គ 1170 សំរាប់ការចោទប្រកាន់ពីខាងដើមរួមមានរាល់ការធ្វើឲ្យប្រសើរ ដែលសមរម្យក្រោមជំពូក 4.5 (ចាប់ផ្តើមជាមួយនឹងវគ្គ1170) នៃ ចំណងជើង7 នៃភាគ 2 ឬរាល់កំឡុងពេលដែលបានដាក់បញ្ញាតិដោយវគ្គ190 ឬ3046។

(B) លក្ខខណ្ឌដែលគ្មានកំណត់ដែលបានពណ៌នាក្នុងកថាខណ្ឌរង (A)នឹងត្រូវបានយកមកប្រើតាមលំដាប់លំដោយទៅកាន់រាល់លក្ខខណ្ឌនៃការជាប់ពន្ធនាគាសំរាប់អ្វីដែលលក្ខខណ្ឌតាមលំដាប់លំដោយប្រហែលជាត្រូវបានដាក់បន្ទុកដោយច្បាប់។ រាល់លក្ខខណ្ឌផ្សេងទៀតបានដាក់បន្ទុកជាបន្តបន្ទាប់ទៅកាន់លក្ខខណ្ឌមិនកំណត់ដែលបានពណ៌នាអំពីកថាខណ្ឌរង (A) នឹងមិនត្រូវបានបញ្ចូលគ្នានៅក្នុងនោះ ប៉ុន្តែនឹងចាប់ផ្តើមនាពេលដែលជននោះនឹង បើមិនដូច្នោះទេបាន ដោះលែងពីពន្ធនាគារ។

*(C) បើសិនជាចុងចោទមានការចោទប្រកាន់ពីមុនពីបទឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សាដូចដែលបានកំណត់នៅក្នុងអនុផ្នែក(c) នៃវគ្គ 667.5 ឬអនុផ្នែក(c) នៃវគ្គ1192.7 ដែលត្រូវបានឆ្លើយ និង បកស្រាយ ហើយបទល្មើសបច្ចុប្បន្នមិនមែនជាបទឧក្រិដ្ឋធ្ងន់ធ្ងរ ឬហិង្សាដូចដែលបានកំណត់នៅក្នុងអនុផ្នែក(d) ភាគីចុងចោទ គួរត្រូវបានកាត់ទោសស្របតាមកថាខណ្ឌ(1)នៃអនុផ្នែក (e) ដរាប ណាការកាត់សេចក្តីឆ្លើយថានិងបកស្រាយដូចករណីខាងក្រោម ៖*

*(i) បទល្មើសបច្ចុប្បន្នគឺជាការចោទប្រកាន់ខាងសារធាតុដែល មានការគ្រប់គ្រង ដែលក្នុងនោះការចោទប្រកាន់ក្រោមវគ្គ 11370.4 ឬ 11379.8នៃក្រមសុខភាពនិងសុវត្ថិភាពត្រូវបានសារភាព ឬកំណត់ថាពិត។*

*(ii) បទល្មើសបច្ចុប្បន្នគឺជាបទល្មើសឧក្រិដ្ឋខាងផ្លូវភេទដែល ត្រូវបានកំណត់ក្នុងអនុផ្នែក(d)នៃវគ្គ 261.5 ឬវគ្គ 262 ឬរាល់បទល្មើសឧក្រិដ្ឋដែលលទ្ធផលក្នុងការចុះបញ្ជីការដ៏ចំបាច់បំផុតដូចជាជនល្មើសខាងផ្លូវភេទជាប់តាមអនុផ្នែក (c) នៃវគ្គ 290 លើកលែងតែចំពោះអំពើហិង្សានៃវគ្គ266និង 285, កថាខណ្ឌ (1) នៃអនុផ្នែក (b)និងអនុផ្នែក (e) នៃវគ្គ 286 កថាខណ្ឌ (1) នៃអនុផ្នែក (b)និងអនុផ្នែក (e) នៃវគ្គ 288a វគ្គ 311.11និងវគ្គ314។*

*(iii) កំឡុងពេលការប្រតិបត្តិនៃបទល្មើសបច្ចុប្បន្ន ជនជាប់ចោទ បានប្រើកាំភ្លើងដៃ បានត្រូវបានបំពាក់ប្រដាប់ដោយកាំភ្លើងខ្លី ឬអាវុធ ដែលអាចគ្រោះថ្នាក់ដល់ស្លាប់ឬមានចេតនាធ្វើឲ្យរបួសធ្ងន់ធ្ងររាងកាយចំពោះជនដទៃ។*

*(iv) ចុងចោទបានរងការឈឺចាប់ពីបទល្មើសមុនដែលធ្ងន់ធ្ងរនិង/ ឬជា ហិង្សាដូចបានកំណត់ក្នុងអនុផ្នែក(d) នៃវគ្គនេះសំរាប់រាល់ បទល្មើសថ្នាក់ឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សាដូចខាងក្រោមៈ*

*(I) "បទល្មើសផ្លូវភេទឃោរឃៅ"ដូចបានកំណត់ដោយអនុផ្នែក (b) នៃវគ្គ 6600 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា។*

*(II) ការរួមភេទតាមមាត់ជាមួយកុមារដែលមានអាយុក្រោម 14 ឆ្នាំ និងដែលមានអាយុច្រើនជាង10 ឆ្នាំក្មេងជាងគាត់ឬនាងដូចដែលបានកំណត់ដោយវគ្គ 288a ការរួមភេទតាមរន្ធគូទជាមួយមនុស្សដទៃ ដែលមានអាយុក្រោម 14 ឆ្នាំនិងដែលមានអាយុច្រើនជាង10ឆ្នាំក្មេង ជាងគាត់ឬនាងដូចដែលបានកំណត់ដោយវគ្គ 286 ឬការបៀតបៀន ផ្លូវភេទជាមួយមនុស្សដទៃទៀតដែលមានអាយុក្រោម14 ឆ្នាំនិងដែលមានអាយុច្រើនជាង10 ឆ្នាំក្មេងជាងគាត់ឬនាងដូចដែលបានកំណត់ដោយ វគ្គ 289។*

*(III) អំពើអាសគ្រាមឬដែលបណ្តាលឲ្យមានចំណង់ផ្លូវភេទដែលពាក់ព័ន្ធនឹងកុមារក្រោមអាយុ 14 ឆ្នាំក្នុងការល្មើសច្បាប់នៃវគ្គ 288។*

*(IV) រាល់បទល្មើសមនុស្សឃាតរួមមានរាល់បទល្មើសមនុស្សឃាតដែលប៉ុនប៉ងបានកំណត់ក្នុងវគ្គ 187 ទៅ 191.5 ដែលរាប់បញ្ចូល។*

*(V) ការអំពាវនាវធ្វើឃាតកម្មដូចបានកំណត់ក្នុងវគ្គ 653f។*

*(VI) ការវាយប្រហារដោយកាំភ្លើងយន្តទៅលើមន្ត្រីការពារសន្តិភាពឬអ្នកពន្លត់អគ្គីភ័យដូចបានកំណត់ក្នុងកថាខណ្ឌ(3) នៃអនុផ្នែក(d) នៃវគ្គ 245។*

*(VII) ការកាន់កាប់នៃអាវុធនៃការបំផ្លិចបំផ្លាញទ្រង់ទ្រាយធំដូចបានកំណត់ក្នុងកថាខណ្ឌ(1)នៃអនុផ្នែក (a)នៃវគ្គ11418។*

*(VIII) រាល់បទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សាដែលអាចដាក់ទោសក្នុងរដ្ឋកាលីហ្វ័រញ៉ាដោយឲ្យដាក់គុកអសស់មួយជីវិតឬដល់ស្លាប់។*

(f) (1) យ៉ាងណាមាន ច្បាប់ផ្សេងៗណាក៏ដោយ អនុផ្នែក(b) ដល់(i) ចូលគ្នានឹងត្រូវបានអនុវត្តក្នុងរាល់ករណីដែលចុងចោទ ម្នាក់មាន~~បទល្មើស~~ពីមុនថ្នាក់ឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សា *មួយ ឬច្រើន* ដូចដែលបានកំណត់ក្នុងអនុផ្នែក(d)។ សុភាចារបុរសនឹង ជជែកនិងបង្ហាញបទល្មើសឧក្រិដ្ឋ ពីមុន *ធ្ងន់ធ្ងរ និង/ឬ ហិង្សា* នីមួយៗលើកលែងដូចបានផ្តល់ក្នុងកថាខណ្ឌ (2)។

(2) សុភាចារបុរសប្រហែលជាផ្លាស់ប្តូរដើម្បីអនុញ្ញាតឲ្យបែកចេញឬគូសពាក្យចោទប្រកាន់ដែលគ្មានភស្តុតាងលើបទឧក្រិដ្ឋពីមុន*ធ្ងន់ធ្ងរនិង/ឬហិង្សា* ក្នុងការធ្វើឲ្យជឿនលឿនទៅមុខនៃយុត្តិធម៌ស្រប តាមវគ្គ1385ឬបើមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីបង្ហាញបទឧក្រិដ្ឋពីមុន *ធ្ងន់ធ្ងរនិង/ឬហិង្សា*។ ប្រសិនបើលើការបំពេញនៃតុលាការ ដែលមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីបង្ហាញការចោទប្រកាន់បទ ឧក្រិដ្ឋពីមុនដែល*ធ្ងន់ធ្ងរនិង/ឬហិង្សា*តុលាការប្រហែលជាផ្លាស់ប្តូរ ដើម្បីអនុញ្ញាតឲ្យបែកចេញពាក្យចោទប្រកាន់គ្មានភស្តុតាងគ្រប់គ្រាន់។ គ្មានអ្វីក្នុងវគ្គនេះនឹងត្រូវបានសិក្សាដើម្បីកែប្រែអំណាចរបស់តុលាការក្រោមវគ្គ1385។

(g) កាចោទពីបទល្មើសដែលមានភាព*ធ្ងន់ធ្ងរ និង/ឬហិង្សា* ពីមុននឹងមិនត្រូវបានប្រើក្នុងការតវ៉ាថាមានឬគ្មានទោសទេ ដូចបានកំណត់ ក្នុងអនុផ្នែក (b) នៃវគ្គ1192.7.ការយកមកកាត់ទោសនឹងត្រូវបាន ជជែកនិងបង្ហាញរាល់ការចោទប្រកាន់បទឧក្រិដ្ឋពីមុនដែល*ធ្ងន់ធ្ងរនិង/ឬហិង្សា*និងនឹងមិនចូលទៅក្នុងរាល់កិច្ចព្រមព្រៀងដើម្បីដាក់បន្ទុក ឬស្វែងរកការអនុញ្ញាតឲ្យចេញនៃការចោទប្រកាន់គ្មានភស្តុតាងលើ បទឧក្រិដ្ឋពីមុនដែលធ្ងន់ធ្ងរនិង/ឬហិង្សាលើកលែងដូចបានផ្តល់ក្នុង កថាខណ្ឌ(2)នៃអនុផ្នែក(f)។

(h) សេចក្តីយោងទាំងអស់សំដៅទៅលើលក្ខន្តិកៈក្នុងអនុផ្នែក (c)ដល់(g) រួមចូលគ្នាគឺជាលក្ខន្តិកៈដូចដែលពួកវាមានស្រាប់ នៅ ~~ថ្ងៃ 30ខែមិថុនា ឆ្នាំ 1993~~ *ថ្ងៃ 7 ខែវិច្ឆិកា ឆ្នាំ 2012* ។

(i) បើសិនខដែលមានចែងនៃអនុផ្នែក(b)ទៅ(h) រួមបញ្ចូលឬ វគ្គ1170.126 ឬពាក្យសុំនៃវគ្គនោះទៅកាន់រាល់បុគ្គលឬរាល់កាលៈទេសៈគឺត្រូវបានកាន់កាប់ទុកជាមោឃៈដែលមោឃកម្មនេះនឹងមិនមានឥទ្ធិពលទៅកាន់ ខដែលបែងចែកឬការស្នើសុំផ្សេងទៀតនៃអនុផ្នែកទាំងនោះដែលអាចត្រូវបានផ្តល់ឥទ្ធិពលដោយគ្មានខដែលបានចែង ដែលមោឃៈឬការស្នើសុំដែលមោឃៈនិងចុងបញ្ចប់នៃខដែលបាន ចែងនៃអនុផ្នែកទាំងនោះគឺដែលអាចកាត់ចេញបាន។

(j) ខដែលបានចែងនៃវគ្គនេះនឹងមិនត្រូវបានកែប្រែដោយអង្គនីតិបញ្ញត្តិលើកលែងដោយលក្ខន្តិកៈច្បាប់ដែលបានឆ្លងកាត់រាល់គ្រឹះស្ថាននីមួយៗដោយការបោះឆ្នោតដោយការកោះហៅឈ្មោះបានចូលទៅក្នុងទិន្នានុប្បវត្តិពីរភាគបីនៃការព្រមព្រៀងជាភាពសមាជិកឬ ដោយលក្ខន្តិកៈច្បាប់ ដែលមានប្រសិទ្ធិភាពពេលបានទទួលយល់ព្រមដោយអ្នកបោះឆ្នោតប៉ុណ្ណោះ។

វគ្គទី 3. វគ្គ667.1 នៃច្បាប់ព្រហ្មទណ្ឌគឺធ្វើវិសោធនកម្មឱ្យបកស្រាយថា ៖

667.1 យ៉ាងណាក៏ដោយអនុផ្នែក(h)នៃវគ្គ 667សំរាប់ បទ គ្រប់ល្មើសបានប្រព្រឹត្តនៅឬបន្ទាប់ពីថ្ងៃមានសុពលភាពនៃថ្ងៃទី 7 ខែវិច្ឆិកាឆ្នាំ2012 រាល់ឯកសារយោងដើម្បីលក្ខន្តិកៈកើតមានឡើងក្នុងអនុផ្នែក(c) ទៅ(g) រួមបញ្ចូលនៃវគ្គ667គឺដើម្បី លក្ខន្តិកៈទាំងនោះដូចដែលវាបានមាន~~នៅថ្ងៃដែលមានសុពលភាពនៃកិច្ចការនេះរួមមានវិសោធនកម្មដែលបានបង្កើត ដើម្បីលក្ខន្តិកៈទាំងនោះដោយកិច្ចការបានអនុម័តកំឡុងឆ្នាំ2005 06 សម័យប្រជុំ ជាទៀងទាត់ដែលបានកែប្រែវគ្គនេះ~~*ថ្ងៃទី 7 ខែវិច្ឆកា ឆ្នាំ 2012*។

វគ្គទី 4. វគ្គ 1170.12នៃច្បាប់ព្រហ្មទណ្ឌគឺធ្វើវិសោធនកម្មឱ្យបកស្រាយ ថា ៖

1170.12. ~~(a) លក្ខខណ្ឌរួមផ្សំទាំងអស់និងជាលំដាប់លំដោយសំរាប់បទល្មើសច្រើនបែប បទល្មើសដំបូងជាបទល្មើសឧក្រិដ្ឋ ការសន្យា នឹងធ្វើនិងការធ្វើឲ្យមានគុណភាពល្អផ្សេងៗឬការដាក់ទណ្ឌកម្ម។~~

(a) យ៉ាងក៏ដោយរាល់ខដែលមានចែងនៃច្បាប់ បើសិនចុងចោទ ម្នាក់បានផ្តន្ទាទោសអំពីបទឧក្រិដ្ឋនិងវបានជជែកការពារហើយបាន បង្ហាញថាចុងចោទនោះមានបទល្មើសឧក្រិដ្ឋ*ធ្ងន់ធ្ងរនិង/ឬហិង្សា*ពីមុនម្តងឬច្រើនដងដូចបានកំណត់ក្នុងអនុផ្នែក(b)តុលាការនឹងប្រកាន់ខ្ជាប់នូវរាល់អ្វីៗជាបន្ត បន្ទាប់ ៖

(1) វានឹងមិនមែនជាលក្ខខណ្ឌការកំណត់រួមផ្សំសរុបមួយសំរាប់គោលបំណងនៃការកាត់ទោសជាបន្តបន្ទាប់សំរាប់រាល់បទឧក្រិដ្ឋដែលកើតមានបន្តបន្ទាប់។

(2) ការសាកល្បងសំរាប់បទល្មើសបច្ចុប្បន្ននឹងមិនត្រូវបានយល់ព្រម ឬការប្រហារជីវិតឬការដាក់ពិន័យនៃការកាត់ទោសនឹងមិនត្រូវបានព្យួរសំរាប់រាល់បទល្មើសមុនឡើយ។

(3) ថេរវេលាចន្លោះបទល្មើសឧក្រិដ្ឋពីមុនដែល*ធ្ងន់ធ្ងរ និង/ឬហិង្សា* និងបទល្មើសឧក្រិដ្ឋបច្ចុប្បន្ននឹងមិនមានឥទ្ធិពលលើការដាក់ពិន័យ នៃការកាត់ទោសឡើយ។

(4) វានឹងមិនមែនជាការសន្យានឹងធ្វើទៅកាន់រាល់បរិក្ខារផ្សេងលើសពីពន្ធនាគាររដ្ឋឡើយ។ ការបែងចែកនឹងមិនទទួល យល់ព្រមឬចុងចោទនឹងមិនមានសិទ្ធិសំរាប់ការសន្យានឹងធ្វើទៅកាន់មជ្ឈមណ្ឌលនិតិសម្បទារដ្ឋកាលីហ្វ័រញ៉ាឡើយដូចដែលបានកំណត់ក្នុងចំណងជើង2(ចាប់ផ្តើមជាមួយនឹងវគ្គ3050)នៃជំពូកទី1នៃផ្នែក 3នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា។

(5) បរិមាណសរុបនៃឥណទានដែលបានប្រគល់ស្របតាមមាត្រា 2.5 (ចាប់ផ្តើមជាមួយនឹងវគ្គ2930)នៃជំពូកទី7នៃចំណងជើង2នៃវគ្គទី3នឹងមិនលើសពីមួយភាគប្រាំនៃលក្ខខណ្ឌទាំងអស់នៃការដាក់គុកដែលបានដាក់បន្ទុកនឹងមិនចូលជាធរមានរហូតចុងចោទគឺត្រូវ បានដាក់ដោយរាងកាយទៅក្នុងពន្ធនាគាររដ្ឋ។

(6) បើសិនវាមានបទល្មើសបច្ចុប្បន្នសំរាប់លើសពីបទឧក្រិដ្ឋមួយដែលមិនបានប្រព្រឹត្តនៅពេលវេលាដូចគ្នានិងមិនកើតមានឡើងពីឈុតដូចគ្នានៃភាពពិតកំពុងអនុវត្ត តុលាការនឹងវិនិច្ឆ័យទោសចុងចោទជា បន្តបន្ទាប់លើបញ្ជីនីមួយៗស្របតាមវគ្គនេះ។

(7) បើសិនជាមានបទល្មើសបច្ចុប្បន្នសំរាប់លើសពីបទឧក្រិដ្ឋធ្ងន់ធ្ង ឬហិង្សាមួយដូចដែលបានពណ៌នាក្នុង~~កថាខណ្ឌ(6)~~ នៃអនុផ្នែកនេះ(b) តុលា ការនឹងដាក់បន្ទុកការកាត់ទោសសំរាប់បទល្មើសជាបន្ត បន្ទាប់ដើម្បីការកាត់ទោសចំពោះរាល់បទល្មើសផ្សេងទៀតសំរាប់អ្វីដែលចុងចោទប្រហែលជាត្រូវ បានកាត់ទោសជាលំដាប់លំដោយក្នុងរបៀបដែលបានដាក់កម្រិតដោយច្បាប់។

~~(8) រាល់ការកាត់ទោសដែលបានដាក់បន្ទុកស្របតាមវគ្គនេះនឹងមិនត្រូវដាក់បន្ទុកជាលំដាប់លំដោយទៅរាល់ការកាត់ទោសដទៃទៀតដែលចុងចោទគឺកំពុងបំពេញមុខងារ លុះត្រាតែផ្ទុយពីនេះបើបានផ្តល់ដោយច្បាប់។~~

(b) យ៉ាងណាក៏ដោយរាល់ខដែលមានចែងដទៃទៀតនៃច្បាប់និងសំរាប់គោលដៅនៃវគ្គនេះ បទល្មើសឧក្រិដ្ឋមួយដែល*ធ្ងន់ធ្ងរ និង/ ឬហិង្សា*នឹងត្រូវបានកំណត់ជា៖

36

(1) រាល់បទល្មើសដែលបានកំណត់ក្នុងអនុផ្នែក(c) នៃវគ្គ 667.5 ដូច បទល្មើសឧក្រិដ្ឋហិង្សាឬរាលបទល្មើសក្នុងរដ្ឋ។ ការប្តេជ្ញានៃថាតើបទល្មើសមុនគឺជាបទល្មើសឧក្រិដ្ឋមួយដែល*ធ្ងន់ធ្ងរនិង/ឬហិង្សា* មួយសំរាប់គោល បំណងនៃវគ្គនេះនឹងត្រូវបានបង្កើតលើថ្ងៃនៃបទល្មើសមុននោះនិងមិនមែនត្រូវបានប៉ះពាល់ដោយការកាត់ទោសដែលបានដាក់បន្ទុកលុះត្រាតែការកាត់ទោសជាស្វ័យប្រវត្តិ។ គ្មានការចែកចាយជាបន្តបន្ទាប់ នឹងមានឥទ្ធិពល លើការសំរេចចិត្ត ដែលបទល្មើស មុន ដែល*ធ្ងន់ធ្ងរនិង/ឬហិង្សា*មួយគឺជាបទឧក្រិដ្ឋ មួយដែល*ធ្ងន់ធ្ងរ និង/ឬហិង្សា*សំរាប់គោលបំណងនៃវគ្គនេះ៖

(A) ការព្យួរនៃការដាក់បន្ទុកនៃការវិនិច្ឆ័យឬកាត់ទោស។

(B) ការពន្យារនៃការប្រតិបត្តិនៃការកាត់ទោស។

(C) ការសន្យានឹងផ្ញើទៅកាន់ក្រសួងការបរទេសនៃសេវាកម្មសុខភាពដូចជាជនល្មើសផ្លូវភេទដែលខូចសតិបញ្ញាទៅតាមបទល្មើសនៃបទឧក្រិដ្ឋមួយ។

(D) ការសន្យានឹងផ្ញើទៅកាន់មជ្ឈមណ្ឌលនីតិសម្បទារដ្ឋកាលីហ្វ័រ នីញ៉ា ឬរាល់បរិក្ខារដែលមុខងាររបស់វាគឺការប្តូរទិសដៅនីតិសម្បទាពីពន្ធនាគាររដ្ឋ។

(2) បទល្មើសមុនមួយក្នុងអំណាចច្បាប់មួយផ្សេងទៀតសំរាប់បទល្មើសមួយដែល បើសិនជាបានប្រព្រឹត្តរដ្ឋកាលីហ្វ័រញ៉ា គឺដែលអាច ដាក់ទណ្ឌកម្មបានដោយការជាប់គុកក្នុងពន្ធនាគាររដ្ឋ*គួរតែងតាំង*ឡើងបទល្មើសមុនមួយនៃបទឧក្រិដ្ឋ *ធ្ងន់ធ្ងរនិង/ឬហិង្សា*ជាពិសេសមួយនឹងរួមមាន*បើសិនបទល្មើស* មុនក្នុងអំណាចច្បាប់មួយទៀត *ផ្សេងទៀត គឺ*ចំពោះបទល្មើសមួយដែល រួមមានរាល់កត្តានៃបទឧក្រិដ្ឋ*ហិង្សា*ណាមួយដូចបានកំណត់ក្នុងអនុផ្នែក(c) នៃវគ្គ 667.5 ឬឧក្រិដ្ឋ*ធ្ងន់ធ្ងរដូចបានកំណត់* ក្នុងអនុផ្នែក(c) នៃវគ្គ1192.7។

(3) ការកាត់ក្តីដំបូងសំរាប់ជនដែលមានវ័យក្មេងមួយនឹងត្រូវតាំង ឡើងជាបទឧក្រិដ្ឋមុនដែល*ធ្ងន់ធ្ងរ និង/ឬហិង្សា*មួយសំរាប់គោល បំណងនៃការធ្វើឲ្យកាន់តែប្រសើរកាត់ទោសបើ ៖

(A) យុវវ័យអាយុ16ឆ្នាំឬច្រើនជាងនេះត្រឹមពេលគាត់ឬនាងបានប្រព្រឹត្តបទល្មើសមុន និង

(B) បទល្មើសមុនគឺ

(i) បានចុះបញ្ជីក្នុងអនុផ្នែក (b) នៃវគ្គ707 នៃចក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា ឬ

(ii) បានចុះបញ្ជីក្នុងអនុផ្នែកដូចបទឧក្រិដ្ឋ *ធ្ងន់ធ្ងរ និង/ឬហិង្សា*មួយ និង

(C) យុវវ័យបានត្រូវបានរកឃើញថាជាត្រូវម៉ាច់និងកម្មវត្ថុត្រឹមត្រូវជាប់ទាក់ទងជាមួយនឹងតុលាការច្បាប់សំរាប់ជនមានវ័យក្មេង និង

(D) យុវវ័យបានត្រូវបានកាត់សេចក្តីក្នុងការគ្រប់គ្រងនៃយុវតុលាការជានៅក្នុងខ្លឹមសារនៃវគ្គ 602 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានាពីព្រោះ បុគ្គលបានប្រព្រឹត្តបទល្មើសមួយដែលបានចុះបញ្ជីក្នុង អនុផ្នែក (b) នៃវគ្គ 707 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា។

(c) សំរាប់គោលបំណងនៃវគ្គនេះនិងជាការបន្ថែមទៅកាន់រាល់ការធ្វើឲ្យប្រសើរឡើងផ្សេងៗឬដែលមានចែងការដាក់ទណ្ឌកម្មដែលប្រហែលអនុវត្តអ្វីៗជាបន្តបន្ទាប់នឹងអនុវត្តកន្លែងដែលចុងចោទជាប់ទោស *ជាប់ទោសច្រើន* បទឧក្រិដ្ឋមុន *មួយឬច្រើនដែលធ្ងន់ធ្ងរនិង/ឬហិង្សា៖*

(1) បើសិនជាចុងចោទម្នាក់មានបទឧក្រិដ្ឋមុនមួយដែល*ធ្ងន់ធ្ងរនិង/ឬហិង្សា*ដូចដែលបាន*កំណត់ក្នុងអនុផ្នែក* (b)ដែលបានជជែកនិង បង្ហាញល័ក្ខខ័ណ្ឌដែលបានកំណត់នឹងពីដងលក្ខខណ្ឌបើមិនដូច្នោះ ទេបានផ្តល់ដូចការដាក់ទណ្ឌកម្មសំរាប់បទឧក្រិដ្ឋបច្ចុប្បន្ន។

(2) (A) មើ លើកលែងដូចដែលបានផ្តល់ក្នុងកថាខណ្ឌរង (c) នៃចុងចោទម្នាក់មានបទឧក្រិដ្ឋមុនពីរឬច្រើនដែល*ធ្ងន់ធ្ងរនិង/ឬហិង្សា*ដូចបានកំណត់ក្នុងកថាខណ្ឌ~~(1)~~ នៃអនុផ្នែក(b)ដែលបានជជែកនិងបានបង្ហាញលក្ខខណ្ឌសំរាប់បទឧក្រិដ្ឋបច្ចុប្បន្ននឹងជាលក្ខខណ្ឌ ដែលបានកំណត់មួយនៃការជាប់គុកអស់មួយជីវិតជាមួយនឹងលក្ខខណ្ឌជាអប្បបរមានៃការកាត់ទោសដែលបានកំណត់ដែលបានប៉ាន់ស្មានដូចភាពធំជាង *ធំជាទីបំផុត* នៃ ៖

(i) លក្ខខណ្ឌ3ដងបើមិនដូច្នោះទេបានផ្តល់ដូចការដាក់ទណ្ឌកម្មសំរាប់បទឧក្រិដ្ឋបច្ចុប្បន្ននីមួយៗជាបន្តបន្ទាប់ទៅចំពោះបទឧក្រិដ្ឋមុនពីរឬច្រើនដងដែល*ធ្ងន់ធ្ងរ និង/ឬហិង្សា* ឬ

(ii) 25ឆ្នាំ ឬ

(iii) លក្ខខណ្ឌបានកំណត់ដោយតុលាការស្របតាមវគ្គ1170 សំរាប់បទល្មើសដែលជាមូលដ្ឋានរួមមានការធ្វើឲ្យប្រសើរដែលអាចអនុវត្តបានក្នុងជំពូកទី4.5 (ចាប់ផ្តើមជាមួយនឹងវគ្គ1170) នៃ ចំណងជើងទី 7 នៃវគ្គ2ឬរាល់កំឡុងពេលដែលបានដាក់កម្រិត ដោយវគ្គ190ឬ3046។

(B) លក្ខខណ្ឌដែលបានកំណត់បានពិពណ៌នាក្នុងកថាខណ្ឌរង (A) នៃកថាខណ្ឌ(2)នៃអនុផ្នែកនឹងត្រូវបានបម្រើជាលំដាប់លំដោយទៅកាន់រាល់លក្ខខណ្ឌផ្សេងៗទៀតនៃការជាប់គុកសំរាប់អ្វី ដែលលក្ខខណ្ឌតៗគ្នាប្រហែលត្រូវបានដាក់បន្ទុកដោយច្បាប់។ រាល់ លក្ខខណ្ឌដែលបានដាក់បន្ទុកដែលកើតឡើងបន្តបន្ទាប់ទៅ កាន់លក្ខខណ្ឌដែលមិនបានកំណត់បានពិពណ៌នាក្នុងកថាខណ្ឌរង (A) នៃកថាខណ្ឌ (2)នៃអនុផ្នែកនេះនឹងមិនត្រូវបានបញ្ចូលគ្នានៅក្នុងនោះប៉ុន្តែ បើមិនដូច្នោះទេនឹងចាប់ផ្តើមនៅពេលមនុស្សនឹងត្រូវបានដោះលែងពីពន្ធនាគារ។

*(C) បើសិនចុងចោទមានបទឧក្រិដ្ឋពីរឬច្រើនដែលធ្ងន់ធ្ងរនិង/ឬហិង្សាដូចបានកំណត់ក្នុងអនុផ្នែក(c)នៃវគ្គ 667.5 ឬអនុផ្នែក(c) នៃវគ្គ 1192.7 ដែលបានជជែកនិងបានបង្ហាញ,និងបទល្មើសបច្ចុប្បន្នគឺមិនមែនជាបទឧក្រិដ្ឋមួយដែលបានពិពណ៌នាក្នុងមាត្រា(1)នៃអនុផ្នែក(b)នៃវគ្គនេះឡើយ ចុងចោទនឹងត្រូវបានកាត់ទោស ស្របតាមកថាខណ្ឌ(1)នៃអនុផ្នែក (c) នៃវគ្គនេះ លុះត្រាតែការគឺ ដើមបណ្តឹងជជែកនិង បង្ហាញរាល់អ្វីៗជាបន្តបន្ទាប់ ៖*

*(i) បទល្មើសបច្ចុប្បន្នគឺការចោទប្រកាន់សារជាតិដែលត្រូវគ្រប់គ្រងដែលក្នុងនោះការចោទប្រកាន់ដែលប្រកាន់ដែលគ្មានភស្តុតាងក្រោមវគ្គ11370.4 ឬ11379.8នៃច្បាប់សុខភាពនិងសុវត្ថិភាពបានត្រូវបានសារភាពឬបានរកឃើញថាពិត។*

*(ii) បទល្មើសបច្ចុប្បន្នគឺជាបទល្មើសឧក្រិដ្ឋផ្លូវភេទមួយដែល បានកំណត់ក្នុងអនុផ្នែក(d)នៃវគ្គ261.5 ឬវគ្គ 262 ឬរាល់បទ ល្មើសឧក្រិដ្ឋដែលមានលទ្ធផលក្នុងការចុះបញ្ជីការជាចាំបាច់ដូចជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទស្របតាមអនុផ្នែក(C) នៃវគ្គ 290 លើកលែងសំរាប់ការល្មើសច្បាប់នៃវគ្គ 266 និង285កថាខណ្ឌ(1)នៃអនុផ្នែក(b)និងអនុផ្នែក(e)នៃវគ្គ288a,វគ្គ314,និងវគ្គ311.11។*

*(iii)កំឡុងពេលការប្រតិបត្តិនៃបទល្មើសបច្ចុប្បន្នជនជាប់ចោទ បានប្រើកាំភ្លើងដៃ បានត្រូវបានបំពាក់ប្រដាប់ដោយកាំភ្លើងខ្លីឬអាវុធ ដែលអាចគ្រោះថ្នាក់ដល់ស្លាប់ឬមានចេតនាធ្វើឲ្យរបួសធ្ងន់ធ្ងរខាង រាងកាយចំពោះជនដទៃ។*

*(iv) ចុងចោទបានរងការឈឺចាប់ពីបទល្មើសមុនដូចបានកំណត់ ក្នុងការបែងចែងតូចៗ(b)នៃវគ្គនេះសំរាប់រាល់បទល្មើសថ្នាក់ឧក្រិដ្ឋធ្ងន់ធ្ងរ និង/ឬហិង្សាជាបន្តបន្ទាប់៖*

*(I) "បទល្មើសផ្លូវភេទឃោរឃៅ"ដូចបានកំណត់ដោយអនុផ្នែកនៃ វគ្គ 6600 នៃក្រមផ្នែកសុខមាលភាព និងស្ថាប័ននានា។*

*(II) ការរួមភេទតាមមាត់ជាមួយកុមារដែលមានអាយុក្រោម 14 ឆ្នាំនិងដែលមានអាយុច្រើនជាង10ឆ្នាំ ក្មេងជាងគាត់ឬនាងដូចដែល បានកំណត់ដោយវគ្គ 288a ការរួមភេទតាមរន្ធគូទជាមួយ មនុស្សដទៃ ដែលមានអាយុក្រោម14ឆ្នាំនិងដែលមានអាយុច្រើន ជាង 10 ឆ្នាំ ក្មេងជាងគាត់ឬនាងដូចដែលបានកំណត់ដោយ វគ្គ 286ឬការបៀតបៀនផ្លូវភេទជាមួយមនុស្សដទៃទៀតដែលមាន អាយុក្រោម14ឆ្នាំនិងដែលមានអាយុច្រើនជាង10ឆ្នាំក្មេងជាងគាត់ឬនាងដូចដែលបានកំណត់ដោយវគ្គ289។*

*(III) អំពើអាសគ្រាមឬដែលបណ្តាលឲ្យមានចំណង់ផ្លូវភេទដែល ពាក់ព័ន្ធនឹងកុមារក្រោមអាយុ14ឆ្នាំក្នុងការល្មើសច្បាប់នៃវគ្គ 288។*

*(IV) រាល់បទល្មើសមនុស្សឃាតរួមមានរាល់បទល្មើសមនុស្សឃាតដែលឬប៉ុងបានកំណត់ក្នុងវគ្គ187ទៅ191.5 ដែលរាប់បញ្ចូល។*

*(V) ការអំពាវនាវធ្វើឃាតកម្មដូចបានកំណត់ក្នុងវគ្គ 653f។*

*(VI) ការវាយប្រហារដោយកាំភ្លើងយន្តទៅលើមន្ត្រីការពារសន្តិភាពឬអ្នកពន្លត់អគ្គីភ័យដូចបានកំណត់ក្នុងកថាខណ្ឌ(3)នៃអនុផ្នែក (d)នៃវគ្គ 245។*

*(VII) ការកាន់កាប់នៃអាវុធនៃការបំផ្លិចបំផ្លាញទ្រង់ទ្រាយធំដូចបានកំណត់ក្នុងកថាខណ្ឌ(1)នៃអនុផ្នែក (a) នៃវគ្គ11418។*

*(VIII) រាល់បទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សាដែលអាចដាក់ទោសក្នុងរដ្ឋកាលីហ្វ័រញ៉ាដោយឲ្យដាក់គុកអសស់មួយជីវិតឬដល់ស្លាប់។*

36

(d) (1) យ៉ាងណាក៏ដោយរាល់ខដែលបានចែងនៃច្បាប់វគ្គនេះ នឹងត្រូវបានអនុវត្តក្នុងរាល់ករណីដែលចុងចោទម្នាក់~~ជាប់ទោស~~ *ជាប់ទោសច្រើនបទល្មើសពីមុនថ្នាក់ឧក្រិដ្ឋធ្ងន់ធ្ងរនិង/ឬហិង្សា មួយឬច្រើន*ដូចដែលបានកំណត់ក្នុងវគ្គនេះ។ សុភាចារបុរសនឹងជជែកនិងបង្ហាញបទឧក្រិដ្ឋពីមុនថ្នាក់*ធ្ងន់ធ្ងរនឹង/ឬហិង្សា* នីមួយៗលើកលែងដូចបាន ផ្តល់ក្នុងកថាខណ្ឌ(2)។

(2) សុភាចារបុរសប្រហែលជាផ្លាស់ប្តូរដើម្បីអនុញ្ញាតឲ្យបែកចេញឬគូសពាក្យចោទប្រកាន់ដែលគ្មានភស្តុតាងលើបទឧក្រិដ្ឋពីមុនធ្ងន់ធ្ងរនិង/ឬហិង្សាក្នុងការធ្វើឲ្យជឿនលឿនទៅមុខនៃយុត្តិធម៌ស្រប តាមវគ្គ1385ឬបើមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីបង្ហាញបទ ឧក្រិដ្ឋពីមុនធ្ងន់ធ្ងរនិង/ឬហិង្សា។ ប្រសិនបើលើការបំពេញនៃ តុលាការដែលមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីបង្ហាញការចោទ ប្រកាន់បទឧក្រិដ្ឋពីមុនដែលធ្ងន់ធ្ងរនិង/ឬហិង្សាតុលាការប្រហែលជាផ្លាស់ប្តូរដើម្បីអនុញ្ញាតឲ្យបែកចេញពាក្យចោទប្រកាន់គ្មានភស្តុតាងគ្រប់គ្រាន់។ *គ្មានអ្វីក្នុងវគ្គនេះនឹងត្រូវបានសិក្សាដើម្បីកែប្រែអំណាច របស់តុលាការក្រោមវគ្គ1385*។

(e) ការចោទប្រកាន់បទឧក្រិដ្ឋពីមុនដែល*ធ្ងន់ធ្ងរនិង/ឬហិង្សា*នឹង មិនត្រូវបានប្រើក្នុងការចរចាប្តូរចំឡើយជាមួយការសម្រាលទោសដូចបានកំណត់ក្នុងអនុផ្នែក (b)នៃវគ្គ1192.7.ការយកមកកាត់ទោសនឹងត្រូវបានជជែក និងបង្ហាញរាល់ការចោទប្រកាន់បទឧក្រិដ្ឋពីមុនដែល *ធ្ងន់ធ្ងរនិង/ឬហិង្សា* នឹងមិនចូលទៅក្នុងរាល់កិច្ចព្រមព្រៀងដើម្បីដាក់បន្ទុកឬស្វែងរកការអនុញ្ញាតឲ្យចេញនៃការចោទប្រកាន់គ្មានភស្តុតាងលើបទឧក្រិដ្ឋពីមុនដែល *ធ្ងន់ធ្ងរនិង/ឬហិង្សា*លើកលែងដូចបានផ្តល់ក្នុងកថាខណ្ឌ (2) នៃអនុផ្នែក (d)។

*(f) បើសិនខដែលមានចែងនៃអនុផ្នែក (a)ទៅ(e) រួមបញ្ចូល ឬ វគ្គ1170.126ឬពាក្យសុំនៃវគ្គនោះទៅកាន់រាល់បុគ្គលឬរាល់កាលៈទេសៈគឺត្រូវបានកាន់កាប់ទុកជាមោឃៈដែលមោឃកម្មនេះនឹងមិនមាន ឥទ្ធិពលទៅកាន់ ខដែលបែងចែកឬការស្នើសុំផ្សេងទៀតនៃអនុផ្នែក ទាំងនោះដែលអាចត្រូវបានផ្តល់ឥទ្ធិពលដោយគ្មានខដែលបានចែងដែលមោឃៈឬការស្នើសុំដែលមោឃៈនិងចុងបញ្ចប់នៃខដែលបាន ចែងនៃអនុផ្នែកទាំងនោះគឺដែលអាចកាត់ចេញបាន។*

*(g) ខដែលបានចែងនៃវគ្គនេះនឹងមិនត្រូវបានកែប្រែដោយអង្គនីតិបញ្ញត្តិលើកលែងដោយលក្ខន្តិកៈច្បាប់ដែលបានឆ្លងកាត់រាល់គ្រឹះ ស្ថាននីមួយៗដោយការបោះឆ្នោតដោយការកោះហៅឈ្មោះបានចូលទៅក្នុងទិន្នានុប្បវត្តិ ពីរភាគបីនៃការព្រមព្រៀងជាភាពសមាជិកឬ ដោយលក្ខន្តិកៈច្បាប់ ដែលមានប្រសិទ្ធិភាពពេលបានទទួលយល់ ព្រមដោយអ្នកបោះឆ្នោតប៉ុណ្ណោះ។*

វគ្គ5.វគ្គ1170.125នៃក្រមព្រហ្មទណ្ឌបានធ្វើវិសោធនកម្មឱ្យបកស្រាយ ថា ៖

1170.125. ថ្វីបើមានវគ្គទី2 នៃសំណើប្រជាមតិលេខ 184 ដូច បានសំរួលតាម នៅថ្ងៃទី 8 ខែវិច្ឆិកា ឆ្នាំ1994 ~~ការបោះឆ្នោតសកល~~ *ការបោះឆ្នោតសកល* សម្រាប់បទល្មើសទាំងអស់ដែលប្រព្រឹត្តនៅថ្ងៃ ឬបន្ទាប់ពី~~កាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ~~ *ថ្ងៃទី7 ខែវិច្ឆិកា ឆ្នាំ 2012* រាល់ឯកសារយោងដែលមានសម្រាប់លក្ខន្តិកៈដែលមានស្រាប់ ~~ក្នុងវគ្គ~~ វគ្គ 1170.12 និង 1170.126 គឺសំរាប់~~លក្ខន្តិកៈ~~ *វគ្គ* ទាំងនោះដូចដែលមានស្រាប់នៅ ~~កាលបរិច្ឆេទចូលជាធរមាននៃច្បាប់ នេះរួមទាំងការធ្វើវិសោធនកម្មទៅលើលក្ខន្តិកៈ ដោយច្បាប់បាន អនុម័តក្នុងអំឡុងសម័យប្រជុំ 2005-06 ដែលបានធ្វើការកែប្រែ លើវគ្គនេះ~~ *នៅថ្ងៃទី7 ខែវិច្ឆិកា ឆ្នាំ2012* ។

វគ្គទី 6. វគ្គ 1170.126 ត្រូវបានបន្ថែមលើក្រមព្រហ្មទណ្ឌឱ្យបកស្រាយ ថា៖

*1170.126. (a) ខចែងនៃការកាត់ទោសឡើងវិញនៅក្រោមវគ្គនេះ និងលក្ខន្តិកៈពាក់ព័ន្ធទាំងនេះ មានចេតនាប្រើដើម្បីអនុវត្តតែ ចំពោះបុគ្គលដែលជាប់ពន្ធនាគារថ្មីៗគ្មានពេលជាក់លាក់ដោយ អនុលោមតាមកថាខណ្ឌ(2) នៃអនុផ្នែក(e) នៃវគ្គ 667 ឬកថា ខណ្ឌ(2) នៃអនុផ្នែក(c) នៃវគ្គ 1170.12 ដែលការកាត់ទោសនៅ ក្រោមច្បាប់នេះ មិនអាចជាការកាត់ទោសដាក់គុកគ្មានពេលជាក់លាក់នោះទេ។*

*(b) បុគ្គលណាមួយដែលជាប់ពន្ធធានាគារគ្មានពេលជាក់លាក់ ដែលដាក់ទោសដោយអនុលោមតាមកថាខណ្ឌ(2) នៃអនុផ្នែក (e) នៃវគ្គ 667 ឬកថាខណ្ឌ(2) នៃអនុផ្នែក (c) នៃវគ្គ1170.12 អាស្រ័យលើការផ្តន្ទាទោសថាតើដោយសារការជំនុំជម្រះក្តី ឬការចរចាបស់ចុងចោទពីបទឧក្រិដ្ឋមួយឬបទឧក្រិដ្ឋដែលមិនបានកំណត់ថាធ្ងន់ធ្ងរ ហើយ/ឬបទឧក្រិដ្ឋ រំលោភបំពានតាមអនុផ្នែក(c) នៃវគ្គ 667.5 ឬអនុផ្នែក (c) នៃវគ្គ1192.7 អាចចងក្រងបណ្តឹងទាមទារ សម្រាប់រំលឹក ការកាត់ទោស ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទចូលជា ធរមាន នៃច្បាប់នេះ បានចុះបន្ថែមក្នុងវគ្គនេះឬនៅកាល បរិច្ឆេទក្រោយៗ អាស្រ័យលើការបង្ហាញបុព្វហេតុល្អណាមួយ ចំពោះមុខតុលាការជំនុំ ជម្រះក្តី ដែលឈានចូល ដល់ការសម្រេច ដាក់ទោសក្នុងករណីរបស់ខ្លួន ដើម្បីស្នើសុំឲ្យ កាត់ទោសឡើងវិញ ស្របតាមខចែងនៃអនុផ្នែក(e) នៃវគ្គ 667 ហើយនិងអនុផ្នែក (c) នៃវគ្គ1170.12 ដូចដែលលក្ខន្តិកៈទាំងនោះបានកែសម្រួល ដោយច្បាប់ និងបញ្ចូលបន្ថែមក្នុងវគ្គនេះ។*

*(c) គ្មានបុគ្គលណាដែលបច្ចុប្បន្នកំពុងជាប់ពន្ធធានាគារ សម្រាប់ ការកាត់ទោស "កំរិតទី 2" ដាក់កំរិតដោយអនុលោមតាមកថា ខណ្ឌ (1) នៃអនុផ្នែក(e) នៃវគ្គ 667 ឬកថាខណ្ឌ(1) នៃអនុ វគ្គ(c) នៃវគ្គ1170.12 ត្រូវតែមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការកាត់ទោសឡើងវិញនៅក្រោមខចែងនៃវគ្គនេះ។*

*(d) បណ្តឹងទាមទារការកោះហៅឲ្យមានការកាត់ទោសឡើងវិញ ដូចបានចែងក្នុងអនុផ្នែក(b) ត្រូវបញ្ជាក់នូវរាល់បទឧក្រិដ្ឋដែលបានចោទ ប្រកាន់បច្ចុប្បន្នទាំងអស់ ដែលជាលទ្ធផលពីការកាត់ទោសនៅក្រោម កថាខណ្ឌ(2) នៃអនុផ្នែក(e) នៃវគ្គ 1170.12 ឬទាំងពីរ ហើយត្រូវតែបញ្ជាក់ឲ្យច្បាស់ផងដែរពីផ្តន្ទាទោសដែលបានអះអាង និងផ្តល់ភស្តុតាងនៅក្រោមអនុផ្នែក (d) នៃវគ្គ 667 និងអនុផ្នែក (b) នៃវគ្គ 1170.12។*

*(e) អ្នកទោសមានសិទ្ធិឲ្យមានការកាត់ទោសឡើងវិញបើសិនជាៈ*

*(1) អ្នកទោសជាប់ពន្ធធានាគារគ្មានពេលជាក់លាក់ដោយ អនុលោមតាមកថាខណ្ឌ(2) នៃអនុផ្នែក (e) នៃវគ្គ 667 ឬ អនុផ្នែក(c) នៃវគ្គ 1170.12 សម្រាប់ការផ្តន្ទាទោសលើបទ ឧក្រិដ្ឋមួយឬច្រើន ដែលមិនបានកំណត់ថាធ្ងន់ធ្ងរ និង/ឬបទឧក្រិដ្ឋរំលោភបំពាន តាមអនុផ្នែក(c) នៃវគ្គ 667.5 ឬអនុផ្នែក (c) នៃវគ្គ1192.7។*

*(2) ការកាត់ទោសបច្ចុប្បន្នរបស់អ្នកទោស គឺមិនបានបង្ខំសម្រាប់ បទល្មើសណាមួយ ដែលមានបង្ហាញក្នុងអនុប្រយោគ(i) ដល់ (iii) រាប់បញ្ចូល នៃអនុកថាខណ្ឌ (C) នៃកថាខណ្ឌ(2) នៃអនុផ្នែក (e) នៃវគ្គ 667 ឬអនុប្រយោគ (i) ដល់ (iii) រាប់បញ្ចូល នៃអនុកថាខណ្ឌ(C) នៃកថាខណ្ឌ(2) នៃអនុផ្នែក (c) នៃវគ្គ1170.12។*

*(3) អ្នកទោសដែលគ្មានការផ្តន្ទាទោសពីមុន សម្រាប់បទល្មើសណាមួយដែលបង្ហាញក្នុងប្រការ(iv) នៃអនុកថាខណ្ឌ(C) នៃ កថាខណ្ឌ (2)នៃអនុផ្នែក (e) នៃវគ្គ 667 ឬអនុប្រយោគ (iv) នៃអនុកថាខណ្ឌ (C) នៃកថាខណ្ឌ(2) នៃអនុផ្នែក(c) នៃវគ្គ1170.12។*

*(f) ពេលទទួលបានពាក្យបណ្តឹងសំរាប់ការកោះហៅការកាត់ទោសឡើងវិញក្រោមវគ្គនេះ តុលាការត្រូវតែកំណត់ថាតើអ្នក ដាក់បណ្តឹងបំពេញតាមលក្ខណៈវិនិច្ឆ័យក្នុងអនុផ្នែក(e) ឬទេ។ បើសិនអ្នកដាក់បណ្តឹងទាមទារ បំពេញតាមលក្ខណៈវិនិច្ឆ័យ ក្នុងវគ្គរង(e) អ្នកដាក់បណ្តឹងទាមទារ ត្រូវតែបានកាត់ទោសឡើងវិញ ដោយអនុលោមតាមកថាខណ្ឌ(1) នៃអនុផ្នែក(e) នៃវគ្គ 667 និងកថាខណ្ឌ(1) នៃអនុផ្នែក(c) នៃវគ្គ1170.12 លុះត្រាតែតុលាការក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន មិនកំណត់ថាការ កាត់ទោសឡើងវិញ អ្នកដាក់បណ្តឹងនឹងបង្កហានិភ័យនៃគ្រោះថ្នាក់ ខ្ពស់មិនសមហេតុផលដល់សុវត្ថិភាពសាធារណៈ។*

*(g) ក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងអនុផ្នែក(f) តុលាការអាចនឹងពិចារណា ៖*

*(1) ប្រវត្តិជាប់ទោសឧក្រិដ្ឋរបស់អ្នកដាក់បណ្តឹង រួមទាំងប្រភេទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ទំហំនៃការបង្ករបួសដល់ជនរងគ្រោះ រយៈពេលនៃការជាប់ពន្ធនាគារពីមុន និងភាពដាច់ពីគ្នានៃបទឧក្រិដ្ឋ ៖*

*(2) កំណត់ត្រាវិន័យរបស់អ្នកដាក់បណ្តឹងទាមទារ និងកំណត់ត្រានៃការស្តារនីតិសម្បទា ក្នុងអំឡុងពេលដែលជាប់ឃុំ; និង*

*(3) ភស្តុតាងដទៃផ្សេងទៀត ដែលតុលាការក្នុងឆន្ទានុសិទ្ធិរបស់ ខ្លួនកំណត់ថាពាក់ព័ន្ធនឹងការសម្រេចចិត្ត ថាតើការកាត់ទោសថ្មី អាចមានលទ្ធផលក្នុងការបង្កហានិភ័យនៃគ្រោះថ្នាក់ដល់សុវត្ថិភាព សាធារណៈឬទេ។*

*(h) ទោះនៅក្រោមលក្ខខណ្ឌណាក៏ដោយ ការកាត់ទោសឡើងវិញនៅក្រោមច្បាប់នេះ មិនអាចមានលទ្ធផលក្នុងការបង្ខំឲ្យទទួល ទោសយូរជាង*

36

*ការកាត់ទោសដំបូងនោះទេ។*

*(i) ថ្វីបើអនុផ្នែក(b) នៃវគ្គ 977 ចុងចោទដាក់បណ្តឹងដើម្បីធ្វើ ការកាត់ទោសឡើងវិញ អាចសុំលើកលែងបង្ហាញមុខរបស់គាត់ក្នុងតុលាការសម្រាប់ការកាត់ទោសឡើងវិញ ប្រសិនបើសេចក្តី ថ្លែងអះអាង ដោយចោទប្រកាន់មិនត្រូវបានកែប្រែនៅពេល កាត់ទោសឡើងវិញ ហើយដែលថាការជំនុំជម្រះក្តីថ្មី ឬកាត់ក្តីម្តង ទៀតសម្រាប់បុគ្គលម្នាក់ នឹងមិនកើតមានទេ។ ការសុំលើកលែង បង្ហាញមុខត្រូវសរសេរជាលាយល័ក្ខអក្សរ ហើយចុះហត្ថលេខាដោយចុងចោទ។*

*(j) បើសិនជាតុលាការដែលបានកាត់ទោសចុងចោទតាំងពីដើម មិនអាចកាត់ទោសចុងចោទឡើងវិញ ប្រធានសវនាការត្រូវចាត់តាំងចៅក្រមមួយទៀត ដើម្បីជំនុំជម្រះបណ្តឹងរបស់ចុងចោទ។*

*(k) គ្មានអ្វីក្នុងវគ្គនេះមានចេតនាចង់បន្ថយឬច្រានចោលសិទ្ធិ ឬដំណោះស្រាយណាមួយ ដែលអាចមានចំពោះចុងចោទទេ។*

*(l) គ្មានអ្វីក្នុងវគ្គនេះនិងវគ្គដែលទាក់ទងមានចេតនាចង់បន្ថយ ឬច្រានចោលនូវសេចក្តីចុងក្រោយនៃការវិនិច្ឆ័យក្នុងករណីណាមួយ ដោយមិនគោរពតាមវង្វង់សមត្ថកិច្ចនៃច្បាប់នេះទេ។*

*(m) ការធ្វើសវនាការកាត់ទោសឡើងវិញចេញដីការ ក្រោមច្បាប់នេះត្រូវបង្កើត "ចំណាត់ការដោះលែងក្រោយពីកាត់ទោសរួច" ក្រោម កថាខណ្ឌ(7) នៃអនុផ្នែក(b) នៃវគ្គ២៨ នៃមាត្រា I នៃច្បាប់រដ្ឋ ធម្មនុញ្ញកាលីហ្វ័រញ៉ា (ច្បាប់របស់ Marsy)។*

*វគ្គ 7. ការស្ថាបនាសេរីភាព ៖*

*ច្បាប់នេះគឺជាការប្រើប្រាស់អំណាចសាធារណៈរបស់ប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ា សម្រាប់ការការពារសុខភាព សុវត្ថិភាព និងសុខមាលភាពនៃប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ា ហើយនិងត្រូវ អធិប្បាយយ៉ាងទូលំទូលាយ ដើម្បីអនុវត្តតាមគោលបំណងទាំងនេះ។*

*វគ្គ 8. ខបំរុង ៖*

*បើសិនជាខចែងណាមួយនៃច្បាប់នេះ ឬបណ្តឹងស្នើសុំរបស់បុគ្គល ឬល័ក្ខខ័ណ្ឌណាមួយ បានចាត់ទុកជាមោឃៈ ភាពជាមោឃៈនោះ នឹងមិនត្រូវមានឥទ្ធិពលលើខចែង ឬបណ្តឹងស្នើសុំដទៃផ្សេងទៀតនៃ ច្បាប់នេះឡើយ ដែលអាចចូលជាធរមានបាន ដោយមិនបាច់មានខ ចែង ឬពាក្យស្នើសុំដែលមោឃៈ ដើម្បីអនុវត្តតាមគោលបំណងនៃ ច្បាប់នេះ។ ចុងបញ្ចប់នេះ ខចែងនៃច្បាប់នេះគឺ អាចចាត់ទុកថាជាខបំរុង។*

*វគ្គទី 9. វិធានការដ៏ចំរូងចំរាស់៖*

*បើសិនជាវិធានការនេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ប៉ុន្តែត្រូវ បានជំនួសដោយវិធានការបោះឆ្នោតដ៏ចំរូងចំរាស់ផ្សេងទៀតដែល បានអនុម័តដោយអ្នកបោះឆ្នោតច្រើនជាង នៅក្នុងការបោះឆ្នោតដូច គ្នាហើយវិធានការបោះឆ្នោតដ៏ចំរូងចំរាស់នេះត្រូវបានចាត់ជាមោឃៈនាពេលក្រោយ នេះជា ចេតនារបស់អ្នកបោះឆ្នោតដែលថាច្បាប់នេះ ត្រូវបានផ្តល់អំណាចច្បាប់ទាំងស្រុង។*

*វគ្គ 10. កាលបរិច្ឆេទចូលជាធរមាន ៖*

*ច្បាប់នេះត្រូវចូលជាធរមាន នៅថ្ងៃទីមួយបន្ទាប់ពីបានការអនុម័តដោយអ្នកបោះឆ្នោត។*

*វគ្គ 11. ការធ្វើវិសោធនកម្ម ៖*

*លើកលែងតែដូចបានផ្តល់ក្នុងអត្ថបទនៃលក្ខន្តិកៈ បើមិនដូច្នោះទេ ខចែងក្នុងច្បាប់នេះមិនត្រូវផ្លាស់ប្តូរ ឬកែប្រែ លើកលែងតែដោយ លក្ខន្តិកៈ ដូចខាងក្រោម ៖*

*(a) តាមលក្ខន្តិកៈដែលបានអនុម័តនៅក្នុងសភានៃអង្គនីតិបញ្ញត្តិ ដោយការចុះបញ្ជីឈ្មោះបានបញ្ចូលក្នុងទិន្នានុប្បវត្តិដោយមាន សំលេងពីរភាគបីនៃសមាជិកភាព និងអភិបាលបានយល់ស្របតាម ឬ*

*(b) តាមលក្ខន្តិកៈដែលបានអនុម័តនៅក្នុងសភានៃអង្គនីតិ បញ្ញត្តិ ដោយការចុះបញ្ជីឈ្មោះបានបញ្ចូលក្នុងទិន្នានុប្បវត្តិ ដោយមានសំលេងភាគច្រើននៃសមាជិកភាពដែលបានយល់ ស្របតាម ដែលនឹងត្រូវដាក់នៅក្នុងសន្លឹកឆ្នោតសកលលើកក្រោយ និងត្រូវបានអនុម័តដោយសំលេងភាគច្រើននៃអ្នកបោះឆ្នោត ឬ*

*(c) តាមលក្ខន្តិកៈដែលចូលជាធរមាននៅពេលដែលបានអនុម័ត ដោយសំលេងភាគច្រើននៃអ្នកបោះឆ្នោត។*

## សំណើប្រជាមតិ 37

វិធានការផ្តើមប្រជាសិទ្ធិនេះគឺត្រូវបានដាក់ឲ្យប្រជាពលរដ្ឋដោយអនុលោមទៅតាម ខដែលមានចែងនៃមាត្រា II វគ្គទី 8 នៃរដ្ឋធម្មនុញ្ញ រដ្ឋកាលីហ្វ័រ ញ៉ា។

វិធានការការផ្តើមប្រជាសិទ្ធិនេះធ្វើវិសោធនកម្ម និងបន្ថែមវគ្គខ្លះទៅ លើក្រមស្តីពីសុខភាព និងសុវត្ថិភាព ដូចនេះខចែងថ្មីៗដែល បានស្នើដើម្បី បន្ថែមត្រូវបោះពុម្ពចេញជា *លក្ខណៈអក្សរទ្រេត* ដើម្បីបញ្ជាក់ថាខចែងទាំងនេះគឺថ្មី។

## ច្បាប់ដែលស្នើ

*ប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ាធ្វើការអនុម័តដូចខាងក្រោម ៖*

ច្បាប់ស្តីពីសិទ្ធិរបស់រដ្ឋកាលីហ្វ័រញ៉ាដើម្បីដឹងពីចំណីអាហារដែលធ្វើវិស្វកម្មពន្ធុ

វគ្គទី 1. ការរកឃើញ និងសេចក្តីប្រកាស

(a) អ្នកបរិភោគអាហារនៃរដ្ឋកាលីហ្វ័រញ៉ាមានសិទ្ធិដឹងថាតើអាហារដែលពួកគេទិញត្រូវបានផលិតដោយប្រើវិស្វកម្មពន្ធុ។ ការធ្វើវិស្វកម្មពន្ធុលើរុក្ខជាតិ និងសត្វ ជាញឹកញាប់បណ្តាលឲ្យមានផលប៉ះពាល់ ដែលមិនបានរំពឹងទុកជាច្រើន។ ការកែច្នៃសែន និងការចាក់បញ្ចូលវាទៅក្នុងសារពាង្គកាយគឺជាដំណើរការមិនច្បាស់លាស់។ លទ្ធផលគឺតែងតែមិនអាចទាយជាទុកមុនបាន ឬគ្រប់គ្រងបាន ហើយអាហារទាំងនេះអាចបណ្តាលឲ្យមានផប៉ះពាល់ដល់សុខភាព ឬបរិស្ថានយ៉ាងអាក្រក់។

(b) អ្នកវិទ្យាសាស្ត្ររបស់រដ្ឋាភិបាលបានបង្ហាញថាការដាក់បញ្ចូល DNA សិប្បនិម្មិតទៅក្នុងរុក្ខជាតិ ជាវិធីសាស្ត្រតែមួយចំពោះការធ្វើវិស្វកម្មពន្ធុ ដែលអាចបណ្តាលឲ្យមានបញ្ហាសំខាន់ៗជាច្រើនជាមួយម្ហូប អាហារដែលជា រុក្ខជាតិ។ ការធ្វើវិស្វកម្មពន្ធុបែបនោះ អាចបង្កើនកំរិតជាតិពុលដែលគេស្គាល់ក្នុងម្ហូបអាហារនិងនាំមកនូវជាតិពុលថ្មីនិងការព្រួយបារម្ភដល់សុខភាព។

(c) កំណត់សំគាល់ដ៏ចាំបាច់នៃម្ហូបអាហារ ដែលផលិតតាមរយៈការធ្វើវិស្វកម្មពន្ធុ អាចផ្តល់នូវវិធីសាស្ត្រដ៏សំខាន់សម្រាប់ការតាមដានផលប៉ះពាល់សុខភាពដែលមានសក្តានុពលខាងការទទួលទានម្ហូបអាហារធ្វើវិស្វកម្មពន្ធុ។

(d) គ្មានច្បាប់សហព័ន្ធ ឬច្បាប់រដ្ឋកាលីហ្វ័រញ៉ា ដែលតំរូវឲ្យអ្នកផលិតម្ហូបអាហារ បញ្ជាក់ថាតើម្ហូបដែលបានផលិតប្រើការធ្វើវិស្វកម្មពន្ធុឬទេ។ ទន្ទឹមនឹងនេះ រដ្ឋបាលគ្រប់គ្រងឱសថ និងម្ហូបអាហាររបស់សហរដ្ឋអាមេរិក មិនបានតំរូវឲ្យមានការសិក្សាពីសុវត្ថិភាពម្ហូបអាហារទាំងនោះទេ។ បើម្ហូបអាហារទាំងនោះ មិនមានសារជាតិ ដែលធ្វើឲ្យទាស់ដែលគេស្គាល់ទេ នោះ FDA មិនតំរូវឲ្យអ្នកដាំដំណាំ ធ្វើវិស្វកម្មពន្ធុ ពិភាក្សាជាមួយក្រុមភ្នាក់ងារនោះទេ។

(e) ការស្ទង់មតិបង្ហាញជាបន្តបន្ទាប់ថាសាធារណជនលើសពី 90 ភាគរយ ចង់ដឹងថាបើម្ហូបអាហាររបស់ពួកគេត្រូវបានផលិតដោយប្រើការធ្វើវិស្វកម្មពន្ធុឬទេ។

(f) ប្រទេសចំនួន 50 រួមមានរដ្ឋជាសមាជិកសហគមអឺរ៉ុប ប្រទេសជប៉ុន និងដៃគូជំនួញសំខាន់ៗរបស់សហរដ្ឋអាមេរិក មានច្បាប់ ឲ្យមានការបង្ហាញនូវអាហារធ្វើវិស្វកម្មពន្ធុ។ គ្មានកិច្ចព្រមព្រៀង អន្តរជាតិណាហាមឃាត់អត្តសញ្ញាណចាំបាច់នៃអាហារដែលផលិតតាមរយៈការធ្វើវិស្វកម្មពន្ធុនោះឡើយ។

(g) គ្មានការបិទផ្សាយ អ្នកបរិភោគអាហារធ្វើវិស្វកម្មពន្ធុ អាចបំពានលើការការដាក់កំហិតខាងទទួលទានអាហារនិង តាមសាសនារបស់ខ្លួនដោយមិនបានដឹងខ្លួន។

(h) ការប្រមូលផលដំណាំធ្វើវិស្វកម្មពន្ធុ ក៏អាចបង្កផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដល់បរិស្ថានផងដែរ។ ឧទាហរណ៍ ដំណាំធ្វើវិស្វកម្មពន្ធុភាគច្រើនត្រូវបានបង្កើតឡើងដើម្បីទប់ទល់នឹងថ្នាំសម្លាប់ស្មៅ ដែលគេស្គាល់ថាជា ថ្នាំសម្លាប់ស្មៅ។ ជាលទ្ធផល ថ្នាំសម្លាប់ស្មៅរាប់រយលានផោន ត្រូវបានប្រើក្នុងកសិដ្ឋានសហរដ្ឋអាមេរិក។ ពីព្រោះតែការប្រើប្រាស់ផលិតផលច្រើនបែបនោះ ស្មៅដែលអាចទ្រាំនឹងថ្នាំសម្លាប់ ស្មៅបាន បានលូតលាស់— ជាបញ្ហាមួយដែលធ្វើឲ្យមានការប្រើប្រាស់ថ្នាំសម្លាប់ស្មៅ ដែលមានជាតិពុលកាន់តែខ្លាំង។

ថ្នាំសម្លាប់ ស្មៅ ដែលមានជាតិពុលទាំងនេះ បំផ្លាញតំបន់កសិកម្មរបស់យើង ធ្វើឲ្យទឹកពិសាររបស់យើងខូច ហើយធ្វើឲ្យកម្មករកសិដ្ឋាន និងអ្នកបរិភោគមានគ្រោះថ្នាក់ដល់សុខភាព។ អ្នកបរិភោគក្នុងរដ្ឋកាលីហ្វ័រញ៉ា គួរតែមានជម្រើសដើម្បីជៀសវាងការទិញផលិតផលអាហារដែល អាចមានការប៉ះពាលបរិស្ថានបែបនោះ។

(i) ការធ្វើកសិដ្ឋានសរីរាង្គគឺជាវគ្គសំខាន់មួយនិងមានសារៈ សំខាន់កាន់តែខ្លាំងនៃវិស័យកសិកម្មរបស់រដ្ឋកាលីហ្វ័រញ៉ា។ រដ្ឋកាលីហ្វ័រញ៉ាមានដីដំណាំសរីរាង្គច្រើនជាងរដ្ឋផ្សេង ហើយមាន ស្ទើរតែមួយក្នុងបួននៃការអនុវត្តប្រតិបត្តិសរីរាង្គដោយមានការ ទទួលស្គាល់នៅក្នុងប្រទេស។ កសិកម្មសរីរាង្គរបស់រដ្ឋកាលីហ្វ័រញ៉ា កំពុងតែលូតលាស់ លើសពី20ភាគរយក្នុងមួយឆ្នាំ។

(j) កសិករសរីរាង្គត្រូវបានគេហាមឃាត់មិនឲ្យប្រើប្រាស់គ្រាប់ពូជធ្វើវិស្វកម្មពន្ធុ។ យ៉ាងណាក៏ដោយ ពូជដំណាំរបស់កសិករទាំងនេះជាទូទៅត្រូវទទួលការគំរាមកំហែង ដោយភាពកខ្វក់ ដោយចៃដន្យ ពីដីអ្នកជិតខាងដែលមានដំណាំធ្វើវិស្វកម្មពន្ធុច្រើន។ គ្រោះថ្នាក់ពីការបំពុលនេះ អាចបន្ថយទំនុកចិត្តសាធារណជនចំពោះផលិត ផលសរីរាង្គរបស់រដ្ឋកាលីហ្វ័រញ៉ា ធ្វើឲ្យចុះខ្សោយខាងវិស័យ ឧស្សាហកម្មនេះ។ អ្នករដ្ឋកាលីហ្វ័រញ៉ាគួរតែមានជំរើសដើម្បី ចៀសវាងការទិញម្ហូបអាហារដែលមានការផលិតអាចបង្កគ្រោះថ្នាក់ ដល់កសិករសរីរាង្គនិង ឧស្សាហកម្មម្ហូបអាហារសរីរាង្គនេះ។

(k) ការបិទផ្លាក ការផ្សាយពាណិជ្ជកម្ម និងការរកទីផ្សារនៃអាហារធ្វើវិស្វកម្មពន្ធុ ដោយប្រើពាក្យដូចជា "ធម្មជាតិ", "ត្រូវបានធ្វើតាមធម្មជាតិ", "លូតលាស់តាមធម្មជាតិ" ឬ "ធម្មជាតិទាំងអស់" គឺធ្វើឲ្យអ្នកបរិភោគរដ្ឋកាលីហ្វ័រញ៉ាយល់ខុស។

វគ្គ 2. សេចក្តីថ្លែងពីគោលបំណង

គោលបំណងនៃវិធានការនេះ គឺដើម្បីបង្កើតនិងពង្រឹងសិទ្ធិមូលដ្ឋានគ្រឹះរបស់ប្រជាពលរដ្ឋនៃរដ្ឋកាលីហ្វ័រញ៉ា ឲ្យបានជ្រាបទាំងស្រុងថាតើម្ហូបអាហារដែលខ្លួនទិញ និងបរិភោគជាម្ហូបអាហារធ្វើវិស្វកម្មពន្ធុ ហើយមិនបានដាក់ឈ្មោះខុសថាជាធម្មជាតិ ដូច្នោះពួកគាត់អាច ជ្រើសរើសដោយខ្លួនឯង ថាតើត្រូវទិញ និងបរិភោគអាហារបែបនោះ ឬទេ។ ច្បាប់នេះនឹងត្រូវបង្កើតឡើងដោយសេរីដើម្បីបំពេញតាមគោល បំណងនេះ។

វគ្គ 3. មាត្រា 6.6 (ចាប់ផ្តើមជាមួយនឹងវគ្គ110808) ត្រូវបានបន្ថែមទៅលើជំពូកទី5 នៃភាគទី5 នៃផ្នែក 104 របស់ក្រមស្តីពីសុខភាព និងសុវត្ថិភាពឱ្យបកស្រាយថា ៖

មាត្រា 6.6

*ច្បាប់ស្តីពីសិទ្ធិប្រចាំរដ្ឋកាលីហ្វ័រញ៉ាក្នុងការយល់ដឹងអំពីម្ហូបអាហារធ្វើវិស្វកម្មពន្ធុ*

*110808. និយមន័យ*

*និយមន័យខាងក្រោមត្រូវអនុវត្តតែសម្រាប់គោលបំណងនៃមាត្រានេះតែប៉ុណ្ណោះ៖*

*(a) ធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម។ ពាក្យថា "ធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្ម" សំដៅទៅលើការដាំដុះឬចិញ្ចឹមដោយបុគ្គលម្នាក់ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ឬអាជីវកម្មរបស់ខ្លួននិងលក់នៅ ក្នុងសហរដ្ឋ។*

*(b) អង់ស៊ីម។ ពាក្យថា "អង់ស៊ីម" សំដៅលើប្រូតេអ៊ីនដែលធ្វើជាកាតាលីករសម្រាប់ប្រតិកម្មគីមីនៃសារធាតុផ្សេងដោយមិនឲ្យមានការខូចខាត ឬការកែប្រែនៅពេលចប់ប្រតិកម្ម។*

*(c) ធ្វើវិស្វកម្មពន្ធុ។ (1) ពាក្យថា "ធ្វើវិស្វកម្មពន្ធុ" សំដៅទៅលើអាហារណាដែលផលិតចេញពីសរីរាង្គមួយ ឬសរីរាង្គច្រើនដែលសារធាតុសែ៊នត្រូវបានផ្លាស់ប្តូរតាមការអនុវត្តខាងក្រោម៖*

*(A) តាមបច្ចេកទេសអាស៊ីតនុយក្លេអ៊ិចនៃភាវរស ក្នុងនោះគិតទាំងបច្ចេកទេសអាស៊ីឌីអុកស៊ីបូនុយក្លេអ៊ិច(DNA) ផ្សំ និងការចាក់បញ្ចូលដោយផ្ទាល់នៃអាស៊ីតនុយក្លេអ៊ិចទៅក្នុងកោសិកា ឬសរីរាង្គតូច ឬ*

*(B) ការលាយកោសិកា រួមទាំងការបញ្ចូលប្រត្តូផ្លាស់ ឬបច្ចេកទេសបង្កាត់ពូជដើម្បីឈ្នះលើឧបសគ្គខាងសរីរសាស្ត្រ ការបន្តពូជឬការផ្សំឡើងវិញ ដែលកោសិកា ឬប្រូតូផ្លាស់របស់អ្នកបរិច្ចាគ មិនធ្លាក់ទៅក្នុងសណ្តានវិទ្យាសាស្ត្រដូចគ្នា តាមរបៀបដែលមិនកើតឡើងតាមទ្វេគុណបែបធម្មជាតិ ឬការផ្សំឡើងវិញតាមលក្ខណៈធម្មជាតិ។*

*(2) គោលបំណងនៃអនុផ្នែកនេះ ៖*

*(A) "សរីរាង្គ" មានន័យថាអង្គជីវសាស្ត្រណាដែលអាចបង្កើតជំនាន់ថ្មីបាន បន្តពូជបាន ឬអាចបញ្ជូនសារធាតុសែ៊នបាន។*

*(B) ពាក្យថា "តាមបច្ចេកទេសអាស៊ីតនុយក្លេអ៊ិចក្នុងភាវរស់" រួមមានប៉ុន្តែមិនកំណត់ត្រឹមតែ បច្ចេកទេសផ្សំ DNA ឬ RNA ដែលប្រើប្រព័ន្ធវិកទ័រ និងបច្ចេកទេសដែលមានដូចជាការដាក់បញ្ចូលទៅនឹងសរីរាង្គតពូជថ្មីផ្ទាល់ដែលបានរៀបចំពីខាងក្រៅសរីរាង្គដូចជាការចាក់បញ្ចូលក្នុងកម្រិតតិច ឬការចាក់បញ្ចូលក្នុងកម្រិតច្រើន ប្រតិបត្តិការគីមី ប្រតិបត្តិការអគ្គិសនី ការចាក់បញ្ចូលមីក្រូ អង់កាប់ស៊ុលកម្ម និងលីប៉ូសូម។*

*(d) អាហារកែច្នៃ។ ពាក្យថា "អាហារកែច្នៃ" សំដៅទៅលើអាហារទាំងឡាយណាក្រៅពីអាហារជាកសិផលធាតុដើម រួមមានដូចជាអាហារកំប៉ុងឆ្អើរ កែច្នៃ ចំអិនទុក បង្កក សំងួត ល្បើង ឬកិន។*

*(e) ជំនួយកែច្នៃ។ "ជំនួយកែច្នៃ" សំដៅលើ៖*

*(1) សារធាតុដែលបន្ថែមលើម្ហូបអាហារ ក្នុងពេលកែច្នៃដូចជាអាហារ តែបានដកចេញនូវសារធាតុខ្លះមុនពេលវេចខ្ចប់ក្នុងទំរង់ ចុងក្រោយ។*

*(2) សារធាតុដែលត្រូវបានបន្ថែមទៅលើអាហារពេលកំពុងកែច្នៃត្រូវបានបម្លែងទៅជាសារធាតុផ្សំ ដែលមានក្នុងអាហារហើយមិនបង្កើនច្រើននូវចំនួនសារធាតុផ្សំតាមធម្មជាតិក្នុងអាហារទេ ឬ*

*(3) សារធាតុដែលត្រូវបានបន្ថែមទៅក្នុងអាហារសម្រាប់បង្កើនអានុភាពបច្ចេកទេសឬសំខាន់នៅពេលកែច្នៃ តែវាមិនមាននៅក្នុងផលិតផលអាហារសម្រេចច្រើនទេ ហើយមិនមានអានុភាពបច្ចេកទេស ឬឥទ្ធិពលមុខងារសំខាន់ច្រើនទេនៅពេលអាហារផលិតរួច។*

*(f) កន្លែងផលិតអាហារ។ ពាក្យថា "កន្លែងផលិតអាហារ" គឺមានចែងនៅក្នុងវគ្គ 113789។*

*110809. ការបង្ហាញការគោរពចំពោះអាហារធ្វើវិស្វកម្មពន្ធុ។*

*(a) តាំងពីថ្ងៃទី1 ខែកក្កដា ឆ្នាំ 2014 ទៅ អាហារទាំងឡាយណាដែលផ្តល់សម្រាប់លក់រាយនៅកាលីហ្វ័រញ៉ាដែលដាក់ស្លាកសញ្ញាមិនត្រឹមត្រូវ ដែលត្រូវបានផលិតមួយវគ្គឬទាំងស្រុងដោយ ធ្វើវិស្វកម្មពន្ធុហើយមិនត្រូវបានបើកបង្ហាញ៖*

*(1) នៅក្នុងករណីដែលអាហារកសិផលដើមមានស្លាកសញ្ញានិង លក់រាយ ដោយលើកញ្ចប់នោះមានពាក្យច្បាស់ឬចែងថា" ធ្វើវិស្វកម្មពន្ធុ" នៅខាងមុខកញ្ចប់នៃផលិតផលនោះ ឬនៅក្នុងករណីដែលផលិតផលនោះ មិនត្រូវបានដាក់នៅក្នុងកញ្ចប់ឬដាក់ស្លាក នៅលើស្លាកមានលេចឡើងនៅកន្លែងលក់រាយ ឬក្នុងធុងដែលសារធាតុទាំងនោះត្រូវបានដាក់តាំងសម្រាប់លក់។*

*(2) នៅក្នុងករណីដែលអាហារកែច្នៃ ប្រើពាក្យច្បាស់លាស់ ហើយលេចជ្រងោ ឬចែងនៅខាងមុខឬខាងក្រោយនៃកញ្ចប់នៃអាហារនោះ ដោយប្រើពាក្យថា " ផលិតដោយប្រើ វិស្វកម្មពន្ធុភាគខ្លះ " ឬ "អាចផលិតដោយបានធ្វើវិស្វកម្មពន្ធុភាគខ្លះ។"*

*(b) អនុផ្នែក (a) នៃវគ្គនិងអនុផ្នែក (e) នៃវគ្គ 110809.2 មិនត្រូវចាត់ទុកថាជាការចាំបាច់សម្រាប់ចុះបញ្ជី ឬការកំណត់អត្តសញ្ញាណនៃគ្រឿងផ្សំ ឬគ្រឿងផ្សំទាំងឡាយដែលត្រូវបានធ្វើវិស្វកម្មពន្ធុ ឬមានប្រើពាក្យ "ធ្វើវិស្វកម្មពន្ធុ" ត្រូវបានដាក់នៅខាងមុខឈ្មោះទូទៅ ឬព័ត៌មានបរិយាយនៃផលិតផលនៃអាហារ។*

*110809.1. ការដាក់សញ្ញាមិនត្រឹមត្រូវនៃអាហារវិស្វកម្មពន្ធុថាជា "ធម្មជាតិ"*

*ក្រៅពីការចាំបាច់ឲ្យបង្ហាញដូចមានកំណត់នៅក្នុងវគ្គ 110809 ប្រសិនបើអាហារឆ្លើយតបទៅនឹងនិយមន័យនៅក្នុងអនុផ្នែក (c) ឬ (d) នៃវគ្គ 110808 ហើយមិនទទួលបានការលើកលែងពីការដាក់ស្លាកតាមវគ្គ 110809.2 អាហារដែលមិននៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា លើស្លាក អមដោយស្លាកសញ្ញានៅកន្លែងលក់រាយ ឬក្នុងសម្ភារផ្សាយពាណិជ្ជកម្ម ឬឃោសនាដែលចែងឬបង្កប់ន័យថាអាហារគឺ "ធម្មជាតិ" "ផលិតដោយធម្មជាតិ" "ដាំតាមបែបធម្មជាតិ" "ធម្មជាតិទាំងស្រុង" ឬមានពាក្យណាដែលបង្កប់ន័យដូច្នេះ ក្នុងគោលបំណងបំភ័ន្តអតិថិជន។*

37

*110809.2. ការដាក់សញ្ញាមិនត្រឹមត្រូវនៃអាហារវិស្វកម្មពន្ធ-- ការលើកលែងលក្ខខណ្ឌតំរូវនៃវគ្គ 110809 មិនត្រូវអនុវត្តចំពោះចំណុចខាងក្រោមទេ៖*

*(a) អាហារដែលចម្រាញ់ទាំងស្រុង ឬមួយវគ្គចេញពីសត្វដែលមិនបានកែប្រែសេនេទិក ទោះជាសត្វត្រូវបានចិញ្ចឹមឬចាក់បញ្ចូលអាហារស្វកម្មពន្ធុ ឬថ្នាំទាំងឡាយដែលបានផលិតតាមរបៀបវិស្វកម្មពន្ធុ។*

*(b) សារធាតុដើមកសិផលឬអាហារដែលបានចម្រាញ់ចេញពីសត្វក្នុងទម្រង់ដាំ ចិញ្ចឹម ឬផលិតដោយមិនបានដឹង ហើយមានគោលបំណងប្រើសម្រាប់គ្រាប់ពូជឬអាហារដែលបានធ្វើវិស្វកម្មពន្ធ។ អាហារនឹងត្រូវចាត់ទុកថាស្ថិតនៅក្នុងស្ថានភាពពីមុនតែក្នុងករណីដែលអ្នកទទួលខុសត្រូវក្នុងការអនុវត្តតាមតំរូវការនៃវគ្គរងនេះ (a) នៃវគ្គ 110809 ជាមួយនឹងការគោរពចំពោះសារធាតុដើមនៃកសិផល ឬអាហារដែលបានទទួលពីអ្នកលក់ទៅដល់ជននោះ ហើយបានសន្យាអំពីគុណភាពនៃផលិតផលនោះ ឬអាហារនោះ៖ (1) ដោយខ្លួនបានដឹងច្បាស់និងមានចេតនាធ្វើវិស្វកម្មពន្ធ ហើយ (2) បានបំបែកពី ហើយមិនបានដឹងនិងមិនមានចេតនាផ្សំចូលគ្នាជាមួយអាហារដែលអាចធ្វើវិស្វកម្មពន្ធទាល់តែសោះ។ ក្នុងការផ្តល់ការសន្យាបែបនោះ អ្នកដែលជឿលើការសន្យារបស់អ្នកផ្តល់ទំនិញមកខ្លួន ដែលមានចែងច្បាស់លាស់។*

*(c) រាល់អាហារកែច្នៃត្រូវស្ថិតនៅក្រោមវគ្គ 110809 តែមួយមុខ ព្រោះវាមានសារធាតុបន្ថែម ឬអង់ស៊ីមអាហារធ្វើវិស្វកម្មពន្ធមួយឬច្រើន។*

*(d) ភេសជ្ជៈមានជាតិអាល់កុលដែលគឺស្ថិតនៅក្រោមច្បាប់គ្រប់គ្រងភេសជ្ជៈមានជាតិអាល់កុល ដូចមានកំណត់នៅក្នុងវគ្គទី 9 (ចាប់ផ្តើមពីវគ្គ 23000) នៃក្រមអាជីវកម្មនិងវិជ្ជាជីវៈ។*

*(e) រហូតមកដល់ថ្ងៃទី1 ខែកក្កដា ឆ្នាំ 2019 រាល់អាហារកែច្នៃនឹងត្រូវស្ថិតនៅក្រោមវគ្គ 110809 តែមួយ ព្រោះវាមានសារធាតុបន្ថែមមួយឬច្រើនដែលធ្វើវិស្វកម្មពន្ធដែល៖ (1) មិនមានសារធាតុតែមួយមុខសម្រាប់កន្លះភាគរយនៃទម្ងន់សរុបនៃអាហារកែច្នៃនោះ និង (2) អាហារកែច្នៃមិនមានគ្រឿងផ្សំនោះច្រើនជាង 10 មុខ។*

*(f) អាហារដែលអង្គការឯករាជ្យបានកំណត់ថាមិនបានដឹងឬមិនមានចេតនាផលិតតាមរបៀបធ្វើវិស្វកម្មពន្ធពីគ្រាប់ពូជឬធ្វើវិស្វកម្មពន្ធអាហារឡើយ ឲ្យតែការកំណត់នោះត្រូវបានធ្វើឡើងដោយមានការយកវត្ថុវិភាគនិងធ្វើតេស្តតាមទម្រង់ការបានកំណត់ត្រឹមត្រូវដោយច្បាប់របស់ក្រសួង។ មិនមានវត្ថុវិភាគឬទម្រង់ការណាមួយត្រូវបានអនុម័តដោយក្រសួងទេ លើកលែងតែការជ្រើសរើសវិភាគត្រូវបានធ្វើដោយត្រឹមត្រូវ ទៅតាមផែនការគំរូត្រឹមត្រូវតាមវិធានស្ថិតិ តាមគោលការណ៍ទទួលស្គាល់ជាអន្តរជាតិដូចជាអង្គការស្តង់ដារអន្តរជាតិ (ISO) និងសមគមពាណិជ្ជកម្មគ្រាប់ធញ្ញជាតិនិងអាហារ (GAFTA)។ ការធ្វើតេស្តមិនត្រូវបានអនុម័តដោយនាយកដ្ឋានឡើងលើកលែងតែ៖ (1) វាស្របទៅតាម "គោលការណ៍ណែនាំស្តីពីលក្ខណៈវិនិច្ឆ័យនិងការផ្ទៀតផ្ទាត់លើវិធីសាស្ត្រសម្រាប់រក កំណត់ និងចំនួននៃលំដាប់ DNA ជាក់លាក់និងប្រូតេអ៊ីនជាក់លាក់នៅក្នុងអាហារ" (CAC/GL 74 (2010)) ដែលបានចេញផ្សាយចុងក្រោយបំផុតដោយគណៈកម្មការ Codex Alimentarius និង (2) វាមិនពឹងផ្អែកតែលើការធ្វើតេស្តលើអាហារកែច្នៃដែលមិនអាចរក DNA បាន។*

*(g) អាហារដែលច្បាប់បានបញ្ជាក់ត្រឹមត្រូវនិងដាក់ស្លាកត្រឹមត្រូវធ្វើទីផ្សារដាក់លក់ជាសារធាតុសរីរាង្គ " ស្របតាមច្បាប់ផលិតផលអាហារសរីរាង្គសហព័ន្ធឆ្នាំ 1990 និងបទបញ្ញត្តិដែលបានប្រកាសឲ្យប្រើប្រាស់ស្របទៅតាមក្រសួងកសិកម្មរបស់សហរដ្ឋ។*

*(h) Fអាហារដែលមិនត្រូវបានវេចខ្ចប់សម្រាប់លក់រាយនិងដែល ៖*

*(1) ត្រូវបានកែច្នៃនិងរៀបចំសម្រាប់ប្រើបន្ទាន់របស់មនុស្សឬ (2) ត្រូវបានបម្រើ លក់ ឬផ្តល់នៅតាមភោជនីយដ្ឋានឬកន្លែងលក់ម្ហូបផ្សេងទៀតដែលជាប់ពាក់ព័ន្ធក្នុងការលក់ម្ហូបដែលរៀបចំនិងមាន បំណងសម្រាប់តែការប្រើប្រាស់បន្ទាន់របស់មនុស្ស។*

*(i) អាហារជាឱសថ។*

*110809.3. ការអនុម័តនៃបញ្ញត្តិ*

*ក្រសួងអាចនឹងសំរបតាមបទបញ្ញត្តិណាមួយដែលកំណត់ថាចាំបាច់សម្រាប់ការពង្រឹងនិងបកស្រាយមាត្រានេះ ឲ្យតែក្រសួងនោះមិនត្រូវបានអនុញ្ញាតិឲ្យបង្កើតការលើកលែងណាមួយ លើសពីការកំណត់នៅក្នុងវគ្គ 110809.2។*

*110809.4. ការពង្រឹងច្បាប់*

*បន្ថែមលើសកម្មភាពផ្សេងទៀតនៅក្រោមមាត្រា4 (ចាប់ផ្តើមជាមួយនឹងវគ្គ 111900) នៃជំពូក 8 រាល់ការល្មើសលើវគ្គ110809 ឬ 110809.1 នឹងចាត់ទុកជាការល្មើសលើកថាខណ្ឌទី (5) នៃអនុផ្នែក(a) នៃវគ្គ 1770 នៃក្រមរដ្ឋប្បវេណី ហើយអាចទទួលទោស ពីក្រោយចំណងជើអ 1.5 (ចាប់ផ្តើមជាមួយនឹងវគ្គ 1750) នៃភាគ 4 នៃផ្នែក 3 នៃក្រមរដ្ឋប្បវេណី លើកលែងតែអ្នកប្រើប្រាស់មិនចាត់ទុកជាការខូចខាតជាក់លាក់ ឬអះអាងថាមិនពឹងផ្អែកលើសារធាតុនោះ ប្រឆាំងនឹងការចោទថាល្មើស។ បរាជ័យក្នុងការបង្ហាញតាមការកំណត់ដោយវគ្គ 110809 ឬការធ្វើអំណះអំណាងដែលបានហាមឃាត់ដោយក្រសួងតាមវគ្គ 110809.1 នឹងត្រូវចាត់ទុកថាបណ្តាលឲ្យមានសារធាតុយ៉ាងតិចស្មើនឹងចំនួនជាក់លាក់ឬចំនួនដែលបានផ្តល់នៅក្នុងការលក់រាយនៃកញ្ចប់ ឬ ផលិតផលនីមួយៗដែលត្រូវបានចោទថាមានការល្មើស។*

វគ្គទី 4. ការពង្រឹងច្បាប់

វគ្គទី111910 នៃក្រមសុខភាពនិងសុវត្ថិភាពត្រូវបានកែប្រែដើម្បី ចែងថា៖

111910. (a) ទោះយ៉ាងណា ខចែងនៃវគ្គ 111900 ឬខចែង នៃច្បាប់ផ្សេងៗដទៃណាមួយ បុគ្គលណាមួយអាចនាំយកនូវវិធានការ ខាងតុលាការជាន់ខ្ពស់ស្របតាមវគ្គនេះ ហើយតុលាការគួរមាន យុត្តាធិការលើសវនាការនិងសំរាប់បុព្វហេតុដែលបានបង្ហាញ ដើម្បី ផ្តល់ឲ្យនូវសេចក្តីបង្គាប់ជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍ ដែលដាក់ កំរិតបុគ្គលណាមួយពីការរំលោភលើខចែងណានៃ*មាត្រា 6.6 (ចាប់ ផ្តើមជាមួយនឹងវគ្គ 110808) ឬ* មាត្រា 7 (ចាប់ផ្តើមជាមួយនឹងវគ្គ 110810) នៃជំពូក 5។ នីតិវិធីណានៅក្រោមវគ្គនេះគួរអនុលោម ទៅតាមតំរូវការនៃជំពូក 3 (ចាប់ផ្តើមជាមួយនឹងវគ្គ 525) នៃចំណងជើងទី 7 នៃវគ្គទី 2 របស់ក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែថា បុគ្គលនោះនឹងមិនតំរូវឲ្យចោទប្រកាន់ការពិត ចាំបាច់ត្រូវបង្ហាញនូវ ឬមានបំណងបង្ហាញនូវកង្វះខាតមធ្យោបាយ ដោះស្រាយ គ្រប់គ្រាន់តាមច្បាប់ ឬដើម្បីបង្ហាញឬមានបំណងបង្ហាញនូវការបំផ្លិចបំផ្លាញ ឬការខាតបង់ដែលមិនអាចជំនួសមកវិញបាន ឬដើម្បីបង្ហាញ ឬមានបំណងបង្ហាញនូវ ការរងរបួស ឬការបំផ្លិចបំផ្លាញជាលក្ខណៈ បុគ្គលពិសេស ឬមានតែមួយ។

(b) បន្ថែមទៅលើការធូរស្រាលដែលជាបញ្ហាដែលត្រូវបានផ្តល់ឱ្យនៅក្នុង វគ្គ (a) តុលាការអាចផ្តល់រង្វាន់ដល់បុគ្គល អង្គការ ឬ អង្គភាពនូវថ្លៃមេធាវីដ៏សមរម្យ និង*តម្លៃសមហេតុ ផលទាំងអស់ដែលបានជួបប្រទះក្នុងការស៊ើបអង្កេតនិងការកាត់ ទោសលើសកម្មភាពនេះដូចដែលត្រូវ*បានកំណត់ដោយតុលាការ។

(c) វគ្គនេះនឹងមិនត្រូវបានបកស្រាយដើម្បីកម្រិត ឬ ជំនួសនូវអំណាច នានារបស់នាយកដ្ឋាន និងភ្នាក់ងារដែលមានធរមានរបស់ខ្លួន ដើម្បីនាំមកនូវវិធានការដើម្បីអនុវត្តជំពូកនេះ ដោយយោងតាមវគ្គ 111900 ឬបញ្ញាត្តិដទៃណាមួយនៃច្បាប់នេះឡើយ។

វគ្គទី 5 ការដាក់ឈ្មោះម៉ាកខុស

វគ្គ 110663 ត្រូវបានដាក់បន្ថែមទៅលើក្រមសុវត្ថិភាព និងសុខភាព ដែលបានចែងថា:

*110663. រាល់ម្ហូបអាហារទាំងឡាយណាដែលបានដាក់ ឈ្មោះខុស ប្រសិនបើការដាក់ឈ្មោះរបស់ខ្លួនមិនស្របតាម តំរូវការនៃវគ្គ 110809 ឬ 110809.1។*

វគ្គទី 6 ខបំរុង

ប្រសិនបើខចែងណាមួយនៃការផ្តើមប្រជាសិទ្ធិនេះ ឬទម្រប់បែបបទនេះគឺសម្រាប់ហេតុផលណាមួយត្រូវបានចាត់ទុកជាមោឃៈ ឬដែលផ្ទុយពីរដ្ឋធម្មនុញ្ញ ដែលនឹងមិនជះឥទ្ធិពលដល់ខចែង ឬបែបបទដទៃនៃការផ្តើមប្រជាសិទ្ធិដែលអាចត្រូវបានផ្តល់ផលប៉ះ ពាល់ដោយមិនមានខចែង ឬបែបបទដែលជាមោឃៈ ឬផ្ទុយពីរដ្ឋ ធម្មនុញ្ញនេះ និងទៅកាន់សេចក្តីបញ្ចប់នៃខចែងនានានៃការផ្តើមប្រជាសិទ្ធិនេះ អាចចាត់ទុកជាខបំរុងបាន។

វគ្គទី 7 ការកសាងជាមួយច្បាប់ផ្សេងទៀត

ការផ្តើមប្រជាសិទ្ធិនេះនឹងត្រូវបានបកស្រាយដើម្បីបន្ថែម មិនមែន ដើម្បីជំនួស លើតំរូវការនៃសហព័ន្ធ ឬច្បាប់រដ្ឋកាលីហ្វ័រញ៉ា ឬ បទបញ្ញាណាមួយ

ដែលផ្តល់ឱ្យសម្រាប់ការកម្រិតតិច ឬការដាក់ ឈ្មោះលើរបស់ប្រើប្រាស់ជាវត្ថុធាតុដើមកសិកម្មណាមួយពេញលេញតិច ឬម្ហូបដែលផលិតស្រាប់ដែលអាចប្រឈមនឹងខចែងនានានៃការផ្តើមប្រជាសិទ្ធិ។

វគ្គទី 8 កាលបរិច្ឆេទជាធរមាន

ការផ្តើមប្រជាសិទ្ធិនេះនឹងត្រូវមានប្រសិទ្ធិភាពលើការប្រកាសច្បាប់ ដោយយោងតាមចំណុច(a)នៃវគ្គទី 10នៃមាត្រា IIរបស់រដ្ឋធម្មនុញ្ញរដ្ឋកាលី ហ្វ័រញ៉ា ។

វគ្គទី 9. វិធានការខ្វែងគំនិតគ្នា

ក្នុងព្រឹត្តការណ៍ដែល វិធានការមួយផ្សេង ឬវិធានការនានាដែលកើតមាននៅក្នុងការបោះឆ្នោតទូទាំងរដ្ឋតែមួយដាក់នូវ តំរូវការបន្ថែមចំពោះការផលិត ការលក់ និង/ឬការដាក់ឈ្មោះ នៃម្ហូបអាហារដែលបានផលិតឡើងដោយធ្វើវិស្វកម្មពន្ធ បន្ទាប់មក ខចែងនានានៃវិធានការដទៃទៀតឬវិធានការនានា ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោត នឹងត្រូវបានដាក់បន្ស៊ីជាមួយខចែងនានានៃច្បាប់នេះ ប្រសិនបើខចែងនានានៃវិធានការដទៃមិនបានហាម បារមឬមិនបានផ្តល់នូវហេតុផលពីការប្រព្រឹត្តតាម តំរូវការនានារបស់ច្បាប់ នេះ ។

ក្នុងករណីដែលខចែងនានានៃវិធានការដទៃទាំងនេះហាមបាម្រឬផ្តល់នូវហេតុផលពីការប្រព្រឹត្តតាមខចែងនានានៃច្បាប់ នេះ ហើយច្បាប់នេះទទួលបាននូវចំនួនសម្លេងឆ្នោតគាំទ្រកាន់តែច្រើន នោះខចែងនានានៃច្បាប់នេះនឹងឈ្នះលើសារព័ន្ធ របស់ពួកគេ ហើយវិធានការដទៃនឹងចាត់ត្រូវទុកជាមោឃៈ និងនិរាករ។

វគ្គទី 10. វិសោធនកម្ម

ការផ្តើមប្រជាសិទ្ធិនេះអាចត្រូវបានកែសម្រួលដោយអង្គនីតិបញ្ញត្តិ ប៉ុន្តែសម្រាប់តែបន្ថែមនូវចេតនា និងបំណងរបស់ខ្លួនប៉ុណ្ណោះ ដោយច្បាប់ដោយសម្លេងឆ្នោតពីរភាគបីក្នុងមណ្ឌលនីមួយៗ ។

## សំណើប្រជាមតិ 38

វិធានការផ្តើមប្រជាសិទ្ធិនេះគឺត្រូវបានដាក់ឲ្យប្រជាពលរដ្ឋដោយអនុលោមទៅតាមខដែលមានចែងក្នុងវគ្គទី 8នៃមាត្រា IIនៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រ ញ៉ា។

វិធានការផ្តើមប្រជាសិទ្ធិនេះកែប្រែនិងបន្ថែមវគ្គខ្លះទៅលើក្រមអប់រំ ក្រមព្រហ្មទណ្ឌ និងក្រមប្រាក់ចំណូល និងពន្ធអាករ។ ដូចនេះខចែង មានស្រាប់ដែលបានស្នើឡើងដើម្បីលុបចោល ត្រូវបោះពុម្ពចេញជា~~លក្ខណៈឆ្នូតលុបកាត់~~ ហើយ ខចែងថ្មីដែលបានស្នើឡើងដើម្បីបន្ថែមត្រូវបោះពុម្ពចេញជា*លក្ខណៈអក្សរទ្រេត* ដើម្បីបញ្ជាក់ថាវាថ្មី។

## ច្បាប់ដែលស្នើ

កូនៗរបស់យើង អនាគតរបស់យើង ៖ ច្បាប់ស្តីពីការវិនិយោគ លើការអប់រំវ័យដំបូង និងសាលារៀនក្នុងតំបន់និងការកាត់បន្ថយប័ណ្ណបំណុល

វគ្គទី 1: ចំណងជើង

វិធានការប្រជានុម័តិនេះនឹងត្រូវបានគេស្គាល់ថា ហើយអាចត្រូវបាន គេដាក់អំណៈ អំណាងថា "កូនៗរបស់យើង អនាគតរបស់យើង ៖ ច្បាប់ស្តីពីការវិនិយោគ លើការអប់រំវ័យដំបូង និងសាលារៀនក្នុងតំបន់ និងការកាត់បន្ថយប័ណ្ណបំណុល។"

វគ្គទី 2: លទ្ធផលដែលរកឃើញ និងសេចក្តីប្រកាសអំពីគោលបំណង។

(a) រដ្ឋកាលីហ្វ័រញ៉ាកំពុងតែធ្វើមិនសមរម្យលើអនាគតកូនៗ របស់យើង និងរដ្ឋរបស់យើង។ បច្ចុប្បន្ននេះ រដ្ឋរបស់យើងស្ថិតក្នុងលំដាប់ ជាតិ ទី 46 លើអ្វីដែលយើងវិនិយោគដើម្បីអប់រំសិស្សម្នាក់ៗ។ រដ្ឋកាលីហ្វ័រញ៉ាក៏ស្ថិតក្នុងលំដាប់ចុងក្រោយបង្អស់ គឺទី 50 ក្នុង ចំណោម 50 រដ្ឋដែលមានទំហំថ្នាក់រៀនធំជាងគេបំផុតក្នុងប្រទេស។

(b) ការកាត់បន្ថយថវិកាថ្មីៗនេះ កំពុងតែដាក់សាលារៀនរបស់យើងកាន់តែដាច់ឆ្ងាយជាងមុន ។ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ ទឹកប្រាក់ច្រើនជាង 20 ពាន់លានដុល្លារ ត្រូវបានគេកាត់បន្ថយចេញពី សាលារៀនរដ្ឋកាលីហ្វ័រញ៉ា ។ កម្មវិធី និងសេវាចាំបាច់ ដែលសិស្ស ទាំងអស់ត្រូវការដើម្បីទទួលបានជោគជ័យ ត្រូវបានលុបចោល ឬកាត់បន្ថយ ។ ហើយអ្នកអប់រំលើសពី 40,000 នាក់ត្រូវបានបញ្ឈប់ ពីការងារ។

(c) យើងកំពុងទទួលបរាជ័យផងដែរជាមួយនឹងកម្មវិធីអភិវឌ្ឍកុមារវ័យដំបូង ដែលការសិក្សាជាច្រើនបញ្ជាក់ថាជាកម្មវិធីមួយ ក្នុងចំណោមការវិនិយោគលើការអប់រំដ៏ល្អបំផុតនានាដែលយើងអាច ធ្វើបាន។ កម្មវិធីសាលាមត្តេយ្យសាធារណៈដែលមានមូលនិធិស្ទើរ របស់យើង បម្រើត្រឹមតែ 40 ភាគរយនៃកុមារដែលមានអាយុបី និងបួនឆ្នាំ ដែលមានលក្ខណៈគ្រប់គ្រាន់ប៉ុណ្ណោះ។ ត្រឹមតែ 5 ភាគ រយប៉ុណ្ណោះនៃទារក និងកូនក្មេងដែលមានប្រាក់ចំណូលទាបខ្លាំង ដែលត្រូវការការគាំទ្របំផុត បានទទួលនូវកម្មវិធីកុមារវ័យដំបូងទាំងនេះ។

(d) យើងអាច និងត្រូវតែធ្វើវាឱ្យបានប្រសើរជាមុន។ ក្មេងៗគឺជា អនាគតរបស់យើង។ ការវិនិយោគក្នុងសាលារៀន និងកម្មវិធីកុមារ ភាពដំបូងរបស់យើង ដើម្បីរៀបចំកុមារឱ្យទទួលបានជោគជ័យគឺជារឿងដ៏ល្អបំផុតមួយដែលយើងអាចធ្វើសម្រាប់ក្មេងៗរបស់យើង និងអនាគតសេដ្ឋកិច្ចរបស់យើង និងរដ្ឋរបស់យើង ។ មិនមានការអប់ រំប្រកបដោយគុណភាពទេនោះ កូនៗរបស់យើងនឹងមិនអាចប្រកួតប្រជែងក្នុងសេដ្ឋកិច្ចជាសកលបាននោះទេ។ មិនមានកម្លាំងការងារ ប្រកបដោយជំនាញទេនោះ រដ្ឋរបស់យើង នឹងមិនអាចប្រកួតប្រជែង ដើម្បីការងារនានាបានទេ។ យើងត្រូវតែផ្តល់ថវិការសម្រាប់កូនៗរបស់យើង និងសម្រាប់ខ្លួនយើងផ្ទាល់ ដើម្បីលើកកម្ពស់ការអប់រំ របស់កូនៗរបស់យើង។

(e) វាគឺជាពេលដែលត្រូវធ្វើការផ្លាស់ប្តូរឱ្យពិតប្រាកដមួយៈ មិន មែនជាវិធានការសម្រេចបានពាក់កណ្តាលទេ ប៉ុន្តែពិតប្រាកដ ការវិនិយោគដែលផ្លាស់ប្តូររូបរាងក្នុងសាលារៀននានា ដែលអនាគតរដ្ឋ របស់យើង និងក្រុមគ្រួសារយើងពឹងផ្អែកលើ។ ច្បាប់នេះនឹង អនុញ្ញាតឱ្យសាលារៀននានាអាចផ្តល់នូវការអប់រំដ៏ល្អមួយ ដែលគាំទ្រដល់មហាវិទ្យាល័យ និងការត្រៀមលក្ខណៈការងារ សម្រាប់សិស្សគ្រប់គ្នា ដែលរួមមាន កម្មវិធីសិក្សាប្រកបដោយគុណភាពខ្ពស់នៃមុខវិជ្ជាសិល្បៈ តន្ត្រី ការអប់រំរាយកាយ វិទ្យាសាស្ត្រ បច្ចេកទេសវិស្វករ គណិតវិទ្យា និងមុខវិជ្ជាអប់រំខាងបណ្តុះបណ្តាលនិងបច្ចេកទេស ទំហំថ្នាក់រៀន បណ្ណាល័យសាលាកាន់តែតូចជាងមុន គិលានុបដ្ឋាកសាលា និងក្រុមប្រឹក្សាយោបល់កាន់តែតិចជាងមុន។

(f) ច្បាប់នេះនឹងតំរូវថា កាសម្រេចចិត្តអំពីរបៀបប្រើប្រាស់មូលនិធីថ្មីដ៏ល្អបំផុត ដើម្បីលើកកម្ពស់សាលារៀនរបស់យើង ត្រូវតែបាន បង្កើតឡើងមិនមែននៅក្នុង Sacramento ទេ ប៉ុន្តែនៅក្នុងតំបន់ ដោយគោរពតាមសំឡេងរបស់ឪពុកម្តាយ គ្រូបង្រៀន បុគ្គលិកសាលាដទៃទៀត និងសមាជិកសហគមន៍នានា។ វាតំរូវឱ្យសាលារៀនក្នុងតំបន់ចាំបាច់ត្រូវគណកម្មការសាលាឱ្យធ្វើការជាមួយឪពុកម្តាយ គ្រូបង្រៀន បុគ្គលិកសាលាផ្សេងៗ និងសមាជិកសហគមន៍ដើម្បីសម្រេចពីអ្វីដែលត្រូវការបំផុតនៅសាលាជាក់លាក់ណាមួយ។

(g) ដើម្បីឱ្យសាលារៀនរបស់យើងទាំងអស់អាចត្រូវបានបំលែងដែរអាចឱ្យកុមារទាំងអស់ទទួលបាននូវអត្ថប្រយោជន៍ ច្បាប់នេះ ធ្វើឱ្យធានាថា ការផ្តល់មូលនិធិថ្មីទទួលបានបានដោយសាលារៀន ក្នុងតំបន់នីមួយៗ--រាប់បញ្ចូលទាំងសាខាសាលារៀន សាលាក្នុង ខោនធី និងសាលាសម្រាប់ក្មេងៗដែលមានតំរូវការពិសេស--និងត្រូវ បានបម្រុងទុកដោយស្មើភាព និងតម្លាភាព។ ការផ្តល់មូលធិនិថ្មី នឹងត្រូវបានបានបម្រុងទុកសម្រាប់សាលារៀនក្នុងតំបន់នីមួយៗលើ មូលដ្ឋានសម្រាប់សិស្សម្នាក់ៗ ជាមួយមូលនិធិដែលបានតំរូវឱ្យ ចំណាយនៅសាលារៀនក្នុងតំបន់ មិនមែនទីការិយាល័យកណ្តាលក្នុងស្រុកទេ ។

(h) វិធានការនេះធ្វើឱ្យគណៈគ្រប់គ្រងសាលារៀនក្នុងតំបន់មានទំនួលខុសត្រូវលើរបៀបដែលពួកគេចំណាយលុយពីអ្នកបង់ពន្ធថ្មី។ ពួកគេត្រូវបានតំរូវឱ្យពន្យល់ពីរបៀបដែលការចំណាយនឹងលើក កម្ពស់លទ្ធផលអប់រំ និងពីរបៀបដែលពួកគេស្នើសុំកំណត់ថាតើការ ចំណាយទាំងនេះបានជោគជ័យដែរឬទេ។ ពួកគេនឹងត្រូវបានតំរូវ ឱ្យរាយការណ៍មកវិញលើលទ្ធផលអ្វីដែលត្រូវបានសម្រេច ដើម្បីឱ្យឪពុកម្តាយ គ្រូបង្រៀន បុគ្គលិកដទៃ និងសមាជិកសហគមន៍ នឹងដឹងថាតើលុយរបស់ពួកគេកំពុងត្រូវបានប្រើប្រាសដោយឆ្លាតវៃដែរ ឬទេ។

(i) ច្បាប់នេះកម្រិតពីអ្វីដែលសាលារៀននានាអាចចំណាយពី មូលនិធិថ្មីទាំងនេះលើថ្លៃរដ្ឋបាល ដែលមិនឱ្យលើសពី 1 ភាគរយហើយធានាថាសាលារៀននានា នឹងមិនអាចប្រើប្រាស់មូលនិធិថ្មី ទាំងនេះ ដើម្បីបង្កើនប្រាក់ខែ និងអត្ថប្រយោជន៍ទេ។

37
38

(j) ច្បាប់នេះនឹងជួយរៀបចំកុមារក្មេងដែលចាញ់ប្រៀបឱ្យទទួលបានជោគជ័យក្នុងសាលារៀន និងក្នុងជីវិត ដោយបង្កើននូវបទដ្ឋាននានាសម្រាប់កម្មវិធីអប់រំកុមារវ័យដំបូង និង ដោយការបង្កើននូវចំនួនកុមារដែលអាចចូលរួមបាន។

(k) ក្នុងនាមជាប្រជាពលរដ្ឋរដ្ឋកាលីហ្វ័រញ៉ា យើងទាំងអស់គ្នាគួរតែចែករំលែកនូវតម្លៃក្នុងការលើកកម្ពស់សាលារៀន និងកម្មវិធីអប់រំ វ័យដំបូងរបស់យើង ពីព្រោះយើងទាំងអស់គ្នាចូលរួមទទួលបាននូវអត្ថប្រយោជន៍ដែលសាលារៀន និកម្លាំងការងារដែលទទួលបានការអប់រំល្អ នឹងនាំមកនូវសេដ្ឋកិច្ចរបស់យើង និងគុណភាពជីវិតក្នុងរដ្ឋរបស់យើងដ៏ប្រសើរ។

(l) សាលារៀន និងកម្មវិធីកុមារវ័យដំបូងរបស់យើងបានរងគ្រោះជាច្រើនឆ្នាំពីការទទួលបានការប្រែប្រួលដ៏តិចតួច។ ប្រសើរជាការអនុញ្ញាតនូវការកាត់បន្ថយបន្ថែម យើងត្រូវការបង្កើននូវការផ្តល់មូល និធិដើម្បីផ្តល់ដល់កុមារ នីមួយៗនូវឱកាសទទួលបានជោគជ័យ។ ប្រសិនបើយើងទាំងគ្នាចូលរួមជាមួយគ្នាក្នុងការបញ្ចូនធនធានបន្ថែម ទៅកាន់កុមារ និងថ្នាក់រៀនទាំងអស់របស់យើង ហើយយើងទាំងអស់ គ្នាចូលរួមក្នុងការធ្វើការធានាថាការសម្រេចចិត្តត្រឹមត្រូវ ត្រូវបានធ្វើឡើងអំពីរបៀបប្រើប្រាស់មូលនិធិទាំងនេះឱ្យមានប្រសិទ្ធិភាព យើងអាចធ្វើឱ្យសាលារៀននៅរដ្ឋកាលីហ្វ័រញ៉ាអស្ចារ្យ ឡើងវិញនិងអាចធ្វើឱ្យសេដ្ឋកិច្ចរបស់យើងលូតលាស់ម្តងទៀត។

(m) វិធានការនេះបង្កើននូវលុយដែលត្រូវការដើម្បីវិនិយោគជាមួយកុមាររបស់យើង តាមរយៈការបង្កើនពន្ធប្រាក់ចំណូលអត្រា ចំណាយផ្សេងទៀតដែលប្រែប្រួលតាមលទ្ធភាពបង់របស់អ្នកបង់ពន្ធ ជាមួយនឹងអ្នករកប្រាក់ចំណូលបានខ្ពស់បំផុតដែលបាន បរិច្ចាគច្រើនបំផុត។

(n) ក្នុងអំឡុងពេលបួនឆ្នាំដំបូងនៃការផ្តើមប្រជាសិទ្ធិ ដូចដែលបានពិពណ៌នាខាងក្រោម 60 ភាគរយនៃមូលនិធិទាំងនេះ នឹងផ្តល់ទៅ ឱ្យសាលារៀនចំណេះដឹងទូទៅ (K-12) 10 ភាគរយនឹងផ្តល់ទៅ ឱ្យការអប់រំវ័យដំបូង និង 30 ភាគរយនឹងត្រូវផ្តល់ទៅដើម្បីកាត់បន្ថយបំណុលរដ្ឋ និងការពារការកាត់បន្ថយថវិកាដ៏អន្តរាយបន្ថែមទៀត ដែលអាចធ្វើឲ្យខ្សោយដល់ការ វិនិយោគការអប់រំថ្មីទាំងនេះ។ សម្រាប់ រយៈពេលប្រាំបីឆ្នាំនៃការផ្តើមប្រជាសិទ្ធិដែលនៅសល់ ចាប់ពីឆ្នាំ 2017 ទៅ 100 ភាគរយនៃមូលនិធិនឹងបង្កើននូវការអប់រំចំណេះដឹងទូទៅ (K-12) និងការផ្តល់មូលនិធិអប់រំវ័យដំបូង។ ដើម្បីជៀសវាងនូវការ ប្រែប្រួលដ៏ទូលាយក្នុងប្រាក់ចំណូល និងធានាថាការវិនិយោគជាបន្តក្នុងសលារៀននៅក្នុងសាលា និងមណ្ឌលអប់រំវ័យដំបូងដែលត្រូវការប្រាក់ចំណូលណា ដែលលើសពីអត្រាលូតលាស់នៃរដ្ឋកាលីហ្វ័រញ៉ា ក្នុងមួយកាពីតា ប្រាក់ចំណូលក្នុងមនុស្សម្នាក់ នឹងត្រូវបានប្រើប្រាស់ដើម្បីជួយជួសជុល និងសងប្រាក់បំណុលអប់រំរបស់រដ្ឋដែលនៅសល់ ធានាថាលទ្ធភាពរបស់រដ្ឋកាលីហ្វ័រញ៉ាក្នុងការចេញ ផ្សាយនូវបំណុលថ្មី ដូចដែលត្រូវការដើម្បីកសាង និងធ្វើឱ្យ សាលារៀន និងមណ្ឌលអប់រំវ័យដំបូងឲ្យទំនើបឡើង។

(o) ទឹកប្រាក់ថ្មីទាំងអស់ដែលបានរៃអង្គាសដោយការផ្តើមប្រជាសិទ្ធិនេះនឹងត្រូវបានដាក់ក្នុងមូនិធីដ៏ទុកចិត្តដោយឡែកដែលអាចត្រូវបានចំណាយសម្រាប់ *តែ* សាលារៀនក្នុងតំបន់ ប៉ុណ្ណោះ សម្រាប់ការថែទាំនិងការអប់រំកុមារវ័យដំបូង និងដើម្បីជួយជួសជុលនូវការខូចខាត និងជួយសងបំណុលជំពាក់របស់សាលារៀន ដោយយោងតាមខចែងនៃច្បាប់នេះ។ អង្គនីតិបញ្ញត្តិ និងអភិបាលនឹងមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ថវិកានេះសម្រាប់កិច្ចការផ្សេង និងមិនឱ្យពួកគេអាចកែប្រែប្រព័ន្ធលែ ទុកសម្រាប់សិស្សម្នាក់ៗ ដែលធានាថាថវិកាផ្តល់ដោយស្មើភាពគ្នា ចំពោះសាលារៀនក្នុងតំបន់នីមួយៗ។

(p) ការផ្តើមប្រជាសិទ្ធិនេះមាននូវខចែងទទួលខុសត្រូវមានប្រសិទ្ធិភាព និងរឹងមាំ ដែលតំរូវឲ្យមានការត្រួតពិនិត្យ ការជំរះបញ្ជី និងការបង្ហាញជាសាធារណៈ។ សម្រាប់លើកដំបូង យើងនឹងមានថវិកាទី តាំងសាលារៀងច្បាស់លាស់ និងដឹងយ៉ាងជាក់លាក់ពីរបៀប ដែលលុយរបស់យើងកំពុងត្រូវបានចាយនៅក្នុងសាលារៀននីមួយៗ របៀបណា។ នរណាម្នាក់បំពានដោយចេតនាលើការបំរុងទុក ឬខចែងខាងការបែងចែកនៃច្បាប់នេះនឹងត្រូវមានទោសពីបទឧក្រិដ្ឋ។

(q) ការផ្តើមប្រជាសិទ្ធិបង្កើតផងដែរនូវស្រទាប់ទំនួលខុសត្រូវ បន្ថែមមួយដោយការបញ្ចប់ការយកពន្ធបន្ទាប់ពីរយៈពេល 12 ឆ្នាំ ប្រសិនបើវាមិនត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតនានាទេ។ ការនោះផ្តល់ឱ្យសាលារៀនរបស់យើងនូវពេលវេលាគ្រប់គ្រាន់ដើម្បីបង្ហាញថាមូលនិធិថ្មីពិតជាបានជួយលើកកម្ពស់លទ្ធផលអប់រំ ដែលកំពុងការពារអ្នកបង់ពន្ធនានា ដោយការលុបចោលនូវពន្ធ ប្រសិនបើអ្នកបោះឆ្នោត នានាសម្រេចថាពួកគេមិនចង់រក្សាវាទុក។

(r) ការផ្តើមប្រជាសិទ្ធិនេះនឹងមានសុពលភាពសម្រាប់ជា មធ្យោបាយដោះស្រាយរដ្ឋកាលីហ្វ័រញ៉ា ជាមួយនឹងការធ្លាក់ចុះមួយ ក្នុងចំណោមការធ្លាក់ចុះសេដ្ឋកិច្ចដ៏អាក្រក់បំផុតនានាក្នុងប្រវត្តិ សាស្ត្ររបស់ខ្លួន។ ប្រសិនបើការផ្តើមប្រជាសិទ្ធិនេះត្រូវបានអនុវត្តពេញលេញភ្លាមៗ ហើយមិនមានអ្វីៗត្រូវបានធ្វើឡើងដើម្បីជួយបិទ បញ្ឈប់នូវឱនភាពថវិការដ្ឋរបស់យើង ដែលបន្តនូវការកាត់បន្ថយ ថវិកាដ៏ច្រើន អាចដកហូតនូវការគាំទ្រពីកុមារ និងសាលារៀនរបស់ យើង ដែលពួកគេត្រូវបានដើម្បីទទួលបានផលប្រយោជន៍ពេញលេញពីការ វិនិយោគអប់រំដែលបានផ្តល់ឱ្យដោយច្បាប់នេះ។ ដូច្នេះ ការផ្តើមប្រជាសិទ្ធិនេះនឹងត្រូវបានអនុវត្តជាពីរដំណាក់កាល ។ សម្រាប់សារពើពន្ធបួនឆ្នាំដំបូង រហូតដល់ចុងឆ្នាំ 2016- 17 30 ភាគរយនៃ មូលនិធិនេះ ដែលប្រមាណជា 3 ពាន់លានដុល្លារ នឹងផ្តល់ទៅសេវាជួសជុល និងសងបំណុលជំពាក់របស់សាលារដ្ឋ និងបំណុលដទៃទៀត ដែលធ្វើរួចខ្លួននូវចំនួនដូចគ្នាមួយដើម្បីបំពេញនូវសេចក្តីត្រូវការ ថវិកាដទៃដែលសំខាន់សម្រាប់ការធំធាត់សរុបនៃកុមារ និងគ្រួសារ និងសហគមន៍ដែលពួកគេរស់នៅក្នុង។ ដោយចាប់ផ្តើមក្នុងឆ្នាំ 2017- 18 សំណើប្រជានុម័តិនេះនឹងត្រូវបានអនុវត្តយ៉ាងពេញលេញ និង 100 ភាគរយនៃមូលនិធិ នឹងជាថវិកាថ្មី ដែលមិនអាចត្រូវ បានប្រើប្រាស់ជំនួសកន្លែងសំណើប្រជាមតិទី 98 ឬការផ្តល់នូវ មូលនិធិបច្ចុប្បន្នដទៃណាមួយសម្រាប់ការអប់រំចំណេះដឹងទូទៅ (K-12) ឬកម្មវិធីកុមារវ័យដំបូងបានទេ។ លទ្ធផលនៃទំនាក់ទំនងធ្វើនៅ ដំណាក់កាលនេះនឹងជាកាលដែលចាប់ផ្តើមភ្លាមៗ 70 ភាគរយនៃ មូលនិធិទាំងនេះនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើនការផ្តល់មូលនិធិ សម្រាប់សាលារៀន និងកម្មវិធីអប់រំវ័យដំបូងដូចដែលត្រូវបានតំរូវ ដោយច្បាប់នេះ និងបន្ទាប់ពីរយៈពេលបួនឆ្នាំ មូលនិធិទាំងអស់ 100 ភាគរយ ត្រូវបានចំណាយសម្រាប់គោលបំណងនោះដើម្បីបំពេញ នូវកាតព្វកិច្ចរបស់យើងចំពោះកុមាររបស់យើង និងអនាគតរបស់យើង ។

វគ្គទី 3 គោលបំណង និងចេតនា

ប្រជាពលរដ្ឋក្នុងរដ្ឋកាលីហ្វ័រញ៉ាសូមប្រកាសថាច្បាប់នេះត្រូវ មានចេតនាក្នុងការធ្វើដូចតទៅនេះ៖

(a) ដើម្បីពង្រឹង និងគាំទ្រសាលារៀនសាធារណៈរបស់រដ្ឋកាលីហ្វ័រញ៉ា ដែលរួមមានទាំងសាខាសាលា ដោយបង្កើននូវ ការផ្តល់មូលនិធិសម្រាប់សិស្សម្នាក់ៗដើម្បីលើកកម្ពស់លទ្ធផលការសិក្សា អត្រាបញ្ចប់ការសិក្សា និង ការត្រៀមខ្លួនសម្រាប់ បណ្តុះបណ្តាលវិជ្ជាជីវៈ មហាវិទ្យាល័យ អាជីព និងជីវិត។

(b) ដើម្បីពង្រឹង និងគាំទ្រការអប់រំកុមារក្នុងរដ្ឋកាលីហ្វ័រញ៉ា ដោយការស្តារឡើងវិញនូវការផ្តល់មូលនិធិ ការលើកកម្ពស់គុណភាព និងការពង្រីកការទទួលបានកម្មវិធីអប់រំ និងថែទាំ វ័យដំបូងសម្រាប់កុមារមានគុណវិបត្តិនិងងាយរងគ្រោះ។

(c) ដើម្បីបង្កើតនូវការទទួលខុសត្រូវ តម្លាភាព និង ការចូលរួមសហគមន៍បន្ថែមទៀតពីរបៀបដែលមូលនិធិអប់រំសាធារណៈត្រូវបានចំណាយ។

(d) ដើម្បីធានាថាប្រាក់ចំណូលដែលបានមកពីច្បាប់នេះ នឹងត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពអប់រំចំណេះដឹងទូទៅ (K-12)នៅទីតាំងសាលារៀនដើម្បីពង្រីក និងពង្រឹងការអប់រំ និងការថែទាំវ័យដំបូង សម្រាប់កុមារដែលមានគុណវិបត្តិ និងចំពោះវិសាលភាពកំនត់ និងស្ថិតក្រោមកាលៈទេសៈកំណត់ ដែលទទួលការអនុញ្ញាតជាពិសេសដោយច្បាប់នេះ ដើម្បីពង្រឹងនូវតំណែងសារពើពន្ធសរុបនៃរដ្ឋ និងលើកទឹកចិត្តដល់ ការវិនិយោគនាពេលអនាគតគ្រប់គ្រាន់ក្នុងមណ្ឌលអប់រំ ដោយការ កាត់បន្ថយនូវបន្ទុកនៃបំណុលអប់រំរដ្ឋនាពេលបច្ចុប្បន្ន។

(e) ដើម្បីធានាថាប្រាក់ចំណូលដែលត្រូវបានបង្កើតដោយច្បាប់ នេះមិនអាចត្រូវបានប្រើប្រាស់ដើម្បីជំនួសនូវមូលនិធិរដ្ឋដែលមាន ស្រាប់សម្រាប់ការអប់រំចំនេះដឹងទូទៅ (K-12) ឬការអប់រំ និងថែទាំ វ័យដំបូង ។

(f) ដើម្បីធានាថាអង្គនីតិវិធីមិនអាចខ្ចី ឬផ្លាស់ប្តូរទិសដៅជាមួយ ប្រាក់ចំ

ណ្ឌលដែលបានបង្កើតដោយច្បាប់នេះ សម្រាប់គោលបំណង ដទៃណាមួយ ឬមិនធ្វើការប្រាប់ដល់សហាគមសាលាក្នុងតំបន់ពី របៀបដែលមូលនិធិទាំងនោះនឹងត្រូវបានចំណាយទេ ។

វគ្គទី 4 ភាគទី 9.7 (ចាប់ផ្តើមជាមួយវគ្គទី 14800) ត្រូវបានបន្ថែមទៅកាន់បំណែក 1 នៃប្រការ 1 នៃច្បាប់អប់រំ ចែងថា ៖

*ភាគទី 9.7 កុមាររបស់យើង អនាគតរបស់យើង ៖ ច្បាប់ស្តីពីការវិនិយោគលើការអប់រំវ័យដំបូង និងសាលារៀនក្នុងតំបន់ និងការកាត់បន្ថយប័ណ្ណបំណុល*

*14800. ភាគនេះនឹងត្រូវបានគេស្គាល់ និងអាចត្រូវបានធ្វើជាអំណះអំណាងជាច្បាប់កុមាររបស់យើង អនាគតរបស់យើង៖ សាលារៀនក្នុងតំបន់ការវិនិយោគអប់រំវ័យដំបូង និងកាត់បន្ថយបំណុលជំពាក់។*

*14800.5. សម្រាប់គោលបំណងនៅវគ្គនេះ និងជំពូកទី 1.8 (ការចាប់ផ្តើមជាមួយវគ្គ 8160)នៃភាគទី 6នៃបំណែកទី 1នៃប្រការ ទី 1 ការកំណត់នានាដូចខាងក្រោមត្រូវបានអនុវត្តៈ*

*(a) "ភ្នាក់ងារអប់រំក្នុងតំបន់" ឬ "LEA" រាប់បញ្ចូលទាំងសាលាក្នុង តំបន់ការិយាល័យអប់រំក្នុងខោនធី គណៈគ្រប់គ្រងសាខាសាលាសាធារណៈឯករាជ្យ និងស្ថាប័ន គ្រប់គ្រងនៃសេវាណែនាំដោយផ្ទាល់ដែលបានផ្តល់ឱ្យដោយរដ្ឋ ដែលរួមមានសាលារៀនរដ្ឋកាលីហ្វ័រញ៉ាសម្រាប់ជនពិការភ្នែក និងសាលារៀនរដ្ឋកាលីហ្វ័រញ៉ាសម្រាប់ជនងងឹតភ្នែក។*

*(b) "សាលារៀន K-12" ឬ "សាលារៀន"មានន័យថាជាសាលារៀនរដ្ឋណាមួយ ដែលរួមមានទាំង ប៉ុន្តែមិនត្រូវបានកម្រិតនូវសាខាសាលាណាមួយ សាលាក្នុងខោនធីណាមួយ ឬសាលារៀនសម្រាប់កុមារមានតំរូវការពិសេសនានា ដែលចុះឈ្មោះចូលរៀនជារៀងរាល់ឆ្នាំ និងផ្តល់នូវសេវាណែនាំដោយផ្ទាល់ ទៅកាន់សិស្សក្នុងថ្នាក់មត្តេយ្យណាមួយ ឬទាំងអស់រហូតដល់ថ្នាក់ទី 12 នឹងដែលស្ថិតក្រោមយុត្តិការប្រតិបត្តិការនៃ LEA ណាមួយ ។ រយៈពេលនៃ "សាលាមត្តេយ្យ" ក្នុងវគ្គនេះរួមបញ្ចូលទាំងអន្តរៈសាលាមត្តេយ្យ។*

*(c) "ការអប់រំ និងថែទាំវ័យដំបូង" ឬ "ECE" មានន័យថាថ្នាក់ មត្តេយ្យ និងកម្មវិធីដទៃទៀត ដែលត្រូវបានរៀបចំឡើងដើម្បីយក ចិត្តទុកដាក់ និងបន្ថែមការអប់រំកុមារពីពេលកើតរហូតដល់អាចចូល រៀនសលាមត្តេយ្យបាន រាប់បញ្ចូលទាំងកម្មវិធីទាំងពីរដែលបានផ្តល់ ឱ្យនូវការអប់រំ និងថែទាំវ័យដំបូងដល់កុមារ និងកម្មវិធីនានាដែល ពង្រឹងនូវសមត្ថភាពអប់រំ និងថែទាំវ័យដំបូងនៃឪពុកម្តាយ និងអ្នក ថែទាំងនានា ដើម្បីឱ្យពួកគេអាចបម្រើកុមារបានប្រសើរជាងមុន។*

*(d) សម្រាប់ឆ្នាំសិក្សា 2013-2014 "ការចុះឈ្មោះចូលរៀន"របស់ សាលារៀនមានន័យថាជាលក្ខណៈចុះឈ្មោះនាខែតុលាសម្រាប់ ឆ្នាំសិក្សា 2012-2013 ដែលត្រូវបានកាត់បន្ថយ ឬដំឡើងដោយការ លូតលាស់ ឬការថយចុះនូវភាគរយជាមធ្យមក្នុងតួលេខចុះឈ្មោះ ចូលរៀននាខែតុលារបស់ខ្លួននៅពេញបីឆ្នាំសិក្សាកន្លងទៅ។ សម្រាប់ឆ្នាំបន្តបន្ទាប់ "ការចុះឈ្មោះចូលរៀន"របស់សាលារៀន មានន័យថាជាការចុះឈ្មោះចូលរៀនសកម្មប្រចាំខែជាមធ្យមសម្រាប់ ឆ្នាំសិក្សាមុនដែលត្រូវបានគណនាដោយយោងតាមវគ្គ 46305 ឬការចុះឈ្មោះនាខែតុលាសម្រាប់ឆ្នាំសិក្សាមុន ប្រសិនបើ តួលេខនៃវគ្គទី 46305 មិនទាន់មាន ត្រូវបានកាត់បន្ថយ ឬ ត្រូវបានដំឡើងដោយការលូតលាស់ ឬការធ្លាក់ចុះនូវភាគរយជា មធ្យមក្នុងតួលេខចុះឈ្មោះចូលរៀនទាំងនេះ នៅរយៈពេលបីឆ្នាំកន្លងទៅ។ រាល់ការចុះឈ្មោះចូលរៀនរបស់ LEA នីមួយៗ នឹងត្រូវ សុរបការចុះឈ្មោះចូលរៀននានានៅសាលារៀនទាំងអស់ស្ថិតក្រោម យុត្តាធិការរបស់ LEA ។ ការចុះឈ្មោះចូលរៀនទូទាំងរដ្ឋនឹងត្រូវជាការសរុបនៃការចុះឈ្មោះចូលរៀនរបស់ LEA ទាំងអស់។*

*(e) "កម្មវិធីអប់រំ"មានន័យថាជាការចំណាយសម្រាប់គោលបំណងដូចខាងក្រោមនៅតំបន់សាលាចំណេះដឹងទូទៅ(K-12) ដែលបានអនុម័តនៅសវនាការសាធារណៈដោយគណៈគ្រប់គ្រង នៃ LEA ជាមួយនឹងយុត្តិការទៅលើសាលារៀននេះ ដើម្បីលើកកម្ពស់ការបំពេញការសិក្សារបស់កូនសិស្ស អត្រាបញ្ចប់ការសិក្សា និងការ ត្រៀមខ្លួនបណ្តុះបណ្តាលវិជ្ជាជីវៈ អាជីព មហាវិទ្យាល័យ និងជីវិត។*

*(1) ការណែនាំលើមុខវិជ្ជាសិល្បៈ ការអប់រំរាងកាយ វិទ្យាសាស្ត្របច្ចេកវិជ្ជា វិស្វកម្ម គណិតវិទ្យា ប្រវត្តិវិទ្យា ពលរដ្ឋវិទ្យា អក្ខរកម្មហិរញ្ញវត្ថុ ភាសាអង់គ្លេស និងភាសាបរទេស និងការអប់រំបច្ចេកទេស វិជ្ជាជីវៈ ឬ អាជីព ។*

*(2) ទំហំថ្នាក់រៀនតូចជាងមុន។*

*(3) ក្រុមប្រឹក្សា បណ្ណារក្ស គិលានុបដ្ឋាយិកាសាលា និងបុគ្គលិក ទ្រទ្រង់ដទៃនៅតំបន់សាលារៀនច្រើនជាមុន។*

*(4) ពន្យាពេលវេលាសិក្សា តាមរយៈថ្ងៃសាលាកាន់តែវែងជាង មុន ឬឆ្នាំសិក្សាសាលាកាន់តែវែងជាងមុន សាលារៀនរដូវក្តៅ ថ្នាក់មត្តេយ្យ កម្មវិធីបំប៉នបន្ទាប់ពីសាលា និងការបង្រៀងតាមផ្ទះ។*

*(5) ការគាំទ្រសង្គម និងសិក្សាបន្ថែមសម្រាប់អ្នកសិក្សាភាសាអង់គ្លេស កូនសិស្សដែលមានប្រាក់ចំណូលទាប និងកូនសិស្សដែលមានសេចក្តីត្រូវការពិសេស។*

*(6) គំរូការអប់រំជាជម្រើសផ្សេង ដែលបានកសាងនូវសមត្ថភាពរបស់កូនសិស្សសម្រាប់ការគិតដ៏ស៊ីជម្រៅ និងគំនិតច្នៃប្រឌិត។*

*(7) ការទំនាក់ទំនង និងការចូលរួមបន្ថែមជាមួយឪពុក ម្តាយក្នុងការធ្វើជាដៃគូពិតបាក្រដជាមួយសាលារៀនក្នុងការជួយ ឱ្យកុមារទាំងអស់ទទួលបានជោគជ័យ។*

*(f) "មូលនិធិ CETF"មានន័យថាប្រាក់ចំណូលទាំងនោះ ត្រូវបានដាក់ក្នុងមូលនិធិគួរទុកចិត្តខាងការអប់រំរដ្ឋកាលីហ្វ័រញ៉ា ដោយយោងតាមវគ្គ 17041.1 នៃច្បាប់ប្រាក់ចំណូល និង ការបង់ពន្ធ ជាមួយគ្នានឹងការប្រាក់ទាំងអស់ដែលត្រូវ រកបាននៅលើមូលនិធិទាំងនោះ ដែលកំពុងតែរង់ចាំនូវការធ្វើបំណែងចែកដំបូង និងការប្រាក់ទាំងអស់ដែលរកបាននៅលើមូលនិធិដែលបានទទួល មកវិញ ដែលកំពុងតែរង់ចាំការធ្វើបំណែងចែកពួកគេ។*

*(g) "អ្នកមើលការខុសត្រូវ" មានន័យថាអ្នកមើលការខុសត្រូវលើការណែនាំជាសាធារណៈ។*

*14801. (a)មូលនិធិគួរទុកចិត្តខាងការអប់រំរដ្ឋកាលីហ្វ័រញ៉ា (CETF) គឺនៅទីនេះត្រូវបានបង្កើតក្នុងរតនាគាររដ្ឋ។ មូលនិធិ CETF ត្រូវបានរក្សាទុកដោយជឿជាក់ និងទោះបីជាមានវគ្គទី 13340 នៃក្រុមរដ្ឋាភិបាលក៏ដោយ ត្រូវបានធ្វើឱ្យសមរម្យជាបន្តបន្ទាប់ ដោយមិនជាប់ពាក់ព័ន្ធនឹងឆ្នាំសារពើពន្ធ សម្រាប់គោលបំណងទាំងស្រុងដែលបានកំណត់ទៅមុខនៅក្នុងច្បាប់នេះ*

*ទេ។*

*(b) មូលនិធិ CETF ដែលបានផ្ទេរ និងបែងចែកទៅកាន់ ឬមកពីមូលនិធិគួរទុកចិត្តខាងការអប់រំរដ្ឋកាលីហ្វ័រញ៉ានឹងមិនគួរផ្តើមឲ្យមានការធ្វើឱ្យសាកសមដែលប្រឈមនឹងការកំណត់សម្រាប់គោលបំណងនៃមាត្រា XIIIB នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។ មូលនិធិ CETF គួរត្រូវបានរក្សាទុកក្នុងការទុកចិត្តសម្រាប់គោលបំណង នៃច្បាប់នេះតែមួយគត់ និងមិនត្រូវបានចាត់ទុកជាប្រាក់ចំណូលមូល និធិទូទៅ ឬប្រាក់ចំណូលរបស់ពន្ធដារ ហើយដូច្នេះនឹងមិនត្រូវបានបញ្ចូលក្នុង ការគណនានានាដែលតំរូវដោយវគ្គទី 8 នៃមាត្រា XVI ឬ មិនអាចប្រែប្រួលតាមខចែងនៃវគ្គទី 12 នៃមាត្រា IV ឬ វគ្គទី 20 នៃមាត្រា XVI នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។*

*(c) មូលនិធិ CETF នឹងត្រូវបានបែងចែក និងប្រើប្រាស់តែចំពោះដូចដែលបានកំណត់ទៅមុខក្នុងច្បាប់នេះ និងមិនត្រូវបានប្រើប្រាស់ដើម្បីចំណាយលើថ្លៃរដ្ឋបាល លើកលែងតែត្រូវ បានផ្តល់សិទ្ធិជាពិសេសដោយច្បាប់។ ទោះបីជាយ៉ាងណាខចែងដទៃណាមួយផ្សេងទៀតនៃច្បាប់នេះ មូលនិធិ CETF នឹងមិនត្រូវបានផ្ទេរ ឬ ផ្តល់ប្រាក់កម្ចីទៅលើមូលនិធិទូទៅ ឬទៅលើមូលនិធិដទៃណាមួយ បុគ្គល ឬអង្គភាពណាមួយ សម្រាប់គោលបំណង ឬនៅពេលណាមួយ លើក លែងតែត្រូវបានអនុញ្ញាតយ៉ាងច្បាស់ក្នុងវគ្គទី 14813។*

*(d) មូលនិធិ CETFដែលបានបែងចែកទៅកាន់ LEAs និង អ្នកមើលការខុសត្រូវពី CETF នឹងត្រូវដាក់បន្ថែមក្នុងមូលនិធិរដ្ឋ ក្នុងតំបន់*

38

និងសហព័ន្ធ ដែលបានកំណត់ទុកសម្រាប់សាលារៀនចំ ណេះដឹងទូទៅ (K-12) និងការអប់រំ និងថែទាំវ័យដំបូង ចាប់ផ្តើមពី ថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2012 និងមិនត្រូវបានប្រើប្រាស់ដើម្បីជំនួសឱ្យ ក្នុងមួយកាពីតានៃកម្រិតមូលនិធិរដ្ឋ ក្នុងតំបន់ ឬ សហព័ន្ធ ដែលមានជាស្រេច សម្រាប់គោលបំណងទាំងនេះ ចាប់ផ្តើមពី កាលបរិច្ឆេទនោះតទៅដែលបានធ្វើឱ្យត្រឹមត្រូវសម្រាប់ការផ្លាស់ប្តូរក្នុងថ្លៃរស់នៅ និងដោយគោរពលើមូលនិធិសហព័ន្ធ សម្រាប់ការថយចុះទាំងស្រុងក្នុងអ្វីដែលមានក្នុងការផ្គត់ផ្គង់របស់សហព័ន្ធ។ ចំនួនទឹកប្រាក់ដែលត្រូវបានធ្វើឱ្យសមរម្យពីមូលនិធិនានា ក្រៅពី CETF សម្រាប់ការគាំទ្រ នូវប្រព័ន្ធអប់រំអប់រំចំណេះដឹងទូទៅ K-12 និងកម្មវិធីអប់រំ និងថែទាំវ័យដំបូង ថាតើត្រូវបានកំណត់អាណត្តិដោយរដ្ឋធម្មនុញ្ញ ឬផ្សេងពីនេះ នឹងមិនត្រូវបានកាត់បន្ថយ ជាលទ្ធផលនៃមូល និធិដែលបានធ្វើបំណែងចែកដោយយោងតាមច្បាប់នេះ ។

14802. (a)គណៈកម្មការត្រួតពិនិត្យសារពើពន្ធ នៅទីនេះ ត្រូវបានបង្កើតឡើង ដើម្បីផ្តល់នូវការត្រួតពិនិត្យមើល និងទំនួលខុសត្រូវក្នុងការបែងចែក និងប្រើប្រាស់មូលនិធិ CETF ទាំងអស់។ សមាជិកនានានៃគណៈកម្មការជាអ្នកត្រួតតា្រសវនកររដ្ឋ ទេសាភិបាល និងប្រធានមេធាវី និងនាយកគ្រប់គ្រងហរិញ្ញវត្ថុ។ គណៈកម្មការត្រួតពិនិត្យសារពើពន្ធ ត្រូវមានទំនួលខុសត្រូវសម្រាប់ការធានាថាមូលនិធិ CETF ត្រូវ បានចែកចាយយ៉ាងច្បាស់លាស់ ដូចដែលត្រូវបានផ្តល់ឱ្យដោយ វគ្គនេះ និងត្រូវបានប្រើប្រាស់យ៉ាងស៊ីជម្រៅ សម្រាប់តែគោលបំណង នានា ដូចដែលបានកំណត់នៅក្នុងវគ្គនេះ។

(b) ទោះបីយ៉ាងណា ខចែងនៃច្បាប់ដទៃណាមួយ ថ្លៃពិតប្រាកដ ដែលបានកើតឡើងដោយគណៈគ្រប់គ្រងលើការពិនិត្យសារពើពន្ធ អ្នកត្រួតត្រា និងអ្នកមើលការខុសត្រូវក្នុងការចាត់ចែងលើមូលនិធិ គួរទុកចិត្តខាងការអប់រំរដ្ឋកាលីហ្វ័រនីញ៉ា នឹងត្រូវបានបង់ ប្រាក់ដោយមូលនិធិ CETF ទោះបីជាយ៉ាងណា ប្រសិនបើថ្លៃចំ ណាយទាំងនោះអាចនឹងមិនលើសពីបីភាគដប់នៃចំនួន 1 ភាគរយនៃប្រាក់ចំណូលទាំងអស់ដែលបានប្រមូលក្នុងមូលនិធិក្នុង អំឡុងពេលបីឆ្នាំណាមួយ ដែលជាចំនួនមធ្យមនៃមួយភាគដប់នៃចំនួន 1 ភាគរយជាប្រចាំឆ្នាំ។ រហូតដល់ចុងឆ្នាំសារពើពន្ធ 2016-17 ចំនួន 30 ភាគរយនៃថ្លៃចំណាយដែលបានផ្តល់សិទ្ធិឱ្យ ដោយវគ្គនេះនឹងត្រូវបានកាត់ចេញពីមូលនិធិគាំទ្របណ្តោះ អាសន្នដែលបានផ្តល់ឱ្យដោយយោងតាមវគ្គទី 14802.1 ចំនួន 60 ភាគរយនៃថ្លៃចំណាយដែលត្រូវបានផ្តល់សិទ្ធិឱ្យដោយវគ្គនេះ នឹងត្រូវបានបានកាត់ចេញពីមូលនិធិដែលបានកំណត់ ទុកប៉ុំសម្រាប់ K-12 ដោយយោងតាមវគ្គទី 14803 និងចំនួន 10 ភាគរយនៃថ្លៃចំណាយដែលបានផ្តល់សិទ្ធិឱ្យដោយវគ្គនេះ នឹងត្រូវបានកាត់ចេញពីមូលនិធិដែលបានកំណត់ទុកប៉ុំ សម្រាប់ ECE ដោយយោងតាមវគ្គទី 14803 ។ ក្រោយមក ចំនួន 85 ភាគរយនៃថ្លៃចំណាយដែលបានផ្តល់សិទ្ធិដោយ វគ្គនេះនឹងត្រូវបានកាត់ចេញពីមូលនិធិដែលបានកំណត់ទុក ប៉ុំសម្រាប់ K-12 និងចំនួន 15 ភាគរយនឹងត្រូវបានកាត់ចេញពី មូលនិធិនានាដែលបានកំណត់សម្រាប់ ECE ដោយយោងតាម វគ្គទី 14803។

(c) គណកម្មការត្រួតពិនិត្យសារពើពន្ធអាចទទួលយកនូវបទបញ្ជាបែបទាំងនោះ ដែលរួមបញ្ចូលទាំង បទបញ្ជាបន្ទាន់ ដូចដែលចាំបាច់ក្នុងការបំពេញនូវកាតព្វកិច្ចនានារបស់ខ្លួននៅក្រោមច្បាប់នេះ។

14802.1. (a) រហូតដល់ចុងឆ្នាំសារពើពន្ធ 2016-17 អ្នកត្រួតតានឹងបែងចែកចំនួន 30 ភាគរយនៃមូលនិធិ CETF ដូចដែលបានផ្តល់ឱ្យក្នុងវគ្គនេះ ហើយអ្វីដែលនៅសល់ ដែលស្របតាមវគ្គទី 14803, 14804, 14805, 14806 និង14807។ បន្ទាប់មក មូលនិធិ CETF ទាំងអស់ នឹងត្រូវបានគេបែងចែក ដោយយោងតាមវគ្គ 14803, 14804, 14805, 14806 និង14807។

(b) រហូតដល់ចុងឆ្នាំសារពើពន្ធ 2016-17 ពាក្យថា "មូលនិធិ CETF" ដូចដែលត្រូវបានប្រើប្រាស់ក្នុងវគ្គទី 14803 នឹងសំដៅទៅលើចំនួន 70 ភាគរយនៃមូលនិធិ CETF ដែលត្រូវបានធ្វើបំណែងចែកយោងតាមវគ្គ 14803, 14804, 14805, 14806 និង14808 ហើយពាក្យថា "មូលនិធិគាំទ្របណ្តោះ អាសន្ន" នឹងត្រូវសំដៅទៅដល់ ចំនួន 30 ភាគរយនៃមូលនិធិ CETF ដែលត្រូវបានបែងចែក ស្របតាមវគ្គនេះ។

(c) រហូតដល់ចុងឆ្នាំសារពើពន្ធ 2016-17 លើ មូលដ្ឋានត្រីមាស អ្នកត្រួតពិនិត្យនឹងធ្វើភស្តុតាងលើ និងចែក ចាយមូលនិធិគាំទ្របណ្តោះអាសន្នទៅកាន់មូលនិធិសេវាបំណុល អប់រំ ដែលបានធ្វើឡើងដោយវគ្គ 14813 សម្រាប់ការចែក ចាយដោយយោងតាមវគ្គនោះ។

14803. (a) ក្នុងអំឡុងឆ្នាំសារពើពន្ធពេញពីរឆ្នាំដំបូងបន្តពីកាលបរិច្ឆេទជាធរមាននៃច្បាប់នេះ អ្នកត្រួតពិនិត្យនឹងកំណត់នូវ ចំនួន 85 ភាគរយនៃមូលនិធិ CETF ដោយឡែក សម្រាប់ការ បែងចែងទៅកាន់ភ្នាក់ងារអប់រំក្នុងតំបន់ សម្រាប់សាលារៀនចំណេះ ដឹងទូទៅ K-12 និងចំនួន 15 ភាគរយនៃមូលនិធិ CETF សម្រាប់ការបែងចែកទៅកាន់អ្នកមើលការខុសត្រូវសម្រាប់ខចែងនេះ ចំពោះកម្មវិធីអប់រំ និងការថែទាំវ័យដំបូងក្នុងចំនួន និងវិធីដែលបានកំណត់ទុកក្នុងច្បាប់នេះ។ មូលនិធិ ទាំងនេះ ដកថ្លៃពិតប្រាកដចេញ ដោយយោងតាមចំណុច (b)នៃ វគ្គ 14802 នឹងត្រូវបានបានចាត់ទុកជា "ប្រាក់ចំណូលដែលមាន" ស្ថិតក្រោមវគ្គ 14804។

(b) ដើម្បីផ្តល់នូវស្ថេរភាព និងជៀសវាងពីការប្រែប្រួលទូលំទូលាយនានាក្នុងការផ្តល់ថវិកា មូលនិធិ CETF នឹងត្រូវបានចែកចាយដូចខាងក្រោមក្នុងឆ្នាំ សារពើពន្ធនីមួយៗ បន្តបន្ទាប់ពីឆ្នាំសារពើពន្ធពេញលេញពីរឆ្នាំដំបូង បន្ទាប់ពីកាលបរិច្ឆេទដែលមានសុពលភាពនៃច្បាប់នេះ ៖

(1) (A) ចាប់ផ្តើមពីឆ្នាំសារពើពន្ធ 2015-16 និងសម្រាប់ ឆ្នាំនីមួយៗ ក្រៅពីឆ្នាំសារពើពន្ធ ឆ្នាំ 2017-18 នៅពេលដំបូងនៃឆ្នាំសារពើពន្ធនេះ គណៈគ្រប់គ្រងការត្រួតពិនិត្យសារពើពន្ធនេះ នឹងត្រូវកំណត់នូវអត្រាជាមធ្យមដែលប្រាក់ចំណូលផ្ទាល់ខ្លួន ក្នុងរដ្ឋកាលីហ្វ័រញ៉ាក្នុងមួយកាពីតាបាន កើនឡើងពេញក្នុងរយៈពេលប្រាំឆ្នាំមុន និងត្រូវអនុវត្តអត្រាភាគរយនៃការកើនឡើងនៃមូលនិធិ CETFនោះ ដែលត្រូវបានចែកចាយ សំរាប់ LEAs និងអ្នកមើលការខុសត្រូវពីមូលនិធិគួរទុកចិត្តខាងការ អប់រំរដ្ឋកាលីហ្វ័រញ៉ាក្នុងឆ្នាំសារពើពន្ធដែលទើបតែបញ្ចប់។

(B) សម្រាប់តែឆ្នាំសារពើពន្ធ 2017-18 ដើម្បីធ្វើឲ្យ ការផ្លាស់ប្តូរពីមូលនិធិគាំទ្របណ្តោះអាសន្នទាំងនេះ ដែលបានផ្តល់ឱ្យដោយចំណុច (ក) នៃវគ្គទី 1402.1 ចំពោះ ការផ្តល់មូលនិធិសាលារៀនចំណេះដឹងទូទៅ K-12 ពេញលេញ និង កម្មវិធី ECE នៅពេលដំបូងនៃឆ្នាំសារពើពន្ធ គណៈគ្រប់គ្រងការត្រួតពិនិត្យសារពើពន្ធនេះ នឹងកំណត់ពីអត្រាជាមធ្យមដែល ប្រាក់ចំណូលបុគ្គលម្នាក់ក្នុងរដ្ឋកាលីហ្វ័រញ៉ាក្នុងមួយកាពីតាបាន កើន ឡើងនៅប្រាំឆ្នាំកន្លង ហើយនឹងត្រូវអនុវត្តថាអត្រាភាគរយនៃការកើនឡើងលើផលគុណ 1.429 គុណនឹងចំនួន ទឹកប្រាក់មូលនិធិ CETF ដែលត្រូវបានចែកចាយទៅកាន់ LEAs និងអ្នកមើលការខុសត្រូវពីមូលនិធិគួរទុកចិត្តខាងការអប់រំរដ្ឋកាលីហ្វ័រញ៉ា ក្នុងឆ្នាំសារពើពន្ធដែលទើបតែបញ្ចប់។(2)ចំនួនទឹកប្រាក់ដែលបានកំណត់ដោយយោងតាមវគ្គទី (1) ដកនូវថ្លៃចំណាយពិតប្រាកដចេញ ដោយយោងតាមចំណុច(b) នៃវគ្គទី 14802 នឹងត្រូវបានចាត់ទុកជា "ប្រាក់ចំណូលដែលមាន" ស្ថិតក្រោមវគ្គទី 14804 នឹងត្រូវមានសម្រាប់ការចែកចាយលើមូលដ្ឋានត្រីមាសចំពោះ LEAs និង អ្នកមើលការខុសត្រូវក្នុងឆ្នាំសារពើពន្ធនេះបន្ទាប់ពីការចាប់ផ្តើម។

(2) ចំនួនដែលត្រូវបានកំណត់ដោយអនុលោមតាមកថាខណ្ឌ (1) ដកពីថ្លៃសរុបពិតប្រាកដដោយអនុលោមតាមកថាខណ្ឌរង (b) នៃ វគ្គទី 14802 គួរត្រូវពិចារណាថាជា "ប្រាក់ចំណូលដែលមាន" ក្រោមវគ្គ 14804 ហើយគួរមានសំរាប់ចែកចាយប្រចាំត្រីមាសទៅឱ្យ LEAs និងស្នងការសិក្សាក្នុងឆ្នាំសារពើពន្ធ រួចនៅពេលចាប់ផ្តើម។

(c) មូលនិធិ CETF ដែលលើសពីប្រាក់ចំណូលដែលមាន នឹងត្រូវបានចែកចាយនៅដំណាច់ឆ្នាំសារពើពន្ធនេះ ដោយយោង តាមវគ្គទី 14813។

(d) រាល់មូលនិធិ CETF ទាំងអស់ដែលត្រូវបានបម្រុងទុកសំរាប់ LEAs នឹងត្រូវបានចំណាយដោយ LEAs ក្នុងរយៈ ពេលមួយឆ្នាំពីការទទួលបាន ទោះបីជាយ៉ាងណា ប្រសិនបើ LEAs អាចនៅមានប្រសិទ្ធិភាពមិនលើសពី 10 ភាគរយនៃថវិកាទាំងនេះ សម្រាប់ការចំណាយក្នុងឆ្នាំសិក្សាបន្តបន្ទាប់។ គណៈគ្រប់គ្រងការត្រួតពិនិត្យសារពើពន្ធនឹងត្រូវបានយកមកវិញនូវមូលនិធិណា មួយដែលមិនត្រូវបានចំណាយនៅក្នុងអំឡុងពេលមួយឆ្នាំដើមដំបូងនិងមូលនិធិណាមួយដែលបានធ្វើឱ្យមានប្រសិទ្ធិភាព ប៉ុន្តែមិនត្រូវបានចំណាយក្នុងឆ្នាំបន្តបន្ទាប់។ រាល់មូលនិធិទាំងអស់ដែលត្រូវបាន យកមកវិញ នឹងត្រូវ

បានចាត់ទុកជាប្រាក់ចំណូលដែលមាន នឹងត្រូវ បានដាក់បញ្ចូលជាមួយ ប្រាក់ចំណូលដែលមានដទៃទៀត ហើយនឹងត្រូវបានធ្វើបំណែងចែងឡើងវិញ ដោយយោងតាមវគ្គទី 14804។

14804. (a) ស្ថិតលើមូលដ្ឋានត្រីមាស អ្នកត្រួតពិនិត្យនឹងធ្វើ ការធានា និងចែកចាយចំនួន 15 ភាគរយនៃប្រាក់ចំណូលដែល អាចរកបានទៅឱ្យអ្នកមើលការខុសត្រូវលើខថែងចំពោះកម្មវិធីអប់រំ និងការថែទាំវ័យដំបូង និងការគាំទ្រនានាក្នុងរបៀបនិងចំនួនទឹកប្រាក់ ដែលត្រូវបានផ្តល់ឱ្យដោយជំពូក 1.8 (ដែលចាប់ផ្តើមក្នុងវគ្គទី 8160) នៃភាគទី 6។

(b) ស្ថិតលើមូលដ្ឋានត្រីមាសអ្នកត្រួតពិនិត្យនឹងធ្វើការធានា និងចែកចាយចំនួន 85 ភាគរយនៃប្រាក់ចំណូលដែលអាចរកបាន ទៅឱ្យ LEAs ដែលត្រូវបានរក្សាសម្រាប់ការ ចំណាយនៅសាលារៀនចំណេះដឹងទូទៅ K-12 ក្នុងយុត្តិការរបស់ LEAនីមួយៗ ក្នុងចំនួនទឹកប្រាក់ដែលបានគណនាឱ្យដោយអ្នកត្រួត ពិនិត្យ ដោយយោងតាមវគ្គ 14805 ដល់ 14807 បញ្ចូលគ្នា។

(c) វគ្គនេះ និងវគ្គ 14802.1, 14803, 14805, 14806 និង 14807 គឺជាការប្រតិបត្តិដោយខ្លួនឯង និងមិនតំរូវឱ្យមានវិធានការ ច្បាប់ដើម្បីឲ្យមានប្រសិទ្ធិភាព។ ការចែកចាយមូលនិធិ CETF នានា និងមូលនិធិគាំទ្របណ្តោះអាសន្ននឹងមិនត្រូវបានពន្យា ឬធ្វើឱ្យមាន ប្រសិទ្ធិភាពផ្សេង ដោយភាពបរាជ័យនៃអង្គនីតិបញ្ញត្តិ និងអភិបាល ដើម្បីតាក់តែងនូវកិច្ចព្រមព្រៀងថវិកាប្រចាំឆ្នាំ ដោយ យោងតាមវគ្គ 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញកាលីហ្វ័រញ៉ា ឬមិនតាម ភាពសកម្ម ឬភាពអសកម្មដទៃណាមួយនៃលើវគ្គ នេះនៃអភិបាល ឬអង្គនីតិបញ្ញត្តិ។

14805. ក្នុងចំណោមប្រាក់ចំណូលមានស្រាប់ ដែលត្រូវបានបែងចែកសម្រាប់ការចែកចាយជាត្រីមាសទៅឱ្យ LEAs ស្ថិតក្រោមចំណុច (b)នៃវគ្គទី 14804 អ្នកត្រួតពិនិត្យនឹងត្រូវបានបែងចែកនូវចំនួន 70 ភាគរយធ្វើជាប្រាក់ដែលផ្តល់ដោយរដ្ឋាភិបាលសម្រាប់កម្មវិធីអប់រំ សម្រាប់កូនសិស្សម្នាក់។ ចំនួន និងទំហំ នៃប្រាក់ដែលផ្តល់ពីរដ្ឋាភិបាលសម្រាប់កម្មវិធីអប់រំដើម្បីត្រូវបាន រក្សាសម្រាប់សាលារៀនចំណេះដឹងទូទៅ K-12 ស្ថិតក្រោមយុត្តិការរបស់ LEA នឹងត្រូវធ្វើដូចខាងក្រោម៖

(a) អ្នកត្រួតពិនិត្យនឹងត្រូវបង្កើតនូវឯកសណ្ឋាន ថវិកាផ្តល់ដោយ រដ្ឋាភិបាលសម្រាប់កូនសិស្សម្នាក់ទូទាំងរដ្ឋសម្រាប់កូនសិស្សម្នាក់ៗ សម្រាប់រាល់ក្រុមកម្រិតថ្នាក់ទីបីដូចខាងក្រោម: សាលាមត្តេយ្យរហូត ដល់ថ្នាក់ទី 8 បញ្ចូលគ្នា ("ការផ្តល់ថវិកាដល់ K-3") ពីថ្នាក់ទី 4 រហូតដល់ថ្នាក់ទី 8 បញ្ចូលគ្នា ("ការផ្តល់ថវិកាថ្នាក់ទី 4-8") និង ថ្នាក់ទី 9 រហូតដល់ថ្នាក់ទី 12 បញ្ចូលគ្នា ("ការផ្តល់ថវិកាថ្នាក់ទី 9-12")។

(b) ការផ្តល់នូវឯកសណ្ឋានទាំងនេះនឹងត្រូវបានធ្វើដោយផ្អែកលើការចុះឈ្មោះចូលរៀនទូទាំងរដ្ឋសរុប ក្នុងក្រុមកម្រិតថ្នាក់ទីបី នីមួយៗ ។ ចំនួនទឹកប្រាក់ផ្តល់ឱ្យដល់កូនសិស្សថ្នាក់ទី4-8ម្នាក់ៗ នឹងជាចំនួន 120 ភាគរយនៃចំនួនទឹកប្រាក់ផ្តល់ឱ្យដល់កូនសិស្ស K-3ម្នាក់ៗ ហើយចំនួនទឹកប្រាក់ផ្តល់ឱ្យដល់កូនសិស្សថ្នាក់ទី 9-12 ម្នាក់ៗនឹងត្រូវជាចំនួន 140ភាគរយនៃចំនួនទឹកប្រាក់ផ្តល់ឱ្យដល់កូន សិស្ស K-3 ម្នាក់ៗ។

(c) រាល់ LEA នីមួយៗត្រូវទទួលនូវចំនួនទឹកប្រាក់ផ្តល់ឱ្យដល់ K-3 ដូចគ្នា នៅពេលវាមានការចុះឈ្មោះចូលរៀនក្នុងថ្នាក់មត្តេយ្យ រហូតដល់ ថ្នាក់ទី 3 បញ្ចូលគ្នា។ ចំនួនទឹកប្រាក់ផ្តល់ឱ្យពីថ្នាក់ទី 4-8 ដូចគ្នា នៅពេលវាមានការចុះឈ្មោះចូលរៀនក្នុងថ្នាក់ទី 4 រហូតដល់ថ្នាក់ទី 8 បញ្ចូលគ្នា។ ហើយចំនួយទឹកប្រាក់ផ្តល់ឱ្យដល់ ថ្នាក់ទី 9-12 ដូចគ្នា នៅពេលវាមានការចុះឈ្មោះក្នុងថ្នាក់ទី 9 រហូតដល់ ថ្នាក់ទី 12 បញ្ចូលគ្នា។

(d) រាល់ទឹកប្រាក់នីមួយៗដែលបានផ្តល់ឱ្យកូនសិស្សម្នាក់ៗត្រូវបានរក្សាទុកសម្រាប់សាលារៀន K-12 ដែលការចុះឈ្មោះចូលរៀន ក្នុងសលានេះបានផ្តល់នូវការកើនឡើងនូវលទ្ធភាពដែលអាចប្រើ ប្រាស់របស់ LEA សម្រាប់ទឹកប្រាក់នោះ។

(e) ការកែសម្រួលកម្រិតថ្នាក់ ដែលត្រូវបានផ្តល់ក្នុងចំណុច (a) និង (b) នឹងជាការងាកចេញតែមួយគត់ ក្នុងការចែកចាយដល់កូនសិស្សម្នាក់ៗនូវមូលនិធិកម្មវិធីអប់រំចំពោះសាលារៀន K-12 ទាំង អស់ ដោយអាស្រ័យលើការចុះឈ្មោះចូលរៀនរបស់ពួកគេ។

14806. ក្នុងចំណោមប្រាក់ចំណូលដែលអាចរកបាន ដែលត្រូវ បែងចែងសម្រាប់ការចែកចាយជាត្រីមាសទៅឱ្យ LEAs ស្ថិតក្រោមចំណុច (b) នៃវគ្គ 14804 អ្នកត្រួតត្រានឹងចែកចាយ 18 ភាគរយ ធ្វើជាការផ្តល់ឱ្យកូនសិស្សដែលមានប្រាក់ចំណូលទាប ម្នាក់ៗ។ ចំនួន និងទំហំនៃទឹកប្រាក់ដែលផ្តល់ឱ្យក្នុងកូនសិស្សដែល មានប្រាក់ចំណូលទាបម្នាក់ៗ ដើម្បីត្រូវបានគេលៃទុកសម្រាប់រាល់ សាលារៀន K-12 ស្ថិតក្រោមយុត្តិការរបស់ LEA ត្រូវដូចខាង ក្រោម:

(a) ផ្អែកលើការចុះឈ្មោះចូលរៀនសរុបរបស់កូនសិស្សទូទាំងរដ្ឋក្នុងសាលារៀន K-12 ទាំងអស់ដែលត្រូវបានគេកំណត់អត្តសញ្ញាណ ថាអាចទទួលបានសិទ្ធិសម្រាប់អាហារដោយឥតគិតថ្លៃស្ថិតក្រោម សេចក្តីណែនាំទទួលបានប្រាក់ចំណូល ដែលបានបង្កើតឡើងដោយក្រសួងកសិកម្មសហរដ្ឋអាមេរិក ដើម្បីអនុវត្តច្បាប់អាហារថ្ងៃត្រង់របស់ សាលារៀនថ្នាក់ជាតិ Richard B. Russell របស់សហព័ន្ធ និងច្បាប់អាហារូបត្ថម្ភកុមារ សហព័ន្ធឆ្នាំ 1966 ("កូនសិស្សដែលទទួលបានសិទ្ធិអាហារដោយឥតគិតថ្លៃ") អ្នកត្រួតពិនិត្យនឹងត្រូវបង្កើតនូវឯកសណ្ឋានប្រាក់ផ្តល់ ឱ្យកូនសិស្សម្នាក់ៗទូទាំងរដ្ឋ ដើម្បីផ្តល់ការគាំទ្រការអប់រំ បន្ថែម សម្រាប់កូនសិស្សដែលមានប្រាក់ចំណូលទាប ទាំងនេះ ("ការផ្តល់ប្រាក់សម្រាប់កូនសិស្សដែលមានប្រាក់ចំណូលទាប")។

(b) LEA នីមួយៗនឹងត្រូវទទួលបានចំនួនប្រាក់ផ្តល់ឱ្យសម្រាប់កូនសិស្សដែលមានប្រាក់ចំណូលទាប ដូចដែលវាមានកូនសិស្សដែល អាចទទួលបានអាហារឥតគិតថ្លៃ។

(c) រាល់ការផ្តល់ប្រាក់ឱ្យកូនសិស្សម្នាក់ៗដែលបានប្រាក់ចំណូលទាបនឹងត្រូវបានរក្សាទុកសម្រាប់សាលារៀនថ្នាក់ K-12 ជាក់លាក់ ដែលកូនសិស្សដែលអាចទទួលបានអាហារឥតគិតថ្លៃបានផ្តល់នូវការកើនឡើងនូវលទ្ធភាពដែលអាចប្រើប្រាស់របស់ LEA សម្រាប់ទឹកប្រាក់នោះ។

14807. ក្នុងចំណោមប្រាក់ចំណូលដែលមាន ដែលត្រូវបានរក្សាទុកសម្រាប់ការចែកចាយជាត្រីមាសទៅកាន់ LEAs នៅក្រោមចំណុច (b) នៃវគ្គទី 140804 អ្នកត្រួតពិនិត្យនឹង ចែកចាយនូវចំនួន 12 ភាគរយ សម្រាប់ទឹកប្រាក់ដែលផ្តល់លើ សម្ភារៈបណ្តុះបណ្តាល បច្ចេកទេស និងសម្ភារៈបង្រៀនជាលក្ខណៈសម្រាប់កូនសិស្សម្នាក់។ ចំនួន និងទំហំនៃការផ្តល់ទឹកប្រាក់ទាំងនេះដែលនឹងត្រូវចែកចាយដល់ LEA នីមួយៗ ហើយចំនួន និងទំហំនៃការផ្តល់ទឹកប្រាក់ទាំងនេះដែលនឹងត្រូវរក្សាទុក សំរាប់ សាលារៀន K-12នីមួយៗ ស្ថិតក្រោមយុត្តិការរបស់ LEA នឹងធ្វើដូចតទៅនេះ៖

(a) ផ្អែកលើការចុះឈ្មោះចូលរៀនសរុបរបស់កូនសិស្សទូទាំងរដ្ឋ ក្នុងសាលារៀន K-12 ទាំងអស់ អ្នកត្រួតត្រានឹងបង្កើតនូវការផ្តល់ប្រាក់ដល់កូនសិស្សទូទាំងរដ្ឋស្មើៗគ្នា ដើម្បីគាំទ្រដល់ជំនាញអប់រំនានាដែលត្រូវបានបង្កើនសម្រាប់បុគ្គលិកសាលារៀន K-12 និង បច្ចេកវិទ្យាទាន់សម័យ និងសម្ភារៈបង្រៀននានា ("ការផ្តល់ ប្រាក់លើសម្ភារៈបង្រៀន បច្ចេកវិទ្យា និងការបណ្តុះបណ្តាល" ឬ "ការផ្តល់ប្រាក់ 3T") ។

(b) រាល់ LEA នីមួយៗត្រូវទទួលបាននូវចំនួនទឹកប្រាក់ផ្តល់ឱ្យ 3T ស្មើគ្នាពេលដែលវាមានកូនសិស្ស ដោយផ្អែកលើការចុះឈ្មោះរបស់ LEA ។

(c) រាល់ការផ្តល់ 3T ដល់កូនសិស្សទាំងនេះនឹងត្រូវបានគេ រក្សាទុកសម្រាប់សាលារៀន K-12 ជាក់លាក់ណាមួយដែលការ ចុះឈ្មោះចូលរៀនរបស់វាបានផ្តល់ឱ្យនូវការកើនឡើងនូវសិទ្ធិដែល LEA អាចទទួលបានសម្រាប់ការផ្តល់ប្រាក់នេះ។

14808. (a) ជាមួយនឹងការលើកលែងគ្មានកំណត់ដែលត្រូវបានផ្តល់ឱ្យក្នុងកថាខណ្ឌ (2) នៃចំណុច (c) មូលនិធិ LEAs ទទួលបានដោយយោងតាមវគ្គ 14805, 14806 និង 14807 នឹងត្រូវបាន ចំណាយ ឬត្រូវបានដាក់កម្រិតតែមួយគត់នៅសាលារៀន K-12 ជាក់លាក់មួយ ដែលពួកគេត្រូវបានរក្សាទុកសម្រាប់ ដោយយោង តាមចំណុច (d) នៃវគ្គ 14805 ចំណុច (c) នៃ វគ្គ 14806 និង ចំណុច (c) នៃវគ្គ 14807 តាមលំដាប់លំដោយ និងត្រូវបានប្រើ ប្រាស់ យ៉ាងទូលំទូលាយសម្រាប់តែគោលបំណង ដែលបានផ្តល់សិទ្ធិឱ្យដោយវគ្គនេះ។

(b) កម្មវិធីអប់រំ និងការផ្តល់ប្រាក់ដល់កូនសិស្សដែលទទួលបាន ប្រាក់ចំណូលទាបអាចត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីអប់រំនានា ឬ រហូតដល់ចំនួនសរុប 200 ភាគរយនៃការផ្តល់ប្រាក់ 3T របស់សាលា រៀនណាមួយសម្រាប់គោលបំណងណាមួយដែលត្រូវបានអនុញ្ញាត សម្រាប់ការផ្តល់ប្រាក់ 3T មួយ។ ការផ្តល់ប្រាក់ 3T នឹងត្រូវបាន ចំណាយយ៉ាងទូលំទូលាយ

38

*សម្រាប់សម្ភារៈបង្រៀនទាន់សម័យ និង បច្ចេកវិទ្យា និងដើម្បីពង្រឹងជំនាញនៃបុគ្គលិកសាលារៀន ក្នុងមធ្យោ បាយនានា ដែលលើកកម្ពស់ការបំពេញការសិក្សារបស់កូនសិស្ស អត្រាបញ្ចប់ការសិក្សានិងការត្រៀមលក្ខណៈវិជ្ជាជីវៈ អាជីព មហាវិទ្យាល័យ និងការត្រៀមខ្លួនក្នុងជីវិត។*

*(c) (1) ក្រៅពីត្រូវបានផ្តល់ដោយជាក់លាក់សម្រាប់កថាខណ្ឌ (2) មូលនិធិដែលបានទទួលទាំងអស់ ដោយយោងតាមវគ្គ 14805 ដល់ 14807 បញ្ចូលគ្នា នឹងត្រូវបានចំណាយសម្រាប់តែ បញ្ញត្តិផ្ទាល់នៃសេវាកម្មឬសម្ភារៈនៅទីតាំងសាលារៀន K-12 តែប៉ុណ្ណោះ និងមិនត្រូវបានចំណាយនៅលើសេវាកម្ម ឬសម្ភារៈដែល មិនមែនត្រូវបានយកមកឱ្យដោយរូបរាងខាងក្រៅទៅកាន់សាលារៀន ឬកូនសិស្សរបស់វា និងមិនសម្រាប់បុគ្គលការិយាល័យពេញម៉ោង ណាមួយ ដែលមិនបានចំណាយយ៉ាងតិចណា 90 ភាគរយនៃពេល វេលាដែលបានផ្តល់ឱ្យពួកគេ ជារូបរាងខាងក្រៅដែលបង្ហាញនៅ សាលារៀននេះ ឬជាមួយកូនសិស្សម្នាក់ៗរបស់សាលារៀន និងមិន សម្រាប់បុគ្គលិកការិយាល័យណាមួយ លើកលែងក្នុងការគ្របដណ្តប់នូវចំនួនពេលវេលាដែលបុគ្គលិកការិយាល័យដែលបាន បង្ហាញនូវរូបរាងខាងក្រៅនៅសាលារៀន ឬជាមួយកូនសិស្សម្នាក់ៗ របស់សាលារៀន ឬមិនសម្រាប់ថ្លៃចំណាយរដ្ឋបាលដោយផ្ទាល់ និងមិនផ្ទាល់ ដែលបានធ្វើឱ្យកើតឡើងដោយ LEA។*

*(2) (A) គណកម្មការគ្រប់គ្រងនៃ LEA ម្នាក់ៗ អាចដកទុក លើមូលដ្ឋានភាគរយស្មើគ្នាមួយ ពីថវិកាដែលបានផ្តល់ឱ្យកូនសិស្ស ម្នាក់ៗដែលទទួលចំនួនដែលគ្រប់គ្រងក្នុងគ្របដណ្តប់ថ្លៃចំណាយ ពិតប្រាកដរបស់វា ដោយយោងតាមការប្រជុំជាសាធារណៈរបស់វគ្គ នេះ ការធ្វើសវនការ ថវិកា និងតំរូវការបាយការណ៍នានា។ មូលនិធិនានាដែលបានដកទុកសម្រាប់គោលបំណងបែបទាំងនេះ នឹងមិនត្រូវឱ្យលើសពី 2 ភាគរយ នៃថវិកាដែលបានផ្តល់ឱ្យទាំង ស្រុង ដែលបានទទួលបានក្នុងអំឡុងពេលពីឆ្នាំណាមួយដែលមានជាមធ្យម 1 ភាគរយក្នុងមួយឆ្នាំ។*

*(B) ថ្លៃចំណាយលើកម្មវិធីលើកកម្ពស់ជំនាញ ដែលបានផ្តល់ឱ្យ ចេញពីទីតាំងនេះដល់សមាជិកនានា របស់បុគ្គលិកសាលារៀនជាពិសេសស ដើម្បីធ្វើឱ្យជំនាញពួកគេប្រសើរឡើងនៃទីតាំងនេះ ឬ ទៅដល់កូនសិស្សរបស់សាលារៀននេះ អាចត្រូវបានគ្របដណ្តប់ ដោយថវិកាដែលបានផ្តល់ឱ្យកូនសិស្សម្នាក់ៗទាំងនេះ នៅពេល ខចែងក្រៅទីតាំងនៃសេវាបែបទាំងនេះ គឺមានតម្លៃល្អជាង ទឹកប្រាក់ដែលបានផ្តល់ឱ្យ ជាជាងខចែងនៅក្នុងទីតាំង។*

*(d) មិនមានមូលនិធិ CETFនានានឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើនប្រាក់ខែ ឬផលប្រយោជន៍សម្រាប់បុគ្គលិកការិយាល័យណា មួយ ឬប្រភេទនៃបុគ្គលិកការិយាល័យ លើសពីប្រាក់ខែ និងផលប្រយោជន៍ដែលបានស្ថិតនៅកន្លែងសម្រាប់បុគ្គលិកការិយាល័យទាំងនោះ ឬប្រភេទបុគ្គលិកការិយាល័យនោះ ចាប់ពីថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2012 ទោះបីជាយ៉ាងណា ប្រសិនបើត្រូវបានផ្តល់មូល និធិទាំងស្រុង ឬដោយវគ្គ ដោយច្បាប់នេះ អាចទទួលពីមូលនិធិ CETF នូវការដំឡើងប្រាក់ខែ និងផលប្រយោជន៍ ដែលទទួលធ្វើ ដោយគណៈគ្រប់គ្រង និងស្មើនឹងការដំឡើងដែលកំពុងត្រូវបាន ទទួលដោយអ្នកដទៃ ដូចជានិយោជិកក្នុងសាលារៀននេះ លើ មូលដ្ឋានសមាមាត្រចំពោះស្ថានភាពពេញម៉ោង ឬក្រៅម៉ោងរបស់ ពួកគេ ។*



*14809. មិនលើសពី 30 ថ្ងៃបន្តបន្ទាប់ពីការបំរុងបែងចែកជាត្រីមាស នីមួយៗនៃមូលនិធិ CETF គណៈកម្មការត្រួតពិនិត្យសារពើពន្ធនឹងត្រូវបង្កើតបញ្ជី LEA នីមួយៗ ដែលបានទទួលនូវមូលនិធិ និងចំនួនទឹកប្រាក់មូលនិធិដែលត្រូវបានបំរុងទុកសម្រាប់សាលារៀននីមួយៗ នៅក្នុង LEA នោះ ស្ថិតក្រោមប្រភេទនៃការផ្តល់មូលនិធិនីមួយៗ ដែលត្រូវបានបញ្ជាក់ក្នុងវគ្គទី 14805, 14806, និង 4807។ គណៈកម្មការត្រូវបោះពុម្ពផ្សាយបញ្ជីនេះក្នុងប្រព័ន្ធអ៊ីនធើណែត នៅទីកន្លែង ស័ក្តិសមមួយ ហើយអ្នកមើលការខុសត្រូវនឹងត្រូវបោះពុម្ពផ្សាយនូវ តំណភ្ជាប់ទៅក្នុងប្រព័ន្ធដែលរៀបរាប់ក្នុងចំណុចដ៏ធំមួយនៅលើទំព័រ ដើមនៃគេហទំព័រអ៊ីធើណេតរបស់អ្នកមើលការខុសត្រូវ។*

*14810. មិនទាំងអង្គនីតិបញ្ញត្តិ ឬអភិបាល ឬមិនទាំងរដ្ឋដទៃ ឬអង្គភាពរដ្ឋាភិបាលក្នុងតំបន់ លើកលែងតែគណៈកម្មការគ្រប់គ្រង LEA ដែលមាននូវយុត្តិការប្រតិបត្តិការ ទៅលើសាលារៀន និងត្រូវ ដឹកនាំពីរបៀបដែលមូលនិធិ CETF ត្រូវបានគេប្រើប្រាស់នៅ សាលារៀននោះ។ រាល់គណៈគ្រប់គ្រងត្រូវបានធរមានផ្តាច់មុខនៅ លើការសម្រេចចិត្តនោះ ទោះបីជាយ៉ាងណាវាអាស្រ័យដូចតទៅ នេះ*

*(a) រាល់ឆ្នាំ គណៈកម្មការគ្រប់គ្រង ដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងនានាដែលស័ក្តិសម ត្រូវស្វែងរកការបញ្ចូល នៅក្នុងការប្រជុំ ជាសាធារណៈបើកទូលាយជាមួយ ឪពុកម្តាយរបស់សាលារៀន លោកគ្រូអ្នកគ្រូ បុគ្គលិករដ្ឋបាល បុគ្គលិកសាលារៀនដទៃទៀត និងកូនសិស្ស ដែលស័ក្តិសម ("សហគមសាលារៀន") នៅឯ ឬនៅ ក្បែរទីតាំងសាលារៀន អំពីរបៀបដែលមូលនិធិ CETF នឹងត្រូវបាន ប្រើប្រាស់នៃសាលារៀននោះ និងពីមូលហេតុ។*

*(b) បន្ទាប់ពីការប្រជុំនោះ LEA ឬអ្នកតំណាងដែលស័ក្តិសម ត្រូវផ្តល់នូវការណែនាំជាលាយលក្ខណ៍អក្សរសម្រាប់ការប្រើប្រាស់ នូវមូលនិធិ CETF នៃក្នុងការប្រជុំជាសាធារណៈបើកទូលាយនៅឯ ឬនៅក្បែរទីតាំងសាលារៀនដែលសហគមសាលារៀនត្រូវបានគេ ផ្តល់នូវឱកាសដើម្បីឆ្លើយតបទៅនឹងការណែនាំរបស់ LEA។*

*(c) គណៈកម្មការគ្រប់គ្រងត្រូវធានាថា ក្នុងកំឡុងពេលធ្វើប្រតិបត្តិ ក្នុងការសម្រេចចិត្ត ដែលទាក់ទងនឹងការប្រើប្រាស់មូលនិធិ CETF សមាជិកសហគមសាលារៀនទាំងអស់នេះត្រូវបានផ្តល់ឱ្យនូវឱកាស ក្នុងការដាក់ជូននូវយោបល់នេះជាលាយលក្ខណ៍អក្សរ ឬទៅក្នុងប្រព័ន្ធអ៊ីនធើណែត។*

*(d) នៅពេលដែលគណៈកម្មការនេះធ្វើការសម្រេចរបស់ខ្លួនអំពី ការប្រើប្រាស់មូលនិធិ រាល់ឆ្នាំ គណៈកម្មការគ្រប់គ្រងត្រូវពន្យល់ជា សាធារណៈនិងក្នុងប្រព័ន្ធ ពីរបៀបដែលការចំណាយនៃមូលនិធិ CETF ដែលបានស្នើសុំរបស់ខ្លួននឹងត្រូវកំណត់ ថាតើលទ្ធផល ដែល បានធ្វើឱ្យប្រសើរទាំងនោះបានទទួលជោគជ័យឬក៏អត់។*

*14811. (a)ខណៈពេលលក្ខខណ្ឌនៃការទទួលបានមូលនិធិ CETF រាល់ LEA នីមួយៗគួរតែបង្កើតនូវគណនីដាច់ដោយឡែក ពីគ្នា សម្រាប់ការទទួលនិងសម្រាប់ការចំណាយថវិការដែលគណនី នោះត្រូវ តែមានការកំណត់ឲ្យច្បាស់លាស់ដូចគណនី California Education Trust Fund នោះផងដែរ។ LEA នីមួយៗ គួរតែបម្រុង និងចំណាយ មូលនិធិនៅក្នុងគណនីឲ្យសមស្របទៅនឹងមាត្រា 14805ដល់ 14808 បញ្ចូលគ្នា។*

*(b) សវនកម្មហិរញ្ញវត្ថុដែលឯករាជ្យ និងសមស្របតំរូវឲ្យមាន សាលាថ្នាក់ស្រុក ព្រមទាំងតំរូវការទាំងឡាយផ្សេងទៀតនៃច្បាប់បញ្ជាក់និងផ្ទៀងផ្ទាត់ថាតើមូលនិធិ CETF ត្រូវបានចែកចាយ និងចំណាយ ត្រឹមត្រូវដូចមាត្រានេះដែរឬទេ។ តំរូវការនេះគួរ តែត្រូវបានបន្ថែមទៅកាន់តំរូវការដែលបានណែនាំសម្រាប់ការ ធ្វើសវនកម្មសម្រាប់សាលាថ្នាក់ស្រុក និងគួរតែជាវគ្គមួយនៃរបាយ ការណ៍សវនកម្មដែលបានផ្ទៀងផ្ទាត់និងបានត្រួតពិនិត្យដោយអ្នក គ្រប់គ្រងសមស្របទៅនឹងវគ្គ 14504 ។*

*(c) LEAs គួរតែត្រូវបានរៀបចំធ្វើជារៀងរាល់ឆ្នាំ និងប្រកាសតាមរយៈបណ្តាញអ៊ិនធឺណិតរបស់ពួកគេ ក្នុងរយៈពេល60ថ្ងៃបន្ទាប់ពីការ បិទវគ្គក្នុងឆ្នាំសិក្សានីមួយៗពួកគេ*

*ត្រូវតែប្រកាសរបាយការណ៍មូលនិធិដែលត្រូវបានចំណាយក្នុងឆ្នាំ សិក្សានីមួយៗប្រកបដោយតម្លាភាពនិងច្បាស់លាស់តាមយុត្តាធិការរបស់ពួកគេ និងអំពីគោលដៅដែលត្រូវចំណាយដូចដែលបានចែងឡើងវិញសម្រាប់សាលារៀនក្នុងសហគមន៍តាមវគ្គ14810រហូតដល់គោលដៅត្រូវបានទទួល។មន្ត្រីវគ្គអប់រំជាន់ខ្ពស់គួរតែផ្តល់នូវតំណនៅលើតំបន់បណ្តាញតាមរយៈអ៊ីនធឺណិតរបស់ពួកគេដើម្បីឲ្យសមាជិកនៅក្នុងសហគមន៍និងអ្នកសិក្សាស្រាវជ្រាវគ្រប់រូបអាចចូលមើលរបាយការណ៍ដែលបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីរបាយការណ៍ទាំងនោះត្រូវបានប្រកាសដោយ LEAs។*

*14812. (a) នៅដើមឆ្នាំសិក្សា 2012-13 ដូចដែលបានចែងដោយ លក្ខខណ្ឌនៃការទទួលមូលនិធិ CETF ក្រុមអភិបាលកិច្ច LEA នីមួយៗ ដែលនឹងទទួលបានមូលនិធិនៅក្រោមច្បាប់នេះគួរតែបង្កើត និងធ្វើការផ្សព្វផ្សាយអំពីថវិកាសម្រាប់គ្រប់សាលារៀន ទាំងអស់តាមរយៈយុត្តាធិការរបស់ LEA ដើម្បីប្រៀបធៀប មូលនិធិ និងការចំណាយជាក់ស្តែងសម្រាប់សាលារៀនចាប់ពីដើមឆ្នាំនៃសារពើពន្ធនិងរវាងមូលនិធិជាកញ្ចប់ថវិកានិងការចំណាយសម្រាប់សាលានៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន។ អ្នកគ្រប់គ្រងវគ្គអប់រំជាន់ខ្ពស់គួរតែផ្តល់នូវតំណដែលនឹងអាចអនុញ្ញាតិឲ្យសមាជិកនៅក្នុងសហគមន៍ និងអ្នកសិក្សាស្រាវជ្រាវគ្រប់រូបអាចចូលមើលព័ត៌មាន អំពីថវិកាសម្រាប់ឆ្នាំសិក្សា*

ថ្មី និងឆ្នាំសិក្សាចាស់ដោយរាប់គិត ចាប់ពីឆ្នាំសិក្សា 2012-13។ ថវិកានេះគួរតែបង្ហាញអំពីប្រភពនិងចំនួន មូលនិធិ ទាំងអស់ដែលកំពុងតែត្រូវបានចំណាយនៅឯសាលារៀន បូករួមទាំងថវិកាដែលត្រូវបានផ្តល់ក្រោមមាត្រានេះនិងអំពីរបៀបចំណាយតាមប្រភេទនៃប្រភពថវិកានីមួយៗលើតំបន់បណ្តាញតាមរយៈអ៊ីនធឺណិត ។ ថវិកាគួរតែមានភាពសមស្របតាមការដែលបានកំណត់និងអនុម័តដោយមន្ត្រីវគ្គអប់រំជាន់ខ្ពស់។ ការចំណាយគួរតែត្រូវបានធ្វើ របាយការណ៍សរុបសម្រាប់រាល់សិស្សម្នាក់ៗនិងតាមរយៈប្រាក់ខែជាមធ្យមរបស់គ្រូបង្រៀនព្រមទាំងតាមសម្ភារៈឧបទ្ទេស ការគ្រប់គ្រង តំហែទាំ និងតាមរយៈប្រភេទសម្ភារៈសំខាន់ៗផ្សេងទៀត ។ ក្រសួងអប់រំគួរតែធ្វើការតំរូវ និងធានាថាសាលារៀនថ្នាក់ស្រុក និងកម្រងសាលារៀនទាំងមូលធ្វើការរាយការណ៍អំពីរបាយការណ៍ចំណាយមួយដែលមានភាពស្របគ្នា និងខុសគ្នារវាងការចំណាយ របស់សាលាថ្នាក់ស្រុកនិងសាលាទូទៅ។ ថវិកាក៏គួរតែត្រូវ បានរួមបញ្ចូលនូវការចំណាយរបស់បុគ្គលិកតាមចំនួន ប្រភេទ និងឋានៈខ្ពង់ខ្ពស់របស់បុគ្គលិក និងការប្រើប្រាស់ជាក់ស្តែង និងចំនួនខ្ទង់ដែលបានទទួលសម្រាប់បុគ្គលិកនៅតាមសាលាដោយមិនមានព័ត៌មានដែលបានកំណត់ដាច់ដោយឡែកពីគ្នាផងដែរ។ រាល់ថ្នាក់ K-12 ដែលបានទទួលលុយមូលនិធិជឿជាក់លើការអប់ រំរដ្ឋកាលីហ្វ័រញ៉ា ក៏ត្រូវតែរួមបញ្ចូលមូលនិធិទាំងនេះជាវគ្គមួយដាច់ ដោយឡែកពីគ្នានៅក្នុងផែនការសាលាតែមួយដែលសមស្របទៅ នឹងលក្ខណវិនិច្ឆ័យនៃចំណុច (d) (f) និង (h) នៃចំណុច64001។

(b)ចំណែកដែលបានមកពីមូលនិធិជឿជាក់លើការអប់រំរដ្ឋកាលីហ្វ័រញ៉ានឹងត្រូវបានផ្តល់ដល់សិស្សដោយមានការគាំទ្របន្ថែម ហើយ ក្រៅពីនេះត្រូវបានផ្តល់តាមរយៈប្រភពស្ថាប័នរដ្ឋ តាមរយៈមូលដ្ឋាននិងសហព័ន្ធ។ ដើមឆ្នាំសារពើពន្ធ 2013-14 LEAs នឹងបង្កើតនូវ រាល់កិច្ចខំប្រឹងប្រែងដ៏សមហេតុផល ដើម្បីធ្វើឲ្យមូលនិធិដែល ទទួលបាន ក្រៅពីលក្ខខណ្ឌដែលបានចែងនៅក្នុងមាត្រានេះ សម្រាប់រាល់ការចំណាយរបស់សិស្សម្នាក់ៗនៅតាមសាលា យ៉ាងហោចណាស់ឲ្យមានស្ថិរភាពស្មើរនឹងឆ្នាំសារពើពន្ធ 2012-13 និងលៃសម្រាប់ការផ្លាស់ប្តូរដែលទាក់ទងនឹងការចំណាយនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ការធ្វើដូច្នេះត្រូវបានគេហៅថា "ការរក្សានូវយុទ្ធសាស្ត្រនៃកិច្ចខំប្រឹងប្រែង"សម្រាប់សាលារៀននោះ ។ ថវិកាក្នុងកម្រងសាលាតែមួយត្រូវបានទាមទារដោយចំណុច (a) នឹងត្រូវរួមបញ្ចូលនូវរបាយការណ៍ច្បាស់លាស់ អំពីការចំណាយ នៅក្នុងសាលារៀនក្នុងឆ្នាំសារពើពន្ធ201213 ក្រៅពីប្រភពមូលនិធិដែលបានផ្តល់ដោយវគ្គតូចៗនេះនិងការឆ្លុះបញ្ចាំអំពីរាល់ការចំណាយសម្រាប់ឆ្នាំសិក្សាថ្មីប្រសិនបើសាលានោះ អាចបំពេញនូវ ោលការណ៍ ការរក្សាយុទ្ធសាស្ត្រនៃកិច្ចខំប្រឹងប្រែងរបស់វា។ ប្រសិនបើនៅក្នុងឆ្នាំណាមួយ LEA មិនអាចបំពេញនូវគោលការណ៍ ការថែរក្សាយុទ្ធសាស្ត្រនៃកិច្ចខំប្រឹងប្រែងរបស់វាសម្រាប់សាលារៀនណាមួយនោះ LEA នឹងធ្វើការពន្យល់អំពីថវិកាតាមសាលារៀនរបស់វាសំរាប់សាលានោះនិងគួរពិភាក្សានៅឯកិច្ចប្រជុំជាសាធារណៈ នឹងត្រូវបានប្រារព្ធធ្វើនៅក្បែរ ឬនៅជិតទីធ្លាសាលាដើម្បីឲ្យ ស្របទៅនឹងវគ្គ 14810។ នៅក្នុងកិច្ចប្រជុំនោះ មន្ត្រីនានាដែលមកពី LEA នឹងធ្វើការបង្ហាញនូវមូលហេតុដែលមិនអាចបំពេញតាម ការរក្សាយុទ្ធសាស្ត្រនៃកិច្ចខំប្រឹងប្រែង សម្រាប់សាលានោះ ជា ពិសេសតែម្តងព្រមទាំងពន្យល់អំពីរបៀបដែលភ្នាក់ងារស្នើទុកនូវ ភាពបរាជ័យដើម្បីបំពេញយុទ្ធសាស្ត្រដែលផ្តល់ជាផល អវិជ្ជមាន ទៅលើសិស្ស និងគ្រួសាររបស់ពួកគេ។

14813. (a) មូលនិធិបែងចែកស្របតាមចំណុច (a) នៃវគ្គលេខ14802.1 និងមូលនិធិ CETF ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាត្រួតពិនិត្យសារពើពន្ធដើម្បីនាំមុខទាំងចំណូល និងក្រុមប្រឹក្សា ហើយចំណាយលើសំណងជាក់ស្តែងស្របតាមវគ្គលេខ 14803 ត្រូវផ្ទេររៀងរាល់ត្រីមាសទៅមូលនិធិសេវាកម្មបំណុលការអប់រំដោយអ្នកត្រួតពិនិត្យ ដែលត្រូវបានបង្កើតឡើងនៅក្នុងរតនាគារ ។ ថវិកា មូលនិធិសេវាកម្មបំណុលការអប់រំត្រូវធ្វើឡើងដោយសេចក្តីទុកចិត្ត ហើយដោយមិនគិតពីវគ្គលេខ 13340 នៃលេខកូដរដ្ឋាភិបាលមានលក្ខណៈសមស្របជាបន្តតាមឆ្នាំសារពើពន្ធសម្រាប់គោលបំណងពិសេសមាននៅក្នុងវគ្គនេះ។

(b) ថវិកានៅក្នុងមូលនិធិសេវាកម្មបំណុលការអប់រំត្រូវយកទៅប្រើទាំងស្រុងក្នុងការបង់ថ្លៃសេវាកម្មបំណុលជាទម្រង់ប័ណ្ណបំណុល ឬដើម្បីលោះ ឬដើម្បីបន្ថយថ្លៃប័ណ្ណបំណុល ដែលកើនជាបន្តបន្ទាប់តាមឆ្នាំសារពើពន្ធដែល (1) ធ្លាប់ត្រូវ ឬត្រូវចេញដោយរដ្ឋសម្រាប់ការសាងសង់ ការសាងសង់ជាថ្មី ការធ្វើឱ្យប្រសើរឡើងវិញ ឬការជំនួសនៃថ្នាក់មុនមត្តេយ្យតាមរយៈសម្ភារៈថ្នាក់មហាវិទ្យាល័យរួមមាន សម្ភារៈសាលារៀនដែលបានផ្គត់ផ្គង់ និងដំឡើង ឬការទទួលបាន ឬការជួលចលនទ្រព្យសម្រាប់សម្ភារៈសាលារៀនទាំងនោះ ("ប័ណ្ណបំណុលសាលារៀន") ឬ (2) ក្នុងទំហំកំណត់មួយអនុញ្ញាតដោយវគ្គរង (c) ធ្លាប់ត្រូវ ឬត្រូវចេញដោយមន្ទីរពេទ្យកុមាររដ្ឋ ឬប័ណ្ណបំណុលជាប់កាតព្វកិច្ចទូទៅផ្សេងទៀត។

(c) ពីថវិកាផ្ទេរទៅមូលនិធិសេវាកម្មបំណុលការអប់រំ ដោយជាការកាត់បន្ថយការចំណាយទៅមូលនិធិទូទៅ អ្នកត្រួតពិនិត្យត្រូវផ្ទេរក្នុងចំនួនចាំបាច់ដើម្បីទូទាត់ការចំណាយលើការទូទាត់សេវាកម្មបំណុលនាពេលថ្មីៗ ដែលធ្វើឡើងពីមូលនិធិទូទៅលើប័ណ្ណបំណុលសាលារៀន មន្ទីរពេទ្យកុមារ ឬប័ណ្ណបំណុលជាប់កាតព្វកិច្ចផ្សេងទៀត ឬដើម្បីលោះ ឬកាត់បន្ថយប័ណ្ណបំណុលសាលារៀន មន្ទីរពេទ្យកុមារ ឬប័ណ្ណបំណុលជាប់កាតព្វកិច្ចផ្សេងទៀត ដូចត្រូវបានចាត់ចែងដោយប្រធានវគ្គហិរញ្ញវត្ថុថាមិនមានមូលនិធិណាក្នុងមូលនិធិសេវាកម្មបំណុលសាលារៀនត្រូវបានយកទៅប្រើដើម្បីលោះការចំណាយសេវាកម្មបំណុលនាពេលថ្មីៗលើប័ណ្ណបំណុលមន្ទីរពេទ្យកុមារ ឬប័ណ្ណបំណុលជាប់កាតព្វកិច្ចទូទៅផ្សេងទៀត ឬដើម្បីលោះ ឬបន្ថយ ថ្លៃប័ណ្ណមន្ទីរពេទ្យកុមារ ឬប័ណ្ណជាប់កាតព្វកិច្ចទូទៅផ្សេងទៀត រហូត និងលុះណាអ្នកត្រួតពិនិត្យបានសងទៅមូលនិធិទូទៅគ្រប់ចំនួនមុនគេសម្រាប់ការទូទាត់ចំណាយលើសេវាកម្មបំណុលនាពេលបច្ចុប្បន្នលើប័ណ្ណបំណុលសាលារៀន។ មូលនិធិត្រូវផ្ទេរមិនបង្កើតជានីតិវិធីមូលនិធិទូទៅនៃពន្ធស្របតាមមាត្រា XIII B នៃធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា សម្រាប់គោលបំណងក្នុងវគ្គលេខ 8 នៃមាត្រា XVI នៃធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

14814 (a) មិនយូរជាងប្រាំមួយខែក្រោយចប់ឆ្នាំសារពើពន្ធនីមួយៗ ក្រុមប្រឹក្សាត្រួតពិនិត្យសារពើពន្ធត្រូវធ្វើសវនកម្មឯករាជ្យមួយលើមូលនិធិទំនុកចិត្តការអប់រំរដ្ឋកាលីហ្វ័រញ៉ា ហើយត្រូវប្រគល់ទៅអង្គនីតិបញ្ញត្តិ និងទេសាភិបាល ហើយត្រូវផ្សាយលើគេហទំព័រប្រព័ន្ធអ៊ីនធឺណិតរបស់ក្រុមប្រឹក្សាត្រួតពិនិត្យសារពើពន្ធ ជាមួយលីងភ្ជាប់ទៅរបាយការណ៍បង្ហាញយ៉ាងច្បាស់នៅលើគេហទំព័រដើមទាំងរបាយការណ៍សវនកម្មពេញលេញ និងការសង្ខេបនូវលទ្ធផលងាយយល់នៃសវនកម្មនោះ។ របាយការណ៍ត្រូវរួមបញ្ចូលនូវគណនេយ្យនៃរាល់ទឹកប្រាក់ទាំងអស់របស់ពន្ធបន្ថែមផ្ទាល់ខ្លួន ដែលត្រូវបានបង្កើតឡើងស្របតាមវគ្គលេខ 17041.1 នៃលេខកូដចំណូល និងពន្ធ រាល់ការផ្ទេរទឹកប្រាក់ទាំងអស់នៃដំណើរការទាំងនោះទៅមូលនិធិទំនុកចិត្តការអប់រំរដ្ឋកាលីហ្វ័រញ៉ា ការរៀបរាប់ពី បរិមាណមូលនិធិទទួលបានពីមូលនិធិទំនុកចិត្តការអប់រំរដ្ឋកាលីហ្វ័រញ៉ា នៅឆ្នាំសារពើពន្ធនោះដោយ LEA និងសាលារៀននីមួយៗ ក្នុងដែនយុត្តាធិការរបស់ LEA និងការសង្ខេបមួយ ដោយផ្អែកលើរបាយការណ៍តំរូវដោយ LEAs ទាំងអស់ដោយចំណុច (c) នៃវគ្គលេខ 14811 ដែលបង្ហាញពីវិធី LEA នីមួយៗប្រើមូលនិធិនៅតាមសាលានីមួយៗរបស់ខ្លួន និងលទ្ធផលដែល LEA ស្វែងរក និងសម្រេចបាន។

(b) តាមការពិគ្រោះជាមួយក្រុមប្រឹក្សាត្រួតពិនិត្យសារពើពន្ធ អ្នកមើលការខុសត្រូវ ត្រូវរៀបចំ និងផ្តល់ឱ្យ LEA នីមួយៗ និងអ្នកផ្តល់ ECE នូវបែបបទ និងទម្រង់មួយ សម្រាប់ការធានាឱ្យមានការរាយការណ៍ព័ត៌មានជាសណ្ឋានតំរូវសម្រាប់របាយការណ៍ សវនកម្ម ។

(c) ចំណាយលើការធ្វើសវនកម្មប្រចាំឆ្នាំ និងការបង្កើត ការចែកចាយ និងការប្រមូលរបាយការណ៍ដែលត្រូវការ ត្រូវកំណត់ដោយក្រុមប្រឹក្សាត្រួតពិនិត្យសារពើពន្ធដើម្បីធានាបាននូវការប្រើប្រាស់មូលនិធិដោយប្រយ័ត្ន ខណៈធានាថាសម្រេចឱ្យបាននូវគោលបំណងនៃទង្វើនេះ។ ការចំណាយទាំងនោះត្រូវរួមបញ្ចូលក្នុងរបស់ដែលចំណាយជាក់ស្តែងត្រូវបានទូទាត់សម្រាប់មូលនិធិ CETF ស្របតាមចំណុច (b) នៃវគ្គលេខ 14802។

(d) ក្នុងពេលប្រតិបត្តិការ និងធ្វើរបាយការណ៍ពីការធ្វើសវនកម្មប្រចាំឆ្នាំ សវនករឯករាជ្យត្រូវរាយការណ៍ទៅមេធាវីជាន់ខ្ពស់ និងសាធារណជនពីការសង្ស័យលើការចាត់ចែង ឬប្រើប្រាស់មូលនិធិបំពានលើទង្វើនេះថាតើដោយក្រុមពិនិត្យសារពើពន្ធ ឬភ្នាក់ងារ ឬដោយ LEA ណាមួយ។

(e) រាល់បុគ្គលិកពាក់ព័ន្ធជាមួយការចាត់ចែង ឬការចែកមូលនិធិ តាមវគ្គលេខ 14803, 14804, 14805, 14806, និង14807 ដែលមិនបាន

38

ចាត់ចែង ឬបែងចែកមូលនិធិទៅ LEA នីមួយៗ និងសាលារៀននីមួយៗក្នុងតំបន់តាមមូលដ្ឋានសម្រាប់សិស្សម្នាក់ៗ ដូចមានបញ្ជាក់ក្នុងវគ្គទាំងនោះ ត្រូវជាប់ចោទពីការប្រព្រឹត្តបទឧក្រិដ្ឋត្រូវកាត់ទោសដោយមេធាវីជាន់ខ្ពស់ ឬប្រសិនបើលោក ឬនាងមិនបានប្រព្រឹត្តឱ្យបានត្រឹមត្រូវមេធាវីប្រចាំតំបន់ដោយស្របតាមចំណុច (b) ក្នុងវគ្គលេខ 425 នៃលេខកូដកំហុសព្រហ្មទណ្ឌ។ មេធាវីជាន់ខ្ពស់ ឬប្រសិនបើមេធាវីជាន់ខ្ពស់មិនបានប្រព្រឹត្ត មេធាវីប្រចាំតំបន់ត្រូវតាមដានដោយប្រុងប្រយ័ត្ន និងត្រូវរកទណ្ឌកម្មបទឧក្រិដ្ឋកម្ម និងបញ្ហាដោះលែងភ្លាមៗសម្រាប់ការចាត់ចែង ឬចែកចាយមូលនិធិដោយបំពានវគ្គលេខ 14803,14804,14805,14806, និង 14807។

វគ្គទី 5: វគ្គលេខ 46305 នៃលេខកូដការអប់រំត្រូវបានធ្វើវិសោធនកម្មឱ្យបកស្រាយថា ៖

46305. ថ្នាក់បឋមសិក្សា វិទ្យាល័យ និងតំបន់មានសាលារៀនរួម និងសាលារៀនធម្មនុញ្ញឯករាជ្យនីមួយៗ  ការិយាល័យការអប់រំប្រចាំតំបន់ និងសាលារៀនរបស់រដ្ឋ ត្រូវរាយការណ៍ទៅអ្នកចាត់ការការអប់រំជាសាធារណៈ ក្នុងទម្រង់រៀបចំដោយការិយាល័យអប់រំបន្ថែមលើវត្តមានទិន្នន័យត្រូវការការចុះឈ្មោះយ៉ាងសកម្មនៅថ្ងៃពុធសប្តាហ៍ទីបីនៃខែនីមួយៗ ហើយវត្តមានជាក់ស្តែងនៅថ្ងៃពុធសប្តាហ៍ទីបីនៃខែនីមួយៗ លើកលែងតែថា ប្រសិនបើថ្ងៃនោះគឺជាថ្ងៃឈប់សម្រាករបស់សាលារៀន ការចុះឈ្មោះយ៉ាងសកម្ម និងវត្តមានជាក់ស្តែងមុនថ្ងៃសិក្សាទីមួយត្រូវរាយការណ៍។ "ការចុះឈ្មោះយ៉ាងសកម្ម" នៅថ្ងៃចាប់ផ្តើមរាប់ គឺមានន័យថាសិស្សដែលចុះឈ្មោះទៀងទាត់តាមថ្ងៃ កំណត់របស់សាលានៅថ្ងៃទីមួយនៃឆ្នាំសិក្សា ដែលសាលារៀនចាប់ផ្តើម ដោយគិតទាំងអ្នកចុះឈ្មោះចូលរៀនតាមក្រោយ ដកសិស្សបោះបង់ចោលការសិក្សាចាប់តាំងពីថ្ងៃនោះ ដែលមិនមានវត្តមានយ៉ាងហោចណាស់មួយថ្ងៃ រវាងថ្ងៃដំបូងនៃឆ្នាំសិក្សា ឬថ្ងៃសិក្សាដំបូង បន្តទៅថ្ងៃបន្ទាប់ដែលគិតទៅតាមវគ្គនេះ ហើយនៅថ្ងៃដែលគិតការរាប់ អ្នកគ្រប់គ្រងត្រូវកែប្រែការបរិច្ឆេទការប្រមូល ឬវិធីសាស្ត្រដើម្បីកាត់បន្ថយកាតព្វកិច្ចរដ្ឋបាលរបស់ភ្នាក់ងារអប់រំក្នុងស្រុកក្នុងការអនុវត្តន៍វគ្គនេះ។

វគ្គទី 6: ជំពូកទី 1.8 (ចាប់ផ្តើមជាមួយវគ្គលេខ 8160) ត្រូវបញ្ចូលទៅផ្នែកទី 6 នៃការបែកចែកទី 1 ក្រោមប្រធានបទទី 1 មានចំណងជើងថាលេខកូដការអប់រំ ដើម្បីបកស្រាយថា ៖

*ជំពូក 1.8 កម្មវិធីធ្វើឲ្យប្រសើឡើង និងវត្ថារកម្មលើគុណភាពដើមកុមារភាព*

*មាត្រា 1. ខចែងទូទៅ*

8160. និយមន័យខាងក្រោមនេះ អាចប្រើបាន នៅក្នុងជំពូកនេះទាំង មូល ៖

(a) ពាក្យ "កម្មវិធីថែទាំពីក្មេង និងការអប់រំ" ឬ "កម្មវិធី ECE" មានន័យថាជាការថែទាំកុមារ មុនចូលសាលារៀន ដែលស្ថិតក្រោមការគាំទ្ររបស់រដ្ឋ ឬឧបត្ថម្ភធនដោយរដ្ឋ ឬកម្មវិធីអប់រំ និងការថែទាំរហ័សដែលគាំទ្រដោយរដ្ឋ និងឧបត្ថម្ភធនដោយរដ្ឋផ្សេងទៀត សម្រាប់កុមារ ចាប់តាំងពីចាប់កំណើតរហូតដល់អាចចូលរៀនថ្នាក់មត្តេយ្យ ដោយរួមមានកម្មវិធីដែលឧបត្ថម្ភទាំងស្រុង ឬមួយវគ្គពី មូលនិធិក្តីសង្ឃឹមកុមារ និងគ្រួសារកាលីហ្វ័រញ៉ា (California Children and Families Trust Fund) តែមិនដាក់កំហិតនោះទេ។ បើសិនជាកម្មវិធី ECE មិនត្រូវបានឧបត្ថម្ភធនផ្ទាល់មុខដោយមូលនិធិរដ្ឋទេ ពាក្យ "កម្មវិធី ECE" មានន័យថា មួយចំណែកក្នុងកម្មវិធីត្រូវបានឧបត្ថម្ភដោយរដ្ឋ។

(b) ពាក្យ "អ្នកផ្គត់ផ្គង់ ECE" ឬ "អ្នកផ្គត់ផ្គង់" មានន័យថាបុគ្គល ឬភ្នាក់ងារណាមួយដែលមានសិទ្ធិស្របច្បាប់ក្នុងការចែកចាយកម្មវិធី ECE។

(c) ពាក្យ "អត្រា បន្ត (Take-up rate)" មានន័យថាជាកម្រិតដែលអ្នកផ្គត់ផ្គង់ ECE ស្នើសុំ និងត្រូវបានទទួលមូលនិធិឧបត្ថម្ភកម្មវិធីក្រោមវិធានការរបស់ជំពូកនេះ។

(d) ពាក្យ "អត្រាសំណង" មានន័យថា ជាការការចំណាយលើកុមារម្នាក់ដែលអ្នកផ្គត់ផ្គង់ ECE ទទួលបាន ក្នុងនាមជាគ្រួសារមានសិទ្ធិ ពីមូលនិធិរដ្ឋដើម្បីផ្គត់ផ្គង់លើការចំណាយក្នុងការផ្តល់សេវាកម្ម ECE។

(e) ពាក្យ "មូលនិធិ ECE" មានន័យថាជាមូលនិធីដែលត្រូវបានបែងចែកឲ្យការអប់រំ និងការថែទាំរហ័សដោយអនុលោមតាមវគ្គ 14803 និង 14804។

(f) ពាក្យ "មូលនិធិ SAE" មានន័យថាជាមូលនិធិដែលត្រូវបានកំណត់សម្រាប់ពង្រឹង និងពង្រីកកម្មវិធី ECE ដោយអនុលោមតាមចំណុច (b) នៃវគ្គ 8161។

(g)ពាក្យ "កុមារស្ថិតក្នុងហានិភ័យខ្ពស់" មានន័យថា ជាកុមារដែលមកពីគ្រួសារបង្កើតមានប្រាក់ចំណូលទាប គ្រួសារចិញ្ចឹមមានប្រាក់ចំណូលទាប ឬមកពីក្រុមផ្ទះដែលមានប្រាក់ចំណូលទាប ហើយក៏ជាកុមារ (1) ដែលត្រូវបានចិញ្ចឹម ឬត្រូវបានទទួលសេវាកម្មការពារកុមារ (Child Protection Services) (2) ដែលជាកូនរបស់មាតាបិតាវ័យក្មេងដែលមាតិបិតាផ្ទាល់នោះក៏កំពុងស្ថិតក្នុងការចិញ្ចឹមបីបាច់ ឬ (3)ដែលត្រូវបានរំលោភបំពានមិនយកចិត្តទុកដាក់ ឬកេងប្រវ័ញ្ច ឬអាចស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភបំពានមិនយកចិត្តទុកដាក់ ឬកេងប្រវ័ញ្ច ដោយនឹងត្រូវកំណត់ជាបន្តដោយអ្នកមើលការខុសត្រូវ។

8161. មូលនិធិ ECE អាចត្រូវបានបែងចែករៀងរាល់ឆ្នាំ ដើម្បីឲ្យអ្នកមើលការខុសត្រូវប្រើប្រាស់ដូចខាងក្រោម៖

(a) មូលនិធិ ECE មិនលើសពី 23 ភាគរយ នឹងត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

(1) បីរយលានដុល្លារ (300,000,000 ដុល្លារ) សម្រាប់កម្មវិធី ECE ដែលមានស្រាប់ ដើម្បីស្តារមូលនិធិឲ្យដល់កម្រិតឆ្នាំសារពើពន្ធ 2008-09 ដើម្បីរួមចំណែកក្នុងការកាត់បន្ថយដែលត្រូវបានធ្វើឡើងចំពោះ កម្មវិធី ECE នីមួយៗនៅក្នុងឆ្នាំសារពើពន្ធ 2009-10 ដល់ 2012-13 ដោយមានកំណត់ដូចខាងក្រោម ៖

(A) ការស្តារឡើងវិញ នឹងធ្វើឲ្យបានស្មើៗគ្នាចំពោះការកាត់បន្ថយគ្រប់ប្រភេទ ដូចជាការកាត់បន្ថយភាពអាចទទួលយកបានរបស់កុមារ ការកាត់បន្ថយអត្រាសំណង ការកាត់បន្ថយទឹកប្រាក់ក្នុងកិច្ចសន្យាបច្ចុប្បន្ន បើពុំនោះដូចជាការកាត់បន្ថយលើចំនួនកិច្ចសន្យាដែលអនុញ្ញាតជាដើម។

(B) ទៅដល់កម្រិតមួយដែលអ្នកមើលការខុសត្រូវត្រូវបែងចែកមូលនិធិទៅឲ្យនាយកដ្ឋានសេវាកម្មសង្គមរបស់រដ្ឋ (State Department of Social Services) ឬភ្នាក់ងារជោគជ័យផ្សេងៗទៀត ដើម្បីសម្រេចការស្តារមូលនិធិនេះ គេអាចនឹងធ្វើបែបនេះ។  (C) បើសិនអ្នកមើលការខុសត្រូវនិងនាយកដ្ឋានសេវាកម្មសង្គមរបស់រដ្ឋ រកឃើញរួមគ្នាថា មូលនិធីណាមួយមិនអាចស្តារឡើងវិញ ដោយសារការធ្លាក់ចុះនៃអត្រាបន្ត (Take-up rate) មូលនិធិទាំងនោះ នឹងត្រូវប្រើប្រាស់សម្រាប់បង្កើនអត្រាសំណងគុណភាពមូលដ្ឋាន ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមចំណុច (b) នៃវគ្គ 8168។

(2) ប្រាំលានដុល្លារ (5,000,000 ដុល្លារ) សម្រាប់វគ្គផ្តល់អាជ្ញាប័ណ្ណថែទាំសុខភាពនៃនាយកដ្ឋានសេវាកម្មសង្គមរបស់រដ្ឋ (Community Care Licensing Division of the State Department of Social Services) ឬ ភ្នាក់ងារជោគជ័យអ្នកមួយ ដើម្បីបង្កើនភាពញឹកញាប់នៃការធ្វើអធិការកិច្ចផ្តល់អាជ្ញាប័ណ្ណលើអ្នកផ្គត់ផ្គង់ ECE ឲ្យលើសពីកម្រិតឆ្នាំសារពើពន្ធ 2011-12 ក្រោមកិច្ចព្រមព្រៀងដែលធ្វើឡើងដោយអ្នកមើលការខុសត្រូវ និងនាយកដ្ឋានសេវាកម្មសង្គមរបស់រដ្ឋ ឬភ្នាក់ងារជោគជ័យណាមួយ ដោយមិនឲ្យផុតពីថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2013។

(3) ច្រើនរហូតដល់ដប់លានដុល្លារ (10,000,000 ដុល្លារ) ដើម្បីអភិវឌ្ឍន៍ និងអនុវត្តកម្រងទិន្នន័យ ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមវគ្គ 8171 ដើម្បីធ្វើការតាមដានដំណើរការណ៍អប់រំរបស់កុមារ ដែលបានចូលរួមក្នុងកម្មវិធី ECE របស់រដ្ឋ។

(4) សែសិបលានដុល្លារ (40,000,000 ដុល្លារ) សម្រាប់អភិវឌ្ឍ អនុវត្ត និងរក្សាការកំណត់គុណភាពការរៀនរហ័ស និងប្រព័ន្ធកែលម្អ (ប្រព័ន្ធ QRIS) ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមមាត្រា 4 (ចាប់ផ្តើមពី វគ្គ 8167)។ មូលនិធិដែលត្រូវបានផ្តល់ឲ្យដោយវគ្គនេះ នឹងមិនត្រូវបានប្រើ ប្រាស់សម្រាប់បង្កើនអត្រាសំណងរបស់អ្នកផ្គត់ផ្គង់ ឬសំណងផ្សេងទៀត របស់អ្នកផ្គត់ផ្គង់ឡើយ ប៉ុន្តែប្រើដើម្បីបង្កើត អនុវត្ត និងវាយតម្លៃទៅលើ ប្រព័ន្ធសម្រាប់ការវាយតម្លៃអ្នកផ្គត់ផ្គង់ ECE និងការអភិវឌ្ឍន៍សមត្ថភាព សម្រាប់ការកែលម្អ និងពង្រីកកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ECE ដែលផ្តល់ឲ្យដោយមហាវិទ្យាល័យសហគមន៍ និងអ្នកបណ្តុះបណ្តាលគុណភាពខ្ពស់ ផ្សេងទៀត ដើម្បីរក្សា និងវិភាគទិន្នន័យ ហើយសម្រាប់ធ្វើការទាក់ទងជា មួយសាធារណៈជនអំពីកម្រិតគុណភាពដែលសម្រេចបានដោយអ្នកផ្គត់ ផ្គង់ ECE។

(5) ចំនួនទឹកប្រាក់ដែលកំណត់នៅក្នុងកថាខណ្ឌ (1) ដល់ (4) នឹងត្រូវធ្វើការកែតម្រូវរៀងរាល់ឆ្នាំដោយសម្រួលអតិផរណា ដែលគណនាតាមអនុផ្នែក (b) នៃវគ្គ 42238.1 ដូចកាលបរិច្ឆេទនៃការអនុម័តរបស់វគ្គនេះ។

(6) នៅក្នុងឆ្នាំណាក៏ដោយដែលមូលនិធិ ECE មិនគ្រប់គ្រាន់ដើម្បីចំណាយតាមតម្រូវការនៃកថាខណ្ឌ (1) (3) និង (4) ចំនួនទឹកប្រាក់ដែលត្រូវការនៃកថាខណ្ឌទាំងនោះអាចនឹងត្រូវកាត់បន្ថយតាមសមាមាត្រ។

(b) បន្ទាប់ពីធ្វើការបែងចែកមូលនិធិស្តារឡើងវិញ និងកែលម្អប្រព័ន្ធដែលមានចែងនៅក្នុងអនុផ្នែក (a) អ្នកមើលការខុសត្រូវអាចប្រើប្រាស់មូលនិធិ ECE ដែលនៅសល់ ដែលត្រូវបានគេស្គាល់ថាជា "មូលនិធិ SAE" ដោយអនុលោមតាមចំណុច (f) នៃវគ្គ 14802 ដើម្បីពង្រឹង និងពង្រីកកម្មវិធី ECE ដូចបានកំណត់ក្នុងជំពូកនេះ។

(c) មូលនិធិ ECE ដែលត្រូវបានបែងចែកទៅ អ្នកមើលការខុសត្រូវ អាចប្រើប្រាស់ទៅតាមគោលបំណងដែលមានចែងក្នុងជំពូកនេះក្នុងរយៈពេលមួយឆ្នាំនៃការទទួលបានរបស់អ្នកមើលការខុសត្រូវ។ ក្រុមប្រឹក្សាពិនិត្យសារពើពន្ធ (Fiscal Oversight Board) ដែលត្រូវបានបង្កើតឡើយដោយអនុលោមទៅតាមវគ្គ 14802 អាចប្រមូលត្រឡប់មកវិញនូវមូលនិធិដែលមិនត្រូវបានចំណាយជារៀងរាល់ឆ្នាំ ហើយមូលនិធិទាំងនោះនឹងអាចក្លាយជាមូលនិធិ ECE សម្រាប់ធ្វើការបែងចែកសារជាថ្មី ដោយអនុលោមតាមជំពូកនេះ។

8162. (a) លើកលែងតែមានការត្រូវការពីច្បាប់សហព័ន្ធ ភាពអាចទទួលយកបានរបស់កុមារ ចំពោះកម្មវិធី ECE ទាំងអស់ ដែលរួមមានតែមិនដាក់កំហិត ដូចជាកម្មវិធី ECE ដែលបានបង្កើត កែលម្អ ឬពង្រីកដោយប្រើប្រាស់មូលនិធិក្នុងជំពូកនេះ នឹងត្រូវបង្កើតឡើងម្តងជារៀងរាល់ឆ្នាំផ្អែកលើការចុះឈ្មោះរបស់កុមារនៅក្នុងកម្មវិធី។ បន្ទាប់ពីការចុះឈ្មោះកុមារនឹងត្រូវកំណត់ថាអាចទទួលយកបានក្នុងការចូលរួមកម្មវិធីទាំងឡាយផ្សេងទៀតនៅក្នុងឆ្នាំកម្មវិធី ហើយបន្ទាប់មកនឹងអាចធ្វើការកំណត់ភាពអាចទទួលយកសារជាថ្មីក្នុងឆ្នាំបន្ទាប់ ដោយផ្អែកលើមូលដ្ឋានប្រចាំឆ្នាំ។

(b) ការចាប់ផ្តើមនៅក្នុងឆ្នាំសារពើពន្ធ 2013-14 ការបម្រុងប្រាក់ទុកប្រចាំឆ្នាំ សម្រាប់កម្មវិធី ECE គិតជាភាគរយនៃមូលនិធិទូទៅ (General Funds) នឹងមានត្រូវបានកាត់បន្ថយ ដោយសារមូលនិធិដែលបានបែងចែកនៅក្នុងច្បាប់នេះស្ថិតនៅក្នុងភាគរយនៃប្រាក់ចំណូលមូលនិធិទូទៅដែលបម្រុងសម្រាប់កម្មវិធី ECE នៅក្នុងឆ្នាំសារពើពន្ធ 2012-13។

8163. អ្នកមើលការខុសត្រូវ អាចបែងចែកមូលនិធិ SAE ដូចខាងក្រោម៖

(a) ម្ភៃប្រាំភាគរយនៃមូលនិធិ SAE នឹងត្រូវបានបែងចែកសម្រាប់ផលប្រយោជន៍កុមារចាប់ពីចាប់កំណើតរហូតដល់អាយុ បីឆ្នាំដោយអនុលោមតាមអនុផ្នែកដូចខាងក្រោម៖

(1) ច្រើនរហូតដល់ 1 ភាគរយនៃមូលនិធិ SAE អាចធ្វើការបែងចែកសម្រាប់បង្កើនអត្រាសំណងនៅក្នុងកម្មវិធីថែទាំជាក្រុមដែលមានកិច្ចសន្យាសម្រាប់ក្មេងអាយុតិចជាង 18 ខែ ក្នុងការធ្វើការកំណត់អត្រាសំណងគុណភាពមូលដ្ឋាន ដូចមានចែងក្នុងចំណុច (b) នៃវគ្គ 8168។

(2) ច្រើនរហូតដល់ 2 ភាគរយនៃមូលនិធិ SAE ជាអត្រាបន្ត (Take-up rate) នឹងត្រូវបានបែងចែកសម្រាប់បង្កើនអត្រាសំណងដែលខ្ពស់ជាងកម្រិតឆ្នាំសារពើពន្ធ 2012-13 តាមរយៈការផ្តល់ប្រាក់បន្ថែមក្រោមប្រព័ន្ធ QRIS សម្រាប់កម្មវិធី ECE និងអ្នកផ្គត់ផ្គង់ទាំងនោះ ដោយបម្រើឲ្យកុមារចាប់ពីចាប់កំណើត រហូតដល់អាយុ ៣ ឆ្នាំ ដែលជម្រុញស្តង់ដារគុណភាពនៃកម្មវិធីដោយប្រើប្រាស់ប្រព័ន្ធ QRIS ឬបង្ហាញថាកម្មវិធី ឬអ្នកផ្គត់ផ្គង់ទាំងនោះ ឈានដល់ស្តង់ដារគុណភាព QRIS ខ្ពស់ជាងស្តង់ដារគុណភាពមូលដ្ឋានដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមចំណុច (b) នៃវគ្គ 8168។

(3) ម្ភៃមួយ កន្លះភាគរយនៃមូលនិធិ SAE នឹងត្រូវបានបែងចែកទៅកម្មវិធី California Early Head Start ដែលបង្កើតឡើងដោយអនុលោមតាមមាត្រា 2 (ចាប់ពីវគ្គ 8164)។ មិនតិចជាង 35 ភាគរយនៃមូលនិធិ SAE ដែលត្រូវបានបែងចែកទៅឲ្យកម្មវិធី California Early Head Start ដូចមានចែងក្នុងកថាខណ្ឌនេះ នឹងត្រូវបានប្រើប្រាស់ជាពិសេសសម្រាប់ពង្រឹងមាតាបិតា ឬអាណាព្យាបាលផ្សេងៗទៀតដោយអនុលោមតាមចំណុច(d) នៃវគ្គ 8164។

(b) ចិតសិបភាគរយនៃមូលនិធិ SAE នឹងត្រូវបានប្រើប្រាស់សម្រាប់ពង្រីក និងពង្រឹងកម្មវិធីមុនចូលសាលា សម្រាប់កុមារអាយុចាប់ពីបី ឆ្នាំដល់ ប្រាំឆ្នាំ ដូចបានកំណត់ក្នុងមាត្រា 3(ចាប់ពីវគ្គ 8165)។

(c) មិនលើសពី 3 ភាគរយនៃមូលនិធិ SAE នឹងត្រូវចំណាយលើតម្លៃរដ្ឋបាលគ្រប់ជាន់ថ្នាក់ទាំងអស់ក្នុងរដ្ឋ។

(d) មិនលើសពី 15 ភាគរយនៃមូលនិធិ ដែលអ្នកផ្គត់ផ្គង់ ECE ទទួលបានពីមូលនិធិ SAE នឹងត្រូវប្រើសម្រាប់ការកំណត់គោលបំណងជាថ្មី ស្វែងរកគំនិតថ្មី ការអភិវឌ្ឍន៍ ការថែរក្សា ឬជួល និងការចំណាយលើការជួលសម្ភារបម្រុងសម្រាប់កម្មវិធី។ អ្នកមើលការខុសត្រូវអាចប្រកាសឲ្យប្រើវិន័យសមស្រប ដើម្បីមើលជាមុន និងកំណត់ការប្រើប្រាស់សមស្របនៃមូលនិធិ SAE សម្រាប់បរិក្ខា។

មាត្រា 2. កម្មវិធី California Early Head Start

8164. ការប្រើប្រាស់មូលនិធិដែលបានបែងចែកដោយអនុលោមតាមកថាខណ្ឌ (3) នៃចំណុច (a) នៃវគ្គ 8163 អ្នកមើលការខុសត្រូវអាចអភិវឌ្ឍ និងអនុវត្តកម្មវិធី California Early Head Start ដើម្បីពង្រីកការថែទាំសម្រាប់កុមារចាប់ពីចាប់កំណើតរហូតដល់អាយុ 3 ឆ្នាំដូចខាងក្រោម ៖

(a) កម្មវិធីនឹងស្ថិតនៅក្នុងវិន័យ និងការត្រួតពិនិត្យជាប្រចាំរបស់អ្នក មើលការខុសត្រូវ ប៉ុន្តែវានឹងយកគំរូតាមកម្មវិធី Early Head Start សហព័ន្ធ ដែលបង្កើតឡើងដោយអនុលោមតាម វគ្គ 9849a ចំណងជើង 42 នៃច្បាប់របស់សហរដ្ឋអាមេរិក។ ដោយមានការប្រឹក្សាយោបល់ជាមួយ ក្រុមប្រឹក្សាយោបល់នៃការសិក្សារហ័ស (Early Learning Advisory Council: ELAC) ដែលបានបកស្រាយក្នុងវគ្គ 8167 អ្នកមើលការខុស ត្រូវ នឹងធ្វើឲ្យប្រាកដថាកម្មវិធី California Early Head Start ត្រឹមត្រូវ តាមស្តង់ដារគុណភាព និងខ្លឹមសារទាំងអស់ ហើយតម្រូវការមានគ្រប់ គ្រាន់គិតត្រឹម ខែ វិច្ឆិកា ឆ្នាំ 2011 សម្រាប់កម្មវិធី Early Head Start សហព័ន្ធ។ អ្នកមើលការខុសត្រូវអាចដាក់ចុះតម្រូវការ និងស្តង់ដាររបស់ កម្មវិធី Early Head Start សហព័ន្ធជាបន្តបន្ទាប់ទៅតាមការយល់ឃើញ របស់ខ្លួន។

(b) មូលនិធិដែលត្រូវបានប្រើប្រាស់សម្រាប់កម្មវិធី California Early Head Start នឹងមិនត្រូវបានប្រើប្រាស់សម្រាប់ជំនួសថវិកាដែលបច្ចុប្បន្នកំពុងប្រើនៅក្នុងកម្មវិធីសហព័ន្ធ ឬរដ្ឋផ្សេងសម្រាប់កុមារចាប់ពីចាប់កំណើតដល់អាយុ 3 ឆ្នាំឡើយ។

(c) ស្នងការសិក្សាអាចដាក់ចុះស្តង់ដារភាពអាចទទួលយកបានដូចគ្នា ដែលត្រូវបានប្រើប្រាស់ដោយកម្មវិធី Early Head Start សហព័ន្ធ ត្រឹមខែវិច្ឆិកា ឆ្នាំ 2011 ប៉ុន្តែអទិភាពខ្ពស់បំផុតនៃការចុះឈ្មោះនឹងទៅដល់ កុមារមានហានិភ័យខ្ពស់មុនគេដូចបានចែងក្នុងកថាខណ្ឌ (1) នៃចំណុច(g) នៃវគ្គ 8160 បន្ទាប់មកគឺកុមារស្ថិតក្នុងភាពហានិភ័យខ្ពស់ដូចមានចែងក្នុងកថាខណ្ឌ (2) នៃអនុផ្នែក (g)នៃវគ្គ 8160 ហើយបន្ទាប់មកត្រូវផ្តល់ឲ្យកុមារស្ថិតក្នុងភាពហានិភ័យខ្ពស់ដែលមានចែងក្នុងកថាខណ្ឌ (3) នៃអនុផ្នែក (g) នៃវគ្គ 8160។

(d) បន្ថែមលើការផ្តល់ឲ្យនូវក្រុមថែទាំដែលមានគុណភាពខ្ពស់ក្នុងមជ្ឈមណ្ឌលអាជ្ញាប័ណ្ណ និងផ្ទះថែទាំគ្រួសារ កម្មវិធី California Early Head Start នឹងផ្តល់សេវាកម្មដល់គ្រួសារ និងអាណាព្យាបាលកុមារដែលបានចុះឈ្មោះក្នុងក្រុម California Early Head Start។ សេវាកម្មទាំងនេះ នឹងត្រូវរៀបចំឡើងដើម្បីពង្រឹងសមត្ថភាពមាតាបិតា និងអាណាព្យាបាលនៃកុមារចាប់ពីចាប់កំណើតរហូតដល់អាយុបីឆ្នាំ ដើម្បីធ្វើឲ្យការថែទាំ ការអប់រំ និងសុខភាពរបស់កុមារតូចៗទាំងនៅកន្លែងថែទាំ និងនៅផ្ទះមានលក្ខណៈប្រសើរឡើង។ សេវាកម្មអាចរាប់បញ្ចូលសេវាកម្មទាំងឡាយដែលត្រូវបានផ្តល់ឲ្យដល់គ្រួសាររបស់សហព័ន្ធ ឬអ្នកបានចុះឈ្មោះចូលក្នុងក្រុមថែទាំ California Early Head Start រួមមានតែមិនដាក់កំហិត ដូចជាការទៅលេងផ្ទះដោយស្ម័គ្រចិត្ត ការពិនិត្យ និងអន្តរាគមន៍លើការអភិវឌ្ឍន៍រហ័ស កម្មវិធីចំណេះដឹងគ្រួសារ និងអាណាព្យាបាល និងវគ្គបណ្តុះបណ្តាលមាតាបិតា និងអាណាព្យាបាល។ ក្នុងចំណោមកម្មវិធីដែលបានផ្តល់ឲ្យអ្នកផ្តល់ការថែទាំ អនុលោមតាមអនុផ្នែកនេះ អាទិភាព នឹងត្រូវផ្តល់ទៅឲ្យកម្មវិធីសម្រាប់គ្រួសារដែលរួចពីអាជ្ញាប័ណ្ណ មិត្តភក្តិ និងអ្នកផ្គត់ផ្គង់ជិតខាង។

(e) ក្នុងការប្រឹក្សាយោបល់ជាមួយ ELAC អ្នកមើលការខុសត្រូវនឹង

បង្កើតជាស្តង់ដារគុណភាព សម្រាប់សេវាកម្មដែលផ្តល់ឲ្យក្រោមអនុផ្នែក (d) ដោយរួមបញ្ចូលស្តង់ដារ និងការបណ្តុះបណ្តាលរបស់កម្មវិធី Early Head Start សហព័ន្ធ។ អ្នកមើលការខុសត្រូវនឹងសម្របសម្រួលជាមួយភ្នាក់ងារសាធារណៈផ្សេងទៀតដែលប្រតិបត្តិការលើកម្មវិធីស្រដៀងគ្នា ដើម្បីទទួលបានស្តង់ដារឯកសណ្ឋានសម្រាប់កម្មវិធីទាំងនេះ។

(f) មូលនិធិ California Early Head Start អាចត្រូវបានប្រើប្រាស់សម្រាប់បន្ថែមចំនួនកុមារដែលមាននៅក្នុងកម្មវិធី ECE បច្ចុប្បន្ន សម្រាប់កុមារចាប់ពីចាប់កំណើត រហូតដល់អាយុបីឆ្នាំ ដោយបញ្ជាក់ថាកម្មវិធីដល់ស្តង់ដារគុណភាពដែលមានចែកនៅក្នុងចំណុច(a) និង (e) ហើយកុមារដែលនៅក្នុងកម្មវិធីមានភាពអាចទទួលយកបានត្រឹមត្រូវតាមចំណុច (c)។

(g) យ៉ាងហោចណាស់ 75 ភាគរយនៃទីកន្លែងថែទាំជាក្រុម ដែលត្រូវបានបង្កើតឡើងទូទាំងរដ្ឋ ដោយប្រើប្រាស់មូលនិធិ California Early Head Start នឹងផ្តល់ការថែទាំពេញមួយថ្ងៃ និងពេញមួយឆ្នាំ។

មាត្រា 3. កម្មវិធីពង្រឹង និងពង្រីកវគ្គមុនចូលសាលា

8165. (a) មូលនិធិ SAE ដែលត្រូវបានបែងចែកសម្រាប់កម្មវិធីពង្រឹង និងពង្រីកវគ្គមុនចូលសាលា សម្រាប់កុមារអាយុពី បី ដល់ ប្រាំឆ្នាំដោយអនុលោមតាមអនុផ្នែក (b) នៃវគ្គ 8163 នឹងត្រូវបែងចែកដូចខាងក្រោម៖

(1) ច្រើនរហូតដល់ 8 ភាគរយនៃមូលនិធិ SAE ក្នុងន័យជាអត្រាបន្ត (take-up rate) ដើម្បីបង្កើនអត្រាសំណងដែលលើសពីអត្រាឆ្នាំសារពើពន្ធ 2012-13 តាមរយៈការផ្តល់ជាប្រាក់បន្ថែមក្រោមប្រព័ន្ធ QRIS សម្រាប់កម្មវិធី និងអ្នកផ្គត់ផ្គង់កម្មវិធី ECE ដែលបម្រើឲ្យកុមារអាយុចាប់ពី បីឆ្នាំដល់ប្រាំឆ្នាំ ដោយធ្វើឲ្យប្រសើរឡើងនូវស្តង់ដារគុណភាពក្នុងប្រព័ន្ធ QRIS ឬបង្ហាញថាកម្មវិធីទាំងនោះបានឈានដល់ស្តង់ដារគុណភាព QRIS ដែលខ្ពស់ជាងស្តង់ដារគុណភាពមូលដ្ឋាន ដោយអនុលោមតាមចំណុច(b) នៃវគ្គ 8168។

(2) អ្វីដែលនៅសល់ មិនតិចជាង 67 ភាគរយនៃមូលនិធិ SAE នឹងត្រូវបានប្រើប្រាស់សម្រាប់បន្ថែមចំនួនកុមារដែលត្រូវបានបម្រើនៅក្នុងកម្មវិធីមុនចូលសាលាគុណភាពខ្ពស់សម្រាប់កុមារអាយុចាប់ពីបី ដល់ ប្រាំឆ្នាំ នៅក្នុងអាជ្ញាប័ណ្ណ ឬកម្មវិធីមានមូលដ្ឋានលើ K-12 ដែលឈានដល់ការកំណត់ស្តង់ដារគុណភាពខ្ពស់បំផុតពីរ ដោយធ្វើឡើងតាមប្រព័ន្ធ QRIS។ រហូតដល់ QRIS ក្នុងរដ្ឋទាំងមូលត្រូវបានបង្កើតឡើង និងអាចប្រើបានលើកម្មវិធីមួយចំនួននោះ អ្នកមើលការខុសត្រូវអាចចេញផ្សាយគោលការណ៍បណ្តោះអាសន្ន ដែលកំណត់លើការប្រើប្រាស់មូលនិធិពង្រីកដូចមានចែងក្នុងអនុផ្នែកនេះ សម្រាប់កម្មវិធី  បើពុំនោះត្រូវមានស្តង់ដារគុណភាពខ្ពស់ ដោយរាប់ទាំង តែមិនដាក់កំហិត កម្មវិធីដែលមានអត្រាជាប់លំដាប់កំពូល ពីនៃប្រព័ន្ធ QRIS ក្នុងស្រុកពីមុន និងក្នុងតំបន់ កម្មវិធីដែលមានការទទួលស្គាល់គុណភាពថ្នាក់ជាតិ ឬកម្មវិធីដែលមានស្តង់ដារគុណភាពប្រហាក់ ប្រហែលនឹងមតេយ្យសិក្សា ប្រព័ន្ធ QRIS នឹងត្រូវបានបង្កើត និងចែកផ្សាយជាសាធារណៈដោយមិនឲ្យហួសពី ថ្ងៃទី 1 ខែមករា ឆ្នាំ 2014 នោះទេ។ អ្នកផ្គត់ផ្គង់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោមគោលការណ៍បណ្តោះអាសន្នរបស់អ្នកមើលការខុសត្រូវ នឹងទទួលបានអាទិភាព ក្នុងការវាយតម្លៃដោយប្រើប្រាស់ប្រព័ន្ធថ្មី។ គោលការណ៍បណ្តោះអាសន្ន នឹងផុតកំណត់នៅថ្ងៃទី 1 ខែមករា ឆ្នាំ2015 ហើយអ្នកផ្គត់ផ្គង់ដែលមានការបញ្ជាក់ បណ្តោះអាសន្ន នឹងត្រូវសម្រេចលក្ខណៈសម្បត្តិដោយប្រើស្តង់ដារកម្មវិធី QRIS ដែលបានបង្កើតដើម្បីទទួលបានមូលនិធិឧបត្ថម្ភ មិនឲ្យផុតថ្ងៃទី 1 ខែមករា ឆ្នាំ 2017។

(3) យ៉ាងតិចបំផុត 65 ភាគរយនឹងទីធ្លាថ្មីដែលត្រូវបានបង្កើតឡើងទូទាំងរដ្ឋដោយអនុលោមតាមកថាខណ្ឌ (2) នឹងក្លាយជាកន្លែងពេញថ្ងៃ ឬពេញឆ្នាំ ដោយអាចបង្កើតបានទាំងស្រុងនៅក្នុងជំពូកនេះ ឬដោយរួមបញ្ចូលការឧបត្ថម្ភមូលនិធិពី ប្រភពពីរ ឬច្រើនទៀតដើម្បីបង្កើត កម្មវិធីថ្ងៃសិក្សារួមគ្នា បន្ទាប់ពីសាលា និងកម្មវិធីបំប៉ននៅរដូវក្តៅ។

(b) កុមារនឹងត្រូវកំណត់ "ពីអាយុបី ដល់ ប្រាំឆ្នាំ" ដូច្នេះគឺអាចចូលរួមក្នុងកម្មវិធីដែលផ្តល់មូលនិធិដោយអនុលោមតាមកថាខណ្ឌ (2) នៃចំណុច (a) បើសិនជាពួកគេមានអាយុបី ឬបួនឆ្នាំគិតត្រឹមថ្ងៃទី 1 ខែកញ្ញានៃឆ្នាំសិក្សានៅសាលា ដែលពួកគេបានចុះឈ្មោះចូលរៀនក្នុងកម្មវិធី និងមិនទាន់អាចចូលរៀននៅថ្នាក់មតេយ្យបាន។

8166. (a) ដោយប្រើប្រាស់ទិន្នន័យពីការិយាល័យជំរឿនសហរដ្ឋអាមេរិក (United States Census Bureau) អ្នកមើលការខុសត្រូវអាចចំណាយមូលនិធិដែលត្រូវបានបែងចែកដោយអនុលោមតាមកថាខណ្ឌ (2) នៃចំណុច (a) នៃវគ្គ 8165 (មូលនិធិពង្រីកថ្នាក់មុនចូលសាលា) ដោយយោងទៅតាមបញ្ជីប្រាក់ចំណូល របស់គ្រប់សង្កាត់ទាំងអស់ក្នុងកាលីហ្វញ៉ា ដោយចាប់ផ្តើមពីសង្កាត់ដែលមានប្រាក់ចំណូលទាបបំផុត និងធ្វើដំណើរការណ៍ឡើងលើដោយយោងតាមប្រាក់ចំណូល ខណៈការអនុញ្ញាតមូលនិធិពង្រីកថ្នាក់មុនចូលសាលា មានដូចខាងក្រោម៖

(1) អ្នកមើលការខុសត្រូវនឹងបង្កើតជាបញ្ជីសង្កាត់មួយ ដោយវគ្គលើចំណូលគ្រួសារជាមធ្យម និងលើសង្កាត់ដែលបានកំណត់ដោយ Zip Codes ឬខ្នាតភូមិសាស្ត្រប្រហាក់ប្រហែល។ នៅក្នុងវគ្គនេះ ពាក្យ "សង្កាត់" មានន័យថាជា Zip Code ឬខ្នាតភូមិសាស្ត្រដែលមានតម្លៃស្មើ ដែលត្រូវ បានរាប់បញ្ចូលនៅក្នុងបញ្ជីសង្កាត់។ តាមរយៈការប្រើប្រាស់ទិន្នន័យដែលមានលើភាពអាចរកបានរបស់ ECE អ្នកមើលការខុសត្រូវនឹងធ្វើការកំណត់អត្តសញ្ញាណសង្កាត់រៀងរាល់ឆ្នាំ និងស្រុក សាលាដែលជាកន្លែងកុមាររស់នៅ ហើយដែលជាកុមារដែលមានអាយុសមស្របសម្រាប់មូលនិធិពង្រីកថ្នាក់មុនចូលសាលា និងជាអ្នកដែលមិនទាន់បានចូលក្នុងកម្មវិធី ECE ឬកម្មវិធីអន្តរៈ មត្តេយ្យ។

(2) សម្រាប់ Zip code នីមួយៗ ឬខ្នាតភូមិសាស្ត្រប្រហាក់ប្រហែល អ្នកមើលការខុសត្រូវនឹងធ្វើការកំណត់ពីចំនួនកុមារដែលស័ក្តសម តែមិនទាន់ទទួលបានសេវា និងផ្តល់ព័ត៌មានដល់សាលាក្នុងស្រុក បណ្តាញអប់រំថែទាំកុមារក្នុងផ្ទះ (Family Child Care Home Education Networks) ដែលមានអាជ្ញាប័ណ្ណ (បណ្តាញដែលមានអាជ្ញាប័ណ្ណ) អ្នកផ្គត់ផ្គង់ ECE ដែលមានអាជ្ញាប័ណ្ណនៅក្នុងតំបន់ និងអ្នកផ្គត់ផ្គង់ Head Start សហព័ន្ធ ឬកម្មវិធី ECE សហព័ន្ធផ្សេងៗទៀត ("អ្នកផ្គត់ផ្គង់សហព័ន្ធ") ដែលកំពុងធ្វើការនៅក្នុង Zip Code ឬខ្នាតភូមិសាស្ត្រប្រហាក់ប្រហែលដែលពួកគេអាចពង្រីកកម្មវិធី របស់ខ្លួនដើម្បីបម្រើដល់កុមារទាំង នេះ និងសួររកសំណុំបែបបទពីភាគីទាំងនោះសម្រាប់ការផ្តល់មូលនិធិពង្រីកថ្នាក់មុនចូលសាលា។ ដើម្បីអាចស័ក្តិសមសម្រាប់ការឧបត្ថម្ភមូល និធិ បេក្ខជនគួរតែអាច និងមានបំណងបម្រើដល់កុមារ ដែលកំពុងត្រៀម ខ្លួនចូលរួមក្នុងឆ្នាំដំបូងនៅសាលា ដោយមានការប្រកាសភាពអាចទទួល យកបាន។

(3) បណ្តាញមានអាជ្ញាប័ណ្ណ កម្មវិធី ECE មានអាជ្ញាប័ណ្ណដែលមានមូលដ្ឋាននៅកណ្តាល និងអ្នកផ្គត់ផ្គង់សហព័ន្ធ ដែលកំពុងប្រតិបត្តិការនៅក្នុង Zip Code ឬខ្នាតភូមិសាស្ត្រប្រហាក់ប្រហែល នឹងមានអាទិភាព បើ សិនជាមានពាក្យស្នើសុំពីរលើភាពអាចទទួលយកបានដូចគ្នា។ តាមរយៈ ការផ្តល់អាទិភាពដល់ពាក្យស្នើសុំរួមគ្នា អ្នកមើលការខុសត្រូវអាចលើកទឹកចិត្តដល់សាលាក្នុងស្រុក បណ្តាញមានអាជ្ញាប័ណ្ណ អ្នកផ្គត់ផ្គង់ ECE មានមូលដ្ឋាននៅកណ្តាលមានអាជ្ញាប័ណ្ណ និងអ្នកផ្គង់ផ្គង់សហព័ន្ធ នៅក្នុងទីតាំងស័ក្តិសមដើម្បីឲ្យដាក់ពាក្យស្នើសុំរួមគ្នា ដែលអាចបង្កើនភាពខ្លាំងនៃគ្រប់កម្មវិធីទាំងអស់ និងកាត់បន្ថយជម្លោះ។ ប្រសិនបើសាលាក្នុងស្រុក បណ្តាញដែលអាចដាក់បាន កម្មវិធីមានមូលដ្ឋាននៅកណ្តាលដែលអាចដាក់បាន និងអ្នកផ្គត់ផ្គង់សហព័ន្ធមិនអាច ឬបដិសេធមិនបម្រើកុមារដែលពួកគេអាចបម្រើបាន ឬមិនថាភាគីណាទេ អ្នកមើលការខុសត្រូវអាចស្នើសុំភ្នាក់ងារអប់រំក្នុងស្រុក បណ្តាញមានអាជ្ញាប័ណ្ណ អ្នកផ្គត់ផ្គង់ ECE មានមូលដ្ឋាននៅកណ្តាលមានអាជ្ញាប័ណ្ណ និងអ្នកផ្គត់ផ្គង់សហព័ន្ធដើម្បីមកបម្រើសេវាកម្មដល់កុមារទាំងនោះវិញ។ ក្នុងពេលស្វែងរកអ្នកផ្គត់ផ្គង់ដែលអាចទទួលបានផ្សេង អ្នកមើលការខុសត្រូវអាចធ្វើការទាក់ទងជាពិសេស តែមិនដាក់កំហិតជាមួយអ្នកផ្គត់ផ្គង់ការចំណាយដែលកំពុងធ្វើការនៅក្នុងប្រទេសដែលកុមារកំពុងរស់នៅ។

(4) ការចូលរួមនៅថ្នាក់មុនចូលសាលា រួមទាំងកម្មវិធីមុនចូលសាលាត្រូវបានបង្កើតឡើង និងពង្រីកដោយអនុលោមតាមជំពូកនេះ គឺដោយស្ម័គ្រចិត្ត។ ទីធ្លាមិនពេញដែលត្រូវបានផ្តល់ឲ្យនៅក្នុង Zip Code ឬខ្នាតភូមិសាស្ត្រប្រហាក់ប្រហែលណាមួយ សម្រាប់រយៈពេលបីឆ្នាំជាប់គ្នាដោយមានការសហការយ៉ាងមានប្រសិទ្ធភាពជាមួយសហគមន៍ ប៉ុន្តែនៅតែមិនអាចបំពេញបាន និងត្រូវសម្រេចបដិសេធចោល ហើយអាចនឹងផ្តល់ទៅឲ្យ

*សង្កាត់ដែលមានចំណូលច្រើនបំផុតបន្ទាប់ ដោយមើលតាមបញ្ជីសង្កាត់។*

*(5) យ៉ាងតិចបំផុតម្តងរៀងរាល់ប្រាំឆ្នាំ អ្នកមើលការខុសត្រូវអាចពិនិត្យឡើងវិញលើកន្លែងណាដែលត្រូវសម្រេចបដិសេធចោល ហើយស្តារឡើង វិញនូវភាពដែលអាចទទួលយកបានដែលបាត់បង់ទៅសង្កាត់ផ្សេងឲ្យដល់កម្រិតលក្ខខណ្ឌប្រែប្រួលមួយ ដែលចង្អុលបង្ហាញថា ទីកន្លែងអាចបំពេញបានហើយ។*

*(b) កុមារនឹងអាចទទួលយកបានឲ្យចូលរួមក្នុងកម្មវិធីឧបត្ថម្ភមូលនិធិ ដោយមូលនិធិពង្រីកថ្នាក់មុនចូលសាលា ដោយបង្ហាញថាពួកគេរស់នៅ ក្នុង Zip Code ឬខ្នាតភូមិសាស្ត្រដែលអាចទទួលយកបាន ឬគ្រួសាររបស់ពួកគេដល់តំរូវការប្រាក់ចំណូលដែលអាចទទួលយកបាននៃកម្មវិធី ECE ដែលមានស្រាប់ ប៉ុន្តែអាទិភាពខ្ពស់បំផុតសម្រាប់ការចុះឈ្មោះនឹងបានទៅកុមារដែលស្ថិតក្នុងហានិភ័យខ្ពស់ ដូចមានកំណត់នៅក្នុងកថាខណ្ឌ (1) នៃអនុផ្នែក(g) នៃវគ្គ 8160 បន្ទាប់មកបានទៅកុមារស្ថិតក្នុងហានិភ័យខ្ពស់ ដូចមានកំណត់ក្នុងកថាខណ្ឌ (2) នៃចំណុចដដែល និងបន្ទាប់មកបានទៅកុមារស្ថិតក្នុងហានិភ័យខ្ពស់ដែលដូចមានកំណត់ក្នុងកថាខណ្ឌ (3) នៃ អនុផ្នែកនោះ។*

*មាត្រា 4. ប្រព័ន្ធកំណត់អត្រា និងធ្វើឲ្យប្រសើរឡើងនូវគុណភាពសិក្សាវ័យកុមារនៅរដ្ឋកាលីហ្វ័នីញ៉ា*

*8167. ដូចបានប្រើនៅក្នុងមាត្រានេះ ពាក្យ "ក្រុមប្រឹក្សាយោបល់ការសិក្សារហ័ស" ("Early Learning Advisory Council" (ELAC)) មានន័យថាជាក្រុមប្រឹក្សាយោបល់ការសិក្សារហ័សដែលត្រូវបានបង្កើតឡើងដោយអនុលោមតាម ការបង្គាប់បញ្ជាឲ្យប្រតិបត្តិ S-23-09 ឬជាភ្នាក់ងារជោគជ័យផ្សេងៗទៀត។*

*8168. (a) ដោយមានការយកចិត្តទុកដាក់ របាយការណ៍ និងអនុសាសន៍ត្រូវបានរៀបចំដោយគណៈកម្មការទីប្រឹក្សាប្រព័ន្ធកែលម្អ គុណភាពការសិក្សារហ័សនៅកាលីហ្វញ៉ា (California Early Learning Quality Improvement System Advisory Committee) នៅឆ្នាំ 2010 អ្នកមើលការខុសត្រូវ ដោយមានការប្រឹក្សាយោបល់ជាមួយ ELACអាចបង្កើត និងអនុវត្តប្រព័ន្ធកំណត់អត្រា និងធ្វើឲ្យប្រសើរឡើងនូវគុណភាពសិក្សាវ័យកុមារ (ប្រព័ន្ធ QRIS) ដោយមិនឲ្យផុតថ្ងៃទី 1 ខែមករា ឆ្នាំ 2014 ដែលរួមមានដូចខាងក្រោម៖*

*(1) មាត្រដ្ឋានកំណត់គុណភាពដោយស្ម័គ្រចិត្តមាននៅគ្រប់កម្មវិធីអប់រំដើមកុមារភាព (ECE) ទាំងអស់ ដោយរាប់បញ្ចូលទាំងមុនចូលសាលាដែលសំដៅលើកុមារចាប់ពីចាប់កំណើតរហូតដល់អាយុ 5 ឆ្នាំ រួមមានកុមារមានអាយុមុនចូលសាលារៀន ទារក និង កូនក្មេង។ មាត្រដ្ឋានកំណត់គុណភាព នឹងផ្តល់អាទិភាពខ្ពស់ទៅលើលក្ខណៈពិសេសៗ របស់ការអប់រំដើមកុមារភាព (ECE) ដែលបានបង្ហាញថាបានចូលរួមយ៉ាងមានប្រសិទ្ធភាពទៅកាន់ការអភិវឌ្ឍន៍សង្គម និងផ្លូវចិត្តដ៏រឹងមាំ និងភាពរួចរាល់របស់កុមារសម្រាប់ជោគជ័យនៅក្នុងសាលា។*

*(2) ការវាយតម្លៃដោយស្ម័គ្រចិត្តនិងកម្មវិធីអភិវឌ្ឍន៍ជំនាញ ដើម្បីជួយអ្នកផ្តត់ផ្គង់ការអប់រំដើមកុមារភាព (ECE) ក្នុងការបង្កើនការកំណត់គុណភាពនៃកម្មវិធីរបស់ពួកគេក្រោមប្រព័ន្ធ QRIS។*

*(3) វិធីសាស្ត្រសម្រាប់បង្កើនអត្រាសំណងលើអត្រាឆ្នាំសារពើពន្ធ 2011-2012 តាមរយៈការផ្តល់បន្ថែមសម្រាប់កម្មវិធីអប់រំដើមកុមារភាព (ECE) និងអ្នកផ្គត់ផ្គង់ដែលកែលម្អការកំណត់របស់ពួកគេ ឬបញ្ជាក់ថាពួកគេបាន ឈានដល់ចំណុចស្តង់ដារខ្ពស់មួយរួចទៅហើយ ដោយឈរលើប្រព័ន្ធ QRIS។*

*(4) វិធីសាស្ត្រមួយដែលមាតាបិតា និងអាណាព្យាបាលទទួលបានព័ត៌មានសុក្រិតអំពីគុណភាព និងប្រភេទនៃកម្មវិធី ដែលបុត្រធីតារបស់ពួកគេ*បានចុះឈ្មោះ ឬអាចនឹងចុះឈ្មោះ ដោយរួមមាន ការបោះពុម្ពផ្សាយរហ័សនៃការកំណត់គុណភាពរបស់កម្មវិធី និងអ្នកផ្គត់ផ្គង់ ដែលត្រូវបានធ្វើឡើងដោយអនុលោមតាមប្រពន្ធ QRIS។

(b) ដោយមានការប្រឹក្សាយោបល់ជាមួយ ELAC អ្នកមើលការខុសត្រូវក៏អាចបង្កើតជាអត្រាសំណងគុណភាពជាមូលដ្ឋាន ដែលគ្រប់គ្រាន់សម្រាប់ការចំណាយលើការផ្គត់ផ្គង់កម្មវិធី ECE ទៅតាមស្តង់ដារគុណភាព ស្ថិតក្រោមច្បាប់ និងគោលការណ៍ដែលបានកំណត់លើកម្មវិធីទាំងនេះដោយគិតមកដល់ ថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2012 (អត្រាសំណងគុណភាពជាមូលដ្ឋាន)។ បើសិនអត្រាសំណងបច្ចុប្បន្នណាមួយ ស្ថិតក្រោមអត្រាសំណងគុណភាពជាមូលដ្ឋាន អ្នកមើលការខុសត្រូវអាចប្រើកញ្ចប់ថវិកា ដែលមានបញ្ជាក់នៅក្នុងអនុកថាខណ្ឌ (c) នៃកថាខណ្ឌ (1) នៃចំណុច (a) នៃវគ្គ 8161 ឬសម្រាប់កម្មវិធីសម្រាប់កុមារអេយុក្រោម 18 ខែ មូលនិធិមានបញ្ជាក់ក្នុងកថាខណ្ឌ (1) នៃចំណុច(a) នៃវគ្គ 8163 ដើម្បីធ្វើការបង្កើនអត្រាសំណាងនោះ។

*8169. (a) ELAC និងអ្នកមើលការខុសត្រូវអាចធ្វើការសហការជាមួយក្រុមប្រឹក្សាផែនការក្នុងស្រុក គណៈកម្មការកាលីហ្វញ៉ាដំបូងទាំង 5 (The First 5 California Commission) និងគណៈកម្មការក្នុងស្រុកដំបូងទាំង 5 ដើម្បីបង្កើត និងមើលការខុសត្រូវលើ QRIS កម្មវិធីកាលីហ្វ័នីញ៉ា Early Head Start និងកម្មវិធីសម្រាកមុនចូលសាលា ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមមាត្រា 2 (ចាប់ពីវគ្គ 8164) មាត្រា 3 (ចាប់ពីផ្នែក 8165) និងមាត្រានេះ។ បុគ្គល និងអត្ថិភាពទាំងនេះ នឹងធ្វើការជាមួយគ្នាដើម្បីប្រើប្រាស់ធនធាន ក្នុងស្រុក របស់រដ្ឋ សហព័ន្ធ និងឯកជន ដោយ រាប់ទាំងធនធានដែលមាននៅក្នុងច្បាប់ កុមារ និងគ្រួសារកាលីហ្វញ៉ា ឆ្នាំ 1998 (California Children and Families Act of 1998) (លេខ 108 (ចាប់ពីវគ្គ 130100) នៃក្រមសុខភាព និងសុវត្ថិភាព (Health and Safety Code) ដែលជាវគ្គមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនសមត្ថភាព ប្រសិទ្ធភាពអប់រំ និងអភិវឌ្ឍន៍ និងទំនួលខុសត្រូវសហគមន៍របស់ ប្រព័ន្ធ ECE។*

*(b) ELAC នឹងធ្វើកិច្ចប្រជុំសាធារណៈរួមគ្នាមួយយ៉ាងតិចមួយលើកក្នុងមួយឆ្នាំនៅក្នុងតំបន់នីមួយៗរបស់រដ្ឋ ជាមួយក្រុមប្រឹក្សាផែនការក្នុងស្រុករបស់តំបន់ និងគណៈកម្មការដំបូងទាំងក្នុងស្រុក First Five (ម្យ៉ាងទៀតហៅថា គណៈកម្មការកុមារ និងគ្រួសារកាលីហ្វ័នីញ៉ា) ដើម្បីទទួលបានការចូលរួមសាធារណៈ និងរបាយការណ៍អំពីដំណើរការណ៍ នៃកម្មវិធីដែលបានធ្វើឡើងដោយអនុលោមតាមច្បាប់នេះ។*

*(c) មូលនិធិ ដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ (4) នៃអនុផ្នែក (a) នៃវគ្គ 8161 អាចត្រូវបានប្រើប្រាស់ដើម្បីផ្គត់ផ្គង់ដល់ការសហការ និងសកម្មភាពរួមគ្នាដែលត្រូវការនៅក្នុងវគ្គនេះ។*

*8170. (a) អ្នកមើលការខុសត្រូវអាចផ្តល់ព័ត៌មានលម្អិតពីថវិកាដែលបានទទួល ដែលអនុលោមក្នុងជំពូកនេះ ដាច់ផ្សេងពីថវិកាបន្ទាប់ពីបទបញ្ជីឆ្នាំសារពើពន្ធនីមួយ អាចរៀបចំជារបាយការណ៍ប្រចាំឆ្នាំមួយ ដែលរាយឈ្មោះកម្មវិធី ECE ដែលទទួលបានមូលនិធី ជាមួយនឹងការកំណត់គុណភាពដែលមាន ចំនួនទឹកប្រាក់ដែលកម្មវិធីនីមួយៗបានទទួល ចំនួនកុមារដែលកម្មវិធីនោះបានធ្វើការ ប្រភេទសេវាកម្មដែលកុមារបានទទួល និងលទ្ធផលដែលកុមារទទួលបាន បើសិនជាមាន។ បន្ទាប់ពីរៀបចំរបាយការណ៍រួចរាល់ហើយ អ្នកមើលការខុសត្រូវ អាចផ្សាយរបាយការណ៍នោះលើគេហទំព័ររបស់ខ្លួនភ្លាមៗ និងផ្តល់តំណភ្ជាប់របស់របាយការណ៍នោះនៅលើគេហទំព័ររបស់ខ្លួនផងដែរ។ របាយការណ៍អាចដាក់បញ្ចូលទៅក្នុងរបាយការណ៍ដែលបានចេញផ្សាយដោយអនុលោមតាមវគ្គ 82361។ ក្រុមប្រឹក្សាពិនិត្រសារពើពន្ធ (Fiscal Oversight Board) អាចធ្វើការពិនិត្យលើអត្ថន័យនៃរបាយការណ៍ និងដាក់វាបញ្ចូលទៅក្នុងរបាយការណ៍សាវនកម្មប្រចាំឆ្នាំ ដែលមានបញ្ជាក់នៅក្នុងអនុផ្នែក (a) នៃវគ្គ 14814។*

*(b) អ្នកមើលការខុសត្រូវក៏អាចធ្វើបានដូចខាងក្រោម៖*

*(1) ឃ្លាំមើលសមិទ្ធផលនៃកិច្ចសន្យារ ដើម្បីឲ្យច្បាស់ថាអ្នកផ្គត់ផ្គង់ ECE ត្រូវតាមស្តង់ដារគុណភាព។*

*(2) ធ្វើឲ្យប្រាកដថាមាន ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាឯកសណ្ឋាន និងសាវនកម្មប្រចាំឆ្នាំដោយឯករាជ្យ សម្រាប់គ្រប់ភាគីផ្តល់ ECE ដែលទទួលបានមូលនិធិក្រោមជំពូកនេះ។*

*(3) ទទួល ស៊ើបអង្កេត និងចាត់វិធានការណ៍ទៅតាមការមិនពេញចិត្តពាក់ព័ន្ធនឹងរូបភាពនៃកម្មវិធីដែលបានបង្កើតឡើងក្នុងជំពូកនេះ។*

*8171. (a) អ្នកមើលការខុសត្រូវ គួរធ្វើឲ្យប្រាកដថារាល់កុមាទើបតែចាប់ កំណើតរហូតដល់អាយុ 5 ឆ្នាំ ដែលបានចូលរួមក្នុងកម្មវិធី ECE ត្រូវបានកំណត់សន្ទស្សន៍ជាក់លាក់មួយ ដែលត្រូវបានកត់ និងរក្សាទុក ជាវគ្គនៃកម្រងទិន្នន័យសេវាកម្មអប់រំរហ័ស ដោយមិនឲ្យហួសពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2014។*

*(b) កម្រងទិន្នន័យសេវាកម្មអប់រំរហ័ស (Early Education System) អាចជាវគ្គ*

38

ទាំងមូលមួយនៃប្រព័ន្ធទិន្នន័យសមិទ្ធផលសិស្សនៅកាលីហ្វ័រញ៉ា (California Longitudinal Pupil Achievement Data System :CALPADS) ឬប្រព័ន្ធទិន្នន័យកម្រិតសិស្សដែលជោគជ័យណាមួយ ដែល អាចតាមដានការសិក្សារបស់កុមារតាំងពីចាប់កំណើតរហូតដល់អាយុ 18 ឆ្នាំ ដូច្នេះ ប្រវត្តិសិក្សាពេញលេញរបស់កុមារដោយរួមទាំងការចូលរួម ECE នឹងអាចមើលឃើញដោយស្វ័យប្រវត្តិតាមរយៈសន្ទស្សន៍ជាក់លាក់របស់ កុមារ។

(c) នៅកម្រិតអប្បបរមា កម្រងទិន្នន័យសេវាកម្មអប់រំរហ័ស អាចមានផ្ទុកទិន្នន័យពីកុមារដូចខាងក្រោម៖

(1) Zip code នៃទីលំនៅរបស់កុមារក្នុងឆ្នាំនីមួយៗ

(2) សេវាកម្ម ECE អ្វីដែលកុមារបានទទួលក្នុងឆ្នាំនីមួយៗ ដូចជាថាតើក្មេងបានចូលរួមកម្មវិធីពេញ ឬមិនពេញថ្ងៃ។

(3) ការកំណត់ដែលសេវាកម្ម ECE ត្រូវបានចែកចាយ។

(4) ភ្នាក់ងារដែលចែកចាយសេវាកម្ម ECE។

(5) ការកំណត់ QRIS និងការកំណត់គុណភាពផ្សេងទៀត ដែលមានសម្រាប់អ្នកផ្គត់ផ្គង់ ECE នោះ។

(6) ការវាយតម្លៃលើការត្រៀមខ្លួនចូលសាលាមត្តេយ្យរបស់កុមារ ប្រសិនបើមាន ដោយរាប់បញ្ចូល ភាសាដើមរបស់កុមារ កម្រិតដែលចេះ និងថាតើកុមារនោះមានត្រូវបានពិនិត្យសម្រាប់ការអន្តរាគមន៍រហ័សឬអត់ ប៉ុន្តែមិនមែនត្រូវតែមាននោះទេ។

(d) CALPADS អាចនឹងត្រូវសងសំណងចំពោះការចំណាយជាក់ស្តែងក្នុងការអនុវត្តវគ្គនេះ ដែលអាចស្មើនឹងចំនួនកំណត់ប្រចាំឆ្នាំ ដែលមាននៅក្នុងកថាខណ្ឌ (3) នៃអនុផ្នែក (a) នៃវគ្គ 8161។

8172. ស្នងការសិក្សាអាចចេញជាវិន័យ ដែលរួមមានវិន័យបន្ទាន់ ដើម្បីអនុវត្តជំពូកនេះ។

វគ្គទី 7.វគ្គ425នៃច្បាប់ព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មឱ្យបកស្រាយថា៖

425. (a) រាល់មន្ត្រីដែលត្រូវបានចោទប្រកាន់ថា បានទទួល រក្សាទុក ឬចាយវាយប្រាក់សាធារណៈ ដោយមិនបាន ឬមិនអាចរក្សាទុក និងចំណាយឲ្យដូចតាមការចែករបស់ច្បាប់ គឺត្រូវមានទោសជាបទឧក្រិដ្ឋ។

(b) មន្ត្រីដែលត្រូវបានចោទប្រកាន់ពីការបែងចែក ឬចែកចាយមូលនិធិដែលចែងនៅក្នុងវគ្គ 14803, 14804, 14805, 14806, និង 14807 នៃក្រមអប់រំ (Education Code) ដោយត្រូវបានដឹងថាមិនបានបែងចែក ឬចែកចាយមូលនិធីទៅឲ្យភ្នាក់ងារអប់រំក្នុងស្រុកនីមួយៗ ឬសាលាក្នុងស្រុកនីមួយៗដែលឈរលើមូលដ្ឋានសិស្សដូចមានបញ្ជាក់ក្នុងវគ្គទាំងនោះនឹងត្រូវមានទោសបទឧក្រិដ្ឋ ដោយត្រូវឆ្លងកាត់ការកាត់ក្តីពីអគ្គមេធាវី ឬ បើសិនជាគេមិនអាចធ្វើសកម្មភាពបានល្អ មេធាវីស្រុកក្នុងតំបន់នីមួយៗនឹងធ្វើការលើរឿងនោះ។ អគ្គមេធាវី ឬ បើសិនជាអគ្គមេធាវីបរាជ័យ មេធាវីស្រុកក្នុងតំបន់ អាចធ្វើការស៊ើបអង្កេត និងធ្វើការពិន័យពីបទឧក្រិដ្ឋ ហើយបង្គាប់ភ្លាមៗទៅលើការបែងចែក ឬចែកចាយមូលនិធិដែលមានចែកក្នុងវគ្គ 14803, 14804, 14805, 14806, និង 14897 នៃក្រមអប់រំ។ បុគ្គលណាមានកំហុសដោយរំលោភបំពានលើអនុផ្នែកនេះ អាចនឹងត្រូវផ្តន្ទាទោស ទៅតាមវគ្គ 18 និងអាចត្រូវបញ្ឈប់មិនឲ្យកាន់តំណែងណាមួយនៅក្នុងរដ្ឋ នេះទៀតឡើយ។

38

វគ្គទី 8. វគ្គ 17041.1 ត្រូវបានបន្ថែមទៅក្នុងក្រមប្រាក់ចំណូល និងពន្ធអាករ (Revenue and Taxation Code) ឱ្យបកស្រាយថា ៖

17041.1 (a) សម្រាប់ឆ្នាំដែលអាចយកពន្ធអាករបានចាប់ផ្តើមពី ឬបន្ទាប់ពី ថ្ងៃទី 1 ខែមករា ឆ្នាំ 2013 ដែលជាការបន្ថែមទៅលើពន្ធផ្សេងទៀតកំណត់ដោយវគ្គនេះ ពន្ធបន្ថែមត្រូវបានដាក់ចុះលើ ប្រាក់ចំណូលដែលត្រូវបង់ពន្ធ នៃអ្នកបង់ពន្ធណាមួយ ដោយពន្ធនោះត្រូវបានគណនាតាមអនុផ្នែក (a) នៃវគ្គ 17041 ដើម្បីទ្រទ្រង់មូលនិធិក្តីសង្ឃឹមអប់រំកាលីហ្វ័រញ៉ា (California Education Trust Fund)។ ពន្ធបន្ថែមសម្រាប់ឆ្នាំបង់ពន្ធ ដែលចាប់ផ្តើមពី ឬបន្ទាប់ពី ថ្ងៃទី 1 ខែមករា ឆ្នាំ 2013 និងមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2014 អាចគណនាដោយផ្អែកលើតារាងអត្រាខាងក្រោម ជា មួយនឹង គំលាតពន្ធ (Tax bracket) ដែលត្រូវបានកំណត់នៅក្នុងចំណុច (h) នៃវគ្គ 17091 សម្រាប់ការប្រែប្រួលនៅក្នុងលិបិក្រមតម្លៃវត្ថុប្រើប្រាស់ កាលីហ្វ័រញ៉ា (California Consumer Price Index រវាងឆ្នាំ 2011 និង 2013 ៖

| បើប្រាក់ចំណូលបង់ពន្ធគឺ៖ | ពន្ធអាករបន្ថែមលើ ប្រាក់ចំណូលបង់ពន្ធគឺ៖ |
|---|---|
| មិនលើស $7,316 | 0 |
| លើស $7,316 តែមិន លើស $17,346 | 0.4% នៃចំនួនលើសពី $7,316 |
| លើស $17,346 តែមិន លើស $27,377 | $40 បូក0.7% នៃចំនួន លើសពី $17,346 |
| លើស $27,377 តែមិន លើស $38,004 | $110 របូក 1.1% នៃចំនួន លើសពី $27,377 |
| លើស $38,004 តែមិន លើស $48,029 | $227 បូក 1.4% នៃចំនួន លើសពី $38,004 |
| លើស $48,029 តែមិន លើស $100,000 | $368 បូក 1.6% នៃចំនួន លើសពី $48,029 |
| លើស $100,000 តែមិន លើស $250,000 | $1,199 បូក 1.8% នៃចំនួន លើសពី $100,000 |
| លើស $250,000 តែមិន លើស $500,000 | $3,899 បូក 1.9% នៃចំនួន លើសពី $250,000 |
| លើស $500,000 តែមិន លើស $1,000,000 | $8,649 បូក 2.0% នៃចំនួន ចំនួនលើសពី $500,000 |
| លើស $1,000,000 តែមិន លើស $2,500,000 | $18,649 បូក 2.1%នៃចំនួន ចំនួនលើសពី $1,000,000 |
| លើស $2,500,000 | $50,149 បូក2.2%នៃចំនួន លើសពី $2,500,000 |

(b) សម្រាប់ឆ្នាំបង់ពន្ធដែលចាប់ផ្តើមពី ឬបន្ទាប់ពីថ្ងៃទី 1 ខែមករាឆ្នាំ 2012 ដែលបន្ថែមទៅលើពន្ធអាករផ្សេងៗទៀតដែលដាក់នៅក្នុងវគ្គនេះ ពន្ធអាករបន្ថែមមួយត្រូវបានកំណត់ទៅតាមចំណូលបង់ពន្ធនៃបុគ្គលត្រូវបង់ពន្ធណាមួយ ហើយពន្ធអាករនេះត្រូវគណនាទៅតាមអនុផ្នែក (c) នៃវគ្គ 17041 ដើម្បីទ្រទ្រង់មូលនិធិក្តីសង្ឃឹមអប់រំកាលីហ្វូញ៉ា (California Education Trust Fund)។ ពន្ធអាករបន្ថែមសម្រាប់ឆ្នាំបង់ពន្ធ ដែលចាប់ផ្តើមពី ឬបន្ទាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2014 និងមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2014 នឹងត្រូវគណនាដោយផ្អែកលើតារាងអត្រាខាងក្រោម ជាមួយនឹងគំលាតពន្ធដែលត្រូវបានកំណត់ដោយ អនុផ្នែក (ជ) នៃវគ្គ 17041 សម្រាប់ការប្រែប្រួលក្នុងលិបិក្រោមតម្លៃវត្ថុប្រើប្រាស់កាលីហ្វូញ៉ា (California Consumer Price Index)រវាងឆ្នាំ 2011 និង 2013៖

| បើប្រាក់ចំណូលបង់ពន្ធគឺ៖ | ពន្ធអាករបន្ថែមលើ ប្រាក់ចំណូលបង់ពន្ធគឺ៖ |
|---|---|
| លើស $14,642 | 0% |
| លើស $14,642 តែមិន លើស $34,692 | 0.4% នៃចំនួនលើស $14,642 |
| លើស $34,692 តែមិន លើស $44,721 | $80 បូក 0.7%នៃចំនួន លើស $34,692 |
| លើស $44,721 តែមិន លើស $55,348 | $150 បូក 1.1% នៃចំនួន លើស $44,721 |
| លើស $55,348 តែមិន លើស $65,376 | $267 បូក1.4% នៃចំនួន លើស $55,348 |
| លើស $65,376 តែមិន លើស $136,118 | $408 បូក1.6%នៃចំនួន លើស $65,376 |
| លើស $136,118ដ តែមិន លើស $340,294 | $1,540 បូក1.8% នៃចំនួន លើស $136,118 |
| លើស $340,294 តែមិន លើស $680,589 | $5,215ដុល្លារបូក1.9%នៃ ចំនួនលើស $340,294 |
| លើស $680,589 តែមិន លើស $1,361,178 | $11,680 បូក2.0%នៃ ចំនួនលើស $680,589 |
| លើស $1,361,178 តែមិន | $25,292 បូក 2.1%នៃចំនួន |

| | |
|---|---|
| *លើស $3,402,944* | *លើស $25,292 បូក2.1%* |
| *លើស $3,402,944* | *$68,169 បូក 2.2%នៃចំនួន លើស $3,402,944* |

*(c) សម្រាប់ឆ្នាំបង់ពន្ធអាករដែលចាប់ផ្តើមពី ឬបន្ទាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2013 ពន្ធអាករបន្ថែមដែលត្រូវបានដាក់នៅក្នុងវគ្គនេះនឹងគណនាទៅ តាមតារាងអត្រាដែលបានបង្ហាញនៅក្នុងអនវគ្គ (a) និង (b) ជាមួយនឹង គំលាតដែលមានប្រសិទ្ធភាពសម្រាប់ឆ្នាំបង់ពន្ធដែលចាប់ផ្តើមពី ឬបន្ទាប់ ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2013 និងមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2014 ដោយកែ តំរូវរៀងរាល់ឆ្នាំដូចមានចែកក្នុងចំណុច (h) នៃវគ្គ 17041 សម្រាប់ការប្រែ ប្រួលនៃលិបិក្រមតម្លៃវត្ថុប្រើប្រាស់កាលីហ្វ័រញ៉ា (Carlifornia Consumer Price Index)។*

*(d) មានលើកលែងដូចបញ្ជាក់ក្នុងអនុផ្នែក (e) និង (f) ពន្ធអាករបន្ថែមដែលដាក់ក្នុងវគ្គនេះនឹងត្រូវត្រឡប់ទៅជាពន្ធអាករក្រោមវគ្គ 17041 ក្នុងគ្រប់គោលបំណងដើម្បីប្រគល់កូដនេះ ដោយរាប់បញ្ចូលទាំង វគ្គ 17045 ឬការប្រគល់ឲ្យផ្សេងទៀតដែលពាក់ព័ន្ធនឹងសមិទ្ធផលរួមគ្នា។*

*(e) បរិមាណវាយតម្លៃនៃប្រាក់ចំណូល ការផ្ទេរប្រាក់វិញតិច គឺមានដើមកំណើតមកពីពន្ធអាករបន្ថែមដែលបានចែងក្នុងវគ្គនេះ ដែលនឹងអាចដាក់សន្សំជាប្រចាំខែ នៅក្នុងមូលនិធិក្តីសង្ឃឹមអប់រំកាលីហ្វញ៉ា ដែលបង្កើតឡើងដោយវគ្គ 14801 នៃក្រមអប់រំ នៅក្នុងទម្រង់មួយដែលឆ្លើយតបទៅនឹងដំណើរការណ៍ដែលកំណត់ដោយវគ្គ 19602.5 នៃក្រមនេះ ហើយត្រូវបានបង្កើតឡើងដោយច្បាប់ ដោយក្រុមប្រឹក្សាពន្ធអាករលក់ដូរ (Franchise Tax Board) ដោយផ្អែកលើពន្ធអាករបន្ថែមដែលបានកំណត់ក្នុងវគ្គនេះ មិនឲ្យហួសពីថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2012។ ការអនុវត្ត និងវិសោធនកម្ម ឬមោឃកម្មនៃវិន័យដែលអនុញ្ញាតនៅក្នុងវគ្គនេះត្រូវបានលើកលែងពីការបង្កើតច្បាប់របស់ ច្បាប់គោលការណ៍រដ្ឋបាល (Administrative Procedure Act (ជំពូក 3.5(ចាប់ពីវគ្គ 11340 នៃវគ្គ 1 នៃលេខ 3 នៃចំណងជើង 2 នៃក្រមរដ្ឋាភិបាល)។*

*(f) ថ្វីបើមាន វគ្គ 13340 នៃក្រមរដ្ឋាភិបាល មូលនិធិក្នុងភារៈគ្រប់គ្រងវគ្គអប់រំកាលីហ្វ័នីញ៉ា (California Education Trust Fund) នៅតែបន្តសកម្មភាព ដោយមិនគិតពីឆ្នាំសារពើពន្ធ ក្នុងគោលបំណងគាំទ្រមូលនិធិកូនៗ របស់យើង អនាគតរបស់យើង ៖ ច្បាប់ស្តីពីការវិនិយោគ លើការអប់រំវ័យដំបូង និងសាលារៀនក្នុងតំបន់ និងការកាត់បន្ថយប័ណ្ណបំណុល។*

*(g) ពន្ធអាករបន្ថែមដែលដាក់នៅក្នុងវគ្គនេះ មិនត្រូវបានអនុវត្តនៅឆ្នាំបង់ពន្ធដែលចាប់ផ្តើមពី ឬបន្ទាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2025 នោះទេ លើកលែងតែមានការផ្តល់ឲ្យនៅការវាស់វែងមួយដែលបន្លាយ កូនៗ របស់យើង អនាគតរបស់យើង ៖ ច្បាប់ស្តីពីការវិនិយោគ លើការអប់រំវ័យដំបូង និងសាលារៀនក្នុងតំបន់ និងការកាត់បន្ថយប័ណ្ណបំណុល។និងត្រូវបានអនុញ្ញាត ដោយការបោះឆ្នោតនៅក្នុងរដ្ឋទាំងមូល ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃ ឬមុនថ្ងៃអង្គារដំបូងបន្ទាប់ពីថ្ងៃចន្ទដំបូងក្នុងខែ វិច្ឆិកា ឆ្នាំ 2024។*

វគ្គទី 9. វគ្គ 19062 នៃក្រមប្រាក់ចំណូល និងពន្ធអាករត្រូវបានធ្វើវិសោធនកម្មឱ្យបកស្រាយថា ៖

19062. លើកលែងសម្រាប់ចំនួនដែលប្រមូល ឬសងក្រោមវគ្គ17935, 17941, 17948, 19532, និង 19561និងប្រាក់ចំណូលដែលបានដាក់បញ្ញើ ដោយអនុលោមតាមវគ្គ 19602.5 និងប្រាក់ចំណូលដែលប្រមូលតាមវគ្គ 17041.1 គ្រប់ថវិកា និង ការផ្ញើប្រាក់ឲ្យដែលទទួលដោយក្រុមប្រឹក្សាពន្ធអាករជួញដូរ (Franchise Tax Board) ជាចំនួនដែលកំណត់ ដោយវគ្គ 10 (ចាប់ផ្តុមពីវគ្គ 17001) និងការផាកពិន័យដែលពាក់ព័ន្ធ ការ បន្ថែមពន្ធ និងការប្រាក់ដែលបានកំណត់ក្នុងវគ្គនេះ អាចនឹងត្រូវដាក់ជា បញ្ញើ បន្ទាប់ពីពិនិត្យលើការផ្ញើប្រាក់រួចរាល់នៅក្នុងរតនាគារ (State Treasury) និងបញ្ជូនទៅឲ្យមូលនិធិចំណូលពន្ធអាករបុគ្គល (Personal Income Tax Fund)។

វគ្គទី 10. ឧបំរុង

ការផ្តល់ឲ្យនូវច្បាប់នេះ គឺអាចមានការកែប្រែបាន។ បើសិនជាការផ្តល់ឲ្យនៃវិធានការណ៍នេះ ឬភាពអាចប្រព្រឹត្តិទៅបាននៃការផ្តល់ឲ្យនៃវិធានការណ៍ទៅលើបុគ្គល ឬកាលៈទេសៈណាមួយត្រូវបានរកឃើញថាមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាព ការរកឃើញនោះនឹងមិនធ្វើឲ្យប៉ះពាល់ដល់ដំណើរការណ៍ផ្សេងទៀតនៃច្បាប់ ឬការប្រើប្រាស់នៃវិធានការណ៍ដែលនៅសល់ចំពោះបុគ្គល ឬកាលៈទេសៈណាឡើយ។

វគ្គទី 11. ការផ្តួចផ្តើមដែលចម្រូងចម្រាស់

(a) នៅក្នុងករណីដែលវិធានការណ៍នេះ និងវិធានការណ៍ផ្សេងទៀត ដែលបានធ្វើឲ្យផ្លាស់ប្តូរដល់អត្រាពន្ធចំណូលបុគ្គលនៅកាលីហ្វញ៉ាសម្រាប់អ្នកបង់ពន្ធ ឬក្រុមអ្នកបង់ពន្ធណាមួយ ឬកែប្រែលើអត្រាពន្ធដែលកំណត់ដោយអ្នកលក់បន្ត សម្រាប់ជាកម្មសិទ្ធិបញ្ញាក្នុងការលក់ទ្រព្យសម្បត្តិឯកជននៅក្នុងហាង ឬកែប្រែអត្រាពន្ធនៅកន្លែងស្តុក ប្រើប្រាស់ ឬការប្រើប្រាស់ផ្សេងៗទៀតនៅក្នុងរូបភាពទ្រព្យសម្បត្តិឯកជនជាក់ស្តែង ដែលបានទិញមកសម្រាប់ស្តុកទុក ប្រើប្រាស់ឬការប្រើប្រាស់ផ្សេងទៀតនៅក្នុងរូបភាពមួយ ដោយវានឹងកើតឡើងទៅតាមសន្លឹកឆ្នោតក្នុងរដ្ឋទាំងមូលដូចគ្នា ការកែប្រែអត្រានៃវិធានការណ៍ ឬការអនុវត្តន៍វិធានការណ៍ ដែលត្រូវបានផ្តល់ថវិការដោយការអនុវត្តនេះ អាចនឹងមានភាពចម្រូងចម្រាស់។ នៅក្នុងករណីដែលវិធានការណ៍នេះទទួលបានសន្លឹកឆ្នោតគាំទ្រច្រើនជាងវិធានការណ៍ផ្សេងទៀត ការផ្លាស់ប្តូអត្រារបស់វិធានការណ៍ផ្សេងទៀត និងការអនុវត្តទាំងឡាយរបស់វិធានការណ៍ទាំងនោះនឹងត្រូវទុកជាមោឃ និងរំសាយចោល ហើយការអនុវត្តវិធានការណ៍ថ្មីនេះនឹងចូលទៅជំនួសវិញ។

(b) ភាពចម្រូងចម្រាស់ជាមួយការអនុវត្តផ្សេងទៀត ដែលមិនមានបញ្ជាក់នៅក្នុងអនុផ្នែក (a) នឹងត្រូវដោះស្រាយដោយអនុលោមតាមចំណុច (b) នៃវគ្គ 10 មាត្រា II នៃច្បាប់រដ្ឋធម្មនុញ្ញកាលីហ្វ័នីញ៉ា។

វគ្គទី 12. វិសោធនកម្ម

ច្បាប់នេះនឹងមិនត្រូវបានធ្វើវិសោធនកម្មនោះទេ លើកលែងទេមានសំឡេងបោះឆ្នោតគាំទ្រភាគច្រើនពីប្រជាជនក្នុងរដ្ឋទាំងមូល។

វគ្គទី 13. កាលបរិច្ឆេទចុះជាធរមាន និងការផុតកំណត់

(a) វិធានការណ៍នេះនឹងចុះជាធរមាននៅថ្ងៃបន្ទាប់ពីការអនុម័ត។ កាលបរិច្ឆេតប្រតិបត្តិសម្រាប់ការអនុវត្តផ្សេងៗនៃវិធានការណ៍នៃនឹងត្រូវបានកំណត់ជាបន្តបន្ទាប់នៅក្នុងច្បាប់។

(b) ពន្ធអាករដែលត្រូវបានកំណត់នៅក្នុងអនុផ្នែក (a) និង (b) នៃវគ្គ 7041.1 នៃក្រមប្រាក់ចំណូល និងពន្ធអាករ (Revenue and Taxation Code) ដែលត្រូវបានដាក់បន្ថែមទៅក្នុងច្បាប់នេះ នឹងត្រូវបញ្ឈប់ប្រតិបត្តិការ និងផុតកំណត់នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2024 ប្រសិនបើអ្នកបោះឆ្នោតសំឡេងភាគច្រើនមិនអនុញ្ញាតឲ្យបន្លាយពេលវេលាសម្រាប់ច្បាប់នេះនៅក្នុងការបោះឆ្នោតទូទាំងរដ្ឋទាំងមូល ដែលនឹងប្រព្រឹត្តិទៅនៅ ឬមុនថ្ងៃអង្គារដំបូង បន្ទាប់ពីថ្ងៃចន្ទដំបូងក្នុងខែវិច្ឆិកាឆ្នាំ 2024។

## សំណើប្រជាមតិ 39

វិធានការផ្តើមប្រជាសិទ្ធិនេះគឺត្រូវបានដាក់ឲ្យប្រជាពលរដ្ឋដោយអនុលោមទៅតាមខដែលមានចែងក្នុងវគ្គទី 8 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

វិធានការផ្តើមប្រជាសិទ្ធិនេះកែប្រែ លុបចោលនិងបន្ថែមវគ្គខ្លះ ទៅលើក្រមធនធានសាធារណៈ និងក្រមបាក្រចំណូល និងពន្ធដារ។ ដូចនេះខចែងមានស្រាប់ដែលបានស្នើឡើងដើម្បីលុបចោល ត្រូវបោះពុម្ពចេញជា~~លក្ខណៈឆ្នូតលុបកាត់~~ ហើយខចែងថ្មី ដែលបានស្នើឡើងដើម្បី បន្ថែមត្រូវបោះពុម្ពចេញជា*លក្ខណៈអក្សរទ្រេត* ដើម្បីបញ្ជាក់ថាវាថ្មី។

### ច្បាប់ដែលស្នើ

សកម្មភាពការងារថាមពលស្អាតរដ្ឋកាលីហ្វ័រញ៉ា

វគ្គទី1 ប្រជាពលរដ្ឋរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាត្រូវរក និងប្រកាសនូវរាល់ចំណុចខាងក្រោមៈ

(1) រដ្ឋកាលីហ្វ័រញ៉ារងផលប៉ះពាល់ពីឱនភាពដែលបានធ្វើឱ្យប្រជាពលរដ្ឋនៅទីនោះបាត់បង់ការងារ។

(2) ច្បាប់ពន្ធថ្មីរារាំងក្រុមហ៊ុនពហុរដ្ឋក្នុងការបង្កើតការងារនៅរដ្ឋកាលីហ្វ័រញ៉ា ហើយដាក់ក្រុមហ៊ុនទាំងនោះក្រោឧត្តមភាពប្រកួតប្រជែង។

(3) ដើម្បីលើកបញ្ហានេះឡើង បណ្តារដ្ឋផ្សេងទៀតភាគច្រើនបានធ្វើការ

កែប្រើច្បាប់ពន្ធក្រុមហ៊ុនពហុរដ្ឋលើភាគរយនៃការលក់នៅក្នុងរដ្ឋ ដែលវិធីនោះត្រូវបានចាត់ទុកជា "កត្តាលក់ទោល"។

(4) ប្រសិនបើរដ្ឋកាលីហ្វ័រញ៉ាអនុម័តកត្តាលក់ទោលនេះ ការិយាល័យឯករាជ្យរបស់អ្នកវិភាគច្បាប់ធ្វើការប៉ាន់ប្រមាណថា ចំណូលរបស់រដ្ឋនឹងកើនប្រមាណ 1.1 ពាន់លានដុល្លារក្នុងរយៈពេលមួយឆ្នាំ ហើយបង្កើតបានការងារបន្ថែមចំនួន 40, 000 នៅទីនោះ។

(5) បន្ថែមពីលើនេះ តាមរយៈការបញ្ចូលចំណូលដែលកើនចំនួនមួយវគ្គទៅលើការបង្កើតការងារក្នុងវគ្គលទ្ធភាពនៃថាមពល និងថាមពលស្អាតកាលីហ្វ័រញ៉ាអាចបង្កើតបានការងារបន្ថែមជាច្រើនពាន់ភ្លាម អាចកាត់បន្ថយភាពគ្មានការងារធ្វើ ធ្វើឱ្យសេដ្ឋកិច្ចប្រសើរ ព្រមទាំងជួយសន្សំអ្នកមានកាតព្វកិច្ចបង់ពន្ធលើថាមពលថែមទៀត។

(6) ចំណូលបន្ថែមអាចត្រូវបានយកទៅប្រើនៅតាមបណ្តាសាលារៀនរបស់រដ្ឋ ស្របតាមច្បាប់ថ្មីរបស់រដ្ឋកាលីហ្វ័រញ៉ា។

វគ្គទី 2 ចំណុចទី 16.3 (ចាប់ផ្តើមជាមួយវគ្គលេខ 26200) ត្រូវបានបញ្ចូលទៅក្នុងចំណុចក្រមធនធានសាធារណៈ ឱ្យបកស្រាយថា ៖

*ផ្នែកទី 16.3: ការបង្កើតការងារថាមពលស្អាត*

*ជំពូកទី 1: បញ្ញត្តិទូទៅ*

*26200. បញ្ញត្តិនេះគួរត្រូវបានដឹង និងទុកធ្វើជាឯកសារយោងក្រោមប្រធានបទសកម្មភាពការងារថាមពលស្អាតរដ្ឋកាលីហ្វ័រញ៉ា។*

*26201. បញ្ញត្តិនេះមានកម្មវត្ថុដូចតទៅ:*

*(a) បង្កើតការងារលទ្ធភាពនៃថាមពល និងថាមពលស្អាតដែលទទួលបានប្រាក់កម្រៃខ្ពស់។*

*(b) ឱ្យរដ្ឋកាលីហ្វ័រញ៉ាធ្វើការរៀបចំជាថ្មី និងធ្វើឱ្យសាលារៀន និងអគារនៅតាមទីសាធារណៈមានភាពទាន់សម័យដើម្បីឱ្យលទ្ធភាពនៃថាមពល និងថាមពលស្អាតមានភាពប្រសើរឡើងក្នុងការបង្កើតការងារ និងជួយសន្សំថាមពល ព្រមទាំងប្រាក់កាស។*

*(c) ជម្រុញការបង្កើតវិស័យការងារឯកជនថ្មីដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពនៃថាមពលនៅតាមបណ្តាអគារពាណិជ្ជកម្ម និងស្នាក់នៅ។*

*(d) សម្រេចបាននូវការបង្កើតការងារ និងអត្ថប្រយោជន៍នៃថាមពលក្នុងកម្រិតអតិបរមាជាមួយថវិកាដែលមាន។*

*(e) ធ្វើការជំនួស បន្ថែម និងផ្តល់អានុភាពលើលទ្ធភាពនៃថាមពល និងថាមពលស្អាតដែលមានស្រាប់ដើម្បីបង្កើនអត្ថប្រយោជន៍លើវិស័យសេដ្ឋកិច្ច និងថាមពលនៅរដ្ឋកាលីហ្វ័រញ៉ាដោយសហការជាមួយគណៈកម្មាធិការថាមពលរដ្ឋកាលីហ្វ័រញ៉ា និងគណៈកម្មាធិការប្រយោជន៍សាធារណៈរដ្ឋកាលីហ្វ័រញ៉ា។*

*(f) ផ្តល់នូវគណនីសាធារណៈពេញលេញរបស់ថវិកាដែលបានចំណាយ និងការងារ និងអត្ថប្រយោជន៍សម្រេចបានទាំងអស់ ដើម្បីឱ្យកម្មវិធី និងគម្រោងទទួលបានការឧបត្ថម្ភ ដែលអនុលោមតាមបញ្ញត្តិនេះ អាចទទួលបានការពិនិត្យ និងវាយតម្លៃ។*

*ជំពូកទី 2: មូលនិធិសម្រាប់ការបង្កើតការងារថាមពលស្អាត*

*26205 មូលនិធិសម្រាប់ការបង្កើតការងារថាមពលស្អាតត្រូវបានបង្កើតឡើងនៅក្នុងរតនាគារ។ លើកលែងចំពោះការលើកក្នុងឡើងក្នុងវគ្គលេខ 26208 ទឹកប្រាក់សរុបចំនួនប្រាំរយហាសិបលានដុល្លារ ($550, 000, 000) ត្រូវផ្ទេរពីមូលនិធិទូទៅ ទៅមូលនិធិបង្កើតការងារក្នុងឆ្នាំសារពើពន្ធ 2013-14, 2014-15, 2015-16, 2016-17, និង 2017-18។ ទឹកប្រាក់នៅក្នុងមូលនិធិនោះអាចយកទៅប្រើប្រាស់សមស្របតាមគោលបំណងនៃគម្រោងមូលនិធិ ដែលអាចបង្កើតការងារនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាដើម្បីធ្វើឱ្យលទ្ធភាពនៃថាមពល និងការពង្រីកជំនាន់ថាមពលស្អាតមានភាពប្រសើរឡើង រួមទាំងចំណុចខាងក្រោម:*

*(a) សាលារៀន និងប្រយោជន៍សាធារណៈ:*

*(1) សាលារៀនរបស់រដ្ឋ: ការបង្កើតលទ្ធភាពនៃថាមពលដែលត្រូវបានបញ្ចូលវគ្គថ្មី និងថាមពលស្អាត រួមជាមួយការធ្វើឱ្យប្រសើរឡើង និងការជួសជុលពាក់ព័ន្ធ ដែលរួមចំណែកកាត់បន្ថយថ្លៃដើមប្រតិបត្តិការ និងធ្វើឱ្យសុខភាព ព្រមទាំងលក្ខខណ្ឌសុវត្ថិភាពនៅតាមបណ្តាសាលារៀនរបស់រដ្ឋ មានភាពប្រសើរឡើង។*

*(2) សាកលវិទ្យាល័យ និងមហាវិទ្យាល័យ: ការធ្វើឱ្យមានភាពប្រសើរលើលទ្ធភាពនៃថាមពលដែលត្រូវបានបញ្ចូលវគ្គថ្មី ថាមពលស្អាត និងប្រព័ន្ធថាមពលដទៃទៀតដើម្បីកាត់បន្ថយថ្លៃដើម និងទទួលបានថាមពល ព្រមទាំងប្រយោជន៍បរិស្ថាន។*

*(3) អាគារ និងប្រយោជន៍ដទៃទៀត: ការផ្តល់ជំនួយវគ្គហិរញ្ញវត្ថុ និងបច្ចេកទេស ដោយរួមមានការបង្វិលមូនិធិកម្ចី កាត់បន្ថយការប្រាក់កម្ចី ឬជំនួយវគ្គហិរញ្ញវត្ថុដទៃទៀតសម្រាប់ការបង្កើតលទ្ធភាពនៃថាមពលដែលត្រូវបានបញ្ចូលវគ្គថ្មី និងថាមពលស្អាតឱ្យប្រសិទ្ធភាពថ្លៃដើមចំពោះប្រយោជន៍សាធារណៈ។*

*(b) ការបណ្តុះបណ្តាលការងារ និងការអភិវឌ្ឍន៍កម្លាំងការងារ: ការផ្តល់មូលនិធិឱ្យសាជីវកម្មអភិរក្សរដ្ឋកាលីហ្វ័រញ៉ា សាជីវកម្មអភិរក្សសហគមន៍ដែលទទួលបានការបញ្ជាក់ ការកសាងកម្លាំងយុវជន និងកម្មវិធីអភិវឌ្ឍន៍កម្លាំងការងារមានស្រាប់ ដើម្បីបណ្តុះបណ្តាល និងផ្តល់ការងារឱ្យយុវជនសមត្ថភាពមិនអំណោយផលពីកំណើត និងលទ្ធភាពនៃថាមពល ព្រមទាំងគម្រោងថាមពលស្អាតដទៃទៀត។*

*(c) ដៃគូសាធារណៈ និងឯកជន: ការផ្តល់ជំនួយឱ្យរដ្ឋាភិបាលក្នុងការបង្កើត និងអនុវត្តកម្មវិធីការប៉ាន់ប្រមាណទ្រព្យថាមពលស្អាត (PACE) ឬការផ្តល់ជំនួយវគ្គហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ការបន្ថែមវគ្គថ្មីដែលមានប្រសិទ្ធភាពថ្លៃដើម ដោយរួមមានតំរូវការការទូទាត់ប្រាក់។ ការផ្តល់មូលនិធិត្រូវធ្វើឡើងជាអាទិភាពដើម្បីធ្វើអតិបរមាកម្មលើបង្កើតការងារ ការសន្សំសំចៃថាមពល និងសមភាពលើវគ្គភូមិសាស្ត្រ និងសេដ្ឋកិច្ច។ បើអាចទៅរួច ការទូទាត់លើចំណូល គួរត្រូវប្រើដើម្បីបង្កើតការបង្វិលកម្ចីមូលនិធិ ឬកម្មវិធីផ្តល់ជំនួយវគ្គហិរញ្ញវត្ថុដែលកំពុងដំណើរការ ដើម្បីឱ្យមានអត្ថប្រយោជន៍លើការបង្កើតការងារជាបន្តទៀត។*

*26206. លក្ខខណ្ឌខាងក្រោមអាចយកទៅអនុវត្តលើរាល់ការចំណាចទាំងអស់របស់មូលនិធិបង្កើតការងារ:*

*(a) ការជ្រើសរើស និងការពិនិត្យមើលលើគម្រោងគួរត្រូវបានគ្រប់គ្រងដោយភ្នាក់ងាររដ្ឋាភិបាលរបស់រដ្ឋ និងក្នុងតំបន់ជាមួយអ្នកឯកទេសក្នុងការគ្រប់គ្រងគម្រោង និងកម្មវិធីថាមពល។*

*(b) គម្រោងទាំងអស់ត្រូវជ្រើសរើសដោយផ្អែកលើការបង្កើតការងារ និងអត្ថប្រយោជន៍នៃថាមពលនៅក្នុងរដ្ឋសម្រាប់ប្រភេទគម្រោងនីមួយៗ។*

*(c) គម្រោងទាំងអស់ត្រូវមានប្រសិទ្ធភាពថ្លៃដើម: អត្ថប្រយោជន៍សរុបគួរមានលក្ខណៈជាថ្លៃដើមគម្រោង។ ការជ្រើសរើសគម្រោងត្រូវមានការពិចារណាលើអត្ថប្រយោជន៍មិនប្រើថាមពល ដូចជាសុខភាព និងសុវត្ថិភាពបន្ថែមលើអត្ថប្រយោជន៍ថាមពល។*

*(d) គម្រោងទាំងអស់គួរតំរូវឱ្យមានកិច្ចសន្យាដែលកំណត់ចំណុចពិសេសរបស់គម្រោង ថ្លៃដើម និងការសន្សំសំចៃថាមពល។*

*(e) គម្រោងទាំងអស់ត្រូវមានការធ្វើសវនកម្ម។*

*(f) កម្មវិធីដែលត្រូវការថ្លៃដើមលើសមិនត្រូវចំណាយលើស 4 ភាគរយនៃមូលនិធិសរុបទេ។*

*(g) មូលនិធិត្រូវមានលក្ខណៈសមស្របសម្រាប់តែភ្នាក់ងារដែលមានអ្នកឯកទេសបង្កើតសម្រាប់ការគ្រប់គ្រងគម្រោង និងកម្មវិធីថាមពលតែប៉ុណ្ណោះ។*

*(h) កម្មវិធីទាំងអស់ត្រូវមានការសម្របសម្រួលជាមួយគណៈកម្មាធិការថាមពលរដ្ឋកាលីហ្វ័រញ៉ា និងគណៈកម្មាធិការប្រយោជន៍សាធារណៈរដ្ឋកាលីហ្វ័រញ៉ាដើម្បីចៀសវាងការលួចចម្លង និងដើម្បីធ្វើអតិបរមាកម្មជាអានុភាពលើការងារលទ្ធភាពថាមពល និងថាមពលស្អាត។*

*(i) ការចំណាយចាំបាច់រួមមានថ្លៃដើមដែលពាក់ព័ន្ធជាមួយការផ្តល់ជំនួយវគ្គបច្ចេកទេស និងជាមួយការកាត់បន្ថយថ្លៃដើម និងពន្យារពេលរបស់គម្រោង ដូចជាដំណើរការការអភិវឌ្ឍន៍ និងការអនុវត្តដែលកាត់បន្ថយថ្លៃដើមនៃការរចនា ការអនុញ្ញាត ឬការធ្វើហិរញ្ញប្បទាន ឬរនាំងផ្សេងទៀតលើការបញ្ចប់គម្រោង និងការបង្កើតការងារ។*

*26208 ប្រសិនបើការិយាល័យហិរញ្ញវត្ថុ និងអ្នកវិភាគច្បាប់ធ្វើការ*

*កំណត់រួមគ្នាថា ការប៉ាន់ប្រមាណលើការកើនឡើងនៃចំណូលប្រចាំឆ្នាំដែលជាលទ្ធផលនៃការធ្វើវិសោធនកម្ម ការបន្ថែម ឬការលុបចោលនូវវគ្គលេខ 25128 25128.5 25128.7 និង 25136 នៃលេខកូដចំណូល និងពន្ធ គឺតិចជាងមួយពាន់មួយរយលានដុល្លារ ($1,100,000,000) ហើយចំនួនដែលផ្ទេរទៅមូលនិធិបង្កើតការងារត្រូវកាត់បន្ថយតាមចំនួនស្មើនឹងមួយកន្លះនៃការប៉ាន់ប្រមាណលើការកើនឡើងនៃចំណូលប្រចាំឆ្នាំ។*

*ជំពូកទី 3: ការទទួលខុសត្រូវ ការធ្វើសវនកម្មឯករាជ្យ ការបង្ហាញជាសាធារណៈ*

*26210 (a) ក្រុមប្រឹក្សាត្រួតពិនិត្យប្រជាពលរដ្ឋ ត្រូវបានបង្កើតឡើងនៅទីនេះ។*

*(b) ក្រុមប្រឹក្សាត្រូវបង្កើតឡើងដោយមានសមាជិកប្រាំបួននាក់: សមាជិកបីនាក់ត្រូវតែតាំងដោយរតនាការ បីនាក់ទៀតតែងតាំងដោយអ្នកត្រួតពិនិត្យ និងបីនាក់ទៀតដោយមេធាវីជាន់ខ្ពស់។ ការិយាល័យតែងតាំងនីមួយៗត្រូវតែងតាំងសមាជិកម្នាក់ដែលអាចបំពេញតាមលក្ខខណ្ឌខាងក្រោមនេះ:*

*(1) ជាវិស្វករ ស្ថាបត្យករ ឬបុគ្គលមានអាជីពដទៃទៀតដែលមានចំណេះដឹង និងឯកទេសខាងសាងសង់ ឬរចនាអាគារ ។*

*(2) ជាគណនេយ្យករ អ្នកសេដ្ឋកិច្ច ឬបុគ្គលមានអាជីពដទៃទៀតដែលមានចំណេះដឹង និងឯកទេសខាងវាយតម្លៃប្រតិបត្តិការហិរញ្ញវត្ថុ និង កម្មវិធីប្រសិទ្ធភាពថ្លៃដើម។*

*(3) ជាអ្នកឯកទេសបច្ចេកទេសលើលទ្ធភាពនៃថាមពល ថាមពលស្អាត ឬប្រព័ន្ធ និងកម្មវិធីថាមពល។*

*(c) គណៈកម្មាធិការប្រយោជន៍សាធារណៈរដ្ឋកាលីហ្វ័រញ៉ា និងគណៈកម្មាធិការថាមពលរដ្ឋកាលីហ្វ័រញ៉ាម្នាក់ៗត្រូវចាត់តាំងសមាជិកការិយាល័យឱ្យជួយក្រុមប្រឹក្សា។*

*(d) ក្រុមប្រឹក្សាត្រូវធ្វើចំណុចខាងក្រោម:*

*(1) ពិនិត្យឡើងវិញជាប្រចាំឆ្នាំនូវរាល់ការចំណាយពីមូលនិធិបង្កើតការងារ។*

*(2) ចុះធ្វើបេសកកម្ម និងពិនិត្យឡើងវិញនូវការធ្វើសវនកម្មឯករាជ្យប្រចាំឆ្នាំលើមូលនិធិបង្កើតការងារ និងការជ្រើសរើសគម្រោងដែលបានបញ្ចប់ដើម្បីប៉ាន់ប្រមាណលើប្រសិទ្ធភាពការចំណាយដើម្បីសម្រេចឱ្យបានកម្មវត្ថុក្នុងចំណុចនេះ។*

*(3) ចេញផ្សាយប្រតិបត្តិការគណនេយ្យពេញលេញនៃរាល់ការចំណាយប្រចាំឆ្នាំនីមួយៗ តាមរយៈការផ្សាយព័ត៌មានលើគេហទំព័រមួយក្នុងប្រព័ន្ធអ៊ីនធឺណិតដែលអាចចូលទៅមើលជាសាធារណៈបាន។*

*(4) ប្រគល់ការវាយតម្លៃកម្មវិធីទៅអង្គនីតិបញ្ញត្តិដោយធ្វើការកំណត់លើការប្រែប្រួលចាំបាច់ដើម្បីសម្រេចឱ្យបាននូវកម្មវត្ថុក្នុងចំណុចនេះ។*

*ជំពូកទី 4. និយមន័យ*

*26220. និយមន័យខាងក្រោមត្រូវយកទៅអនុវត្តក្នុងចំណុចនេះ:*

*(a) "ថាមពលស្អាត" គឺជាឧបករណ៍ ឬបច្ចេកវិទ្យាដែលបំពេញនិយមន័យឱ្យ "ថាមពលដែលអាចប្រើជាថ្មីបាន" ក្នុងវគ្គលេខ 26003 ឬដែលរួមចំណែកធ្វើឱ្យការគ្រប់គ្រង ឬលទ្ធភាពនៃថាមពលមានភាពប្រសើរឡើង។*

*(b) "ក្រុមប្រឹក្សា" គឺសំដៅដល់ក្រុមប្រឹក្សាត្រួតពិនិត្យប្រជាពលរដ្ឋដែលត្រូវបានបង្កើតក្នុងវគ្គលេខ 26210។*

*(c) "មូលនិធិបង្កើតការងារ" គឺជាមូលនិធិបង្កើតការងារថាមពលស្អាតដែលត្រូវបានបង្កើតឡើងនៅក្នុងវគ្គលេខ 26205។*

*(d) "កម្មវិធីចំណាយថ្លៃដើមលើស" រួមមានការចាត់ចែងបុគ្គលិកសម្រាប់ការអភិវឌ្ឍន៍ និងការគ្រប់គ្រងភ្នាក់ងាររដ្ឋនៃកម្មវិធីផ្តល់មូលនិធិស្របតាមវគ្គនេះ ប៉ុន្តែមិនគិតលើការផ្តល់ជំនួយវគ្គបច្ចេកទេស ការវាយតម្លៃការវាស់វែង និងការបញ្ជាក់ពីសុពលភាព ឬការចំណាយពាក់ព័ន្ធនឹងការបង្កើនលទ្ធភាពគម្រោង ឬការប្រតិបត្តិការ ព្រមទាំងចំណាយពាក់ព័ន្ធនឹងការអនុវត្តន៍ក្នុងតំបន់។*

វគ្គទី 3: វគ្គលេខ 23101នៃលេខកូដចំណូល និងពន្ធត្រូវបានកែប្រែដើម្បីអាន:

23101. (a) "ការធ្វើជំនួញ" សំដៅដល់ពាក់ព័ន្ធយ៉ាងសកម្មក្នុងការធ្វើប្រតិបត្តិការដើម្បីសម្រេចឱ្យបាននូវកម្មវត្ថុនៃអត្ថប្រយោជន៍វគ្គហិរញ្ញវត្ថុ ឬប្រាក់កាស ឬប្រាក់ចំណេញ។

(b) ចំពោះឆ្នាំគិតពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ2011 អ្នកមានកាតព្វកិច្ចបង់ពន្ធកំពុងធ្វើជំនួញនៅក្នុងរដ្ឋនេះសម្រាប់ឆ្នាំពន្ធមួយប្រសិនបើបំពេញបាននូវលក្ខខណ្ឌខាងក្រោម:

(1) អ្នកមានកាតព្វកិច្ចបង់ពន្ធត្រូវទទួលបានការរៀបចំ ឬតាំងលំនៅក្នុងន័យពាណិជ្ជកម្មនៅក្នុងរដ្ឋនេះ។

(2) ការលក់របស់អ្នកមានកាតព្វកិច្ចបង់ពន្ធនៅក្នុងរដ្ឋនេះ ដូចដែលបានកំណត់ក្នុងវគ្គរង (ង) ឬ (ច) នៃវគ្គលេខ 25120 អនុវត្តបានសម្រាប់ឆ្នាំបង់ពន្ធ លើសយ៉ាងតិចណាស់ប្រាំរយពាន់ដុល្លារ ($500,000) ឬត្រូវនឹង 25ភាគរយនៃការលក់សរុបរបស់អ្នកមានកាតព្វកិច្ចបង់ពន្ធ។ ក្នុងវត្ថុបំណងនៃកថាខណ្ឌនេះ ការលក់របស់អ្នកមានកាតព្វកិច្ចបង់ពន្ធរួមមានការលក់ដោយភ្នាក់ងារ ឬអ្នកជាប់កិច្ចសន្យាឯករាជ្យរបស់អ្នកមានកាតព្វកិច្ចបង់ពន្ធ។ ចំពោះវត្ថុបំណងនៃកថាខណ្ឌនេះ ការលក់នៅក្នុងរដ្ឋនេះត្រូវកំណត់ដោយប្រើច្បាប់ការចាត់ចែងការលក់ក្រោម~~វគ្គមួយ~~ វគ្គច្រើន 25135 និងចំណុច ~~(b) នៃវគ្គលេខ~~ 25136 និងបទបញ្ញត្តិដូចបានបញ្ជាក់ក្នុងបទបញ្ញត្តិក្នុងវគ្គលេខ 25137។

(3) ទ្រព្យជាក់ស្តែង និងទ្រព្យរូបិយផ្ទាល់ខ្លួនរបស់អ្នកមានកាតព្វកិច្ចបង់ពន្ធក្នុងរដ្ឋនេះលើសយ៉ាងតិចណាស់ហាសិបពាន់ដុល្លារ ($50,000) ឬ 25ភាគរយនៃទ្រព្យជាក់ស្តែង និងទ្រព្យរូបិយផ្ទាល់ខ្លួនសរុបរបស់អ្នកមានកាតព្វកិច្ចបង់ពន្ធ។ តម្លៃរបស់ទ្រព្យជាក់ស្តែង និងទ្រព្យរូបិយផ្ទាល់ខ្លួន និងការកំណត់ថាតើទ្រព្យនៅក្នុងរដ្ឋនេះគួរត្រូវបានកំណត់ដោយប្រើច្បាប់មានក្នុងវគ្គលេខ 25129 ដល់ 25131 និងបញ្ញត្តិនៅទីនោះ ដូចបានបញ្ជាក់ក្នុងបទបញ្ញត្តិវគ្គលេខ 25137។

(4) ទឹកប្រាក់បង់នៅក្នុងរដ្ឋដោយអ្នកមានកាតព្វកិច្ចបង់ពន្ធសម្រាប់ការសងជម្ងឺចិត្ត ដូចបានកំណត់ក្នុងវគ្គរង (c) នៃវគ្គលេខ 25120 លើសយ៉ាងតិចណាស់ហាសិបពាន់ដុល្លារ ($50,000) ឬ 25ភាគរយនៃការសងជម្ងឺចិត្តសរុបបង់ដោយអ្នកមានកាតព្វកិច្ចបង់ពន្ធ។ ការសងជម្ងឺចិត្តក្នុងរដ្ឋនេះត្រូវកំណត់ដោយប្រើច្បាប់ក្នុងការចាត់ចែងបញ្ជីប្រាក់ខែមាននៅក្នុងវគ្គលេខ 25133 និងបទបញ្ញត្តិដូចបានបញ្ជាក់ដោយបទបញ្ញត្តិក្នុងវគ្គលេខ 25137។

(c) (1) ក្រុមប្រឹក្សាការបង់ពន្ធការទិញសិទ្ធលក់ត្រូវពិនិត្យឡើងវិញជាប្រចាំឆ្នាំនូវទឹកប្រាក់ក្នុងកថាខណ្ឌលេខ (2) (3) និង(4) នៃវគ្គរង (ខ) ស្របតាមវគ្គរង (h) នៃវគ្គលេខ 17041។

(2) សម្រាប់គោលបំណងនៃការកែសម្រួលតំរូវនៅក្នុងកថាខណ្ឌ (1) វគ្គរង (ជ) នៃវគ្គលេខ 17041 ត្រូវបានយកទៅអនុវត្តតាមរយៈការជំនួស "1988" ដោយ "2012"

(d) ការលក់ ទ្រព្យសម្បត្តិ និងបញ្ជីប្រាក់ខែរបស់អ្នកមានកាតព្វកិច្ចបង់ពន្ធរួមមានអត្រារបស់អ្នកជាប់កាតព្វកិច្ចបង់ពន្ធ ឬភាគហ៊ុនរួមចំណែករបស់ភាគីរួចកាតព្វកិច្ច។ ក្នុងគោលបំណងនៃវគ្គរងនេះ "បុគ្គលរួចកាតព្វកិច្ច" គឺជាភាពជាដៃគូ ឬសាជីវកម្មអក្សរ "S"។

វគ្គទី 4: វគ្គលេខ 25128 នៃលេខកូដប្រាក់ចំណូល និងពន្ធត្រូវបានកែសម្រាប់ការអាន:

25128 (a) ដោយមិនគិតពីវគ្គលេខ 38006 សម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមពីថ្ងៃទី 1 ខែមករា ឆ្នាំ 2013 ចំណូលទាំងអស់ពីការធ្វើជំនួញត្រូវបែងចែកទៅរដ្ឋនេះដោយគុណនឹងចំណូលពីការធ្វើជំនួញគិតជាប្រភាគ ដោយភាគយកគឺកត្តាទ្រព្យបូកកត្តាបញ្ជីប្រាក់ខែបូកកត្តាការលក់ចំនួនពីរដង ហើយភាគបែងស្មើបួន លើកលែងការផ្តល់ឱ្យក្នុងអនុផ្នែក (b) និង (c)។

(b) បើពាណិជ្ជកម្ម ឬជំនួញដែលបែងចែកចេញមកច្រើនជាង 50ភាគរយនៃ "ការទូទាត់ការធ្វើជំនួញសរុប" ពីការធ្វើសកម្មភាពជំនួញមានគុណភាពមួយ ចំណូលទាំអស់ពីការធ្វើជំនួញនៃការបែងចែកការធ្វើពាណិជ្ជកម្ម ឬជំនួញត្រូវបែងចែកទៅរដ្ឋនេះដោយគុណនឹងចំណូលពីការធ្វើជំនួញក្នុងទំរង់ប្រភាគ ដែលភាគយកគឺជាកត្តាទ្រព្យបូកកត្តាបញ្ជីប្រាក់ខែ បូកកត្តាការលក់ ហើយភាគបែងស្មើនឹងបី។

(c) ចំពោះគោលបំណងនៃវគ្គនេះ "សកម្មភាពជំនួញមានគុណភាព" គឺសំដៅដល់សកម្មភាពដូចខាងក្រោម:

(1) សកម្មភាពជំនួញលើវិស័យកសិកម្ម

(2) សកម្មភាពជំនួញទាញយក

(3) សកម្មភាពសន្សំ និងកម្ចី

(4) សកម្មភាពជំនួញខាងវត្តធនាគារ ឬហិរញ្ញវត្ថុ

(d) ចំពោះគោលបំណងនៃវគ្គនេះ ៖

(1) "ការទូទាត់ការធ្វើជំនួញសរុប" គឺសំដៅលើការទូទាត់ដែលត្រូវបានពិពណ៌នានៅក្នុងអនុផ្នែក (e) ឬ (f) នៃវគ្គលេខ 25120 (ជាជាងការទូទាត់សរុបពីការលក់ ឬប្រតិបត្តិការផ្សេងទៀតនៅក្នុងពាណិជ្ជកម្ម ឬជំនួញដែលមានការបែងចែករវាងសមាជិកក្រុមសាជីវកម្ម ដែលមានកត្តាចំណូល និងការបែងចែកតំរូវឱ្យបញ្ចូលក្នុងរបាយការណ៍នៅក្នុងវគ្គលេខ 25101 កំណត់ដោយវគ្គលេខ 25110) ថាតើការទូទាត់ទាំងនោះត្រូវបានដកចេញពីកត្តាការលក់ដោយប្រតិបត្តិការក្នុងវគ្គលេខ 25137។

(2) "សកម្មភាពជំនួញលើវិស័យកសិកម្ម" សំដៅលើសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងភាគហ៊ុន ទឹកដោះគោ បសុសត្វ ផ្លែឈើ ពាមសត្វ ឬកសិដ្ឋាន ចម្ការ ក្រោល កន្លែងបណ្តុះ ឬឆ្លាចិញ្ចឹមសត្វ។ "សកម្មភាពជំនួញលើវត្តកសិកម្ម" ក៏រាប់បញ្ចូលសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងការធ្វើដីដាំដុះ ឬការចិញ្ចឹមសត្វ ឬការច្រូតកាត់ក្នុងវិស័យកសិកម្ម ឬសាកវប្បកម្ម រួមមានការចិញ្ចឹមសត្វ ការកាត់ ការចិញ្ចឹម ការមើលថែ ការបណ្តុះបណ្តាល ឬការមើលសត្វនៅកសិដ្ឋាន ក៏ដូចជាការកាន់ សម្ងួត វេចខ្ចប់ ធ្វើឱ្យទាល ឬទុកដាក់នៅក្នុងកសិដ្ឋាននូវទំនិញកសិកម្ម ឬសាកវប្បកម្មក្នុងរដ្ឋមិនធ្វើការផលិត តែលុះត្រាណាម្ចាស់ ភាគីជួល ឬអ្នកប្រតិបត្តិការនៅកសិដ្ឋានផលិតបានច្រើនជាងមួយកន្លះនៃទំនិញឱ្យបានជាប្រចាំ។

(3) "សកម្មភាពជំនួញទាញយក" សំដៅដល់សកម្មភាពពាក់ព័ន្ធនឹងផលិតកម្ម ការចម្រាញ់ ឬដំណើរការផលិតប្រេង ឧស្ម័នធម្មជាតិ ឬរ៉ែខ និង។

(4) "សកម្មភាពសន្សំ និងកម្ចី" គឺជាសកម្មភាពធ្វើឡើងដោយសហគមន៍សន្សំ និងកម្ចី ឬធនាគារសន្សំដែលត្រូវបានដាក់បញ្ចូលក្នុងធម្មនុញ្ញដោយច្បាប់សហព័ន្ធ ឬច្បាប់រដ្ឋ។

(5) "សកម្មភាពជំនួញលើវត្តធនាគារ ឬហិរញ្ញវត្ថុ" គឺជាសកម្មភាពកំណត់ឱ្យពាក់ព័ន្ធនឹងប្រាក់ ឬមូលធនក្នុងការប្រកួតប្រជែងត្រឹមត្រូវ ជាមួយជំនួញរបស់ធនាគារជាតិ។

(6) "ពាណិជ្ជកម្ម ឬជំនួញដែលមានការបែងចែក" គឺជាពាណិជ្ជកម្ម ឬជំនួញដោយឡែក ដែលមានចំណូលពីការធ្វើជំនួញតំរូវឱ្យបែងចែកក្នុងវគ្គលេខ 25110 ដោយប្រើភាគបែងដូចគ្នាសម្រាប់កត្តាបញ្ជីប្រាក់ខែ ទ្រព្យសម្បត្តិ និងការលក់នីមួយៗ។

(7) កថាខណ្ឌ (4) នៃអនុផ្នែក (គ) ត្រូវយកទៅអនុវត្តលុះត្រាណាក្រុមប្រឹក្សាពន្ធលើការទិញសិទ្ធិអនុម័តរូបមន្តរបស់គណៈកម្មាធិការយកពន្ធពហុរដ្ឋដែលបានស្នើ សម្រាប់ការបែងចែកជាសណ្ឋាននូវចំណូលពីស្ថាប័នហិរញ្ញវត្ថុ ឬស្ថាប័នមានលក្ខខណ្ឌស្មើ ហើយក្លាយជាមានប្រតិបត្តិការតាមកាលបរិច្ឆេទប្រតិបត្តិការដូចគ្នា ដូចដែលបានអនុវត្តតាមរូបមន្ត។

(8) ក្នុងករណីដែលកត្តាចំណូល និងការបែងចែករបស់សហគមន៍ ឬសាជីវកម្មចំនួនតិចច្រើនត្រូវតំរូវឱ្យដាក់បញ្ចូលក្នុងរបាយការណ៍រួមក្នុងវគ្គលេខ 25101 ដោយវគ្គលេខ 25110 ត្រូវយកចំណុចទាំងពីរខាងក្រោមមកអនុវត្ត:

(A) ការអនុវត្តន៍ការធ្វើតេស្តសាកល្បងច្រើនជាង 50ភាគរយ នៃអនុផ្នែក

(b) ត្រូវធ្វើឡើងឱ្យស្របតាម "ការទូទាត់ការធ្វើជំនួញសរុប" នៃការធ្វើពាណិជ្ជកម្ម ឬជំនួញដែលបែងចែកទាំងអស់របស់ក្រុម។

(B) ចំណូលបានពីការធ្វើជំនួញទាំងអស់របស់ក្រុមត្រូវបែងចែកឱ្យស្របតាមអនុផ្នែក (a) ~~ឬ (b) ឬអនុផ្នែក (b) នៃវគ្គលេខ 25128.5~~ វគ្គលេខ 251258.5 ឬ 25128.7។

វគ្គទី 5: វគ្គលេខ 25128.5 នៃក្រមប្រាក់ចំណូល និងពន្ធត្រូវកែប្រែដើម្បីអាន: 25128.5។ (a) ដោយមិនគិតពីវគ្គលេខ 38006 សម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2011 និងមុន *ថ្ងៃទី1 ខែមករា ឆ្នាំ2013* ការធ្វើពាណិជ្ជកម្ម ឬជំនួញណាមួយ ក្រៅពីការធ្វើពាណិជ្ជកម្ម ឬជំនួញដូចមានពិពណ៌នាក្នុងអនុផ្នែក (b)នៃវគ្គលេខ 25128 ត្រូវធ្វើការបោះឆ្នោតប្រចាំឆ្នាំមិនអាចបញ្ច្រាស់បានលើសំណងដើមដែលរៀបចំតាមកាលកំណត់ក្នុងបែបផែន និងទម្រង់ចេញបញ្ញត្តិដោយក្រុមប្រឹក្សាពន្ធលើការទិញសិទ្ធិដើម្បីបែងចែកចំណូលស្របតាមវគ្គនេះ ហើយមិនស្របតាមវគ្គលេខ 25128។

(b) ដោយមិនគិតពីវគ្គលេខ 38006 សម្រាប់ឆ្នាំបង់ពន្ធនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2011 និង*មុនថ្ងៃទី1 ខែមករា ឆ្នាំ2013* ចំណូលទាំងអស់ពីការធ្វើជំនួញនៃការធ្វើពាណិជ្ជកម្ម ឬជំនួញបង្កើតការបោះឆ្នោតដូចមានពិពណ៌នានៅក្នុងវគ្គរង (a) ត្រូវបែងចែកទៅរដ្ឋនេះដោយគុណចំណូលពីការធ្វើជំនួញនឹងកត្តាការលក់។

(c) ក្រុមប្រឹក្សាពន្ធលើការទិញសិទ្ធិមានសិទ្ធិចេញបទបញ្ញត្តិចាំបាច់ ឬសមស្របពាក់ព័ន្ធនឹងការធ្វើការបោះឆ្នោតនៅក្នុងវគ្គនេះ ដោយរួមមានបទបញ្ញត្តិស្របតាមច្បាប់សម្រាប់ការបោះឆ្នោតនៅក្នុងវគ្គលេខ 25113។

(d) *វគ្គនេះមិនអនុវត្តលើឆ្នាំបង់ពន្ធចាប់ផ្តើមនៅឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2012 ហើយវគ្គដាក់ឱ្យអនុវត្តនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2013 ត្រូវលុបចោល។*

វគ្គទី 6: វគ្គលេខ 25128.7 ត្រូវបញ្ចូលទៅក្នុងលេខកូដចំណូល និងពន្ធ ឱ្យបកស្រាយថា ៖

*25128.7 ដោយមិនគិតលើវគ្គលេខ 38006 សម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2013 ចំណូលទាំងអស់ពីការធ្វើជំនួញនៃការធ្វើពាណិជ្ជកម្ម ឬជំនួញក្រៅពីការធ្វើពាណិជ្ជកម្ម ឬជំនួញដូចមានពិពណ៌នាក្នុងអនុផ្នែក (b) នៃវគ្គលេខ 25128 ត្រូវបែងចែកទៅរដ្ឋនេះដោយធ្វើការគុណចំណូលពីការធ្វើជំនួញ នឹងកត្តាការលក់ ។*

វគ្គទី 7: វគ្គលេខ 25136 នៃលេខកូដចំណូល និងពន្ធត្រូវបានធ្វើវិសោធនកម្ម ឱ្យបកស្រាយថា ៖

25136 (a) សម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមមុនថ្ងៃទី1 ខែមករា ឆ្នាំ2011 និងសម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2011និង*មុនថ្ងៃទី1 ខែមករា ឆ្នាំ2013* ដែលវគ្គលេខ 25128.5 ត្រូវធ្វើប្រតិបត្តិការ ហើយការបោះឆ្នោតក្នុងវគ្គរង (a) នៃវគ្គលេខ 25128.5 មិនទាន់ត្រូវបានធ្វើឡើង ការលក់ក្រៅពីការលក់ទ្រព្យរូបិយផ្ទាល់ខ្លួនស្ថិតនៅក្នុងរដ្ឋនេះ ប្រសិនបើ ៖

(1) សកម្មភាពរកប្រាក់ចំណូលត្រូវបានធ្វើនៅក្នុងរដ្ឋនេះ ឬ

(2) សកម្មភាពរកប្រាក់ចំណូលត្រូវបានធ្វើទាំងនៅក្នុង និងក្រៅរដ្ឋ ហើយសកម្មភាពរកប្រាក់ចំណូលមួយវគ្គធំជាងនេះត្រូវធ្វើនៅក្នុងរដ្ឋជាជាងនៅរដ្ឋផ្សេងទៀតដោយផ្អែកលើថ្លៃដើមនៃការធ្វើប្រតិបត្តិការ។

(3) អនុផ្នែកនេះត្រូវយកទៅអនុវត្ត ហើយអនុផ្នែក (b) មិនត្រូវយកទៅអនុវត្តសម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2011 និងមុនថ្ងៃទី1 ខែមករា ឆ្នាំ2013 ដែលវគ្គលេខ 25128.5 មិនត្រូវប្រតិបត្តិសម្រាប់អ្នកមានកាតព្វកិច្ចបង់ពន្ធដែលជាកម្មវត្ថុនៃពន្ធដាក់នៅក្នុងវគ្គនេះ។

(b) សម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2011 *និងមុនថ្ងៃទី1 ខែមករា ឆ្នាំ2013* ៖

(1) ការលក់ពីសេវាកម្មនៅក្នុងរដ្ឋនេះក្នុងទំហំដែលអ្នកទិញសេវាកម្មទទួលបានអត្ថប្រយោជន៍ពីសេវាកម្មនៅក្នុងរដ្ឋ។

(2) ការលក់ពីទ្រព្យអរូបិយក្នុងរដ្ឋនេះក្នុងទំហំដែលទ្រព្យត្រូវយកទៅប្រើប្រាស់នៅក្នុងរដ្ឋ។ ក្នុងករណីមានមូលបត្រទីផ្សារ ការលក់ស្ថិតនៅក្នុងរដ្ឋប្រសិនបើអតិថិជននៅក្នុងរដ្ឋនេះ។

(3) ការលក់ពីការលក់ ជួល ឬការផ្តល់អាជ្ញាប័ណ្ណលើចលនទ្រព្យផ្ទាល់ខ្លួននៅក្នុងរដ្ឋនេះប្រសិនបើទ្រព្យមានទីតាំងនៅក្នុងរដ្ឋនេះ។

(4) ការលក់ពីការជួល ឬការផ្តល់អាជ្ញាប័ណ្ណលើចលនទ្រព្យផ្ទាល់ខ្លួននៅក្នុងរដ្ឋនេះប្រសិនបើទ្រព្យមានទីតាំងនៅក្នុងរដ្ឋនេះ។

(5) (A) ប្រសិនបើវគ្គលេខ 25128.5 ត្រូវប្រតិបត្តិ អនុផ្នែកនេះត្រូវយកទៅអនុវត្តជំនួសឱ្យអនុផ្នែក (a) សម្រាប់ឆ្នាំបង់ពន្ធណាមួយដែលការបោះឆ្នោតធ្វើឡើងក្នុងអនុផ្នែក (a) នៃវគ្គលេខ 25128.5។

(B) ប្រសិនបើវគ្គលេខ 25128.5 មិនប្រតិបត្តិ អនុផ្នែកនេះមិនត្រូវយកទៅអនុវត្តទេ ហើយអនុផ្នែក (a) ត្រូវយកទៅអនុវត្តលើអ្នកមានកាតព្វកិច្ចបង់ពន្ធដែលជាកម្មវត្ថុនៃការបង់ពន្ធដាក់ក្នុងវគ្គនេះ។

(C) ដោយមិនគិតលើកថាខណ្ឌរង (A) ឬ (B) អនុផ្នែកនេះត្រូវយកទៅអនុវត្តសម្រាប់គោលបំណងនៃកថាខណ្ឌ (2) នៃអនុផ្នែក (b) នៃវគ្គលេខ 23101។

(c) ក្រុមប្រឹក្សាពន្ធលើការទិញសិទ្ធិពិសេសត្រូវចេញបញ្ញត្តិទាំងនោះតាមការចាំបាច់ ឬសមស្របក្នុងការសម្រេចឱ្យបាននូវគោលបំណងរបស់ ចំណុច (b)។

*(d) វគ្គនេះមិនត្រូវយកទៅអនុវត្តក្នុងឆ្នាំបង់ពន្ធចាប់ផ្តើមនៅឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2013 ហើយវគ្គដែលនឹងដាក់ឱ្យអនុវត្តនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2013 ត្រូវលុបចោល។*

វគ្គទី 8: វគ្គលេខ 25136 ត្រូវបញ្ចូលក្នុងក្រមស្តីពីពន្ធដារ និងប្រាក់ចំណូលឱ្យបកស្រាយថា ៖

*25136 (a) ដោយមិនគិតលើវគ្គលេខ 28006 សម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2013 ការលក់ក្រៅពីការលក់ចលនទ្រព្យផ្ទាល់ខ្លួននៅក្នុងរដ្ឋនេះប្រសិនបើ:*

*(1) ការលក់ពីសេវាកម្មនៅក្នុងរដ្ឋនេះក្នុងទំហំដែលអ្នកទិញសេវាកម្មទទួលបានអត្ថប្រយោជន៍ពីសេវាកម្មនៅក្នុងរដ្ឋ។*

*(2) ការលក់ពីទ្រព្យអរូបិយក្នុងរដ្ឋនេះក្នុងទំហំដែលទ្រព្យត្រូវយកទៅប្រើប្រាស់នៅក្នុងរដ្ឋ។ ក្នុងករណីមានមូលបត្រទីផ្សារ ការលក់ស្ថិតនៅក្នុងរដ្ឋប្រសិនបើអតិថិជននៅក្នុងរដ្ឋនេះ។*

*(3) ការលក់ពីការលក់ ជួល ឬការផ្តល់អាជ្ញាប័ណ្ណលើចលនទ្រព្យផ្ទាល់ខ្លួននៅក្នុងរដ្ឋនេះប្រសិនបើទ្រព្យមានទីតាំងនៅក្នុងរដ្ឋនេះ។*

*(4) ការលក់ពីការជួល ឬការផ្តល់អាជ្ញាប័ណ្ណលើចលនទ្រព្យផ្ទាល់ខ្លួននៅក្នុងរដ្ឋនេះប្រសិនបើទ្រព្យមានទីតាំងនៅក្នុងរដ្ឋនេះ។*

*(b) ក្រុមប្រឹក្សាពន្ធលើការទិញសិទ្ធិពិសេសត្រូវចេញបញ្ញត្តិទាំងនោះតាមការចាំបាច់ ឬសមស្របក្នុងការសម្រេចឱ្យបាននូវគោលបំណងនៃវគ្គនេះ។*

វគ្គទី 9: វគ្គលេខ 25136.1 ត្រូវបញ្ចូលក្នុងក្រមស្តីពីពន្ធដារ និងប្រាក់ចំណូល ឱ្យបកស្រាយថា ៖

*25136.1 (a) សម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2013 អ្នកមានកាតព្វកិច្ចបង់ពន្ធមានការបែងចែកចំណូលពីការធ្វើជំនួញនៅក្នុងវគ្គលេខ 25128.7 ត្រូវអនុវត្តបទបញ្ញត្តិខាងក្រោមនេះ:*

*(1) ដោយមិនគិតពីវគ្គលេខ 25137 ការលក់ត្រឹមត្រូវដែលធ្វើនៅក្នុងរដ្ឋនេះត្រូវស្មើនឹង 50ភាគរយ នៃបរិមាណការលក់ដែលនឹងត្រូវកំណត់ចូលក្នុងរដ្ឋ ស្របតាមវគ្គលេខ 25136 ប៉ុន្តែសម្រាប់ជាការអនុវត្តន៍នៅក្នុងវគ្គនេះ។ 50ភាគរយដែលនៅសល់មិនត្រូវកំណត់ចូលក្នុងរដ្ឋទេ។*

*(2) រាល់ការលក់ផ្សេងទៀតត្រូវកំណត់ឱ្យស្របតាមវគ្គលេខ 25136។*

*(b) សម្រាប់ជាគោលបំណងនៃវគ្គនេះ ៖*

*(1) "អ្នកមានកាតព្វកិច្ចបង់ពន្ធមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" គឺជាសមាជិកក្រុមធ្វើសេចក្តីរាយការណ៍រួមដែលក៏ជាក្រុមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផងដែរ ដែលនេះដូចតាមការកំណត់នៅក្នុងកថាខណ្ឌ (10) នៃអនុផ្នែក (b) របស់វគ្គលេខ 25106.5 ក្រោមប្រធានបទទី 18 មានចំណងជើងថា ក្រមនៃបទបញ្ញត្តិរដ្ឋកាលីហ្វ័រញ៉ា ចូលជាធរមានចាប់ពីកាលបរិច្ឆេទសុពលភាពនៃសកម្មភាពបញ្ចូលក្នុងវគ្គនេះ។*

*(2) "ក្រុមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" គឺជាក្រុមធ្វើសេចក្តីរាយការណ៍រួមដូចមានកំណត់ក្នុងកថាខណ្ឌ (3) នៃអនុផ្នែក (b) របស់វគ្គលេខ 25106.5 ក្រោមប្រធានបទទី18 មានចំណងជើងថា ក្រមនៃបទបញ្ញត្តិរដ្ឋកាលីហ្វ័រញ៉ា ចូលជាធរមានចាប់ពីកាលបរិច្ឆេទសុពលភាពនៃសកម្មភាពបញ្ចូលក្នុងវគ្គនេះ ដែលបំពេញនូវលក្ខខណ្ឌខាងក្រោម ៖*

*(A) បំពេញតាមសេចក្តីត្រូវការការវិនិយោគអប្បរមាសម្រាប់ឆ្នាំបង់ពន្ធ។*

*(B) ចំពោះការធ្វើសេចក្តីរាយការណ៍រួមរបស់ក្រុមដែលឆ្នាំបង់ពន្ធចាប់ផ្តើមក្នុងឆ្នាំនៃប្រតិទិន 2006 ក្រុមធ្វើសេចក្តីរាយការណ៍រួមទាញយកច្រើនជាង 50ភាគរយនៃការទូទាត់សរុបចំពោះការធ្វើជំនួញតាមបណ្តាញរបស់សហរដ្ឋអាមេរិក ពីប្រតិបត្តិការរបស់បណ្តាញខ្សែកាបមួយ ឬច្រើន។*

*(C) សម្រាប់គោលបំណងបំពេញឱ្យបានតាមតំរូវការក្នុងកថាខណ្ឌរង (b) ច្បាប់ខាងក្រោមនេះត្រូវយកទៅអនុវត្ត ៖*

*(i) ប្រសិនបើសមាជិករបស់ក្រុមធ្វើសេចក្តីរាយការណ៍រួមសម្រាប់ឆ្នាំបង់ ពន្ធមិនមែនជាសមាជិកក្នុងធ្វើសេចក្តីរាយការណ៍រួមដូចគ្នាសម្រាប់ឆ្នាំបង់ ពន្ធចាប់ផ្តើមក្នុងឆ្នាំប្រតិទិន 2006 ការទូទាត់លើការធ្វើជំនួញសរុបនៃសមាជិកមិនត្រូវបានរាប់បញ្ចូលនោះ ត្រូវគិតបញ្ចូលក្នុងការកំណត់ការទូ ទាត់ការធ្វើជំនួញរបស់ក្រុមធ្វើសេចក្តីរាយការណ៍រួមសម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមក្នុងឆ្នាំប្រតិទិន 2006 ប្រសិនបើសមាជិកមិនត្រូវបានរាប់បញ្ចូលនោះគឺជាសាមជិករបស់ក្រុមធ្វើសេចក្តីរាយការណ៍រួមសម្រាប់ឆ្នាំបង់ពន្ធចាប់ផ្តើមក្នុងឆ្នាំប្រតិទិន 2006។*

*(ii) ការទូទាត់ការធ្វើជំនួញសរុបត្រូវគិតបញ្ចូលការទូទាត់ការធ្វើជំនួញរបស់ភាពជាដៃគូមានលក្ខណសម្បត្តិគ្រប់គ្រាន់ តែគិតត្រឹមតែផលប្រយោជន៍របស់សមាជិកក្នុងភាពជាដៃគូនោះប៉ុណ្ណោះ។*

*(3) "បណ្តាញខ្សែកាប" និង "បណ្តាញ" គឺមានន័យដូចគ្នា ដូចមានកំណត់ក្នុងវគ្គលេខ 5830 នៃកូដប្រយោជន៍សាធារណៈ ដែលចូលជាធរមានចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃសកម្មភាពបញ្ចូលក្នុងវគ្គនេះ។ "សេវាកម្មបណ្តាញ" សំដៅដល់វីដេអូ ខ្សែកាប សំឡេង ឬសេវាកម្មទិន្នន័យ។*

*(4) "ការទូទាត់ការធ្វើជំនួញសរុប" គឺជាការទូទាត់សរុបដូចមានកំណត់ក្នុងកថាខណ្ឌ (2) នៃអនុផ្នែក (f) ក្នុងវគ្គលេខ 25120 (ក្រៅពីការទូទាត់សរុបពីការលក់ ឬប្រតិបត្តិការផ្សេងទៀតរវាង ឬក្នុងចំណោមសមាជិករបស់ក្រុមធ្វើសេចក្តីរាយការណ៍រួមដោយវគ្គលេខ 25110)។*

*(5) "តំរូវការការវិនិយោគអប្បរមា" សំដៅដល់ការចំណាយមិនតិចជាងពីរយហាសិបលានដុល្លារ ($250,000,000) ដោយក្រុមធ្វើសេចក្តីរាយការណ៍រួមក្នុងឆ្នាំប្រតិទិនដែលរួមបញ្ចូលទាំងដើមឆ្នាំបង់ពន្ធផងដែរ។*

*(6) "ការចំណាយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" គឺជាការបូកបញ្ចូលគ្នានូវរាល់ការចំណាយចូលជាចំណែកក្នុងរដ្ឋនេះសម្រាប់ចលនទ្រព្យ ប្រាក់ខែ សេវាកម្ម ថ្លៃទិញលក់សិទ្ធិពិសេស ឬការបែងចែកអចលនទ្រព្យណាមួយ ឬសិទ្ធិផ្សេងទៀត ដែលបានបង់ ឬធ្វើឡើងដោយ ឬតំណាងឱ្យសមាជិកក្រុមធ្វើសេចក្តីរាយការណ៍រួម។*

*(A) ការចំណាយមិនសម្រាប់ចលនទ្រព្យត្រូវចូលរួមចំណែកក្នុងរដ្ឋប្រសិនបើសមាជិកនៃក្រុមធ្វើសេចក្តីរាយការណ៍រួមទទួលបានផលប្រយោជន៍ពីការទិញ ឬការចំណាយនៅក្នុងរដ្ឋ។*

*(B) ការទិញ ឬចំណាយលើចលនទ្រព្យត្រូវចូលរួមជាចំណែកក្នុងរដ្ឋប្រសិនបើទ្រព្យនោះត្រូវយកទៅបំរើជាសេវាកម្មជូនរដ្ឋ។*

*(C) ការចំណាយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បូកបញ្ចូលការចំណាយដោយក្រុមធ្វើសេចក្តីរាយការណ៍រួមលើទ្រព្យសម្បត្តិ ឬសេវាកម្មដែលបានទិញ ប្រើ ឬប្រគល់ឱ្យមកវិញដោយអ្នកធ្វើកិច្ចសន្យាឯករាជ្យ។*

*(D) ការចំណាយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក៏គិតបញ្ចូលការចំណាយដោយដៃគូដែរ តែសម្រាប់តែផលប្រយោជន៍របស់សមាជិកដៃគូប៉ុណ្ណោះ។*

*(7) "ភាពជាដៃគូមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" សំដៅដល់ភាពជាដៃគូបើកត្តាចំណូល និងការបែកចែក ត្រូវគិតបញ្ចូលក្នុងកត្តាចំណូល និងការបែងចែករបស់ភាពជាដៃគូនៃសមាជិករបស់ក្រុមធ្វើសេចក្តីរាយការណ៍រួម តែសម្រាប់តែផលប្រយោជន៍របស់សមាជិកដៃគូប៉ុណ្ណោះ។*

*(8) "ការលក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់" សំដៅដល់ការទូទាត់ការធ្វើជំនួញសរុបពីការផ្តល់នូវសេវាកម្មបណ្តាញ ដោយមិនគិតពីការទូទាត់ការធ្វើជំនួញសរុបពីការលក់ ឬជួលទីតាំងឧបករណ៍របស់អតិថិជន។ "ការលក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់" ត្រូវគិតបញ្ចូលការលក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយភាពជាដៃគូមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តែសម្រាប់តែផលប្រយោជន៍របស់សមាជិកដៃគូប៉ុណ្ណោះ។*

*(c) ច្បាប់ក្នុងវគ្គនេះស្របតាមការលក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវគោរពតាមច្បាប់សម្រាប់ភាពជាដៃគូក្នុងកថាខណ្ឌ (3) នៃអនុផ្នែក (f) ក្នុងវគ្គលេខ 25137-1 ក្រោមច្បាប់ជំពូកទី 18 នៃក្រមបទបញ្ញត្តិរដ្ឋកាលី ហ្វ័រញ៉ា។*

## សំណើប្រជាមតិ 40

ផែនទីព្រឹទ្ធសភាទូទាំងរដ្ឋត្រូវបានបញ្ជាក់ដោយគណៈកម្មការពលរដ្ឋបែងចែកមណ្ឌលនៅថ្ងៃទី 15 ខែសីហា ឆ្នាំ 2011 គឺត្រូវបានដាក់បញ្ជូនមកពលរដ្ឋសំរាប់ជាប្រជាមតិដោយអនុលោមតាមអនុផ្នែក (i) នៃភាគ 2 នៃមាត្រា XXI នៃរដ្ឋធមនុញ្ញរដ្ឋកាលីហ្វ័រញ៉ា។

**PROPOSED LAW**

**FILED**
**in the office of the Secretary of State of the State of California**
**AUG 15 2011**

**ដំណោះស្រាយ**
**គណៈកម្មការពលរដ្ឋបែងចែកមណ្ឌលរដ្ឋកាលីហ្វ័រញ៉ា**
**វិញ្ញាបនកម្មនៃផែនទីព្រឹទ្ធសភាក្នុងរដ្ឋទាំងមូល**

**ថ្ងៃទី 15 សីហា ឆ្នាំ 2011**

ដោយហេតុថា នៅថ្ងៃទី 29 ខែកក្កដា ឆ្នាំ 2011 គណៈកម្មការពលរដ្ឋបែងចែកមណ្ឌលរដ្ឋកាលីហ្វ័រញ៉ា (គណៈកម្មការ) បានបោះឆ្នោតអនុម័តសំរាប់បិទប្រកាស និងសុំអនុសាសន៏ជាសាធារណៈលើផែនទីព្រឹទ្ធសភាទូទាំងរដ្ឋ(ផែនទីព្រឹទ្ធសភា) ដែលបានយោងថាជាផែនទីព្រឹទ្ធសភាបញ្ចប់ជាដំបូង; និង,

ដោយហេតុថា នៅថ្ងៃ ទី15 ខែសីហា ឆ្នាំ 2011, ដោយអនុលោមតាម មាត្រា XXI, ភាគ 2(c)(5) នៃរដ្ឋធមនុញ្ញរដ្ឋកាលីហ្វ័រញ៉ា, គណៈកម្មការបានបោះឆ្នោតអនុម័តទទួលយកជាចុងបញ្ចប់នៃផែនទីព្រឹទ្ធសភា ដូចបានសំគាល់ដោយ crc_20110815_senate_certified_statewide.zip និង secure hash algorithm (SHA-1) លេខ 14cd4e126ddc5bdce946f67376574918f3082d6b.

ដូច្នេះហើយ ឥឡូវនេះ ត្រូវសម្រេចថា ដោយអនុលោមតាម មាត្រា XXI, ភាគ 2 (g) នៃរដ្ឋធមនុញ្ញរដ្ឋកាលីហ្វ័រញ៉ា, ផែនទីព្រឹទ្ធសភា,ដូចមាន សំគាល់តាមកំណត់យោងខាងលើ SHA -1 ក្នុងនេះត្រូវបានបញ្ជាក់ដោយគណៈកម្មការ ហើយត្រូវតែបញ្ជូនភ្លាមទៅឱ្យរដ្ឋលេខាធិការរដ្ឋកាលីហ្វ័រញ៉ា; ហើយ,

ការសម្រេចតទៅទៀត ថាសមាជិកគណៈកម្មការបានប្រថាប់ហត្ថលេខារបស់គេនៅក្នុងដំណោះស្រាយនេះ។

| | |
|---|---|
| Gabino Aguirre, ស្នងការ (D) | Stanley Forbes, ស្នងការ (DTS) |
| Angelo Ancheta, ស្នងការ (D) | Connie Galambos-Malloy, ស្នងការ (DTS) |
| Vincent Barabba, ស្នងការ (R) | Lilbert "Gil" Ontai, ស្នងការ (R) |
| Maria Blanco, ស្នងការ (D) | M. Andre Parvenu, ស្នងការ (DTS) |
| Cynthia Dai, ស្នងការ (D) | Jeanne Raya, ស្នងការ (D) |
| Michelle DiGuilio, ស្នងការ (DTS) | Michael Ward, ស្នងការ (R) |
| Jodie Filkins Webber, ស្នងការ (R) | Peter Yao, ស្នងការ (R) |




មណ្ឌល ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា

40




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 1




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 2




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 3




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 4

40




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 5




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 6




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 7




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 8




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 9




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 10




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 11




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 12

40




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 13




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 14




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 15




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 16

40




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 17




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 18




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 19




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 20




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 21




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 22




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 23




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 24

40




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 25




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 26




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 27




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 28




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល **29**




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល **30**




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល **31**




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល **32**

40




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 33




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 34




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 35




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 36




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 37




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 38




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 39




ព្រឹទ្ធសភារដ្ឋកាលីហ្វ័រញ៉ា មណ្ឌល 40

40

# សៀវភៅមគ្គុទ្ទេសក៍អក្សរបោះពុម្ពធំៗនិងខ្សែអាត់សំឡេងសំរាប់អ្នកបោះឆ្នោត

ដើម្បីបញ្ជាសុំសៀវភៅមគ្គុទ្ទេសក៍បោះពុម្ពអក្សរធំៗ, កាសែតសំឡេង ឫថាស់ស៊ីឌីសំរាប់ពត៌មានការ ណែនាំអ្នកបោះឆ្នោតជាផ្លូវការ ចូរទៅ មើលគេហទំព័រ *www.voterguide.sos.ca.gov/alt-versions* ឬទូរស័ព្ទបណ្តាញបោះឆ្នោតឆ្លើយទាន់ហេតុការដោយគ្មានគិតឈ្នួល របស់លេខាធិការរដ្ឋតាមលេខ (888) 345-4917។

សំរាប់ការទាញដកយកកាសែតសំឡេងតាមកម្មវិធី MP3 នៃមគ្គុទ្ទេសក៍ពត៌មានអ្នកបោះឆ្នោត ជាផ្លូវការ ចូរទៅមើលគេហទំព័រ *www.voterguide.sos.ca.gov/audio*។

# ទទួលប្រាក់ ហើយធ្វើឱ្យមានភាពខុសគ្នា បំរើជាអ្នកធ្វើការនៅតាមមន្ទីរបោះឆ្នោតនៅថ្ងៃបោះឆ្នោត!

ជាបន្ថែមពីលើការទទួលបទពិសោធន៍ផ្ទាល់ដៃជាមួយនឹងឧបករណ៍ ប្រជាធិបតេយ្យរបស់យើង, អ្នកធ្វើការនៅតាមមន្ទីរ បោះឆ្នោត អាចទទួលប្រាក់ថែមទៀតសំរាប់សេវាដ៏មានតំលៃរបស់គេនៅថ្ងៃបោះឆ្នោត។ សូមទាក់ទង មកការិយាល័យបោះឆ្នោតនៅតាមខោនធីរបស់អ្នក ឫទូរស័ព្ទមលេខ (888) 345-4917 ដើម្បីទទួលព័ត៌មានថែមទៀតអំពីការងារ ជាអ្នកធ្វើការនៅមន្ទីរបោះឆ្នោត។

# ការចុះឈ្មោះរបស់អ្នកបោះឆ្នោត

អ្នកត្រូវទទួលខុសត្រូវសំរាប់ការធ្វើឱ្យទាន់សម័យនូវពត៌មានការចុះឈ្មោះរបស់អ្នកបោះឆ្នោត របស់អ្នក។ អ្នកត្រូវតែធ្វើ ឱ្យទាន់សម័យនូវការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក បើអ្នកផ្លាស់ អាស័យដ្ឋានផ្ទះរបស់អ្នក,ប្តូរអាស័យដ្ឋានផ្ញើសំបុត្ររបស់អ្នក, ប្តូរឈ្មោះរបស់អ្នក, ឬចង់ប្តូរ ឬជ្រើសយកអាទិភាពគណៈបក្សនយោបាយមួយ។

ចំណាំ៖ បើអ្នកបានប្តូរទៅអាស័យដ្ឋានថ្មី ក្រោយថ្ងៃទី 22 ខែតុលា ឆ្នាំ 2012, អ្នកអាចបោះឆ្នោតនៅកន្លែងចាស់របស់អ្នក។

ការចុះឈ្មោះបោះឆ្នោតគឺងាយស្រួលនិងគ្មានអស់ប្រាក់។ ក្រដាសបែបបទ ចុះឈ្មោះ គឺមានតាមបណ្តាញអិនធឺណិត *www.sos.ca.gov* និងស្ទើរគ្រប់ស្ថានីយប៉ុស្តិ៍សំបុត្រ, បណ្ណាល័យ, ការិយាល័យសាលាក្រុង និងរដ្ឋបាលខោនធី, និងការិយាល័យលេខាធិការរដ្ឋកាលីហ្វ័រញ៉ា។

ដើម្បីចុះឈ្មោះបោះឆ្នោត អ្នកត្រូវតែជាពលរដ្ឋសហរដ្ឋអាមេរិក; ពលរដ្ឋរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា; យ៉ាងហោចណាស់មានអាយុ 18 ឆ្នាំនៅថ្ងៃបោះឆ្នោត; មិនជាប់ក្នុងពន្ធនាគារ ឬក្នុងមន្ទីរឃុំឃាំងខោនធី (ជាប់ក្នុងមន្ទីរឃុំឃាំងរដ្ឋតាមការកាត់ទោស ឬជាប់ក្នុងមន្ទីរឃុំឃាំង លើសពីមួយឆ្នាំសំរាប់ការកាត់ទោសពីបទឧក្រិដ្ឋ"កំរិតទាប"), ឬដោះលែងមានល័ក្ខខ័ណ្ឌ, ដោះលែងនៅក្រោមការត្រួតត្រាមើលរបស់សហគមន៍, ឬដោះលែងនៅក្រោមកិច្ចសន្យាសំរាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋ; និងមិនបានវិនិច្ឆ័យដោយតុលាការថាត្រូវជាខ្វះសមត្ថកិច្ចផ្នែកសតិ។

# ការតំរូវរបស់រដ្ឋនិងសហព័ន្ធឱ្យអ្នកបោះឆ្នោតមានអត្តសញ្ញាណប័ណ្ណ

ស្ទើរតែគ្រប់ករណីទាំងអស់ អ្នកបោះឆ្នោតក្នុងរដ្ឋកាលីហ្វ័រញ៉ាគឺមិនតំរូវឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណមុនពេលបោះឆ្នោតទេ។ បើអ្នកបោះឆ្នោតនៅលើកទីមួយ ក្រោយពេលដែលបានចុះឈ្មោះផ្ញើតាមប៉ុស្តិ៍សំបុត្ររួច ហើយមិនបានផ្តល់លេខប័ណ្ណបើកបររបស់អ្នក, លេខអត្តសញ្ញាណប័ណ្ណរដ្ឋកាលីហ្វ័រញ៉ា, ឬលេខសន្តិសុខបួនខ្ទង់ចុងក្រោយរបស់អ្នកនៅលើប័ណ្ណចុះឈ្មោះបោះឆ្នោត, អ្នកក៏ប្រហែលត្រូវគេឱ្យបង្ហាញក្រដាសទម្រង់អត្តសញ្ញាណប័ណ្ណនៅពេលអញ្ជើញមកកាន់មន្ទីរបោះឆ្នោត។ សូមឱ្យប្រាកដ អ្នកយកអត្តសញ្ញាណប័ណ្ណមកជាមួយពេលមកមន្ទីរបោះឆ្នោត ឬដោយរួម ទាំងក្រដាសចម្លងជាមួយនឹងសន្លឹកឆ្នោតបោះផ្ញើតាមប៉ុស្តិ៍សំបុត្រ។ បន្ទាប់ទៅនេះគឺជាបញ្ជីរាយឈ្មោះឯកសារមួយចំនួននៃក្រដាសបែបបទអត្តសញ្ញាណប័ណ្ណលើសពីចំនួន 30 ដែលគេយល់ព្រមទទួល។ អ្នកក៏អាចទៅមើលគេហទំព័ររបស់លេខាធិការរដ្ឋនិងរកមើល "Help America Vote Act Identification Standards" នៅ *www.sos.ca.gov/elections/elections_regs.htm*។

- ប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណចេញពីរដ្ឋ
- លិខិតឆ្លងដែន
- ប័ណ្ណបុគ្គលិកធ្វើការ
- ប័ណ្ណក្រេឌិត ឬប័ណ្ណឥណពន្ធ
- អត្តសញ្ញាណប័ណ្ណយោធា
- អត្តសញ្ញាណប័ណ្ណសិស្ស

# កម្រងសិទ្ធិឯកកត្តជនអ្នកបោះឆ្នោត

1. អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះត្រឹមត្រូវ។
   អ្នកបោះឆ្នោតដែលបានចុះឈ្មោះបានត្រឹមត្រូវមានន័យថាជាសញ្ជាតិអាមេរិកដែលជាពលរដ្ឋនៅក្នុងរដ្ឋនេះដែលមានអាយុយ៉ាងតិច 18 ឆ្នាំ និងមិនជាប់ពន្ធនាគារឬត្រូវដោះលែងមានល័ក្ខខ័ណ្ឌសំរាប់ការប្រព្រឹត្តបទឧក្រិដ្ឋ ធ្ងន់ធ្ងរហើយបានចុះឈ្មោះបោះឆ្នោតនៅអាស័យដ្ឋានរស់នៅបច្ចុប្បន្នរបស់គេ។
2. អ្នកមានសិទ្ធិបោះឆ្នោតបណ្ដោះអាសន្ន ប្រសិនបើឈ្មោះរបស់អ្នកមិនត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត។
3. អ្នកមានសិទ្ធិបោះឆ្នោតប្រសិនបើអ្នកមានវត្តមាននៅក្នុងជួររង់ចាំនៅកន្លែងបោះឆ្នោតមុនពេលបិទការបោះឆ្នោត។
4. អ្នកមានសិទ្ធិបោះឆ្នោតជាសំងាត់ដោយគ្មានការគំរាមកំហែង។
5. អ្នកមានសិទ្ធិទទួលបាននូវសន្លឹកឆ្នោតថ្មីប្រសិនបើមុនពេលការបោះឆ្នោតរបស់អ្នក អ្នកជឿថាអ្នកបានធ្វើខុស។ ប្រសិនបើនៅពេលណាក៏ដោយ មុនពេលអ្នកសំរេចចិត្តចុងក្រោយថាបោះសន្លឹកឆ្នោតរបស់អ្នក ហើយអ្នកមានអារម្មណ៍ថា អ្នកបានធ្វើខុស អ្នកមានសិទ្ធិសុំដូរសន្លឹកឆ្នោតដែលខូចសំរាប់សន្លឹកឆ្នោតថ្មី។ អ្នកបោះឆ្នោតតាមសំបុត្រ អាចស្នើសុំ និងទទួលសន្លឹកឆ្នោតថ្មីប្រសិនបើពួកគេបញ្ជូនសន្លឹកឆ្នោតដែលខូចរបស់ពួកគេទៅឱ្យមន្ត្រីបោះឆ្នោតមុនពេលបិទការបោះឆ្នោតនៅថ្ងៃបោះឆ្នោត។
6. អ្នកមានសិទ្ធិទទួលបាននូវការជួយសំរួលក្នុងការបោះឆ្នោតរបស់អ្នក ប្រសិនបើអ្នកមិនអាចបោះឆ្នោតបានដោយគ្មានការជួយជ្រោមជ្រែង។
7. អ្នកមានសិទ្ធិបញ្ជូនត្រឡប់មកវិញនូវសន្លឹកឆ្នោតតាមសំបុត្រដែលបំពេញរួច ទៅកាន់ការិយាល័យបោះឆ្នោតណាមួយនៅក្នុងតំបន់។
8. អ្នកមានសិទ្ធិជ្រើសរើសឯកសារបោះឆ្នោតជាភាសាមួយផ្សេងទៀត ប្រសិនបើ មានពលរដ្ឋគ្រប់គ្រាន់នៅមណ្ឌលបោះឆ្នោតរបស់អ្នកដើម្បីធានានូវផលិតផល។
9. អ្នកមានសិទ្ធិសួរសំណួរអំពីនីតិវិធីបោះឆ្នោតនិងសង្កេតដំណើរការបោះឆ្នោត។
   អ្នកមានសិទ្ធិសួរសំណួរអំពីគណៈកម្មការមណ្ឌលបោះឆ្នោតនិងមន្ត្រីបោះឆ្នោតពាក់ព័ន្ធនឹងនីតិវិធីបោះឆ្នោត និងដើម្បីទទួលបាននូវចំឡើយ ឬការណែនាំបន្តទៅកាន់មន្ត្រីសមស្របដែលអាចផ្តល់ចំឡើយបាន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើការសួរសំណួរមិនអស់មិនហើយមានការរំខានដល់ការអនុវត្តតួនាទីរបស់ពួកគេគណៈកម្មការ ឬមន្ត្រីបោះឆ្នោតអាចបញ្ឈប់ការឆ្លើយតបនឹងសំណួរបាន។
10. អ្នកមានសិទ្ធិរាយការណ៍នូវសកម្មភាពខុសច្បាប់ ឬការក្លែងបន្លំទៅកាន់មន្ត្រីបោះឆ្នោតក្នុងតំបន់ ឬទៅកាន់ការិយាល័យរដ្ឋលេខាធិការ។

---

**ប្រសិនបើអ្នកជឿជាក់ថាអ្នកត្រូវបានគេបដិសេធនូវសិទ្ធិទាំងនេះ**
**ឬអ្នកដឹងថាមានការបន្លំការបោះឆ្នោតឬការប្រព្រឹត្តមិនគប្បី**
**សូមទូរស័ព្ទមកលេខសំងាត់ទាន់ហេតុការណ៍សំរាប់អ្នកបោះឆ្នោតដោយឥតគិតថ្លៃគឺ (888) 345-4917។**

---

ព័ត៌មាននៅលើលិខិតថ្លែងសច្ចាចុះឈ្មោះបោះឆ្នោតរបស់អ្នកនឹងត្រូវប្រើដោយមន្ត្រីបោះឆ្នោតដើម្បីផ្ញើឱ្យអ្នកនូវព័ត៌មានផ្លូវការចំពោះដំណើរការបោះឆ្នោត ដូចជាទីកន្លែងបោះឆ្នោតរបស់អ្នកនិងបញ្ហានានា ព្រមទាំងបេក្ខជនដែលនឹងមាននៅលើសន្លឹកឆ្នោត។ ការប្រើជាលក្ខណៈពាណិជ្ជកម្មនៃព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតគឺត្រូវបានហាមប្រាមដោយច្បាប់និងចាត់ទុកជាបទល្មើសមជ្ឈឹម។ ព័ត៌មានអ្នកបោះឆ្នោតអាចត្រូវផ្តល់ជូនដល់បេក្ខជនឈរឈ្មោះគណៈកម្មការវិធានការបោះឆ្នោត ឬបុគ្គលសំរាប់គោលបំណងការបោះឆ្នោត ការសិក្សា សារព័ត៌មាន នយោបាយ ឬរដ្ឋាភិបាល ដូចដែលបានកំណត់ដោយរដ្ឋលេខាធិការ។ ប័ណ្ណបើកបរនិងលេខសុវត្ថិភាពសង្គម (social security numbers) ឬហត្ថលេខារបស់អ្នកដូចដែលមានបង្ហាញនៅលើកាតចុះឈ្មោះបោះឆ្នោត មិនអាចត្រូវបានបញ្ចេញសំរាប់គោលបំណង ទាំងនោះទេ។ ប្រសិនបើអ្នកមានសំណួរអ្វីអំពីការប្រើព័ត៌មានអ្នកបោះឆ្នោតឬមានបំណងរាយការណ៍នូវការប្រើខុសដែលសង្ស័យនូវព័ត៌មានដូចនេះសូមទូរស័ព្ទមកលេខទាន់ហេតុការណ៍សំរាប់អ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការគឺ (888) 345-4917។

អ្នកបោះឆ្នោតមួយចំនួនដែលប្រឈមមុខនឹងស្ថានភាពគំរាមកំហែងដល់ជីវិតអាចមានសិទ្ធិសំរាប់ស្ថានភាពអ្នកបោះឆ្នោតជាសំងាត់។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលេខឥតគិតថ្លៃរបស់កម្មវិធីសុវត្ថិភាពនៅផ្ទះរបស់រដ្ឋលេខាធិការគឺ (877) 322-5227 ឬ ទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការគឺ *www.sos.ca.gov*។

**California Secretary of State**
**Elections Division**
1500 11th Street
Sacramento, CA 95814

NONPROFIT
U.S. POSTAGE
PAID
CALIFORNIA
SECRETARY OF STATE

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service ®

# កា លី ហ្វ័ រ ញ៉ា ការបោះឆ្នោតសកល

www.voterguide.sos.ca.gov

## សៀវភៅមគ្គុទ្ទេសក៍ព័ត៌មានជាផ្លូវការសំរាប់អ្នកបោះឆ្នោត

ចូរចងចាំទៅបោះឆ្នោត!
**ថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា ឆ្នាំ 2012**
មន្ទីរបោះឆ្នោតបើកទ្វារពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់

**ថ្ងៃច័ន្ទ ទី 22 ខែតុលា ឆ្នាំ 2012**
ជាថ្ងៃ ចុងក្រោយសំរាប់ចុះឈ្មោះបោះឆ្នោត

For additional copies of the Voter Information Guide in English, please contact your county elections office or call (800) 345-VOTE (8683). For TTY/TDD, call (800) 833-8683.

Para obtener copias adicionales de la Guía de Información para el Votante en español, póngase en contacto con la oficina electoral de su condado o llame al (800) 232-VOTA (8682).

如需索取額外的中文選民資訊指南，請與您的縣立選舉辦事處聯繫或致電(800) 339-2857。

हिन्दी में मतदाता जानकारी मार्गदर्शिका की अतिरिक्त प्रतियां प्राप्त करने के लिए, कृपया अपने काउंटी चुनाव कार्यालय से संपर्क करें या इस नंबर पर फ़ोन करें (888) 345-2692।

投票情報ガイドの日本語版をご希望の場合は、最寄の郡選挙事務所にお問い合わせになるか(800) 339-2865にお電話ください。

សំរាប់សំណៅបន្ថែម នៃព័ត៌មានណែនាំអ្នកបោះឆ្នោត ជាភាសាខ្មែរ សូមទាក់ទងការិយាល័យបោះឆ្នោត ខោនធីរបស់អ្នក ឬទូរស័ព្ទ (888) 345-4917។

한국어로 된 유권자 정보 지침의 사본이 추가로 필요할 경우 해당 카운티 선거관리 사무실로 연락하거나 다음 번호로 전화하십시오: (866) 575-1558

Para sa mga karagdagang kopya ng Patnubay na Impormasyon Para sa Botante sa Tagalog, mangyaring makipag-ugnayan sa opisina sa mga halalan ng inyong county o tumawag sa (800) 339-2957.

สำหรับสำเนาเพิ่มเติมของคู่มือสำหรับผู้ออกเสียงเลือกตั้งเป็นภาษาไทย กรุณาติดต่อสำนักงานการเลือกตั้งประจำเทศมณฑลของคุณ หรือโทรศัพท์ถึง (855) 345-3933

Muốn có thêm Tập Hướng Dẫn Cử Tri bằng Việt Ngữ, xin liên lạc với văn phòng bầu cử quận của quý vị hoặc gọi số (800) 339-8163.

ដើម្បីកាត់បន្ថយថ្លៃចំណាយលើការបោះឆ្នោត រដ្ឋផ្ញើតែ សៀវភៅមគ្គុទ្ទេសក៍មួយច្បាប់សំរាប់ក្រុមគ្រួសារនិមួយ។

OSP 12 127220